


សេចក្តីផ្តើម

# សិទ្ធិមនុស្សនៅអាស៊ីអាគ្នេយ៍




វគ្គទីមួយ

កែសម្រួលដោយ

Azmi Sharom Hadi Rahmat Purnama Matthew Mullen Melizel Asuncion Michael Hayes

RAOUL WALLENBERG INSTITUTE
OF HUMAN RIGHTS AND HUMANITARIAN LAW

ការបកប្រែ និងការបោះពុម្ពផ្សាយនៃសៀវភៅពុម្ពនេះត្រូវបានគាំទ្រ និងសម្របសម្រួលដោយវិទ្យាស្ថានសិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌រ៉ាអុលវ៉ាលេនបឺក (RWI) ដោយមានការគាំទ្រហិរញ្ញប្បទានពីកិច្ចសហប្រតិបត្តិការដើម្បីការអភិវឌ្ឍនៃប្រទេសស៊ុយអែត។

RWI គឺជាវិទ្យាស្ថានសិក្សាអប់រំឯករាជ្យមួយ ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៨៤ ក្នុងមហាវិទ្យាល័យច្បាប់នៃសាកលវិទ្យាល័យលុន ក្នុងប្រទេសស៊ុយអែត។ វិទ្យាស្ថានមានបេសកកម្មក្នុងការលើកកម្ពស់ការគោរពជាសកលលើសិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌តាមរយៈមធ្យោបាយនៃការស្រាវជ្រាវ ការសិក្សាអប់រំ និងកម្មវិធីពង្រឹងសមត្ថភាពស្ថាប័ន ហើយទស្សនៈវិស័យរបស់វិទ្យាស្ថានយើងខ្ញុំ គឺដើម្បីក្លាយខ្លួនជាមជ្ឈមណ្ឌលគំរូដ៏ល្អមួយក្នុងការលើកកម្ពស់ការអភិវឌ្ឍសង្គម ដោយផ្អែកលើវប្បធម៌សិទ្ធិមនុស្ស។ ទីស្នាក់ការកណ្តាលរបស់វិទ្យាស្ថានស្ថិតនៅទីក្រុងលុនប្រទេសស៊ុយអែត។ RWI ក៏មានការិយាល័យនៅក្នុងទីក្រុងប៉េកាំង ណៃរ៉ូប៊ី ហ្សាកាតា អ៊ីស្តែនប៊ុល អាំម៉ែន និងភ្នំពេញផងដែរ។

ការកសាងសមត្ថភាពក្នុងប្រទេសកម្ពុជាពីឆ្នាំ ២០១៣ ដល់ឆ្នាំ២០១៧។
ពេលបច្ចុប្បន្ននេះវិទ្យាស្ថានអនុវត្តកម្មវិធីកសាងសមត្ថភាពសិទ្ធិមនុស្ស ក្នុងប្រទេសកម្ពុជាពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៧។ កម្មវិធីនេះមានកម្មវត្ថុចម្បងៗចំនួនពីរៈ

១. ធ្វើការពង្រឹងសមត្ថភាពស្ថាប័ន ដល់ស្ថាប័នសិក្សាអប់រំដែលបានជ្រើសរើសមួយចំនួនដើម្បីបង្កើតកម្មវិធី និងធ្វើការអប់រំ និងការស្រាវជ្រាវសិទ្ធិមនុស្សប្រកបដោយគុណភាព ព្រមទាំងបង្កើតវេទិកាសិក្សាអប់រំដើម្បីជាការជជែកវែកញែក និងសន្ទនាពីបញ្ហាសិទ្ធិមនុស្ស និង
២. ធ្វើការពង្រឹងសមត្ថភាព របស់ស្ថាប័នរដ្ឋាភិបាលដែលបានជ្រើសរើសតាមយុទ្ធសាស្ត្រក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន អនុលោមតាមស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ។

ការផ្តោតសំខាន់របស់កម្មវិធីគឺដើម្បីគាំទ្រដល់ការអប់រំ និងការស្រាវជ្រាវសិទ្ធិមនុស្សតាមបណ្តាស្ថាប័នសិក្សាអប់រំក្នុងប្រទេសកម្ពុជា។ RWI ធ្វើការសហការជាមួយនឹងសាកលវិទ្យាល័យ និងស្ថាប័នសិក្សាអប់រំផ្សេងៗគ្នាក្នុងប្រទេសកម្ពុជា ក្នុងគោលបំណងដើម្បីពង្រឹងស្ថាប័នទាំងនេះ។

RAOUL
WALLENBERG
INSTITUTE
OF HUMAN RIGHTS AND HUMANITARIAN LAW

The translation and publication of this text book was supported and coordinated by the Raoul Wallenberg Institute of Human Rights and Humanitarian Law (RWI) with financial support from Swedish Development Cooperation.

RWI is an independent academic institution, founded in 1984 at the Law Faculty at Lund University in Sweden. The mission of the Institute is to promote universal respect for human rights and humanitarian law, by means of research, academic education and institutional development programme and our vision is to be a center of excellence promoting the development of societies based on a human rights culture. The institute's head office is located in Lund, Sweden. RWI also have office in Beijing, Nairobi, Jakarta, Istanbul, Amman and Phnom Penh.

Capacity Development in Cambodia 2013-2017

The institute currently implements a Human Right Capacity Development Programme in Cambodia 2013-2017. The programme has two main objectives:

1. To strengthen institutional capacities of selected academic institutions to develop and deliver high quality human rights education and research as well as provide an academic platform of human rights debates and dialogue; and
2. To strengthen the capacity of strategically selected government institutions to fulfill their obligation in accordance with international human rights standards.

The main focus of the programme is to support human rights education and research at academic institution in Cambodia. RWI cooperates with a number of different universities academic institutions in Cambodia in order to strengthen these institutions.

# សេចក្តីផ្តើមពីសិទ្ធិមនុស្សនៅអាស៊ីអាគ្នេយ៍

## វគ្គទីមួយ


កែសម្រួលដោយ

Azmi Sharom    Hadi Rahmat Purnama    Matthew Mullen    Melizel Asuncion    Michael Hayes



ស្នាដៃនេះត្រូវបានចែកចាយតាមអាជ្ញាប័ណ្ណ

Creative Commons៖

CC BY-NC-SA

Attribution-NonCommercial-hareAlike

ព័ត៌មានបន្ថែមពីអាជ្ញាប័ណ្ណនេះមាននៅ៖

https://creativecommons.org/licenses/by-nc-sa/4.0/

# អារម្ភកថា


សេចក្តីព្រាងទីមួយនៃសៀវភៅពុម្ពនេះ មិនអាចលេចចេញជារូបរាងបាននោះទេ ប្រសិនជាគ្មានការរួមចំនែកពីបុគ្គលជាច្រើន។ ដូចដែលគម្រោងនេះនឹងដំណើរការទៅមុនទៀត យើងខ្ញុំសង្ឃឹមថាពួកគាត់នឹងបន្តនូវកិច្ចការដ៏មានអត្ថន័យរបស់ពួកគាត់។

គម្រោងនេះត្រូវបានសម្របសម្រួលដោយ Matthew Mullen និង Mike Hayes។

អ្នកនិពន្ធដែលរួមចំនែករួមមាន Azmi Sharom, Eko Riyadi, Elizabeth guiling-Pangalangan, Hadi Rahmat Purnama, R. Herlambang Perdana Wiratraman, Matthew Mullen, Melizel Asuncion, Mike Hayes, Muhadi Sugiono, Ray Paolo J. Santiago។

អ្នកត្រួតពិនិត្យកែសម្រួល និងអ្នកត្រួតពិនិត្យអង្គហេតុក្នុងផ្នែកជាក់លាក់នីមួយៗរួមមាន៖
ជំពូកទី៤៖ Benjamin Lee មកពីវេទិកាអាស៊ីប៉ាស៊ីហ្វិច។
ជំពូកទី៦៖ ស្តីពីជនភៀសខ្លួន៖ Brian Barbour ពីសមាគមជប៉ុនដើម្បីជនភៀសខ្លួន និង Saya Uematsu Austin ពីសាកលវិទ្យាល័យ Brooklyn។

ក្រុមកែសម្រួល និងស្រាវជ្រាវរួមមាន៖ Abhay Luthra, Douglas Sanders, Gary Cuenoud, Giulia Patane, Huong Ngo, Nicole Ostrand, Jari Trabert, Joel Barredo, Kamarulzaman Askandar, Rhona Smith, Sripapha Petcharamesree, Uzma Shukrana, Yanuar Samarlan។

អានផ្ទៀងផ្ទាត់ដោយ Magdalen Paskell និង Loskaru Sdn Bhd

រូបភាពគំរបមុខដោយ៖ Lillian Suwanrumpha [ផ្នែកខាងលើ]
Qiqo Simbol of Focus on the Global South [ផ្នែកខាងក្រោម]

គម្រោងបណ្តាញសិក្សាសិទ្ធិមនុស្សអាស៊ីអាគ្នេយ៍ត្រូវបានផ្តល់មូលនិធិគាំទ្រ ដោយទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអភិវឌ្ឍអន្តរជាតិស៊ុយអែត-SIDA និងសហការជាមួយនឹងវិទ្យាស្ថានច្បាប់សិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌ រ៉ាអុលវ៉ាលេនបឺក។

# O1 ជំពូកទី១៖ មូលដ្ឋានគ្រឹះនៃសិទ្ធិមនុស្ស


6 ១.១ តើសិទ្ធិមនុស្សជាអ្វី?

១.១.១ ជាមនុស្ស

១.១.២ សិទ្ធិរបស់មនុស្ស

១.២.៣ មូលដ្ឋានគ្រឹះនៃសិទ្ធិមនុស្ស

17 ១.២ លក្ខណៈពិសេសជាមូលដ្ឋាន និងទស្សនៈទានក្នុងសិទ្ធិមនុស្ស

១.២.១ ភាពជាសកល

១.២.២ ភ្ជាប់តាំងពីកំណើត

១.២.៤ មិនអាចដកហូតបាន

១.២.៥ ភាពថ្លៃថ្នូរ

១..២.៦ សមភាព

22 ១.៣ ច្បាប់សិទ្ធិមនុស្ស៖ សិទ្ធិ និងកាតព្វកិច្ច

១.៣.១ នីតិរដ្ឋ

១.៣.២ កាតព្វកិច្ចសិទ្ធិមនុស្ស

១.៣.៣ ការពារខ្សែឈរ និងខ្សែដេក

១.៣.៤ កាតព្វកិច្ចរបស់រដ្ឋ៖ "គោរព ការពារ បំពេញ" និង "លើកកម្ពស់ ការពារ និងបង្ការ"

31 ១.៤ ប្រភេទនៃសិទ្ធិ

១.៤.១ ការញែកចេញពីគ្នា និងការរួមបញ្ចូលគ្នានៃប្រភេទនៃសិទ្ធិ

១.៤.២ VDPA៖ សេចក្តីប្រកាស និងផែនការសកម្មភាពទីក្រុងវីយែន

40 ១.៨ ហេតុអ្វីត្រូវសិក្សាសិទ្ធិមនុស្ស

១.៨.១ ការអប់រំសិទ្ធិមនុស្សគឺជាសិទ្ធិមនុស្ស

១.៨.២ ការពារជនងាយរងគ្រោះ

១.៨.៣ សិទ្ធិមនុស្សធ្វើឲ្យមានការឃោគយល់ក្នុងតំបន់

១.៨.៤ ការអប់រំសិទ្ធិមនុស្សបន្ថែមតម្លៃដល់ចំនេះដឹងផ្សេងទៀត

51 ជំពូកទី២៖ ស្តង់ដារសិទ្ធិមនុស្សអន្តរជាត

55 ២.១ ច្បាប់អន្តរជាតិសាធារណ: ៖ មូលដ្ឋានគ្រឹះ

57 ២.២ ប្រភពនៃច្បាប់អន្តរជាតិ

61 ២.៣ ប្រវត្តិនៃការអភិវឌ្ឍស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ

២.៣.១ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស(UDHR)

69 ២.៤ ការបង្កើតសន្ធិសញ្ញា៖ ទិដ្ឋភាពទូទៅមួយ

២.៤.១ ខលក្ខខណ្ឌ និងការយល់ដឹងពីសន្ធិសញ្ញា

76 ២.៥ ហេតុអ្វីរដ្ឋផ្តល់សច្ចាប័នលើសន្ធិសញ្ញាដែលជាបន្ទុកកាតព្វកិច្ចផ្លូវច្បាប់ដល់ ពួកគេ?

83 ជំពូកទី៣៖ សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ

86 ៣.១ ICCPR

៣.១.១ ពិធីសារបន្ថែម ICCPR

89 ៣.២ សិទ្ធិក្នុង ICCPR

៣.២.១ ស្វ័យសម្រេច(មាត្រា១)

៣.២.២ ការមិនរើសអើង(មាត្រា ២)

៣.២.៣ សិទ្ធិរស់រានមានជីវិត(មាត្រា៦)

៣.២.៤ សិទ្ធផ្លូវច្បាប់(មាត្រា ៩ ១០ ១៤ និង២៦)

៣.២.៥ សេរីភាពក្នុងការដើរហើរ(មាត្រា១២)

៣.២.៦ សេរីភាពសាសនា(មាត្រា១៨)

៣.២.៧ សេរីភាពនៃការបញ្ចេញមតិ(មាត្រា១៩)

៣.២.៨ សិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍ និងមានបុត្រធីតា(មាត្រា២៣)

៣.២.៩ សិទ្ធិសមាគម និងការប្រជុំ(មាត្រា ២១ និង ២២)

៣.២.១០ សិទ្ធិក្នុងការបោះឆ្នោត (មាត្រា ២៥)

97 ៣.៣ ដែនកំណត់នៃសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

៣.៣.១ ដែនកំណត់ចំពោះសិទ្ធិទាំងអស់

៣.៣.២ ដែនកំណត់លើសិទ្ធិជាក់លាក់ដែលបានកំណត់ដោយរដ្ឋាធិបាល

៣.៣.៣ បដិប្បញ្ញត្តិក្នុងភាពអាសន្នសាធារណ:

101 ៣.៤ ICESCR

៣.៤.១ ការសម្រេចបានជាបណ្តើរៗ

៣.៤.២ យុត្តិកម្ម

109 ៣.៥ សិទ្ធិក្នុង ICESCR

៣.៥.១ សិទ្ធិសេដ្ឋកិច្ច

៣.៥.២ សិទ្ធិសង្គម

113 ៣.៦ វប្បធម៌ និងសិទ្ធិមនុស្ស

## 123 ជំពូកទី៤៖ ការការពារសិទ្ធិមនុស្សនៅអាស៊ីអាគ្នេយ៍

125 ៤.១ ស្ថានភាពនៃការការពារសិទ្ធិមនុស្សនៅអាស៊ីអាគ្នេយ៍

129 ៤.២ ការអនុវត្តសិទ្ធិមនុស្សថ្នាក់ជាតិ

៤.២.១ ស្តង់ដារអន្តរជាតិទៅក្នុងច្បាប់ជាតិ

៤.២.២ សិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញអាស៊ីអាគ្នេយ៍

137 ៤.៣ ស្ថាប័នសិទ្ធិមនុស្សជាតិ

៤.៣.១ ដើមកំណើតនៃNHRIs

៤.៣.២ ប្រភេទ និងមុខងាររបស់ NHRIs

៤.៣.៣ សកម្មភាព NHRIs

៤.៣.៤ ស្តង់ដារតាមដានរបស់ NHRI

៤.៣.៥ ដែនកំណត់នៃ NHRIs

146 ៤.៤ យន្តការថ្នាក់តំបន់

151 ៤.៥ យន្តការសិទ្ធិមនុស្សអាស៊ាន

155 ៤.៦ តួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាល(NGOs)

៥.៦.១ សកម្មភាព NGO

៥.៦.២ NGOs នៅតាមមូលដ្ឋាន

171 ជំពូកទី ៥៖ ការការពារសិទ្ធិមនុស្ស៖ អង្គការសហប្រជាជាតិ និងប្រព័ន្ធអន្តរជាតិ

174 ៥.១ សិទ្ធិមនុស្សនៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិដ៏ធំទូលាយ

183 ៥.២ ស្ថាប័នសិទ្ធិមនុស្សរបស់ UN

៥.២.១ ស្ថាប័នធម្មនុញ្ញ៖ ក្រុមប្រឹក្សាសិទ្ធិមនុស្ស

៥.២.២ សកម្មភាពក្រុមប្រឹក្សាសិទ្ធិមនុស្សក្នុងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស

196 ៥.៣ ការិយាល័យឧត្តមស្នងការទទួលបន្ទុកកិច្ចការសិទ្ធិមនុស្ស

197 ៥.៤ ស្ថាប័នសន្ធិសញ្ញា

215 ជំពូកទី ៦៖ សិទ្ធិរបស់ជនមិនមែនជាពលរដ្ឋ៖ ជនភៀសខ្លួន និងភាពគ្មានសញ្ជាតិ

218 ៦.១ ទេសន្តប្រវេសន៍នៅអាស៊ីអាគ្នេយ៍

៦.១.១ ពាក្យពេចន៍

៦.១.២ បរិបទប្រវត្តិសាស្ត្រ និងសេដ្ឋកិច្ចនៃទេសន្តប្រវេសន៍នៅអាស៊ីអាគ្នេយ៍

225 ៦.២ ប្រភេទសិទ្ធិទាំងបួនរបស់ប្រជាជនមិនមែនជាពលរដ្ឋ៖ ទិដ្ឋភាពទូទៅ

៦.២.១ គំលាត និងភាពជាន់គ្នានៃការការពារផ្លូវច្បាប់

230 ៦.៣ អនុសញ្ញាជនភៀសខ្លួន

៦.៣.១ និយមន័យនៃជនភៀសខ្លួន

៦.៣.២ ស្តង់ដារអនុសញ្ញាជនភៀសខ្លួន

239 ៦.៤ ប្រជាជនដែលជាជនភៀសខ្លួន និងការការពារនៅអាស៊ីអាគ្នេយ៍

៦.៤.១ អង្គការជនភៀសខ្លួន៖ UNHCR

៦.៤.២ អង្គការជនភៀសខ្លួន៖ អង្គការសង្គមស៊ីវិល

247 ៦.៥ ជនគ្មានសញ្ជាតិ

៦.៥.១ កំណត់និយមន័យគ្មានសញ្ជាតិ

៦.៥.២ ការរំលោភបំពានលើសិទ្ធិរបស់ជនគ្មានសញ្ជាតិ

៦.៥.៣ អនុសញ្ញាជនគ្មានសញ្ជាតិ

៦.៥.៤ មូលហេតុនៃភាពគ្មានសញ្ជាតិ

៦.៥.៥ សកម្មភាពក្នុងការលុបបំបាត់ភាពគ្មានសញ្ជាតិ

271 ជំពូកទី៧៖ សិទ្ធិរបស់ជនមិនមែនជាពលរដ្ឋៈពលករទេសន្តប្រវេសន៍ និងមនុស្សដែលត្រូវបានជួញដូរ

272 ៧.១ ពលករទេសន្តប្រវេសន៍

៧.១.១ អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិរបស់ពលករទេសន្ត
ប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ (ICRMW)

276 ៧.២ អនុសញ្ញាស្តីពីការការពារសិទ្ធិរបស់ពលករទេសន្តប្រវេសន៍គ្រប់រូប និង
សមាជិកគ្រួសាររបស់ពួកគេ (ICRMW)
៧.២.១ និយមន័យនៃពលករទេសន្តប្រវេសន៍
៧.២.២ សិទ្ធិពលករទេសន្តប្រវេសន៍ក្នុង ICRMW
៧.២.៣ ការប្រឈមនៃ ICRMW
៧.២.៤. ហេតុផលចំពោះការផ្តល់សច្ចាប័នតិច

285 ៧.៣ ការរំលោភបំពានលើសិទ្ធិរបស់ពលករទេសន្តប្រវេសន៍
៧.៣.១ សកម្មភាពរដ្ឋាភិបាល ដែលអាចការពារសិទ្ធិពលករទេសន្តប្រវេសន៍
៧.៣.២ អង្គការពលករទេសន្តប្រវេសន៍

296 ៧.៤ មនុស្សដែលត្រូវបានជួញដូរ
៧.៤.១ ពិធីសារក្នុងការបង្ការ ទប់ស្កាត់ និងដាក់ទោសលើការជួញដូរមនុស្ស
ជាពិសេសស្ត្រី និងកុមារ ឆ្នាំ២០០៣ (ពិធីសារប៉ាលីម៉ូ)
៧.២.២ និយមន័យនៃការជួញដូរ
៧.២.៣ ធាតុផ្សំសិទ្ធិមនុស្សក្នុងពិធីសារជួញដូរ

308 ៧.៥ ការប្រឈមក្នុងការកំណត់អត្តសញ្ញាណមនុស្សដែលត្រូវបានជួញដូរ
៧.៥.១ ការឆ្លើយតបរបស់ NGO

# បញ្ជីនៃតារាង

## ជំពូកទី១


ការពិភាក្សា និងការជជែកវែកញែក ៖ ការដកហូតសិទ្ធិមនុស្ស
ទស្សនៈទាន ៖ ក្រមបដិភាព
ការពិភាក្សា និងការជជែកវែកញែក ៖ ចំណាត់ប្រភេទនៃសិទ្ធិ
ការពិភាក្សា និងការជជែកវែកញែក ៖ ច្បាប់ធម្មជាតិ និងទស្សនៈវិជ្ជមានផ្លូវច្បាប់
ការពិភាក្សា និងការជជែកវែកញែក ៖ ភាពជាសកល
ការពិភាក្សា និងការជជែកវែកញែក៖ តើអ្នករស់នៅក្នុងរដ្ឋដែលមានការគោរពនីតិរដ្ឋមែនដែរឬទេ?
ទស្សនៈទាន ៖ ទ្រឹស្តី“បីជំនាន់”


## ជំពូកទី២


ការពិភាក្សា និងការជជែកវែកញែក ៖ តើសិទ្ធិមនុស្សមានជម្លោះមួយនឹងអធិបតេយ្យភាពរដ្ឋយ៉ាងដូចម្តេច?
ទស្សនៈទាន ៖ សារៈសំខាន់នៃច្បាប់ទំនៀមទំលាប់ jus cogens និងវិធានដាច់ខាតនៅអាស៊ីអាគ្នេយ៍
ការពិភាក្សា និងការជជែកវែកញែក ៖ តើអ្នកណាជាអ្នកបកស្រាយស្តង់ដារសិទ្ធិមនុស្ស?
ព្រឹត្តការណ៍ ៖ ក្របខណ្ឌពេលវេលានៃការបង្កើតច្បាប់សិទ្ធិមនុស្សអន្តរជាតិ
ការពិភាក្សា និងការជជែកវែកញែក ៖ ស្ថានភាពគតិយុត្តនៃ UDHR
ផ្តោតសំខាន់លើ ៖ បញ្ជីនៃសិទ្ធិក្នុង UDHR
ផ្តោតសំខាន់លើ ៖ ចាប់តាំងពីការបញ្ចុះបញ្ចូលដល់ការអនុវត្ត
ផ្តោតសំខាន់លើ ៖ សន្ធិសញ្ញាអន្តរជាតិស្នូលទាំងប្រាំបួន
ផ្តោតសំខាន់លើ ៖ ពីការបញ្ចុះបញ្ចូលទៅជាការអនុវត្ត


## ជំពូកទី៣


ផ្តោតសំខាន់លើ ៖ ពិធីសារបន្ថែម ICCPR
ការពិភាក្សា និងការជជែកវែកញែក ៖ ទោសប្រហារជីវិត
ផ្តោតសំខាន់លើ ៖ ទោសប្រហារជីវិតនៅអាស៊ីអាគ្នេយ៍
ការពិភាក្សា និងការជជែកវែកញែក ៖ រដ្ឋស្ថិតក្នុងភាពអាសន្ន

ការពិភាក្សា និងការជជែកវែកញែក៖ អ្នកណាគេជាអ្នកទទួលខុសត្រូវចំពោះការធានា ESCR ៖ រដ្ឋាភិបាល ឬបុគ្គល?

ករណីសិក្សា ៖ ការកាត់ក្តីលើសិទ្ធិលំនៅដ្ឋាន

ផ្តោតសំខាន់លើ ៖ សង្ខេប ESCR

ផ្តោតសំខាន់លើ ៖ ការធានាស្តង់ដារនៃសិទ្ធិស្តង់ដារជីវភាព

ករណីសិក្សា ៖ ការលោតមុងសាយចិននៅក្នុងប្រទេសឥណ្ឌូនេស៊ី

## ជំពូកទី៤

ផ្តោតសំខាន់លើ ៖ ស្ថានភាពនៃការការពារសិទ្ធិមនុស្ស

ការពិភាក្សា និងការជជែកវែកញែក ៖ តើសិទ្ធិមនុស្ស ការអភិវឌ្ឍ និងប្រជាធិបតេយ្យ មានការពាក់ព័ន្ធគ្នាដែរឬទេ?

ការពិភាក្សា និងការជជែកវែកញែក ៖ ចំនេះដឹងពីសិទ្ធិមនុស្ស

ករណីសិក្សា ៖ តុលាការកំពូលហ្វីលីពីនប្រើប្រាស់ UDHR និងICCPR

តារាង ៖ រដ្ឋធម្មនុញ្ញនៅអាស៊ីអាគ្នេយ៍

ការពិភាក្សា និងការជជែកវែកញែក ៖ រដ្ឋធម្មនុញ្ញមីយ៉ាន់ម៉ា

តារាង ៖ NHRIs នៅអាស៊ីអាគ្នេយ៍

តារាង ៖ អំណាចនៃ NHRIs នៅអាស៊ីអាគ្នេយ៍

ការពិភាក្សា និងការជជែកវែកញែក ៖ តើប្រព័ន្ធអាស៊ានគួរតែមានរូបរាងដូចម្តេច?

ការពិភាក្សា និងការជជែកវែកញែក ៖ តើ TOR របស់ AICHR មានចំនុចខ្លាំងកម្រិតណា?

ការពិភាក្សា និងការជជែកវែកញែក ៖ តើ NGO គួរតែបានគ្រប់គ្រងយ៉ាងដូចម្តេច?

ករណីសិក្សា ៖ វេទិកា-អាស៊ី(FORUM-ASIA)

ផ្តោតសំខាន់លើ ៖ HRW លើប្រទេសវៀតណាម

ករណីសិក្សា ៖ ការប្រមូលឯកសារលើការរំលោភសេពសន្ថវៈជាប្រព័ន្ធ

## ជំពូកទី៥

តារាង ៖ ប្រទេសអាស៊ីអាគ្នេយ៍នៅក្នុង UN

ការពិភាក្សា និងការជជែកវែកញែក ៖ តើនយោបាយបញ្ឈប់ការការពារសិទ្ធិមនុស្ស ដោយ UNSC មែនដែរឬទេ?

ផ្តោតសំខាន់លើ ៖ សេចក្តីសម្រេចក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ១៣២៥ និងរបាយការណ៍អាជ្ញាប័ណ្ណក្នុងការរំលោភសេពសន្ថវៈ

ផ្តោតសំខាន់លើ ៖ តាមដានព័ត៌មានពីសកម្មភាពរបស់ UN

តារាង ៖ ភាពខុសគ្នាចម្បងៗរវាងស្ថាប័នធម្មនុញ្ញ និងស្ថាប័នសន្ធិសញ្ញា
ទស្សនៈទាន ៖ ប្លុកប្រចាំតំបន់របស់អង្គការសហប្រជាជាតិ
ផ្តោតសំខាន់លើ ៖ ដំណើរការ UPR ជាក់ស្តែង- ករណីសិក្សានៃការត្រួតពិនិត្យលើកទីមួយរបស់ឥណ្ឌូនេស៊ីក្នុងខែមេសា ឆ្នាំ២០០៨
ផ្តោតសំខាន់លើ ៖ នីតិវិធីពិសេស
ផ្តោតសំខាន់លើ ៖ ទស្សនៈកិច្ចរបស់ Alston ទៅកាន់ប្រទេសហ្វីលីពីនក្នុងនាមជាអ្នករាយការណ៍ពិសេសលើការសម្លាប់រង្គាលក្រៅប្រព័ន្ធតុលាការ
តារាង ៖ ការស៊ើបអង្កេតលើរដ្ឋដោយយន្តការបណ្តឹងរបស់គណៈកម្មាការសិទ្ធិមនុស្ស
តារាង ៖ សង្ខេបពីស្ថាប័នសន្ធិសញ្ញា
ការពិភាក្សា និងការជជែកវែកញែក ៖ តើរបាយការណ៍រដ្ឋភាគីជាមធ្យោបាយមានសារៈសំខាន់មួយក្នុងការកំណត់ស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសមួយមែនដែរឬទេ?
ការពិភាក្សា និងការជជែកវែកញែក ៖ តើប្រទេសផ្លាស់ប្តូរដោយសារតែនីតិវិធីរបាយការណ៍របស់រដ្ឋដែរឬទេ?
តារាង ៖ ប្រទេសនៅអាស៊ីអាគ្នេយ៍ដែលអនុញ្ញាតឲ្យមានបណ្តឹងបុគ្គល
ទស្សនៈទាន ៖ ការបញ្ចប់នីតិវិធីបណ្តឹងថ្នាក់ជាតិ
តារាង ៖ ការប្តេជ្ញាចិត្តលើនីតិវិធីបណ្តឹង
ការពិភាក្សា និងការជជែកវែកញែក ៖ តើវិចារណកថាចងកាតព្វកិច្ចផ្លូវច្បាប់ដែរឬទេ?

## ជំពូកទី៦

ការពិភាក្សា និងការជជែកវែកញែក ៖ វិធីសាស្រ្តក្នុងការការពារប្រជាជនមិនមែនជាពលរដ្ឋពីការរើសអើង និងការកេងប្រវ័ញ្ច
ទស្សនៈទាន ៖ ការហៅបុគ្គលណាម្នាក់ថាមិនស្របច្បាប់
ការពិភាក្សា និងការជជែកវែកញែក ៖ តើការភ័យខ្លាចរបស់ប្រជាជនលើជនទេសន្តប្រវេសន៍មានភាពត្រឹមត្រូវកម្រិតណា?
ផ្តោតសំខាន់លើ ៖ ជនជាតិរ៉ូហ៊ីងញ៉ា Rohingya
ការពិភាក្សា និងការការជជែកវែកញែក ៖ ការកំណត់ឋានៈជនភៀសខ្លួន
ការពិភាក្សា និងការជជែកវែកញែក ៖ ជនភៀសខ្លួនបរិស្ថាន
ផ្តោតសំខាន់លើ ៖ មាត្រា ៣៣ នៃការហាមឃាត់ការបណ្តេញចេញ ឬបញ្ជូនទៅវិញ ("ការមិនបញ្ជូនត្រលប់ទៅវិញ")
ផ្តោតសំខាន់លើ ៖ (TBC) សម្ព័ន្ធព្រំដែនថៃ
ករណីសិក្សា ៖ ការឆ្លើយតបនឹងជនភៀសខ្លួនរស់នៅទីក្រុងក្នុងប្រទេសថៃ
ផ្តោតសំខាន់លើ ៖ ឧទាហរណ៍នៃភាពគ្មានសញ្ជាតិក្នុងតំបន់អាស៊ីអាគ្នេយ៍
ទស្សនៈទាន ៖ សញ្ជាតិ
ការពិភាក្សា និងការជជែកវែកញែក ៖ ច្បាប់ស្តីពីសញ្ជាតិរបស់អ្នក

ផ្តោតសំខាន់លើ ៖ ភាពគ្មានសញ្ជាតិ តាមផ្លូវច្បាប់ (*De Jure*) vs តាមអង្គហេតុ (*De Facto*)
ផ្តោតសំខាន់លើ ៖ សញ្ជាតិដែលមានប្រសិទ្ធិភាព
ករណីសិក្សា ៖ ការស្ទង់មតិសហគមន៍កុលសម្ព័ន្ធលើភ្នំក្នុងប្រទេសថៃ

## ជំពូកទី៧

ផ្តោតសំខាន់លើ ៖ សេចក្តីផ្តើមពីអង្គការអន្តរជាតិខាងការងារ (ILO)
ផ្តោតសំខាន់លើ ៖ អនុសញ្ញា និងអនុសាសន៍ ILO ពាក់ព័ន្ធនឹងពលករទេសន្តប្រវេសន៍
ផ្តោតសំខាន់លើ ៖ សិទ្ធិពលករទេសន្តប្រវេសន៍ និងគ្រួសាររបស់ពួកគេមានសិទ្ធិទទួលបាន ដោយមិនគិតពីស្ថានភាពឯកសារ
ទស្សនៈទាន ៖ ប្រាក់បញ្ញើរ
ករណីសិក្សា ៖ ករណីផ្លូវ ខនថែមផ្លេសិន Flor Contemplacion
ករណីសិក្សា ៖ ការភ័យខ្លាចរបស់ជនមិនមែនជាពលរដ្ឋ
ករណីសិក្សា ៖ ពលកម្មដោយបង្ខំ
ករណីសិក្សា ៖ ការការពារពលករទេសន្តប្រវេសន៍ជាកុមារ
ករណីសិក្សា ៖ អ្នកជួយកិច្ចការផ្ទះនៅសឹង្ហបូរីរៀបរាប់ពីហេតុការណ៍
ករណីសិក្សា ៖ ត្រូវបានជួញដូរទៅលើទូកនេសាទ
ការពិភាក្សា និង ការជជែកវែកញែក ៖ តើករណីណាមួយខាងក្រោមចាត់ទុកជាការជួញដូរ?
ករណីសិក្សា ៖ អ្នកណាត្រូវបានជួញដូរ? ជនរងគ្រោះដែលមិនសាកសម
ផ្តោតសំខាន់លើ ៖ ភាពខុសគ្នារវាងការជួញដូរមនុស្ស និងការរត់ពន្ធមនុស្ស
ករណីសិក្សា ៖ ប្រទេសថៃ (ខែមេសា ឆ្នាំ២០០៨)
តារាង ៖ ច្បាប់ប្រឆាំងនឹងការជួញដូរនៅអាស៊ីអាគ្នេយ៍

# បុព្វកថា

នៅពេលដែលបណ្តាញសិក្សាសិទ្ធិមនុស្សអាស៊ីអាគ្នេយ៍ត្រូវបានបង្កើតឡើង ក្នុងឆ្នាំ២០០៩ សកម្មភាពមួយក្នុងចំណោមសកម្មភាពដំបូងនៃបណ្តាញនេះ គឺជាការបង្កើតសៀវភៅពុម្ពសម្រាប់សិស្សនិស្សិតនៅអាស៊ីអាគ្នេយ៍។ កិច្ចការនេះឆ្លើយតបនឹងកម្មវត្ថុរបស់បណ្តាញក្នុងការលើកកម្ពស់ការបង្រៀនសិទ្ធិមនុស្ស នៅសកលវិទ្យាល័យនៅអាស៊ីអាគ្នេយ៍។ ដោយហេតុថាការអប់រំសិទ្ធិមនុស្សគឺជាសិទ្ធិមនុស្ស និងដោយសារសិស្សនិស្សិតមួយចំនួនតូចប៉ុណ្ណោះ ដែលបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ ហើយមានចំនេះដឹងពីសិទ្ធិមនុស្ស ដូចនេះមានការងារជាច្រើនដែលត្រូវធ្វើ។

សាស្ត្រាចារ្យជាច្រើននៅសាកលវិទ្យានៅអាស៊ីអាគ្នេយ៍ បានត្អូញត្អែរពីការលំបាកដែលមិនមានសៀវភៅពុម្ពសម្រាប់វគ្គសិក្សារបស់ខ្លួន។ ខណៈពេលដែលមានសៀវភៅពុម្ពសិទ្ធិមនុស្សជាច្រើន សៀវភៅទាំងនេះមិនតែងតែឆ្លើយតបនឹងតម្រូវការរបស់សិស្សនិស្សិតក្នុងសកលវិទ្យាល័យអាស៊ីអាគ្នេយ៍នោះទេ។ ការបកប្រែជាបញ្ហាមួយដ៏ធំ ដោយហេតុថាសិស្សថ្នាក់ឧត្តមសិក្សាទាំងអស់ សិក្សាជាភាសាជាតិរបស់ខ្លួន។ តម្លៃនៃសៀវភៅពុម្ពក៏ជាការប្រឈមមួយផងដែរ ដោយសារសៀវភៅទាំងនេះមានតម្លៃស្មើនឹងការចំណាយរស់នៅមួយខែសម្រាប់សិស្សនិស្សិតទូទៅ។ បន្ថែមពីលើនេះទៀត សៀវភៅពុម្ពភាគច្រើនមិនរៀបរាប់ពីអាស៊ីអាគ្នេយ៍ និងមិនផ្តោតសំខាន់លើកង្វល់ ដែលពាក់ព័ន្ធនឹងសិស្សនិស្សិតនោះទេ។

## គោលការណ៍នៃសៀវភៅពុម្ពនេះ

ដើម្បីឆ្លើយតបនឹងតម្រូវការទាំងនេះ SEAHRN បានចាប់ផ្តើមព្រាងសៀវភៅពុម្ពសិទ្ធិមនុស្សមួយសម្រាប់សិស្សនិស្សិតនៅអាស៊ីអាគ្នេយ៍។ បន្ទាប់មកមានការបង្កើតនូវគោលការណ៍មួយចំនួនៈ

- សៀវភៅពុម្ពត្រូវតែជាធនធានបើកចំហ ហើយសិស្សនិស្សិតទាំងអស់អាចទទួលបានដោយមិនចាំបាច់បង់ថ្លៃ។ មិនមានការដាក់កម្រិតលើការចែកចាយតាមរយៈសិទ្ធិអ្នកនិពន្ធ ឬត្រូវបានគ្រប់គ្រងដោយរោងពុម្ពអន្តរជាតិណាមួយនោះឡើយ។
- ជំពូក និងខ្លឹមសារនឹងដាក់នៅលើគេហទំព័រជាទម្រង់ PDF។
- សៀវភៅពុម្ពនឹងមានទម្រង់ដែលងាយស្រួលក្នុងការព្រីន និងក្ញពី។
- អ្នកប្រើប្រាស់សៀវភៅជាសិស្សនិស្សិតឧត្តមសិក្សា ដែលសិក្សាសិទ្ធិមនុស្សជាមុខវិជ្ជាទូទៅ ឬមុខវិជ្ជាដែលបានជ្រើសរើស។ សិស្សមិនចាំបាច់មានចំនេះជ្រៅជ្រះពី

មុនពីច្បាប់ នយោបាយ ការអភិវឌ្ឍន៍ ឬសង្គមវិទ្យានោះទេ ប៉ុន្តែសៀវភៅពុម្ពនេះនឹងបន្ថែមចំនេះដឹង ដល់សិស្សនិស្សិតដែលសិក្សាជំនាញទាំងនេះ។

- ខ្លឹមសារនៃសៀវភៅនេះនឹងត្រួតពិនិត្យស្ថានភាពសិទ្ធិមនុស្ស នៅអាស៊ីអាគ្នេយ៍ ហើយរាល់ប្រធានបទទាំងអស់នឹងស្ថិតក្នុងបរិបទនេះ។
- សៀវភៅពុម្ពនេះនឹងត្រូវបានបកប្រែជាភាសាសំខាន់ៗ នៅអាស៊ីអាគ្នេយ៍នៅពេលអនាគត។
- ខណៈពេលដែលគោលបំណង គឺដើម្បីចងក្រងសៀវភៅពុម្ពដែលមានគុណភាពខ្ពស់មួយ ក៏មានការផ្តល់អាទិភាពលើការបង្កើតសៀវភៅដែលងាយស្រួលក្នុងការបកប្រែផងដែរ។ ការសម្រួលដល់ការបកប្រែឲ្យភាពងាយស្រួលជាវិធីសាស្ត្រមួយក្នុងការធានាថាសៀវភៅពុម្ពនេះ អាចត្រូវបានទទួលបានដោយទូលំទូលាយ មានភាពជាក់លាក់ចំពោះតំបន់ និងការមានការចូលរួមទូលំទូលាយ។
- សៀវភៅពុម្ពនេះយោងតែទៅលើអត្ថបទដែលពាក់ព័ន្ធ ហើយអាចស្វែងរកបានដោយសិស្សនិស្សិតប៉ុណ្ណោះ ។ ដោយសារតែធនធានបណ្ណាល័យមានកម្រិត ហើយតម្លៃនៃអត្ថបទអន្តរជាតិថ្លៃ សៀវភៅពុម្ពនេះយោងទៅលើស្នាដៃដែលមានលើប្រព័ន្ធអ៊ិនធឺណែតហើយអាចទាញយកបានដោយមិនបាច់បង់ថ្លៃ។

ការងារក្នុងការបង្កើតសៀវភៅពុម្ពនេះ មានភាពយឺតយ៉ាវជាងការរំពឹងទុកតាំងពីដំបូង ហើយកិច្ចការមានកាន់តែច្រើនឡើងពេលបច្ចុប្បន្ននេះ។ ការវាយប្រហារដែលមានការកើនឡើងមកលើសេរីភាពលើការសិក្សាក្នុងប្រទេសនៅអាស៊ីអាគ្នេយ៍ និងតម្រូវការដែលជាបន្ទុកដល់គ្រឹះស្ថានសិក្សាបានរារាំងដល់ការបង្កើតសៀវភៅពុម្ពនេះ។ យ៉ាងណាមិញ ក្រុមការងារមួយក្រុមធំនៃអ្នកនិពន្ធ អ្នកស្រាវជ្រាវ និងអ្នកត្រួតពិនិត្យបានចំណាយកម្លាំងកាយចិត្តក្នុងការបង្កើតវគ្គទីមួយនៃសៀវភៅពុម្ពនេះ ហើយពួកគេសម្រេចបាននូវការងារសំខាន់មួយចំនួន ឆ្ពោះទៅកាន់ការរៀបចំជំពូកនៅក្នុងវគ្គទីពីរនៃសៀវភៅនេះថែមទៀតផង។

ទោះបីខ្លឹមសារទាំងស្រុងនៃសៀវភៅពុម្ពត្រូវបានធ្វើរួចរាល់ ក៏វាជាការប្រឈមមួយធំផងដែរក្នុងការបង្រៀនសៀវភៅនេះក្នុងសាកលវិទ្យាល័យនានាក្នុងតំបន់។ មិនត្រឹមតែរដ្ឋាភិបាលមានការស្ទាក់ស្ទើរក្នុងការបញ្ចូលសិទ្ធិមនុស្ស ក្នុងកម្មវិធីសិក្សាស្នូលប៉ុណ្ណោះទេ ប៉ុន្តែសិស្សនិស្សិតជាច្រើនមិនមានចំណាប់អារម្មណ៍ ឬអង្កេតឃើញថាមិនពាក់ព័ន្ធអ្វីក្នុងការសិក្សាពីសិទ្ធិមនុស្សនោះទេ។ ការពិភាក្សាពីប្រធានបទសិទ្ធិមនុស្សមួយចំនួន ដូចជាព្រឹត្តការណ៍ប្រវត្តិសាស្ត្រ ឬជម្លោះនយោបាយបច្ចុប្បន្នអាចជាបញ្ហារសើប។

# លក្ខណៈពិសេសនៃសៀវភៅពុម្ពនេះ

វគ្គទីមួយជាសកម្មភាពសហប្រតិបត្តិការ ដែលមានការចូលរួមពីសាស្ត្រាចារ្យ និងសិស្សនិស្សិតទូទាំងតំបន់។ ខណៈពេលដែលវាជាការប្រឈមក្នុងការសហការជាមួយនឹងសាស្ត្រាចារ្យ និងសិស្សនិស្សិតជាច្រើនពីប្រទេសផ្សេងៗ ភាពចម្រុះគ្នានេះ បានបន្ថែមនូវខ្លឹមសារយ៉ាងច្រើនក្នុងសៀវភៅពុម្ពនេះ។ លក្ខណៈពិសេសនៃសៀវភៅពុម្ពនេះក្នុងការជួយដល់សិស្សនិស្សិតមានដូចតទៅ៖

- តារាងនិយមន័យ៖ ជួយសិស្សនិស្សិតក្នុងការចាប់បាននូវអត្ថន័យនៃពាក្យគន្លឹះសិទ្ធិមនុស្ស
- ប្រធានបទពិភាក្សា និងចំនុចជជែកវែកញែក៖ ការប្រើប្រាស់តារាងទាំងនេះគឺដើម្បីបង្កើនការពិភាក្សា និងការជជែកវែកញែកជាមួយសិស្សនិស្សិតស្តីពីការប្រឈមនៃសិទ្ធិមនុស្ស។
- ឧទាហរណ៍ក្នុងអាស៊ីអាគ្នេយ៍៖ នៅពេលដែលពាក់ព័ន្ធ សិទ្ធិមនុស្សត្រូវបានពន្យល់ដោយផ្តោតលើសកម្មភាពក្នុងប្រទេសទាំង ១១ ក្នុងអាស៊ីអាគ្នេយ៍។
- ផ្នែកសំណួរគំរូ ជួយដល់សាស្ត្រាចារ្យក្នុងការបង្កើតសំណួរប្រលង និងសំណួរដែលងាយស្រួល។

នៅចុងបញ្ចប់នៃជំពូកនីមួយៗ មានសេចក្តីសង្ខេប និងការបញ្ជាក់លម្អិតខ្លីមួយពីប្រភពដែលសិស្សនិស្សិតអាចស្វែងរកឯកសារបន្ថែម។ ដោយដឹងថាប្រភពឯកសារមានកម្រិតសម្រាប់សិស្សនិស្សិតភាគច្រើន ការងារបន្ថែមគឺផ្តោតសំខាន់លើគេហទំព័រ និងស្ថាប័នសំខាន់ៗមួយចំនួនដែលអនុញ្ញាតឲ្យធ្វើការស្រាវជ្រាវដោយមិនបង់ចាំបាច់បង់ថ្លៃ។ ដោយសិស្សនិស្សិតទាំងអស់មានសមត្ថភាពចំនេះដឹងក្នុងការស្រាវជ្រាវលើប្រព័ន្ធអ៊ិនធឺណែត ដូចនេះមិនចាំបាច់វាយ URLs ដែលស្មុគ្រស្មាញនោះទេ ហើយនៅក្នុងផ្នែកនេះនឹងផ្តល់នូវពាក្យគន្លឹះសម្រាប់ការស្រាវជ្រាវតាមបណ្តាញអ៊ិនធឺណែត និងឈ្មោះរបស់អ្នកនិពន្ធដែលអាចត្រូវបានស្រាវជ្រាវដើម្បីស្វែងរកការបោះពុម្ពផ្សាយ និងអត្ថបទទស្សនាវដ្តីផ្សេងៗ។

កំណាត់ចំណាំពីការប្រើប្រាស់ពាក្យអាស៊ីអាគ្នេយ៍៖ សៀវភៅពុម្ពនេះប្រើប្រាស់ពាក្យអាស៊ីអាគ្នេយ៍ជាជាងអាស៊ានពីព្រោះសៀវភៅពុម្ពនេះ រួមបញ្ចូលប្រទេសទាំង១១នៅអាស៊ីអាគ្នេយ៍ ដែលជាប្រទេសអាស៊ាន និងទីម័រខាងកើត ដែលប្រហែលជានឹងចូលអាស៊ាននៅពេលឆាប់ៗខាងមុខនេះ។

# ទន្និងរងចាំវគ្គទីពីរ

វគ្គទីមួយជាជំហានបឋមមួយឆ្ពោះទៅកាន់វគ្គទីពីរដែលមានខ្លឹមសារច្រើនជាងនេះ ដែលមានបញ្ជាក់លម្អិតខាងក្រោម។ ដោយសារតែមានឧបសគ្គខាងពេលវេលា និងធនធាន ការបោះពុម្ពផ្សាយវគ្គទីពីរត្រូវបានផ្អាក់មួយរយៈសិន ហើយវគ្គទីមួយនេះជាការប្រមូលផ្តុំនូវជំពូកដែលត្រូវបានបញ្ចប់ដំណើរការត្រួតពិនិត្យ និងការកែសម្រួល។ វគ្គទីពីរនឹងមានជំពូកដែលផ្តោតសំខាន់លើប្រវត្តិនៃសិទ្ធិនៅអាស៊ីអាគ្នេយ៍ និងបញ្ជាក់ពីបញ្ហាសិទ្ធិមនុស្សពេលបច្ចុប្បន្ន។ ការបែងចែកមាតិកាដែលស្ថិតក្រោមការរៀបរៀងសម្រាប់វគ្គទីពីរមានដូចខាងក្រោម៖


| | |
|---|---|
| ជំពូកទី ១ | មូលដ្ឋាននៃសិទ្ធិមនុស្ស |
| ជំពូកទី ២ | ប្រវត្តិនៃសិទ្ធិមនុស្សនៅអាស៊ីអាគ្នេយ៍ |
| ជំពូកទី ៣ | បញ្ហាបច្ចុប្បន្ននៅអាស៊ីអាគ្នេយ៍ |
| ជំពូកទី ៤ | ស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ |
| ជំពូកទី ៥ | សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ៖ ICCPR និងICESCR |
| ជំពូកទី ៦ | ការពារសិទ្ធិមនុស្សនៅអាស៊ីអាគ្នេយ៍៖ យន្តការការពារថ្នាក់ជាតិ និងថ្នាក់តំបន់ |
| ជំពូកទី ៧ | ការការពារ៖ ប្រព័ន្ធអន្តរជាតិ |
| ជំពូកទី ៨ | ភាពចម្រុះនៃភេទ និងយែនឌ័រ |
| ជំពូកទី ៩ | កុមារ |
| ជំពូកទី ១០ | ពិការភាព |
| ជំពូកទី ១១ | សិទ្ធិរបស់ជនមិនមែនជាពលរដ្ឋ៖ ជនភៀសខ្លួន និងជនគ្មានសញ្ជាតិ |
| ជំពូកទី ១២ | សិទ្ធិរបស់ជនមិនមែនជាពលរដ្ឋ៖ ពលករទេសន្តប្រវេសន៍ និងមនុស្សដែលត្រូវបានជួញដូរ |
| ជំពូកទី ១៣ | សិទ្ធិជនជាតិដើមភាគតិច សិទ្ធិជនជាតិភាគតិច និងសិទ្ធិវប្បធម៌ |
| ជំពូកទី ១៤ | ការអភិវឌ្ឍ ធុរកិច្ច បរិស្ថាន និងសិទ្ធិមនុស្ស |
| ជំពូកទី ១៥ | សិទ្ធិមនុស្ស ដំណើរការប្រជាធិបតេយ្យ និងប្រព័ន្ធផ្សព្វផ្សាយ |
| ជំពូកទី ១៦ | សន្តិភាព ជម្លោះ និងសិទ្ធិមនុស្ស (IHL) |
| ជំពូកទី ១៧ | យុត្តិធម៌អន្តរកាល ICC ( CHA លក្ខន្តិកៈក្រុងរ៉ូម) |
| ជំពូកទី ១៨ | ទារុណកម្ម និងការបាត់ខ្លួន |
| ជំពូកទី ១៩ | ការស្រាវជ្រាវសិទ្ធិមនុស្ស |


យើងខ្ញុំសូមស្វាគមន៍ចំពោះធាតុចូលទាំងអស់លើការរចនា ខ្លឹមសារ ការប្រើប្រាស់ និងទស្សនៈសម្រាប់វគ្គទីពីរ។

# 1

# មូលដ្ឋានគ្រឹះនៃសិទ្ធិមនុស្ស

តើសិទ្ធិមនុស្សជាអ្វី? តើភាពខុសគ្នាអ្វីខ្លះដែលសិទ្ធិមនុស្សអាចធ្វើឲ្យកើតមានឡើងចំពោះបុគ្គលម្នាក់? នេះជាសំណួរសាមញ្ញទូទៅ នៅពេលដែលយើងព្យាយាមស្វែងយល់ពីទស្សនៈនៃសិទ្ធិមនុស្ស ហើយសំណួរទាំងពីរនេះអាចត្រូវបានស្វែងយល់បានតាមរយៈការត្រួតពិនិត្យស្ថានភាពពីរផ្សេងគ្នាអំពីសិទ្ធិមនុស្សនៅអាស៊ីអាគ្នេយ៍។

# ច្បាប់សិទ្ធិមនុស្សអន្តរជាតិ

១៩៤៨

UDHR | ១៩៤៨
សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

១៩៦៥

ICERD | ២១ ធ្នូ ១៩៦៥
អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍
ត្រួតពិនិត្យដោយ CERD

១៩៦៦

ICCPR | ១៦ ធ្នូ ១៩៦៦
កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ
ត្រួតពិនិត្យដោយ CCPR

ICESCR | ១៦ ធ្នូ ១៩៦៦
កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
ត្រួតពិនិត្យដោយ CESR

១៩៧៩

CEDAW | ១៨ ធ្នូ ១៩៧៩
អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ
ត្រួតពិនិត្យដោយ CEDAW

១៩៨៤

CAT | ១០ ធ្នូ ១៩៨៤
អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប
ត្រួតពិនិត្យដោយ CAT

១៩៨៩

CRC | ២០ វិច្ឆិកា ១៩៨៩
អនុសញ្ញាស្តីពីសិទ្ធិកុមារ
ត្រួតពិនិត្យដោយ CRC

១៩៩០

ICMW | ១៨ ធ្នូ ១៩៩០ អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិពលករទេសន្តប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ
ត្រួតពិនិត្យដោយ CMW

២០០៦

CRPD | ១៣ ធ្នូ ២០០៦
អនុសញ្ញាស្តីពីសិទ្ធិជនពិការ
ត្រួតពិនិត្យដោយ CRPD
CPED | ២០ ធ្នូ ២០០៦

# ហេតុការណ៍ទី ១

ថ្ងៃចាប់ផ្តើមជាធម្មតា។ មានភាពច្របូកច្របល់នៅខាងក្រៅ ប៉ុន្តែជាដំបូងអ្នកមិនខ្វល់ពីវានោះទេ រហូតដល់អ្នកលឺសំលេងកាំភ្លើង និងបុរសម្នាក់ស្រែក។ អ្នក និងក្រុមគ្រួសាររបស់អ្នកចេញមកក្រៅ ហើយក៏បានឃើញប្រជាជនប្រុសស្រីកាន់កាំភ្លើងក្នុងដៃពាសពេញផ្លូវ។ ពួកគេប្រាប់អ្នកឲ្យយករបស់របរណាដែលសំខាន់ ហើយចេញពីផ្ទះឲ្យបានឆាប់។ នៅពេលដែលអ្នកចេញពីផ្ទះ ក្រុមគ្រួសារ និងអ្នកជិតខាងរបស់អ្នកត្រូវបានគៀងឲ្យដើរលើផ្លូវ។ មានការលេចលឺដំណឹងថាទីក្រុងទាំងមូលត្រូវបានជម្លៀស។ អ្នកបានដឹងថាភាពវឹកវរកំពុងមានក្នុងប្រទេសរបស់អ្នក ប៉ុន្តែអ្នកមិនដែលបានគិតថាការសង្គ្រាមមកដល់ទ្វារផ្ទះរបស់អ្នកនោះទេ។ បន្ទាប់មកដំណឹងបានលេចលឺ៖ ខ្មែរក្រហមកំពុងតែជម្លៀសទីក្រុងធំៗទាំងអស់របស់កម្ពុជា ដោយធ្វើការអះអាងថាពួកគេកំពុងព្យាយាមការពារប្រជាជនពីគ្រាប់បែកអាមេរិកកាំង។ ពួកគេប្រាប់ក្រុមគ្រួសារ និងមិត្តភ័ក្តិរបស់អ្នក ថាអ្នកនឹងអាចត្រលប់មកផ្ទះវិញក្នុងរយៈពេលពីរបីថ្ងៃទៀត បន្ទាប់ពីគេឈប់ទម្លាក់គ្រាប់បែក។ ទាហានដែលស្លៀកពាក់ខ្មៅ និងកាន់កាំភ្លើងពេញដៃ ដែលភាគច្រើនមើលទៅដូចជាក្មេងអាយុ១៦ឆ្នាំ និយាយថាពួកគេនឹងរៀបចំចាត់ចែងអ្វីៗគ្រប់យ៉ាង។ យ៉ាងណាមិញ ប៉ុន្មានថ្ងៃក្រោយមក អ្នកចាប់ផ្តើមដឹងបន្តិចម្តងៗថាអ្នកមិនអាចត្រលប់មកផ្ទះវិញបាននោះទេ។

បន្ទាប់មកអ្នកដឹងថាវាជាថ្ងៃជម្លៀស (១៧ មេសា ១៩៧៥) ដែលជាថ្ងៃចាប់ផ្តើមនូវអ្វីដែលប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិបានហៅថាជា ″ឆ្នាំសូន្យ″។ អស់រយៈពេលជាច្រើនសប្តាហ៍ និងច្រើនខែ ជីវិតថ្មីរបស់អ្នកកាន់តែបង្ហាញច្បាស់។ ខ្មែរក្រហមប្រាប់អ្នកមិនឲ្យគិតពីរឿងបុគ្គល ថាគោលដៅថ្មីនៃជីវិតរបស់អ្នកគឺជាការបម្រើដល់កម្ពុជាប្រជាធិបតេយ្យ និងគោរពដល់ ″អង្គការ″ ដែលជាអំណាចគ្រប់គ្រងខ្ពស់បំផុត។ អ្នកទទួលបញ្ជាមិនឲ្យសួរសំណួរដល់កិច្ចការរបស់រដ្ឋថ្មីនេះ ឬ និយាយអំពីជីវិតនៅចំពោះមុខខ្មែរក្រហម។ បន្ថែមពីលើនេះទៀត អ្នកទទួលបញ្ជាឲ្យភ្លេចទាំងស្រុងនូវជីវិតចាស់របស់អ្នក ពីព្រោះអង្គការដឹងអ្វីដែលល្អប្រសើរបំផុតសម្រាប់អ្នក និងសង្គមរបស់អ្នក។ ផ្ទះសម្បែង និងទ្រព្យសម្បត្តិរបស់អ្នកមិនមែនជាកម្មសិទ្ធិរបស់អ្នកទៀតនោះទេ ហើយបានក្លាយជាកម្មសិទ្ធិរបស់កម្ពុជាប្រជាធិបតេយ្យ។ អង្គការហាមឃាត់មិនឲ្យមានកម្មសិទ្ធិផ្ទាល់ខ្លួនណាមួយនោះទេ។ សញ្ញាណណាមួយនៃឥទ្ធិពលបរទេសត្រូវបានបំផ្លាញ។ មន្ទីរពេទ្យ រោងចក្រ និងសាលារៀនត្រូវបានបិទទ្វារ។ សាសនាត្រូវបានដាក់ក្រៅច្បាប់ ហើយអាពាហ៍ពិពាហ៍មិនមែនជាជម្រើសរបស់បុគ្គលទៀតនោះទេ។ អ្នករៀនសូត្រត្រូវបានបំបែកចេញពីក្រុមរបស់អ្នក ហើយបាត់ខ្លួនជារៀងរហូត។ មិនពាក់ព័ន្ធនឹងមុខរបររបស់អ្នក អ្នកត្រូវបានបង្ខំឲ្យធ្វើការក្នុងវាលស្រែពេញមួយថ្ងៃ ហើយមានម្តងម្កាលប៉ុណ្ណោះទទួលបានបាយពីរចាន និងត្រីងៀតខ្លះក្នុងមួយថ្ងៃ។ ដោយក្តីអស់សង្ឃឹម អ្នកបានត្រឹមតែមើល

មនុស្សនៅជុំវិញអ្នក ស្លាប់ដោយសារភាពអត់ឃ្លាន និងជម្ងឺ។ អ្នកសួរខ្លួនឯងថាការស្លាប់ និងការបំផ្លិចបំផ្លាញកំពុងតែកើតមានឡើងមែនទេ? ហេតុអ្វីប្រជាជនកម្ពុជាសម្លាប់ប្រជាជនកម្ពុជាខ្លួនឯង?

## ហេតុការណ៍ទី២

តាមផ្លូវទៅកាន់សាកលវិទ្យាល័យរបស់អ្នក អ្នកប្រទះឃើញម្តាយវ័យក្មេងម្នាក់ និងកូនរបស់គាត់កំពុងសុំទាននៅតាមផ្លូវ។ ប៉ូលីសម្នាក់បានដើរមកជិត ហើយដេញគាត់។ ស្ត្រីនោះព្យាយាមក្នុងការតវ៉ា ប៉ុន្តែមិនឈ្នះប៉ូលីស។ ប៉ូលីសនោះរុញគាត់ធ្លាក់ពីផ្លូវ បង្ខំឲ្យគាត់ដើរចេញពីទីនោះដោយដៃទទេ។ ស្ត្រីនេះសុំទានតាមចិញ្ចើមផ្លូវជាមួយកូនរបស់គាត់ពីព្រោះគាត់ និងក្រុមគ្រួសាររបស់គាត់បានមកទីក្រុងដើម្បីស្វែងរកជីវភាពល្អប្រសើរ។ ប៉ុន្តែដោយសារប្តីរបស់ស្ត្រីរូបនេះមិនអាចស្វែងរកការងារ ហើយការពិបាកចិត្តរបស់គាត់បានក្លាយទៅជាកំហឹង ធ្វើឲ្យគាត់ផឹកស្រាជោគជាំ ហើយវាយប្រពន្ធ។ ក្រោយមកដើម្បីសុវត្ថិភាពផ្ទាល់ខ្លួន និងកូនរបស់គាត់ ស្ត្រីរូបនោះបានចាកចេញ ហើយបោះបង់ចោលនូវក្តីសង្ឃឹមតូចនេះ ដោយមកដេកតាមចិញ្ចើមថ្នល់ និងសុំទានដើម្បីចិញ្ចឹមជីវិត។

នៅពេលដែលស្ត្រីរូបនោះ និងកូនរបស់គាត់ដើរចេញ អ្នកគិតថាស្ថានភាពនេះជារឿងអាក្រក់បំផុតរបស់គាត់នៅថ្ងៃនេះ។ ប៉ុន្តែមានរឿងរ៉ាវ ដែលក្រុមជើងកាងផ្តល់ការការពារដល់អ្នកសុំទាន "ដែលជាសេវាមួយ" ដែលជាទូទៅយកកម្រៃជាងពាក់កណ្តាលនៃចំណូលប្រចាំថ្ងៃរបស់អ្នកសុំទានទាំងនោះ ហើយអ្នកគិតថាស្ត្រីរូបនោះនឹងប្រឈមនឹងការធ្វើទុកបុកម្នេញ ឬ អត់ដោយសារគាត់មិនអាចរកលុយបានគ្រប់សម្រាប់ថ្ងៃនេះ។ មានអ្វីកើតឡើងប្រសិនកូនរបស់គាត់ធ្លាក់ខ្លួនឈឺ ហើយគាត់មិនអាចបង់ថ្លៃថ្នាំ? បន្ទាប់មកគាត់មិនអាចរកលុយគ្រប់គ្រាន់ទិញទឹកដោះគោឲ្យកូនគាត់ប្រចាំថ្ងៃ ហើយចំនីអាហារដែលអត់មានគុណភាព និងតិចតួចដែលគាត់បញ្ចុកកូនគាត់ប្រចាំថ្ងៃ អាចធ្វើឲ្យកូនគាត់ឈឺ។ គាត់សង្ឃឹមថាអាចត្រលប់ទៅផ្ទះវិញឆាប់ៗ ប៉ុន្តែអ្នកមានចង្ងល់ថាតើក្រុមគ្រួសាររបស់គាត់ នឹងទទួលយកគាត់ឬក៏អត់ដោយសារឥឡូវនេះគាត់បានចាកចេញពីប្តីរបស់គាត់។

ស្ថានការណ៍ទាំងនេះបញ្ជាក់ពីស្ថានភាពធ្ងន់ធ្ងរនៃសិទ្ធិមនុស្ស។ ការបំផ្លិចបំផ្លាញទាំងស្រុងលើសង្គមកម្ពុជាដោយខ្មែរក្រហមជារឿងដែលកម្រ និងជាការប៉ះពាល់ធ្ងន់ធ្ងរបំផុតដែលបង្ហាញពីអ្វីដែលបានកើតឡើង នៅពេលដែលអវត្តមានទាំងស្រុងនៃសិទ្ធិមនុស្សនៅក្នុងសង្គមមួយ ហើយចោទជាសំណួរសំខាន់ៗមួយចំនួនៈ តើហេតុការណ៍អាចកើតឡើងបានយ៉ាងដូចម្តេច? តើមានបញ្ហាអ្វី? តើយើងអាចធ្វើអ្វីបានខ្លះដើម្បីបញ្ឈប់ការរំលោភទាំងនេះនាពេលអនាគត? តើវាអាចកើតមានឡើងម្តងទៀតដែរឬទេ? គួរឲ្យ

ស្តាយកម្រិតនៃអមនុស្សធម៌ ដែលមានក្នុងអំឡុងពេលខ្មែរក្រហមក្នុងប្រទេសកម្ពុជាបានកើតឡើង នៅពេលដែលពិភពលោកមិនទាន់បានត្រៀមខ្លួនក្នុងការចាប់បង្ខំអនុវត្តសិទ្ធិមនុស្សនៅឡើយ ជាកំហុសមួយដែលប្រជាជនជាច្រើននិយាយថានឹងមិនអាចកើតមានឡើងសារជាថ្មីឡើយ ទោះបីជាវាបានកើតឡើងសារជាថ្មីក៏ដោយ។

សេណារីយ៉ូទីពីរនៃម្តាយ និងកូនរបស់គាត់ដែលជួបប្រទះការលំបាកធ្ងន់ធ្ងរ ជាហេតុការណ៍ដែលកើតមានឡើងស្ទើរតែរាល់ថ្ងៃក្នុងទីក្រុងនៅអាស៊ីអាគ្នេយ៍។ យ៉ាងណាមិញបញ្ហាចោទមិនមែនថាហេតុអ្វីបានជាវាកើតឡើងនោះទេ ប៉ុន្តែលើថាតើសិទ្ធិមនុស្សអាចត្រូវបានប្រើប្រាស់យ៉ាងដូចម្តេចដើម្បីជួយ និង ការពារដល់ប្រជាជនទាំងនេះ? សំណួរសំខាន់មួយ គឺថាតើភាពក្រីក្រខ្លាំងធ្វើឲ្យអ្នកក្រីក្រសុំទានលើចិញ្ចឹមផ្តល់ជាបញ្ហាសិទ្ធិមនុស្ស ឬវាជាបញ្ហានៃការអភិវឌ្ឍ សេដ្ឋកិច្ច ឬសុខាមាលភាព? តើសិទ្ធិមនុស្សអាចជួយដោះស្រាយបញ្ហាទាំងនេះបានដែរឬទេ ឬ សិទ្ធិមនុស្សនឹងគ្រាន់តែបង្ហាញពីបញ្ហាដែលកើតមាននៅក្នុងសង្គម ហើយមិនអាចធ្វើអ្វីបាន? សៀវភៅពុម្ពនេះអះអាងថាជាការសំខាន់ក្នុងការក្រលេកមើលសិទ្ធិមនុស្ស ក្នុងស្ថានភាពទាំងពីរនេះពីព្រោះការការពារសិទ្ធិមនុស្ស ជាកិច្ចការប្រចាំថ្ងៃក្នុងជីវិតប្រជាជនភាគច្រើន។ សិទ្ធិមនុស្សមិនគួរគ្រាន់តែគ្របដណ្តប់លើករណីដែលអាក្រក់បំផុតនោះទេ ប៉ុន្តែត្រូវគ្របដណ្តប់ផងដែរលើវិធីដែលសង្គមបានប្រព្រឹត្តមកលើ និងគោរពប្រជាជនដែលងាយរងគ្រោះរបស់ខ្លួនមិនថាពួកគេក្រ ជនពិការ ឬកុមារនោះទេ។ ដូចដែលសៀវភៅពុម្ពនឹងបញ្ជាក់លម្អិតសិទ្ធិមនុស្សការពារ និងគាំទ្រដល់ភាពថ្លៃថ្នូររបស់ប្រជាជន និងអនុញ្ញាតឲ្យប្រជាជនគ្រប់គ្រងលើជីវិតរបស់ពួកគេដោយមិនមានការចាប់បង្ខំ ឬការរើសអើង មិនថាពីរដ្ឋាភិបាលក្រុមប្រដាប់អាវុធ ឬបើមិនដូចនេះទេពីអ្នកមានអំណាចក្នុងសង្គមនោះឡើយ។

នៅពេលបច្ចុប្បន្ននេះ រដ្ឋាភិបាល និងសង្គមមានកំណត់ត្រាចម្រុះក្នុងការគាំទ្រសិទ្ធិមនុស្ស ៖ ការបោះឆ្នោតមានការកើនឡើងនូវ ″ភាពសេរី និងយុត្តិធម៌″។ ភាពក្រីក្រត្រូវបានកាត់បន្ថយ (ទោះបីជាមិនអាចលុបបំបាត់បានក៏ដោយ)។ ក្មេងស្រីចូលរៀន និងបន្តការសិក្សាទៅថ្នាក់ខ្ពស់មានការកើនឡើង។ សេវាសុខភាពពេលបច្ចុប្បន្ននេះអាចទទួលបានដោយប្រជាជនភាគច្រើន។ ស្របពេលជាមួយគ្នានេះផងដែរ ការរំលោភបំពានសិទ្ធិជាមូលដ្ឋានលេចឡើងក្នុងសារព័ត៌មានរៀងរាល់ថ្ងៃ ប្រជាជនត្រូវបានបណ្តេញចេញពីដីធ្លីរបស់ពួកគាត់ ទាហាន ឬប៉ូលីសគម្រាមកំហែងសហគមន៍មូលដ្ឋាន ពលករទេសន្តប្រវេសន៍ត្រូវបានកេងប្រវ័ញ្ចនៅទីតាំងការដ្ឋាន ស្ត្រីរងការប្រមាថ ប្រជាជនរស់នៅកន្លែងអនាធិបតេយ្យ ហើយស្លាប់ក្នុងអគ្គីភ័យ កុមារមិនអាចចូលរៀនបាន។ លទ្ធភាពក្នុងការដោះស្រាយស្ថានភាពទាំងនេះ និងអ្វីដែលធានាថាភាពឃោរឃៅដែលបានកើតឡើងក្នុងអំឡុងពេលខ្មែរក្រហមនឹងមិនកើតឡើងម្តងទៀត គឺពឹងផ្អែកយ៉ាងចម្បង

លើសិទ្ធិមនុស្ស ប្រជាជនដឹងពីសិទ្ធិរបស់ខ្លួន រដ្ឋាភិបាលធានាថាសិទ្ធិទាំងនោះត្រូវបាន រក្សា ហើយសង្គមអន្តរជាតិមួយនឹងចាត់ឲ្យរដ្ឋាភិបាលអនុវត្តនូវការប្តេជ្ញាចិត្តរបស់ខ្លួន។

# ១.១ តើសិទ្ធិមនុស្សជាអ្វី?

មានចម្លើយសាមញ្ញមួយ និងស្មុគ្រស្មាញមួយលើសំណួរដែលថាសិទ្ធិមនុស្សជាអ្វី ប៉ុន្តែ ចម្លើយទាំងពីរនេះ គួរតែត្រូវបានបញ្ជាក់ដើម្បីស្វែងយល់ពីសិទ្ធិទស្សនៈនៃសិទ្ធិមនុស្ស។ ចម្លើយសាមញ្ញអាចនិយាយបានថាពាក្យពេចន៍នេះ ផ្តល់ការពន្យល់ដោយខ្លួនឯង៖ សិទ្ធិ មនុស្សជាសិទ្ធិទាំងឡាយណា ដែលបុគ្គលមួយរូបមានពីព្រោះពួកគេជាមនុស្ស។ ក្នុង ន័យម្យ៉ាងទៀត មនុស្សលោកសាកសមក្នុងការទទួលបានកម្រិតជាក់លាក់ណាមួយនៃ សេរីភាព ឬស្តង់ដារជីវភាពដែលសាមញ្ញពីព្រោះពួកគេជាមនុស្ស។

ចម្លើយដែលស្មុគ្រស្មាញគឺថាសិទ្ធិមនុស្សមាននូវស្តង់ដារ ដែលបានទទួលស្គាល់ជា អន្តរជាតិមួយពីវិធីសាស្ត្រដែលប្រជាជនគួរតែត្រូវបានប្រព្រឹត្តមកលើ មិនពាក់ព័ន្ធនឹង ស្ថានភាព ឬកន្លែងដែលពួកគេរស់នៅនោះទេ។ តាមនិយមន័យនេះ សិទ្ធិមនុស្សមាន ធាតុនិត្យានុកូលជាមូលដ្ឋាន ហើយសិទ្ធិមនុស្សធានាថារដ្ឋាភិបាល និងភាគីដទៃមិន ដាក់កម្រិតលើសេរីភាព ឬបង្កឲ្យមានការឈឺចាប់ដែលមិនចាំបាច់ដល់ប្រជាជននោះ ទេ។ ប្រសិនជាសិទ្ធិទាំងនេះត្រូវបានរក្សា ប្រជាជនទាំងអស់អាចរស់នៅប្រកបដោយ ភាពថ្លៃថ្នូរ។ ចំនួននៃសិទ្ធិដែលបានទទួលស្គាល់ជាអន្តរជាតិកំពុងតែមានការកើនឡើង ដែលស្ថិតក្រោមការជជែកវែកញែកនៅអង្គការសហប្រជាជាតិ (UN) និងស្ថាប័នដទៃ។

សិទ្ធិមនុស្សអាចត្រូវបានពន្យល់ទៅតាមរយៈអ្វីដែលសិទ្ធិទាំងនោះផ្តល់ជូនដល់មនុស្ស៖

- សេរីភាពក្នុងការធ្វើសកម្មភាពជាក់លាក់ (ជាឧទាហរណ៍ធ្វើដំណើរ បង្ហាញពីទស្សនៈ របស់ខ្លួន ឬគោរពសាសនាមួយ) ។
- សេរីភាពរួចផុតពីលក្ខខណ្ឌជាក់លាក់មួយចំនួន (ជាឧទាហរណ៍ទារុណកម្ម និងទាស ភាព)។
- សិទ្ធិក្នុងការទទួលបានសេវាកម្ម (ជាឧទាហរណ៍ការអប់រំ សុខភាព ប្រព័ន្ធច្បាប់ ដែលយុត្តិធម៌ និងលទ្ធភាពក្នុងការធ្វើការងារ)
- ការការពារដល់ក្រុមប្រជាជនងាយរងគ្រោះដូចជាជនពិការ កុមារ ស្ត្រី និងជនភៀស ខ្លួន។

ជាសង្ខេប សិទ្ធិមនុស្សធានាថាប្រជាជនមានលទ្ធភាពក្នុងការចូលរួមពេញលេញក្នុងសង្គមមួយ ហើយរស់នៅជីវិតមួយប្រកបដោយភាពថ្លៃថ្នូរ។ សិទ្ធិមនុស្សក៏ធានាផងដែរថាតម្លៃរបស់មនុស្សយើងត្រូវបានទទួលស្គាល់ និងការពារ។ ផ្នែកបន្ទាប់ចោទជាសំណួរថាតើបុគ្គលមួយរូបទទួលបានសិទ្ធិមនុស្សរបស់ពួកគេបានយ៉ាងដូចម្តេច ហើយអ្នកណាជាអ្នកសម្រេចថាសិទ្ធិទាំងនោះជាអ្វី?

## ១.១.១ ជាមនុស្ស

លក្ខណៈវិនិច្ឆ័យចាំបាច់តែមួយគត់ក្នុងការទទួលបានសិទ្ធិមនុស្ស គឺត្រូវតែជាមនុស្ស មិនមានលក្ខខណ្ឌ គុណវុឌ្ឍិ ឬចំនេះដឹងផ្សេងទៀតដែលចាំបាច់នោះទេ។ នៅក្នុងជីវិតប្រចាំថ្ងៃមិនមានការពិបាកក្នុងការញែកមនុស្សពីសត្វឬរុក្ខជាតិនោះទេ៖ រូបរាងជីវសាស្ត្រជាក់ស្តែងបញ្ជាក់ថាមនុស្សជាមនុស្ស។ យ៉ាងណាមិញជាការពិបាកក្នុងការកំណត់ថាបុគ្គលណាម្នាក់ក្លាយទៅជាមនុស្ស ហើយនៅពេលណាខ្លះដែលពួកគេឈប់ក្លាយជាមនុស្ស។

### នៅពេលណាដែលបុគ្គលណាម្នាក់ក្លាយជាមនុស្ស?

ជុំវិញពិភពលោក មិនមានការព្រមព្រៀងជាសកលលើថាពេលណាជីវិតមនុស្សចាប់ផ្តើមនោះទេ។ សង្គមខ្លះអះអាងថាជីវិតចាប់ផ្តើមនៅពេលកើត ខ្លះទៀតចាត់ទុកតាំងពីពេលចាប់មានគភ៌ថាជាពេលសំខាន់ និងខ្លះទៀតកំណត់ថា នៅពេលដែលទារកមួយរូបអាចរស់នៅដោយមិនមានម្តាយរបស់ខ្លួន ។ ខណៈពេលដែលបុគ្គលម្នាក់អាចក្រលេកមើលស្ត្រីដែលមានផ្ទៃពោះមួយរូប ហើយឃើញនូវជីវិតមួយ (ស្ត្រីរូបនោះ) អ្នកខ្លះទៀតអាចឃើញជីវិតពីរ (ស្ត្រីរូបនោះ និងទារករបស់គាត់)។ ឥទ្ធិពលនៃសិទ្ធិមនុស្សមានន័យពីរយ៉ាង។ ទីមួយ និយមន័យច្បាប់នឹងកំណត់និត្យានុកូលភាពនៃការបញ្ចប់ការមានផ្ទៃពោះ។ ទីពីរនិយមន័យនេះមានការបង្កប់ន័យចម្បងលើសុខភាពបន្តពូជ និងសិទ្ធិស្ត្រីជុំវិញបញ្ហាពាក់ព័ន្ធសិទ្ធិរបស់ស្ត្រីមានផ្ទៃពោះ ក្នុងការសម្រេចថានឹងធ្វើអ្វីចំពោះទារកដែលមិនទាន់កើត ដែលនឹងមានបញ្ជាក់ក្នុងជំពូកក្រោយៗ។ យ៉ាងណាមិញ នៅពេលកើត មនុស្សទទួលបានសិទ្ធិមនុស្សជាស្វ័យប្រវត្តិ មិនពាក់ព័ន្ធនឹងកន្លែងដែលពួកគេកើត ឬថាតើពួកគេដឹងថាសិទ្ធិមនុស្សជាអ្វីឬក៏អត់នោះទេ។

### ហើយនៅពេលណាខ្លះដែលបុគ្គលណាម្នាក់ឈប់ក្លាយជាមនុស្ស?

សំណួរដែលថានៅពេលណា ដែលសិទ្ធិមនុស្សរបស់បុគ្គលណាម្នាក់លែងមានគឺបង្ហាញពីលក្ខណៈពិសេសផ្សេងទៀតនៃអ្វីដែលត្រូវចាត់ទុកថាជាមនុស្ស។ មរណៈភាព

ជាស្ថានការណ៍ដែលបញ្ជាក់ច្បាស់ ហើយមនុស្សមួយចំនួនមានបញ្ហាក្នុងការបែងចែករវាងអ្នកស្លាប់ និងអ្នកដែលនៅរស់។ យ៉ាងណាមិញ មានអ្វីកើតឡើងប្រសិនបើជនណាម្នាក់ត្រូវបានធ្វើកោសល្យវិច័យ រកឃើញថាខួរក្បាលរបស់គាត់ឈប់ដើរ ឬក៏គាត់មានជម្ងឺផ្លូវចិត្តធ្ងន់ធ្ងរ ឬខូចខួរក្បាល? នៅកម្រិតណាមួយដែលឆន្ទៈក្នុងការរក្សាបុគ្គលណាម្នាក់ឲ្យនៅមានជីវិត បន្ទាប់ពីគាត់ទទួលរងនូវគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬអសមត្ថភាពផ្លូវចិត្តអាចត្រូវបានចាត់ទុកថាសមហេតុផល?

ការឆ្លើយសំណួរទាំងនេះ បង្ហាញពីលក្ខណៈសំខាន់នៃលក្ខខណ្ឌជាមនុស្ស។ ជាទស្សនៈសាមញ្ញមួយដែលថាបុគ្គលមួយរូបត្រូវតែដឹងខ្លួន ហើយមានការគិតដែលសមហេតុផលដើម្បីធ្វើជាមនុស្សពេញលេញ។ មានតែនៅពេលដែល ខួរក្បាលបុគ្គលមួយរូបលែងដើរ ឬក៏មិនអាចគិត ទើបគេអាចបិតឧបករណ៍ទ្រទ្រង់ជីវិត។ ខណៈពេលដែលរដ្ឋផ្សេងៗមាននីតិវិធីផ្សេងៗគ្នាក្នុងការធ្វើសេចក្តីសម្រេចចិត្តលើបញ្ហានេះ (ជារឿយៗរួមមានការចរចាររវាងអ្នកផ្តល់ដំបូន្មានវេជ្ជសាស្ត្រ ឆន្ទៈរបស់ក្រុមគ្រួសារ ហើយនិងចំណាយថ្លៃព្យាបាល) សេចក្តីសម្រេចក្នុងការធ្វើបែបនេះជារឿយៗ ផ្អែកទៅលើថាតើអ្នកជម្ងឺអាចមានមុខងារជាមនុស្សបានឬក៏អត់។

លើសពីនេះទៀត ជាមនុស្សមានន័យថាប្រជាជនអាចចូលរួមដោយសមហេតុផលនៅក្នុងសង្គម។ នៅពេលនរណាម្នាក់បានបាត់បង់ការគិតសមហេតុផលរបស់គាត់ ប្រហែលជាដោយសារជម្ងឺផ្លូវចិត្ត ឬការខូចខួរក្បាល រដ្ឋាភិបាល ឬអាណាព្យាបាលរបស់គាត់ត្រូវកាន់កាប់សិទ្ធិ និងមានទំនួលខុសត្រូវជំនួសគាត់មួយចំនួន។ ដូចនេះរដ្ឋាភិបាលគួរតែមានវិធីសាស្ត្រមួយក្នុងការកំណត់ពីបញ្ហានេះ ព្រមទាំងមានអាជ្ញាធរដែលត្រូវបានតែងតាំងក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ ដូចនេះនៅពេលដែលស្ថានភាពនេះកើតមានឡើង អ្នកដែលទទួលរងផលប៉ះពាល់តាមវិធីណាមួយ មិនបាត់បង់សិទ្ធិរបស់ពួកគេនោះឡើយ ប៉ុន្តែសិទ្ធិទាំងនេះត្រូវបានផ្តល់ជូនដល់អាណាព្យាបាល ឬអ្នកមើលថែរបស់ពួកគេ។ ជាថ្មីម្តងទៀត សង្ឃឹមថារដ្ឋាភិបាលនឹងមានច្បាប់ជាធរមានដើម្បីការពារសិទ្ធិជាមូលដ្ឋានរបស់ប្រជាជនទាំងនេះ ខណៈពេលនោះផងដែរ ទទួលស្គាល់ថាពួកគេមិនមានសមត្ថភាពចាំបាច់ ក្នុងការមានមុខងារនៅក្នុងសង្គមនោះទេ។ នៅក្នុងទស្សនៈនៃសិទ្ធិមនុស្ស មនុស្សត្រូវបានចាត់ទុកថាជាសភាវៈដែលមានការគិតសមហេតុផលដូចដែលបានបញ្ជាក់លម្អិតក្នុងមាត្រា១ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR)។

## ការពិភាក្សា និងការជជែកវែកញែក

### ការដកហូតសិទ្ធិមនុស្ស

មានបញ្ហាចោទដែលពិបាកឆ្លើយ នៅពេលដែលបុគ្គលមួយរូបទទួលរងការខូចខាតខួរក្បាលធ្ងន់ធ្ងរ ឬមានជម្ងឺផ្លូវចិត្តធ្ងន់ធ្ងរដែលជាលទ្ធផលធ្វើឲ្យពួកគេមិនអាចមានមុខងារដោយសមហេតុផលក្នុងសង្គម ពួកគេអាចបង្កគ្រោះថ្នាក់ដល់ខ្លួនឯង ឬអ្នកដទៃ។ ទូទាំងពិភពលោក ឧក្រិដ្ឋកម្មធ្ងន់ធ្ងរជារឿយៗត្រូវបានដាក់ទណ្ឌកម្មដោយការដាក់ពន្ធនាគារ ។

***ប្រសិនបើបុគ្គលនេះត្រូវបានបញ្ជូនទៅពន្ធនាគារ ឬចាក់សោរទុកឲ្យឆ្ងាយពីគេពីព្រោះគាត់មានជម្ងឺឆ្កួតពោគចិត្ត តើគាត់មិនបាត់បង់សិទ្ធិរបស់គាត់ទេមែនទេ? ដូចនេះ តើនេះមានន័យថាសិទ្ធិមនុស្សមិនមែនជាសកលទេមែនទេ?***

យ៉ាងណាមិញ ទោះបីជានៅក្នុងពន្ធនាគារក៏ដោយ មនុស្សនៅតែមានសិទ្ធិជាច្រើនរបស់ពួកគេ។ ជាចាំបាច់ ពួកគេត្រូវរក្សាសិទ្ធិជាមូលដ្ឋានរបស់ខ្លួន (ដូចជាសិទ្ធិក្នុងការរស់រានមានជីវិត សេរីភាពរួចផុតពីការធ្វើទារុណកម្ម និងទាសភាព និងការប្រព្រឹត្តមកលើដែលមិនមានការរើសអើង)។

## ១.១.២ សិទ្ធិរបស់មនុស្ស

សិទ្ធិត្រូវបានទទួលស្គាល់ពីព្រោះសិទ្ធិទាំងនេះត្រូវបានចាត់ទុកថា ″ត្រឹមត្រូវ″ និង "យុត្តិធម៌″ ។ នៅក្នុងភាសាអង់គ្លេសអត្ថន័យពីរនៃសិទ្ធិមនុស្សពាក់ព័ន្ធនឹង៖ អ្នកមាន ″សិទ្ធិ″ ក្នុងការទទួលបានអ្វីមួយពីព្រោះវាត្រូវបានចាត់ថា ″ជារឿងត្រឹមត្រូវ″ ឬ "ត្រឹមត្រូវ″ ។ សិទ្ធិមួយជាអ្វីដែលត្រូវបានជំពាក់ដល់បុគ្គលម្នាក់ (ដែលគាត់សាកសមនឹងទទួលបាន) ឬវាអាចអនុវត្តចំពោះលក្ខខណ្ឌមួយ ដែលពួកគេអាចរួចផុតពីលក្ខខណ្ឌទាំងនោះ។ ដូចនេះ ទស្សនៈនៃសិទ្ធិមួយអាចទាំងមានភាពសាមញ្ញ និងស្មុគ្រស្មាញ។ ក្នុងន័យសាមញ្ញ សិទ្ធិមួយគឺជាអ្វីដែលបុគ្គលមួយរូបអាចទទួលបានដោយត្រឹមត្រូវ មានសេរីភាពក្នុងការធ្វើអ្វីមួយ ឬត្រូវបានការពារដោយ។ មានសិទ្ធិផ្សេងៗគ្នាជាច្រើន៖ សិទ្ធិអ្នកប្រើប្រាស់ សិទ្ធិអ្នកដំណើរ សិទ្ធិរបស់ពលរដ្ឋ សិទ្ធិរបស់អ្នកទស្សនា សិទ្ធិលើអចលនទ្រព្យ សិទ្ធិរបស់សិស្សនិស្សិត សិស្សសិក្សារៀនសូត្រ សិទ្ធិក្នុងការទស្សនៈកិច្ច និងមានច្រើនទៀត។ សិទ្ធិនីមួយៗបង្កប់នូវសិទ្ធិរបស់បុគ្គលម្នាក់ក្នុងការធ្វើអ្វីមួយ។

ការឆ្លើយតបដែលស្មុគ្រស្មាញ រួមបញ្ចូលនូវការស្វែងយល់ពីធាតុផ្សំនៃទស្សនៈផ្លូវច្បាប់នៃសិទ្ធិមួយ ដែលរួមមាននូវលក្ខណៈពិសេសមួយចំនួន។ ដំបូង សិទ្ធិមួយត្រូវពាក់ព័ន្ធនឹងកម្មវត្ថុមួយ ដែលនេះជាអ្វីជាក់លាក់ដែលសិទ្ធិមួយផ្តល់ជូន អនុញ្ញាត ឬធានា។ នេះជាខ្លឹមសារនៃសិទ្ធិ ហើយសម្រាប់សិទ្ធិមនុស្ស កម្មវត្ថុទាំងនេះត្រូវបានបញ្ជាក់នៅក្នុងច្បាប់ និងសន្ធិសញ្ញា។ សម្រាប់ប្រភេទនីមួយៗនៃសិទ្ធិ គឺមាននូវបុព្វសិទ្ធិមួយចំនួន ៖ ជាឧទាហរណ៍ សិស្សមួយរូបមានសិទ្ធិក្នុងការសួរសំណួរក្នុងថ្នាក់ ខ្ចីសៀវភៅពីបណ្ណាល័យ ហើយមានឱកាសសមស្របក្នុងការបញ្ចប់ការសិក្សា។ អ្នកបើកបរមានសិទ្ធិមួយដើម្បីប្រើប្រាស់ផ្លូវថ្នល់ អ្នកធ្វើដំណើរមានសិទ្ធិក្នុងការប្រើប្រាស់ឡានក្រុងសាធារណៈ ។ល។

ទីពីរ សិទ្ធិមួយត្រូវតែពាក់ព័ន្ធនឹងនរណាម្នាក់ ឬស្ថាប័នមួយដែលមានកាតព្វកិច្ចក្នុងការផ្តល់សិទ្ធិនោះ។ ប្រសិនបើគ្មានបុគ្គលនោះ ឬស្ថាប័ននោះមិនចាំបាច់មានសិទ្ធិនោះទេ។ នេះមានន័យថាសិទ្ធិមួយអាចត្រូវចាត់ទុកថាជាសិទ្ធិប្រសិនបើភាគីទីពីរ (មិនថាជារដ្ឋ ក្រុមហ៊ុនមួយ ឬសាកលវិទ្យាល័យមួយ) ត្រូវបានស្នើរឲ្យធ្វើការគោរព និងរក្សានូវសិទ្ធិនោះ។ មិនចាំបាច់ផ្តល់សិទ្ធិដល់អ្នកណាម្នាក់នូវសិទ្ធិក្នុងការដកដង្ហើមនោះទេ ពីព្រោះថាមានខ្យល់ច្រើនណាស់ដើម្បីដកដង្ហើម។ យ៉ាងណាមិញប្រសិនបើខ្យល់ត្រូវបានបំពុល ហើយពិបាកក្នុងការដកដង្ហើម ដូចនេះត្រូវមានអ្នកទទួលកាតព្វកិច្ចក្នុងការធានានូវសិទ្ធិដល់ប្រជាជនក្នុងការដកដង្ហើមខ្យល់បរិសុទ្ធ។ នេះត្រូវបានហៅថាជាកាតព្វកិច្ចដែលមានទំនាក់ទំនងនឹងសិទ្ធិមួយ ដែលនឹងត្រូវបានពន្យល់បន្ថែមក្នុងផ្នែកក្រោយទៀតនៃសៀវភៅនេះ។

សិទ្ធិមិនត្រឹមតែអនុវត្តចំពោះមនុស្សនោះទេ៖ សាជីវកម្ម ក៏មានសិទ្ធិ និងកាតព្វកិច្ចផងដែរ ហើយសត្វក៏មានសិទ្ធិផងដែរ។ នេះមិនមែនមានន័យថាពួកគេទទួលបានសិទ្ធិស្មើគ្នានឹងមនុស្សនោះទេ ប៉ុន្តែមានន័យថាមានអ្នកមានកាតព្វកិច្ចដែលត្រូវផ្តល់សិទ្ធិដល់សត្វ ឬសាជីវកម្ម។ វាមិនមែនជាការសមហេតុផលនោះទេ ក្នុងការផ្តល់ដល់សត្វនូវសិទ្ធិដូចគ្នាទៅនឹងមនុស្ស ដោយសត្វមិនចាំបាច់ត្រូវបោះឆ្នោត ឬមានសញ្ជាតិនោះទេ ប៉ុន្តែពួកគេត្រូវការសិទ្ធិក្នុងការធានាថាពួកគេទទួលបានការប្រព្រឹត្តមកលើសមរម្យ ហើយត្រូវការពារពួកគេពីការរំលោភបំពានពីមនុស្ស។ តាមរយៈនេះ សិទ្ធិរបស់សត្វគឺស្រដៀងគ្នានឹងមនុស្ស ៖ ដោយសារសិទ្ធិមនុស្សការពារមនុស្សពីការរំលោភបំពានដោយរដ្ឋ ឬសង្គម សិទ្ធិរបស់សត្វការពារសភាវៈសត្វ ពីការរំលោភបំពានដោយមនុស្ស។

## ១.១.៣ មូលដ្ឋានគ្រឹះនៃសិទ្ធិមនុស្ស

សិទ្ធិមនុស្សត្រូវបានបង្កើតឡើងនៅក្នុងចំណោម សិទ្ធិផ្លូវច្បាប់ សិទ្ធិសីលធម៌ និង សង្គម។ សិទ្ធិទាំងបីប្រភេទនេះ (ផ្លូវច្បាប់ សីលធម៌ និងសង្គម) ទាមទារឲ្យមានការពិភាក្សា។ ទីមួយ សិទ្ធិមនុស្សគួរតែត្រូវបានចាត់ទុកថាជាសិទ្ធិដោយច្បាប់។ មានសិទ្ធិផ្លូវច្បាប់ជាច្រើន (ជាឧទាហរណ៍ សិទ្ធិរបស់អ្នកណាម្នាក់ក្នុងការរៀបការ ឬកាន់កាប់ទ្រព្យសម្បត្តិដោយស្របច្បាប់) ដែលត្រូវបានការពារដោយច្បាប់។ រដ្ឋាភិបាលគួរតែគោរពសិទ្ធិមនុស្ស មិនមែនគ្រាន់តែដោយសារវាជា "សិទ្ធិ" ឬ "សីលធម៌" នោះទេ ប៉ុន្តែពីព្រោះពួកគេត្រូវបានចងកាតព្វកិច្ចក្នុងការរក្សានូវសិទ្ធិមនុស្សទាំងនោះ។ ដោយព្រមព្រៀងលើសិទ្ធិមនុស្សជាអន្តរជាតិ ឬ តាមរយៈការចូលជាសមាជិក UN រដ្ឋាភិបាលព្រមព្រៀងថារដ្ឋរបស់ខ្លួនមានសិទ្ធិមនុស្ស ហើយសិទ្ធិមនុស្សទាំងនេះមានមូលដ្ឋានផ្លូវច្បាប់។ មូលដ្ឋានផ្លូវច្បាប់នេះ មានសារៈសំខាន់ទាំង សម្រាប់ផ្តល់ការទទួលស្គាល់លើសិទ្ធិមនុស្ស និងព្រមទាំងសម្រាប់ការអនុវត្តនូវសិទ្ធិមនុស្សទាំងនោះ។ ដោយមានមូលដ្ឋានក្នុងច្បាប់ រដ្ឋាភិបាល និងភាគីដទៃទៀតមានកាតព្វកិច្ចតាមផ្លូវច្បាប់ក្នុងការគោរពសិទ្ធិមនុស្ស។ ជំពូកទី ៤ និងទី ៥ នឹងធ្វើការពិភាក្សាតើថាកាតព្វកិច្ចផ្លូវច្បាប់ទាំងនេះមានការវិវត្តន៍យ៉ាងដូចម្តេច ហើយតើថារដ្ឋមានកាតព្វកិច្ចយ៉ាងណា ក្នុងការអនុវត្តនូវកាតព្វកិច្ចផ្លូវច្បាប់ទាំងនេះ។

ទីពីរ សិទ្ធិមនុស្សក៏ជាសិទ្ធិសីលធម៌ផងដែរ៖ សិទ្ធិមនុស្សមានរូបរាងដោយសារសិទ្ធិមនុស្សទាំងនេះត្រូវបានចាត់ទុកថាជាសីលធម៌ ឬសមរម្យ។ យ៉ាងណាមិញ មិនមែនគ្រប់សិទ្ធិសីលធម៌ទាំងអស់ត្រូវបានផ្អែកលើច្បាប់នោះទេ មានសកម្មភាពជាច្រើនដែលត្រូវបានចាត់ទុកថាមិនមានសីលធម៌ ប៉ុន្តែមិនផ្ទុយនឹងច្បាប់នោះទេ (ជាឧទាហរណ៍ ផិតក្បត់នឹងដៃគូស្នេហារបស់ខ្លួន)។ សិទ្ធិសីលធម៌មួយចំនួនត្រូវបានការពារដោយច្បាប់ ជាឧទាហរណ៍ ការហាមឃាត់ប្រព័ន្ធផ្សព្វផ្សាយ ដែលត្រូវបានចាត់ទុកថាអាសអាភាសនៅក្នុងប្រទេសមួយចំនួន។ ប្រជាជនជារឿយៗ ទទួលស្គាល់នៅពេលដែលសិទ្ធិសីលធម៌មួយ ត្រូវបានរំលោភបំពានដោយសារនៅក្នុងសង្គមមួយមានជំនឿស្រដៀងគ្នាលើអ្វីត្រូវ ឬក៏ខុស។ ទោះបីជាសីលធម៌ជារឿយៗមានភាពជាក់លាក់តាមវប្បធម៌ ជាឧទាហរណ៍ ទស្សនៈនៃការស្លៀកពាក់លើឆ្នេរខ្សាច់ "សមរម្យ" គឺផ្អែកលើតម្លៃវប្បធម៌ ហើយដូចនេះទើបប្រទេសអាស៊ីអាគ្នេយ៍មួយចំនួន ចាត់ទុកថាសម្លៀកបំពាក់មុជទឹកខើចរបស់អឺរ៉ុបមិនសមរម្យ ជាទូទៅសង្គមភាគច្រើនចែករំលែកនូវតម្លៃសីលធម៌ស្រដៀងគ្នាពាក់ព័ន្ធនឹងថាអ្វី "សមរម្យ" និង "គួរឲ្យគោរព"។ ទោះបីជាគំនិតនៃមូលដ្ឋានសីលធម៌ដូចគ្នាជាទស្សនៈដែលចម្រូងចម្រាសមួយ វាក៏ជាផ្នែកមួយនៃមូលដ្ឋាននៃសិទ្ធិមនុស្សផងដែរ។ ទស្សនៈនៃសីលធម៌ដូចគ្នា មិនបង្កប់ន័យថាសីលធម៌មិនផ្លាស់ប្តូរនោះទេ ដូចដែលតម្លៃមនោសញ្ចេតនា អាពាហ៍ពិពាហ៍ និងផ្លូវភេទត្រូវបានផ្លាស់យ៉ាងខ្លាំងក្នុងរយៈ

ពេលប៉ុន្មានសតវត្សចុងក្រោយនេះ។ ដូចនេះការគោរពដល់ប្រជាជន ហើយនិងអ្វីដែលពួកគេធ្វើ គឺមានលក្ខណៈដូចគ្នាជាមូលដ្ឋានជុំវិញពិភពលោក ជាពិសេសសម្រាប់បញ្ហាសំខាន់ៗដូចជាសុវត្ថិភាព និងការប្រព្រឹត្តមកលើពួកគេដោយរដ្ឋាភិបាល។

## ទស្សនៈទាន

### ក្រមបដិភាព

ក្រមបដិភាពកំណត់ថា យើងគួរតែប្រព្រឹត្តលើអ្នកដទៃដូចដែលយើងចង់ឲ្យគេប្រព្រឹត្តមកលើខ្លួនយើងដែរ។ ក្រមនេះមានឫសគល់ប្រវត្តិជ្រៅជ្រះ ហើយផ្សារភ្ជាប់សតិ និងអារម្មណ៍របស់យើងជាមួយនឹងអ្នកដែលយើងមានទំនាក់ទំនងជាមួយ។ ជាឧទាហរណ៍៖

- "កុំធ្វើដាក់អ្នកដទៃនូវអ្វីដែលអ្នកមិនចង់ធ្វើលើខ្លួនឯង"។ ខុងជឺ
- "ចាត់ទុកថាការមានបានរបស់អ្នកជិតខាងយើង ជាការមានបានរបស់យើង ហើយការខាតបង់របស់អ្នកជិតខាងយើងថាជាការខាតបង់របស់យើង"។ ឡាវហ្ស៊ឺ (លទ្ធិតាវ)
- "ប្រព្រឹត្តលើអ្នកដទៃដូចដែលអ្នកប្រព្រឹត្តលើខ្លួនឯង"។ ម៉ាហាប់ហារ៉ាតា សាន់ទីបារ៉ា (ហិណ្ឌូ)
- "កុំធ្វើឲ្យអ្នកដទៃឈឺចាប់តាមវិធីដែលអ្នកខ្លួនឯងផ្ទាល់គិតថាជាការឈឺចាប់"។ អូដាណាវ៉ាហ្គា (ព្រះពុទ្ធសាសនា)
- "កុំធ្វើអំពើអ្វីដែលខ្លួនអ្នកមិនចូលចិត្តលើអ្នកដទៃ"។ តូប៊ីត (គ្រឹះសាសនា)
- "ធ្វើដាក់អ្នកដទៃដូចដែលអ្នកចង់ឲ្យអ្នកដទៃធ្វើមកលើខ្លួនអ្នក"។ ម៉ាតធ្យូ៧ ៖ ១២ (គ្រឹះសាសនា)
- "អ្នកនឹងមិនជឿនោះទេ ដរាបណាអ្នកឃើញផ្ទាល់ថាក្ដីស្រលាញ់របស់គាត់ចំពោះបងប្អូនរបស់គាត់ដូចគ្នានឹងក្ដីស្រលាញ់ចំពោះខ្លួនគាត់ផ្ទាល់"។ ហាឌីត ១៣ (អ៊ីស្លាម)
- "ស្រឡាញ់អ្នកជិតខាងដូចដែលអ្នកស្រឡាញ់ខ្លួនឯង"។ eviticus (Judaism)
- "អ្នកដែលត្រាស់ដឹងពិតប្រាកដ ជាអ្នកដែលមិនបង្កឲ្យមានការភ័យខ្លាចដល់អ្នកដទៃ និងមិនភ័យខ្លាចអ្នកដទៃ"។ វ៉ា សារាង (Sikhism)

ទីបី សិទ្ធិមនុស្សជាសិទ្ធិសង្គមដែលធានាថាប្រជាជនរស់នៅដោយសុវត្ថិភាព និងមានសុភមង្គលជាមួយគ្នានៅក្នុងសង្គម។ ជាថ្មីម្ដងទៀត មិនមែនគ្រប់សិទ្ធិសង្គមទាំងអស់ត្រូវបានការពារដោយច្បាប់នោះទេ (ហើយសិទ្ធិទាំងនេះក៏មិនចាំបាច់ជាសិទ្ធិសីលធម៌នោះទេ) ប៉ុន្តែសិទ្ធិសង្គមទាំងនេះពិតជាធានានូវដំណើរការទៅមុខដោយរលូននៃសង្គម។

ជាឧទាហរណ៍ តម្រង់ជួរនៅធនាគារ ឬឲ្យកៅអីឡានក្រុងទៅអ្នកដទៃអង្គុយមិនមែនជាសកម្មភាពដែលតម្រូវដោយច្បាប់នោះទេ ដូចនេះសិទ្ធិទាំងនេះមិនមែនជាសិទ្ធិមនុស្សនោះទេ ប៉ុន្តែប្រជាជនត្រូវបានរំពឹងថានឹងអនុវត្តតាមនិយាមដែលមិនមានការសរសេរជាលាយលក្ខអក្សរទាំងនេះដើម្បីឲ្យសង្គមមានដំណើរដោយភាពគួរសម។ សិទ្ធិសង្គមរួមមានអ្វីដែលបុគ្គលណាម្នាក់ អាចរំពឹងថានឹងទទួលបានពីរដ្ឋាភិបាល (ជាឧទាហរណ៍ ការអប់រំ និងសុខភាព) ប៉ុន្តែសិទ្ធិទាំងនេះក៏គ្រប់ដណ្តប់ផងដែរលើសេចក្តីរំពឹងទុកក្នុងការរស់នៅក្នុងសហគមន៍មួយ។ សិទ្ធិសង្គមជាគំរូនៃភាពគួរសម ការជួយគ្នាប្រកបដោយមិត្តភាព ការអត់ឱន និងសូម្បីតែភាពរីករាយ ដែលធ្វើឲ្យជីវិតកាន់តែមានភាពងាយស្រួល និងរីករាយសម្រាប់យើងទាំងអស់គ្នា។ សិទ្ធិសង្គមកំណត់ថាប្រជាជនត្រូវតែមានសុវត្ថិភាព និងសន្តិសុខ ហើយតម្រូវការរបស់ពួកគេត្រូវបានបំពេញដោយសង្គម ឬរដ្ឋ។

## ការពិភាក្សា និងការជជែកវែកញែក

### ចំណាត់ប្រភេទនៃសិទ្ធិ

១. នៅក្នុងប្រទេសរបស់អ្នក តើប្រជាជនមានកាតព្វកិច្ចក្នុងការអនុវត្តតាមសកម្មភាពដែលបញ្ជាក់ខាងក្រោមដោយសារពួកគេបានរំលោភបំពាន(ក) សិទ្ធិផ្លូវច្បាប់ (ខ) សិទ្ធិសីលធម៌ (គ) សិទ្ធិសង្គម ឬ(ឃ)សិទ្ធិចម្រុះនៃសិទ្ធិខាងលើ ដែរឬទេ?

២. តើអ្នកគិតថាចម្លើយរបស់អ្នកនឹងអនុវត្តក្នុងប្រទេសអាស៊ានដទៃទៀត បានកម្រិតណា?

៣. តើអ្នកគិតថាសកម្មភាពទាំងនេះ គួរតែត្រូវបានការពារតាមរយៈសិទ្ធិមនុស្សដែរឬទេ?

- ស្មោះត្រង់នឹងប្រពន្ធ/ប្តី
- មិនថតរូបអ្នកណាម្នាក់កំពុងស្លៀកពាក់ ក្នុងបន្ទប់ផ្លាស់ប្តូរសម្លៀកបំពាក់ដោយសម្ងាត់
- មិនខាកស្តោះផ្តេសផ្តាស
- ប្រគល់កាបូបដែលបាត់ដោយមិនបានប៉ះពាល់អ្វីទៅម្ចាស់ដើមវិញ
- ប្រាប់មិត្តភ័ក្ត្ររបស់អ្នកថាម៉ូតសក់កាត់ថ្មីដែលថ្លៃរបស់គាត់អាក្រក់មើល
- ប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ
- សុខចិត្តឈរដោយឲ្យកន្លែងដល់មនុស្សចាស់អង្គុយនៅលើឡានក្រុង
- សងប្រាក់ដែលជំពាក់ដល់មិត្តភ័ក្ត្រវិញ។

ទ្រឹស្តីមួយពីមូលដ្ឋាននៃសិទ្ធិមនុស្ស គឺថាសិទ្ធិមនុស្សត្រូវបានវិវត្តិពី "ច្បាប់ធម្មជាតិ"។ នេះមានន័យថាសិទ្ធិ និងកាតព្វកិច្ចមានលក្ខណៈជាសកល និងទូលំទូលាយដូចទៅនឹងធម្មជាតិ ហើយនិងថាភាពសមហេតុផល និងសនិទានភាពនៃច្បាប់ប្រហែលជាមានមូលដ្ឋានក្នុងធម្មជាតិរបស់មនុស្ស។ ច្បាប់ធម្មជាតិផ្តោតសំខាន់លើទស្សនៈ ដូចជាភាពថ្លៃថ្នូររបស់មនុស្ស និងសិទ្ធិជាមូលដ្ឋានដែលកើតចេញពីបទដ្ឋានសីលធម៌ដែលមានពីធម្មជាតិ (ដែលជាបទដ្ឋានសីលធម៌ដែលបុគ្គលមានតាំងពីកំណើត) ដែលមនុស្សទាំងអស់មានតាំងពីកំណើត។ ជាឧទាហរណ៍ ក្នុងទ្រឹស្តីនេះ មនុស្សមិនសម្លាប់គ្នាទៅវិញទៅមកដោយសារអំពើនេះប្រឆាំងនឹងធម្មជាតិ។ នេះជាអ្វីដែលមនុស្សមាននៅក្នុងសីលធម៌ធម្មជាតិរបស់ខ្លួន នូវជំនឿមួយដែលថាការសម្លាប់ជាអំពើអាក្រក់ ឬបំណងក្នុងការការពារខ្លួន ឬញាណដែលមានតាំងពីកំណើតថាអ្វីល្អ និងអ្វីអាក្រក់។ ដូចនេះច្បាប់ធម្មជាតិត្រូវបានចាត់ទុកថាជាកម្រងមួយនៃសិទ្ធិ និងកាតព្វកិច្ចដែលគោរព និងគាំទ្រជាចម្បងដល់ចរិកលក្ខណៈទាំងនេះរបស់ប្រជាជន។

ទស្សនៈនៃច្បាប់ធម្មជាតិមានភាពចម្រូងចម្រាស។ ជាបឋមទស្សនៈនៃអ្វីដែលត្រូវបានចាត់ថាជា "ធម្មជាតិ" ត្រូវបានផ្លាស់ប្តូរតាមពេលវេលា។ ជាឧទាហរណ៍ ការរើសអើងពូជសាសន៍ និងទាសភាពអស់រយៈយ៉ាងយូរអង្វែងមួយត្រូវបានចាត់ទុកថាសមហេតុផលដោយអ្នកសិក្សាច្បាប់ធម្មជាតិ។ តាមធម្មជាតិ ស្ត្រីត្រូវបានចាត់ទុកថាមិនស្មើនឹងបុរស ដែលជាទស្សនៈមួយត្រូវបានច្រានចោលពេលបច្ចុប្បន្ននេះ។ ប្រសិនជាទស្សនៈមួយមានការផ្លាស់ប្តូរតាមពេលវេលា ហើយមានភាពខុសគ្នាពីសង្គមមួយទៅសង្គមមួយប្រហែលជាមិនត្រូវបានចាត់ទុកថាជាទស្សនៈធម្មជាតិនោះទេ ប៉ុន្តែជាទស្សនៈសង្គមមួយ។ ទីពីរ ច្បាប់ធម្មជាតិជារឿយៗមានការពាក់ព័ន្ធនឹងគំនិតសាសនា ហើយជាពិសេសជាមួយនឹងវ៉ូមាំងកាតូលិក។ សម្រាប់ហេតុផលនេះច្បាប់របៀបនេះមិនត្រូវបានចាត់ទុកថា "ជាធម្មជាតិ" ដោយមនុស្សគ្រប់រូបនោះទេ។ សកម្មភាពរួមភេទដូចគ្នាត្រូវបានចាត់ទុកថា "មិនមែនជារឿងធម្មជាតិ" តាមច្បាប់ក្នុងសតវត្សទី១៩ ប៉ុន្តែទស្សនៈនេះត្រូវបានបដិសេធយ៉ាងទូលំទូលាយពេលបច្ចុប្បន្ននេះ។ លើសពីនេះទៀត សាសនា ឬគោលការណ៍ទស្សនៈវិជ្ជាជាក់លាក់មួយចំនួន ជារឿយៗត្រូវបានសំអាងដើម្បីជាហេតុផលបញ្ជាក់ដល់សិទ្ធិទាំងនេះ ជាឧទាហរណ៍ថាសិទ្ធិទាំងនេះ "ត្រូវបានប្រទានដោយព្រះជាម្ចាស់" ដែលនាំមានសំណួរថាតើព្រះជាម្ចាស់មួយណា ឬក៏ព្រះនីមួយៗបានកំណត់ពីតារាងនៃសិទ្ធិទាំងនេះដោយខ្លួនឯង? ដោយសារភាពខុសគ្នាបន្តិចបន្តួចនេះ ជារឿងធម្មតាដែលអ្នកស្រាវជ្រាវសិទ្ធិមនុស្ស ស្ថាប័នដូចជា UN និងសកម្មជនសិទ្ធិមនុស្សប្រកាន់យកទស្សនៈ "វិជ្ជមាន" ដែលថាសិទ្ធិមនុស្សមានទម្រង់ជាក់លាក់ និងលម្អិតមួយ៖ សិទ្ធិមនុស្សជាអ្វីដែលមានក្នុងសន្ធិសញ្ញាសិទ្ធិមនុស្ស។

ការជជែកវែកញែកលើថា សិទ្ធិមនុស្សជាអ្វី ប្រហែលជាមានទំនាក់ទំនងនឹងច្បាប់ធម្មជាតិ ជាឧទាហរណ៍ ទស្សនៈដូចជាភាពថ្លៃថ្នូរ យុត្តិធម៌ និងសមភាពត្រូវបានសន្និដ្ឋានថាជាក្ដីប្រាថ្នានៅក្នុងគ្រប់សង្គមទាំងអស់ ប៉ុន្តែសព្វថ្ងៃនេះ ទស្សនៈវិជ្ជមានផ្លូវច្បាប់ត្រូវបានលើកលែងជារឿយៗផងដែរ។ ទស្សនៈវិជ្ជមានផ្លូវច្បាប់ចាត់ទុកសិទ្ធិមនុស្សថាជារចនាបថសង្គម ដែលថាសិទ្ធិមនុស្សត្រូវបានបង្កើតឡើងដោយប្រជាជនដើម្បីផ្ដល់ដល់ប្រជាជននូវសិទ្ធិ និងកាតព្វកិច្ចជាពិសេស ។ សិទ្ធិទាំងនេះបើកចំហដល់ការធ្វើឲ្យប្រសើរឡើង កែសម្រួល និងគិតគូរសារឡើងវិញ។ ម្យ៉ាងអ្នកដែលគាំទ្រដល់ភាពវិជ្ជភាពផ្លូវច្បាប់ជ្រាបបន្ថែមទៀតថា ទាមទារឲ្យមានការព្រាងច្បាប់ដើម្បីកម្រិតអំណាចរបស់រដ្ឋ ហើយម្យ៉ាងវិញទៀតដើម្បីណែនាំដល់អំពើរបស់រដ្ឋក្នុងន័យវិជ្ជមាន។ សិទ្ធិមនុស្សជាលទ្ធផលនៃសង្គមសហសម័យ និងឆ្លុះបញ្ចាំងពីបញ្ហា និងកង្វល់នៅក្នុងសង្គមបច្ចុប្បន្ន។

## ការពិភាក្សា និងការជជែកវែកញែក

### ច្បាប់ធម្មជាតិ និងទស្សនៈវិជ្ជមានផ្លូវច្បាប់

ច្បាប់ធម្មជាតិកំណត់ថាច្បាប់ខ្លះ ឆ្លុះបញ្ចាំងពីធម្មជាតិរបស់មនុស្ស។ ចំនែកឯទស្សនៈវិជ្ជមានផ្លូវច្បាប់ចាត់ទុកថាច្បាប់មានវត្តមានដោយសារតែប្រជាជនព្រាង និងចាប់បង្ខំប្រជាជនឲ្យអនុវត្តច្បាប់ទាំងនេះ ជាឧទាហរណ៍ យើងមិនសម្លាប់គ្នាទៅវិញទៅមកពីព្រោះយើងមានច្បាប់ក្នុងការហាមឃាត់យើងមិនឲ្យធ្វើដូចនេះ។

***តើទស្សនៈណាមួយក្នុងចំណោមទស្សនៈទាំងពីរនេះមានលក្ខណៈជាក់ស្តែងពិតប្រាកដជាងគេ?***

ប្រសិនបើយើងគិតថាច្បាប់ជាទស្សនៈវិជ្ជមាន តើនេះមានន័យថាយើងធ្វើល្អដោយសារតែច្បាប់ប្រាប់យើងឲ្យធ្វើដូចនេះ? តើទស្សនៈដូចជាសមភាព និងយុត្តិធម៌ត្រូវបានបង្កើតឡើងដើម្បីរក្សាសង្គមឲ្យមានសណ្ដាប់ធ្នាប់មែនដែរឬទេ? ឬប្រសិនបើច្បាប់ត្រូវបានទាញចេញពីធម្មជាតិ ហេតុអ្វីបានជាយើងមានច្បាប់ស្ដីពីពន្ធដារ និងការបើកបរដោយសារតែសកម្មភាពទាំងនេះមិនមានកើតឡើងតាមធម្មជាតិនោះទេ?

មូលដ្ឋាននៃសិទ្ធិមនុស្សទាមទារការគាំទ្រទូលំទូលាយ ដើម្បីក្លាយទៅជាសកល ហើយមាននូវការជម្រុញចម្បងៗជាច្រើនដើម្បីសម្រេចបានលទ្ធផលនេះ។ យើងត្រូវទទួលស្គាល់ថាអស់រយៈពេលជាច្រើនឆ្នាំមកហើយ មេដឹកនាំសាសនា អ្នកទស្សនៈវិជ្ជាផ្នែកសីលធម៌ និងអ្នកច្បាប់បានជួយបង្កើតស្តង់ដារសីលធម៌។ ជាការពិតណាស់ គ្រប់វប្បធម៌ទាំងអស់មាននូវតម្លៃថាអ្វីខុស និងអ្វីត្រូវ ពាក់ព័ន្ធនឹងការប្រព្រឹត្តលើអ្នកដទៃ

មិនថាពាក់ព័ន្ធនឹងអំពើហិង្សា ទំនាក់ទំនងមិត្តភាព ភាពស្មោះត្រង់ក្នុងមុខជំនួញរបស់ខ្លួន ឬបង្ខំឲ្យអ្នកដទៃធ្វើអ្វីមួយដែលពួកគេមិនចង់ធ្វើនោះទេ។ មានកត្តាផ្សេងទៀតដែលធ្វើឲ្យស្តង់ដារទាំងនេះក្លាយទៅជាសកលៈ (១) សិទ្ធិមនុស្សត្រូវបានចែងក្នុងច្បាប់អន្តរជាតិ (២) ការចូលរួមជាសកលរបស់រដ្ឋក្នុងប្រព័ន្ធ UN ដែលចាប់បង្ខំអនុវត្តច្បាប់អន្តរជាតិ និង (៣) រដ្ឋអនុវត្តតាមស្តង់ដារសិទ្ធិមនុស្ស។ សិទ្ធិមនុស្ស និងតម្លៃដែលសិទ្ធិមនុស្សទាំងនេះទាមទារគឺកើតចេញពីកិច្ចព្រមព្រៀងអន្តរជាតិ។ ស្តង់ដារទាំងនេះមិនមែនគ្រាន់តែជាទស្សនៈរបស់ UN និងរដ្ឋាភិបាលនោះទេ ប៉ុន្តែវត្តមានរបស់ស្ថាប័ននេះ ពេលបច្ចុប្បន្ននេះ ជាលទ្ធផលនៃការខិតខំប្រឹងប្រែងអស់រយៈពេលមួយសតវត្សក្នុងការកំណត់ស្តង់ដារនៃការប្រព្រឹត្តប្រកបដោយមនុស្សធម៌ទៅលើមនុស្សជាតិ។

កត្តាចម្បងមួយ ដែលប្រែក្លាយសិទ្ធិមនុស្សពីស្ថានភាពក្នុងប្រទេសមួយទៅជាស្តង់ដារច្បាប់ជាសកល គឺជាការឆ្លើយតបនឹងភាពរន្ធត់នៃសង្គ្រាមលោកលើកទីពីរ។ អំឡុងពេលមុននេះ សិទ្ធិមានវត្តមានក្នុងប្រទេសជាច្រើន ប៉ុន្តែសិទ្ធិទាំងនេះខុសៗគ្នាយោងទៅតាមសាសនា ធម្មនុញ្ញ និងវប្បធម៌ ហើយដូចនេះមិនមានលក្ខណៈជាសកលនោះទេ។ លើសពីនេះទៀត ក្នុងករណីជាច្រើនសិទ្ធិទាំងនេះសម្រាប់ប្រជាជនជាក់លាក់មួយចំនួនប៉ុណ្ណោះមិនបានផ្តល់ជូនដល់មនុស្សគ្រប់រូបនោះទេ (ដូចនេះជារឿយៗ មិនមានការផ្តល់សិទ្ធិដល់ក្រុមជនជាតិដើមភាគតិច ជនមិនមែនជាពលរដ្ឋ ឬស្ត្រីនោះទេ) ហើយសិទ្ធិទាំងនេះក៏មិនអាចឆ្លងដែនបានដែរ (ច្បាប់សិទ្ធិនៅក្នុងប្រទេសអង់គ្លេស ឬសហរដ្ឋអាមេរិកត្រូវបានប្រើប្រាស់ក្នុងប្រទេសទាំងនេះតែប៉ុណ្ណោះ) ។ ក្នុងអំឡុងពេលសង្គ្រាមលោកលើកទីពីរ រដ្ឋាភិបាល ជាពិសេស អាឡឺម៉ង់ដែលស្ថិតក្រោមរបបសង្គមជាតិនិយម មិនអើពើលើទស្សនៈដែលថាមនុស្សគ្រប់រូបមានសិទ្ធិនោះទេ ហើយបានប្រព្រឹត្តលើក្រុមមួយចំនួន (ជីហ្វ ជីបស៊ី ក្រុមប្រឆាំងនយោបាយ និងអ្នករួមភេទដូចគ្នា) ដូចពួកគេមិនមែនជាមនុស្សនោះទេ។ សិទ្ធិរបស់ពួកគេត្រូវបានដកហូត ហើយប្រជាជនជាច្រើនលាននាក់បានបាត់បង់ជីវិត។ តាមផ្លូវច្បាប់ មិនមានអ្វីច្រើនដែលប្រទេសដទៃទៀតអាចអន្តរាគមន៍បាននោះទេ ប៉ុន្តែអ្វីដែលកាន់តែយ៉ាប់ជាងនេះទៀតនោះ គឺប្រទេសផ្សេងមិនមានឆន្ទៈក្នុងការធ្វើអន្តរាគមន៍នោះទេ។ ទោះបីនៅក្នុងរយៈពេលវែង ភាពរន្ធត់នៃហាយនភាពបានផ្តល់ការជម្រុញទឹកចិត្ត ក្នុងការធ្វើឲ្យសិទ្ធិមនុស្សចងកាតព្វកិច្ចផ្លូវច្បាប់ដល់រដ្ឋទាំងអស់ ថាជាស្តង់ដារជាសកលមួយ ដែលមានន័យថាប្រសិនបើអំពើយង់ឃ្នងដូចនេះកើតមានម្តងទៀត គឺវាជាការរំលោភបំពានច្បាប់ ហើយជាលទ្ធផលត្រូវមានការអន្តរគមន៍ពីសហគមន៍អន្តរជាតិ។

## ១.២ លក្ខណៈពិសេសជាមូលដ្ឋាន និងទស្សនៈទានក្នុងសិទ្ធិមនុស្ស

សិទ្ធិមនុស្សមានលក្ខណៈពិសេសមួយចំនួនដែលអាចញែកដាច់ពីសិទ្ធិដទៃ ហើយក៏ជាការចាំបាច់ផងដែរក្នុងការការពារ និងផ្តល់អំណាចដល់ប្រជាជន។ លក្ខណៈពិសេសផ្តល់ឋានៈពិសេសដាច់គេមួយដល់សិទ្ធិមនុស្ស ដែលញែកសិទ្ធិមនុស្សទាំងនេះដាច់ពីប្រភេទដទៃទៀតនៃសិទ្ធិ។

### ១.២.១ ភាពជាសកល

ជាទូទៅ សិទ្ធិមានដែនកំណត់តាមទីកន្លែង និងពេលវេលាដែលសិទ្ធិទាំងនេះអនុវត្ត។ យ៉ាងណាមិញសិទ្ធិមនុស្សមិនមានដែនកំណត់ទាំងនេះនោះទេ សិទ្ធិមនុស្សមានលក្ខណៈជាសកល។ អង្គហេតុតែមួយគត់គឺឋានៈជាមនុស្សនៅលើផែនដីនេះមានភាពគ្រប់គ្រាន់ក្នុងការទទួលបានសិទ្ធិមនុស្ស។ សិទ្ធិមនុស្សមិនពឹងផ្អែកលើសញ្ជាតិនោះទេ ឬដោយសារការរស់នៅលើទឹកមួយដែលទទួលស្គាល់សិទ្ធិទាំងនោះទេ។ ទាំងនេះញែកដាច់សិទ្ធិមនុស្សពីសិទ្ធិភាគច្រើនដទៃទៀត ដែលត្រូវបានកម្រិតតាមរយៈវិធីសាស្ត្រមួយចំនួន ជាឧទាហរណ៍គ្រប់អាយុក្នុងការចូលរៀនសម្រាប់សិទ្ធិរបស់សិស្ស ឬមានអាយុគ្រប់គ្រាន់សម្រាប់ពលរដ្ឋក្នុងការទទួលបានសិទ្ធិក្នុងការបោះឆ្នោត ។ **ភាពជាសកល** ធានាថាបុគ្គលនីមួយៗមានសិទ្ធិមនុស្ស ដែលតែងតែមានគ្រប់ទីកន្លែងសម្រាប់ពួកគេ។

**ភាពជាសកល**
សិទ្ធិមនុស្សជាមធ្យោបាយសកលមានន័យថាមនុស្សគ្រប់រូបមានសិទ្ធិ។ សិទ្ធិមនុស្សគួរតែមានចំពោះមនុស្សជាតិណាមួយក៏ដោយកន្លែងណាក៏ដោយ។

ទស្សនៈដែលថាសិទ្ធិមនុស្សជាសកល មិនមែនមានន័យជាចាំបាច់ថាមនុស្សគ្រប់រូបមានសិទ្ធិដូចគ្នានោះទេ។ ផ្ទុយទៅវិញ មនុស្សគ្រប់រូបមានសិទ្ធិមនុស្ស ហើយអាចទាមទារសិទ្ធិទាំងនោះបាន ប៉ុន្តែធាតុផ្សំពិតប្រាកដនៃការទាមទារនេះផ្អែកលើ (១) តើបុគ្គលនៅកន្លែងណា (២) គាត់ជាអ្នកណា (៣) តើគាត់គួរតែមានសិទ្ធិអ្វី។ ម្យ៉ាងវិញទៀតខណៈពេលដែលសិទ្ធិមនុស្សដូចគ្នាសម្រាប់មនុស្សគ្រប់រូប សិទ្ធិពិតប្រាកដដែលបុគ្គលម្នាក់ទទួលបានគឺផ្អែកលើកត្តាមួយចំនួន។

## ការពិភាក្សា និងការជជែកវែកញែក

### ភាពជាសកល

ស្ត្រីមួយរូបប្រឈមនឹងអំពើហិង្សា និងការរំលោភបំពានជាទៀងទាត់ពីប្តីរបស់គាត់ ប៉ុន្តែជារឿងរ៉ាវដែលធម្មតានៅក្នុងសង្គមគាត់ ហើយត្រូវបានចាត់ទុកថាជាផ្នែកមួយនៃវប្បធម៌។ គាត់មិនបានត្អូញត្អែរអ្វីទាំងអស់។ ក្រៅពីនេះ មិនមានអ្នកណាម្នាក់អន្តរាគមន៍នៅក្នុងសហគមន៍នោះទេ ដោយសារគ្រប់ៗគ្នាទទួលស្គាល់ថាអំពើហិង្សាជារឿងធម្មតា។ ជាវប្បធម៌ ប្រពន្ធជឿជាក់ថាប្តីត្រូវបានអនុញ្ញាតឲ្យវាយប្រពន្ធរបស់គាត់ ហើយដូចនេះគាត់មិនបានរាយការណ៍ជូនប៉ូលីសនោះទេ។
តើនេះមានន័យថាអំពើរបស់ប្តីវាយតបប្រពន្ធគួរតែត្រូវបានអនុញ្ញាតមែនដែរឬទេ?
តើនេះជាបទឧក្រិដ្ឋឬក៏អត់? តើនេះជាការរំលោភសិទ្ធិមនុស្សឬក៏អត់?

សេចក្តីសន្និដ្ឋានថាសិទ្ធិមនុស្សជាសកល មានន័យថាស្ត្រីរូបនេះមានសិទ្ធិមនុស្សទោះបីជាគាត់មិនដឹងក៏ដោយ ឬសូម្បីតែគាត់មិនយល់ស្របក៏ដោយ។ សិទ្ធិរបស់ស្ត្រីរូបនេះក្នុងការការពារខ្លួនពីអំពើហិង្សាគឺជាសកល និងមិនអាចដកហូតបាន ហើយមិនអាចប្រកែកបាន។ ហេតុផលតែមួយគត់ដែលគាត់មិនត្រូវបានការពារគឺដោយសារអ្នកផ្សេងបានប្រាប់គាត់ឲ្យទទួលយកការប្រព្រឹត្តបែបនេះ។ ទោះបីជាវាប្រហែលជាមិនមែនជាបទឧក្រិដ្ឋ ដោយសារថាគាត់មិនបានរាយការណ៍ដល់ប៉ូលីស ការរំលោភបំពាននៅតែជាការរំលោភលើសិទ្ធិរបស់គាត់។ ម្យ៉ាងវិញទៀត មិនថាគាត់ព្រមព្រៀងឬក៏អត់នោះទេ អំពើហិង្សាលើគាត់ត្រូវបានចាត់ទុកថាជាការរំលោភបំពានមួយ។

***នេះមិនមែនជាការបង្ខំអនុវត្តតម្លៃពីប្រទេសផ្សេងលើជំនឿរបស់គាត់ទេមែនទេ? តើអ្នកខាងក្រៅមានសិទ្ធិក្នុងការចូលទៅក្នុងសហគមន៍បែបនេះ ហើយប្រាប់ដល់ពួកគេថាវប្បធម៌របស់ពួកគេគឺមិនត្រឹមត្រូវ ហើយថាពួកគេត្រូវតែផ្លាស់ប្តូរនូវជំនឿរបស់ពួកគេ និងអនុវត្តដើម្បីអនុលោមតាមស្តង់ដារអន្តរជាតិដែរឬទេ?***

ប្រជាជនមួយចំនួនអះអាងថាសិទ្ធិមនុស្សចាប់បង្ខំនូវសីលធម៌ និងប្រព័ន្ធក្រមសីលធម៌បរទេសលើវប្បធម៌ដទៃ។ នេះប្រហែលជាការពិតក្នុងស្ថានភាពដែលថាទំនៀមទំលាប់សង្គមមួយដែលទទួលយកដោយប្រជាជនគ្រប់គ្នាក្នុងសង្គមនោះ អាចត្រូវបានចាត់ទុកថាជាការមិនត្រឹមត្រូវ ហើយជាការរំលោភបំពានសិទ្ធិមនុស្ស (ជាឧទាហរណ៍ក្មេងស្រីត្រូវបានហាមឃាត់មិនឲ្យទៅសាលារៀន)។ យ៉ាងណាមិញ ភាពជាសកលនៃសិទ្ធិមនុស្សអាចឈ្នះលើតម្លៃវប្បធម៌ជាក់លាក់មួយចំនួន។ មានហេតុផលសម្រាប់បញ្ជាក់

លើទស្សនៈនេះ។ ប្រសិនបើសិទ្ធិមនុស្សជាផ្នែកមួយនៃតម្លៃវប្បធម៌ មានន័យថាសិទ្ធិទាំងនេះមិនមានលក្ខណៈជាសកលនោះទេ ប៉ុន្តែជាវិធានជាក់លាក់តាមវប្បធម៌។ សិទ្ធិរបស់កុមារម្នាក់ៗមិនត្រូវបានរើសអើងក្នុងការចូលរៀន គឺមានលក្ខណៈជាសកល។ បន្ថែមពីលើនេះទៀត កិច្ចការមួយនៃសិទ្ធិមនុស្សគឺដើម្បីប្រាប់ដល់មនុស្សគ្រប់រូបពីសិទ្ធិរបស់ពួកគេ។ តម្លៃនៃវប្បធម៌មិនអាចត្រូវបានប្រើប្រាស់ដើម្បីជាលេសមួយក្នុងការមិនប្រាប់ដល់មនុស្សពីសិទ្ធិមនុស្សរបស់ពួកគេឡើយ។ ជារួម តម្លៃវប្បធម៌ភាគច្រើន គាំទ្រដល់សិទ្ធិរបស់មនុស្ស ហើយបញ្ហាចម្បងនៅទីនេះគឺនៅពេលដែលវប្បធម៌ត្រូវបានប្រើប្រាស់ជាលេសសម្រាប់ការរំលោភបំពានសិទ្ធិមនុស្ស។ នៅក្នុងករណីភាគច្រើន នៅពេលដែលប្រជាជនយល់ស្របលើការរំលោភបំពាន (ជាឧទាហរណ៍ ក្មេងស្រីម្នាក់យល់ព្រមក្នុងការមិនទៅសាលារៀន) ជារឿយៗពួកគេមិនដឹងពីសិទ្ធិរបស់ពួកគេ ហើយដូចនេះមិនបានយល់ស្របក្នុងមធ្យោបាយមួយ ដែលបានជ្រាបព័ត៌មានឲ្យបានពេញលេញនោះទេ។ ដូចនេះភាពជាសកលនៃសិទ្ធិ អនុញ្ញាតឲ្យប្រជាជន សហគមន៍ និងវប្បធម៌ក្នុងការធ្វើការសម្រេចចិត្តអំពីការអនុវត្តជាវប្បធម៌របស់ខ្លួន ក្នុងវិធីសាស្ត្រមួយដែលបានជ្រាបព័ត៌មានពេញលេញ។

## ១.២.២ ភ្ជាប់តាំងពីកំណើត

សិទ្ធិមនុស្សមានលក្ខណៈពិសេសដោយសារ សិទ្ធិទាំងនេះមានសុពលភាពនៅពេលបុគ្គលម្នាក់ៗបានកើត។ បុគ្គលមិនចាំបាច់ស្វែងរកសិទ្ធិមនុស្សនោះទេ។ ខុសគ្នាពីសិស្សនិស្សិត ឬអ្នកបើកបរ ដែលត្រូវតែប្រលងជាប់ដើម្បីបានសិទ្ធិរបស់ខ្លួន សិទ្ធិមនុស្សអាចទទួលបានដោយគ្រាន់តាមរយៈការកើតជាមនុស្សប៉ុណ្ណោះ។ ក្នុងន័យម្យ៉ាងទៀត យើងអាចនិយាយបានថាសិទ្ធិមនុស្ស ត្រូវបាន**ភ្ជាប់តាំងពីកំណើត** ដល់មនុស្សដោយមិនចាំបាច់មានគុណវុឌ្ឍិផ្សេងនោះទេ។ វាក៏មិនមែនជាការចាំបាច់នោះទេសម្រាប់ប្រជាជន ក្នុងការដឹងថាពួកគេមានសិទ្ធិមនុស្សក្នុងការមានកម្មសិទ្ធិលើសិទ្ធិទាំងនេះ សិទ្ធិទាំងនេះមានវត្តមាន សូម្បីតែបុគ្គលម្នាក់ៗមិនដឹងថាសិទ្ធិរបស់ពួកគេត្រូវបានរំលោភបំពាន។ ប្រសិនបើការដឹងលឺជាលក្ខន្តិកៈមួយសម្រាប់ការកាន់កាប់សិទ្ធិ រដ្ឋអាចជៀងវាងនូវការអនុលោមតាមដោយងាយស្រួល ដោយគ្រាន់តែតាមរយៈមិនប្រាប់ប្រជាជនពីសិទ្ធិរបស់ពួកគេ (ហើយរដ្ឋខ្លះនៅតែមានកំហុសក្នុងការធ្វើដូចនេះ)។ ការធ្វើឲ្យសិទ្ធិមនុស្សមានភ្ជាប់តាំងពីកំណើតគឺអាចជៀសវាងបញ្ហានេះបាន។

**ភ្ជាប់តាំងពីកំណើត**
ភ្ជាប់តាំងពីកំណើតសំដៅលើអ្វីដែលអចិន្ត្រៃយ៍ ឬផ្នែកដែលមិនអាចបំបែកបាននៃអ្វីមួយ។ សិទ្ធិមនុស្សភ្ជាប់តាំងពីកំណើតចំពោះមនុស្ស។ សិទ្ធិមនុស្សទាំងនេះគឺជាអចិន្ត្រៃយ៍ និងមិនអាចបំបែកបាន សិទ្ធិមនុស្សទាំងនេះតែងតែនៅជាប់ជាមួយមនុស្ស មិនខ្វល់ថាក្នុងស្ថានភាពណានោះឡើយ។

## ១.២.៤ មិនអាចដកហូតបាន

ជាករណីដែលមិនអាចកើតមាន ដែលបុគ្គលណាម្នាក់បាត់បង់សិទ្ធិមនុស្សរបស់ខ្លួន (ជាការពិតណាស់លុះត្រាណាតែពួកគេស្លាប់) ។ សិទ្ធិជាច្រើន ដូចជាសិទ្ធិក្នុងការមានទ្រព្យសម្បត្តិ ឬសិទ្ធិជាសិស្សនឹងត្រូវបញ្ចប់នៅចំនុចណាមួយ នៅពេលដែលអ្នកលក់កង់របស់អ្នក អ្នកបាត់បង់សិទ្ធិក្នុងការធ្វើជាម្ចាស់លើកង់នោះ ឬនៅពេលដែលអ្នកបញ្ចប់ការសិក្សា អ្នកលែងជាសិស្សនិស្សិតទៀតហើយ។ មនុស្សមិនអាចបាត់បង់សិទ្ធិរបស់ខ្លួនដោយសារតែខ្លួនធ្វើអ្វីមួយនោះទេ មិនពាក់ព័ន្ធថាអំពើរបស់ពួកគេសាហាវឃោរឃៅយ៉ាងណានោះទេ សូម្បីតែ ប៉ុល ពត និង អាដុល ហ៊ីត្លែរនៅតែអាចទទួលបានសិទ្ធិមនុស្សរបស់ខ្លួន។ មិនអាចទៅរួចដែលរដ្ឋមួយធ្វើការសម្រេចថាសិទ្ធិមនុស្សលែងមានទៀតហើយ ឬក្នុងការសម្រេចចិត្តថាសិទ្ធិដែលរដ្ឋទាំងនោះធ្លាប់បានទទួលស្គាល់លែងមានការពាក់ព័ន្ធទៀតហើយ។ ទោះបីជាពេលដែលរដ្ឋថ្មីមួយត្រូវបានបង្កើត ជាឧទាហរណ៍ ប្រទេសទីម័រខាងកើត បានទទួលឯករាជ្យភាពពីឥណ្ឌូនេស៊ី ជាការរំពឹងដែលថាពលរដ្ឋនឹងនៅតែរក្សានូវសិទ្ធិមនុស្សអ្វីក៏ដោយ ដែលពួកគាត់ធ្លាប់ទទួលបាននៅពេលដែលពួកគាត់ជាផ្នែកមួយនៃរដ្ឋមុន (ក្នុងករណីនេះគឺប្រទេសឥណ្ឌូនេស៊ី)។ យ៉ាងណាមិញ ជាការសំខាន់ក្នុងការចងចាំថា **ការមិនអាចដកហូតបាន** មិនមែនមានន័យថាបុគ្គលមួយរូបមិនអាចបាត់បង់សិទ្ធិរបស់ខ្លួនជារៀងរហូតបាននោះទេ ជារឿយៗសិទ្ធិមួយចំនួនដែលបុគ្គលមួយរូបទទួលបានអាចមានការផ្លាស់ប្តូរ ជាឧទាហរណ៍ នៅពេលដែលបុគ្គលមួយរូបមានអាយុ ១៨ ឆ្នាំ ពួកគេនឹងបាត់បង់សិទ្ធិកុមាររបស់ពួកគេ ហើយឋានៈរបស់ពួកគេនឹងផ្លាស់ប្តូរ។ នៅក្នុងករណីទាំងនេះ ពលរដ្ឋនៅតែរក្សានូវសិទ្ធិមនុស្សរបស់ពួកគេ ប៉ុន្តែមិនមែនសិទ្ធិរបស់ពួកគេក្នុងនាមជាកុមារនោះទេ។

**ការមិនអាចដកហូតបាន**
អ្វីដែលមិនអាចដកហូតបាន គឺមិនអាចយកចេញ បោះបង់ ឬផ្ទេរបាននោះទេ។ លើសពីនេះទៀត គឺមិនអាចត្រូវបានទិញ លក់ ឬចរចារនោះទេ។ ដូចនេះទោះបីជាត្រូវបានចាត់ទុកជាកាតព្វកិច្ចសិទ្ធិមិនអាចដកហូតបានគឺតែងតែមានវត្តមាន។

## ១.២.៥ ភាពថ្លៃថ្នូរ

មួយក្នុងចំណោមកម្មវត្ថុចម្បងៗនៃសិទ្ធិមនុស្ស គឺធានាថាមនុស្សអាចរស់នៅប្រកបដោយ**ភាពថ្លៃថ្នូរ** ដែលក្នុងន័យម្យ៉ាងទៀត គឺថាពួកគេទទួលបានការគោរព ការប្រព្រឹត្តមកលើល្អប្រសើរ ហើយនឹងមានតម្លៃ។ ប្រសិនបើបុគ្គលមួយរូបមានសិទ្ធិមនុស្សរបស់ខ្លួន បន្ទាប់មកគាត់អាចមានជីវិតប្រកបដោយភាពថ្លៃថ្នូរ។ ប្រសិនបើសិទ្ធិរបស់បុគ្គលមួយរូបត្រូវបានដកហូត បន្ទាប់មកទៀតគាត់មិនអាចទទួលបានការប្រព្រឹត្តមកលើប្រកបដោយភាពថ្លៃថ្នូរនោះទេ។

ភាពថ្លៃថ្នូរមិនមែនត្រឹមតែអំពីការធានាថាមិនមានការរំលោភច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែជាការប្រព្រឹត្តលើមនុស្សក្នុងវិធីសាស្ត្រមួយ ដែលពួកគេអាចត្រូវបានគោរពក្នុងនាមជា

**ភាពថ្លៃថ្នូរ**
សិទ្ធិមនុស្សត្រូវបានបង្កើតឡើងដើម្បីគាំទ្រ និងរក្សាភាពថ្លៃថ្នូររបស់បុគ្គល ដោយរួមមានភាពទំនុកចិត្តផ្ទាល់ខ្លួន តម្លៃផ្ទាល់ខ្លួន និងសមត្ថភាពរបស់ពួកគេក្នុងការប្រើប្រាស់ជំនាញរបស់ពួកគេ។ ភាពថ្លៃថ្នូរមានន័យថាមនុស្សមានអារម្មណ៍ថាត្រូវបានគោរព និងមានតម្លៃ។

មនុស្ស ដូចទៅនឹងមនុស្សដទៃទៀតដែរ។ ជាឧទាហរណ៍សិទ្ធិក្នុងការទទួលចំនីអាហារ មិនគ្រាន់តែជាបរិមាណដែលមាន ២២០០កាឡូរី ក្នុងមួយថ្ងៃនោះទេ។ ចំនួននៃកាឡូរី មានន័យតិចតួចបំផុត ប្រសិនបើបុគ្គលមួយរូបត្រូវបានបង្ខំឲ្យបរិភោគលើកម្រាលឥដ្ឋ ឬប្រសិនបើជនជាតិម៉ូស្លីមត្រូវបានផ្តល់អាហារសាច់ជ្រូករៀងរាល់ពេល។ តម្លៃនៃជីវជាតិមួយមុខមិនធានានូវភាពថ្លៃថ្នូរនោះទេ។ ភាពថ្លៃថ្នូរមានន័យថាបុគ្គលរូបនោះអាចញ៉ាំអាហារដូចមនុស្សដែលមានភាពថ្លៃថ្នូរ ហើយនេះតាមរយៈការគោរពតម្លៃសង្គម និងវប្បធម៌ពាក់ព័ន្ធនឹងចំណីអាហារ ដូចជាការញ៉ាំអាហារជាមួយមិត្តភ័ក្ត្រ និងក្រុមគ្រួសារតាមអ្វីដែលត្រូវបានចាត់ទុកថាជាវិធីធម្មតា។

## ១.២.៦ សមតាព

**សមភាព**
នៅក្នុងសង្គម មនុស្សទាំងអស់គួរតែត្រូវបានប្រព្រឹត្តមកលើដូចៗគ្នាជាពិសេសពាក់ព័ន្ធនឹងសិទ្ធិរបស់ពួកគេ។ ស្មើគ្នាមានន័យថាមនុស្សទាំងអស់មិនត្រូវបានប្រព្រឹត្តមកលើខុសៗគ្នាដោយសារតែភេទ ទ្រព្យសម្បត្តិ ភាសា និងទស្សនៈនយោបាយរបស់ពួកគេនោះទេ។ល។ ខណៈពេលដែលមានករណីពិសេសខ្លះចំពោះការប្រព្រឹត្តមកលើខុសគ្នា (ដូចជាអាហាររូបករណ៍ពិសេស ដូចនេះកុមារក្រីក្រអាចទៅសាលារៀនបាន) ការប្រព្រឹត្តទាំងនេះគួរតែត្រូវបានប្រើប្រាស់ដើម្បីបង្កើនកម្រិតនៃភាពស្មើគ្នានៅក្នុងសង្គមប៉ុណ្ណោះ។

សិទ្ធិមនុស្សមានវត្តមានដើម្បីធានានូវ**សមភាព**។ ជាការពិតណាស់ ទស្សនៈនេះត្រូវបានបញ្ជាក់ក្នុងរាល់ឯកសារសិទ្ធិមនុស្សទាំងអស់ ដោយសង្កត់បញ្ជាក់ពីការទទួលបាននូវសិទ្ធិដោយស្មើភាពដោយគ្មានការរើសអើង។ មាត្រា ១ នៃ UDHR ចែងថា ″ មនុស្សទាំងអស់កើតមកមានសេរីភាព និងសមភាពក្នុងផ្នែកសេចក្តីថ្លៃថ្នូរ និងសិទ្ធិ ″។ ប្រៀបធៀបឧប្បញ្ញត្តិនេះ ទៅនឹងបុព្វកថានៃសេចក្តីប្រកាសឯករាជ្យរបស់សហរដ្ឋអាមេរិក ដែលបានចែងថា (១៧៧៦) ៖ "យើងទាំងអស់គ្នាទទួលយកការពិតដែលថាមនុស្ស (men) ទាំងអស់មានភាពស្មើគ្នា″ ឬទៅនឹងមាត្រា ១ នៃសេចក្តីប្រកាសសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋរបស់ប្រទេសបារាំង(១៧៨៩)៖ "មនុស្ស (men) កើតមកមានសិទ្ធិនិង សេរីភាពស្មើគ្នា។″

ជាការពិតណាស់ឯកសារនីមួយៗនៃឯកសារទាំងនេះ គាំទ្រលើទស្សនៈដែលថាសិទ្ធិមនុស្សត្រូវបានភ្ជាប់តាំងពីកំណើត (មានន័យថាមនុស្សកើតមកត្រូវភ្ជាប់ជាមួយនឹងសិទ្ធិមនុស្ស) ដែលផ្តល់នូវសេរីភាព និងភាពស្មើភាពតាំងពីកំណើតដល់ពួកគេ។ ប៉ុន្តែសមភាពពិតប្រាកដគឺពិបាកក្នុងការទទួលបាន។ ជាការសំខាន់ក្នុងការចងចាំថាភាសាយែនឌ័រនៃខ្លឹមសារសិទ្ធិមនុស្សកាលពីជំនាន់មុនបង្ហាញថា សមភាពពិតប្រាកដរវាងភេទមិនទាន់សម្រេចបាននូវឡើយទេ បុរសគឺស្មើភាពគ្នាជាមួយនឹងបុរសដទៃទៀត ប៉ុន្តែត្រូវការពេលវេលាមួយចំនួន មុនពេលដែលស្ត្រីត្រូវបានចាត់ថាស្មើគ្នានឹងបុរស។ ស្រដៀងគ្នានេះផងដែរ ប្រជាជនដែលស្ថិតក្រោមអាណានិគមនឹងតស៊ូដើម្បីសមភាពរបស់ខ្លួនក្នុងអំឡុងសតវត្សទី ២០។

សមភាពធានាថាមនុស្សទទួលបានការប្រព្រឹត្តមកលើដូចគ្នា មិនថានៅចំពោះមុខច្បាប់ នៅកន្លែងការងារ ឬក្នុងការរៀបអាពាហ៍ពិពាហ៍នោះទេ។ យ៉ាងណាមិញមិនមានសង្គមណាមួយដែលមានភាពស្មើគ្នាទាំងស្រុងគ្រប់រូបភាពនោះទេ។ ជាឧទាហរណ៍

មិនមែនមនុស្សគ្រប់រូបមានលទ្ធភាពក្នុងការទទួលបានការសិក្សា ថ្នាក់សកលវិទ្យាល័យនោះទេ។ ទោះបីជាការអប់រំថ្នាក់ខ្ពស់ជាសិទ្ធិមនុស្សមួយក៏ដោយ គឺវាទាមទារនូវលក្ខខណ្ឌមួយចំនួន ជាឧទាហរណ៍ត្រូវប្រលងជាប់ មានសញ្ញាប័ត្រវិទ្យាល័យ មានចំនេះដឹងផ្នែកភាសា ជារឿយៗត្រូវបានតម្រូវមុនពេលទទួលឲ្យចូលរៀន។ ជាជាងលទ្ធភាពដែលស្មើគ្នា ជាលក្ខខណ្ឌយុត្តិធម៌មួយដែលការទទួលឲ្យចូលរៀនរបស់សាកលវិទ្យាល័យត្រូវបានពឹងផ្អែកលើការមិនរើសអើង។ ការរើសអើងសំដៅលើស្ថានភាពដែលជនណាម្នាក់ទទួលបានការប្រព្រឹត្តខុសពីគេ ត្រូវបានពិន័យ ឬដាក់ទណ្ឌកម្មដោយសារតែលក្ខណៈដាច់ដោយឡែករបស់ពួកគេ។ ទម្រង់ដែលទូទៅ និងច្បាស់លាស់មួយគឺជាការរើសអើងលើស្ត្រីភេទ។ នៅក្នុងសង្គមជាច្រើន មានជំនឿថាស្ត្រីមិនខ្លាំងក្លា ឬមានសមត្ថភាពដូចទៅនឹងបុរសនោះទេ ហើយដូចនេះមិនសាកសមក្នុងការទទួលបានប្រាក់កម្រៃស្មើគ្នានោះទេ។ ទម្រង់ទូទៅមួយទៀតនៃការរើសអើងរួមមានពូជសាសន៍ សាសនា ជនជាតិភាគតិច ឬជនមិនមែនជាពលរដ្ឋ។

# ១.៣ ច្បាប់សិទ្ធិមនុស្ស៖ សិទ្ធិ និងកាតព្វកិច្ច

អំណាចនៃសិទ្ធិមនុស្សកើតចេញពីអង្គហេតុដែលត្រូវបានគាំទ្រដោយច្បាប់។ ទស្សនៈដែលថាសិទ្ធិមនុស្សមានលក្ខណៈជាសកល និងមានសីលធម៌ល្អ មិនគ្រប់គ្រាន់ក្នុងការចាប់បង្ខំសិទ្ធិមនុស្សទាំងនេះនោះទេ។ សិទ្ធិជាច្រើនពឹងផ្អែកតែលើតម្លៃសង្គមដើម្បីចាប់បង្ខំអនុវត្តសិទ្ធិទាំងនេះ ៖ ការមិនរំលងជួររងចាំនៅធនាគារត្រូវបានចាប់បង្ខំដោយការខឹងសម្បាររបស់អតិថិជនដទៃ។ នេះមិនមែនជាវិធីសាស្ត្រដែលមានប្រសិទ្ធិភាពបំផុតក្នុងការចាប់បង្ខំអនុវត្តសិទ្ធិមួយនោះទេ ។ ម្យ៉ាងវិញទៀត សិទ្ធិមនុស្ស ត្រូវបានដឹងថាជាច្បាប់ដែលត្រូវបានការពារដោយស្ថាប័នអនុវត្តច្បាប់ ហើយនេះជាឋានៈដែលបង្ការប្រជាជន និងស្ថាប័នពីការរំលោភបំពានលើសិទ្ធិទាំងនេះ។ ផ្នែកខាងក្រោមនេះនឹងបញ្ជាក់ពិស្តារពីលក្ខណៈចម្បងដែលសិទ្ធិមនុស្សត្រូវបានចាត់ទុកថាជាច្បាប់។

## ១.៣.១ នីតិរដ្ឋ

សិទ្ធិមនុស្សជាសិទ្ធិផ្លូវច្បាប់ ដោយសារសិទ្ធិមនុស្សត្រូវបានចងកាតព្វកិច្ចដោយច្បាប់ ប៉ុន្តែសិទ្ធិមនុស្សក៏ធានាផងដែរថាមានប្រព័ន្ធច្បាប់ដែលមានយុត្តិធម៌ នឹងមានដំណើរការមួយ។ វត្តមាននៃប្រព័ន្ធច្បាប់ដែលមានយុត្តិធម៌មួយអាចកើតមាន លុះត្រាតែសង្គមត្រូវពឹងផ្អែកលើទស្សនៈនៃនីតិរដ្ឋ។ ក្នុងគោលបំណងចាប់បង្ខំអនុវត្តសិទ្ធិមនុស្សគួរតែមានប្រព័ន្ធដែលអនុញ្ញាតឲ្យមនុស្ស ស្វែងរកយុត្តធម៌។ រចនាបថចម្បងពីខាង

ក្រោយនីតិរដ្ឋត្រូវបានសង្ខេបក្នុងឧទាហរណ៍ខាងក្រោម៖ សាកគិតមើលនៅពេលដែលអ្នកកំពុងលេងហ្គេមមួយដូចជាអុកជាមួយនឹងអ្នកណាម្នាក់ ប៉ុន្តែអ្នកមិនដឹងពីក្បួននៃការលេងនោះទេ ប៉ុន្តែភាគីម្ខាងទៀតដឹង។ អ្នកបានដើរកូនអុក ហើយគេបានស៊ីកូនអុកនោះ ប៉ុន្តែនៅពេលដែលអ្នកព្យាយាមដើរដូចគេ គេអះអាងថាខុសនឹងក្បួននៃការលេង។ វាមិនសមហេតុផលនោះទេដែលការដើររបស់គេត្រូវទាំងអស់ ហើយការដើររបស់អ្នកត្រូវបានគេពិន័យដោយវិធីផ្សេងៗ ហើយនៅពេលដែលអ្នកសួរពីក្បួននៃការលេង គេបដិសេធក្នុងការពន្យល់ពីក្បួន។ ជាការពិតណាស់យើងមិនអាចឈ្នះក្នុងស្ថានភាពនេះបាននោះទេពីព្រោះវាមិនមាននីតិរដ្ឋនោះទេ។ នៅពេលដែលគូភាគីរបស់អ្នកត្រូវបានអនុញ្ញាតឲ្យផ្លាស់ប្តូរក្បួនលេងដូចនេះ គេអាចដើរបានស្រេចតែចិត្ត ដូចនេះអ្នកនឹងមិនអាចឈ្នះបាននោះទេ។

គួរឲ្យស្តាយ សង្គមមួយចំនួនមានមុខងារដូចនេះ៖ ជាឧទាហរណ៍ក្នុងប្រទេសមួយចំនួន ប៉ូលីសអាចចាប់ខ្លួនអ្នកដំណើរដោយមិនហេតុផលបញ្ជាក់ច្បាស់លាស់ ឧក្រិដ្ឋជនដែលបានកាត់ទោសអាចទទួលទណ្ឌកម្មខុសគ្នាខ្លាំងមែនទែន សម្រាប់បទឧក្រិដ្ឋដែលស្រដៀងគ្នា អ្នកមានអាចរួចផុតពីទណ្ឌកម្មពីការប្រព្រឹត្តបទល្មើសមួយ ស្ថាប័នមួយចំនួនអាចប្រជុំជាសាធារណៈ ខណៈពេលដែលស្ថាប័នដទៃទៀតមិនអាច។

ការរស់នៅក្នុងសង្គមមួយដែលពឹងផ្អែកលើនីតិរដ្ឋមានន័យថា៖

- មនុស្សគ្រប់រូបនឹងត្រូវបានវិនិច្ឆ័យ និងការពារដោយច្បាប់ដូចគ្នា។
- មនុស្សគ្រប់រូបមានភាពស្មើគ្នាចំពោះមុខច្បាប់។
- មនុស្សគ្រប់រូបនឹងទទួលបានការការពារដូចគ្នាចំពោះមុខច្បាប់។
- បទដ្ឋាននៃច្បាប់ជាចំនេះដឹងជាសាធារណៈដោយមិនមានដោយគ្មានការយល់ដឹង "ជាសំងាត់" ដោយប្រជាជនមួយក្រុមតូចប៉ុណ្ណោះទេ។
- បុគ្គលគ្រប់រូបមានសិទ្ធិក្នុងការស្វែងរកជំនួយដើម្បីស្វែងយល់ពីច្បាប់។

នីតិរដ្ឋធានានូវប្រព័ន្ធយុត្តិធម៌មួយដែលការពារប្រជាជន និងទ្រព្យសម្បត្តិរបស់ពួកគេនឹងរក្សាសុវត្ថិភាពជូនពួកគេ។ ធាតុសំខាន់នៃនីតិរដ្ឋគឺថាមនុស្សគ្រប់រូបមានភាពស្មើគ្នាចំពោះមុខច្បាប់ ហើយគ្មាននរណាម្នាក់អាចគេចផុតពីសំណាញ់ច្បាប់នោះឡើយ។ យ៉ាងណាមិញ នៅក្នុងករណីមួយចំនួន ប្រជាជនខ្លះអាចគេចផុតពីទណ្ឌកម្មច្បាប់ ជាឧទាហរណ៍ដូចជាអ្នកមានទ្រព្យសម្បត្តិ អ្នកនយោបាយ និងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់អាចគេចផុតពីបទឧក្រិដ្ឋ ឬ អំពើពុករលួយ។ ច្បាប់មិនគួរតែមានវត្តមានសម្រាប់តែការពារ ឬផ្តល់ផលប្រយោជន៍ដល់ប្រជាជនមួយក្រុមតូចនោះទេ។

ភាពស្មើគ្នាចំពោះមុខច្បាប់ មានន័យថាជាការទទួលបានការពារស្មើគ្នាចំពោះមុខច្បាប់ផងដែរ។ គួរឲ្យស្ដាយ មានប្រជាជនជាច្រើនមិនត្រឹមតែមិនទទួលបានការពារដោយប៉ូលីសប៉ុណ្ណោះទេ ប៉ុន្តែក្នុងករណីមួយចំនួនទទួលរងនូវការរំលោភបំពាន និងជាជនរងគ្រោះនៃអំពើរំលោភបំពានទាំងនេះ ដូចជាពលករទេសន្តប្រវេសន៍ ឬស្ត្រីដែលបានរាយការណ៍ពីអំពើហិង្សាក្នុងគ្រួសារ។ នៅក្នុងប្រទេសមួយចំនួន ប្រសិនគ្រូវាយកូនសិស្សក្មេងម្នាក់ នេះមិនមែនជាអំពើខុសច្បាប់នោះទេ ហើយសិស្សមិនត្រូវបានការពារពីហិង្សារបៀបនេះនោះទេ។ យ៉ាងណាមិញ នៅក្នុងប្រទេសអាស៊ីអាគ្នេយ៍ទាំងអស់ ប្រសិនបើសិស្សវាយគ្រូ អំពើនេះត្រូវបានចាត់ទុកថាជាបទឧក្រិដ្ឋមួយ ហើយប៉ូលីសនឹងការពារគ្រូបង្រៀន។ ហាក់បីដូចជាអយុត្តិធម៌ដោយសារពេលគ្រូវាយសិស្ស ប៉ូលីសនៅស្ងៀម ប៉ុន្តែប្រសិនសិស្សវាយគ្រូ សិស្សនោះនឹងត្រូវទទួលទណ្ឌកម្មតាមផ្លូវច្បាប់។ ក្នុងស្ថានភាពនេះ ច្បាប់មិនបានការពារសិស្សដោយស្មើភាពនោះទេ ដោយសារច្បាប់ការពារតែគ្រូ។ ការប្រព្រឹត្តខុសគ្នានេះគឺមិនយុត្តិធម៌នោះទេ ដោយសារច្បាប់គួរតែការពារទាំងសិស្ស និងគ្រូដោយស្មើភាពគ្នា។

លក្ខណៈពិសេសដទៃទៀតនៃនីតិរដ្ឋ គឺថាប្រជាជនទាំងអស់គួរតែមានលទ្ធភាពក្នុងការទទួលបានប្រព័ន្ធសេវាច្បាប់ ហើយត្រូវមានការយល់ដឹងពីដំណើរការនៃប្រព័ន្ធសេវាទាំងនេះ និងយល់ដឹងថាអ្វីខ្លះដែលប្រព័ន្ធនេះអាច និងមិនអាចធ្វើបាន។ នេះអាចត្រូវបានសម្រេចបានតាមរយៈជំនួយផ្លូវច្បាប់ ឬធ្វើការធានាថាមានព័ត៌មានអាចទទួលយកបានដោយមិនចាំបាច់បង់ថ្លៃ។ យ៉ាងណាមិញ ប្រទេសមួយចំនួនមានចេតនាក្នុងការបង្កើតច្បាប់ដែលមិនច្បាស់លាស់ ដែលរដ្ឋាភិបាលអាចប្រើប្រាស់ដើម្បីជាប្រយោជន៍ខ្លួន។ ច្បាប់ដែលចែងពីអំពើក្បត់ជាតិ ការជេរប្រមាថថ្នាក់ដឹកនាំ និងអំពើអាសអាភាសមិនមានភាពច្បាស់លាស់នោះទេ ដែលធ្វើឲ្យមានភាពមិនប្រាកដប្រជា ដែលអាចក្នុងករណីខ្លះធ្វើឲ្យមានការចាប់បង្ខំអនុវត្ត លើអំពើដែលត្រូវបានជ្រើសរើសតែប៉ុណ្ណោះ។ ជាឧទាហរណ៍ ទស្សនៈនៃសកម្មភាព ʹប្រឆាំងរដ្ឋាភិបាលʹ មានភាពខុសៗគ្នាយ៉ាងខ្លាំងនៅអាស៊ីអាគ្នេយ៍។ នៅកន្លែងខ្លះ សូម្បីតែមានឯកសារ ʹខុសច្បាប់ʹ តាមខ្លួនក៏ជាការប្រឆាំងរដ្ឋាភិបាល (ជាឧទាហរណ៍ស្នាដៃនិពន្ធរបស់ កាល ម៉ាក់ ឬសន្ធិសញ្ញាសិទ្ធិមនុស្ស) នៅកន្លែងខ្លះទៀតអាចជាសកម្មភាពធ្វើការដង្ហែរក្បួនតវ៉ាប្រឆាំង។ ទាំងពីរនេះជាឧទាហរណ៍នៃស្ថានភាពដែលនីតិរដ្ឋ មិនត្រូវបានអនុវត្តដោយស្មើភាពគ្នាដោយរដ្ឋាភិបាលនោះទេ។

# ការពិភាក្សា និងការជជែកវែកញែក

តើអ្នករស់នៅក្នុងរដ្ឋដែលមានការគោរពនីតិរដ្ឋមែនដែរឬទេ?

*តើមានសញ្ញាណអ្វីខ្លះដែលបញ្ជាក់ថានីតិរដ្ឋមិនត្រូវបានគោរព?*
*តើអ្នកណាជាអ្នករងគ្រោះនៅពេលដែលនីតិរដ្ឋមិនត្រូវបានគោរព?*

ប្រទេសនៅអាស៊ីអាគ្នេយ៍ជាច្រើនរងគ្រោះដោយសារកង្វះខាតនូវនីតិរដ្ឋ។ អ្នកមាន ឬអ្នកនយោបាយជារឿយៗគេចចេញពីសំណាញ់ច្បាប់ ខណៈពេលដែលអ្នកក្រីក្រទទួលរងនូវទណ្ឌកម្មធ្ងន់ធ្ងរតាមផ្លូវច្បាប់។ ជាឧទាហរណ៍ ប៉ូលីសមួយរូបដែលត្រូវបានជាប់ទោសពីបទចាប់ពង្រត់មេធាវីនៅប្រទេសថៃ ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារចំនួន១៨ ខែ ខណៈពេលដែលជនស៊ីវិលដែលជាប់ទោសស្រដៀងគ្នានេះ ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគាររហូតដល់ ២០ឆ្នាំ។ ស្រដៀងគ្នានេះផងដែរ កូនប្រុសរបស់អ្នកនយោបាយ ដែលពាក់ព័ន្ធនឹងការវាយតបពេលស្រវឹងអាចគេចផុតពីទោសទណ្ឌ ដូចគ្នានឹងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ដែលបានលួចលុយ បៀតបៀនស្ត្រី ឬវាយតបសហជីវិកជាទៀងទាត់ គឺរួចផុតពីការកាត់ទោស។

ប្រជាជនជាច្រើនបន្ទោសការមិនអនុវត្តនីតិរដ្ឋលើប៉ូលីស ឬអ្នកនយោបាយ ប៉ុន្តែអ្នកផ្សេងទៀតត្រូវទទួលការស្តីបន្ទោសផងដែរ។ ជាឧទាហរណ៍ អ្នកបើកបរស្លូកប៉ាន់ប៉ូលីសដើម្បីរួចផុតពីការផាកពិន័យច្រើន អាណាព្យាបាលបង់លុយថ្លៃចុះឈ្មោះកូនឲ្យចូលរៀន បុគ្គលមួយរូបបង់ថ្លៃសេវាដល់រដ្ឋាភិបាល ដើម្បីទទួលបានការអនុញ្ញាតក្នុងការបើកតូបលក់ចំនីអាហារលើផ្លូវថ្នល់ ទោះបីជាការអនុញ្ញាតបែបនេះជាការខុសច្បាប់ក៏ដោយ។

***អ្នកណាជាអ្នកមានកំហុសនៅពេលដែលប្រជាជនគេចពីនីតិរដ្ឋដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនដោយការស្លូកប៉ាន់?*** តើសង្គមធ្វើដូចនេះដោយសាររដ្ឋាភិបាលមិនមានភាពតឹងរឹងក្នុងការអនុវត្តនីតិរដ្ឋ ឬដោយសារតែបុគ្គលមិនចង់អនុវត្តច្បាប់?

## ១.៣.២ កាតព្វកិច្ចសិទ្ធិមនុស្ស

គ្រប់សិទ្ធិមនុស្សទាំងអស់តែងតែមានភាគីទីពីរ (ជាអ្នកដែលមានកាតព្វកិច្ច) ដែលមានកាតព្វកិច្ចក្នុងការធានាថាសិទ្ធិត្រូវបានគោរព អ្នកដែលមានកាតព្វកិច្ច គឺត្រូវមានការទទួលខុសត្រូវ និងកាតព្វកិច្ចចំពោះអ្នកដែលកាន់កាប់សិទ្ធិ។ អ្នកមានកាតព្វកិច្ចមានដូចជារដ្ឋាភិបាល ប្រជាជន សាជីវកម្ម សាកលវិទ្យាល័យ មន្ទីរពេទ្យ ។ល។ អ្នកមានកាតព្វកិច្ច និងអ្នកកាន់កាប់សិទ្ធិគឺមានទំនាក់ទំនងគ្នាមួយ ចំពោះសកម្មភាពក្នុងការទាមទារសិទ្ធិអំពាវនាវដល់អ្នកមានកាតព្វកិច្ច ក្នុងការចាត់វិធានការតាមវិធីសាស្រ្តណាមួយ។

ជាការសំខាន់ដែលបុគ្គលផ្ទាល់យល់ដឹងពីតួនាទីរបស់ខ្លួន ក្នុងនាមជាអ្នកមានកាតព្វកិច្ច អាណាព្យាបាលមានកាតព្វកិច្ចចំពោះកូន គ្រូបង្រៀនមានកាតព្វកិច្ចចំពោះកូនសិស្ស ហើយមិត្តភ័ក្រ្តមានកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមក។ កាតព្វកិច្ចភាគច្រើនគ្រាន់តែមានលក្ខណៈជាសង្គម និងសីលធម៌ប៉ុណ្ណោះ ដូចដែលបានពិភាក្សាខាងលើ។ យ៉ាងណាមិញ កាតព្វកិច្ចសំខាន់ ជាពិសេសកាតព្វកិច្ចសិទ្ធិមនុស្សរបស់បុគ្គលត្រូវបានចែងច្បាស់ក្នុងច្បាប់ព្រហ្មទណ្ឌ។ ប្រសិនបើបុគ្គលមួយរូបរំលោភបំពានសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ សិទ្ធិក្នុងការគោរពសាសនា សិទ្ធឯកជន ឬសេរីភាពក្នុងការដើរហើររបស់អ្នកដទៃ អ្នកមានកាតព្វកិច្ចគឺកំពុងតែប្រព្រឹត្តបទឧក្រិដ្ឋ។ ជាក់ស្តែង កាតព្វកិច្ចសិទ្ធិមនុស្សទាំងនេះត្រូវបានចាប់បង្ខំអនុវត្តតឹងរឹងរួចមកហើយ។ តួនាទីរបស់អ្នកមានកាតព្វកិច្ចអាចត្រូវបានចែងមិនច្បាស់ចំពោះក្រុមផ្សេង (ជាឧទាហរណ៍ក្រុមហ៊ុន ក្រុមប្រដាប់អាវុធ ឬសាសនា)។ ប្រសិនបើក្រុមហ៊ុនមួយមិនអនុញ្ញាតឲ្យបុគ្គលិករបស់ខ្លួនក្នុងការដើរហើរដោយសេរី ឬប្រសិនបើក្រុមប្រដាប់អាវុធជ្រើសរើសកុមារឲ្យធ្វើទាហាន ក្នុងករណីខ្លះការរំលោភបំពានទាំងនេះអាចប្រឈមនឹងទណ្ឌកម្ម។ បញ្ហានៃការការពារប្រជាជន ពីការរំលោភបំពានដោយអ្នកមានកាតព្វកិច្ចទាំងនេះ ត្រូវបានពិភាក្សាក្នុងទស្សនៈនៃការការពារតាមខ្សែឈរ (ដោយផ្ទាល់) ដូចដែលនឹងត្រូវបានពិភាក្សាខាងក្រោម។

អ្នកដែលមានកាតព្វកិច្ចសំខាន់បំផុតគឺរដ្ឋ ដែលជាស្ថាប័នចងកាតព្វកិច្ចផ្លូវច្បាប់ក្នុងការគោរពសិទ្ធិមនុស្សតាមរយៈសន្ធិសញ្ញា។ កាតព្វកិច្ចរបស់រដ្ឋត្រូវបានចែងនៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សផ្សេងៗ។ មានន័យថារដ្ឋត្រូវសង្កត់បញ្ជាក់ពីកាតព្វកិច្ចបុគ្គលចំពោះសង្គមដូចដែលបានចែងយ៉ាងច្បាស់ ក្នុងសេចក្តីប្រកាសពីសិទ្ធិមនុស្សថ្មីរបស់អាស៊ាន។ នេះអះអាងថាសិទ្ធិមនុស្ស "ត្រូវតែមានតុល្យភាពជាមួយនឹងការអនុវត្តកាតព្វកិច្ចដែលជាការឆ្លើយតប ដូចដែលបុគ្គលគ្រប់រូបមានការទទួលខុសត្រូវចំពោះបុគ្គលដទៃទៀតទាំងអស់ សហគមន៍ និងចំពោះសង្គមដែលពួកគេរស់នៅ។" សេចក្តីប្រកាសបានសង្កត់បញ្ជាក់ថាសិទ្ធិមនុស្សមិនត្រឹមតែត្រូវបានចាត់ទុកថាជាសេរីភាពនោះទេ ប៉ុន្តែជា

កាតព្វកិច្ចផងដែរ។ ទោះបីជាមានមូលដ្ឋានមួយចំពោះការអះអាងបែបនេះ ជាការរំពឹងទុកដែលថាមនុស្សនឹងប្រព្រឹត្តដាក់គ្នាទៅវិញទៅមក ក្នុងវិធីសាស្ត្រមួយ ដែលមិនរំលោភសិទ្ធិរបស់ពួកគេ សិទ្ធិមនុស្សជាចម្បងគឺជាការធានាថា រដ្ឋាភិបាលបំពេញនូវកាតព្វកិច្ចរបស់ខ្លួន។ កាតព្វកិច្ចរបស់បុគ្គល ត្រូវបានចែងច្បាស់លាស់ក្នុងច្បាប់ជាតិរបស់ប្រទេសមួយ ហើយការសង្កត់បញ្ជាក់លើកាតព្វកិច្ច របស់រដ្ឋ និងអ្នកកាន់អំណាចធំៗផ្សេងទៀតអាចមានភាពមិនច្បាស់លាស់ ដែលបង្កជាបញ្ហាចម្បងពាក់ព័ន្ធក្នុងការប្រកែកមិនអនុវត្តកាតព្វកិច្ចសិទ្ធិមនុស្ស។

ចរិកលក្ខណៈចងកាតព្វកិច្ចផ្លូវច្បាប់នៃសិទ្ធិមនុស្សជាទូទៅ ចាត់ទុករដ្ឋថាជាអ្នកដែលមានកាតព្វកិច្ចក្នុងការឆ្លើយតប។ កាតព្វកិច្ចអាចត្រូវបានកំណត់តាមវិធីសាស្ត្រពីរយ៉ាង។ ទីមួយ សិទ្ធិជាច្រើនទាមទារឲ្យបុគ្គល ឬស្ថាប័នផ្តល់ទំនិញ សេវាកម្ម ឬធ្វើសកម្មភាពផ្សេងៗ។ ជាឧទាហរណ៍នៃនិយមន័យនេះដូចជា ធ្វើសាលារៀន និងមន្ទីរពេទ្យដូចនេះ កុមារអាចទទួលបានសិទ្ធិអប់រំ និងសិទ្ធិទទួលបានសេវាសុខភាពរបស់ពួកគេ។ ដែលនេះជាកាតព្វកិច្ចវិជ្ជមាន៖ ដែលជាកាតព្វកិច្ចមួយតម្រូវឲ្យធ្វើអ្វីម្យ៉ាង។ ទីពីរ កាតព្វកិច្ចអាចមានន័យជាសាមញ្ញថាមិនធ្វើអន្តរាគមន៍ ឬធ្វើការធានាថាបុគ្គលរួចផុតពីអ្វីមួយ ជាឧទាហរណ៍ មានសិទ្ធិក្នុងការរួចផុតពីទារុណកម្ម ឬក៏និយាយដោយសេរីដោយមិនមានការអន្តរាគមន៍ពីរដ្ឋាភិបាល ដែលទាមទារឲ្យរដ្ឋមិនអនុវត្តអំពើណាមួយជាក់លាក់។ ដែលនេះត្រូវបានហៅថា**កាតព្វកិច្ចអវិជ្ជមាន**។ កាតព្វកិច្ចអវិជ្ជមានកម្រិតអំណាច និងសកម្មភាពរបស់រដ្ឋ និងស្នើឲ្យរដ្ឋនៅស្ងៀមនៅពេលដែល ជាឧទាហរណ៍ អ្នកណាម្នាក់ចង់សំដែងមតិ ឬជំនឿសាសនារបស់ពួកគេ។

**កាតព្វកិច្ចអវិជ្ជមាន**

កាតព្វកិច្ចអវិជ្ជមានតម្រូវឲ្យភាគីបញ្ឈប់សកម្មភាព ឬមិនជ្រៀតជ្រែកជាមួយនឹងអ្នកណាម្នាក់។ កាតព្វកិច្ចអវិជ្ជមានបញ្ឈប់ភាគីពីការធ្វើអ្វីមួយ។

យ៉ាងណាមិញ ជាការសំខាន់ក្នុងការមិនធ្វើឲ្យសិទ្ធិទាំងអស់ទៅជាសិទ្ធិវិជ្ជមាន ឬអវិជ្ជមាន ដូចនេះសិទ្ធិទាំងអស់មានភាពចម្រុះនៃកាតព្វកិច្ចទាំងវិជ្ជមាន និងអវិជ្ជមាន។ ជាឧទាហរណ៍ សេរីភាពនៃការដើរហើរទាមទារឲ្យមាននូវកាតព្វកិច្ចទាំងអវិជ្ជមានក្នុងការធានាថារដ្ឋមិនហាមឃាត់បុគ្គលក្នុងការចេញពីប្រទេស និងព្រមទាំង**កាតព្វកិច្ចវិជ្ជមាន** ដែលតម្រូវឲ្យរដ្ឋ ក្នុងការធ្វើឲ្យការដើរហើរអាចប្រព្រឹត្តទៅបានជាមុនសិនតាមរយៈការផ្តល់សេវាដឹកជញ្ជូនសាធារណៈ ជួសជុលផ្លូវថ្នល់ ឬធ្វើផ្លូវសម្រាប់អ្នកជិះលើរទេះរុញអាចឡើងទៅលើអគារបាន។

**កាតព្វកិច្ចវិជ្ជមាន**

កាតព្វកិច្ចវិជ្ជមានសំដៅលើកាតព្វកិច្ចដើម្បីធ្វើអ្វីមួយ ឬផ្តល់សេវាមួយ។ កាតព្វកិច្ចវិជ្ជមានមិនអាចត្រូវបានបំពេញដោយអសកម្មភាព ឬអាកប្បកិរិយាអព្យាក្រិតនោះទេ។

នៅពេលចុះហត្ថលេខាលើសន្ធិសញ្ញា កាតព្វកិច្ចសិទ្ធិមនុស្សនឹងចងកាតព្វកិច្ចផ្លូវច្បាប់ដល់រដ្ឋ និងរដ្ឋាភិបាលរបស់រដ្ឋនោះ។ នេះមិនគួរត្រូវបានចាត់ទុកថាជាកាតព្វកិច្ចនោះទេ ប្រសិនបើរដ្ឋាភិបាលដែលមានសមត្ថភាពដែលត្រូវបានបោះឆ្នោតជ្រើសរើសឲ្យធ្វើការដឹកនាំប្រទេសខ្លួនគួរតែមានសមត្ថភាព ក្នុងការបំពេញនូវកាតព្វកិច្ចសិទ្ធិមនុស្ស។

បុគ្គលមានកាតព្វកិច្ចក្នុងការគោរពសិទ្ធិមនុស្ស ជាឧទាហរណ៍ មិនឲ្យមានការរើសអើង ដែលរដ្ឋមានកាតព្វកិច្ចក្នុងការចាប់បង្ខំអនុវត្តតាមរយៈច្បាប់ជាតិ។

## ១.៣.៣ ការការពារខ្សែឈរ និងខ្សែដេក

រដ្ឋមានកាតព្វកិច្ចផ្លូវច្បាប់ក្នុងការមិនរំលោភសិទ្ធិមនុស្សបុគ្គល ដែលនេះកំណត់ច្បាស់តាមរយៈស្តង់ដារសិទ្ធិមនុស្ស។ យ៉ាងណាមិញ មានអ្វីកើតឡើងប្រសិនបើភាគីមិនមែនជារដ្ឋរំលោភសិទ្ធិអ្វីមួយ? ជាឧទាហរណ៍ ប្រសិនបើក្រុមហ៊ុនមួយយកដីធ្លីពីអ្នកណាម្នាក់ រោងចក្រមួយបំពុលទឹកទន្លេ ឬក៏ប្តីវាយប្រពន្ធ។ ករណីខាងលើមិនពាក់ព័ន្ធជាមួយនឹងរដ្ឋនោះទេ ប៉ុន្តែពាក់ព័ន្ធនឹងបុគ្គលដែលស្វែងរកការការពារខ្លួនពី ឬត្រូវការសេវាពីមនុស្ស សាជីវកម្ម ឬក្រុមដទៃ។ នេះត្រូវបានហៅថា**ការការពារខ្សែដេក**។ នេះមានភាពខុសគ្នារវាងការការពារពី ឬត្រូវការសេវាពីរដ្ឋ ដែលជាការការពារខ្សែឈរ ហើយការការពារពី ឬត្រូវការសេវាកម្មពីមនុស្ស សាជីវកម្ម ឬក្រុមដទៃត្រូវបានហៅថាជាការការពារខ្សែដេក។ សិទ្ធិមនុស្សជាចម្បងគឺអំពី**ការការពារខ្សែឈរ** ដែលធ្វើការការពារបុគ្គលពីអំណាចរបស់រដ្ឋ ប៉ុន្តែកាលពីពេលថ្មីៗនេះការការពារខ្សែដេកកំពុងតែកើនឡើងនូវសារៈសំខាន់បន្តិចម្តងៗ។ កង្វល់អំពីការការពារស្ត្រី និងកុមារពីអំពើហិង្សា ឬបញ្ឈប់ការរំលោភបំពាននៅកន្លែងការងារ ត្រូវបានឆ្លើយតបដោយការដោះស្រាយចំនុចខ្សោយក្នុងការការពារខ្សែដេក។

**ការការពារខ្សែដេក**
ការការពារ ដែលបានផ្តល់ជូនដោយសិទ្ធិមនុស្ស ពីអំណាចនៃតួអង្គមិនមានរដ្ឋដូចជាមនុស្សដទៃ ក្រុមហ៊ុន មន្ទីរពេទ្យ ប្រព័ន្ធផ្សព្វផ្សាយ។ល។ ការការពារនេះគឺខ្សែដេកដោយសារតួអង្គទាំងនេះគឺមានកម្រិតដូចគ្នា។ ការការពារខ្សែដេកគួរតែត្រូវបានធានាតាមរយៈរដ្ឋតាក់តែងច្បាប់ប្រឆាំងនឹងតួអង្គដែលរំលោភបំពានសិទ្ធិអ្នកដទៃ និងមានស្ថាប័នដែលការពារសិទ្ធិមនុស្ស ដូចជាប៉ូលីស អង្គការសុខមាលភាព និងប្រព័ន្ធផ្សព្វផ្សាយជាដើម។

**ការការពារខ្សែឈរ**
នេះសំដៅលើការការពារពីអំណាចរដ្ឋដែលបានផ្តល់ជូនដោយសិទ្ធិមនុស្ស។ រដ្ឋមានដែនកំណត់លើអំណាចរបស់ខ្លួន ហើយរដ្ឋត្រូវតែធានាថាខ្លួនគោរពសិទ្ធិរបស់មនុស្សដែលស្ថិតក្រោមអំណាចរបស់ខ្លួន។

ចំនុចខ្សោយមួយក្នុងការការពារខ្សែដេក គឺជាការធានាកាតព្វកិច្ចរបស់តួអង្គដែលមិនមែនជារដ្ឋ។ កាតព្វកិច្ចសិទ្ធិមនុស្សមិនត្រឹមតែជាការគ្រប់គ្រងទំនាក់ទំនងរវាងរដ្ឋ មួយជាមួយនឹងបុគ្គលមួយរូបនោះទេ ប៉ុន្តែជាការធានាថាសិទ្ធិរបស់បុគ្គលត្រូវបានការពារពីការរំលោភបំពានដោយអ្នកណាម្នាក់ ឬអ្វីមួយ។ ដូចដែលការការពារសិទ្ធិមនុស្សមានការអភិវឌ្ឍ កាន់តែមានភាពច្បាស់លាស់ដែលតួអង្គដទៃដូចជាសាជីវកម្ម ក្រុមប្រដាប់អាវុធមិនមែនរបស់រដ្ឋ ឬស្ថាប័នដូចជាមន្ទីរពេទ្យ និងប្រព័ន្ធផ្សព្វផ្សាយ ក៏មានកាតព្វកិច្ចចំពោះប្រជាជនផងដែរ។ ខណៈពេលដែលស្ថាប័នទាំងនេះមិនមានការចងកាតព្វកិច្ចផ្លូវច្បាប់នៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្ស ពួកគេនៅតែអនុលោមតាមស្តង់ដារទាំងនេះពីព្រោះរដ្ឋមានកាតព្វកិច្ចក្នុងការធានាថា ប្រជាជនត្រូវបានការពារពីការយាយីរបស់តតិយជន។ នៅពេលដែលតួអង្គមិនមែនរដ្ឋរំលោភបំពានសិទ្ធិមនុស្ស រដ្ឋមានកាតព្វកិច្ចក្នុងការផ្តល់នូវឧបស្រ័យ ដូចជាសំណង ឬការដាក់ទណ្ឌកម្មដល់ជនល្មើស។ ភារកិច្ច និងកាតព្វកិច្ចរបស់សាជីវកម្មអន្តរជាតិនឹងត្រូវបានពិភាក្សាក្នុងជំពូកបន្ទាប់។

## ១.៣.៤ កាតព្វកិច្ចរដ្ឋ៖ 'គោរព ការពារ បំពេញ' និង 'លើកកម្ពស់ ការពារ និងបង្ការ'

មានការសំដែងនូវឆន្ទៈក្នុងការកំណត់ឲ្យបានច្បាស់នូវអ្វីដែលរដ្ឋគួរតែធ្វើ ដើម្បីធានាថាប្រជាជនទទួលបានសិទ្ធិមនុស្សរបស់ពួកគេ ដែលនេះត្រូវបានបញ្ជាក់ក្នុងសេចក្តីថ្លែងការណ៍ផ្សេងគ្នា តែពាក់ព័ន្ធគ្នាចំនួនពីររបស់ UN។ សេចក្តីថ្លែងការណ៍ទាំងពីរមានគោលបំណងក្នុងការជួយពន្យល់ពីអ្វីដែលរដ្ឋគួរធ្វើ ក្នុងការគាំទ្រដល់សិទ្ធិមនុស្ស។ ជាដំបូងសេចក្តីថ្លែងការណ៍នេះចែងថារដ្ឋគួរតែ 'គោរព ការពារ និងបំពេញ' នូវសិទ្ធិ៖

- គោរព ៖ រដ្ឋគួរតែធានាថាសិទ្ធិមនុស្សត្រូវបានគិតគូរដោយយកចិត្តទុកដាក់ ហើយត្រូវទទួលស្គាល់សិទ្ធិទាំងនេះ។
- ការពារ ៖ រដ្ឋគួរតែធានាថាមានរចនាសម្ព័ន្ធច្បាប់ដែលមានដំណើរការមួយ និងយន្តការការពារក្នុងការការពារបុគ្គល ពីការរំលោភបំពានដោយតួអង្គមិនមែនរដ្ឋ (ការការពារខ្សែដេក)។
- បំពេញ ៖ រដ្ឋគួរតែធានាថាបុគ្គលដែលកន្លងមក មិនបានទទួលនូវសិទ្ធិទាំងអស់របស់ខ្លួន ជាឧទាហរណ៍កុមារដែលមិនទាន់បានចូលរៀន សិទ្ធិទាំងនេះនឹងត្រូវបានបំពេញក្នុងពេលអនាគត។

ចង្កោមកាតព្វកិច្ចនេះត្រូវបានចងក្រងជាដំបូងសម្រាប់សិទ្ធិសេដ្ឋកិច្ចសង្គម និងវប្បធម៌ ដោយសារសិទ្ធិទាំងនេះអាចត្រូវបានបំពេញ ជាជាងអាចឆ្លើយតបបានភ្លាមៗដូចជាសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ការចែកដាច់ពីគ្នានេះនឹងត្រូវបានពិភាក្សាលម្អិតពេលក្រោយ។ បន្ទាប់មកសកម្មភាពទាំងនេះអាចត្រូវបានសម្រិតសម្រាំងបន្ថែមទៀតដើម្បីធានាថារដ្ឋធ្វើឲ្យអស់លទ្ធភាព ដែលខ្លួនអាចធ្វើទៅបានដើម្បីធានាថាពលរដ្ឋរបស់ខ្លួនទទួលបាននូវសិទ្ធិមនុស្ស។ ដូចនេះ ក្នុងអំឡុងពេលទសវត្សឆ្នាំ ១៩៩០ មានតារាងថ្មីមួយត្រូវបានបង្ហាញជាមួយនឹងការ "លើកកម្ពស់ ការពារ និងបង្ការ ។"

- លើកកម្ពស់៖ យល់ដឹងពីកាតព្វកិច្ចក្នុងការ 'គោរព' មិនស្មើឲ្យរដ្ឋធ្វើអ្វីច្រើននោះទេ។ ការគោរពជាអាកប្បកិរិយាជាជាងសកម្មភាព។ សកម្មភាពថ្មីក្នុងការ 'លើកកម្ពស់' សិទ្ធិមនុស្សទាមទារឲ្យរដ្ឋធ្វើការផ្សព្វផ្សាយដោយសកម្ម និងធ្វើផែនការដើម្បីអប់រំសិទ្ធិមនុស្សរួមមានការលើកកម្ពស់ការយល់ដឹង ប្រើប្រាស់សិទ្ធិដើម្បីធ្វើឲ្យច្បាប់ប្រសើរឡើង បញ្ច្រៀបនូវការផ្តួចផ្តើម និងបង្រៀនសិទ្ធិមនុស្សនៅសាកលវិទ្យាល័យ។
- ការពារ៖ (ដូចគ្នាទៅនឹងខាងលើ)

- បង្ការ៖ រដ្ឋគួរតែធានាថាពួកគេនឹងធ្វើអ្វីបន្ថែមលើការឆ្លើយតបនឹងការរំលោភបំពានបន្ទាប់ពីការរំលោភបំពានកើតឡើង។ បន្ថែមពីលើនេះ រដ្ឋគួរតែមានគោលនយោបាយ និងផែនការជាធរមានក្នុងការជៀសវាងការរំលោភបំពានទាំងនេះដែលធ្លាប់កើតឡើងរួចមកហើយ ជាឧទាហរណ៍ ការអប់រំពីសិទ្ធិមនុស្ស បណ្តុះបណ្តាលប៉ូលីសបន្ថែម ឬក៏បោះពុម្ពផ្សាយច្បាប់ជាដើម។

ទាំង ‘គោរព ការពារ បំពេញ’ និង ‘លើកកម្ពស់ ការពារ និងបង្ការ’ ផ្តល់នូវសេចក្តីសង្ខេបដែលមានសារៈសំខាន់ពីអ្វីដែលជាការរំពឹងពីរដ្ឋ ហើយពីអ្វីដែលតួអង្គសិទ្ធិមនុស្សគួរតែធ្វើការបំពេញផងដែរ។

# ១.៤ ប្រភេទនៃសិទ្ធិ

ភាគច្រើន សិទ្ធិមនុស្សកើតចេញពីសន្ធិសញ្ញាអន្តរជាតិដែលបានកំណត់ពីប្រភេទមួយចំនួននៃសិទ្ធិ។ ជាការសំខាន់ក្នុងការរៀបរាប់ពីប្រភេទទាំងនេះពីព្រោះសិទ្ធិ និងកាតព្វកិច្ចខុសគ្នាបន្តិចបន្តួចសម្រាប់ប្រភេទនីមួយៗ។ វិធីសាស្ត្រសំខាន់ក្នុងការបញ្ជាក់ពីប្រភេទសិទ្ធិទាំងនេះ គឺធ្វើការត្រួតពិនិត្យតើថាសិទ្ធិទាំងនេះមានខ្លឹមសារយ៉ាងណានៅក្នុងឯកសារសិទ្ធិមនុស្សជាសកលដំបូង គឺ UDHR។ សេចក្តីប្រកាសនេះ ដែលត្រូវបានអនុម័តដោយ UN ក្នុងឆ្នាំ១៩៤៨ មានចំនួន ៩០មាត្រា ដែលមាត្រានីមួយៗបញ្ជាក់ពីសិទ្ធិ និងកាតព្វកិច្ចមួយ។ តារាងនៃសិទ្ធិក្នុង UDHR មានលំដាប់លំដោយជាក់លាក់ដែលជួយក្នុងការបង្ហាញពីប្រភេទនៃសិទ្ធិ។ នឹងមានការអធិប្បាយលម្អិតពីសេចក្តីប្រកាសនៅក្នុងជំពូកក្រោយ ប៉ុន្តែនឹងមានការបញ្ជាក់ដោយសង្ខេបអំពីថាតើសេចក្តីប្រកាសនេះចំណាត់ប្រភេទខុសៗគ្នានៃសិទ្ធិយ៉ាងដូចម្តេចខ្លះ។

សិទ្ធិត្រូវបានរៀបចំតាមប្រភេទដោយសារប្រភេទខ្លះមានលក្ខណៈពិសេសផ្សេងៗគ្នា។ យ៉ាងណាមិញ សិទ្ធិមិនគួរណាត្រូវបានធ្វើចំណាត់ថ្នាក់នោះទេ ដោយសារប្រភេទនីមួយៗ ជាផ្នែកសំខាន់នៃសិទ្ធិមនុស្សរបស់បុគ្គល។ យ៉ាងណាមិញ ដូចដែលប្រវត្តិសាស្ត្របានបង្ហាញ (ដែលមានបញ្ជាក់លម្អិតក្នុងផ្នែកបន្ទាប់) រដ្ឋមួយចំនួនឲ្យតម្លៃសិទ្ធិមួយចំនួនលើសសិទ្ធិមួយចំនួនផ្សេងទៀត ដែលធ្វើឲ្យមានការបែងចែកក្នុងការពារសិទ្ធិមនុស្ស។

## សិទ្ធិជាមូលដ្ឋាន

សិទ្ធិដំបូងនៅក្នុង UDHR គឺពាក់ព័ន្ធជាមួយនឹងថាអ្វីត្រូវបានចាត់ទុកថាជាសិទ្ធិសំខាន់បំផុត សេរីភាពរួចផុតពីទាសភាព និងការធ្វើទារុណកម្ម និងសិទ្ធិរស់រានមានជីវិត ការមិនរើសអើង និងទស្សនៈដែលថាមនុស្សគ្រប់រូបកើតមកមានភាពស្មើគ្នា។ មិនពាក់ព័ន្ធនឹងស្ថានភាពណាមួយនោះទេ គ្មានរដ្ឋណាមួយអាចមិនអើពើ ឬរំលោភបំពានសិទ្ធិទាំងនេះបាននោះទេ។ ដូចដែលបានបញ្ជាក់ពិស្តារក្នុងជំពូកក្រោយ ក្នុងកាលៈទេសៈជាក់លាក់រដ្ឋអាចផ្អាកសិទ្ធិដទៃទៀតបានជាបណ្តោះអាសន្ន ឬបកស្រាយសិទ្ធិទាំងនោះក្នុងវិធីសាស្ត្រផ្សេង ប៉ុន្តែរដ្ឋមិនអាចផ្តល់ហេតុផលសម្រាប់ការរំលោភបំពានសិទ្ធិជាមូលដ្ឋានបាននោះទេ។

## សិទ្ធិក្នុងប្រព័ន្ធច្បាប់

សិទ្ធិផ្លូវច្បាប់មានជាធរមាន ដើម្បីធានាថាបុគ្គលទទួលបានការការពារផ្លូវច្បាប់ដោយស្មើភាពគ្នា។ លើសពីនេះទៀត ប្រព័ន្ធច្បាប់ត្រូវតែផ្អែកលើទស្សនៈនៃយុត្តិធម៌ពិតប្រាកដ ដែលជាទស្សនៈមួយគ្របដណ្តប់នូវលទ្ធភាពក្នុងការប្តឹងទៅតុលាការ ហើយតុលាការមានភាពយុត្តិធម៌ មានសមត្ថកិច្ច និងអព្យាក្រិត។ យុត្តិធម៌ក៏រួមបញ្ចូលផងដែរនូវភាពស្មើគ្នានៃការប្រព្រឹត្តមកលើ ហើយប្រសិនត្រូវបានចាប់ខ្លួន បុគ្គលត្រូវទទួលបានការប្រព្រឹត្តសមរម្យ។ សិទ្ធិដទៃទៀតរួមមានសេរីភាពរួចផុតពីការចាប់ខ្លួន និងការឃុំខ្លួនតាមទំនើងចិត្ត និងការសន្មតជាមុនថាគ្មានទោស។ នៅអាស៊ីអាគ្នេយ៍ សិទ្ធិទាំងនេះបង្កឲ្យមានការប្រឈមជាច្រើន ដោយសារនៅក្នុងប្រទេសជាច្រើន ប្រព័ន្ធតុលាការមិនមានមូលនិធិគ្រប់គ្រាន់ ហើយធ្វើការងារច្រើនពេក ដែលធ្វើឲ្យយុត្តិធម៌មានដំណើរការយឺត។ ម្យ៉ាងវិញទៀត ប៉ូលីសអាចមានស្តង់ដារទាបដែលធ្វើឲ្យការចាប់ខ្លួនខុសនីតិវិធី ឬឧក្រិដ្ឋជនមិនបានត្រូវផ្តន្ទាទោស។ ចុងក្រោយ តុលាការខ្លះមិនអព្យាក្រិត ហើយបើមានអំពើពុករលួយនឹងធ្វើឲ្យមានករណីដែលចៅក្រមបើកផ្លូវក្នុងការស៊ីសំណូក។

## សិទ្ធិក្នុងសង្គម

**សិទ្ធិពលរដ្ឋ**
សិទ្ធិពលរដ្ឋការពារសេរីភាពបុគ្គល និងធានាសេរីភាពដូចជាសេរីភាពនៃការបញ្ចេញមតិ ការគិត និយាយស្តី សាសនា និងដើរហើរ។

**សិទ្ធិពលរដ្ឋ** ផ្តោតសំខាន់លើសមត្ថភាពបុគ្គលក្នុងការចូលរួមក្នុងសង្គម និងរស់នៅប្រកបដោយភាពថ្លៃថ្នូរជាប្រចាំថ្ងៃ។ ភាគច្រើននៃសេរីភាពពលរដ្ឋនេះ ត្រូវប្រទះឃើញនៅក្នុងឯកសារសិទ្ធិមនុស្សកាលពីមុនៗ ដូចជាសេចក្តីប្រកាសសិទ្ធិមនុស្សរបស់សហរដ្ឋអាមេរិក (១៧៨៨) និងសេចក្តីប្រកាសពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋរបស់បារាំង (១៧៨៩)។ ឯកសារទាំងនេះផ្តោតសំខាន់លើការដាក់ដែនកំណត់លើអំណាចរដ្ឋក្នុងការជ្រៀតជ្រែកជាមួយនឹងសេរីភាពបុគ្គលក្នុងសង្គមមួយ។ សេរីភាពទាំងនេះធានានូវឯកជនភាព សេរីភាពក្នុងការដើរហើរនៅក្នុងប្រទេសមួយ សិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍ និងមានបុត្រធីតា ក្នុងការគោរពសាសនា និងសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិពលរដ្ឋដទៃទៀតរួមមានសិទ្ធិក្នុងការមានសញ្ជាតិ សិទ្ធិក្នុងការទទួលការជ្រកកោន និងសិទ្ធិលើទ្រព្យសម្បត្តិ។

## សិទ្ធិនយោបាយ

**សិទ្ធិនយោបាយ**
សិទ្ធិនយោបាយអនុញ្ញាតឲ្យបុគ្គលក្នុងការចូលរួមក្នុងនយោបាយ និងធានានូវប្រព័ន្ធនយោបាយដែលយុត្តិធម៌ ដែលរួមមានសិទ្ធិក្នុងការបោះឆ្នោត សិទ្ធិក្នុងការធ្វើជាអ្នកនយោបាយ និងសិទ្ធិក្នុងការចូលរួមគណៈបក្សណាមួយ។

**សិទ្ធិនយោបាយ** ជាសិទ្ធិដែលអនុញ្ញាតមនុស្សក្នុងការចូលរួមក្នុងឆាកនយោបាយ ហើយពួកគេក៏អាចធានានូវប្រព័ន្ធនយោបាយដែលមានយុត្តិធម៌ផងដែរ។ សិទ្ធិនយោបាយ ដែលពាក់ព័ន្ធនឹងការចូលរួមរួមមានសិទ្ធិក្នុងការបោះឆ្នោត និងសិទ្ធិក្នុងការធ្វើជា

អ្នកនយោបាយ ឬមន្ត្រីរដ្ឋាភិបាល។ សិទ្ធិនេះរួមមានសិទ្ធិក្នុងការបង្កើតសមាគម ក្នុងការបង្កើតគណៈបក្សនយោបាយឬអាចជាការក្លាយជាសមាជិករបស់ក្រុមមួយផងដែរ។ ក្រុមអាចជាគណៈបក្សនយោបាយ សហជីព ឬសម្បីតែក្លឹបអ្នកគាំទ្រ។ សិទ្ធិក្នុងការប្រជុំ ដែលនេះមានន័យថាជួបគ្នា ជាសាធារណៈ ឬជាលក្ខណៈឯកជនក៏ជាសិទ្ធិមនុស្សផងដែរ ហើយអាចគ្របដណ្តប់ការប្រជុំក្នុងការតវ៉ាប្រឆាំងនឹងរដ្ឋាភិបាល ឬលក្ខខណ្ឌការងារ ដើម្បីលើកកម្ពស់បញ្ហាណាមួយ ឬចូលរួមក្នុងសកម្មភាពវប្បធម៌ណាមួយផងដែរ។

## សិទ្ធិសេដ្ឋកិច្ច

**សិទ្ធិសេដ្ឋកិច្ច**
សិទ្ធិសេដ្ឋកិច្ចធានាសុខមាលភាពសេដ្ឋកិច្ចបុគ្គល។ សិទ្ធិសេដ្ឋកិច្ចសំខាន់រួមមានសិទ្ធិក្នុងការធ្វើការ សិទ្ធិក្នុងការទទួលបានសុខមាលភាព និងសិទ្ធិកំសាន្ត។

**សិទ្ធិសេដ្ឋកិច្ច** ជាសិទ្ធិដែលធានាឲ្យបុគ្គលមានលុយ ឬធនធានគ្រប់គ្រាន់ក្នុងការរស់នៅប្រកបដោយភាពថ្លៃថ្នូរក្នុងសហគមន៍របស់ពួកគេ។ សម្រាប់មនុស្សភាគច្រើននេះរួមបញ្ចូលសិទ្ធិក្នុងការធ្វើការ ដែលនិយោជករបស់គេត្រូវឲ្យប្រាក់ដោយសមរម្យយុត្តិធម៌ និងផ្តល់ជូនពួកគេនូវបរិយាកាសការងារដែលមានសុវត្ថិភាព និងមានសុខភាព។ មានការផ្តល់ជូននូវការការពារដល់អ្នកដែលមិនអាចធ្វើការបានផងដែរ ក្នុងទម្រង់ជាប្រាក់សោធនពីរដ្ឋាភិបាល។ មាត្រា ២២ នៃ UDHR បញ្ជាក់ពីសិទ្ធិក្នុងការទទួលបានសន្តិសុខសង្គម ដែលនេះជាសិទ្ធិក្នុងការទទួលបានធនធានចាំបាច់ សម្រាប់ការរស់រានដូចជាការបើកប្រាក់សោធន ឬលទ្ធភាពក្នុងការទទួលបានចំនីអាហារដែលមានតម្លៃទាប។ ប្រទេសភាគច្រើននៅអាស៊ីអាគ្នេយ៍មានប្រព័ន្ធសន្តិសុខសង្គមទន់ខ្សោយ ឬមិនមានតែម្តង ហើយដូចនេះជាវិស័យមួយដែលទាមទារឲ្យមានការអភិវឌ្ឍបន្ថែមទៀត។ សិទ្ធិសេដ្ឋកិច្ចចម្បងដទៃទៀតគឺជាសិទ្ធិក្នុងការសម្រាក និងកំសាន្ត។ ដូចទៅនឹងសិទ្ធិសន្តិសុខសង្គមដែរ សិទ្ធិនេះភាគច្រើនមិនត្រូវបានឲ្យតម្លៃដោយសារមនុស្សភាគច្រើនគិតថានេះគ្រាន់តែសិទ្ធិសម្រាប់កុមារតែប៉ុណ្ណោះ។ យ៉ាងណាមិញ សិទ្ធិក្នុងការកំសាន្តគឺផ្សាភ្ជាប់នឹងសិទ្ធិក្នុងការធ្វើការ។ ម៉ោងការងារអតិបរមា និងថ្ងៃឈប់សម្រាកដែលជាការតម្រូវជាផ្នែកមួយនៃសិទ្ធិក្នុងការធ្វើការ។

**សិទ្ធិសង្គម**
សិទ្ធិសង្គមគឺជាសិទ្ធិក្នុងការទទួលបានសេវាកម្មរដ្ឋាភិបាលដូចជាសុខភាព ការអប់រំ។ ក៏មានសិទ្ធិក្នុងការទទួលបានតម្រូវការចាំបាច់ជាមូលដ្ឋានផងដែរដូចជាចំណីអាហារ ទឹក ទីលំនៅ និងសម្លៀកបំពាក់។ សិទ្ធិទាំងនេះជាសិទ្ធិសង្គម ដោយសារសិទ្ធិទាំងនេះធានាថាមនុស្សអាចរស់នៅក្នុងសង្គមដោយភាពថ្លៃថ្នូរ។ ជារឿយៗសិទ្ធិទាំងនេះត្រូវបានចាត់ទុកថាជាកិច្ចសន្យាសង្គមរវាងប្រជាជននឹងរដ្ឋ៖ តាមរយៈការគោរពច្បាប់មនុស្សអាចទទួលបាននូវសេវាទាំងនេះ។

## សិទ្ធិសង្គម

**សិទ្ធិសង្គម** ជាសិទ្ធិដែលបុគ្គលរំពឹងពីការរស់នៅក្នុងសង្គមមួយ ដូចជាសិទ្ធិក្នុងការទទួលបានសេវាសុខភាព និងការអប់រំ ចំនីអាហារ ទឹក និងលំនៅដ្ឋាន។ ពេលខ្លះសិទ្ធិនេះត្រូវបានហៅថាជាសិទ្ធិនៃជីវភាពរស់នៅ ដែលយើងអាចអះអាងបានថាសិទ្ធិទាំងនេះមានប្រភពចេញពីទស្សនៈនៃកិច្ចសន្យាសង្គម៖ ដែលជាកិច្ចសន្យារវាងបុគ្គល និងរដ្ឋាភិបាលរបស់ខ្លួន ដែលមានន័យថាប្រសិនបើបុគ្គលរស់នៅដោយសន្តិភាព និងដោយស្របច្បាប់ រដ្ឋាភិបាលនឹងផ្តល់នូវសេវាកម្មជាក់លាក់មួយចំនួន ហើយការពារសេវាកម្មដទៃដែលប្រជាជនផ្តល់ជូនខ្លួនពួកគេដោយផ្ទាល់។

សេវាកម្មដែលជាការរំពឹងក្នុងការទទួលបានពីរដ្ឋាភិបាលរួមមានប្រព័ន្ធអប់រំ និងសេវាថែទាំសុខភាព។ មធ្យោបាយដែលរដ្ឋាភិបាលតម្រូវឲ្យប្រជាពលរដ្ឋរបស់ខ្លួនបង់ថ្លៃដល់សេវាទាំងនេះគឺខុសគ្នាពីប្រទេសមួយទៅប្រទេសមួយផ្សេងទៀត ប៉ុន្តែរដ្ឋាភិបាលត្រូវតែផ្តល់សេវាទាំងនេះ។ ជាឧទាហរណ៍ រដ្ឋាភិបាលត្រូវផ្តល់ការអប់រំថ្នាក់បឋមសិក្សាដែលជាការតម្រូវចាំបាច់ដោយឥតគិតថ្លៃដល់កុមារទាំងអស់ ដោយមិនខ្វល់ពីអំបូរសញ្ជាតិ ពលរដ្ឋ ឬភាសានោះទេ។ សិទ្ធិអប់រំ សុខភាព ចំនីអាហារ ទឹក និងលំនៅដ្ឋានមានសារៈសំខាន់ជាពិសេសក្នុងប្រទេសនៅអាស៊ីអាគ្នេយ៍។ ខណៈពេលដែលប្រទេសខ្លះដូចជាសឹង្ហបូរី ធ្វើបានល្អប្រសើរពាក់ព័ន្ធនឹងសិទ្ធិចំនីអាហារ ទឹក លំនៅដ្ឋាន សុខភាព និងការអប់រំ ប្រកបដោយស្តង់ដារខ្ពស់ ប្រទេសដទៃដូចជាភូមា នៅតែមានការពិបាកក្នុងការផ្តល់នូវសិទ្ធិមូលដ្ឋានទាំងនេះ។

## សិទ្ធិវប្បធម៌

ប្រភេទចុងក្រោយគឺជាសិទ្ធិវប្បធម៌ ដែលនេះជាសិទ្ធិសម្រាប់បុគ្គលក្នុងការចូលរួមក្នុងវប្បធម៌របស់ពួកគេ ដែលនេះអាចត្រូវបានបែងចែកជាធាតុផ្សំបី៖ សិទ្ធិភាសា សាសនា និងសកម្មភាពវប្បធម៌។ សិទ្ធិមនុស្សក្នុងការប្រើប្រាស់ភាសាមួយ បង្ការដល់រដ្ឋមិនឲ្យហាមឃាត់មនុស្សក្នុងការនិយាយភាសារបស់ខ្លួន។ វាមិនចាំបាច់ដល់មាន ន័យថារដ្ឋត្រូវផ្តល់សេវាកម្មសម្រាប់អ្នកទាំងនោះជាភាសានេះនោះទេ (ទោះបីជាការរំពឹងទុកដែលថាសេវាកម្មរដ្ឋាភិបាលដែលចាំបាច់មួយចំនួនដូចជាច្បាប់ និងសុខភាពគួរតែមានជាភាសារបស់ពួកគេក៏ដោយ)។ សិទ្ធិសាសនាអនុញ្ញាតឲ្យបុគ្គលក្នុងការជ្រើសរើសសាសនារបស់ពួកគេ និងអនុវត្តសាសនានេះជាក្រុម ជាឧទាហរណ៍ ដូចជាការបួងសួងជាមួយគ្នា។

សិទ្ធិវប្បធម៌គ្របដណ្តប់នូវសកម្មភាពជាច្រើនដូចជាសិទ្ធិក្នុងការបរិភោគ ស្លៀកពាក់ រៀបអាពាហ៍ពិពាហ៍ ធ្វើបុណ្យសព និងប្រារព្ធពិធី តាមសាសនានោះ។ ទូទាំងអាស៊ីអាគ្នេយ៍មានភាពតានតឹងយ៉ាងច្រើនពាក់ព័ន្ធនឹងសិទ្ធិនេះ ដូចជាសិទ្ធិក្នុងការស្លៀកសម្លៀកបំពាក់មួយចំនួន (ជាឧទាហរណ៍ក្រណាត់រុំមុខដោយស្ត្រីម៉ូស្លីមជាដើម) ឬសិទ្ធិរបស់ក្រុមជនជាតិដើមភាគតិចក្នុងការរស់នៅ និងធ្វើការប្រមាញ់លើដីដែលជាទំនៀមទំលាប់របស់ពួកគេ ដែលដីនេះអាចត្រូវបានប្រែក្លាយទៅជាឧទ្យានជាតិដោយរដ្ឋ។

## ១.៤.១ ការញែកចេញពីគ្នា និងការរួមបញ្ចូលគ្នានៃប្រភេទនៃសិទ្ធិ

ការបែងចែកសិទ្ធិជាប្រភេទទាំងនេះមានសារៈសំខាន់ ដោយសារប្រភេទនីមួយៗមានចរិកលក្ខណៈខុសគ្នាបន្តិចបន្តួចពាក់ព័ន្ធនឹងសិទ្ធិ និងកាតព្វកិច្ច។ ជាឧទាហរណ៍ សិទ្ធិជាមូលដ្ឋានមានអំណាចនៃច្បាប់អន្តរជាតិ ក្នុងការចាប់បង្ខំអនុវត្តសិទ្ធិទាំងនោះ ដែលសេរីភាពពលរដ្ឋភាគច្រើនមិនដូចនេះនោះទេ សិទ្ធិសង្គមបញ្ជាក់ពីសេវាកម្មរដ្ឋាភិបាល ហើយមិនភ្លាមៗដូចសិទ្ធិពលរដ្ឋនោះទេ ហើយសិទ្ធិវប្បធម៌គឺផ្តោតសំខាន់ជាចម្បងលើក្រុមជនជាតិភាគតិច។ យ៉ាងណាមិញ ក៏មានគ្រោះថ្នាក់ផងដែរ ក្នុងការញែកសិទ្ធិទាំងនេះជាប្រភេទ ពីព្រោះរដ្ឋាភិបាលមួយចំនួនអាចយកចិត្តទុកដាក់លើប្រភេទសិទ្ធិខ្លះ ហើយមិនអើពើលើប្រភេទដទៃ ឬពួកគេធ្វើការជ្រើសរើសថាសិទ្ធិប្រភេទណាដែលពួកគេគួរតែគាំទ្រ។

ភាគច្រើនក្នុងអំឡុងពេលរវាងឆ្នាំ ១៩៥០ ដល់ឆ្នាំ ១៩៩០ ការបែងចែកជាចម្បងគឺរវាងប្រទេសដែលគាំទ្រសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងប្រទេសដែលគាំទ្រសិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គម។ ជាលទ្ធផលប្រភេទទាំងនេះត្រូវបានញែកដាច់ពីគ្នា និងខុសពីគ្នា។ ការបែងចែកនេះចៃដន្យចំពេលដែលពិភពលោកត្រូវបានបែងចែកតាមមនោគមវិជ្ជារវាងប្រទេសលោកខាងលិច ដែលគាំទ្រមូលធននិយមសេរី និងប្រទេសកុំម្មុយនិស (ដូចជាចិន សូវៀត និងវៀតណាម) ដែលគាំទ្រប្រព័ន្ធនយោបាយកុំម្មុយនិស។ មាននិន្នាការមួយ ទោះបីជានេះមិនពិតក្នុងគ្រប់ករណីក៏ដោយ សម្រាប់ប្រទេសលោកខាងលិចក្នុងការគាំទ្រសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ហើយសម្រាប់ប្រទេសកុំម្មុយនិសគឺគាំទ្រសិទ្ធិសេដ្ឋកិច្ច និងសង្គម។ ជាទូទៅ ប្រទេសលោកខាងលិចហាក់បីដូចជាយកចិត្តទុកដាក់ចំពោះសិទ្ធិពលរដ្ឋ និងនយោបាយពីព្រោះសិទ្ធិទាំងនេះ មាននៅក្នុងច្បាប់សិទ្ធិមនុស្សរបស់ពួកគេរួចជាស្រេចទៅហើយ។ បន្ថែមពីលើនេះទៀត ដោយសារតែប្រទេសអ្នកមាន និងអភិវឌ្ឍន៍ ពួកគេឃើញតម្រូវការតិចតួចក្នុងការដោះស្រាយបញ្ហាសិទ្ធិសេដ្ឋកិច្ចដោយសារមានអ្នកអត់ឃ្លាន ឬអ្នកអត់ផ្ទះសម្បែងតិចតួចបំផុត ឬគឺយល់ឃើញថាសិទ្ធិសង្គមជាសេវាកម្មដែលប្រជាពលរដ្ឋពួកគេត្រូវតែបង់សេវា។ ការបែងចែកនេះ ត្រូវបានគាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាលលោកខាងលិចធំៗជាច្រើន (NGOs) ដូចជា លើកលែងទោសអន្តរជាតិ (Amnesty International) និង អង្គការឃ្លាំមើលសិទ្ធិមនុស្សពិភពលោក (Human Right Watch) ជាដើម ដែលអង្គការទាំងពីរនេះធ្វើការផ្តាច់មុខលើសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រហូតដល់ចុងសតវត្សឆ្នាំ ១៩៩០ មុនពេលពួកគេចាប់ផ្តើមយកចិត្តទុកដាក់ ពីសិទ្ធិ ពីសិទ្ធិសេដ្ឋកិច្ច និងសង្គម។

ប្រទេសកុំម្មុយនិសមើលឃើញថា តួនាទីរបស់រដ្ឋាភិបាលក្នុងការផ្តល់សេវាកម្មដូចជាការអប់រំ សុខភាព និងសុខមាលភាពសេដ្ឋកិច្ចសេរី ប៉ុន្តែពួកគេមិនគាំទ្រសិទ្ធិក្នុងការ

បោះឆ្នោតនោះទេ។ ស្រដៀងគ្នានេះផងដែរ ប្រទេសនៅអាស៊ីអាគ្នេយ៍មួយចំនួនបានសម្រេចចិត្តថាការអភិវឌ្ឍគួរតែមានអាទិភាពលើសេរីភាពពលរដ្ឋ។ ប្រទេសជាច្រើនរួមមានសិង្ហបុរី និងម៉ាឡេស៊ី បានលើកកម្ពស់សិទ្ធិសេដ្ឋកិច្ច និងសង្គមជាងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ពួកគេអះអាងថាទាល់តែមានសុខភាព ការអប់រំ និងទ្រព្យសម្បត្តិទើបមានសិទ្ធិពលរដ្ឋ និង សិទ្ធិនយោយបាយត្រូវបានទទួលស្គាល់ជាក្រោយ (ដូចជាសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិក្នុងការប្រជុំ)។ ពួកគេអះអាងថាការផ្តល់បុគ្គលនូវសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយមុនពេលដែលប្រទេសរបស់ពួកគេអភិវឌ្ឍន៍ពេញលេញ នាំឲ្យមានជម្លោះ និងការភ័ន្តច្រឡំ ដោយសារប្រជាជននឹងតវ៉ាប្រឆាំងជាជាងផ្តោតសំខាន់លើការធ្វើការដើម្បីឆ្ពោះទៅកាន់ការអភិវឌ្ឍ។ ដូចនេះសិទ្ធិពលរដ្ឋត្រូវបានដោះដូរជាមួយនឹងសិទ្ធិសេដ្ឋកិច្ច និងសង្គម។ ខណៈពេលដែលជំពូកទីបី មានការបង្ហាញថាការញែកចេញពីគ្នានៃសិទ្ធិនេះ មិនមែនគ្រាន់តែជាការសម្រេចចិត្តផ្នែកនយោបាយប៉ុណ្ណោះទេ វានៅតែមានឥទ្ធិពលលើថាតើរដ្ឋមានការពាក់ព័ន្ធយ៉ាងដូចម្តេចទៅនឹងសិទ្ធិមនុស្ស។

ការបែងចែករវាងប្រភេទត្រូវបានបង្ហំដោយទស្សនៈដូចជាទ្រឹស្តី ″បីជំនាន់″ ដែលសន្មតថាប្រភេទផ្សេងៗគ្នានៃសិទ្ធិលេចចេញតាមពេលវេលាផ្សេងៗគ្នា។ ទ្រឹស្តីនេះសន្មតថាសិទ្ធិមនុស្សមានក្រុមបីដាច់ដោយឡែកនិងតាមលំដាប់លំដោយ។

## ទស្សនៈទាន

### ទ្រឹស្តី "បីជំនាន់"

ទ្រឹស្តី "បីជំនាន់" ត្រូវបានលើកឡើងដោយអ្នកច្បាប់ជនជាតិឆែក ការ៉ែល វ៉ាសាក់ (Karel Vasak) នៅសតវត្សឆ្នាំ១៩៧០ ហើយកំណត់ថាសិទ្ធិបានលេចចេញនៅពេលវេលាខុសៗគ្នា នៅក្នុងបរិបទផ្សេងៗគ្នា។ ទ្រឹស្តីនេះកំណត់ពីបីជំនាន់ដូចខាងក្រោម៖

- ជំនាន់ទីមួយ ៖ សិទ្ធិមនុស្សដំបូងគឺមានលក្ខណៈជាសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ហើយបានកើតឡើងក្នុងអំឡុងពេលនៃការរីកចំរើនផ្នែកចំនេះដឹង តាំងពីចុងសតវត្សឆ្នាំ១៧០០ រហូតដល់ពាក់កណ្តាលសតវត្សឆ្នាំ១៨០០។ ឧទាហរណ៍មានក្នុងសេចក្តីប្រកាសពីសិទ្ធិមនុស្សរបស់សហរដ្ឋអាមេរិក និងសេចក្តីប្រកាសពីសិទ្ធិមនុស្ស(បុរស) និងសិទ្ធិពលរដ្ឋ។
- ជំនាន់ទីពីរ ៖ ជំនាន់ទីពីរនៃសិទ្ធិលេចចេញជារូបរាងដើម្បីជាការឆ្លើយតបនឹងលក្ខខណ្ឌច្របូកច្របល់នៃបដិវត្តន៍ឧស្សាហកម្ម។ សិទ្ធិទាំងនេះបានការពារកម្មករ និងបង្ខំរដ្ឋក្នុងការផ្តល់សេវាកម្មដូចជាការអប់រំ និងការថៃទាំសុខភាព។ អំឡុងពេលនេះបានចាប់ផ្តើមនៅចុងសតវត្សឆ្នាំ១៨០០ ហើយបានបន្តរហូតដល់សង្គ្រាមលោកលើកទីពីរ។ ក្នុងអំឡុងពេលនេះ ILO មានវត្តមានក្នុងការការពារកម្មកររដ្ឋដែលមានសុខមាលភាពដំបូងបានលេចចេញជារូបរាង ហើយប្រព័ន្ធអប់រំជាសកលជាលើកដំបូងបានចាប់បដិសន្ធិ។
- ជំនាន់ទីបី៖ ជំនាន់ទីបីនៃសិទ្ធិគឺសំខាន់បំផុតសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ និងរួមមានសិទ្ធិក្នុងការ សិទ្ធិស្វ័យសម្រេច សិទ្ធិជនជាតិភាគតិច និងសិទ្ធិវប្បធម៌។ សិទ្ធិទាំងនេះសំខាន់ក្នុងទសវត្សឆ្នាំ១៩៦០ និងឆ្នាំ១៩៧០ នៅពេលដែលសិទ្ធិទាំងនេះចាប់ផ្តើមលេចចេញជារូបរាងក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិផ្សេងៗ។

ខណៈពេលដែលទ្រឹស្តីបីជំនាន់ បានជួយក្នុងការបែងចែកប្រភេទផ្សេងៗគ្នានៃសិទ្ធិ វាបានបង្កើតបញ្ហាច្រើនជាងអ្វីដែលទ្រឹស្តីនេះបានដោះស្រាយ។ បញ្ហាគឺថាការបញ្ជាក់ពីបីជំនាន់បង្កប់ន័យថា សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយគឺជាសិទ្ធិដំបូង និងសិទ្ធិដើមដែលសិទ្ធិដទៃមានតាមក្រោយ។ នេះបញ្ជាក់ការពិតចំពោះការសន្មតដែលថាសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយមានភាពជាចម្បង និងជាមូលដ្ឋាន ខណៈពេលដែលសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌នៅពីក្រោយ។ នេះក៏បង្កប់ន័យផងដែរថាសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយជាសិទ្ធិដែលមានការអភិវឌ្ឍបំផុត ដោយសារសិទ្ធិទាំងនេះមានវត្តមានជាយូរអង្វែងមកហើយ ដែលនេះមិនមែនជាការត្រឹមត្រូវនោះទេ ពីព្រោះវប្បធម៌ជាច្រើនមានប្រវត្តិយូរអង្វែងក្នុងការគោរពនូវភាពខុសគ្នានៃវប្បធម៌ ហើយគាំទ្រដល់អ្នកក្រីក្រ។ ចុងក្រោយ នេះបង្កប់ន័យថាជំនាន់នីមួយៗខុសៗគ្នា ហើយអាចមាន

មុខងារដោយឯករាជ្យពីគ្នា ដែលសន្មតថាប្រភេទសិទ្ធិអាចត្រូវបានញែកដាច់ពីគ្នា។ យ៉ាងណាមិញ ការគិតក្នុងសហសម័យនេះពាក់ព័ន្ធនឹងសិទ្ធិអះអាងថា នេះមិនមែនជាការត្រឹមត្រូវនោះទេ។

## ១.៨.២ VDPA ៖ សេចក្តីប្រកាស និងផែនការសកម្មភាពទីក្រុងវីយ៉ែន

បញ្ហានៃការមិនចូលចិត្តរបស់លោកខាងលិចលើសិទ្ធិសេដ្ឋកិច្ច ឬ កាត់បន្ថយសារៈសំខាន់នៃសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក្នុងតំបន់អាស៊ី ត្រូវបានសង្កេតឃើញថាជាឧបសគ្គលើចលនាសិទ្ធិមនុស្ស។ នៅចុងបញ្ចប់នៃសង្គ្រាមត្រជាក់ និងបន្ទាប់ពីការលុបបំបាត់ការបែងចែកនូវនយោបាយ ឱកាសមួយបានលេចឡើងក្នុងការដោះស្រាយនូវការបែងចែកនេះនៅក្នុងសន្និសិទលោកលើកទីពីរស្តីពីសិទ្ធិមនុស្ស (១៩៩៣) ក្នុងទីក្រុងវីយ៉ែន ។ សន្និសិទ និងឯកសារលទ្ធផលនៃសន្និសិទនេះ ដែលជាសេចក្តីប្រកាស និងផែនការសកម្មភាពទីក្រុងវីយ៉ែន (VDPA) បានដៅពីការវិវត្តន៍សំខាន់មួយក្នុងប្រវត្តិសាស្ត្រសិទ្ធិមនុស្ស។ មានការព្រមព្រៀងដោយរដ្ឋចំនួន ១៧១ ដែលជាចំនួនរដ្ឋទាំងអស់នាពេលនោះ ដែលនេះបង្ហាញពីការទទួលស្គាល់សកល។

VDPA ធ្វើបដិវត្តន៍នូវការយល់ដឹងពីសិទ្ធិមនុស្សតាមរយៈវិធីសាស្ត្រជាច្រើន៖ វាជាការព្យាយាមមួយក្នុងការចែងជាលាយលក្ខអក្សរនៃ ***"សិទ្ធិមនុស្សទាំងអស់សម្រាប់មនុស្សគ្រប់គ្នា"*** ។ VDPA បញ្ចប់នូវទស្សនៈដែលថាសិទ្ធិមនុស្សផ្លាស់ប្តូរយោងទៅតាមភាពជាក់លាក់នៃវប្បធម៌ VDPA បានប្រកាសថាការការពារសិទ្ធិមនុស្សគួរតែជាកង្វល់ផ្លូវច្បាប់មួយរបស់សហគមន៍អន្តរជាតិ ហើយថាការពារសិទ្ធិទាំងនេះមិនមែនជាកិច្ចការផ្តាច់មុខរបស់ជាតិមួយនោះទេ។ វាក៏ផ្សាភ្ជាប់សិទ្ធិមនុស្សទៅនឹងលទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍផងដែរ ដែលបានចែងថាសិទ្ធិ លទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍគឺពឹងផ្អែកគ្នាទៅវិញទៅមកនិងបំពេញឲ្យគ្នាទៅវិញទៅមក។ ក្នុងន័យម្យ៉ាងទៀត ***គឺថាមិនអាចមានសិទ្ធិនោះទេបើមិនមានលទ្ធិប្រជាធិបតេយ្យ គ្មានលទ្ធិប្រជាធិបតេយ្យនោះទេបើមិនមានការអភិវឌ្ឍ និងគ្មានការអភិវឌ្ឍនោះទេបើមិនមានសិទ្ធិមនុស្ស។***

VDPA បានរំកិលសិទ្ធិមនុស្សចេញពីរចនាសម្ព័ន្ធបែងចែកនៃការបែងចែកសិទ្ធិក្នុងសម័យសង្គ្រាមត្រជាក់ ទៅជាទស្សនៈដែលកាន់តែមានការរួមបញ្ចូលគ្នា និងក្តោបជារួម។ ទស្សនៈចម្បងដែលបានស្នើឡើងដោយ VDPA គឺថាសិទ្ធិមនុស្សអវិភាគ ពឹងអាស្រ័យគ្នាទៅវិញទៅមក និងមានការទាក់ទងគ្នាទៅវិញទៅមក។

ពាក្យពេចន៍ទាំងបីនេះបូកចូលគ្នា បញ្ជាក់ថាសិទ្ធិមនុស្សមិនអាចមានវត្តមានជាប្រភេទដែលដាច់ចេញពីគ្នានោះទេ ប៉ុន្តែបង្កើតជាក្រុមតែមួយនៃប្រភេទដែលពាក់ព័ន្ធគ្នាទៅវិញទៅមកនៃសិទ្ធិមនុស្ស។

- ***អវិភាគ*** ៖មានន័យថារដ្ឋាភិបាលមិនអាចបែងចែកសិទ្ធិ ហើយជ្រើសរើសតែប្រភេទសិទ្ធិជាក់លាក់នោះទេ។ រដ្ឋាភិបាលត្រូវទទួលយកសិទ្ធិមនុស្សទាំងស្រុង ហើយមិនមែនគ្រាន់តែទទួលយកប្រភេទដែលបានបែងចែកពីគ្នានោះទេ។

- ***ពឹងអាស្រ័យគ្នាទៅវិញទៅមក*** ៖ មានន័យថាប្រភេទនីមួយៗនៃសិទ្ធិមិនអាចមានមុខងារឯករាជ្យនោះទេ៖ សិទ្ធិពលរដ្ឋជារឿយៗពឹងអាស្រ័យលើសិទ្ធិសង្គម ដែលសិទ្ធិសង្គមប្រហែលជាអាចពឹងអាស្រ័យលើសិទ្ធិនយោបាយ ដែលសិទ្ធិនយោបាយប្រហែលជាអាចពឹងអាស្រ័យលើសិទ្ធិសេដ្ឋកិច្ច។ ជាឧទាហរណ៍ សិទ្ធិទទួលបានការអប់រំ (ជាសិទ្ធិសង្គមមួយ) ត្រូវពឹងអាស្រ័យលើសេរីភាពក្នុងការដើរហើរដើម្បីទៅដល់សាលា (ដែលជាសិទ្ធិពលរដ្ឋ) ប៉ុន្តែការដើរហើរត្រូវពឹងផ្អែកលើការមានលុយគ្រប់គ្រាន់ ដូចជាសម្រាប់សំបុត្រឡានក្រុង (សិទ្ធិសេដ្ឋកិច្ច) ប៉ុន្តែដើម្បីជិះឡានបាន យើងត្រូវមានសុខភាពល្អ (សិទ្ធិសង្គម) ប៉ុន្តែការមានសុខភាពល្អប្រហែលជាអាចពឹងផ្អែកលើការទាមទារឲ្យរដ្ឋាភិបាលក្នុងការធានានូវសិទ្ធិរបស់ពលរដ្ឋ ក្នុងការទទួលបានសេវាថែទាំសុខភាព(សិទ្ធិនយោបាយ)។
- ***ទាក់ទងគ្នាទៅវិញទៅមក*** ៖ មានន័យថាសិទ្ធិជាច្រើនមានការទាក់ទងគ្នាទៅវិញទៅមកគ្រប់ប្រភេទ។ ជាឧទាហរណ៍ សិទ្ធិក្នុងការប្រជុំ(សិទ្ធិនយោបាយ) ក៏រួមបញ្ចូលផងដែរនូវសិទ្ធិក្នុងការចូលសហជីព (សិទ្ធិសេដ្ឋកិច្ច) និងសិទ្ធិជាផ្នែកមួយនៃជនជាតិភាគតិច (សិទ្ធិវប្បធម៌ និងសិទ្ធិពលរដ្ឋ)។ ស្រដៀងគ្នានេះ សិទ្ធិក្នុងការមានបុត្រធីតាគឺជាសិទ្ធិពលរដ្ឋ និងសិទ្ធិសង្គម(ដូចគ្នាចំពោះសិទ្ធិថែទាំសុខភាពផងដែរ)។ ទំនាក់ទំនងទៅវិញទៅមកនេះបង្ហាញយ៉ាងច្បាស់ថា សិទ្ធិមិនផ្តាច់មុខរវាងគ្នាទៅវិញទៅមកនោះទេ ប៉ុន្តែជាបណ្តាញមួយដែលពាក់ព័ន្ធ និងបំពេញបន្ថែមឲ្យគ្នាទៅវិញទៅមក។

ជំពូកនេះបានបង្ហាញនូវទស្សនៈ ទ្រឹស្តី និងការអះអាងជាច្រើនក្នុងការបង្ហាញពីដំណើរការរបស់សិទ្ធិមនុស្ស។ ទស្សនៈទាំងនេះបង្កើតជាមូលដ្ឋានចាំបាច់មួយ ក្នុងការស្វែងយល់ថាហេតុអ្វីបានជាសិទ្ធិមនុស្សមានសារៈសំខាន់ និងតើសិទ្ធិមនុស្សគួរត្រូវបានលើកកម្ពស់ និងការពារបានយ៉ាងដូចម្តេច។ ទស្សនៈជាច្រើនដែលបានបញ្ជាក់នៅទីនេះនឹងត្រូវបានពិភាក្សាបន្ថែមទៀតនៅក្នុងជំពូកក្រោយៗនៃសៀវភៅពុម្ពនេះ។

## ១.៩ ហេតុអ្វីត្រូវសិក្សាសិទ្ធិមនុស្ស

ការសិក្សាពីសិទ្ធិមនុស្ស មានសារៈសំខាន់ណាស់ពេលបច្ចុប្បន្នដោយមានហេតុផលមួយចំនួន។ ជំពូកទីមួយដំបូងនេះណែនាំពីមូលដ្ឋានទ្រឹស្តី នយោបាយ និងទស្សនៈវិជ្ជានៃសិទ្ធិ ហើយបានពន្យល់ពីទស្សនៈស្នូលមួយចំនួន។ យ៉ាងណាមិញ ត្រូវតែមានការចោទសួរ ហេតុអ្វីបានជាយើងត្រូវសិក្សាពីចំនុចនេះ និងថាតើនេះជាប្រធានបទមានសារៈប្រយោជន៍មួយ ឬជាប្រធានបទសម្រាប់ការស្រាវជ្រាវនៅសាកលវិទ្យាល័យ? ចម្លើយចំពោះសំណួរទាំងនេះគឺថា អាចទៅរួច។ ដើម្បីស្វែងយល់ពីហេតុផលដែលប្រជាជនមួយចំនួនមិនបានទទួលការការពារ និងសេរីភាពដូចគ្នា នឹងអ្នកដទៃ គឺទាមទារឲ្យមានស្វែងយល់កាន់តែស៊ីជម្រៅថែមទៀត លើថាតើសិទ្ធិមនុស្សមានដំណើរការយ៉ាងណា។ ចំនេះដឹងនេះ ពឹងផ្អែកលើការយល់ដឹងកាន់តែប្រសើរថែមទៀតពីថាតើសង្គមមានដំណើរការយ៉ាងណា ពីតម្លៃ និងជំនឿក្នុងសង្គមមួយ ហើយនឹងបរិបទនយោបាយ និងសេដ្ឋកិច្ចក្នុងការទាមទារ និងទទួលបានសិទ្ធិ។ សាកលវិទ្យាល័យ មានភារកិច្ចក្នុងការរួមចំនែកដល់ការអភិវឌ្ឍជាតិ ហើយត្រូវការអ្នកដែលមានជំនាញក្នុងដោះស្រាយបញ្ហាក្នុងការអភិវឌ្ឍ។ ការសិក្សាសិទ្ធិមនុស្សអាចរួមចំនែកបង្កើនប្រសិទ្ធិភាពដល់វិជ្ជាជីវៈជាច្រើន មិនថាជាមេធាវី គ្រូបង្រៀន នរវិទូ អ្នកវិទ្យាសាស្រ្តនយោបាយ ឬអ្នកបម្រើសេវាសង្គមនោះទេ។

មានហេតុផលជាច្រើនសម្រាប់សិក្សាសិទ្ធិមនុស្សនៅសាកលវិទ្យាល័យ ដែលត្រូវបានសង្ខេបដូចខាងក្រោមៈ

### ១.៩.១ ការអប់រំសិទ្ធិមនុស្សគឺជាសិទ្ធិមនុស្ស

ការអប់រំពីសិទ្ធិមនុស្សគឺជាសិទ្ធិមនុស្ស។ រដ្ឋាភិបាលត្រូវអប់រំប្រជាពលរដ្ឋរបស់ខ្លួនពីសិទ្ធិទាំងនេះ ជាការពិតណាស់សន្ធិសញ្ញាមួយចំនួន ដែលបានផ្តល់សច្ចាប័នដោយរដ្ឋាភិបាលនៅអាស៊ីអាគ្នេយ៍ (រួមមាន ICESCR និងCRC) កំណត់ថាការអប់រំសិទ្ធិមនុស្សគឺជាកាតព្វកិច្ច។ សិទ្ធិទាំងនេះមានដំណើរការទៅបានលុះត្រាតែបុគ្គលដឹងពីសិទ្ធិរបស់ខ្លួន ដូចនេះជម្រុញឲ្យពួកគាត់ទាមទារនូវសិទ្ធិទាំងនោះ។ ដូចដែលមានបញ្ជាក់ក្នុងសៀវភៅនេះ ចំនុចខ្សោយចម្បងក្នុងការការពារសិទ្ធិមនុស្សគឺប្រជាជនកង្វះខាតនូវការយល់ដឹងពីសិទ្ធិរបស់ពួកគេ។ ជាឧទាហរណ៍ សិស្សនិស្សិតដែលបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ មានចំនួនតិចតួចណាស់ដែលមានចំនេះដឹងពីសិទ្ធិមនុស្ស។ នេះបើនិយាយពីសិក្សាវិទ្យាល័យ កាន់តែមានតិចតួចជាងនេះទៀតដែលយល់ដឹងពីសិទ្ធិ

មនុស្ស។ សិស្សនិស្សិតនៅសាកលវិទ្យាល័យ អាចដើរតួនាទីយ៉ាងសំខាន់នៅពេលដែលពួកគេបញ្ចប់ការសិក្សា ហើយចាប់ផ្ដើមធ្វើការងារ ពួកគេត្រូវធ្វើការសម្រេចចិត្តដោយផ្អែកលើសិទ្ធិមនុស្ស។ នៅពេលសិស្សចូលរួមសកម្មភាពជាមួយនឹងរដ្ឋាភិបាល និងមន្ត្រីរដ្ឋាភិបាល (តាំងពីការបោះឆ្នោត រហូតដល់ការប្រជុំជាមួយនឹងអ្នកតំណាងតាមមូលដ្ឋាន) ពួកគេត្រូវកត់សម្គាល់ថាតើសិទ្ធិមនុស្សត្រូវបានគោរពដែរឬក៏អត់។ ការអប់រំរបស់សិស្សនិស្សិតនៅក្នុងវិស័យនេះ បង្កើតជារួមចំនែកដ៏សំខាន់ក្នុងដំណើរមុខងាររបស់ពលរដ្ឋក្នុងសង្គមឲ្យបានល្អប្រសើរ។

## ១.៩.២ ការពារជនងាយរងគ្រោះ

ប្រជាជនភាគច្រើនក្នុងសង្គមរស់នៅក្នុងជីវិតដែលមានសុវត្ថិភាព។ ផ្ទះរបស់ពួកគេត្រូវបានការពារមិនឲ្យអ្នកដទៃធ្វើឲ្យបាក់បែក ឬចូលបាននោះទេ។ ពួកគេកម្រជួបប្រទះនឹងការគម្រាមកំហែង ឬអំពើហិង្សាណាស់។ ពួកគេមានអាហារគ្រប់គ្រាន់ក្នុងការបរិភោគ ទឹកបរិភោគ និងកន្លែងសម្រាប់រស់នៅ។ នេះជាការពិតសម្រាប់សិស្សនិស្សិតមហាវិទ្យាល័យភាគច្រើន។ ប៉ុន្តែមិនមែនមនុស្សគ្រប់គ្នាមានសំណាងដូចនេះទាំងអស់នោះទេ។ មានក្រុមមនុស្សជាច្រើននៅក្នុងសង្គមអាស៊ីអាគ្នេយ៍ ដែលមិនមានការការពារប្រភេទនេះដូចជាជនភៀសខ្លួន ឬពលករទេសន្តប្រវេសន៍ ឬក៏ក្រុមជនជាតិភាគតិចដទៃទៀតកំពុងតែជួបប្រទះការរើសអើង។ បុគ្គលនីមួយៗមានសិទ្ធិមនុស្សដែលពួកគេមានតាំងពីកំណើត ហើយមិនមាននរណាម្នាក់អាចដកហូតបាននោះទេ។ យ៉ាងណាមិញ ប្រជាជនដែលរស់នៅជីវិតដែលល្អប្រសើរ និងមានសុវត្ថិភាព មិនអាចមើលឃើញពីតម្រូវការក្នុងការសិក្សាពីសិទ្ធិមនុស្សនោះទេ ពីព្រោះសិទ្ធិរបស់ពួកគេមិនត្រូវបានរំលោភបំពាន។ ជារឿយៗប្រជាជនមើលមិនឃើញការការពារដែលពួកគេទទួលពីព្រោះការការពារនេះមិនមានរូបរាង ហើយពួកគេសន្មតថាមនុស្សគ្រប់គ្នាទទួលបានការការពារនេះ និងមានសិទ្ធិក្នុងការទទួលបាន។ ទស្សនៈទូទៅមួយគឺថាការការពារជាអ្វីដែលសាមញ្ញធម្មតា ប៉ុន្តែការពិតគឺថាការការពារគឺជារឿងធម្មតាសម្រាប់អ្នកមួយចំនួននៅក្នុងស្ថានភាពជាក់លាក់មួយចំនួន។ ជាឧទាហរណ៍ប្រហែលជានៅពេលដែលមានវិបត្តិ ដូចជាបាតុភូតធម្មជាតិ ឬជម្លោះនយោបាយតែប៉ុណ្ណោះ ដែលប្រជាជនមានចំណាប់អារម្មណ៍លើសិទ្ធិមនុស្សដោយសារសុវត្ថិភាពរបស់ពួកគេ (និងសិទ្ធិរបស់ពួកគេ) អាចមានគ្រោះថ្នាក់ភ្លាមៗ។

សំណួរចម្បងដើម្បីចោទសួរគឺថា ហេតុអ្វីបានជាមនុស្សមួយចំនួនទទួលបានការការពារ ហើយអ្នកផ្សេងទៀតអត់? តើអ្នកដែលត្រូវបានគេគម្រាមកំហែងអាចត្រូវបានការពារយ៉ាងដូចម្ដេច? នៅក្នុងសង្គមអ្នកមានភាគច្រើន វាអាចជាការប្រឈមមួយដើម្បីឲ្យ

ប្រជាជនមួយក្រុមគិតថាហេតុអ្វីបានជាមនុស្សដទៃឃ្លាន មិនមានដំបូលដើម្បីជ្រក ឬមិនមានលទ្ធភាពក្នុងការទទួលបានទឹកស្អាត។

ប្រជាជនអាចមិនទទួលបានការការពារ ដោយសារហេតុផលមួយចំនួន។ ប្រហែលជាពួកគេត្រូវបានរើសអើង ឬអាចថាជាការពិបាកក្នុងការជួយដល់ពួកគេ ដោយសារពួកគេរស់នៅនៅកន្លែងឆ្ងាយពីរដ្ឋាភិបាល ឬពួកគេមិនត្រូវបានចាត់ទុកថាជាពលរដ្ឋ។ យ៉ាងណាមិញក្នុងករណីជាច្រើន វាមិនច្បាស់នោះទេថាហេតុអ្វីបានជាមនុស្សខ្លះ មិនទទួលបានការការពារ និងសេរីភាពដូចគ្នា នឹងអ្នកដទៃ ឬក៏ហេតុអ្វីអ្នកខ្លះងាយរងគ្រោះក្នុងការបាត់ការការពារនឹងសេរីភាពនេះម្ល៉េះ។

ប្រសិនបើសិស្សនិស្សិតចង់ស្វែងយល់ពីចំនុចនេះ ហើយចង់មានចំនេះដឹងល្អប្រសើរមួយពីតើថាសង្គមអាចការពារបុគ្គលទាំងនេះបានយ៉ាងដូចម្ដេច ពួកគេត្រូវតែយល់ថាតើសិទ្ធិមនុស្សមានដំណើរការយ៉ាងណា។ យើងទាំងអស់គ្នាអាចធ្វើសកម្មភាពក្នុងការលើកកម្ពស់សិទ្ធិមនុស្សសម្រាប់មនុស្សគ្រប់រូប រួមទាំងខ្លួនយើងផងដែរ។ គ្មានអ្នកណាម្នាក់ដឹងច្បាស់ថានៅពេលណាសិទ្ធិមនុស្សរបស់យើងត្រូវបានគម្រាមកំហែងនោះទេ។ ផ្ដល់ការយល់ដឹងជ្រៅជ្រះពីសិទ្ធិមនុស្សមិនធានានូវការការពារនោះទេ ប៉ុន្តែវាអាចជួយបានច្រើន។ ចំនេះដឹងពីសិទ្ធិទាំងនេះធ្វើសិស្សនិស្សិតមិនរំលោភបំពានសិទ្ធិទាំងនោះ។ ហើយពួកគេនឹងមិនអត់ឱនដល់អ្នកដែលរំលោភបំពានសិទ្ធិនោះទេ ហើយនឹងធ្វើការគាំទ្របន្ថែមទៀតដល់រដ្ឋាភិបាល ដែលគោរពដល់ការប្ដេជ្ញាចិត្តរបស់ពួកគេក្នុងការគោរពសិទ្ធិមនុស្ស។

# ១.៨.៣ សិទ្ធិមនុស្សធ្វើឲ្យមានការឃោគយល់ក្នុងតំបន់

តាមរយៈអង្គការប្រចាំតំបន់អាស៊ាន ប្រទេសនៅអាស៊ីអាគ្នេយ៍បានផ្ដួចផ្ដើមនូវការឆ្លើយតបប្រចាំតំបន់មួយទៅលើកង្វល់សិទ្ធិមនុស្ស។ បញ្ហាសិទ្ធិមនុស្សជាច្រើនកើតឡើងឆ្លងព្រំដែនរវាងប្រទេសនៅអាស៊ីអាគ្នេយ៍ ជាឧទាហរណ៍ ពលករទេសន្តប្រវេសន៍ និងការជួញដូរមនុស្ស។ ការឆ្លើយតបសកម្មបំផុតលើកង្វល់នេះមានប្រភពចេញពីតំបន់អាស៊ីអាគ្នេយ៍នេះផ្ទាល់តែម្តង ដែលក្នុងនោះសង្គមស៊ីវិលត្រូវបានគាំទ្រដោយក្រុមផ្សេងក្នុងតំបន់ដើម្បីធ្វើកិច្ចការនេះ។ សៀវភៅពុម្ពនេះនឹងក្រលេកមើលលើសិទ្ធិមនុស្សនៅកម្រិតថ្នាក់តំបន់ និងបង្ហាញពីទំនាក់ទំនង និងការប្រៀបធៀបបញ្ហាសិទ្ធិទូទាំងប្រទេសទាំង ១០ នៅអាស៊ាន។ សៀវភៅពុម្ពនេះនឹងផ្ដល់ជូនដល់សិស្សនិស្សិតនូវមូលដ្ឋានមួយលើទស្សនៈនៃសិទ្ធិមនុស្ស និងពីវិធីសាស្រ្តក្នុងការឆ្លើយតបនឹងបញ្ហាសិទ្ធិមនុស្សធ្ងន់ធ្ងរក្នុងតំបន់ពេលបច្ចុប្បន្ន។

នៅអាស៊ីអាគ្នេយ៍ពេលបច្ចុប្បន្ននេះ ប្រជាជនជួបប្រទះបញ្ហាប្រឈមជាច្រើន។ កុលសម្ព័ន្ធតំបន់ភ្នំ ប្រឈមនឹងការជម្លៀសចេញដោយសារគម្រោងវារីអគ្គីសនី ក្មេងៗត្រូវបានបង្ខំឲ្យធ្វើការ ស្ត្រីប្រឈមនឹងការរើសអើង និងអំពើហិង្សា កុមារពិការមិនមានលទ្ធភាពក្នុងការទទួលបានការអប់រំ បក្សប្រឆាំងនយោបាយត្រូវបានជាប់ពន្ធនាគារ ហើយពលករទេសន្តប្រវេសន៍ ប្រឈមនឹងការកេងប្រវ័ញ្ចនៅកន្លែងការងាររបស់ពួកគេ។ ការរៀបរាប់នេះបង្ហាញថាគ្រប់ប្រទេសទាំងអស់នៅអាស៊ីអាគ្នេយ៍ មានកង្វល់ចម្បងផ្សេងៗគ្នាពាក់ព័ន្ធនឹងសិទ្ធិមនុស្ស។ សាកលវិទ្យាល័យមិនគិតថា នេះជាបញ្ហាសិទ្ធិមនុស្សដែលពួកគេត្រូវដោះស្រាយនោះទេ ដោយសារកង្វះខាតការយល់ដឹងលើប្រទេសដទៃនៅអាស៊ីអាគ្នេយ៍ ឬ ដោយសារបញ្ហាទាំងអស់នេះត្រូវបានចាត់ទុកថា "ជារឿងនយោបាយ" ឬជាបញ្ហារសើបពេក។

កំពុងតែមានការផ្លាស់ប្តូរនៅអាស៊ីអាគ្នេយ៍ ហើយសិទ្ធិមនុស្សកំពុងក្លាយជារឿងសំខាន់។ អាស៊ានបានបញ្ជាក់នូវការប្តេជ្ញាចិត្តរបស់ខ្លួន ចំពោះការគោរពសិទ្ធិមនុស្សក្នុងឯកសារផ្សេងៗ។ កាលពីពេលថ្មីៗនេះ អាស៊ានបានបង្កើតស្ថាប័នថ្នាក់តំបន់មួយដែលបានព្រមព្រៀងលើសេចក្តីប្រកាសប្រចាំតំបន់ស្តីពីសិទ្ធិមនុស្ស។ សេចក្តីប្រកាស និងស្ថាប័ន AICHR អនុវត្តទស្សនៈដែលថាសិទ្ធិមនុស្សគួរតែត្រូវបានត្រួតពិនិត្យនៅថ្នាក់តំបន់។

## ១.៨.៤ ការអប់រំសិទ្ធិមនុស្សបន្ថែមតម្លៃដល់ចំនេះដឹងផ្សេងទៀត

ការសិក្សាសិទ្ធិមនុស្សជាមុខវិជ្ជាចម្រុះ ហើយផ្តល់ជូនសិស្សនិស្សិតនូវចំនេះដឹងមូលដ្ឋានមួយនៅក្នុងមុខវិជ្ជាជាច្រើននៅសាកលវិទ្យាល័យ។

- ច្បាប់៖ សិទ្ធិមនុស្សពាក់ព័ន្ធនឹងការការពារផ្លូវច្បាប់ដល់ប្រជាជន។ សិទ្ធិមនុស្សកើតចេញពីច្បាប់អន្តរជាតិ និងពាក់ព័ន្ធនឹងច្បាប់ជាតិរបស់ប្រទេសនៅអាស៊ីអាគ្នេយ៍។

- វិទ្យាសាស្ត្រនយោបាយ៖ សិទ្ធិមនុស្សបញ្ជាក់ពីវិធីដែលរដ្ឋគួរតែធ្វើការ ហើយតើកាតព្វកិច្ចប្រភេទណាដែលរដ្ឋមាន ហើយសកម្មភាពអ្វីដែលរដ្ឋគួរតែបំពេញដើម្បីក្លាយទៅជារដ្ឋាភិបាលដែលមានប្រសិទ្ធិភាពមួយ។

- សង្គមវិទ្យា៖ សិទ្ធិមនុស្សជួយឲ្យស្វែងយល់ពីសក្តានុពលនៃសង្គមដែលចាំបាច់សម្រាប់ទាំងការការពារសហគមន៍ និងការងារប្រឆាំងនឹងការរើសអើងតាមរយៈការផ្លាស់ប្តូរតម្លៃ និងជំនឿ(ដូចជាហិនភាពរបស់ស្ត្រី)។

- ទស្សនៈវិជ្ជា៖ សិទ្ធិមនុស្សកើតចេញពីទស្សនៈថាអ្វីជាសីលធម៌ និងអំពើល្អ។ មិនមានភ័ស្តុតាងវិទ្យាសាស្ត្រ ដែលថាសិទ្ធិមនុស្សបច្ចុប្បន្នជាការត្រឹមត្រូវនោះទេ ប៉ុន្តែទស្សនៈវិជ្ជាផ្សេងៗអំពីយុត្តិធម៌ ក្រម និងសីលធម៌ផ្តល់ហេតុផលថាហេតុអ្វីបានជាទស្សនៈវិជ្ជាទាំងនេះជាការត្រឹមត្រូវ ហើយថាហេតុអ្វីបានជាមនុស្សគួរតែប្រព្រឹត្តដាក់គ្នាទៅវិញទៅមកដោយការគោរព។

- សិទ្ធិមនុស្សក៏រួមបញ្ចូលផងដែរ នូវទំនាក់ទំនងអន្តរជាតិ ការសិក្សាពីសន្តិភាព សង្គមវិទ្យា និងនរវិទ្យា។

តាមរយៈការសិក្សាសិទ្ធិមនុស្ស សិស្សនិស្សិតនឹងទទួលបាននូវការយល់ដឹងបន្ថែមទៀតពីតើថាប្រជាជនមានទំនាក់ទំនងជាមួយនឹងរដ្ឋាភិបាល និងសហគមន៍តាមរយៈអ្វី។ សិស្សនឹងទទួលបាននូវចំនេះដឹងស៊ីជម្រៅផងដែរ ពីសមាជិកក្នុងសង្គមរបស់ពួកគេ និងការប្រឈមមួយចំនួនដែលប្រជាជនទាំងនេះជួបប្រទះ។ ចុងក្រោយសិស្សនិស្សិតនឹងទទួលបាននូវការយល់ដឹងចាំបាច់ក្នុងការវិភាគ និងរួមចំនែកក្នុងការវិវត្តន៍នៃសិទ្ធិមនុស្សក្នុងតំបន់។

# ក. សេចក្តីសង្ខេបពីជំពូក និងចំនុចគន្លឹះ

## តើសិទ្ធិមនុស្សជាអ្វី?

សិទ្ធិមនុស្សជាសិទ្ធិរបស់បុគ្គលមួយរូបមានដោយគ្រាន់តែមានលក្ខខណ្ឌ ជាមនុស្សប៉ុណ្ណោះ។ សិទ្ធិទាំងនេះចាប់ផ្តើមមានតាំងពីកំណើត ហើយមិនអាចដកហូតបាននោះទេ។ សិទ្ធិដទៃទៀត ដូចជាសិទ្ធិរបស់សិស្សនិស្សិត ឬសិទ្ធិរបស់ពលរដ្ឋ ត្រូវតែស្វែងរក ឬអាចបាត់បង់បាន ដូចនេះសិទ្ធិទាំងនេះខុសពីសិទ្ធិមនុស្ស។

សិទ្ធិមនុស្សត្រូវបានចាប់បង្ខំអនុវត្តដោយច្បាប់ ដូចនេះសិទ្ធិមនុស្សជាសិទ្ធផ្លូវច្បាប់។ សិទ្ធិមនុស្សក៏ជាសីលធម៌ផងដែរ ហើយជួយដល់សង្គមមួយក្នុងការមានដំណើរការកាន់តែល្អប្រសើរ ដូចនេះសិទ្ធិមនុស្សគឺជាសិទ្ធិសីលធម៌ និងសង្គម។ សិទ្ធិមនុស្សដាក់កាតព្វកិច្ចដល់រដ្ឋក្នុងការការពារប្រជាជននៅក្នុងប្រទេសរបស់ខ្លួន។ យ៉ាងណាមិញ ប្រជាជន ធុរកិច្ច សាកលវិទ្យាល័យ និងកងកម្លាំងប្រដាប់អាវុធក៏មានកាតព្វកិច្ចក្នុងការមិនរំលោភបំពានសិទ្ធិរបស់ប្រជាជនដទៃផងដែរ។

សាសនា វប្បធម៌ និងសង្គម ទាំងអស់នេះមានតម្លៃដែលផ្អែកលើសិទ្ធិពាក់ព័ន្ធនឹងការប្រព្រឹត្តលើមនុស្សជាតិ។ ចំពោះវប្បធម៌មួយចំនួន ទាំងនេះត្រូវបានចាត់ទុកថាជាផ្នែកមួយនៃ 'ច្បាប់ធម្មជាតិ' ប៉ុន្តែសិទ្ធិមនុស្សភាគច្រើនត្រូវបានសង្កេតឃើញថាជាសិទ្ធិមួយដែលត្រូវបានចែងជាលាយលក្ខអក្សរនៅក្នុងច្បាប់។

## ទស្សនៈជាមូលដ្ឋាន

សិទ្ធិមនុស្សស្ថិតក្នុងប្រភេទពិសេសមួយ ដោយសារសិទ្ធទាំងនេះមានលក្ខណៈជាសកល (មនុស្សគ្រប់រូបមានសិទ្ធិទាំងនេះ) (សិទ្ធិទាំងនេះមិនអាចបាត់បង់បាននោះទេ) ហើយត្រូវមានភ្ជាប់តាំងពីកំណើត (អ្នកខ្លះអាចទទួលបានដោយសារការកើតមកជាមនុស្ស)។

សិទ្ធិមនុស្សជាការធានាថាប្រជាជនមានជីវិតរស់នៅប្រកបដោយភាពថ្លៃថ្នូរ ដូចនេះពួកគេត្រូវបានគោរព និងទទួលបានការប្រព្រឹត្តល្អប្រសើរ ជាពិសេសដោយរដ្ឋ។ សិទ្ធិមនុស្សធានាផងដែរថាប្រជាជនត្រូវទទួលបានការប្រព្រឹត្តដោយស្មើភាព ដូចនេះប្រជាជនមិនត្រូវបានប្រព្រឹត្តមកលើផ្សេងៗគ្នា។

## ច្បាប់សិទ្ធិមនុស្ស

គោលបំណងនៃសិទ្ធិមនុស្ស គឺដើម្បីធានាថាប្រជាជនអាចរស់នៅក្នុងសង្គមមួយដែលមានការគោរពដល់នីតិរដ្ឋ។ ក្នុងគោលបំណងសម្រេចបានកិច្ចការនេះ បុគ្គលត្រូវដឹងពីច្បាប់ ហើយរដ្ឋត្រូវធានាថាច្បាប់ទាំងនេះត្រូវបានគោរព និងការពារដោយប៉ូលីស និងចៅក្រម ហើយថាច្បាប់ចាត់ទុកថាមនុស្សគ្រប់រូបគឺស្មើភាពគ្នា។ នេះជាកាតព្វកិច្ចមួយចំនួនរបស់រដ្ឋមួយដែលខ្លួនត្រូវតែធ្វើ ក្នុងការធានាប្រជាជនទទួលបានសិទ្ធិរបស់ពួកគេ។ កាតព្វកិច្ចភាគច្រើនពាក់ព័ន្ធជាមួយនឹងការការពារប្រជាជនពីអំណាចរបស់រដ្ឋ (ការការពារខ្សែឈរ) ប៉ុន្តែប្រជាជនត្រូវបានការពារមិនឲ្យសិទ្ធិរបស់ពួកគេត្រូវបានរំលោភបំពានដោយបុគ្គលដទៃ ឬស្ថាប័នដទៃ (ការការពារខ្សែដេក)នោះទេ។ ដើម្បីធ្វើដូចនេះរដ្ឋត្រូវ 'គោរព ការពារ និងបំពេញ' និង 'លើកកម្ពស់ ការពារ និងបង្ការ' សិទ្ធិមនុស្ស។

## ប្រភេទនៃសិទ្ធិ

សិទ្ធិមានចំនួនប៉ុន្មានប្រភេទផ្សេងៗគ្នា។ ប្រភេទដែលសំខាន់ជាងគេ ជារឿយៗត្រូវបានហៅថាសិទ្ធិជាមូលដ្ឋាន ហើយនេះរួមបញ្ចូលសិទ្ធិរស់រានមានជីវិត ឬសេរីភាពរួចផុតពីទាសភាព។ មានសិទ្ធិផ្លូវច្បាប់នៅក្នុងប្រព័ន្ធច្បាប់ផងដែរ ហើសិទ្ធិក្នុងសង្គមដែលត្រូវបានហៅថាសិទ្ធិពលរដ្ឋ។ មនុស្សក៏មានសិទ្ធិនយោបាយ ដូចជាសិទ្ធិក្នុងការបោះឆ្នោត សិទ្ធិសេដ្ឋកិច្ចដែលភាគច្រើនគ្រប់ដណ្តប់បញ្ហាការងារ សិទ្ធិសង្គមដែលជម្រុញ

ទឹកចិត្តដល់រដ្ឋាភិបាលក្នុងការផ្តល់សេវាកម្មសំខាន់ៗ ដូចជាការថែទាំសុខភាព និងការអប់រំ និងសិទ្ធិវប្បធម៌។

ចំពោះប្រវត្តិសម័យទំនើបភាគច្រើននៃសិទ្ធិ ប្រទេសជាច្រើនហាក់បីដូចជាយកចិត្តទុកដាក់លើប្រភេទសិទ្ធិមួយជាងប្រភេទដទៃ ហើយមានការអះអាងជាច្រើនថាប្រភេទណាមួយដែលមានសារៈសំខាន់ជាង។ នេះបណ្តាលមកពីសង្គ្រាមត្រជាក់ ប៉ុន្តែក៏ដោយសារអ្នកទ្រឹស្តីខាងសិទ្ធិផងដែរ ដែលចាត់ទុកសិទ្ធិថាមានភាពខុសៗគ្នាតាមចរិកលក្ខណៈ។ យ៉ាងណាមិញចាប់តាំងពីសេចក្តីប្រកាស និងផែនការសកម្មភាពទីក្រុងវីយែនក្នុងឆ្នាំ១៩៩៣ មានការទទួលស្គាល់ដោយទាំងភាគីរដ្ឋ និងតួអង្គសិទ្ធិមនុស្សថាគ្រប់ប្រភេទទាំងអស់មិនអាចបំបែកចេញពីគ្នាបាន (ប្រភេទណាមួយក៏ដោយមិនអាចត្រូវបានបំភ្លេច ឬមិនអើពើនោះទេ) ទាក់ទងគ្នាទៅវិញទៅមក(ប្រភេទទាំងអស់ត្រូវបានផ្សាភ្ជាប់គ្នា) និងពឹងអាស្រ័យគ្នាទៅវិញទៅមក (ប្រភេទទាំងអស់ពឹងអាស្រ័យលើប្រភេទផ្សេងទៀតទាំងអស់)។

## ហេតុអ្វីត្រូវសិក្សាសិទ្ធិមនុស្ស?

សិទ្ធិមនុស្សមានសារៈសំខាន់ក្នុងការសិក្សាស្វែងយល់ ដោយសារវាជាសិទ្ធិរបស់បុគ្គលម្នាក់ៗ ក្នុងការដឹងពីសិទ្ធិអ្វីដែលពួកគាត់មាន។ សិក្សាពីសិទ្ធិមនុស្សនឹងជួយការពារក្រុមងាយរងគ្រោះភាគច្រើនក្នុងសង្គមដូចជាកុមារ ឬជនពិការ បន្ថែមពីលើនេះទៀតការសិក្សាពីសិទ្ធិមនុស្សជាវិធីសាស្ត្រមួយក្នុងការស្វែងយល់ពីតំបន់អាស៊ាន។ ការអប់រំសិទ្ធិមនុស្សបន្ថែមតម្លៃលើចំនេះដឹងផ្សេង ហើយអាចជួយសិស្សនិស្សិតស្វែងយល់បន្ថែមពីច្បាប់ នយោបាយ សង្គមវិទ្យា ឬសូម្បីតែប្រវត្តិវិទ្យា។

# ខ.សំណួរ

## សំណួរប្រលង ឬសំណួរងាយស្រួល

- ប្រសិនបើប្រទេសមិនគោរពសិទ្ធិមនុស្ស តើមានហេតុផលអ្វីដែលគួរតែសិទ្ធិមនុស្សដែរឬទេ?
- តើអ្វីជាភាពខុសគ្នារវាងសិទ្ធិមនុស្ស និងប្រភេទផ្សេងទៀតនៃសិទ្ធិដូចជាសិទ្ធិរបស់ប្រជាពលរដ្ឋ ឬសិទ្ធិរបស់សិស្សនិស្សិត?

- តើសហគមន៍ និងវប្បធម៌ផ្សេងគ្នាគួរតែមានសិទ្ធិផ្សេងគ្នាដែរឬទេ ឬសិទ្ធិរបស់មនុស្សទាំងអស់ដូចគ្នា?

- ប្រសិនបើសិទ្ធិមនុស្សមានលក្ខណៈសកល តើវាជាការផ្ទុយគ្នាដែរឬទេដែលមានតែស្ត្រីដែលអាចទទួលបានសិទ្ធិស្ត្រី?
- តើកាតព្វកិច្ចវិជ្ជមាន ខុសគ្នាពីកាតព្វកិច្ចអវិជ្ជមានដូចម្តេចខ្លះ?
- តើអ្វីជាការការពារខ្សែដេក និងខ្សែឈរ ហើយតើហេតុអ្វីបានជាយើងត្រូវការការពារខ្សែដេក?

- តើអ្វីជាឧទាហរណ៍នៃសិទ្ធិមនុស្សដែលអវិភាគ ពឹងអាស្រ័យគ្នាទៅវិញទៅមកនិងទាក់ទងគ្នាទៅវិញទៅមក?

# គ. ឯកសារពិគ្រោះបន្ថែម

## អត្ថបទជាភាសាអង់គ្លេស

មានសៀវភៅពុម្ពស្រដៀងគ្នាជាច្រើន សៀវភៅពុម្ពខ្លះទទួលបានដោយមិនចាំបាច់បង់ថ្លៃ។ ការស្រាវជ្រាវតាមអ៊ិនធឺណែតដោយប្រើប្រាស់ពាក្យគន្លឹះនឹងអាចរកបាន អត្ថបទដែលមានខាងក្រោម។

## សៀវភៅពុម្ពទូទៅ
### អាចទាញយកបានដោយមិនចាំបាច់បង់ថ្លៃពីអ៊ិនធឺណែត៖


Benedek, W (ed.) 2008, *ស្វែងយល់ពីសិទ្ធិមនុស្ស ៖ សៀវភៅស្តីពីការអប់រំសិទ្ធិមនុស្ស* មជ្ឈមណ្ឌលស្រាវជ្រាវ និងបណ្តុះបណ្តាលសិទ្ធិមនុស្សអឺរ៉ុបនិងប្រជាធិបតេយ្យ, Graz.

Sepulveda, M & Gudmindsdóttir, GD 2004, *សៀវភៅយោងស្តីពីសិទ្ធិមនុស្ស* សាកលវិទ្យាល័យដើម្បីសន្តិភាព, ប្រទេសកូស្តារីកា.

OHCHR. (2001). សិទ្ធិមនុស្ស៖សៀវភៅមគ្គុទេសន៍មូលដ្ឋានសម្រាប់បុគ្គលិក UN ហ្សឺណែវ៖ OHCHR


## អាចរកទិញបាន


Alston, P & Ryan Goodman 2013, *សិទ្ធិមនុស្សអន្តរជាតិ.* Oxford: Oxford, University Press.

Clapham, A. 2007, *សិទ្ធិមនុស្ស៖ សេចក្តីផ្តើមដោយសង្ខេប។* Oxford University Press, Oxford.

Ishay, MR (ed.) 1997*អ្នកអានពីសិទ្ធិមនុស្ស៖ សំណេរតែងសេចក្តីនយោបាយសំខាន់ៗ សុន្ទរកថា និងឯកសារពីគម្ពីរសាសនារហូតដល់ពេលបច្ចុប្បន្ន។* Routledge, New York.

Ishay, MR 2004, *ប្រវត្តិសិទ្ធិមនុស្ស,* University of California Press, Berkeley.

Novak, M 2004, *សេចក្តីផ្តើមពីសិទ្ធិរបបសិទ្ធិមនុស្សអន្តរជាតិ*, Martinus, Boston.

Rahman, J 2003, *ច្បាប់សិទ្ធិមនុស្សអន្តរជាតិ៖ វិធីសាស្ត្រជាក់ស្តែង*, Longman, London.

Smith, Rhona 2007. *សិទ្ធិមនុស្សអន្តរជាតិ* , Oxford University Press, Oxford.

## គេហទំព័រ

www.ohchr.org

.

គេហទំព័រមានសារៈប្រយោជន៍មួយចំនួន រួមមានការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស ដែលមានអត្ថបទ និងឯកសារដែលមានសារៈប្រយោជន៍មួយចំនួន ទោះបីជាគេហទំព័រនេះបានប្រើប្រាស់ឯកសារផ្លូវការជាច្រើនរបស់ UN ពិបាកយល់ក៏ដោយ។

www.hrea.org.

ប្រភពមានសារៈប្រយោជន៍ផ្សេងទៀតគឺសមាគមអប់រំសិទ្ធិមនុស្ស (HREA) ដែលមានបណ្តាល័យអនឡាញធំមួយដែលមានអត្ថបទស្តីពីបញ្ហាសិទ្ធិមនុស្ស។

http://www1.umn.edu/humanrts

រាល់សន្ធិសញ្ញាដែលបានរៀបរាប់នៅក្នុងជំពូកនេះទាំងអស់មានអនឡាញ។ អាចស្រាវជ្រាវរកតាម Google ទោះបីជាប្រព័ន្ធទិន្នន័យធំៗមាននៅ OHCHR និងនៅបណ្តាល័យសាកលវិទ្យាល័យសិទ្ធិមនុស្សមីនីសូតា

2

# ស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ

សិទ្ធិមនុស្សកំណត់ពីស្តង់ដារជាក់លាក់ នៃការប្រព្រឹត្តមកលើមនុស្សជាតិ។ សិទ្ធិអាចមានភាពមិនច្បាស់លាស់ក្នុងការកំណត់ស្តង់ដារ (ជាឧទាហរណ៍ សេរីភាពរួចផុតពីទាសភាពមិនកំណត់និយមន័យនៃពាក្យ ″ទាសភាព″ នោះទេ) ឬអាចជាក់លាក់(ជាឧទាហរណ៍ គ្រប់កុមារទាំងអស់មានសិទ្ធិក្នុងការទទួលបានការអប់រំ ថ្នាក់បឋមសិក្សាដោយមិនចាំបាច់បង់ថ្លៃ និងជាការតម្រូវចាំបាច់) ស្តង់ដារទាំងនេះត្រូវបានបញ្ជាក់ក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ និងច្បាប់ជាតិដែលមានសង្គតភាព ដែលតាមរយៈនេះអត្ថន័យ និងវិសាលភាពនៃសិទ្ធិមនុស្សនីមួយៗត្រូវបានបញ្ជាក់ច្បាស់។

**ស្តង់ដារសិទ្ធិមនុស្ស**
ពាក្យថា"ស្តង់ដារសិទ្ធិមនុស្ស" សំដៅលើកម្រិតនៃគុណភាពជីវិតដែលត្រូវតែបំពេញតាមច្បាប់។ ជាឧទាហរណ៍ "ស្តង់ដារជីវភាព" សំដៅលើកម្រិតដែលមនុស្សអាចមានគុណភាពជីវិតមួយ សិទ្ធិស្តង់ដារជីវភាពរបស់មនុស្សគឺជារឿងចាំបាច់ (ដូចជាចំណីអាហារ ទឹក លំនៅដ្ឋាន ។ល។) ដែលមនុស្សត្រូវការដើម្បីឆ្លើយតបនឹងសិទ្ធិមនុស្សរបស់ខ្លួន។

ជំពូកបន្ទាប់នឹងបញ្ជាក់ពីចំនួននៃស្តង់ដារទាំងនេះ ហើយផ្តល់នូវការយល់ដឹងមួយពីស្តង់ដារ និងពីវិធីក្នុងការបកស្រាយ ឬវាស់វែងស្តង់ដារទាំងនេះ។ កម្មវត្ថុនេះ គឺដើម្បីផ្តល់ជូនអ្នកអាននូវទិដ្ឋភាពទូទៅជាមូលដ្ឋានមួយ នៃស្តង់ដារសំខាន់ៗមួយចំនួននៃការប្រព្រឹត្តដែលមនុស្សគួរតែរំពឹងក្នុងការទទួលបានពីរដ្ឋាភិបាល និងសង្គមរបស់ខ្លួន។

**ពាក្យថាស្តង់ដារ** ក្រលេកទៅមើលឯកសារសិទ្ធិមនុស្សដំបូង (UDHR) ដែលបានចែងនៅក្នុងបុព្វកថា ថាសិទ្ធិមនុស្សគឺជា "ស្តង់ដារទូទៅនៃការសម្រេចបានសម្រាប់គ្រប់ប្រជាជន និងប្រជាជាតិទាំងអស់" ហើយថាគ្រប់បុគ្គលទាំងអស់ និងគ្រប់ស្ថាប័នរបស់សង្គមទាំងអស់ "ត្រូវព្យាយាមឲ្យអស់លទ្ធភាព....ក្នុងការធានានូវភាពជាសកល និងការទទួលស្គាល់ និងប្រតិបត្តិដោយប្រសិទ្ធិភាពលើសិទ្ធិមនុស្សទាំងនេះ"។

**កតិកាសញ្ញា**
នេះសំដៅលើកិច្ចព្រមព្រៀង ឬការសន្យាដែលចងកាតព្វកិច្ចរវាងមនុស្ស និងថាជាកិច្ចព្រមព្រៀងជាប្រវត្តិសាស្រ្ត។ នៅពេលដែលសន្ធិសញ្ញាសិទ្ធិមនុស្សចម្បងៗទាំងពីរគឺ ICCPR និង ICESCR ត្រូវបានព្រាង។ ឯកសារទាំងពីរនេះត្រូវបានហៅថាជាកតិកាសញ្ញា មិនមែនសន្ធិសញ្ញា ឬអនុសញ្ញានោះទេដោយសារ តែសារៈសំខាន់របស់វា។ មានសន្ធិសញ្ញាតិចប៉ុណ្ណោះដែលត្រូវបានហៅថាជាកតិកាសញ្ញា។

ស្តង់ដារសិទ្ធិមនុស្ស ជាកម្រិតដែលបានតម្រូវជាអប្បរមា ដែលរដ្ឋមិនគួរអនុវត្តទាបជាងស្តង់ដារនេះនោះទេ។ សិទ្ធិមនុស្សគឺជាការធានានូវស្តង់ដារអប្បរមា។ ដូចដែលបានបញ្ជាក់ សិទ្ធិមនុស្សជាកម្រាលខាងក្រោម មិនមែនជាពិដានខាងលើនោះទេ សិទ្ធិមនុស្សកំណត់ពីបាតខាងក្រោម មិនមែនចំនុចកំពូលនោះទេ។

ការបង្កើតច្បាប់សិទ្ធិមនុស្សអន្តរជាតិក្នុងទម្រង់ជា **សន្ធិសញ្ញាអន្តរជាតិ** ជាការឆ្លើយតបមួយទៅនឹងអំណាចដែលគ្មានការត្រួតពិនិត្យ។ សន្ធិសញ្ញាអន្តរជាតិបានបង្កើតវិធាន និងស្តង់ដារពីវិធីសាស្រ្តដែលរដ្ឋគួរតែប្រព្រឹត្តិលើប្រជាជន ហើយពីវិធីសាស្រ្តដែលប្រជាជនគួរប្រព្រឹត្តដាក់គ្នាទៅវិញទៅមក។ យ៉ាងណាមិញ សន្ធិសញ្ញាអន្តរជាតិមិនអាចត្រូវបានចាប់បង្ខំចំពោះរដ្ឋមួយនោះទេ។ សកម្មភាពនៃការព្រមព្រៀងលើសន្ធិសញ្ញាមួយគឺស្ទើរតែជាការស្ម័គ្រចិត្តទាំងស្រុង (ទោះបីជាអ្នកខ្លះអះអាងថារដ្ឋដែលចាញ់សង្គ្រាម ឬរដ្ឋទន់ខ្សោយម្តងម្កាលត្រូវបានបង្ខំឲ្យចុះហត្ថលេខាលើសន្ធិសញ្ញាក៏ដោយ)។ ក្នុងន័យម្យ៉ាងទៀត រដ្ឋមួយត្រូវតែយល់ព្រម និងទទួលយកកាតព្វកិច្ចដោយឆន្ទៈរបស់ខ្លួនចំពោះសន្ធិសញ្ញាមួយ។ នៅពេលដែលរដ្ឋព្រមព្រៀង រដ្ឋទាំងនោះត្រូវបានហៅថាជា "រដ្ឋភាគី" នៃសន្ធិសញ្ញា ហើយពួកគេចងកាតព្វកិច្ចទៅនឹងផលវិបាកដោយសារការខកខានក្នុងការបំពេញកាតព្វកិច្ចនៃសន្ធិសញ្ញា។ នៅក្នុងសន្ធិសញ្ញាទាំងនេះដែលសិទ្ធិមនុស្សត្រូវបានកំណត់និយមន័យ និងបញ្ជាក់ពិស្តារ។ មានឈ្មោះខុសៗគ្នាចំនួនបួនដែលនឹងលេចឡើងក្នុងសៀវភៅពុម្ពនេះ **កតិកាសញ្ញា អនុសញ្ញា ធម្មនុញ្ញ និងពិធីសារ** ដែលទាំងអស់នេះជាសន្ធិសញ្ញា។ សន្ធិសញ្ញាទាំងអស់ មិនពាក់ព័ន្ធនឹងឈ្មោះនោះទេ គឺមានកាតព្វកិច្ច និងអំណាចផ្លូវច្បាប់ដូចគ្នា។

**ធម្មនុញ្ញ**
ជារឿយៗនេះត្រូវបានប្រើប្រាស់ក្នុងការបង្កើតស្ថាប័នអន្តរជាតិ ជាឧទាហរណ៍ ធម្មនុញ្ញអង្គការសហប្រជាជាតិ (១៩៤៥)។ពាក្យស្រដៀងគ្នានេះមាន "ប្រការនៃការព្រមព្រៀង" (ជាឧទាហរណ៍ ធនាគារពិភពលោក និង IMF ត្រូវបានបង្កើតឡើងដោយប្រការនៃការព្រមព្រៀងរវាងរដ្ឋ)។

**អនុសញ្ញា**
នេះប្រហែលជាឈ្មោះទូទៅពេញនិយមមួយចំពោះសន្ធិសញ្ញា។ ប្រាំពីរក្នុងចំណោមសន្ធិសញ្ញាសិទ្ធិមនុស្សមានឈ្មោះថាជាអនុសញ្ញា។

មានប្រភេទផ្សេងទៀតនៃឯកសារអន្តរជាតិដែលបានចុះហត្ថលេខាដោយប្រជាជាតិ។ ទាំងនេះមិនមែនជាសន្ធិសញ្ញានោះទេ ដោយសារពួកគេមិនចងកាតព្វកិច្ចផ្លូវច្បាប់។

**ពិធីសារ**
នេះជាទូទៅជាឧបសម្ព័ន្ធនៃសន្ធិសញ្ញាដទៃ។ ពិធីសារអាចបន្ថែមមាត្រា ឬសិទ្ធិបន្ថែម (ដូចជាពិធីសារស្តីពីទាហានជាកុមារ

ជាឧទាហរណ៍ "កតិកាសញ្ញា" "កិច្ចព្រមព្រៀងសន្តិភាព" "កិច្ចព្រមព្រៀង" និង "សេចក្តីថ្លែងការណ៍ជាផ្លូវការណ៍" អាចចង ឬមិនចងកាតព្វកិច្ច ដោយផ្អែកលើពាក្យពេចន៍នៃឯកសារ។ ដូចដែលបានបញ្ជាក់ពិស្តារ UDHR គឺជាសេចក្តីប្រកាសមួយ មិនមែនជាសន្ធិសញ្ញានោះទេ។ សេចក្តីប្រកាសអាចដូចគ្នាទៅនឹងសន្ធិសញ្ញា ប៉ុន្តែវាមិនចងកាតព្វកិច្ចតាមផ្លូវច្បាប់ដូចគ្នានោះទេ។ សេចក្តីប្រកាសដែលមានភាពល្បីល្បាញមួយទៀតក្នុងវិស័យសិទ្ធិមនុស្សរួមមានសេចក្តីប្រកាស និងផែនការសកម្មភាពទីក្រុងវីយែន (១៩៩៣)។

សេចក្តីសម្រេច និងឯកសារលទ្ធផលសន្និសិទពង្រីកនូវមែកធាងនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ UN បានដាក់ចេញនូវសេចក្តីសម្រេចលើបញ្ហាជាច្រើន។ សេចក្តីសម្រេចដែលចេញពីមហាសន្និបាតមិនចងកាតព្វកិច្ចឡើយ ប៉ុន្តែភាគច្រើនជាសេចក្តីថ្លែងហេតុ។ ដូចនេះ ការរំលោភបំពានលើសេចក្តីសម្រេចបែបនេះនឹងមិនមានផលវិបាកចំពោះរដ្ឋឡើយ។ យ៉ាងណាមិញ សេចក្តីសម្រេចពីក្រុមប្រឹក្សាសន្តិសុខអាចចងកាតព្វកិច្ច ហើយអាចបញ្ជាឲ្យរដ្ឋធ្វើសកម្មភាព ឬបញ្ឈប់សកម្មភាពជាក់លាក់ណាមួយ។ ជាទូទៅ សន្និសិទអន្តរជាតិដែលមានការចូលរួមពីរដ្ឋ (ដូចជាសន្និសិទស្តីពីបរិស្ថាន ឬសន្និសិទពិភពលោកដើម្បីបញ្ចប់ការរើសអើងពូជសាសន៍ជាដើម) នឹងមានបង្កើតឯកសារលទ្ធផល ដែលមិនចងកាតព្វកិច្ចផ្លូវច្បាប់ ប៉ុន្តែមានសារៈសំខាន់ក្នុងការស្នើរបៀបវារៈ ឬកំណត់ពីទស្សនៈទាន។

នៅពេលដែលប្រព័ន្ធសិទ្ធិមនុស្សអន្តរជាតិបានចាប់ផ្តើមដោយ UN ស្ថាប័ននេះបានដំណើរការនូវសកម្មភាពដែលត្រូវបានពង្រីកតាមពេលវេលា ដូចជាកម្រងច្បាប់ដែលមានការអភិវឌ្ឍមួយក្នុងការកំណត់និយមន័យសិទ្ធិមនុស្ស ស្ថាប័នដែលមានការកើនឡើងក្នុងការតាមដានសិទ្ធិមនុស្ស ហើយនឹងចំនួនកើនឡើងនៃមធ្យោបាយក្នុងការឆ្លើយតបចំពោះរដ្ឋដែលរំលោភបំពានសិទ្ធិទាំងនោះ។ ជំពូកបន្ទាប់នឹងត្រួតពិនិត្យកម្រងច្បាប់នេះនៅកម្រិតអន្តរជាតិ ហើយនឹងត្រូវពិនិត្យថាតើច្បាប់ទាំងនេះ ត្រូវបានការពារដោយស្ថាប័នអន្តរជាតិ (ដូចជា UN) ស្ថាប័នតំបន់ (ដូចជាស្ថាប័នសិទ្ធិមនុស្សអាស៊ាន AICHR) និងស្ថាប័នថ្នាក់ជាតិ (ដូចជាគណៈកម្មាការសិទ្ធិមនុស្សជាតិ) យ៉ាងដូចម្តេច។

# ការពិភាក្សា និងការជជែកវែកញែក

## តើសិទ្ធិមនុស្សមានជម្លោះជាមួយនឹងអធិបតេយ្យភាពរដ្ឋយ៉ាងដូចម្តេច?

មុនពេលការបង្កើតច្បាប់សិទ្ធិមនុស្សអន្តរជាតិ ច្បាប់អន្តរជាតិភាគច្រើនគ្រប់គ្រងទំនាក់ទំនងរវាងរដ្ឋដែលមានអធិបតេយ្យភាព។ គោលការណ៍នេះនៅតែតឹងរឹងក្នុងនយោបាយអន្តរជាតិ ហើយដែលមាននៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ(មាត្រា ២.៧) ដែលបានចែងថា“មិនមានបញ្ញត្តិអ្វីនៅក្នុងធម្មនុញ្ញនេះអនុញ្ញាតឲ្យអង្គការសហប្រជាជាតិក្នុងការជ្រែកជ្រៀតក្នុងបញ្ហាដែលយុត្តាធិការជាតិរបស់រដ្ឋមួយនោះទេ”។

***ប៉ុន្តែតើបញ្ញត្តិនេះទុកសិទ្ធិមនុស្សចោលនៅកន្លែងណា?*** តើនេះមានន័យថា UN មិនគួរអន្តរាគមន៍ក្នុងបញ្ហាសិទ្ធិមនុស្សនៅក្នុងប្រទេសមួយទេមែនទេ? ជាឧទាហរណ៍ យើងអាចអះអាងថាមធ្យោបាយដែលប្រទេសមួយដំណើរការមន្ទីរពេទ្យ ឬសាលារៀនត្រូវបានចាត់ទុកថាជារឿងផ្ទៃក្នុងរបស់រដ្ឋ ដូចនេះតើ UN ឬរដ្ឋណាមួយអាចត្រូវបានអនុញ្ញាតក្នុងការរិះគន់ ឬលើកជាសំណើរបានដែរឬទេ? ប្រសិនជាប្រទេសមួយអនុម័តច្បាប់ដើម្បីហាមឃាត់ក្មេងស្រ្តីមិនឲ្យចូលរៀន តើរដ្ឋដទៃអាចអន្តរាគមន៍បានដែរឬទេ? ម្យ៉ាងទៀត ប្រសិនបើរដ្ឋាភិបាលមួយត្រូវបានបោះឆ្នោតជ្រើសរើសតាមប្រជាធិបតេយ្យដោយប្រជាជនរបស់ខ្លួនដើម្បីគ្រប់គ្រង រដ្ឋាភិបាលនោះគួរតែមានសមត្ថកិច្ចនិងធម្មានុភាពក្នុងការសម្រេចពីគោលនយោបាយជាតិ។ ម្យ៉ាងវិញទៀត តាមរយៈការព្រមព្រៀងលើសន្ធិសញ្ញាសិទ្ធិមនុស្ស រដ្ឋមួយបានជ្រើសរើសដោយស្ម័គ្រចិត្តក្នុងការអនុលោមតាមស្តង់ដារច្បាប់ដែលមានចែងក្នុងសន្ធិសញ្ញានោះ។

បន្ទាត់បែងចែងរវាងបញ្ហាជាតិក្រោមអធិបតេយ្យរបស់រដ្ឋ និងស្តង់ដារសិទ្ធិមនុស្សអន្តរជាតិជាប្រធានបទនៃការជជែកវែកញែកក្នុងសិទ្ធិមនុស្ស។ ជារឿយៗរដ្ឋនឹងអះអាងពីអំពើមួយថាជាសិទ្ធិអធិបតេយ្យរបស់ខ្លួន ខណៈពេលដែលសហគមន៍អន្តរជាតិនឹងអះអាងថាគួរតែមានការឆ្លើយតបនឹងស្តង់ដារអន្តរជាតិ មិនពាក់ព័ន្ធនឹងអធិបតេយ្យភាពនោះទេ។

## ២.១ ច្បាប់អន្តរជាតិសាធារណៈ ៖ មូលដ្ឋានគ្រឹះ

សិទ្ធិមនុស្សជាផ្នែកមួយនៃច្បាប់ថ្នាក់ជាតិ (ដែលត្រូវបានហៅថាច្បាប់ក្នុងស្រុក) ជាឧទាហរណ៍ រដ្ឋធម្មនុញ្ញ ច្បាប់សិទ្ធិមនុស្ស ឬច្បាប់ដទៃ និងក្នុងច្បាប់អន្តរជាតិផងដែរ ជាឧទាហរណ៍ក្នុងសន្ធិសញ្ញា។ នៅកម្រិតអន្តរជាតិច្បាប់សិទ្ធិមនុស្សកើតឡើងជាផ្នែកមួយនៃច្បាប់អន្តរជាតិសាធារណៈ (PIL) ដែលពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ និងអំពើរបស់រដ្ឋអធិបតេយ្យ និងអង្គការអន្តរជាតិ។ ទោះបីជាការអភិវឌ្ឍភាគច្រើននៃស្តង់ដារសិទ្ធិមនុស្សកើតមាននៅកម្រិតអន្តរជាតិក៏ដោយ ស្តង់ដារទាំងនេះទំនងជាត្រូវបានចាប់បង្ខំអនុវត្តនៅកម្រិតថ្នាក់ជាតិផងដែរ។ ខណៈពេលដែលច្បាប់អន្តរជាតិ និងច្បាប់ក្នុងស្រុកមានភាពខុសគ្នា ច្បាប់ទាំងពីរនេះមានគោលការណ៍ស្រដៀងគ្នា។ ជាការចាំបាច់ក្នុងការដោះស្រាយនូវភាពខុសគ្នារវាងច្បាប់ក្នុងស្រុក និងច្បាប់អន្តរជាតិដើម្បីពន្យល់ពីរបៀបដែលសិទ្ធិមនុស្សត្រូវបានបង្កើត និងចាប់បង្ខំអនុវត្ត។

ភាពខុសគ្នាចម្បងរវាងច្បាប់កម្រិតថ្នាក់ជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងវិធីដែលច្បាប់ត្រូវបានតាក់តែង ហើយថាតើច្បាប់ទាំងនេះត្រូវបានការពារយ៉ាងដូចម្តេច។ ច្បាប់ក្នុងស្រុកត្រូវបានតាក់តែងឡើងដោយស្ថាប័ននីតិបញ្ញត្តិ ទទួលយកដោយស្ថាប័ននីតិប្រតិបត្តិ ហើយចាប់បង្ខំអនុវត្តដោយស្ថាប័នតុលាការ។ ឧទាហរណ៍សាមញ្ញមួយមានដូចតទៅ៖ សភាធ្វើច្បាប់មួយ ប៉ូលីសចាប់អ្នកដែលរំលោភច្បាប់ ហើយតុលាការជាអ្នកកំណត់ពីទោស និងភាពគ្មានទោសរបស់បុគ្គលម្នាក់ ដាក់ទណ្ឌកម្មបុគ្គលនោះប្រសិនបើត្រូវបានស្វែងរកឃើញថាមានទោស។ ជាពិសេស ពលរដ្ឋនៃប្រទេសមួយដែលជាកម្មវត្ថុនៃច្បាប់ទាំងនេះមានធាតុចូលតិចតួចក្នុងការព្រាង និងអនុវត្តច្បាប់ទាំងនេះ។ នេះខុសគ្នាក្នុងច្បាប់អន្តរជាតិ។ រដ្ឋតាក់តែងច្បាប់ដោយខ្លួនឯង ហើយពួកគេជាកម្មវត្ថុនៃច្បាប់នេះ។ យ៉ាងណាមិញ ប្រសិនបើរដ្ឋមួយមិនពេញចិត្តលើផ្នែកមួយនៃច្បាប់ មិនមានអ្នកណាម្នាក់អាចបង្ខំរដ្ឋក្នុងការព្រមព្រៀងលើផ្នែកនេះនោះទេ (ទោះបីជាមានការលើកលែងមួយចំនួន ដូចជាច្បាប់ទំនៀមទំលាប់ដែលបានបញ្ជាក់ខាងក្រោមក៏ដោយ)។ ដូចនេះប្រព័ន្ធច្បាប់អន្តរជាតិមានចរិកលក្ខណៈជាការស្ម័គ្រចិត្ត។ បន្ថែមពីលើនេះមិនមានកម្លាំងប៉ូលីសអន្តរជាតិដែលការពារច្បាប់ និងធានានូវការអនុលោមនោះទេ (ជាថ្មីម្តងទៀតមានការលើកលែងមួយចំនួន ដូចជាក្រុមប្រឹក្សាសន្តិសុខ UN ប៉ុន្តែសមត្ថភាពរបស់ក្រុមប្រឹក្សានេះបើប្រៀបធៀបទៅនឹងប៉ូលីសរបស់រដ្ឋ គឺនៅមានភាពទន់ខ្សោយ)។

ជាទូទៅ រដ្ឋព្រាងច្បាប់ដែលពួកគេចង់ចងកាតព្វកិច្ច ហើយកំណត់ផងដែរពីវិធីសាស្ត្រដោះស្រាយវិវាទ។ ផលវិបាកគឺថាខណៈពេលដែលច្បាប់ជាតិអាចត្រូវបានអនុវត្តតាមរយៈស្ថាប័នមានអំណាច (ដូចជាប៉ូលីស និងតុលាការ) ច្បាប់អន្តរជាតិមានការបើកចំហចំពោះការបកស្រាយ និងការចរចារ។ និយាយជារួម ក្នុងច្បាប់អន្តរជាតិ មិនមានស្ថាប័នធ្វើច្បាប់តែមួយនោះទេ (ដូចជាសភា) ហើយក៏មិនមានអ្នកចាប់បង្ខំអនុវត្តច្បាប់ដែលមានអំណាចនោះដែរ (ដូចជាប៉ូលីស) ឬតុលាការមួយដែលរាល់វិវាទទាំងអស់ត្រូវបានបញ្ជូនទៅនោះទេ។

ទោះបីជាប្រព័ន្ធច្បាប់ទាំងពីរនេះខុសគ្នាជាចម្បងក៏ដោយ ប្រព័ន្ធទាំងពីរនេះមិនប្រតិបត្តិការដោយឯករាជ្យពីគ្នានោះទេ។ ច្បាប់ជាតិអាចមានឥទ្ធិពលលើច្បាប់អន្តរជាតិ។ ជាឧទាហរណ៍ ច្បាប់អន្តរជាតិ ស្តីពីសេរីភាពក្នុងការបញ្ចេញដែលបានលេចឡើងជាដំបូងក្នុង UDHR ដែលត្រូវបានចម្លងចេញពីរដ្ឋធម្មនុញ្ញរបស់សហរដ្ឋអាមេរិក។ សិទ្ធិភាគច្រើនសម្រាប់ជនពិការជាដំបូង មាននៅក្នុងច្បាប់ស្តីពីជនពិការរបស់ប្រទេសផ្សេងៗ។ ភាពបញ្ច្រាសគ្នាគឺមានភាពសាមញ្ញៈ ច្បាប់អន្តរជាតិមានឥទ្ធិពលលើច្បាប់ជាតិ។ ជាឧទាហរណ៍ ស្តង់ដារសិទ្ធិមនុស្សអាចត្រូវបានប្រែក្លាយទៅជាច្បាប់ជាតិ ហើយក្នុងប្រទេសខ្លះ ច្បាប់អន្តរជាតិត្រូវបានចាត់ទុកថាស្មើគ្នានឹងច្បាប់ជាតិ។ នេះជាប្រព័ន្ធឯកនិយមៈ ឯកមានន័យថា 'មួយ' ដូចនេះ មានតែប្រព័ន្ធច្បាប់មួយ ដែលរួមបញ្ចូលច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ ប្រព័ន្ធទ្វិកនិយម កើតមានឡើងនៅពេលដែលប្រព័ន្ធច្បាប់ពីរត្រូវបានញែកដាច់ពីគ្នា ដូចនេះច្បាប់អន្តរជាតិមិនអាចត្រូវបានប្រើប្រាស់ក្នុងប្រព័ន្ធជាតិ ដោយមិនទាន់បានប្រែក្លាយទៅជាច្បាប់ជាតិជាមុនសិននោះទេ។

កន្លងមក ការពិភាក្សាបានផ្តោតសំខាន់លើសន្ធិសញ្ញាថាជាប្រភពចម្បងនៃច្បាប់អន្តរជាតិឬក៏យ៉ាងណា។ យ៉ាងណាមិញ មានប្រភពផ្សេងទៀត ហើយការប្រើប្រាស់សន្ធិសញ្ញាក្នុងការកំណត់និយមន័យច្បាប់អន្តរជាតិ ជាបាតុភូតកាលពីពេលថ្មីៗនេះ ជាពិសេសបន្ទាប់ពីក្រោយសង្គ្រាមលោកលើកទីពីរ។

# ២.២ ប្រភពច្បាប់អន្តរជាតិ

**សន្ធិសញ្ញា** ជាកិច្ចព្រមព្រៀងរវាងរដ្ឋ។ សន្ធិសញ្ញាមានទម្រង់ជាលាយលក្ខអក្សរ ហើយត្រូវបានបង្កើតបន្ទាប់ពីការចរចាររវាងរដ្ឋដែលពាក់ព័ន្ធ។ នៅពេលដែលរដ្ឋមួយបានព្រមព្រៀងធ្វើជាភាគីសន្ធិសញ្ញាមួយ រដ្ឋនោះត្រូវតែគោរពវិធានដែលមាននៅក្នុងសន្ធិសញ្ញានោះ។ យ៉ាងណាមិញ មានតែភាគីនៃសន្ធិសញ្ញាមួយប៉ុណ្ណោះត្រូវបានចងកាតព្វកិច្ចដោយវិធាននៃសន្ធិសញ្ញានោះ។ កិច្ចព្រមព្រៀងទ្វេភាគីកើតមានរវាងរដ្ឋពីរ។ សន្ធិសញ្ញាពហុភាគីកើតឡើងរវាងរដ្ឋច្រើនពីរឡើងទៅ។ អង្គការសហប្រជាជាតិ ដូចជាអង្គការសហប្រជាជាតិ (UN) អង្គការអន្តរជាតិខាងការងារ (ILO) អង្គការពាណិជ្ជកម្មពិភពលោក (WTO) និងសហភាពអឺរ៉ុប (EU) ត្រូវបានបង្កើតឡើងដោយសន្ធិសញ្ញាពហុភាគី។ តួនាទីចម្បងមួយនៃ UN គឺការព្រាងនូវសន្ធិសញ្ញាទាំងនេះ ដែលរដ្ឋនីមួយៗត្រូវបានអញ្ជើញឲ្យចុះហត្ថលេខា។ សន្ធិសញ្ញាជាប្រភពសំខាន់បំផុតនៃច្បាប់អន្តរជាតិពេលបច្ចុប្បន្ន ដោយសារសន្ធិសញ្ញាទាំងនេះត្រូវបានកំណត់ច្បាស់លាស់ជាងប្រភពដទៃ។ លើសពីនេះទៀត រដ្ឋដែលបានចូលរួមក្នុងការព្រាងច្បាប់មួយ រដ្ឋនោះនឹងមានភាពរីករាយក្នុងការអនុលោមតាមច្បាប់នោះ ហើយនឹងមានចំនេះដឹងសុក្រិតពីច្បាប់នោះ។

**សន្ធិសញ្ញា**
សន្ធិសញ្ញាគឺជាកិច្ចព្រមព្រៀងដែលត្រូវបានគ្រប់គ្រងដោយច្បាប់អន្តរជាតិរវាងរដ្ឋ ដែលបង្កើតជាកាតព្វកិច្ចផ្លូវច្បាប់លើរដ្ឋទាំងនោះដែលព្រមព្រៀងដោយស្ម័គ្រចិត្តក្នុងការចងកាតព្វកិច្ចដោយសន្ធិសញ្ញានេះ។ ច្បាប់នៃការបកស្រាយសន្ធិសញ្ញាត្រូវបានគ្រប់គ្រងដោយអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា (១៩៦៩)។ អនុសញ្ញានេះ កំណត់និយមន័យសន្ធិសញ្ញាថា "ជាកិច្ចព្រមព្រៀងអន្តរជាតិដែលបានព្រមព្រៀងរវាងរដ្ឋជាទម្រង់លាយលក្ខអក្សរ និងត្រូវបានគ្រប់គ្រងដោយច្បាប់អន្តរជាតិ"។

## ទំនៀមទំលាប់

ច្បាប់អន្តរជាតិទំនៀមទំលាប់ឬ "ទំនៀមទំលាប់" ជាទម្រង់មិនលាយលក្ខអក្សរមួយនៃច្បាប់ដែលបានបង្កើតបន្ទាប់ពីការអនុវត្តជាច្រើនឆ្នាំ។ រដ្ឋអាចបង្កើតការអនុវត្តមួយក្នុងចំណោមពួកគេ ហើយបន្ទាប់ពីអំឡុងពេលមួយ អាចជឿជាក់ថាវាមានសុពលភាពផ្លូវច្បាប់។ នៅពេលដែលមានករណីនេះកើតឡើង ច្បាប់អន្តរជាតិទំនៀមទំលាប់ត្រូវបានបង្កើតឡើង។ ឧទាហរណ៍មួយនៃទំនៀមទំលាប់ គឺជាពិធីការដែលរដ្ឋទទួលថ្នាក់ដឹកនាំពីប្រទេសផ្សេងដែលមកធ្វើទស្សនៈកិច្ច។ រដ្ឋមិនចាប់ខ្លួនប្រធានាធិបតី ឬនាយករដ្ឋមន្ត្រីដែលមកធ្វើទស្សនៈកិច្ចនោះទេ។ ជាការសន្មតថាប្រមុខរដ្ឋមានអភ័យឯកសិទ្ធិ។ នេះមិនមានច្បាប់អន្តរជាតិ ឬសន្ធិសញ្ញាការពារប្រមុខរដ្ឋនោះទេ ប៉ុន្តែវាជាការអនុវត្តអស់រយៈពេលច្រើនសតវត្សមកហើយ។ ច្បាប់សិទ្ធិមនុស្សមួយចំនួនអាចត្រូវបានចាត់ទុកថាជាច្បាប់ទំនៀមទំលាប់ ដូចជាការមិនបញ្ជូនជនភៀសខ្លួនទៅប្រទេសដែលពួកគាត់បានភៀសខ្លួនចេញ ការហាមឃាត់របបទាសភាព និងសិទ្ធិរស់រានមានជីវិត។

ទំនៀមទំលាប់ជាប្រភពដ៏សំខាន់មួយនៃច្បាប់។ យ៉ាងណាមិញទំនៀមទំលាប់មិនមានការសរសេរជាលាយលក្ខអក្សរនោះទេ ហើយនីតិវិធីក្នុងការកំណត់ថាតើទំនៀមទំលាប់មានវត្តមានឬក៏អត់ គឺពិតជាមានភាពស្មុគស្មាញ ច្បាប់ទំនៀមទំលាប់មានប្រជាប្រិយតិចជាងសន្ធិសញ្ញា។ ទំនៀមទំលាប់ មានសុពលភាពខ្លាំងជាងសន្ធិសញ្ញាដោយសារ

នៅពេលដែលទំនៀមទំលាប់មួយត្រូវបានបង្កើត និងបញ្ជាក់ វានឹងចងកាតព្វកិច្ចលើរដ្ឋទាំងអស់ (ជាការកម្រដែលរដ្ឋមួយមិនអនុវត្តទំនៀមទំលាប់) មិនដូចគ្នានឹងសន្ធិសញ្ញានោះទេ ដែលចងកាតព្វកិច្ចតែចំពោះភាគីរបស់វាតែប៉ុណ្ណោះ។ មធ្យោបាយតែមួយគត់ក្នុងការជៀសវាងទំនៀមទំលាប់ចំពោះរដ្ឋមួយ គឺរដ្ឋនោះត្រូវបដិសេធទំនៀមទំលាប់នេះចាប់តាំងពីដំបូងមកម្ល៉េះ។

## គោលការណ៍ទូទៅនៃច្បាប់

ច្បាប់អន្តរជាតិក៏រួមបញ្ចូលផងដែរនូវគោលការណ៍ទូទៅនៃច្បាប់ ដែលជាផ្នែកនៃច្បាប់ដូចនេះត្រូវបានប្រើប្រាស់ក្នុងប្រព័ន្ធជាតិ ដែលត្រូវបានរំពឹងថាជាផ្នែករបស់ច្បាប់អន្តរជាតិផងដែរ (ដូចជាទស្សនៈនៃការជំនុះជម្រះក្តីដោយយុត្តិធម៌) គោលការណ៍ខ្លះទទួលបានការគាំទ្រជាច្រើន ដែលគ្មានរដ្ឋណាមួយអាចរំលោភបំពានបាន។ គោលការណ៍នេះរួមមានសិទ្ធិស្វ័យសម្រេច ហើយព្រមទាំងអំពើដែលត្រូវបានហាមឃាត់ទាំងស្រុងតែម្តងដូចជាអំពើប្រល័យពូជសាសន៍។ គោលការណ៍ទាំងនេះត្រូវបានហៅថាជាវិធានដាច់ខាត ដែលជាស្តង់ដារដែលមិនអាចរំលោភបំពានបានទោះក្នុងកាលៈទេសៈណាក៏ដោយ។ វិធានដាច់ខាតមានវត្តមានដោយសារសិទ្ធិជាមូលដ្ឋានមួយចំនួនមិនទាន់មានប្រវត្តិនៃការអនុវត្តជាទំនៀមទំលាប់ (ជាឧទាហរណ៍ ស្វ័យសម្រេច) ប៉ុន្តែយ៉ាងណាក៏ដោយ សហគមន៍អន្តរជាតិទទួលស្គាល់នេះថាជាសិទ្ធិជាមូលដ្ឋាន។ ពាក់ព័ន្ធនឹងទស្សនៈនៃវិធានដាច់ខាតនេះ គឺជា *Jus cogens* ដែលជាវិធានមួយដែលកំណត់ថាមិនមានច្បាប់អន្តរជាតិណាមួយត្រូវបានបង្កើតនោះទេ ប្រសិនបើវារំលោភបំពានលើវិធានដាច់ខាតនោះ។ ជាឧទាហរណ៍សន្ធិសញ្ញាមួយរវាងប្រទេសពីរដើម្បីលក់ទាសករពីប្រទេសមួយទៅប្រទេសមួយទៀតនឹងអសុពលភាព ពីព្រោះវាផ្ទុយនឹងវិធាននៃ *jus cogens*។

ទំនៀមទំលាប់ និងគោលការណ៍ទូទៅធានាថា ទោះបីជារដ្ឋមួយមិនបានព្រមព្រៀងលើសន្ធិសញ្ញាសិទ្ធិមនុស្សមួយ ឬប្រសិនបើបុគ្គលណាមួយស្ថិតនៅខាងក្រៅយុត្តាធិការណាមួយ (ជាឧទាហរណ៍ ពួកគេនៅកណ្តាលមហាសមុទ្រ) ការអនុវត្តដូចជាទាសភាព ការធ្វើទារុណកម្ម នៅតែមិនស្របច្បាប់។ ទំនៀមទំលាប់ និងគោលការណ៍ទូទៅ មានសារៈសំខាន់ផងដែរសម្រាប់អ្នកការពារសិទ្ធិមនុស្សក្នុងរដ្ឋដែលបានព្រមព្រៀងលើសន្ធិសញ្ញាសិទ្ធិមនុស្សមួយចំនួនតូចប៉ុណ្ណោះ។ អ្នកការពារសិទ្ធិមនុស្សមិនអាចស្នើឲ្យរដ្ឋមួយក្នុងការឆ្លើយតបនឹងស្តង់ដារសន្ធិសញ្ញានោះទេ ប៉ុន្តែផ្ទុយទៅវិញពួកគេអាចធានាថាសិទ្ធិមនុស្សដែលជាផ្នែកនៃច្បាប់ទំនៀមទំលាប់ និង វិធានដាច់ខាតត្រូវបានការពារ។

## ទស្សនៈទាន

### សារៈសំខាន់នៃច្បាប់ទំនៀមទំលាប់ *jus cogens* និងវិធានដាច់ខាតនៅអាស៊ីអាគ្នេយ៍

ទំនៀមទំលាប់ *jus cogens* និងវិធានដាច់ខាត ជាប្រភពសំខាន់នៃច្បាប់ពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ពីព្រោះរដ្ឋខ្លះនៅអាស៊ីអាគ្នេយ៍បានផ្តល់សច្ចាប័នលើអនុសញ្ញាសិទ្ធិមនុស្សចំនួនតិចបំផុត។ នេះមិនមែនមានន័យថារដ្ឋទាំងនោះត្រូវបានអនុញ្ញាតឲ្យរំលោភបំពានសិទ្ធិមនុស្សនៅក្នុងអនុសញ្ញាទាំងនោះទេ ដោយសារសិទ្ធិមនុស្សសំខាន់ៗជាច្រើនត្រូវបានការពារតាមរយៈប្រភពទាំងនេះនៃច្បាប់។ ស្តង់ដារនៃការមិនរើសអើង សេរីភាពរួចផុតពីការធ្វើទារុណកម្ម និងទាសភាព សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងលទ្ធភាពក្នុងការទទួលបានយុត្តិធម៌ គួរតែត្រូវបានគោរពដោយរដ្ឋពីព្រោះសិទ្ធិទាំងនេះមានវត្តមានជាទំនៀមទំលាប់ *jus cogens* និងវិធានដាច់ខាត។

ចំពោះអ្នកការពារសិទ្ធិមនុស្ស ជាពិសេសក្នុងប្រទេសមីយ៉ាន់ម៉ា សឹង្ហបូរី ម៉ាឡេស៊ី និងប្រ៊ុយណេ មានន័យថាជំនួសឲ្យការប្រើប្រាស់ច្បាប់ក្នុងស្រុក ឬផ្តល់សច្ចាប័នសន្ធិសញ្ញាដើម្បីទាមទារសិទ្ធិមនុស្ស ពួកគេអាចទាមទារឲ្យមានការអនុលោមតាមទំនៀមទំលាប់ ឬវិធានអន្តរជាតិ។

## សេចក្តីសម្រេចតុលាការ និងការបង្រៀនច្បាប់អន្តរជាតិ

ប្រភពចុងក្រោយនៃច្បាប់អន្តរជាតិជាសេចក្តីសម្រេចតុលាការ និងការបង្រៀនច្បាប់អន្តរជាតិ។ ស្ថាប័នតុលាការអាចរួមបញ្ចូលតុលាការអន្តរជាតិ (ដូចជាតុលាការយុត្តិធម៌អន្តរជាតិ និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ) អង្គជំនុំជម្រះ (ដូចជាអង្គជំនុំជម្រះនីតិសមុទ្រ) និងមជ្ឈតករអន្តរជាតិ។ វាក៏អាចរួមបញ្ចូលតុលាការជាតិ ដែលសេចក្តីសម្រេចអាចត្រូវបានប្រើប្រាស់ក្នុងច្បាប់អន្តរជាតិ ដូចជាបណ្តឹងប្រឆាំងលោកពីណូចិត (Pinochet) (ដែលជាមេដឹកនាំផ្តាច់ការប្រទេសឈីលី ដែលត្រូវបានចាប់ខ្លួន នៅទីក្រុងឡុង ក្នុងឆ្នាំ ១៩៩៨ និងត្រូវបានចោទប្រកាន់ពីការធ្វើទារុណកម្ម) និង Adolf Eichman (បក្សណាស៊ី ដែលត្រូវបានចាប់ខ្លួនក្នុងប្រទេសអាហ្សង់ទីនក្នុងឆ្នាំ១៩៦០ ហើយត្រូវបានបញ្ជូនដោយសម្ងាត់ទៅប្រទេសអ៊ីស្រាអែល ដើម្បីទទួលការចោទប្រកាន់ពីបទរួមគំនិត ក្នុងការប្រល័យពូជសាសន៍ដោយពួកណាស៊ី។

ត្រូវចងចាំថាស្ថាប័នតុលាការក្នុងច្បាប់អន្តរជាតិ ខុសគ្នាពីស្ថាប័នតុលាការថ្នាក់ជាតិ។ ប្រសិនបើបុគ្គលមួយរូប ត្រូវបានចោទប្រកាន់ពីបទរំលោភបំពានច្បាប់ជាតិ គាត់នឹងត្រូវបានបញ្ជូនទៅតុលាការ និងទទួលការវិនិច្ឆ័យនៅទីនោះ។ យ៉ាងណាមិញ តុលាការអន្តរជាតិ មានលក្ខណៈជាការស្ម័គ្រចិត្ត រដ្ឋត្រូវតែព្រមព្រៀងក្នុងការចងកាតព្វកិច្ចដោយសេចក្តីសម្រេចរបស់តុលាការ មុនពេលតុលាការអាចមានយុត្តាធិការលើពួកគេ។ ដូចនេះ សេចក្តីសម្រេចរបស់តុលាការពិតជាដើរតួសំខាន់ ក្នុងការអភិវឌ្ឍច្បាប់សិទ្ធិមនុស្ស ដោយសារពួកគេអាចធ្វើការបកស្រាយប្បញ្ញត្តិសន្ធិសញ្ញា បង្កើតវត្តមាននៃទំនៀមទំលាប់ ប្រកាសថាអ្វីជា *jus cogens* និងដោះស្រាយវិវាទរវាងរដ្ឋ។

ការតាក់តែងច្បាប់អន្តរជាតិដោយអ្នកច្បាប់អន្តរជាតិដែលមានឈ្មោះល្បី គឺប្រហែលជាប្រភពនៃច្បាប់អន្តរជាតិដែលមានការប្រើប្រាស់តិចតួចបំផុត។ ជាឧទាហរណ៍គោលការណ៍ណែនាំម៉ាអាទ្រិច (Maasrticht) និងគោលការណ៍លីមបឺច (Limburg) ស្តីពីការអនុវត្ត ICESCR (ដែលនឹង សិក្សាលើផ្នែកស្តីពីការសម្រេចបានជាបណ្តើរៗ) ជាគំនិតទស្សនៈអ្នកជំនាញដែលត្រូវបានប្រើប្រាស់ ក្នុងការជួយដល់ស្ថាប័នក្នុងការកំណត់ថាតើសិទ្ធិសេដ្ឋកិច្ច សង្គម ឬ វប្បធម៌ត្រូវបានរំលោភបំពានឬក៏អត់។

ការលេចចេញនូវច្បាប់សិទ្ធិមនុស្សអន្តរជាតិ បានផ្លាស់ប្តូរទ្រង់ទ្រាយនៃច្បាប់អន្តរជាតិ។ កាលពីពេលមុន ច្បាប់អន្តរជាតិជាមូលដ្ឋាន រួមមានវិធានដែលរដ្ឋដាក់លើគ្នាទៅវិញទៅមក។ យ៉ាងណាមិញ ច្បាប់សិទ្ធិមនុស្សអន្តរជាតិ បានបង្ហាញនូវធាតុផ្សំសំខាន់ៗមួយចំនួន ដោយដាក់បញ្ហាបុគ្គលក្នុងច្បាប់អន្តរជាតិ ដូចនេះច្បាប់មិនគ្រាន់តែសម្រាប់តែរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់ប្រជាជនផងដែរ។ ច្បាប់អន្តរជាតិប្បញ្ញត្តិពី អាកប្បកិរិយារបស់រដ្ឋនៅក្នុងព្រំដែនរបស់រដ្ឋទាំងនោះ ដែលជាបញ្ហាមួយកម្រនឹងត្រូវបានជ្រៀតជ្រែកណាស់ កាលពីមុនពេលមានច្បាប់សិទ្ធិមនុស្ស។ ជាចុងក្រោយច្បាប់អន្តរជាតិបង្ហាញនូវចង្កោមគោលការណ៍ និងបទដ្ឋានថ្មីសម្រាប់រដ្ឋ។ ជាឧទាហរណ៍ការមិនរើសអើង ដែលពេលបច្ចុប្បន្ននេះ ធានាថាទូទាំងពិភពលោកនេះ ការប្រព្រឹត្តលើមនុស្សខុសៗគ្នា ដោយសារតែភេទ ឬពូជសាសន៍របស់ពួកគេជាការប្រឆាំងនឹងស្តង់ដារដែលអាចទទួលយកបានដោយអាកប្បកិរិយារបស់រដ្ឋ។

## ការពិភាក្សា និងការជជែកវែកញែក

### តើអ្នកណាជាអ្នកបកស្រាយស្តង់ដារសិទ្ធិមនុស្ស?

ការបកស្រាយជាក់ស្តែងនៃសិទ្ធិមនុស្សមួយចំនួន ស្ថិតក្នុងការជជែកវែកញែកនៅឡើយ។ មួយគឺថាប្រព័ន្ធច្បាប់រំពឹងថាការបកស្រាយសិទ្ធិមនុស្ស នឹងត្រូវបានកំណត់ដោយសន្ធិសញ្ញា និងយន្តការច្បាប់អន្តរជាតិ ដូចជាតុលាការអន្តរជាតិ (ICJ) ឬស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សរបស់ UN។ លើសពីនេះទៀត វិធីសាស្ត្រដែលរដ្ឋមួយធ្វើការបកស្រាយពីសេរីភាពនៃការបញ្ចេញមតិ ក្នុងការអនុវត្តជាក់ស្តែងភាគច្រើនត្រូវបានកំណត់ដោយរដ្ឋខ្លួនឯង។ ស្តង់ដារនៃសេរីភាពក្នុងការបញ្ចេញ មានភាពខុសគ្នាខ្លាំងទូទាំងអាស៊ីអាគ្នេយ៍ ជាពិសេសស្តីពីការសំដែងមតិដែលមានលក្ខណៈនយោបាយ។

***តើអ្នកណាគេគួរតែត្រូវបានផ្តល់អំណាចខ្លាំងជាងគេក្នុងការបកស្រាយសិទ្ធិមនុស្ស ៖ រដ្ឋ ឬសហគមន៍អន្តរជាតិ?*** ប្រសិនការបកស្រាយត្រូវបានប្រគល់ជូនរដ្ឋ ការប្តេជ្ញាចិត្ត និងកាតព្វកិច្ចរបស់រដ្ឋទាំងនោះ នឹងធ្លាក់ចុះដោយប្រើលេសដូចជាបញ្ហាវប្បធម៌ ឬសេដ្ឋកិច្ចជាដើម។ ម្យ៉ាងវិញទៀត ការបកស្រាយជាសកលពីប្រព័ន្ធអន្តរជាតិមិនអាចក្តោបភាពខុសគ្នានៃសង្គម វប្បធម៌ និងសេដ្ឋកិច្ចនៃរដ្ឋផ្សេងៗគ្នាបាននោះទេ។ គួរតែមានស្ថាប័នមួយដែលត្រូវបានផ្តល់អំណាចក្នុងការបកស្រាយ ឬអាចមានតុល្យភាពមួយរវាងរដ្ឋ និងស្ថាប័នអន្តរជាតិ?

# ២.៣ ប្រវត្តិនៃការអភិវឌ្ឍស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ

មុនពេលការលេចចេញជារូបរាងនៃ UN សិទ្ធិរបស់មនុស្សមានភាគច្រើននៅកម្រិតថ្នាក់ជាតិដែលរដ្ឋ ឧទាហរណ៍ដូចជា សហរដ្ឋអាមេរិក សហភាពសូវៀត បារាំង ប្រេស៊ីល និងចក្រភពអង់គ្លេស ដែលបានការពារសិទ្ធិប្រជាជននៅកម្រិតថ្នាក់ជាតិ។ ដែលសិទ្ធិទាំងនេះភាគច្រើនត្រូវបានប្រគល់ជូនតាមរយៈសិទ្ធិធម្មនុញ្ញ។ មានការការពារមួយចំនួននៃសិទ្ធិនៅឆាកអន្តរជាតិ ប៉ុន្តែនេះមានការអភិវឌ្ឍតិចតួចជាងច្បាប់ជាតិ។ ស្តង់ដារសិទ្ធិមនុស្សអន្តរជាតិដែលមានវត្តមានសព្វថ្ងៃនេះ មានការអភិវឌ្ឍតាមពេលវេលាដោយ៖

- សន្ធិសញ្ញាស្តីពីការជួញដូរទាសករ និងទាសភាពចាប់តាំងពីដើមសតវត្សឆ្នាំ ១៨០០

- ខប្បញ្ញត្តិមនុស្សធម៌ក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ និងច្បាប់នៃជម្លោះប្រដាប់អាវុធចាប់តាំងពីទសវត្សឆ្នាំ១៨៦០។
- ខប្បញ្ញត្តិស្តីពីសិទ្ធិជនជាតិភាគតិចជាក់លាក់ ក្នុងសន្ធិសញ្ញាសន្តិភាពដែលបញ្ចប់សង្គ្រាមលោកលើកទី១នៅអឺរ៉ុប។
- សិទ្ធិកម្មករដែលបានបង្កើតឡើងដោយ ILO ដែលមានក្នុងធម្មនុញ្ញ ILO ឆ្នាំ១៩២០ ។

កម្មវត្ថុដំបូងបំផុតមួយរបស់ UN នៅពេលដែលស្ថាប័ននេះត្រូវបានបង្កើតឡើងភ្លាមៗ (១៩៤៥) គឺដើម្បីបង្កើតមូលដ្ឋានមួយនៃសិទ្ធិមនុស្សអន្តរជាតិ។ ដើម្បីធ្វើដូចនេះ ពួកគេនឹងប្រើប្រាស់សិទ្ធិដែលមានស្រាប់ដែលមានក្នុងរដ្ឋធម្មនុញ្ញជាតិ និងស្តង់ដារអន្តរជាតិដែលមានក្នុងទំនៀមទំលាប់និងសន្ធិសញ្ញាអន្តរជាតិ។




ធម្មនុញ្ញរបស់ UN (១៩៤៥) ចែងថា ‘‘ដើម្បីសង្គ្រោះមនុស្សជំនាន់ក្រោយពីការបំផ្លិចបំផ្លាញនៃសង្គ្រាម ដែលបានបង្កឲ្យមានភាពក្រៀមក្រំ ដែលមិនអាចរៀបរាប់បានដល់មនុស្សជាតិចំនួនពីរដងក្នុងឆាកជីវិតរបស់យើង ’’ UN គួរតែព្យាយាមក្នុងការធានានូវសន្តិភាពពិភពលោក តាមរយៈការបង្កើតលក្ខខណ្ឌដែលរដ្ឋអាចរក្សាទំនាក់ទំនងប្រកបដោយមិត្តភាព។ ដើម្បីធានាលក្ខខណ្ឌទាំងនេះ UN នឹងចាត់វិធានការសំខាន់ដើម្បីឆ្លើយតបនឹងការគម្រាមកំហែងដល់សន្តិភាព និងសន្តិសុខអន្តរជាតិដោយធ្វើការធានានូវការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមរបស់រដ្ឋសមាជិក និងបង្កើតសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន។ ធម្មនុញ្ញ UN ក៏បានផ្តល់កាតព្វកិច្ចដទៃដល់ UN ផងដែរ ដូចជាការគ្រប់គ្រងច្បាប់អន្តរជាតិ ការលើកកម្ពស់សាសនានិយម និងការគ្រប់គ្រងទឹកដីដែលស្ថិតក្រោមអាណាព្យាបាល។ ខណៈពេលពាក្យថាសិទ្ធិមនុស្សត្រូវបានរំលេចប៉ុន្មានដងក្នុងធម្មនុញ្ញ UN (មានពាក្យសិទ្ធិមនុស្សចំនួនប្រាំបីដងក្នុងចំណោមជាង ១០០ មាត្រា) សិទ្ធិទាំងនេះពិតជាដើរតួនាទីសំខាន់ ដោយសារការបង្កើតសិទ្ធិមនុស្សជាគោលបំណងមួយនៃគោលបំណងចម្បងរបស់ UN ។ សិទ្ធិមនុស្សត្រូវបានរៀបរាប់ដំបូងក្នុងបុព្វកថា ហើយបន្ទាប់មកទៀតនៅក្នុងមាត្រាដំបូងបំផុតដែលជាគោលបំណងរបស់ UN។

បន្ទាប់មកទៀតក្នុងមាត្រា ៥៥ និង ៥៦ ធម្មនុញ្ញបានបញ្ជាក់ថាដើម្បីឲ្យមានការអភិវឌ្ឍផ្នែកសង្គម និងសេដ្ឋកិច្ច រដ្ឋត្រូវតែគោរពសិទ្ធិមនុស្ស។ មាត្រា៥៥ អំពាវនាវដល់សមាជិកក្នុងការ "លើកកម្ពស់ ការគោរពជាសកលលើ និងការប្រតិបត្តិនៃសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន។" មាត្រា ៥៦ ស្នើដល់រដ្ឋក្នុងការធ្វើការជាមួយគ្នា និងជាមួយនឹង UN ដើម្បីធានាសម្រេចបាននូវគោលដៅនេះ។ ដោយសារសិទ្ធិមនុស្សមិនត្រូវបានចាត់ទុកថាបញ្ហាថ្នាក់ជាតិទៀតនោះទេ UN ធ្វើឲ្យការលើកកម្ពស់ និងការពារសិទ្ធិមនុស្សក្លាយទៅជាបញ្ហាអន្តរជាតិ។

## ២.៣.១ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស(UDHR)

ខណៈពេលដែលធម្មនុញ្ញមិនកំណត់និយមន័យច្បាស់លាស់ពីសិទ្ធិមនុស្ស UN បានដាក់កំណត់ការងារដោយខ្លួនឯង តាមរយៈការតែងតាំងគណៈកម្មាធិការសិទ្ធិមនុស្សក្នុងការព្រាង UDHR។ ដើម្បីធ្វើដូចនេះ គណៈកម្មាធិការនេះ ដែលបានដឹកនាំដោយ អេលីណ័រ រូសឺវែល (Eleanor Roosevelt) បានប្រជុំអស់រយៈពេលប្រហែលជាពីរឆ្នាំក្នុងការព្រាងឯកសារដែលក្រោយមកបានក្លាយទៅជា UDHR។ អ្នកព្រាងទាំងនេះត្រូវបានតែងតាំងជាសមាជិក គណៈកម្មាធិការសិទ្ធិមនុស្សដោយរដ្ឋសមាជិក។ ការព្រាងនេះ ជាដំបូងតាមរយៈការប្រមែប្រមូលកម្រងសិទ្ធិពីរដ្ឋធម្មនុញ្ញជាតិ សេចក្តីប្រកាសវិចារណកថាសាសនា និងទស្សនៈវិជ្ជា និងធាតុចូលរបស់អ្នកជំនាញដទៃពីជុំវិញពិភពលោក។ បន្ទាប់មានការពិភាក្សាលើការប្រមូលផ្តុំនេះ និងត្រូវបានកែសម្រួលដោយសមាជិកប្រទេសទាំង ១៥ នៃគណៈកម្មាធិការសិទ្ធិមនុស្ស។ UDHR ត្រូវបានអនុម័តដោយមហាសន្និបាតនៅថ្ងៃទី ១០ ខែធ្នូ ឆ្នាំ១៩៤៨ ដែលចាប់ពីពេលនោះមកត្រូវបានចាត់ទុកថាជាទិវាសិទ្ធិមនុស្ស។ មានការជជែកវែកញែកអំពីថាតើឯកសារចុងក្រោយនេះជាទសន្សៈលោកខាងលិចលើសិទ្ធិមនុស្ស ឬជាទស្សនៈសកលមួយដូចដែលចំនួនដើងរបស់សេចក្តីប្រកាសនេះបានបញ្ជាក់។ ការស្រាវជ្រាវបច្ចុប្បន្នពិតជាពិចារណាថាសមាជិកមិនមែនលោកខាងលិចពីប្រទេសចិន សហភាពសូវៀត លីបង់ ហ្វីលីពីន និងសូម្បីតែរដ្ឋអារ៉ាប់ ពិតជាមានធាតុចូលជាចម្បងក្នុងសេចក្តីប្រកាសនេះ ប៉ុន្តែថាតើធាតុចូលរបស់ពួកគេអាចត្រូវបានចាត់ទុកថា 'លោកខាងលិច' ឬ 'មិនមែនលោកខាងលិច' នៅតែជាការបើកទូលាយសម្រាប់ការពិភាក្សាវែកញែក។

ឯកសារចុងក្រោយដែលត្រូវបានបង្ហាញ ជាសេចក្តីប្រកាសដល់មហាសន្និបាតរបស់ UN មានចំនួន ៣០ មាត្រាដែលបង្កើតជាសរសរស្តម្ភនៃសិទ្ធិមនុស្សពេលបច្ចុប្បន្ន។ យ៉ាងណាមិញ សេចក្តីប្រកាសមិនមែនជាសន្ធិសញ្ញាដែលចងកាតព្វកិច្ចលើរដ្ឋនោះទេ (ទោះបីជាមានមនុស្សភាគច្រើនបានអះអាងថាសេចក្តីប្រកាសនេះ ទទួលបានឋានៈស្មើនឹងសន្ធិសញ្ញាមួយក៏ដោយ)។ ដូចនេះ ជាមួយនឹងការអនុម័ត UDHR តារាងសិទ្ធិជាសកលមួយត្រូវបានដាក់ឲ្យប្រើប្រាស់ ដែលរដ្ឋត្រូវតែទទួលថាជាសិទ្ធិមនុស្សជាសកល។

# ការពិភាក្សា និងការជជែកវែកញែក

## ស្ថានភាពគតិយុត្តនៃ UDHR

មានការជជែកវែកញែកជាច្រើនលើស្ថានភាពគតិយុត្តនៃ UDHR ។ ជាទូទៅសេចក្តីប្រកាសពីមហាសន្និបាត (ដែលជាប្រភពដើមនៃ UDHR) មិនបង្កើតកាតព្វកិច្ចផ្លូវច្បាប់ដល់រដ្ឋនោះទេ។ ប៉ុន្តែ មនុស្សចាត់ទុក UDHR ឬផ្នែកនៃ UDHR ថាចងកាតព្វកិច្ចផ្លូវច្បាប់។ ដោយសារបច្ចុប្បន្ននេះ រដ្ឋជាច្រើនបានផ្តល់សច្ចាប័នលើកតិកាសញ្ញា ដែលបានដកស្រង់ចេញពី UDHR ដែលមាន ICCPR និង ICESCR ស្ថានភាពគតិយុត្តរបស់ UDHR កាន់តែមានការពាក់ព័ន្ធតិចទៅៗ។ យ៉ាងណាមិញ នៅក្នុងស្ថានភាពជាច្រើន ហើយនេះរួមបញ្ចូលឋានៈនៃសិទ្ធិក្នុងប្រទេសជាច្រើន ដែលមិនបានផ្តល់សច្ចាប័នលើ ICCPR ឬ ICESCR ដូចជាសឹង្ហបុរី ម៉ាឡេស៊ី និងមីយ៉ាន់ម៉ា ការជជែកវែកញែកនេះពិតជាមានសារៈសំខាន់។ ជាសង្ខេប បញ្ហា និងការជជែកវែកញែកចម្បងៗ ពីស្ថានភាពគតិយុត្តរបស់ UDHR មានដូចតទៅ៖

១. ចងកាតព្វកិច្ចផ្លូវច្បាប់៖ រដ្ឋដែលចូលរួមជាមួយ UN និងផ្តល់សច្ចាប័នលើធម្មនុញ្ញរបស់ UN ព្រមព្រៀងថាពួកគេនឹងការពារសិទ្ធិមនុស្ស ហើយនិយមន័យរបស់ UN ពីសិទ្ធិមនុស្សជា UDHR។ ដូចនេះតាមរយៈការព្រមព្រៀងលើធម្មនុញ្ញ UN រដ្ឋព្រមព្រៀងក្នុងការគោរពតាម UDHR។

២. ចងកាតព្វកិច្ចផ្លូវច្បាប់៖ យន្តការជាច្រើនក្នុងUN អំពាវនាវឲ្យរដ្ឋក្នុងការគោរព UDHR ជាឧទាហរណ៍ នៅពេលដែលរដ្ឋទទួលការត្រួតពិនិត្យដែលជាផ្នែកមួយនៃការត្រួតពិនិត្យតាមពេលវេលាកំណត់ ការប្តេជ្ញាចិត្តរបស់ពួកគេលើសិទ្ធិក្នុង UDHR នឹងត្រូវបានវាយតម្លៃ។

៣. ចងកាតព្វកិច្ចផ្លូវច្បាប់ដោយផ្នែក៖ រដ្ឋមួយចំនួនទទួលស្គាល់ UDHR ថាជាច្បាប់។ ជាឧទាហរណ៍ UDHR ត្រូវបានប្រើប្រាស់ក្នុងការកាត់ក្តីនៅក្នុងប្រទេសហ្វីលីពីន នៅឆ្នាំ ១៩៥២។

៤. ចងកាតព្វកិច្ចផ្លូវច្បាប់ដោយផ្នែក៖ សិទ្ធិមួយចំនួនក្នុងUDHR ត្រូវបានពិចារណាថាជាទំនៀមទំលាប់ ឬ *Jus cogens* ៖ ជាឧទាហរណ៍ សេរីភាពរួចផុតពីទាសភាព និងទារុណកម្ម ហើយសិទ្ធិក្នុងការអនុវត្តសាសនាត្រូវបានការពារដោយច្បាប់មិនពាក់ព័ន្ធនឹងឋានៈរបស់ UDHR នោះទេ។ ដូចនេះមួយផ្នែ ប៉ុន្តែមិនទាំងអស់នោះទេនៃ UDHR គឺចងកាតព្វកិច្ច។

៥. មិនចងកាតព្វកិច្ច៖ UDHR មិនទាន់ត្រូវបានចុះហត្ថលេខា និងផ្តល់សច្ចាប័នដោយរដ្ឋទាំងអស់ ដែលនេះប្រឆាំងនឹងគោលការណ៍ដែលថាសន្ធិសញ្ញាទាំងអស់គួរតែមានលក្ខណៈស្ម័គ្រចិត្ត។ បន្ថែមពីលើនេះទៀត មាត្រាក្នុង UDHR មិនចែងច្បាស់លាស់ពីសិទ្ធិឲ្យបានគ្រប់គ្រាន់ ដើម្បីចាត់ទុកថាជាការសរសេរជាលាយលក្ខអក្សរមួយនៃសិទ្ធិនោះទេ។ ផ្ទុយទៅវិញរដ្ឋគួរតែយោងទៅលើសន្ធិសញ្ញាជាក់លាក់សម្រាប់ការសរសេរជាលាយលក្ខអក្សរពីសិទ្ធិមួយ។

ក្នុងនាមជាឯកសារសិទ្ធិមនុស្សជាសកលដំបូង UDHR មានតួនាទីសំខាន់មួយក្នុងច្បាប់សិទ្ធិមនុស្សដោយសារហេតុផលមួយចំនួន។ ដើម្បីជាការចាប់ផ្តើម វាជាសេចក្តីថ្លែងការណ៍ 'ជាសកល' ដំបូង ស្តីពីសិទ្ធិមនុស្ស ដែលកាលពីមុនស្ទើរតែគ្រប់សិទ្ធិទាំងអស់ត្រូវបានបង្កើតឡើងនៅថ្នាក់ជាតិប៉ុណ្ណោះ។ សេចក្តីប្រកាសបញ្ជាក់ពិស្តារពីសិទ្ធិជាមូលដ្ឋានដែលរដ្ឋត្រូវតែព្រមព្រៀង ប្រសិនជាពួកគេមានបំណងចង់ក្លាយជាផ្នែកមួយនៃសហគមន៍អន្តរជាតិក្នុង UN។ ទីពីរ UDHR មានការពង្រីកបន្ថែម កាលពីមុនឯកសារសិទ្ធិមនុស្សភាគច្រើន គឺកំណត់ជាក់លាក់ពីប្រភេទសិទ្ធិមួយដូចជាប្រឆាំងនឹងទាសភាព ឬសិទ្ធិជនជាតិភាគតិច។ ចុងក្រោយ UDHR ចាត់ទុកថាជាដំណាក់កាលដំបូងបំផុតក្នុងការកំណត់ស្តង់ដារ ដែលឈានដល់សន្ធិសញ្ញាអន្តរជាតិ ហើយទីបំផុតឈានដល់ការបង្កើតស្ថាប័នតាមដាន។ យុទ្ធសាស្ត្រនេះបានរួមបញ្ចូលផែនការបីជំហាន៖ ទីមួយ ធ្វើសេចក្តីប្រកាសដែលមិនចងកាតព្វកិច្ច ដែលនឹងមិនគម្រាមដល់រដ្ឋដោយសារវាមិនបង្កើតកាតព្វកិច្ចផ្លូវច្បាប់ ទីពីរធ្វើអនុសញ្ញាដែលចងកាតព្វកិច្ចផ្លូវច្បាប់ ហើយជាចុងក្រោយ បង្កើតយន្តការក្នុងការការពារសិទ្ធិទាំងនេះ។ UDHR ត្រូវបានចាត់ទុកផងដែរថាជាផ្នែកនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ ជាវាក្យស័ព្ទមួយដែលត្រូវបានប្រើប្រាស់សម្រាប់ ឯកសារសិទ្ធិមនុស្សសំខាន់ៗទាំងបី ៖ UDHR ICCPR និង ICESCR។

ការសិក្សាលើ UDHR មួយបង្ហាញពីថាតើសិទ្ធិត្រូវបានទទួលស្គាល់ និងរៀបចំជាលំដាប់តាមវិធីណា។ ដូចដែលជំពូក ១.៤ បានពន្យល់ សិទ្ធិ និងសេរីភាពដែលបានបង្ហាញក្នុង UDHR មានលំដាប់លំដោយ៖ ពីសិទ្ធិជាមូលដ្ឋាន ដល់សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងជាចុងក្រោយសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។ បរិបទសំខាន់ក្នុងការស្វែងយល់ពីថាតើសិទ្ធិទាំងនេះ ត្រូវបានយល់ដឹងដោយវិធីណា គឺត្រូវបានបញ្ជាក់ក្នុងបុព្វកថានៃសេចក្តីប្រកាសនេះ។ បុព្វកិថាកំណត់ពីគោលបំណង និងមុខងារនៃ UDHR។ ជាទូទៅ គោលបំណងនៃបុព្វកថាមួយគឺដើម្បីផ្តល់ជាប្រវត្តិនៃការព្រាង និងហេតុផលហេតុអ្វីបានឯកសារនេះជាតម្រូវការ។ បន្ទាប់ខ្លឹមសារទាំងនេះជួយដើម្បីជាការបកស្រាយនៃសន្ធិសញ្ញា ដោយផ្តល់ជាការយល់ដឹងពី**កម្មវត្ថុ និងគោលបំណង**។ បុព្វកថាក៏ត្រូវបានប្រើប្រាស់ដើម្បីយោងថាជាច្បាប់អន្តរជាតិដែលឯកសារមានការពាក់ព័ន្ធនឹងឯកសារមួយ។ បុព្វកថាក្នុង UDHR បញ្ជាក់ពីទស្សនៈជាច្រើនដែលមានក្នុងជំពូកមួយ ដូចជាភាពថ្លៃថ្នូរ សមភាព និងភាពមិនអាចដកហូតបាននៃសិទ្ធិ។ លើសពីនេះទៀត បុព្វកថាចែងថា UDHR ជាតម្រូវការដើម្បីជាឆ្លើយតបមួយ លើភាពសាហាវយ៉ង់ឃ្នងនៃសង្គ្រាមលោកលើកទីពីរ ដែល "អំពើសាហាវយង់ឃ្នង.. ត្រូវបានឆ្លើយតបដោយសម្បជញ្ញៈមនុស្សជាតិ" ។ បុព្វកថាផ្តល់ផងដែរនូវបរិបទច្បាប់ដោយរៀបរាប់ពីធម្មនុញ្ញ UN និងតួនាទីរបស់រដ្ឋសមាជិករបស់ UN ក្នុងការលើកកម្ពស់ការគោរពសិទ្ធិមនុស្ស។

**កម្មវត្ថុ និងគោលបំណងនៃសន្ធិសញ្ញាសិទ្ធិមនុស្សមួយ**
នៅពេលដែលប្រទេសមួយព្រមព្រៀងលើសន្ធិសញ្ញាមួយ ប្រទេសនេះត្រូវបានរំពឹងថានឹងមិនធ្វើអំពើប្រឆាំងនឹង "កម្មវត្ថុ និងគោលបំណង"នៃសន្ធិសញ្ញានេះនោះទេ។ ដូចនេះរដ្ឋមិនអាចបកស្រាយសន្ធិសញ្ញាមួយក្នុងមធ្យោបាយដែលប្រឆាំងនឹងកម្មវត្ថុ និងគោលបំណងនឹងសន្ធិសញ្ញានេះឡើយ។ ជាឧទាហរណ៍ រដ្ឋមួយមិនអាចនិរទេសកុមារទាំងអស់ចេញពីដែនយុត្តាធិការរបស់ខ្លួនដើម្បីជាមធ្យោបាយមួយក្នុងការធានាថាសិទ្ធិរបស់កុមារទាំងអស់ត្រូវបានការពារក្នុងទឹកដីរបស់ខ្លួននោះទេ។ ខណៈពេលដែលមិនមានផ្នែកជាក់លាក់ណាមួយនៃសន្ធិសញ្ញាដែលហាមឃាត់រដ្ឋពីការនិរទេសកុមារ សកម្មភាពនេះគឺច្បាស់ណាស់ដែលប្រឆាំងនឹងកម្មវត្ថុ និងគោលបំណងនៃសិទ្ធិកុមារដែលជាការគោរពសិទ្ធិរបស់កុមារ។

## បញ្ជីនៃសិទ្ធិនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

| | |
|---|---|
| មាត្រា១ | មនុស្សគ្រប់គ្នាកើតមកមានសិទ្ធិស្មើគ្នា |
| មាត្រា២ | សេរីភាពពីការរើសអើង |
| មាត្រា៣ | សិទ្ធិរស់រានមានជីវិត សេរីភាព សន្តិសុខផ្ទាល់ខ្លួន |
| មាត្រា៤ | សេរីភាពពីទាសភាព |
| មាត្រា៥ | សេរីភាពពីការធ្វើទារុណកម្ម និងប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប |
| មាត្រា៦ | សិទ្ធិទទួលស្គាល់ជាមនុស្សនៅគ្រប់ទីកន្លែង |
| មាត្រា៧ | សិទ្ធិស្មើគ្នាចំពោះមុខច្បាប់ |
| មាត្រា៨ | សិទ្ធិរកដំណោះស្រាយដោយតុលាការមានសមត្ថកិច្ច |
| មាត្រា៩ | សេរីភាពពីការចាប់ខ្លួន ឃុំខ្លួន និងនិរទេស |

| | |
|---|---|
| មាត្រា១០ | សិទ្ធិក្នុងការមានសវនការជាសាធារណៈត្រឹមត្រូវ |
| មាត្រា១១ | សិទ្ធិត្រូវសន្មត់ថាគ្មានទោសរហូតដល់ពិរុទ្ធភាពត្រូវបានរកឃើញ |
| មាត្រា១២ | សេរីភាពពីការជ្រៀតជ្រែកជីវិតឯកជន និងកេរ្តិ៍ឈ្មោះ |
| មាត្រា១៣ | សិទ្ធិធ្វើដំណើរដោយសេរី |
| មាត្រា១៤ | សិទ្ធិជ្រកកោន |
| មាត្រា១៥ | សិទ្ធិទទួលបានសញ្ជាតិ និងប្តូរសញ្ជាតិបានតាមចិត្ត |
| មាត្រា១៦ | សិទ្ធិរៀបអាពាហ៍ពិពាហ៍ និងកសាងគ្រួសារ |
| មាត្រា១៧ | សិទ្ធិជាម្ចាស់កម្មសិទ្ធិ |
| មាត្រា១៨ | សេរីភាពនៃជំនឿ និងសាសនា |
| មាត្រា១៩ | សេរីភាពក្នុងការបញ្ចេញមតិ និងទទួលព័ត៌មាន |
| មាត្រា២០ | សិទ្ធិក្នុងការប្រជុំ និងការរួមគ្នាជាសមាគម |
| មាត្រា២១ | សិទ្ធិចូលរួមក្នុងរដ្ឋាភិបាល និងសេរីភាពក្នុងការបោះឆ្នោត |
| មាត្រា២២ | សិទ្ធិទទួលបានសន្តិសុខសង្គម |
| មាត្រា២៣ | សិទ្ធិមានការងារធ្វើ និងចូលរួមក្នុងសហជីព |
| មាត្រា២៤ | សិទ្ធិឈប់សម្រាក និងលំហែកំសាន្ត |
| មាត្រា២៥ | សិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ រួមបញ្ចូលទាំងការថែទាំសុខភាព អាហារ និងលំនៅដ្ឋាន |
| មាត្រា២៦ | សិទ្ធិទទួលបានការអប់រំ |
| មាត្រា២៧ | សិទ្ធិក្នុងការចូលរួមជីវភាពវប្បធម៌របស់សហគមន៍ |
| មាត្រា២៨ | សិទ្ធិនៅក្នុងពិភពលោកដែលត្រូវបានសិទ្ធិមនុស្សការពារ |
| មាត្រា២៩ | ករណីកិច្ចសហគមន៍ដោយសេរី និងពេញបរិបូរណ៍ |
| មាត្រា៣០ | ករណីកិច្ចមិនប្រើប្រាស់សិទ្ធិទៅបំផ្លិចបំផ្លាញអ្នកដទៃ |

## ២.៨ ការបង្កើតសន្ធិសញ្ញា៖ ទិដ្ឋភាពទូទៅមួយ

សន្ធិសញ្ញាបង្កើតកាតព្វកិច្ចចាប់បង្ខំតាមច្បាប់មួយដល់រដ្ឋ តាមច្បាប់អន្តរជាតិ។ ប៉ុន្តែកាតព្វកិច្ចទាំងនេះត្រូវបានសម្រេចជាចម្បងដោយរដ្ឋខ្លួនឯង។ ដូចនេះតើសន្ធិសញ្ញាសិទ្ធិមនុស្សលេចចេញជារូបរាងដូចម្តេច? ដំណាក់កាលទីមួយជាដំណើរការបញ្ចុះ

បញ្ចូលដែលភាគីដែលមានចំណាប់អារម្មណ៍ (ជារឿយៗជាចម្រុះនៃរដ្ឋ អង្គការអន្តរជាតិ និងសង្គមស៊ីវិល) ជួបជុំគ្នាដើម្បីធ្វើផែនការ និងបញ្ចុះបញ្ចូលដើម្បីចងក្រងសិទ្ធិ។ ជាឧទាហរណ៍ មុនពេលសន្ធិសញ្ញាស្តីពីសិទ្ធិកុមារ ត្រូវលេចចេញជារូបរាង រដ្ឋផ្សេងៗដែលគាំទ្រដល់គំនិតផ្តួចផ្តើមនេះ ជាមួយនឹងអង្គការដូចជាសង្គ្រោះកុមារ (Save the Children) និងយូនីសេស (UNICEF) បានចាប់ផ្តើមក្នុងការបញ្ចុះបញ្ចូលដើម្បីទាក់ទាញការគាំទ្រឲ្យកាន់តែទូលំទូលាយមន្ថែមទៀត។ ដំណាក់កាលបន្ទាប់គឺនៅពេលដែល UN ព្រមព្រៀងក្នុងការទទួលយកគម្រោងនៃការបង្កើតសន្ធិសញ្ញានេះ បន្ទាប់មកចាប់ផ្តើម នូវដំណើរការសម្រេចតើថាសិទ្ធិអ្វីគួរតែត្រូវបានបញ្ចូលក្នុងសន្ធិសញ្ញា ហើយថាតើសិទ្ធិ ឬស្តង់ដារទាំងនេះត្រូវបានកំណត់យ៉ាងដូចម្តេច។ នេះជាពេលវេលានៃដំណើរការព្រាងកើតឡើងពិតប្រាដក។ វិធីដែលស្ថាប័ន UN ព្រាងសន្ធិសញ្ញាគឺពឹងផ្អែកលើប្រភេទនៃសន្ធិសញ្ញា និងអង្គការដែលពាក់ព័ន្ធ។

បច្ចុប្បន្ននេះសន្ធិសញ្ញាសិទ្ធិមនុស្សភាគច្រើន ត្រូវបានទទួលបន្ទុកដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស (ដែលពីមុខត្រូវបានស្គាល់ថាជាគណៈកម្មាការសិទ្ធិមនុស្ស) ដែលជាស្ថាប័ន UN ដែលគ្រប់គ្រងបញ្ហាសិទ្ធិមនុស្ស។ បន្ទាប់ក្រុមប្រឹក្សាអាចបង្កើតស្ថាប័នមួយ (ដែលជាទូទៅត្រូវបានហៅថាក្រុមការងារ) ដែលរួមមានរដ្ឋតំណាង និងអ្នកច្បាប់អន្តរជាតិពី UN (ជាទូទៅពីគណៈកម្មាធិការច្បាប់អន្តរជាតិ) ដើម្បីតាក់តែងសន្ធិសញ្ញា។ វាក្លាយជារឿងធម្មតា ពេលបច្ចុប្បន្ននេះ ដែលអនុញ្ញាតឲ្យមានធាតុចូលពីតួអង្គ ដែលមិនមែនរដ្ឋ ដូចជា NGOs ក្នុងការព្រាងសន្ធិសញ្ញា។ ឯកសារដែលលេចចេញ ជារូបរាងនេះ អាចឆ្លងកាត់ដំណាក់កាលផ្សេងៗ៖ ជាដំបូង ប្រហែលអាចជាសេចក្តីប្រកាស ឬសេចក្តីសម្រេចមួយដែលរដ្ឋគាំទ្រ ប្រសិនបើមានការគាំទ្រគ្រប់គ្រាន់ ឯកសារនេះអាចត្រូវបានព្រាងសារជាថ្មីដើម្បីតាក់តែងជាសន្ធិសញ្ញា។ រដ្ឋមានហេតុផលល្អសមរម្យក្នុងការចូលរួមក្នុងការព្រាងនៃឯកសារនេះ ដោយសារតែរដ្ឋអាចនៅថ្ងៃណាមួយ ចងកាតព្វកិច្ចផ្លូវច្បាប់ដោយសារសន្ធិសញ្ញានេះ។ ត្រូវចងចាំថាមិនមែនគ្រប់សន្ធិសញ្ញាទាំងអស់ត្រូវឆ្លងកាត់អង្គការសហប្រជាជាតិនោះទេ។ សន្ធិសញ្ញាខ្លះ ដូចជាសន្ធិសញ្ញាអុតតាវ៉ា (Ottawa) ដែលធ្វើការហាមឃាត់ការប្រើប្រាស់មីនប្រឆាំងមនុស្ស ជៀសវាងការឆ្លងកាត់ប្រព័ន្ធ UN ដូចនេះប្រទេសដែលផលិតអាវុធធំៗមិនអាចបញ្ឈប់ ឬបង្អាក់ដំណើរការព្រាងបាន។

ដំណើរការធ្វើសន្ធិសញ្ញាបញ្ចប់ នៅពេលដែលសន្ធិសញ្ញានេះត្រូវបានអនុម័តដោយមហាសន្និបាត ហើយប្រទេសបានបោះឆ្នោតទទួលពាក្យពេចន៍ចុងក្រោយនៃឯកសារ។ យ៉ាងណាមិញ ដំណើរការអនុម័តនេះ មិនប្រែក្លាយឯកសារនេះទៅជាច្បាប់អន្តរជាតិមួយនោះទេ។ ប៉ុន្តែជាការអនុញ្ញាតលើវគ្គចុងក្រោយនៃសន្ធិសញ្ញាមួយដែលតាមរយៈនេះរដ្ឋអាចព្រមព្រៀងដោយស្ម័គ្រចិត្តលើសន្ធិសញ្ញានេះ។ បន្ទាប់មកសន្ធិសញ្ញាត្រូវបានបើកឲ្យមានការចុះហត្ថលេខា ដែលអនុញ្ញាតដល់រដ្ឋសមាជិកណាមួយរបស់UN

តាមរយៈការចុះហត្ថលេខាលើសន្ធិសញ្ញានេះ ក្នុងការផ្តួចផ្តើមនីតិវិធីដែលតាមរយៈនេះធ្វើឲ្យសន្ធិសញ្ញាក្លាយទៅជាច្បាប់ក្នុងប្រទេសនោះ។ តាមរយៈការផ្តល់សច្ចាប័នលើសន្ធិសញ្ញាមួយ រដ្ឋព្រមព្រៀងលើកម្មវត្ថុ និងគោលបំណងនៃសន្ធិសញ្ញានោះ ខណៈពេលដែលពួកគេចាប់ផ្តើមដំណើរការ ក្នុងការប្រែក្លាយសន្ធិសញ្ញានេះជាច្បាប់ក្នុងប្រទេសរបស់ខ្លួន។ រដ្ឋអាចត្រូវបានចងកាតព្វកិច្ចផ្លូវច្បាប់លើសន្ធិសញ្ញាមួយ នៅពេលលដែលខ្លួនឆ្លងកាត់នីតិវិធីដែលហៅថាជាការផ្តល់សច្ចាប័នប៉ុណ្ណោះ (ទោះបីជាប្រសិនបើ ពួកគេបំពេញនីតិវិធីនេះ បន្ទាប់សន្ធិសញ្ញានេះចូលជាធរមាន នេះត្រូវបានហៅថា 'ការទទួលយក')។ នីតិវិធីនៃការផ្តល់សច្ចាប័នខុសៗគ្នាខ្លាំងរវាងរដ្ឋ។ រដ្ឋភាគច្រើននៅអាស៊ីអាគ្នេយ៍តម្រូវឲ្យសន្ធិសញ្ញា ត្រូវបានអនុម័តដោយសម្លេងភាគច្រើននៃសភា។ រដ្ឋខ្លះបញ្ជាក់ពីនីតិវិធីនេះលម្អិតក្នុងរដ្ឋធម្មនុញ្ញ រដ្ឋខ្លះទៀតបានបង្កើតនីតិវិធីមួយដែលមិននៅក្នុងរដ្ឋធម្មនុញ្ញ។ សម្រាប់ប្រទេស ឥណ្ឌូនេស៊ី ម៉ាឡេស៊ី សិង្ហបុរី និងថៃ សន្ធិសញ្ញានឹងមិនក្លាយជាច្បាប់មួយនោះទេ លុះត្រាណាតែការផ្តល់សច្ចាប័នត្រូវបានបំពេញ ហើយសន្ធិសញ្ញា 'ចូលជាធរមាន' ប៉ុណ្ណោះ។

សន្ធិសញ្ញាក្លាយជាច្បាប់អន្តរជាតិ ឬចូលជា 'ធរមាន' ជាច្បាប់ លុះត្រាតែនៅពេលដែលចំនួនរដ្ឋជាក់លាក់បានផ្តល់សច្ចាប័នប៉ុណ្ណោះ។ រាល់សន្ធិសញ្ញាទាំងអស់ត្រូវការចំនួនរដ្ឋជាក់លាក់មួយក្នុងការផ្តល់សច្ចាប័នមុនពេលសន្ធិនេះ ត្រូវបានចាត់ទុកថាជាច្បាប់អន្តរជាតិ។ ជាឧទាហរណ៍ ICCPR និង ICESCR ទាមទារឲ្យមានភាគីរដ្ឋចំនួន ៣៥ ខណៈពេលដែល CRC CAT និង PWD ត្រូវការតែចំនួន២០ប៉ុណ្ណោះ។ នៅពេលចំនួនដែលចាំបាច់នៃរដ្ឋដែលបានផ្តល់សច្ចាប័នសន្ធិសញ្ញាមួយ ហើយការផ្តល់សច្ចាប័នបានប្រគល់ជូន UN (ក្នុងនីតិវីមួយដែលហៅថា 'ការតម្កល់លិខិតូបករណ៍ផ្តល់សច្ចាប័ន' ) សន្ធិសញ្ញាត្រូវបានចាត់ទុកថាចូលជា 'ធរមាន' និងក្លាយជាច្បាប់អន្តរជាតិ។ យ៉ាងណាមិញត្រូវចងចាំថាសន្ធិសញ្ញា ចូលជាធរមានចំពោះតែប្រទេសដែលបានផ្តល់សច្ចាប័នលើសន្ធិសញ្ញានេះប៉ុណ្ណោះ។ ដូចនេះសន្ធិសញ្ញាមួយអាចជាចូលធរមាន ជាមួយប្រទេសមួយចំនួនដែលបានចងកាតព្វកិច្ចលើសន្ធិសញ្ញានេះ ហើយរដ្ឋផ្សេងទៀត (ដែលមិនបានផ្តល់សច្ចាប័ន) អាចចងកាតព្វកិច្ចត្រឹមតែក្នុងការមិនប្រព្រឹត្តក្នុងវិធីមួយដែលផ្ទុយនឹងកម្មវត្ថុ និងគោលបំណងនៃសន្ធិសញ្ញានេះតែប៉ុណ្ណោះ។

នៅពេលដែលសន្ធិសញ្ញាសិទ្ធិមនុស្សមួយចូលជាធរមាន ការផ្លាស់ប្តូរមួយចំនួនកើតឡើង។ អ្នកជំនាញការមួយក្រុមដែលត្រូវបានហៅថា 'ស្ថាប័នសន្ធិសញ្ញា' ត្រូវបានបង្កើតឡើងក្នុងការគ្រប់គ្រងសន្ធិសញ្ញា។ រដ្ឋភាគីត្រូវបានចាត់ទុកថាចងកាតព្វកិច្ចដោយកាតព្វកិច្ចសន្ធិសញ្ញារបស់ពួកគេ។ រដ្ឋដែលព្រមព្រៀងលើសន្ធិសញ្ញា បន្ទាប់ពីសន្ធិសញ្ញាចូលជាធរមាន ត្រូវបានហៅថាបាន 'ទទួលយក' សន្ធិសញ្ញានោះ។ រដ្ឋដែលបានក្លាយជាភាគីនៃសន្ធិសញ្ញាមួយដោយសារការផ្លាស់ប្តូររដ្ឋ (ជាឧទាហរណ៍ ទីម័រខាងកើតដែលប្រទេសថ្មីមួយបានលេចចេញជារូបរាង) ឬក៏ប្រទេសមួយត្រូវបានចែកជាពីរ

(ជាឧទាហរណ៍ ឆេកូស្លូវ៉ាគីជាឆេក និងស្លូវ៉ាគី) ត្រូវបានហៅថាបាន ‘ទទួលយក’ សន្ធិសញ្ញាមួយ។

## ផ្តោតសំខាន់លើ

### ចាប់តាំងពីការបញ្ចុះបញ្ចូលទៅដល់ការអនុវត្ត



បន្ទាប់ពីការផ្តល់សច្ចាប័ន រដ្ឋអាចចាប់ផ្តើមអនុវត្តសន្ធិសញ្ញា ដែលនេះជានីតិវិធីនៃការធ្វើច្បាប់សន្ធិសញ្ញានៅក្នុងប្រទេសមួយ។ ដូចគ្នានឹងការផ្តលសច្ចាប័នផងដែរការអនុវត្តខុសៗគ្នាដោយផ្អែកលើរដ្ឋផ្សេងៗគ្នា។ សម្រាប់រដ្ឋមួយចំនួន ការផ្តល់សច្ចាប័នគឺដូចគ្នានឹងការអនុវត្ត ដូចនេះសន្ធិសញ្ញាសន្ធិសញ្ញានឹងក្លាយជាច្បាប់ដោយស្វ័យប្រវត្តិ។ សម្រាប់រដ្ឋដទៃ រដ្ឋាភិបាល និងសិក្សាតើថាសិទ្ធិនៅក្នុងសន្ធិសញ្ញាមានសង្គតភាពជាមួយនឹងច្បាប់ និងតម្លៃដែលស្រាប់យ៉ាងដូចម្តេច ក្នុងគោលបំណងសម្រេចពីវិធីក្នុងការកែសម្រួលច្បាប់ជាតិរបស់ខ្លួន (ឬកែសម្រួលសន្ធិសញ្ញាតាមរយៈការធ្វើខលក្ខខណ្ឌ) ដើម្បីធ្វើតម្លៃស្មើគ្នា។ ប្រទេសដទៃអាចបង្កើតច្បាប់ ឬក្រមដែលមានតម្លៃស្មើ (ជាឧទាហរណ៍ 'ច្បាប់ស្តីពីជនពិការ') ឬពួកគេអាចធ្វើឲ្យសន្ធិសញ្ញានេះក្លាយទៅជាច្បាប់តែម្តង (ហើយប្រហែលជាបកប្រែសន្ធិសញ្ញា និងដាក់ឈ្មោះផ្សេង)។ រដ្ឋអាចឆ្លងកាត់នីតិវិធីក្នុងការបច្ចុប្បន្នភាពច្បាប់ ដែលមានស្រាប់របស់ខ្លួនដើម្បីឆ្លើយតបនឹងស្តង់ដារសន្ធិសញ្ញា ដែលមានន័យថាលុបបំបាត់ចោលច្បាប់ដែលមិនស្របជាមួយនឹងសន្ធិសញ្ញា ឬតាក់តែងច្បាប់ថ្មីដើម្បីឆ្លើយតបនឹងសន្ធិសញ្ញា ឬកែសម្រួលច្បាប់ដែលមានស្រាប់។ វិធីសាស្ត្រអ្វីក៏ដោយដែលរដ្ឋាភិបាលប្រើ លទ្ធផលចុងក្រោយ គឺថាស្តង់ដារក្នុងសន្ធិសញ្ញាត្រូវបានចាប់បង្ខំអនុវត្តដោយច្បាប់ក្នុងប្រទេសនោះ។

## ២.៤.១ ខលក្ខខណ្ឌ និងការយល់ដឹងពីសន្ធិសញ្ញា

**ខលក្ខខណ្ឌ និងការយល់ដឹងពីសន្ធិសញ្ញា**

'ខលក្ខខណ្ឌ'កែសម្រួលសុពលភាពផ្លូវច្បាប់របស់មាត្រាមួយ ឬប្បញ្ញត្តិមួយនៃសន្ធិសញ្ញានៅក្នុងប្រទេសដែលដាក់ខលក្ខខណ្ឌ។ "ការយល់ដឹងពីសន្ធិសញ្ញា" ឬ ("សេចក្តីប្រកាសបកស្រាយ") ជាសេចក្តីថ្លែងការណ៍មួយដែលធ្វើឡើងដោយរដ្ឋភាគីដែលបញ្ជាក់បំភ្លឺ ឬពិស្តារពីវិធីដែលរដ្ឋនេះបកស្រាយសិទ្ធិក្នុងសន្ធិសញ្ញាមួយ។

ពេលខ្លះ រដ្ឋាភិបាលគិតថាជាការពិបាកក្នុងការអនុវត្តសិទ្ធិមនុស្សជាក់លាក់មួយចំនួនដោយសារសិទ្ធិទាំងនេះប្រឆាំងនឹងជំនឿជាក់លាក់ក្នុងសង្គមរបស់ពួកគេ ឬអាចថាត្រូវចំណាយថវិកាច្រើនពេកក្នុងការអនុវត្តសិទ្ធិទាំងនោះ ឬសិទ្ធិទាំងនោះប្រឆាំងនឹងច្បាប់ដែលមានស្រាប់ជាច្រើន។ នៅក្នុងករណីទាំងនេះ រដ្ឋាភិបាលអាចកែសម្រួលសន្ធិសញ្ញាតាមរយៈការដាក់**ខលក្ខខណ្ឌ** (មិនបញ្ចូលមាត្រាឬសិទ្ធិទៅក្នុងច្បាប់ និងមិនមានឆន្ទៈក្នុងការអនុវត្ត) ឬធ្វើការបញ្ជាក់ពី**ការយល់ដឹងមួយ**ដែលបញ្ជាក់ពីវិធីដែលរដ្ឋនឹងបកស្រាយសិទ្ធិ។ ពេលខ្លះរដ្ឋប្រើប្រាស់ខលក្ខខណ្ឌ ក្នុងការធ្វើសន្ធិសញ្ញា មានភាពទន់ខ្សោយ។ ដែលស្ថានភាពនេះមិនគួរកើតមាននោះទេដោយសារ ខលក្ខខណ្ឌមិនអាចធ្វើឲ្យកម្មវត្ថុ និងគោលបំណងទន់ខ្សោយបាននោះទេ។ ជាឧទាហរណ៍មួយ រដ្ឋមួយចំនួននៅអាស៊ីអាគ្នេយ៍បានដាក់ខលក្ខខណ្ឌលើ CEDAW ( ដូចដែលនឹងត្រូវបានពិភាក្សាពេលក្រោយ) ដែលត្រូវបានរិះគន់ដោយសារពួកគេអនុញ្ញាតឲ្យមានរើសអើងលើស្ត្រីក្នុងការរៀបអាពាហ៍ពិពាហ៍ ភាពជាពលរដ្ឋ និងសិទ្ធិផ្លូវច្បាប់ អ្នកខ្លះអាចអះអាងថាខលក្ខខណ្ឌទាំងនេះប្រឆាំងនឹងគោលបំណងនៃសន្ធិសញ្ញា ប៉ុន្តែទោះបីជាដូចនេះតើរដ្ឋដទៃអាចធ្វើអ្វីបានខ្លះ? រដ្ឋប្រឆាំងនឹងខលក្ខខណ្ឌទាំងនេះទៅអង្គការសហប្រជាជាតិ ប៉ុន្តែពួកគេនៅតែទទួលស្គាល់រដ្ឋជាភាគីនៃអនុសញ្ញានេះ។ នៅពេលដែលធ្វើការត្រួតពិនិត្យស្ថានភាពសិទ្ធិមនុស្សរបស់រដ្ឋមួយ ខលក្ខខណ្ឌទាំងនេះជារឿយៗត្រូវបាន

ពិភាក្សា ហើយរដ្ឋត្រូវបានស្នើឲ្យលះបង់នូវខលក្ខខណ្ឌ។ ខលក្ខខណ្ឌមិនគួរត្រូវបាន ចាត់ទុកថាជាភាពទន់ខ្សោយក្នុងប្រព័ន្ធសន្ធិសញ្ញានោះទេ ដោយសារខនេះផ្តល់ទំនុក ចិត្តដល់រដ្ឋក្នុងការក្លាយទៅជារដ្ឋភាគី មុនពេលពួកគេមានភាពរួចរាល់ ហើយផ្តល់ ពេលវេលាសម្រាប់ពួកគេក្នុងការផ្លាស់ប្តូរច្បាប់ និងសង្គម ដូចនេះពួកគេអាចលះបង់ ចោលនូវខលក្ខខណ្ឌ និងអនុលោមតាមសិទ្ធិទាំងអស់។

បច្ចុប្បន្ននេះមានសន្ធិសញ្ញាសិទ្ធិមនុស្សចំនួនប្រាំបួន ដែលបានអនុម័តតាមរយៈនីតិវិធី សន្ធិសញ្ញាទាំងស្រុង។ ធ្វើការពិនិត្យមើលលើកាលបរិច្ឆេទអនុម័ត និងការចូលជាធរ មាននៃសន្ធិសញ្ញាទាំងនេះ យើងអាចសង្កេតឃើញថាសន្ធិសញ្ញាខ្លះ ត្រូវបានផ្តល់សច្ចា ប័នភ្លាមៗ (តិចយ៉ាងពីរឆ្នាំសម្រាប់ CEDAW និងCRC) ខណៈពេលដែលសន្ធិសញ្ញាផ្សេង ទៀតត្រូវចំណាយពេលយូរមែនទែន (ដប់ឆ្នាំសម្រាប់ ICCPR និង ICESCR និងដប់បី ឆ្នាំសម្រាប់ ICRMW)។ លើសពីនេះទៀត ប្រាំមួយក្នុងចំណោមសន្ធិសញ្ញាទាំងប្រាំបួន គឺមាននូវពិធីសារបន្ថែម ដែលដាច់ដោយឡែកតែជាសន្ធិសញ្ញាដែលភ្ជាប់ក្នុងការបន្ថែម អ្វីមួយទៅលើសន្ធិសញ្ញាដើម អាចជាសិទ្ធិ ឬយន្តការក្នុងការជួយដល់ការការពារសិទ្ធិ ទាំងនេះ ដូចជាសន្ធិសញ្ញាដែលអនុញ្ញាតឲ្យមានការស៊ើបអង្កេត និងបណ្តឹង។

## សន្ធិសញ្ញាអន្តរជាតិស្នូលទាំងប្រាំបួន

### តាមលំដាប់នៃកាលបរិច្ឆេទដែលចូលជាធរមាន

ICERD៖ អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍
អនុម័ត ឆ្នាំ១៩៦៥។ ចូលជាធរមានឆ្នាំ១៩៦៩។

ICESCR៖ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។
អនុម័ត ឆ្នាំ១៩៦៦។ ចូលជាធរមានឆ្នាំ១៩៧៦។
ពិធីសារបន្ថែម: បណ្តឹងបុគ្គល។ អនុម័តឆ្នាំ២០០៨ (មិនទាន់ចូលជាធរមាន)។

ICCPR៖ កតិកាសញ្ញាអន្តរជាតិអន្តរជាតិស្តីពីពលរដ្ឋ និងសិទ្ធិនយោបាយ
អនុម័ត ឆ្នាំ១៩៦៦។ ចូលជាធរមានឆ្នាំ១៩៧៦។
ពិធីសារបន្ថែម៖ បណ្តឹងបុគ្គល។ អនុម័ត ឆ្នាំ១៩៦៦។ ចូលជាធរមានឆ្នាំ១៩៧៦។
ពិធីសារបន្ថែម៖ ទោសប្រហារជីវិត។ អនុម័ត ឆ្នាំ១៩៨៩។ ចូលជាធរមានឆ្នាំ១៩៩១។

CEDAW៖ អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ

អនុម័ត ឆ្នាំ១៩៧៩។ ចូលជាធរមានឆ្នាំ១៩៨១។
ពិធីសារបន្ថែម៖ បណ្តឹងបុគ្គល។ អនុម័ត ឆ្នាំ១៩៩៩។ ចូលជាធរមានឆ្នាំ២០០០។

CAT៖ អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប
អនុម័ត ឆ្នាំ១៩៨៤។ ចូលជាធរមានឆ្នាំ១៩៨៧។
ពិធីសារបន្ថែម៖ ការស៊ើបអង្កេត និងការចូលមើល។ អនុម័ត ឆ្នាំ២០០២។ ចូលជាធរមានឆ្នាំ២០០៦។

CRC៖ អនុសញ្ញាស្តីពីសិទ្ធិកុមារ
អនុម័ត ឆ្នាំ១៩៨៩។ ចូលជាធរមានឆ្នាំ១៩៩០។
ពិធីសារបន្ថែម: កុមារកងកម្លាំងប្រដាប់អាវុធ។ អនុម័ត ឆ្នាំ២០០០។ ចូលជាធរមានឆ្នាំ២០០២។
ពិធីសារបន្ថែម៖ ការលក់កុមារ ពេស្យាកម្មកុមារ និងកាមសាស្ត្រកុមារ។ អនុម័ត ឆ្នាំ២០០០។ ចូលជាធរមានឆ្នាំ២០០២។
ពិធីសារបន្ថែម នីតិវិធិទំនាក់ទំនង។ អនុម័ត ឆ្នាំ២០១១។ ចូលជាធរមានឆ្នាំ២០០៩។

ICRMW៖ អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិរបស់ពលករទេសន្តប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ
អនុម័ត ឆ្នាំ១៩៩០។ ចូលជាធរមានឆ្នាំ២០០៣។

CRPD៖ អនុសញ្ញាស្តីពីសិទ្ធិជនពិការ
អនុម័ត ឆ្នាំ២០០៦។ ចូលជាធរមានឆ្នាំ២០០៨។
ពិធីសារបន្ថែម៖ បណ្តឹងបុគ្គល។ អនុម័ត ឆ្នាំ២០០៦។ ចូលជាធរមានឆ្នាំ២០០៨។

ICED៖ អនុសញ្ញាអន្តរជាតិស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ
អនុម័ត ឆ្នាំ២០០៦។ ចូលជាធរមានឆ្នាំ២០១០។

## ២.៩ ហេតុអ្វីរដ្ឋផ្តល់សច្ចាប័នលើសន្ធិសញ្ញាដែលជាបន្ទុកកាតព្វកិច្ចផ្លូវច្បាប់ដល់ពួកគេ?

ជាការចំលែកដែលរដ្ឋមួយព្រមព្រៀងដោយស្ម័គ្រចិត្តលើសន្ធិសញ្ញាមួយ ដែលអាចកម្រិតនូវអំណាចរបស់ពួកគេ។ សំណួរច្បាស់លាស់មួយដែលលេចឡើងគឺថាហេតុអ្វីបានជារដ្ឋធ្វើដូចនេះ? មាននូវហេតុផលមួយចំនួន។

១. រដ្ឋមានប្រជាជនដែលមានបំណងចង់ឲ្យមានការការពារសិទ្ធិរបស់ពួកគេ។ ជារឿយៗយើងប្រហែលជាភ្លេចថារដ្ឋត្រូវបានដឹកនាំដោយមនុស្ស ដែលទទួលបានសិទ្ធិរបស់ពួកគេ ឬ ពួកគេពឹងផ្អែកលើសង្គមស៊ីវិលសម្រាប់ការគាំទ្រឲ្យពួកគេបង្កើតរដ្ឋាភិបាល។ សំពាធពីសង្គមស៊ីវិលជាកម្លាំងជម្រុញចម្បងក្នុងការបញ្ចុះបញ្ចូលរដ្ឋក្នុងការព្រមព្រៀងលើសន្ធិសញ្ញា។ ជាការពិតណាស់ អង្គការសង្គមស៊ីវិលនៅក្នុងប្រទេសជាច្រើនបានរៀបចំព្រឹត្តការណ៍ដើម្បីជម្រុញ ឬដាក់សំពាធដល់រដ្ឋក្នុងការចុះហត្ថលេខាលើអនុសញ្ញាអន្តរជាតិ។

២. រដ្ឋព្រមព្រៀងជាស្រេចជាមួយនឹងកម្មវត្ថុ និងគោលបំណងរបស់សន្ធិសញ្ញា។ នៅក្នុងករណីមួយចំនួន សន្ធិសញ្ញាបង្កើតការប្តេជ្ញាចិត្តតិចតួចសម្រាប់រដ្ឋដោយសារពួកគេបានអាចមានសិទ្ធិជាច្រើន នៅក្នុងច្បាប់ជាតិរបស់ពួកគេរួចជាស្រេច។ នេះប្រហែលជាករណីសម្រាប់សិទ្ធិជនពិការ ដូចដែលរដ្ឋជាច្រើនបានទទួលស្គាល់សិទ្ធិជនពិការរួចមកហើយ។ ឬសម្រាប់រដ្ឋនៅអឺរ៉ុប តាមរយៈការព្រមព្រៀងលើអនុសញ្ញាប្រចាំតំបន់របស់ពួកគេ (អនុសញ្ញាស្តីពីសិទ្ធិមនុស្សរបស់អឺរ៉ុបក្នុងឆ្នាំ១៩៥០) ពួកគេត្រូវបានចងកាតព្វកិច្ចផ្លូវច្បាប់រួចជាស្រេចលើសិទ្ធិភាគច្រើនក្នុង ICCPR ឬ CEDAW។

៣. រដ្ឋគិតគូរពីកេរ្តិ៍ឈ្មោះនៅឆាកអន្តរជាតិរបស់ខ្លួន។ បញ្ហាកេរ្តិ៍ឈ្មោះក្នុងឆាកអន្តរជាតិ ហើយរដ្ឋដែលប្រឆាំងនឹងសិទ្ធិមនុស្ស ឬជាអ្នកដែលរំលោភបំពានសិទ្ធិមនុស្ស ជារឿយៗត្រូវបានចុចឈ្មោះ និងជាការអៀនខ្មាស់សម្រាប់រដ្ឋទាំងនេះ។ ដូចនេះ សូម្បីតែរដ្ឋដែលយើងសន្មតថាមិនយល់ស្របលើសិទ្ធិមនុស្ស ក៏នៅតែចុះហត្ថលេខាលើសិទ្ធិមនុស្សដែរ។ ជាឧទាហរណ៍ សូម្បីតែកូរ៉េខាងជើងដែលត្រូវបានចាត់ទុកថាជាអ្នករំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរជាងគេ ក៏បានព្រមព្រៀងលើសន្ធិសញ្ញាសិទ្ធិមនុស្សចំនួនបួនដែរ (ICCPR ICESCR CRC CEDAW)។

៤. សំពាធអន្តរជាតិ។ រដ្ឋអាចត្រូវបានជម្រុញ (ឬសូម្បីតែបង្ខំ) ដើម្បីព្រមព្រៀងលើសន្ធិសញ្ញាសិទ្ធិមនុស្សដោយរដ្ឋដទៃ ឬដោយអង្គការអន្តរជាតិ។ ជាឧទាហរណ៍ ប្រហែលជាផលប្រយោជន៍ដ៏ល្អប្រសើរបំផុត សម្រាប់រដ្ឋមួយក្នុងការព្រមព្រៀងលើសន្ធិសញ្ញាដើម្បីទទួលបានជំនួយ ឬក្លាយទៅជាសមាជិកនៃអង្គការមួយដូចជាអង្គការពាណិជ្ជកម្មពិភពលោក (WTO) ជាដើម។

៥. មិនមានឆន្ទៈក្នុងការអនុលោមតាម។ រដ្ឋខ្លះអាចមិនស្មោះត្រង់នៅពេលព្រមព្រៀងលើសន្ធិសញ្ញាមួយ៖ ពួកគេមិនមានឆន្ទៈក្នុងការអនុលោមតាម ប៉ុន្តែគិតថាសន្ធិសញ្ញានឹងផ្តល់នូវកេរ្តិ៍ឈ្មោះល្អដល់ពួកគេ ដូចនេះពួកគេចុះហត្ថលេខា។ យ៉ាងណាមិញ ដូចដែលការស្រាវជ្រាវបានបង្ហាញ ការព្រមព្រៀងដោយមិនស្មោះត្រង់នៅក្នុងរយៈពេលជារឿយៗមានលទ្ធផលដែលរដ្ឋអនុលោមតាម នៅពេលដែលប្រជាជនជ្រាបដឹងពីសិទ្ធិរបស់ខ្លួន ពួកគេអាចបង្ខំរដ្ឋក្នុងការអនុលោមតាម។

៦. តាមបក្សពួក។រដ្ឋជាច្រើនព្រមព្រៀង ឬបដិសេធ សន្ធិសញ្ញាដើម្បីស្របគ្នាជាមួយនឹងដៃគូតំបន់ ឬនយោបាយរបស់ខ្លួន។ ជាឧទាហរណ៍ រដ្ឋភាគច្រើននៅសហភាពអឺរ៉ុបបានព្រមព្រៀងលើសន្ធិសញ្ញាដូចគ្នា ដូចជានៅអាហ្វ្រិកខាងត្បូងមិនមានរដ្ឋណាបានព្រមព្រៀងលើអនុសញ្ញាជនភៀសខ្លួននោះទេ។ យ៉ាងណាមិញ ប្រទេសនៅអាស៊ីអាគ្នេយ៍មិនអនុវត្តនូវទស្សនៈ រួមថ្នាក់តំបន់នេះក្នុងការព្រមព្រៀងលើសន្ធិសញ្ញានោះទេ ដោយសារចំនួននៃការផ្តល់សច្ចាប័នគឺខុសគ្នាខ្លាំងមែនទែន។ ប្រភេទនៃ "ការតាមបក្សពួក" មួយទៀត កើតឡើងនៅពេលដែលសន្ធិសញ្ញាទទួលបានការគាំទ្រស្ទើរតែជាសកល ដូចជាសិទ្ធិស្ត្រី (ដែលមានតែរដ្ឋចំនួនប្រាំពីរប៉ុណ្ណោះមិនបានព្រមព្រៀង) និងសិទ្ធិកុមារ (ដែលមានតែចំនួនពីរប៉ុណ្ណោះដែលមិនបានផ្តល់សច្ចាប័ន)៖ រដ្ឋនឹងព្រមព្រៀងលើសន្ធិសញ្ញាទាំងនេះ ដោយសារពួកគេមិនចង់ក្លាយជាផ្នែកមួយនៃក្រុមប្រទេសដែលមិនអនុលោមតាមសន្ធិសញ្ញា។ អនុសញ្ញាស្តីពីសិទ្ធិជាពិការកំពុងតែស្ថិតក្នុងគន្លងនេះផងដែរដែលមាន ៨៥% នៃពិភពលោកបានព្រមព្រៀងលើអនុសញ្ញានេះរួចជាស្រេច។

# ក.សេចក្តីសង្ខេបពីជំពូក និងចំនុចគន្លឹះ

## ស្តង់ដារសិទ្ធិមនុស្ស

សិទ្ធិមនុស្សបង្កើតស្តង់ដារជាក់លាក់មួយ នៃការប្រព្រឹត្តមកលើមនុស្សជាតិទាំងអស់។ ស្តង់ដារមាននៅក្នុងទាំងច្បាប់អន្តរជាតិសាធារណៈ (PIL) និងច្បាប់ជាតិ។ ការអភិវឌ្ឍនូវស្តង់ដារទាំងនេះកាលពីពេលថ្មីៗនេះ គឺជាការឆ្លើយតបនឹងភាពសាហាវយង់ឃ្នងនៃសង្គ្រាមលោកលើកទីពីរ។ ស្តង់ដារសិទ្ធិមនុស្សអន្តរជាតិត្រូវបានគាំទ្រដោយសន្ធិសញ្ញាដែលជាកិច្ចព្រមព្រៀងចងកាតព្វកិច្ចផ្លូវច្បាប់។ ជាដំបូងស្តង់ដារសិទ្ធិមនុស្សជារឿងសាមញ្ញទូទៅសម្រាប់ច្បាប់ជាតិ ប៉ុន្តែបច្ចុប្បន្នស្តង់ដារសិទ្ធិមនុស្សជាផ្នែកមួយសំខាន់នៃ PIL។

## ច្បាប់អន្តរជាតិសាធារណៈ មូលដ្ឋានគ្រឹះ

ច្បាប់អន្តរជាតិ និងច្បាប់ជាតិខុសគ្នាជាច្រើន។ ច្បាប់ជាតិត្រូវបានធ្វើឡើងរដ្ឋាភិបាល ហើយចាប់បង្ខំអនុវត្តដោយតុលាការ។ កម្មវត្ថុនៃច្បាប់ជាតិគឺជាប្រជាពលរដ្ឋនៃប្រទេសនោះ ដែលមិនពាក់ព័ន្ធដោយផ្ទាល់ក្នុងការធ្វើ ឬចាប់បង្ខំអនុវត្តច្បាប់ ប៉ុន្តែជាកម្មវត្ថុនៃច្បាប់។ PIL ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ និងអាកប្បកិរិយារបស់រដ្ឋអធិបតេយ្យ និងអង្គការអន្តរជាតិ។ ច្បាប់អន្តរជាតិសាធារណៈត្រូវបានតាក់តែង ដោយរដ្ឋនានាក្នុងការគ្រប់គ្រងនូវអាកប្បកិរិយារបស់ខ្លួន។ ច្បាប់អន្តរជាតិសាធារណៈមានប្រភពបួន សំខាន់ៗ៖ (១)សន្ធិសញ្ញា (២)ទំនៀមទំលាប់ (៣)គោលការណ៍ទូទៅ (៤)សេចក្តីសម្រេចរបស់តុលាការ និងសំណេរស្តីពីច្បាប់អន្តរជាតិ។ សន្ធិសញ្ញាជាកិច្ចព្រមព្រៀងរវាងរដ្ឋ ហើយជារឿយៗកើតមានក្នុងទម្រង់ជាលាយលក្ខអក្សរ ដែលរដ្ឋស្ម័គ្រចិត្តក្នុងការព្រមព្រៀង។ នៅពេលដែលប្រទេសមួយ បានព្រមព្រៀងថាចងកាតព្វកិច្ចស្របច្បាប់លើសន្ធិសញ្ញាមួយ រដ្ឋនោះក្លាយជារដ្ឋភាគីនៃសន្ធិសញ្ញា ច្បាប់អន្តរជាតិទំនៀមទំលាប់ជាទម្រង់ ដែលមិនសរសេរជាលាយលក្ខអក្សរ នៃច្បាប់ដែលជាលទ្ធផលនៃការអនុវត្តដ៏យូរអង្វែងរបស់រដ្ឋ។ គោលការណ៍ទូទៅជាផ្នែកនៃច្បាប់ដែលជារឿងទូទៅក្នុងច្បាប់ជាតិ ដែល ពួកគេរំពឹងថានឹងក្លាយជាផ្នែកមួយនៃPILផងដែរ។ ច្បាប់ទំនៀមទំលាប់ *Jus cogesn* និង វិធានដាច់ខាត ជាផ្នែកនៃPIL ដែលមិនត្រូវការផ្តល់សច្ចាប័នលើសន្ធិសញ្ញាដើម្បីចាត់ទុកថាជាច្បាប់ចំពោះរដ្ឋមួយនោះទេ ជាឧទាហរណ៍រួមមានសេរីភាពដែលរួចផុតពីការធ្វើទារុណកម្ម និងទាសភាព និងសិទ្ធិរស់រានមានជីវិត។

## ប្រវត្តិនៃការអភិវឌ្ឍស្តង់ដារសិទ្ធិមនុស្ស

ស្តង់ដារសិទ្ធិមនុស្សអន្តរជាតិពេលបច្ចុប្បន្ន ភាគច្រើនក្រោយសង្គ្រាមលោកលើកទីពីរ ប៉ុន្តែពួកគេបន្តពីកិច្ចព្រមព្រៀង និងសន្ធិសញ្ញាកាលពីមុនលើប្រធានបទដូចជាទាសភាព ក្រមសីលធម៌នៃសង្គ្រាម និងការការពារជនជាតិភាគតិចជាដើម។ ព្រឹត្តការណ៍សំខាន់សម្រាប់ការអភិវឌ្ឍស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ គឺជាការបង្កើតអង្គការសហប្រជាជាតិ ដែលកំណត់ថាសិទ្ធិមនុស្សគឺជាគោលបំណងចម្បង។ ឯកសារជាសកលដំបូងគឺ UDHR ដែលត្រូវបានបញ្ចប់ការព្រាងក្នុងរយៈពេលពីរឆ្នាំដោយគណៈកម្មាការសិទ្ធិមនុស្ស។ UDHR ជាសេចក្តីប្រកាសដែលមិនមានឋានៈចងកាតព្វកិច្ចផ្លូវច្បាប់ជាផ្លូវការ ទោះបីជាមានការអះអាងថាសេចក្តីប្រកាសនេះ ឬផ្នែកខ្លះនៃសេចក្តីប្រកាសនេះ ពិតជាមានកាតព្វកិច្ចផ្លូវច្បាប់លើរដ្ឋសមាជិករបស់ UN ក៏ដោយ។ UDHR កំណត់ពីមូលដ្ឋានគ្រឹះនៃការបង្កើតសន្ធិសញ្ញាសិទ្ធិមនុស្សដែលចងកាតព្វកិច្ចផ្លូវច្បាប់។

## ការបង្កើតសន្ធិសញ្ញា៖ ទិដ្ឋភាពទូទៅមួយ

សន្ធិសញ្ញាចាប់ផ្តើមនៅពេលដែលសហគមន៍អន្តរជាតិ អង្កេតឃើញពីតម្រូវការដែលក្រុមមួយចំនួនត្រូវការការពារដោយច្បាប់អន្តរជាតិ។ វឌ្ឍនភាពអាចត្រូវបានបង្កើតដោយក្រុមដែលពាក់ព័ន្ធដូចជារដ្ឋ អង្គការអន្តរជាតិ និងសង្គមស៊ីវិល។ សន្ធិសញ្ញាសិទ្ធិមនុស្សជាទូទៅត្រូវបានព្រាងដោយស្ថាប័ន UN មួយ នៅពេលរួចរាល់ បើកឲ្យរដ្ឋសមាជិកចុះហត្ថលេខា។ នៅពេលរដ្ឋចុះហត្ថលេខាលើសន្ធិសញ្ញា ពួកគេព្រមព្រៀងក្នុងការរំលោភបំពានលើកម្មវត្ថុ និងគោលបំណងនៃសន្ធិសញ្ញានោះទេ ប៉ុន្តែរដ្ឋមិនទាន់បានចងកាតព្វកិច្ចផ្លូវច្បាប់ដោយអនុសញ្ញានៅឡើយទេ។ រដ្ឋមានកាតព្វកិច្ចផ្លូវច្បាប់ចំពោះសន្ធិសញ្ញាមួយនៅពេល ដែលខ្លួនបានផ្តល់សច្ចាប័នលើសន្ធិសញ្ញានេះ ហើយសន្ធិសញ្ញានេះចូលជាធរមានដោយតាមរយៈធ្វើខលក្ខខណ្ឌ ដែលមានន័យថារដ្ឋអាចជ្រើសរើសក្នុងការមិនចងកាតព្វកិច្ចលើមាត្រា ដែលខ្លួនបានដាក់ខលក្ខខណ្ឌ ឬធ្វើការបញ្ជាក់ពីការយល់ដឹងលើសន្ធិសញ្ញា ដែលបញ្ជាក់លម្អិតពីវិធីដែលខ្លួននឹងបកស្រាយមាត្រានៃសិទ្ធិ។ សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិចងកាតព្វកិច្ចផ្លូវច្បាប់ ប៉ុន្តែចំពោះរដ្ឋដែលបានផ្តលសច្ចាប័នលើសន្ធិសញ្ញាប៉ុណ្ណោះ។

## ហេតុអ្វីបានជារដ្ឋផ្តល់សច្ចាប័នលើសន្ធិសញ្ញា?

រដ្ឋស្ម័គ្រចិត្តក្នុងការក្លាយទៅជារដ្ឋភាគីនៃសន្ធិសញ្ញាមួយ ដោយមានហេតុផលមួយចំនួន។ ពួកគេឆ្លើយតបនឹងការតស៊ូមតិរបស់សង្គមស៊ីវិល ឬប្រជាជននៅក្នុងប្រទេសរបស់ខ្លួន ឬរដ្ឋាភិបាលអាចព្រមព្រៀងរួចជាស្រេចលើសិទ្ធិក្នុងអនុសញ្ញា។ រដ្ឋអាចព្រមព្រៀងផងដែរលើសន្ធិសញ្ញាដោយសារខ្លួនគិតរដ្ឋដទៃចាត់ទុករដ្ឋខ្លួនថាជារដ្ឋល្អ រដ្ឋដែលគោរពតាមច្បាប់ ឬក៏ពួកគេអនុវត្តតាមសកម្មភាពរបស់រដ្ឋដទៃ ដែលបានព្រមព្រៀងលើសន្ធិសញ្ញា។ រដ្ឋមួយចំនួនអាចត្រូវបានជម្រុញទឹកចិត្តឲ្យចុះហត្ថលេខា

ដូចនេះពួកគេអាចមានលទ្ធភាពក្នុងការចូលជាសមាជិកអង្គការអន្តរជាតិ ឬទទួលជំនួយ ឬពាណិជ្ជកម្មអន្តរជាតិ។ ទោះបីជារដ្ឋព្រមព្រៀងដោយមិនមានឆន្ទៈក្នុងការអនុលោមតាមជាមួយនឹងស្តង់ដារ នៅក្នុងរយៈពេលវែង ពួកគេនឹងអនុវត្តតាមកាតព្វកិច្ចសន្ធិសញ្ញា។

## ខ. សំណួរប្រលង ឬសំណួរងាយស្រួល

- តើអ្វីជាឧទាហរណ៍នៃសិទ្ធិដែលមានក្នុងច្បាប់ជាតិមុនពេលមាន UDHR។ តើប្រទេសរបស់អ្នកមានសិទ្ធិទាំងនេះមុន UDHR ដែរឬទេ?
- តើអ្វីជាការខុសគ្នាចម្បងរវាងការពារសិទ្ធិមនុស្ស ក្នុងប្រព័ន្ធច្បាប់អន្តរជាតិសាធារណៈ និងក្នុងប្រព័ន្ធច្បាប់ជាតិ? តើអ្វីជាចំនុចខ្លាំង និងអ្វីជាចំនុចខ្សោយនៃការការពារក្នុងប្រព័ន្ធនីមួយៗ?
- ពិនិត្យលើសិទ្ធិមនុស្សមួយដែលមានវត្តមានជាទំនៀមទំលាប់ (ជាឧទាហរណ៍សេរីភាពរួចផុតពីទាសភាពនិង/ឬទារុណកម្ម) ហើយពិពណ៌នាពីប្រវត្តិរបស់វា។
- តើតួនាទីអ្វីដែលប្រទេសមិនមែនលោកខាងលិចមានក្នុងការព្រាង UDHR? តើនេះមានន័យថា UDHR ជាឯកសារជាសកលមួយដែរឬទេ ឬវាគ្រាន់តែជាសម្រាប់លោកខាងលិច?
- ហេតុអ្វីបានជាប្រទេសដែលអ្នករស់នៅជ្រើសរើសក្នុងការផ្តល់សច្ចាប័ន ឬមិនផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្ស? តាមរយៈការពិនិត្យលើប្រវត្តិនៃការផ្តល់សច្ចាប័ននៅក្នុងប្រទេសរបស់អ្នក ពិភាក្សាថាហេតុអ្វីបានជាសន្ធិសញ្ញាត្រូវបានផ្តល់សច្ចាប័ននាពេលនោះក្នុងប្រវត្តិសាស្ត្រ។

# គ. ឯកសារពិគ្រោះបន្ថែម

ច្បាប់សិទ្ធិមនុស្ស និងច្បាប់អន្តរជាតិសាធារណៈ៖
មានសៀវភៅពុម្ពសេចក្ដីផ្ដើមស្ដីពីច្បាប់អន្តរជាតិសាធារណៈជាច្រើន ដែលមានក្នុងបណ្ណាល័យតាមសាកលវិទ្យាល័យ។ ខ្លឹមសារដែលមាននៅចុងបញ្ចប់ នៃជំពូកមួយជាការចាប់ផ្ដើមល្អប្រសើរមួយ។

## ការអភិវឌ្ឍនៃសិទ្ធិមនុស្ស

ចំពោះប្រវត្តិនៃការព្រាង និងការអនុម័ត UDHR និងការអភិវឌ្ឍសិទ្ធិមនុស្ស អ្នកអាចស្រាវជ្រាវពីអ៊ិនធឺណែតដោយរកឈ្មោះអ្នកនិពន្ធ ដូចខាងក្រោមដែលបានបោះពុម្ពផ្សាយអត្ថបទ និងសៀវភៅលើប្រធានបទនេះ៖

- Johannes Morsink,
- Mary Ann Glendo,
- Paul Gordon Lauren,

- Samuel Moyn,
- Mark Mazower,
- Susan Waltz

## រដ្ឋ និងការផ្ដល់សច្ចាប័ន

មានការសិក្សាគួរឲ្យចាប់អារម្មណ៍មួយចំនួនតូចលើថាហេតុអ្វីបានជារដ្ឋផ្ដល់សច្ចាប័ន (ឬមិនផ្ដល់សច្ចាប័ន)លើសន្ធិសញ្ញា។ សម្រាប់ឯកសារពិគ្រោះបន្ថែម សូមស្រាវជ្រាវពីអ៊ិនធឺណែតដោយរកឈ្មោះអ្នកនិពន្ធដូចខាងក្រោម៖

- Beth Simmons
- Oona Hathaway
- Ryan Goodman
- Derek Jinks
- Harold Koh

3

# សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ

ដោយទទួលស្គាល់ថា UDHR មិនចងកាតព្វកិច្ច សហគមន៍អន្តរជាតិបានចាប់ផ្ដើមជំហានទីពីរ នៃការបញ្ចូលសិទ្ធិមនុស្សទៅក្នុងឆាកអន្តរជាតិ ដោយសរសេរចូលក្នុងសន្ធិសញ្ញាមួយ។ ការព្រាងចាប់ភ្លាមៗបន្ទាប់ពីការអនុម័ត UDHR ក្នុងឆ្នាំ១៩៤៨។ គោលបំណងដើមនៃការប្រែក្លាយ UDHR ទៅជាសន្ធិសញ្ញាតែមួយត្រូវបានបោះបង់ចោល ហើយបន្ទាប់មកមានផែនការធ្វើសន្ធិសញ្ញាចំនួនពីរ ទោះបីជាក្នុងរយៈពេលដប់ប្រាំបីឆ្នាំ ក្រោយមកទើបសន្ធិសញ្ញាទាំងពីរត្រូវបានបង្ហាញនៅមហាសន្និបាតរបស់ UN (UNGA) សម្រាប់ការចុះហត្ថលេខា និងអនុម័ត។

មានហេតុផលជាច្រើនចំពោះការសម្រេចចិត្តថាមានសន្ធិសញ្ញាពីរ ជាជាងមានមួយៈ ការបែងចែកនយោបាយដែលកើតមានដោយសង្គ្រាមត្រជាក់ ការចូលជាសមាជិករបស់ UN ពីរដ្ឋរួចផុតពីអាណានិគមជាច្រើននៅអាស៊ី និងអាហ្វ្រិកដែលបាននាំមកនូវជាមួយទស្សនៈផ្សេងពីសិទ្ធិមនុស្ស ហើយក៏មានជម្រើសមួយចំនួនលើវិធីសាស្ត្រក្នុងការចាប់បង្ខំអនុវត្តសិទ្ធិផ្សេងៗតាមផ្លូវច្បាប់។

ខណៈពេលដែលអ្នកខ្លះ បានចាត់ទុកសង្គ្រាមត្រជាក់ថាជាការរួមចំនែកចម្បងក្នុងការពន្យាពេល ហេតុផលផ្សេងទៀតក៏មានសារៈសំខាន់ផងដែរ។ រដ្ឋមានភាពប្រុងប្រយ័ត្នពីទស្សនៈលើសិទ្ធិដែលចងកាតព្វកិច្ចផ្លូវច្បាប់ ថាជាការប្រឆាំងនឹងសេចក្តីប្រកាសដែលមានលក្ខណៈទូលំទូលាយ ដូចនេះការព្រាងត្រូវការភាពសុក្រិតពាក់ព័ន្ធនឹងភារកិច្ច និងកាតព្វកិច្ចដែលសន្ធិសញ្ញាដាក់លើរដ្ឋ។ បន្ថែមពីលើនេះទៀត ក្នុងអំឡុងពេលនេះ (១៩៤៨-១៩៦៦) UN ជាស្ថាប័នដែលមានការវិវត្តន៍លឿនមួយដែលមានសមាជិកចំនួនប្រហែលជា ៦០ បានចូលរួមក្នុងអំឡុងពេលនេះ (កើនឡើងចំនួនសមាជិកទ្វេដង) ភាគច្រើននៃរដ្ឋទាំងនោះចងមានធាតុចូលទៅក្នុងសន្ធិសញ្ញាអន្តរជាតិផងដែរ។ ជាចុងក្រោយមានភាពខុសគ្នាមួយចំនួនក្នុងទ្រឹស្តីនៃសិទ្ធិមនុស្ស រវាងរដ្ឋមូលនិធននិយមបែបប្រជាធិបតេយ្យនៃលោកខាងលិច និងប្រទេសសង្គមនិយមនៃសហភាពសូវៀត ហើយក្រោយមកទៀតរដ្ឋដែលរួចផុតពីអាណានិគម ដែលជាប្រទេសកំពុងអភិវឌ្ឍន៍។ ពាក់ព័ន្ធនឹងដំណាក់ចុងក្រោយនេះ សិទ្ធិក្នុងការរួចផុតពីអាណានិគមនិយម (ស្វ័យសម្រេច) និងសិទ្ធិនៃការមិនរើសអើងគឺ មានសារៈសំខាន់បំផុត។ ចំពោះប្រទេសលោកខាងលិចជាច្រើន (ភាគច្រើនប្រជាធិបតេយ្យបែបមូលធននិយម) សិទ្ធិនយោបាយ និងសេរីភាពក្នុងការបញ្ចេញមតិត្រូវបានចាត់ទុកថាមានសារៈសំខាន់។ សម្រាប់ប្រទេសកុំម្មុយនិសកាតព្វកិច្ចរដ្ឋពាក់ព័ន្ធនឹងសុខភាព ការអប់រំ និងសិទ្ធិរបស់កម្មករត្រូវបានចាត់ទុកថាមានសារៈសំខាន់។ ដូចនេះ ផលប្រយោជន៍ដែលមានការប្រកួតប្រជែងនេះមានឥទ្ធិពលក្នុងការពន្យឺតការចរចារជុំវិញនីតិវិធីព្រាងសន្ធិសញ្ញា។

តាំងពីដំបូង មានការយល់ឃើញថាការរក្សាប្រភេទសិទ្ធិទាំងពីរ (សិទ្ធិពលរដ្ឋ និងនយោបាយ ជាមួយនឹងសេដ្ឋកិច្ច និងសង្គម) ក្នុងសន្ធិសញ្ញាតែមួយអាចជាការប្រឈមដោយសារការអនុលោមតាមប្រភេទនីមួយៗនៃសិទ្ធិគឺខុសគ្នា។ ភាពខុសគ្នានេះ ជម្រុញឲ្យមានការបែងចែកគ្នារវាងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក្នុងទិដ្ឋភាពម្យ៉ាង ហើយនិងម្យ៉ាងទៀតគឺរវាងសិទ្ធិសេដ្ឋកិច្ច និងសង្គម។ បន្ទាប់មកទៀតមានការសម្រេចចិត្តថាចង្កោមសិទ្ធិទាំងពីរនេះ អាចត្រូវបានចាប់បង្ខំអនុវត្តតាមរយៈនីតិវិធីផ្សេងគ្នា។ ចំពោះសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ការអនុលោមតាមនៅក្នុងករណីភាគច្រើនត្រូវបាន

អនុវត្តនៅពេលដែលសន្ធិសញ្ញាចូលជាធរមាន។ ជាឧទាហរណ៍ រដ្ឋមិនគួរអនុវត្តការផ្លាស់ប្តូរបន្តិចម្តងៗក្នុងការបញ្ឈប់ការធ្វើទារុណកម្មនោះទេ ប៉ុន្តែពួកគេត្រូវបញ្ឈប់ភ្លាមៗនូវការធ្វើទារុណកម្ម។ យ៉ាងណាមិញ រដ្ឋដែលក្រីក្រ ឬកំពុងអភិវឌ្ឍត្រូវតម្រូវឲ្យធ្វើការបន្តិចម្តងៗ ឆ្ពោះទៅកាន់ផ្តល់ជូនពលរដ្ឋរបស់ខ្លួននូវសិទ្ធិសេដ្ឋកិច្ច និងសង្គម ដូចជាលទ្ធភាពក្នុងការទទួលបានការថែទាំសុខភាព ឬក៏ធានានូវវត្តមាននូវវិទ្យាល័យជាដើម។ ដោយសារការព្រមព្រៀងលើសន្ធិសញ្ញាមួយ ជាការសម្រេចដែលថាវាមិនអាចទៅរួចនោះទេក្នុងការរំពឹងថាប្រទេសកំពុងអភិវឌ្ឍ អាចផ្តល់សិទ្ធិក្នុងការទទួលបានការថែទាំសុខភាព ការអប់រំ និងលំនៅដ្ឋានភ្លាមៗ។ ជាចុងក្រោយ តើថាសិទ្ធិនៅក្នុងសន្ធិសញ្ញាត្រូវបានការពារយ៉ាងដូចម្តេច វាជាកង្វល់សម្រាប់រដ្ឋាភិបាលភាគច្រើន តើអ្នកណាជាអ្នកធានាថារដ្ឋាភិបាលអនុលោមតាមសន្ធិសញ្ញា? ប្រសិនបើរដ្ឋាភិបាលមិនអនុលោមតាម តើរដ្ឋាភិបាលអាចត្រូវទទួលទណ្ឌកម្មដែរឬទេ? ជាការសម្រេចថាសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយមានកាតព្វកិច្ចផ្លូវច្បាប់ច្បាស់លាស់ ហើយទាំងនេះអាចត្រូវបានវាយតម្លៃដោយស្ថាប័នសន្ធិសញ្ញា។ សន្ធិសញ្ញា ICCPR កំណត់នូវនីតិវិធីការងារនៃស្ថាប័នេះ។ យ៉ាងណាមិញ មិនមានផែនការជាបឋមក្នុងការបង្កើតស្ថាប័នសន្ធិសញ្ញាសម្រាប់ ICESCR នោះទេ ដោយសារយល់ឃើញថាសិទ្ធិទាំងនេះមានការពិបាកក្នុងការវាយតម្លៃប្រសិនការរំលោភបំពានមួយកើតឡើង ហើយដូចនេះសន្ធិសញ្ញាមិនបានបង្កើតស្ថាប័នសន្ធិសញ្ញានោះទេ (យ៉ាងណាមិញ ទស្សនៈបានផ្លាស់ប្តូរ ហើយស្ថាប័នមួយត្រូវបានបង្កើតឡើងដំណាលគ្នា នឹងស្ថាប័នសន្ធិសញ្ញា ICCPR ប៉ុន្តែមិនមែនដោយសារ ICESCR នោះឡើយ)។

នៅទីបញ្ចប់ ប្រព័ន្ធបានលេចចេញជារូបរាងដែលធ្វើការចាប់បង្ខំអនុវត្ត ICCPR ភ្លាមៗ បន្ទាប់ពីសន្ធិសញ្ញានេះចូលជាធរមាន។ ការលើកលែងតែមួយគត់គឺសិទ្ធិមួយចំនួនអាចធ្វើបដិប្បញ្ញត្តិបាន ដែលមានន័យថាក្នុងកាលៈទេសៈពិសេសមួយចំនួន រដ្ឋមិនមានកាតព្វកិច្ចក្នុងការចាប់បង្ខំសិទ្ធិទាំងនេះនោះទេ។ តាមន័យថាម្យ៉ាង សិទ្ធិ ICCPR អាចបិទ និងបើក (ដូចជាការបិទ និងបើកភ្លើងផងដែរ) ទោះបីជាសិទ្ធិខ្លះ (មិនអាចធ្វើបដិប្បញ្ញត្តិបាន) ត្រូវតែបើកគ្រប់ពេលក៏ដោយ។ ផ្ទុយទៅវិញ សិទ្ធិក្នុង ICESCR គឺមានលក្ខណៈខុសៗគ្នា។ ជាការពិតរដ្ឋមិនអាចកសាងប្រព័ន្ធសុខភាព និងការអប់រំបានភ្លាមៗនោះទេ ត្រូវធ្វើកិច្ចការនេះបន្តិចម្តងៗ តាមដំណើរការមួយដែលហៅថា 'ការសម្រេចបានជាបណ្តើរៗ'។ ដូចមានបញ្ជាក់លម្អិតខាងក្រោម រដ្ឋមានកាតព្វកិច្ចមួយក្នុងការឈានឆ្ពោះទៅមុខក្នុងការបំពេញសិទ្ធិសេដ្ឋកិច្ច និងសង្គមសម្រាប់មនុស្សគ្រប់រូប។ ជាលទ្ធផលនៃភាពខុសគ្នានេះ សន្ធិសញ្ញាពីរត្រូវបានព្រាងដាច់ដោយឡែកពីគ្នា ប៉ុន្តែត្រូវបានអនុម័តនៅពេលជាមួយគ្នានៅ UNGA ហើយបានចូលជាធរមាននៅស្ទើរតែពេលជាមួយគ្នា (ICESCR បានចូលជាធរមានបីខែមុន ICCPR នៅថ្ងៃទី ៣ ខែមករា ឆ្នាំ១៩៧៦)។ ដូចដែលការចង្អុលបង្ហាញ ពីសារៈសំខាន់របស់ខ្លួន សន្ធិសញ្ញាទាំងពីរ

នេះត្រូវបានដាក់ឈ្មោះថាជា "កតិកាសញ្ញា" ជាជាងអនុសញ្ញា ដោយសារពាក្យថា កតិកាសញ្ញាបង្កប់ន័យថាកិច្ចសន្យាដែលកាន់តែសំខាន់ ឬតឹងរឹង។

## ៣.១ ICCPR

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយបានចូលជាធរមាននៅថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៧៦។ មកដល់ពេលបច្ចុប្បន្ននេះ ប្រទេសប្រហែលជា ១៧០ បានផ្តល់សច្ចាប័នលើកតិកាសញ្ញានេះ។ វៀតណាមផ្តល់សច្ចាប័នមុនគេអង្គស់លើ ICCPR ក្នុងចំណោមរដ្ឋនៅអាស៊ីអាគ្នេយ៍ក្នុងឆ្នាំ (១៩៨២) បន្ទាប់មកហ្វីលីពីន (១៩៨៦) កម្ពុជា (១៩៩២) ថៃ(១៩៩៦) ឡាវ(២០០០) និងឥណ្ឌូនេស៊ី (២០០៦)។ សន្ធិសញ្ញានេះមិនទាន់បានចុះហត្ថលេខាដោយប្រ៊ុយណេ ម៉ាឡេស៊ី ឬសឹង្ហបូរីនៅឡើយទេ។

ខណៈពេលដែលមិនអាចធ្វើទៅបាន ក្នុងការផ្តល់ហេតុផលជាក់លាក់ថាហេតុអ្វីបានជារដ្ឋាភិបាលបដិសេធក្នុងការផ្តល់សច្ចាប័នលើសន្ធិសញ្ញាមួយ សឹង្ហបូរីបាននិយាយថានៅបរិវេណ UN (ដែលក្នុងករណីនេះក្នុងអំឡុងពេលរបាយការណ៍សម្រាប់ការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់ក្នុងឆ្នាំ២០១១) ថា "រដ្ឋាភិបាលសឹង្ហបូរីយកចិត្តទុកដាក់លើកាតព្វកិច្ចអនុសញ្ញារបស់ខ្លួនតឹងរឹងមែនទែន ហើយជ្រើសរើសក្នុងការមិនចុះហត្ថលេខាលើសន្ធិសញ្ញា ដរាបណាខ្លួនមិនច្បាស់ថាខ្លួនអាចអនុវត្តបានពេញលេញតាមកាតព្វកិច្ចរបស់ខ្លួនទាំងអស់"។ ខណៈពេលដែលរដ្ឋាភិបាលមិនបានបញ្ជាក់ច្បាស់លាស់តើថាកាតព្វកិច្ចណាមួយដែលខ្លួនមិនអាចបំពេញនេះ ជាចំនេះដឹងទូទៅដែលថាសឹង្ហបូរីមិនអនុញ្ញាតឲ្យមានសេរីភាព ក្នុងការបញ្ចេញមតិ សិទ្ធិក្នុងការប្រជុំ និងសិទ្ធិសមាគមបានពេញលេញនោះទេ ។ ដែនកំណត់ទាំងនេះមិនត្រូវបានរៀបរាប់ដោយរដ្ឋាភិបាលសឹង្ហបូរីនោះទេ ប៉ុន្តែពួកគេបានបញ្ជាក់ថា "ក្នុងនាមជារដ្ឋក្មេងខ្ចីមួយដែលមានប្រជាជនជម្រុះពូជសាសន៍ សាសនា និងភាសា សឹង្ហបូរីមិនត្រូវមានកំហុសនោះទេ" បង្កប់ន័យថាសេរីភាពខ្លាំងពេកអាចឈានទៅដល់អស្ថេរភាពពូជសាសន៍។ ជាចុងក្រោយ រដ្ឋាភិបាលសឹង្ហបូរីក៏បានសំដៅផងដែរ លើជំហរបស់ខ្លួនដែលថា សិទ្ធិមនុស្សត្រូវអនុលោមតាមស្តង់ដារជាតិរបស់ពួកគេ ហើយមិនមែនផ្ទុយពីនេះនោះទេ នៅពេលដែលខ្លួនបញ្ជាក់ថា "ឥរិយាបថដែលសិទ្ធិទាំងអស់ត្រូវបានទទួល និងអនុវត្ត យ៉ាងណាមិញត្រូវទទួលស្គាល់កាលៈទេសៈ និងឆន្ទៈជាក់លាក់របស់ជាតិ"។ នេះរដ្ឋាភិបាលសឹង្ហបូរីកំពុងសំដៅលើការជជែកវែកញែករវាងសិទ្ធិជាសកល និង 'លក្ខណៈពិសេសជាតិ និងប្រចាំតំបន់' ដែលបានកើតឡើងជុំវិញការអនុម័តសេចក្តីប្រកាស និងផែនការសកម្មភាពទីក្រុងវៀនក្នុងឆ្នាំ១៩៩៣។

ICCPR ធ្វើឲ្យសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក្នុង UDHR ក្លាយទៅជាសិទ្ធិដែលចងកាតព្វកិច្ចផ្លូវច្បាប់។ មិនដូចគ្នាបេះបិទទៅនឹង UDHR នោះទេ ដោយសារ ICCPR ក៏បានបន្ថែមសិទ្ធិដែលមិនមានក្នុង UDHR ផងដែរ ដូចជាស្វ័យសម្រេច និងការហាមឃាត់ការនិរទេស និង សំដីមើលងាយរើសអើង ហើយក៏បានបោះបង់ចោលសិទ្ធិមួយចំនួនក្នុង UDHR ផងដែរ ដូចជាសិទ្ធិទ្រព្យសម្បត្តិ និងសិទ្ធិជ្រកកោនដែលមិនមានក្នុង ICCPR នោះទេ។

## ផ្ដោតសំខាន់លើ

### ពិធីសារបន្ថែម ICCPR

មានពិធីសារបន្ថែមពីរបន្ថែមលើ ICCPR។ ទីមួយអនុញ្ញាតឲ្យបុគ្គលដាក់ពាក្យបណ្ដឹងទៅគណៈកម្មាធិការសិទ្ធិមនុស្ស ជាដំណើរការមួយដែលនឹងត្រូវបានពិភាក្សាបន្ថែមទៀតក្នុងជំពូកបន្ទាប់។ ទីពីរគឺពិធីសារបន្ថែមដែលបញ្ជាក់ពីការប្ដេជ្ញាចិត្តមួយក្នុងការលុបបំបាត់ទោសប្រហារជីវិតដែលនឹងត្រូវពិភាក្សាខាងក្រោម។

រដ្ឋភាគីនៃ ICCPR ចងកាតព្វកិច្ចភ្លាមៗដើម្បី "គោរព និងធានា" សិទ្ធិនៅក្នុងសន្ធិសញ្ញាសម្រាប់បុគ្គលគ្រប់រូបនៅក្នុងទឹកដីរបស់រដ្ឋ និងនៅក្នុងអំណាចរបស់ខ្លួន។ **យុត្តាធិការ**នៃសន្ធិសញ្ញាសិទ្ធិមនុស្សគឺតាមរយៈដែនដី មានន័យថាប្រជាជនទទួលបានសិទ្ធិរបស់ពួកគេមិនមែនតាមរយៈភាពជាពលរដ្ឋនោះទេ ប៉ុន្តែតាមរយៈមានវត្តមានជារូបរាងនៅក្នុងប្រទេសមួយ។ នេះត្រូវបានបញ្ជាក់លម្អិតនៅក្នុងមាត្រា ២.១ ដែលចែងថា "គ្រប់បុគ្គលទាំងអស់នៅក្នុងទឹកដីរបស់ខ្លួន ហើយជាកម្មវត្ថុនៃយុត្តាធិការរបស់ខ្លួន" នឹងមានសិទ្ធ ICCPR ទោះបីជាមានសិទ្ធិចំនួនពីរក្នុង ICCPR ដែលផ្ដាច់មុខសម្រាប់តែពលរដ្ឋក៏ដោយ គឺសិទ្ធិនយោបាយ ដើម្បីបោះឆ្នោតនៅក្នុងប្រទេសមួយ និងសេរីភាពក្នុងការដើរហើរ។ យុត្តាធិការក៏រួមបញ្ចូលផងដែរនូវទឹកដី ដែលស្ថិតនៅក្រោមអំណាចរបស់រដ្ឋ ជាឧទាហរណ៍ អាណានិគម ឬ រដ្ឋក្រោមអាណាព្យាបាល។ ខណៈពេលដែលមានស្ថានភាពនេះចំនួនតិចតួចប៉ុណ្ណោះពេលបច្ចុប្បន្ន ឧទាហរណ៍ នៃទឹកនៅខាងក្រៅយុត្តាធិការនៃរដ្ឋមួយដែល ICCPR អនុវត្ត ពិតជាមានមែន ដូចជា កោះប៉ាស៊ីហ្វិករបស់បារាំងគឺ តាហ៊ីទី (ផ្នែកនៃប៉លីណេស៊ីបារាំង)។ នៅអាស៊ីអាគ្នេយ៍ មិនមានដែនដីដែលមានយុត្តាធិការបែបនេះទេ។ កាលពីពេលថ្មីៗនេះ មានការជជែកវែកញែកមួយចំនួនពាក់ព័ន្ធនឹងយុត្តាធិការ។ ឧទាហរណ៍គឺសហរដ្ឋអាមេរិក ដែលធ្វើការអះអាងថា ICCPR

**យុត្តាធិការ**
យុត្តាធិការមានន័យជាមូលដ្ឋានថាកន្លែងដែលច្បាប់ (យុត្តា) ចែង(ធិការ) ដែលក្នុងន័យម្យ៉ាងទៀត យុត្តាធិការគឺជាកន្លែងដែលច្បាប់មានប្រតិបត្តិការ។

មិនអាចពង្រីកដល់មន្ទីរឃុំឃាំងរបស់ខ្លួននៅជ្រោយ ហ្គាន់តាណាម៉ូ (Guantanamo) នោះទេ។

សន្ធិសញ្ញាសិទ្ធិមនុស្សផ្អែកលើយុត្តាធិការដែនដី មានន័យថាសន្ធិសញ្ញាទាំងនេះអនុវត្ត នៅក្នុងដែនដីនៃរដ្ឋមួយ ប៉ុន្តែមិនអនុវត្តនៅក្រៅព្រំដែននោះទេ។ មានប្រភេទដទៃទៀត នៃយុត្តាធិការដូចជាយុត្តាធិការជាសកល និងយុត្តាធិការលើពលរដ្ឋ។ ខណៈពេល ដែលការកំណត់យុត្តាធិការដែនដី មានភាពងាយស្រួលដោយសម្គាល់ព្រំដែនរបស់រដ្ឋ វាអាចជាការស្មុគ្រស្មាញក្នុងស្ថានភាពដែលរដ្ឋមួយគ្រប់គ្រងរដ្ឋដទៃ ឬនៅលើទូកក្នុង ដែនទឹកអន្តរជាតិ ឬលើយន្តហោះ។ *ជាឧទាហរណ៍ នៅពេលដែលសហរដ្ឋអាមេរិក គ្រប់គ្រងអ៊ីរ៉ាក់ពីប្រហែលជាឆ្នាំ២០០៣-២០០៨ តើច្បាប់មួយណាមានអំណាច? នៅ ក្នុងករណីទាំងនេះ តើកាតព្វកិច្ចសិទ្ធិមនុស្សមកជាមួយនឹងកងកម្លាំងដែលគ្រប់គ្រង ដោយតែរដ្ឋដែលក្រោមការគ្រប់គ្រងស្ថិតក្រោមយុត្តាធិការរបស់កងកម្លាំងឈ្លានពាន?*

បញ្ហាស្រដៀងគ្នានេះ ពាក់ព័ន្ធនឹងបែរក្បាលទូកជនភៀសខ្លួនចេញ ដែលបានកើត ឡើងនៅអាស៊ីអាគ្នេយ៍។ បន្ទាប់ពីជម្លោះក្នុងប្រទេសវៀតណាមនៅអំឡុងទសវត្សឆ្នាំ ១៩៧០ ទូកមួយចំនួនដែលមានផ្ទុកជនជាតិភៀសខ្លួនវៀតណាម ត្រូវបានបង្វែរក្បាល ចេញដោយកងទ័ពជើងទឹករបស់សឹង្ហបុរី និងម៉ាឡេស៊ី។ កាលពីពេលថ្មីៗនេះ ទ័ពជើង ទឹកអូស្ត្រាលីបានបង្វែរក្បាលទូកជនភៀសខ្លួនចេញ ហើយកងទ័ពជើងទឹកថៃក៏ត្រូវ បានរិះយ៉ាងខ្លាំង នៅពេលដែលខ្លួនបដិសេធការចូលចតរបស់ទូកដែលមានផ្ទុកជន ជាតិរ៉ូហ៊ីងញ៉ា (Rohigyas)។ ដូចដែលគណៈកម្មាធិការ ICCPR បានស្នើកាលពីពេល ថ្មីៗនេះ នៅពេលដែលកងទ័ពជើងទឹកបង្វែរក្បាលទូកជនភៀសខ្លួន ទូកនោះគួរតែត្រូវ បានចាត់ទុកថាស្ថិតក្រោមអំណាច និងយុត្តាធិការរបស់ទ័ពជើងទឹក ហើយដូចនេះសិទ្ធិ ICCPR របស់ប្រជាជននៅក្នុងទូកគួរតែត្រូវបានទទួលស្គាល់។ នៅក្នុងករណីកាលពី ថ្មីៗនេះ ក្នុងអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម (Sonko vs Spain ២០១១) នៅពេល ដែលសន្តិសុខជនជាតិអេស្ប៉ាញ ខកខានក្នុងការជួយសង្គ្រោះពលករដែលលង់ទឹក ម្នាក់ ក្នុងដែនទឹកម៉ូរ៉ុកកូ ដែលព្យាយាមក្នុងការចូលទឹកដីអេស្ប៉ាញ ទោះបីជាពលករ មិននៅក្នុងទឹកដីរបស់អេស្ប៉ាញក៏ដោយ គណៈកម្មាធិការ ″អង្កេតឃើញថាមន្ត្រីសន្តិ សុខអនុវត្តការគ្រប់គ្រងបុគ្គលលើនាវា ហើយដូចនេះត្រូវទទួលខុសត្រូវចំពោះសុវត្ថិ ភាពរបស់ពួកគេ″ ដូចនេះយុត្តាធិការមិនមែនជាដែនដីរបស់ខ្លួននោះទេ ប៉ុន្តែរួមបញ្ចូល តំបន់ដែលរដ្ឋាភិបាលអនុវត្តការគ្រប់គ្រងដោយប្រសិទ្ធិភាពផងដែរ។

## ៣.២ សិទ្ធិក្នុង ICCPR

ផ្នែកនេះនឹងបញ្ជាក់ជាសង្ខេបនូវតារាងនៃមាត្រាសំខាន់ៗមួយចំនួន ក្នុងកតិកាសញ្ញា។ សិទ្ធិទាំងនេះភាគច្រើន នឹងត្រូវបានពិភាក្សាស៊ីជម្រៅក្នុងជំពូកក្រោយនៃសៀវភៅពុម្ពនេះ ប៉ុន្តែនៅទីនេះគ្រាន់តែបញ្ជាក់ធាតុសំខាន់ៗប៉ុណ្ណោះ។

### ៣.២.១ ស្វ័យសម្រេច(មាត្រា១)

មាត្រា ១ នៃ ICCPR ជាសិទ្ធិស្វ័យសម្រេច គឺដូចគ្នាទៅនឹងមាត្រា ១ របស់ ICESCR។ នេះពាក់ព័ន្ធនឹងសិទ្ធិសម្រាប់ក្រុមនយោបាយ ក្នុងការជ្រើសរើសប្រព័ន្ធនយោបាយរបស់ខ្លួន និងប្រើប្រាស់ធនធានរបស់ខ្លួនតាមដែលខ្លួនប្រាថ្នា។ ស្វ័យសម្រេចនៅក្នុង ICCPR និង ICESCR ជាសំខាន់សំដៅលើសេរីភាពរួចផុតពីអាណានិគមនិយម។ មាត្រានេះមិនបានគោលបំណងក្នុងការអនុញ្ញាតផ្តល់សេរីភាព ដល់ក្រុមជនជាតិដើមភាគតិច វប្បធម៌ ឬក្រុមជនជាតិភាគតិចក្នុងការបង្កើតប្រទេសដោយខ្លួននោះទេ ទោះបីជាមាត្រានេះផ្តល់សិទ្ធិមួយចំនួនដល់ក្រុមជនជាតិភាគតិច និងក្រុមវប្បធម៌ក៏ដោយ។ សិទ្ធិនេះពាក់ព័ន្ធនឹងបរិបទនៃចលនានៅប្រទេសនៅអាស៊ីអាគ្នេយ៍ ដើម្បីទាមទារសិទ្ធិស្វ័យសម្រេច។

### ៣.២.២ ការមិនរើសអើង(មាត្រា ២)

រាល់សន្ធិសញ្ញាសិទ្ធិមនុស្សទាំងអស់ទទួលស្គាល់សិទ្ធិស្មើភាពគ្នា និងដោយមិនរើសអើង (មាត្រា ២ នៃ ICCPR)។ ដូចដែលបានគ្រប់ដណ្តប់នៅក្នុងជំពូកទីមួយ មិនអាចយកជាហេតុផល ឬមិនអនុញ្ញាតឲ្យមានការរើសអើងដោយមូលដ្ឋានពូជសាសន៍ ភេទ ភាសា គំនិតនយោបាយនោះទេ ។ល។ ICCPR ផ្តល់នូវតារាងមួយដែលអាចជាមូលដ្ឋាននៃការរើសអើង ប៉ុន្តែក៏មាននូវសេចក្តីបញ្ចប់មួយសំខាន់មួយដែល "ក្តោបទាំងអស់" "ឬស្ថានភាពដទៃទៀត" មានន័យថាការរើសអើងអាចលេចចេញក្នុងគ្រប់ទម្រង់។ ការអភិវឌ្ឍសំខាន់មួយនៅក្នុងវិស័យនេះគឺការរើសអើងលើផ្លូវភេទ។ ភេទត្រូវបានកំណត់ក្នុងមាត្រានេះ ប៉ុន្តែមិនមែនផ្លូវភេទនោះទេ។

## ៣.២.៣ សិទ្ធិរស់រានមានជីវិត(មាត្រា៦)

ការអភិវឌ្ឍសំខាន់មួយនៃសិទ្ធិរស់រានមានជីវិតពីសិទ្ធិក្នុង UDHR ជាការរួមបញ្ចូលនូវដែនកំណត់នៃការប្រើប្រាស់ទោសប្រហារជីវិតនៅក្នុង ICCPR។ សិទ្ធិរស់រានមានជីវិតត្រូវតែការពារដោយច្បាប់ ទោះបីជាការពិតជាក់ស្តែង គ្រប់រដ្ឋទាំងអស់បានកាត់ទោសប្រហារជីវិត ឬអំពើដទៃទៀតដែលធ្វើឲ្យបុគ្គលម្នាក់ស្លាប់រួចហើយក៏ដោយ។ តម្រូវឲ្យរដ្ឋមានលក្ខខណ្ឌស្តីពីការប្រើប្រាស់ទោសប្រហារជីវិត។ ICCPR តម្រូវឲ្យរដ្ឋក្នុងការបញ្ចូលនូវលក្ខខណ្ឌស្តីពីការប្រើប្រាស់ទោសប្រហារជីវិតរបស់ពួកគេ៖ ដូចនេះ ទោសនេះអាចត្រូវបានប្រើប្រាស់ចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរប៉ុណ្ណោះ ការកាត់ទោសត្រូវបើកផ្លូវដើម្បីឲ្យមានការប្តឹងឧទ្ធរណ៍ ហើយការកាត់ទោសប្រហារជីវិតមិនអាចធ្វើឡើងចំពោះក្រុមមនុស្សមួយចំនួននោះទេ ដូចជាស្ត្រីមានផ្ទៃពោះ កុមារ អ្នកពិការស្មារតី និងមនុស្សចាស់។ ខណៈពេលដែលមាត្រានេះមិនបានហាមឃាត់នូវទោសប្រហារជីវិត រដ្ឋអាចព្រមព្រៀងលើពិធីសារបន្ថែមទីពីរ ដែលចែងពីការលុបបំបាត់ទោសប្រហារជីវិត ។ ពិធីសារបន្ថែមត្រូវបានព្រមព្រៀងដោយរដ្ឋចំនួន៧៥ ហើយបានចូលជាធរមានចាប់តាំងពីឆ្នាំ ១៩៩១។ យ៉ាងណាមិញ នៅអាស៊ីអាគ្នេយ៍ មានតែប្រទេសហ្វីលីពីន និងទីម័រខាងកើតតែប៉ុណ្ណោះដែលបានផ្តល់សច្ចាប័នលើពិធីសារនេះ។ ពិធីសារបន្ថែមតម្រូវឲ្យរដ្ឋក្នុងការលុបបំបាត់ទោសប្រហារជីវិតជារៀងរហូត។ ដែលស្ថានភាពនេះត្រូវបានអនុវត្តនៅក្នុងទ្វីបអឺរ៉ុបរួចមកហើយ ហើយភាគច្រើននៃប្រទេសអាមេរិកឡាទីនបានលុបបំបាត់ផងដែរ ទោះបីជាតំបន់ទាំងនេះបានសម្រេចកិច្ចការនេះតាមរយៈកិច្ចព្រមព្រៀង និងសន្ធិសញ្ញាក្នុងតំបន់ក៏ដោយ។

### ការពិភាក្សា និងការជជែកវែកញែក

#### ទោសប្រហារជីវិត

នៅជុំវិញពិភពលោក ប្រទេសជាច្រើនបានលុបទោសប្រហារជីវិតចោល។ ប្រទេសជាង ១០០ បានហាមឃាត់ទោសប្រហារជីវិត។ ប្រទេសចំនួន ៥០ ទៀតមិនបានប្រើប្រាស់ទោសប្រហារជីវិតជាង ១០ ឆ្នាំមកហើយ ពេលបច្ចុប្បន្នមានប្រទេសប្រហែលជា ៤២ ប៉ុណ្ណោះដែលនៅប្រើប្រាស់ទោសប្រហារជីវិតទៀងទាត់។

ប្រទេសជាច្រើនអះអាងថាទោសប្រហារជីវិត ជាឧបករណ៍ដែលសំខាន់ក្នុងការប្រឆាំង និងបទឧក្រិដ្ឋ និងជាមធ្យោបាយចាំបាច់ក្នុងការដាក់ទណ្ឌកម្មដល់ទោសឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុត។ ជាឧទាហរណ៍ សឹង្ហបុរី ម៉ាឡេស៊ី និងឥណ្ឌូនេស៊ីអះអាងថាវិធីសាស្ត្រដ៏មានប្រសិទ្ធិភាពតែមួយគត់ក្នុងការប្រឆាំងនឹងការជួញដូរមនុស្ស គឺតាមរយៈទោសប្រហារជីវិត។ នៅក្នុងប្រទេសទាំងនេះ ទោសប្រហារជីវិតជាទូទៅពាក់ព័ន្ធនឹងអ្នកជួញដូរគ្រឿងញៀន។

រដ្ឋដទៃទៀតអះអាងថាទោសប្រហារជីវិត គួរតែត្រូវបានលុបចោលពីព្រោះទោសនេះអាចត្រូវបានកាត់ទោសលើបុគ្គលដែលគ្មានកំហុស ថាទោសនេះមិនកាត់បន្ថយឧក្រិដ្ឋកម្ម និងថាប្រជាជនដែលប្រឈមនឹងទោសនេះភាគច្រើនជាអ្នកក្រីក្រ និងត្រូវបានរើសអើង។ បញ្ហាមួយទៀតនៅក្នុងតំបន់ ពាក់ព័ន្ធនឹងការប្រើប្រាស់ការកាត់ទោសប្រហារជីវិតជាដាច់ខាតក្នុងប្រទេសសឹង្ហបុរី និងម៉ាឡេស៊ី។ ការកាត់ទោសជាដាច់ខាតមានន័យថា ជាឧទាហរណ៍ អ្នកណាម្នាក់ដែលត្រូវបានរកឃើញថាមានបរិមាណគ្រឿងញៀនគ្រប់ចំនួនជាក់លាក់ នឹងត្រូវបានកាត់ទោសប្រហារជីវិតដោយស្វ័យប្រវត្តិ មិនខ្វល់ពីកាលៈទេសៈអ្វីឡើយ។

***តើទោសប្រហារជីវិតចាំបាច់ដែរឬទេ?*** ជាការពិតណាស់ ប្រសិនបុគ្គលពិតជាបានប្រព្រឹត្តឧក្រិដ្ឋធ្ងន់ធ្ងរមែន (ដូចជារំលោភ ឬសម្លាប់) ពួកគេសាកសមនឹងប្រឈមការដាក់ទោសដែលធ្ងន់ធ្ងរបំផុត? ប៉ុន្តែ អ្នកណាជាអ្នកនិយាយថាការស្លាប់ជាការដាក់ទណ្ឌកម្មដែលអាក្រក់បំផុតជាជីវិតនៅក្នុងពន្ធនាគារ?

***តើទោសប្រហារជីវិតពិតជាបញ្ឈប់ប្រជាជនពីការប្រព្រឹត្តបទឧក្រិដ្ឋមែនដែរឬទេ?*** ជាការពិតបញ្ហាគ្រឿងញៀនក្នុងប្រទេសម៉ាឡេស៊ី និងសឹង្ហបុរីត្រូវបានកាត់បន្ថយបើប្រៀបធៀបទៅនឹងប្រទេសដទៃ។ យ៉ាងណាមិញ ប្រជាជននៅតែត្រូវបានកាត់ទោស និងដាក់ទោសប្រហារជីវិតជាទៀងទាត់ នេះមានន័យថា ការជួញដូរគ្រឿងញៀននៅតែកើតមានទោះបីជាមានការព្យាយាមបញ្ឈប់ក៏ដោយ។

***តើសមាជិកគ្រួសារដែលមានទុក្ខមិនគួរណាផ្តល់សិទ្ធិក្នុងការមើលឃាតករត្រូវបានកាត់ទោសប្រហារជីវិតទេមែនទេ? វានឹងផ្តល់ភាពយុត្តិធម៌បន្ថែមទៀតដល់សមាជិកគ្រួសារ។*** ប៉ុន្តែយុត្តិធម៌មិនគួរណាត្រូវបានកំណត់ដោយការជំនុំជម្រះក្តី ដោយយុត្តិធម៌មួយហើយមិនមែនដោយសមាជិកសមាជិកគ្រួសារដែលមានអារម្មណ៍ក្តុកក្តួលទេមែនទេ?

## ផ្តោតសំខាន់លើ

### ការកាត់ទោសប្រហារជីវិតនៅអាស៊ីអាគ្នេយ៍ (ដូចឆ្នាំ២០១៣)

| ប្រទេស | ទោសប្រហារជីវិតត្រូវបានប្រើ? | ការប្រើប្រាស់ទោសប្រហារជីវិត |
| --- | --- | --- |
| ប្រ៊ុយណេ | មាន | ការអនុវត្តច្បាប់ចុងក្រោយនៅឆ្នាំ ១៩៥៧ នៅពេលអង់គ្លេសជាអាណាព្យាបាល |
| កម្ពុជា | អត់ | គ្មានច្បាប់ស្តីពីទោសប្រហារជីវិត។ ការអនុវត្តចុងក្រោយនៅឆ្នាំ១៩៨៩ |
| ឥណ្ឌូនេស៊ី | មាន | ការអនុវត្តចុងក្រោយនៅឆ្នាំ២០០៨ |
| ឡាវ | មាន | ការអនុវត្តចុងក្រោយនៅឆ្នាំ១៩៨៨ |
| ម៉ាឡេស៊ី | មាន | ការកាត់ទោសប្រហារជីវិតជាចាំបាច់ ការអនុវត្តប្រចាំឆ្នាំ |
| មីយ៉ាន់ម៉ា | អត់ | ការអនុវត្តចុងក្រោយនៅឆ្នាំ១៩៩៣ |
| ហ្វីលីពីន | អត់ | ការលុបបំបាត់ពីឆ្នាំ ១៩៨៧-១៩៩៣ ហើយឆ្នាំ ២០០៦ តទៅ |
| ថៃ | មាន | ការអនុវត្តចុងក្រោយនៅឆ្នាំ២០០៩ |
| សិង្ហបុរី | មាន | ការកាត់ទោសប្រហារជីវិតជាចាំបាច់ត្រូវបានកំណត់ ការអនុវត្តប្រចាំឆ្នាំ |
| វៀតណាម | មាន | ការអនុវត្តប្រចាំឆ្នាំ |

## ៣.២.៨ សិទ្ធផ្លូវច្បាប់(មាត្រា ៩ ១០ ១៨ និង២៦)

មាត្រាមួយចំនួនក្នុង ICCPR ធានាថាប្រព័ន្ធច្បាប់មានភាពយុត្តិធម៌ និងមានប្រសិទ្ធិភាព។ សិទ្ធិទាំងនេះគ្រប់ដណ្តប់ទស្សនៈភាពស្មើគ្នាចំពោះមុខច្បាប់ (មាត្រា២៦) ការដាក់ពន្ធនាគារដោយមិនយុត្តិធម៌ (ដូចជាការចាប់ខ្លួនតាមទំនើងចិត្តក្នុងមាត្រា៩ និងការដាក់ពន្ធនាគារដោយអមនុស្សធម៌ក្នុងមាត្រា១០) និងសិទ្ធិក្នុងការប្តឹងទៅតុលាការដែលមានសមត្ថកិច្ច មិនលំអៀង និងយុត្តិធម៌ (កំណត់ក្នុងមាត្រា ១៨ ដែលជាមាត្រា

មានខ្លឹមសារច្រើនជាងគេក្នុងសន្ធិសញ្ញា)៖ សិទ្ធិនៅពេលត្រូវបានចាប់ខ្លួន ឬឃុំខ្លួន (២) សិទ្ធិក្នុងបន្ទប់តុលាការ និង(៣) សិទ្ធិនៅពេលជាប់ពន្ធនាគារ។ ក្រលេកមើលជាសង្ខេបលើសិទ្ធិចម្បងៗទាំងនេះក្នុងវិស័យទាំងនេះ៖

- ការចាប់ខ្លួន៖ បុគ្គលម្នាក់មួយរូបមិនអាចត្រូវបានចាប់ខ្លួនដោយមិនមានហេតុផលនោះទេ ( មានន័យថា ពួកគេមិនអាចត្រូវបានចាប់ខ្លួនដោយទំនើងចិត្តនោះទេ) ពួកគេត្រូវយល់ដឹងពីហេតុផលថាហេតុអ្វីគេត្រូវបានចាប់ខ្លួន មានលទ្ធភាពប្តឹងទៅតុលាការ និងអាចត្រូវបានសន្មតជាមុនថាគ្មានទោសរហូតដល់តុលាការសម្រេចពីភាពគ្មាន ឬមានទោសរបស់គាត់។

- សវនការ៖ ចៅក្រមនៅក្នុងតុលាការត្រូវតែមានសមត្ថភាព និងមិនលំអៀង។ បុគ្គលត្រូវមានលទ្ធភាពក្នុងការអន្តរាគមន៍ពីមេធាវី អាចធ្វើការសួរឆ្លងទៅសាក្សី និងអាចត្រូវបាននាំទៅកាន់សវនការក្នុងអំឡុងពេលដែលសមស្រប។ ជនជាប់ចោទត្រូវមានសិទ្ធិក្នុងការប្រឆាំង ឬប្តឹងតវ៉ាលើការរកឃើញរបស់តុលាការ។ គួរតែមានប្រព័ន្ធសវនការផ្សេងសម្រាប់កុមារ។ ការដាក់ទណ្ឌកម្មត្រូវតែសាកសមនឹងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម។

- ការឃុំខ្លួន៖ បុគ្គលមិនអាចត្រូវបានឃុំខ្លួនដោយគ្មានហេតុផលនោះទេ។ ហេតុផលសម្រាប់ការឃុំខ្លួនរបស់ពួកគេត្រូវតែឲ្យពួកគេដឹង។ ពួកគេមិនអាចត្រូវបានឃុំខ្លួនក្នុងអំឡុងពេលយូរអង្វែង ដោយមិនបានបញ្ជូនទៅតុលាការនោះទេ។ លក្ខខណ្ឌនៃការឃុំខ្លួនត្រូវតែមានលក្ខណៈមនុស្សធម៌។

## ៣.២.៤ សេរីភាពក្នុងការធ្វើដំណើរ(មាត្រា១២)

សេរីភាពក្នុងការផ្លាស់ប្តូរលំនៅដ្ឋានទាំងក្នុងប្រទេស និងផ្លាស់ប្តូរពីប្រទេសមួយទៅប្រទេសមួយ។ យ៉ាងណាមិញ ការធ្វើដំណើរទាំងក្នុងនឹងក្រៅប្រទេសនេះមានដែនកំណត់។ បុគ្គលម្នាក់មួយរូបអាចមានសិទ្ធិក្នុងការចាកចេញពីប្រទេសមួយ ប៉ុន្តែមានសិទ្ធិចូលតែប្រទេសខ្លួនឯងប៉ុណ្ណោះ។ រដ្ឋមួយដោយសារហេតុផលអ្វីក៏ដោយអាចបដិសេធមិនឲ្យបុគ្គលមិនមែនពលរដ្ឋចូលមកប្រទេសរបស់ខ្លួន ឬអាចមានសកម្មភាពតាមទំនើងចិត្តក្នុងការសម្រេចចិត្តបែបនេះ។ ជាឧទាហរណ៍ លក្ខខណ្ឌក្នុងការចូលអាចជាប្រវែងនៃសក់ (សិង្ហបូរីក្នុងទសវត្សឆ្នាំ១៩៦០ និង៧០ បដិសេធជាទៀងទាត់លើបុរសដែលមានសក់វែងក្នុងការចូលក្នុងប្រទេសរបស់ខ្លួន ហើយជាលទ្ធផល ក្រុមតន្ត្រីរ៉ុកលីតហ្ស៊ីបប៉េលីន Led Zeppelin បានលុបចោលការប្រគុំតន្ត្រីរបស់ខ្លួន បន្ទាប់ពីបដិសេធមិនព្រមកាត់សក់របស់ពួកគេ)។

ប្រជាជនក៏មានសេរីភាពក្នុងការធ្វើដំណើរក្នុងប្រទេសផងដែរ ទោះបីជា CCPR ផ្តល់សិទ្ធិនេះចំពោះតែប្រជាជនដែល "ស្របច្បាប់នៅក្នុងទឹកដី" ក៏ដោយ។ មានការកម្រិតច្បាស់លាស់មួយចំនួនលើសេរីភាពនៃការដើរហើរ៖ ប្រជាជនមិនអាចចូលក្នុងផ្ទះអ្នកដទៃ និងស្ត្រីមិនអាចចូលបន្ទប់ទឹកបុរស។ ដែនកំណត់ទាំងនេះ ដូចដែលបានបញ្ជាក់ខាងក្រោម ត្រូវតែស្ថិតនៅក្នុងច្បាប់ និងត្រូវបានចាត់ទុកថាជាការចាំបាច់សម្រាប់ហេតុផលដូចជាសីលធម៌ ឬសិទ្ធិរបស់អ្នកដទៃ។

## ៣.២.៦ សេរីភាពសាសនា(មាត្រា១៨)

ប្រជាជនអាចមានសិទ្ធិក្នុងការជឿ និងអនុវត្តសាសនារបស់ពួកគេ។ សេរីភាពនេះជាន់គ្នាជាមួយនឹងសិទ្ធិជនជាតិភាគតិច និងសិទ្ធិវប្បធម៌ដែលមានបញ្ជាក់នៅក្នុងមាត្រា ២៧។ សេរីភាពសាសនាការពារបុគ្គលដែលចង់សំដែង ឬអនុវត្តនូវជំនឿរបស់ពួកគេដែលនេះអាចគោរពជាលក្ខណៈបុគ្គល និងជាក្រុម។ សេរីភាពសាសនាអាចពង្រីកដល់កន្លែងការងារ និងកន្លែងអប់រំ។ សិទ្ធិក៏ការពារប្រជាជនពីការបង្ខំឲ្យជឿលើសាសនាមួយផងដែរ។ ដូចដែលបានបញ្ជាក់លម្អិត មានការជជែកវែកញែកស្មុគ្រស្មាញជុំវិញសេរីភាពសាសនា និងសិទ្ធិមនុស្ស។ ខណៈពេលដែលមាត្រានេះ អនុញ្ញាតសិទ្ធិក្នុងការផ្លាស់ប្តូរសាសនា នេះមិនតែងតែត្រូវបានទទួលយកដោយសាសនាជាច្រើននោះទេ។ លើសពីនេះទៀត ប្រទេសមួយចំនួននៅអាស៊ីអាគ្នេយ៍មានសាសនារដ្ឋមួយដែលធ្វើឲ្យមានការប្រឈមសម្រាប់អ្នកដែលមិនមានជំនឿ ដែលនឹងពិបាកគេចផុតពីការរើសអើង។ ជាចុងក្រោយ ការអនុវត្តសាសនាមួយចំនួន ដូចជាការជ្រើសរើសមេដឹកនាំសាសនា រើសអើងលើស្ត្រី។ ការអនុវត្តសាសនាមួយចំនួនអាច ត្រូវបានកម្រិតដោយច្បាប់ ជាឧទាហរណ៍ ឯកពន្ធភាព ប៉ុន្តែដូចគ្នាទៅនឹងដែនកំណត់នៃសេរីភាពនៃការបញ្ចេញមតិ ឬដើរហើរ ត្រូវតែនៅក្នុងក្របខណ្ឌច្បាប់ ហើយត្រូវបង្ហាញពីភាពចាំបាច់សម្រាប់ហេតុផលជាក់លាក់ដូចជាសីលធម៌ ឬសន្តិសុខ។

## ៣.២.៧ សេរីភាពនៃការបញ្ចេញមតិ(មាត្រា១៩)

ច្បាប់នៅអាស៊ីអាគ្នេយ៍ដែលកម្រិតសេរីភាពនៃការបញ្ចេញមតិរួមមាន៖(ក) ការបង្ខូចកេរ្តិ៍ និងបរិហារកេរ្តិ៍ (ខ) ប្រមាថអ្នកដទៃដែលនៅក្រោមសមត្ថកិច្ច (គ) ក្បត់ជាតិ (ឃ) អំពើអាសអាភាស (ង) ច្បាប់កម្មសិទ្ធិបញ្ញាការពារសិទ្ធិអ្នកនិពន្ធ។ យ៉ាងណាមិញ ដែន

កំណត់ត្រូវបានកម្រិតដោយប្រទេសមួយចំនួននៅអាស៊ីអាគ្នេយ៍ អាចរំលោភបំពានមាត្រា ១៩។ ជាឧទាហរណ៍ សៀវភៅជាក់លាក់ស្តីពីរាជានិយមមិនអាចលក់នៅប្រទេសថៃបាននោះទេ និងរឿងប្រលោមលោក *The Satanic Verses* ត្រូវបានហាមឃាត់ក្នុងប្រទេសម៉ាឡេស៊ី និងឥណ្ឌូនេស៊ី។

## ៣.២.៨ សិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍ និងមានបុត្រធីតា(មាត្រា២៣)

សិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍ រួមបញ្ចូលសិទ្ធិរបស់ជនណាម្នាក់ក្នុងការរៀបការ ហើយទាមទារថាដៃគូទាំងពីរមានឋានៈស្មើគ្នានៅក្នុងអាពាហ៍ពិពាហ៍។ អ្នកណាម្នាក់ក៏ដោយអាចរៀបអាពាហ៍ពិពាហ៍នៅពេលដែលពួកគេបានដល់ "អាយុរៀបការ" ទោះបីជាមិនបានកំណត់ក្នុងសន្ធិសញ្ញាក៏ដោយ។ នៅអាស៊ីអាគ្នេយ៍ អាយុតាមផ្លូវច្បាប់ ក្នុងការរៀបការជាទូទៅគឺ១៨ឆ្នាំ ដែលជាស្តង់ការទូទៅជុំវិញពិភពលោក ទោះបីជាមានការអនុញ្ញាតមួយចំនួនសម្រាប់មនុស្ស ដែលមានអាយុក្រោម ១៨ឆ្នាំ អាចរៀបការដោយមានការយល់ព្រមពីឪពុកម្តាយក៏ដោយ។ រដ្ឋមួយចំនួនមានបំណងចង់ឲ្យពលរដ្ឋរបស់ខ្លួនរៀបការនៅអាយុច្រើន ដូចនេះពួកគេបានកំណត់អាយុខ្ពស់ជាងនេះដើម្បីរៀបការ ជាឧទាហរណ៍ អាយុរៀបការនៅប្រទេសចិនគឺ ២១ឆ្នាំ សម្រាប់ស្ត្រី និង ២៤ ឆ្នាំសម្រាប់បុរស។ លើសពីនេះទៀត ប្រជាជនត្រូវរៀបការដោយសេរី និងមានការព្រមព្រៀងពេញលេញះមិនមានអ្នកណាម្នាក់អាចត្រូវបានបង្ខំឲ្យរៀបការនោះទេ។ អាពាហ៍ពិពាហ៍ដែលជាការរៀបចំ មិនមែនជាការរំលោភបំពានលើសិទ្ធិនេះនោះទេដោយសារតែប្រជាជនអាចផ្តល់នូវការព្រមព្រៀងពេញលេញ លើអាពាហ៍ពិពាហ៍ដែលបានរៀបចំនេះ។

ជាសេចក្តីរំពឹងថាបុរស និងស្ត្រីរៀបអាពាហ៍ពិពាហ៍ និងលែងលះដោយស្មើភាពគ្នា។ គួរឲ្យស្តាយ នេះមិនមានករណីដូចនេះទាំងអស់នោះទេ នៅក្នុងប្រទេសជាច្រើននៅអាស៊ីអាគ្នេយ៍។ ច្បាប់លែងលះក្នុងប្រទេសនៅអាស៊ីអាគ្នេយ៍មួយចំនួន គឺមានការអនុគ្រោះដល់បុរសជាជាងស្ត្រី ប៉ុន្តែកំពុងតែមានការផ្លាស់ប្តូរ។ ជាឧទាហរណ៍ ច្បាប់លែងលះកាលពីមុនរបស់ប្រទេសថៃ ទាមទារឲ្យស្ត្រីក្នុងការបង្ហាញពីការផិតក្បត់របស់ប្តីរបស់គាត់ ខណៈពេលដែលប្តីមិនចាំបាច់បង្ហាញភ័ស្តុតាងអ្វីនោះទេ។ ស្រដៀងគ្នាក្នុងប្រទេសឥណ្ឌូនេស៊ីផងដែរ តាមប្រព័ន្ធចាស់ ស្ត្រីដែលលែងលះប្តីតាមច្បាប់ឥស្លាមត្រូវបានទទួលការប្រព្រឹត្តមកលើខុសៗគ្នា។ ការលែងលះ មិនត្រូវបានអនុញ្ញាតក្នុងប្រទេសហ្វីលីពីនឡើយ ដែលជារដ្ឋតែមួយគត់លើលោកដែលរក្សាច្បាប់នេះ ហើយប៉ុន្តែការរៀបអាពាហ៍ពិពាហ៍ភេទដូចគ្នា មិនទាន់ត្រូវបានទទួលស្គាល់នៅប្រទេសណាមួយនៅអាស៊ីអាគ្នេយ៍នៅឡើយទេ។

## ៣.២.៩ សិទ្ធិសមាគម និងការប្រជុំ(មាត្រា ២១ និង ២២)

ខណៈពេលដែលសិទ្ធិទាំងនេះត្រូវបានរួមបញ្ចូលក្នុងមាត្រាតែមួយក្នុង UDHR សិទ្ធិទាំងពីរត្រូវបានញែកដាច់ពីគ្នាក្នុង ICCPR។ ទាំងសិទ្ធិក្នុងការប្រជុំ (ដើម្បីធ្វើកិច្ចប្រជុំសាធារណៈដោយសន្តិភាពមួយ) និងសមាគម (ដើម្បីបង្កើតក្រុម) អាចត្រូវបានកម្រិតដោយច្បាប់។ ទាំងនេះជានានូវសិទ្ធិក្នុងការប្រលូកក្នុងឆាកជីវិតនយោបាយដោយតាមរយៈការបង្កើតអង្គការ និងធ្វើការប្រជុំ ទោះបីជាមិនមែនតែក្រុមនយោបាយនោះទេ ដែលត្រូវបានការពារដោយកតិកាសញ្ញា។ ទូទាំងពិភពលោកក្នុងឆ្នាំ ២០១១ និង ២០១២ សិទ្ធិក្នុងការប្រជុំត្រូវបានសាកល្បងនូវព្រំដែនរបស់វា ជាឧទាហរណ៍ ការប្រមូលផ្តុំទ្រង់ទ្រាយធំនៃប្រជាជនប្រទេសអារ៉ាប់ ការតវ៉ាក្នុងទីក្រុងបាងកក និងចលនា Berish ក្នុងប្រទេសម៉ាឡេស៊ី។ យ៉ាងណាមិញ មានដែនកំណត់ចំពោះសិទ្ធិទាំងនេះដោយសារតែការកាន់កាប់កន្លែងមួយយូរអង្វែង អាចប៉ះពាល់ធ្ងរធ្ងរដល់សិទ្ធិរបស់អ្នកដទៃ ជាឧទាហរណ៍ ការកាន់កាប់ព្រលានយន្តហោះ និងកន្លែងផ្សារទំនើបកណ្តាលក្រុងដោយក្រុមពីរដាច់ដោយឡែកក្នុងទីក្រុងបាងកក បានប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិរបស់អ្នកដទៃក្នុងការប្រើប្រាស់ទីកន្លែងទាំងនោះ។

## ៣.២.១០ សិទ្ធិក្នុងការបោះឆ្នោត (មាត្រា ២៥)

សិទ្ធិមនុស្សស្តីពីនយោបាយគ្រប់ដណ្តប់ធាតុផ្សំផ្សេងៗជាច្រើន។ វារួមបញ្ចូលសិទ្ធិក្នុងការចូលរួមនឹងនយោបាយ ដើម្បីក្លាយជាអ្នកនយោបាយ ដើម្បីធ្វើជាមន្ត្រីសាធារណៈ ឬមន្ត្រីរដ្ឋាភិបាល និងសិទ្ធិក្នុងការបោះឆ្នោត។

ខណៈពេលដែលកតិកាសញ្ញាមិនរៀបរាប់ច្បាស់លាស់ពីប្រជាធិបតេយ្យ សិទ្ធិនយោបាយសន្មតថាប្រជាជន គួរតែមានសិទ្ធិក្នុងការចូលរួមក្នុងដំណើរការនយោបាយតាមរយៈការបោះឆ្នោតជ្រើសរើស ឬសិទ្ធិក្នុងការបោះឆ្នោត។ ការបោះឆ្នោតតែមួយគត់មិនអាចចាត់ទុកថាជាប្រជាធិបតេយ្យមួយនោះទេ ដូចដែលប្រទេសមួយចំនួនមិនត្រូវបានចាត់ទុកថាជាប្រជាធិបតេយ្យនោះទេ ដោយគ្រាន់តែមានការបោះឆ្នោត ជាឧទាហរណ៍ ប្រទេសវៀតណាម និងឡាវ។ យ៉ាងណាមិញ ដោយសារថាប្រជាធិបតេយ្យជាប្រព័ន្ធនយោបាយតែមួយគត់ ដែលទាមទារថាការបោះឆ្នោតជាធាតុចាំបាច់មួយ យើងមិនអាចប្រកែកពីទំនាក់ទំនងជិតស្និត រវាងការចូលរួមក្នុងដំណើរការបោះឆ្នោត និងការបោះឆ្នោតនោះទេ។

ជាការសំខាន់ សិទ្ធិក្នុងការបោះឆ្នោតផ្តោតសំខាន់លើដំណើរការដំណើរការនៃការបោះឆ្នោត៖ ដូចនេះការបោះឆ្នោតត្រូវរៀបចំទៅតាមពេលវេលាសមស្រប ដោយឈរលើមូលដ្ឋានជាសកល និងស្មើភាព និងដោយសន្លឹកឆ្នោតជាសម្ងាត់។

ធាតុផ្សំទាំងអស់នេះ មានគោលបំណងក្នុងការធានាថាដំណើរការបោះឆ្នោត មានភាពយុត្តិធម៌ និងស្មើភាព។ ស្ទើរតែគ្រប់ប្រទេសនៅអាស៊ីអាគ្នេយ៍ទាំងអស់ អះអាងថាពួកគេជាប្រទេសប្រជាធិបតេយ្យ ទោះបីជាយើងអាចមានមន្ទិលពីគុណភាពនៃនីតិវិធីប្រជាធិបតេយ្យរបស់ពួកគេថាមិនទាន់ប្រសើរនៅឡើយក៏ដោយ។ ទូទាំងអាស៊ីអាគ្នេយ៍ ស្ទើរតែគ្រប់ពលរដ្ឋទាំងអស់អាចបោះឆ្នោតក្នុងទម្រង់នៃការបោះឆ្នោតណាមួយ ហើយគ្រប់ប្រជាជនទាំងអស់ ត្រូវបានអនុញ្ញាតឲ្យក្លាយទៅជាអ្នកនយោបាយ។ យ៉ាងណាមិញ ថាតើរដ្ឋាភិបាលដែលចេញពីលទ្ធផលនៃការបោះឆ្នោតទាំងនេះ តំណាងឲ្យ 'ឆន្ទៈរបស់ពលរដ្ឋ' ឬក៏អត់ ជាថ្មីម្តងទៀតអាចបើកចំហសម្រាប់ការជជែកវែកញែកបាន។

# ៣.៣ ដែនកំណត់នៃសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

សិទ្ធិនៅក្នុង ICCPR មួយចំនួនអាចត្រូវបានកម្រិតតាមផ្លូវច្បាប់ក្នុងកាលៈទេសៈ ជាក់លាក់មួយចំនួន។ មានប្រភេទនៃដែនកំណត់ផ្សេងៗគ្នា។ ប្រភេទទាំងនេះមានដូចជា៖ (១) ដែនកំណត់ចំពោះសិទ្ធិទាំងអស់ (២) ដែនកំណត់ចំពោះសិទ្ធិជាក់លាក់ដែលបានកំណត់ដោយរដ្ឋាភិបាល និង(៣) ដែនកំណត់តាមរយៈ បដិប្បញ្ញត្តិ។

## ៣.៣.១ ដែនកំណត់ចំពោះសិទ្ធិទាំងអស់

ជាការសំខាន់ក្នុងការចងចាំថាគ្រប់សិទ្ធិមនុស្សទាំងអស់ មិនអនុញ្ញាតឲ្យបុគ្គលមានសេរីភាពអត់ដែនកំណត់ក្នុងការធ្វើបានទាំងអស់ដែលពួកគេចង់នោះទេ។ ផ្ទុយទៅវិញ គ្រប់សិទ្ធិមនុស្សទាំងអស់ត្រូវបានកម្រិត ដោយសារបុគ្គលមិនអាចប្រើប្រាស់សិទ្ធិរបស់ពួកគេក្នុងការរំលោភបំពានសិទ្ធិអ្នកដទៃបាននោះទេ។ ជាឧទាហរណ៍ បុគ្គលមួយរូបមិនអាចប្រើប្រាស់ សិទ្ធសេរីភាពក្នុងការបញ្ចេញមតិរបស់ខ្លួនបាននោះទេ ប្រសិនសិទ្ធិនេះរំលោភបំពានសិទ្ធិអ្នកដទៃ។ នេះត្រូវបានបញ្ជាក់លម្អិតក្នុងមាត្រា ៥ នៃ ICCPR។

## ៣.៣.២ ដែនកំណត់លើសិទ្ធិជាក់លាក់ដែលបានកំណត់ដោយរដ្ឋាភិបាល

ដែនកំណត់ចំពោះសិទ្ធិជាក់លាក់ក្នុង ICCPR ត្រូវបានបញ្ជាក់លម្អិតក្នុងសន្ធិសញ្ញានេះ។ នៅក្នុងករណីទាំងនេះ រដ្ឋាភិបាលអាចធ្វើច្បាប់ក្នុងការកម្រិតវិសាលភាពនៃសិទ្ធិមួយ។ ឧទាហរណ៍សាមញ្ញមួយ គឺការកម្រិតសេរីភាពក្នុងការបញ្ចេញមតិតាមរយៈការត្រួតពិនិត្យការបោះពុម្ពផ្សាយ។ ស្រដៀងគ្នានេះផងដែរ សិទ្ធិនៃការដើរហើរ សាសនា សំដែងមតិ ការប្រជុំ និងសមាគមក៏ត្រូវបានកម្រិតផងដែរ។ យ៉ាងណាមិញ សិទ្ធិទាំងនេះអាចកម្រិតបាន លុះត្រាណាតែមានការឆ្លើយតបនឹងលក្ខនិកៈដូចខាងក្រោម៖

១. ដែនកំណត់នេះត្រូវតែអនុញ្ញាតដោយច្បាប់ដែលចែងជាលាយលក្ខអក្សរ។ នេះដើម្បីធានាថានីតិរដ្ឋ ដែលការពាររដ្ឋពីការធ្វើបទប្បញ្ញត្តិគតិយុត្តតាមទំនើងចិត្តដើម្បីកម្រិតលើសិទ្ធិនោះទេ។ រដ្ឋមួយមិនអាចកម្រិតសិទ្ធិដោយផ្អែកលើអាកប្បកិរិយាសីលធម៌ ឬប្រសិទ្ធិភាពនៃសេដ្ឋកិច្ចបាននោះទេ ចំពោះទស្សនៈ ទាំងនេះត្រូវតែមានការគាំទ្រដោយច្បាប់ដែលចែងជាលាយលក្ខអក្សរ។ ឧទាហរណ៍នៃច្បាប់ដាក់កម្រិតលើសិទ្ធិទាំងនេះ រួមមានការពាក់ព័ន្ធនឹងសិទ្ធិក្នុងការធ្វើបាតុកម្ម (ជាឧទាហរណ៍ មិនអាចអនុញ្ញាតឲ្យបិទផ្លូវនោះទេ) ច្បាប់ពាក់ព័ន្ធនឹងការអនុវត្តសាសនា (ដូចជា ក្រុមសាសនាត្រូវបានហាមឃាត់មិនឲ្យប្រើប្រាស់គ្រឿងញៀនខុសច្បាប់សម្រាប់គោលបំណងសាសនានោះទេ) ឬច្បាប់ស្តីពីទ្រព្យសម្បត្តិឯកជន (ដែលកម្រិតសេរីភាពប្រជាជនក្នុងការផ្លាស់ប្តូរផ្ទះសម្បែង ទៅនៅទីកន្លែងសាធារណៈជាដើម)។

២. រដ្ឋាភិបាលត្រូវតែបង្ហាញថាច្បាប់ទាំងនេះ ចាំបាច់ក្នុងការធានានូវសិទ្ធិមនុស្ស។ ដោយសារតែច្បាប់មួយមានវត្តមាន មិនមែនមានន័យថាវាត្រឹមត្រូវនោះទេ។ ជាឧទាហរណ៍មួយ រដ្ឋាភិបាលមួយមានការពិបាកខ្លាំងក្នុងការការពារច្បាប់ដែលហាមឃាត់ប្រជាជន ពីការអានសៀវភៅស្តីពីសិទ្ធិមនុស្សដោយគ្រាន់តែពួកគេអះអាងថាវាគម្រាមដល់សន្តិសុខជាតិ។ ករណីទាំងនេះបានកើតឡើងកាលពីមុននៅប្រទេសមីយ៉ាន់ម៉ា ដែលប្រជាជនត្រូវបានដាក់ពន្ធនាគារដោយសារមាន UDHR នៅក្នុងដៃ (ទោះបីជាគ្មានច្បាប់តឹងរឹងដែលហាមឃាត់ការអានសៀវភៅក៏ដោយ)។

៣. ដែនកំណត់អាចមានវត្តមាន លុះត្រាណាតែមានហេតុផលជាក់លាក់មួយ។ ហេតុផលជាក់លាក់ដែលបានកំណត់ក្នុង ICCPR គឺសណ្តាប់ធ្នាប់សាធារណៈ ការគោរពសិទ្ធិអ្នកដទៃ សុខភាពសាធារណៈ សន្តិសុខជាតិ ឬសីលធម៌។ ដែន

កំណត់អាចធ្វើទៅបានលុះត្រាណាមានហេតុផលទាំងនេះ និងមិនមានហេតុផលដទៃនោះទេ។ រដ្ឋមិនអាចកម្រិតលើសិទ្ធិដោយសារប្រសិទ្ធិភាពសេដ្ឋកិច្ច និងការអនុវត្តវប្បធម៌បាននោះទេ មានន័យថាដោយសារនេះ មិនត្រូវបានបញ្ចូលថាជាហេតុផល។ សណ្តាប់ធ្នាប់សាធារណៈ សំដៅលើកាតព្វកិច្ចរបស់រដ្ឋាភិបាលក្នុងការធានាដល់ប្រជាជនសាធារណៈ ថាមិនត្រូវបានរំខានដោយអ្នកដទៃដែលកំពុងអនុវត្តសិទ្ធិរបស់ពួកគេផងដែរ (ជាឧទាហរណ៍ តាមរយៈការបិទផ្លូវ ឬព្រលានយន្តហោះ ឬបដិសេធការចូលទៅកាន់កន្លែងសាធារណៈ)។ សុខភាពសាធារណៈ អាចត្រូវបានប្រើប្រាស់ក្នុងការកម្រិតលើសិទ្ធិ នៅពេលដែលព្យាយាមក្នុងការបញ្ឈប់ការឆ្លងរាលដាលនៃជម្ងឺមួយដែលរដ្ឋ នឹងធ្វើការកម្រិតលើសេរីភាពនៃការដើរហើរ។ ខណៈពេលដែលដែនកំណត់ទាំងនេះមួយចំនួនត្រឹមត្រូវ តែងតែមានឱកាសដែលរដ្ឋាភិបាល ទាញចំណេញពីនិយមន័យនេះ។ ឧទាហរណ៍រួមមានសីលធម៌សាធារណៈ (ឧទាហរណ៍ក្នុងការកម្រិតលើសិទ្ធិ ទំនាក់ទំនងផ្លូវភេទដែលខុសពីគេ) និងសន្តិសុខជាតិ (ជាឧទាហរណ៍ ហាមឃាត់ ឬកម្រិតលើការប្រឆាំងនឹងនយោបាយ)។

## ៣.៣.៣ បដិប្បញ្ញត្តិក្នុងភាពអាសន្នសាធារណៈ

សិទ្ធិជាក់លាក់មួយចំនួន អាចត្រូវបានកម្រិតក្នុងស្ថានភាពជាក់លាក់ពិតប្រាកដដូចជាភាពអាសន្នសាធារណៈ។ ភាពអាសន្នសាធារណៈ (ដែលជាទូទៅត្រូវបានហៅថា ‘រដ្ឋស្ថិតក្នុងភាពអាសន្ន’) ដែលជាស្ថានភាពដែលយោងទៅតាម ICCPR “ដែលគម្រាមកំហែងដល់ជោគវាសនារបស់ជាតិ”។ នេះរួមមានគ្រោះធម្មជាតិ ជម្លោះ ឬរដ្ឋប្រហារជាដើម។ នៅក្នុងស្ថានភាពទាំងនេះ រដ្ឋត្រូវបានអនុញ្ញាតក្នុងការរំលោភ មិនអើពើ ឬបដិប្បញ្ញត្តិលើកាតព្វកិច្ចមួយចំនួនរបស់ខ្លួនចំពោះសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក្នុងអំឡុងពេលកំណត់មួយ។ បដិប្បញ្ញត្តិជាពាក្យស័ព្ទច្បាប់ដែលមានន័យថាជាការផ្អាកការអនុវត្តច្បាប់មួយជាបណ្តោះអាសន្ន។ ICCPR ញែកដាច់រវាងប្រភេទសិទ្ធិទាំងពីរនេះ ៖ សិទ្ធិ**ដែលអាចធ្វើបដិប្បញ្ញត្តិបាន** និងសិទ្ធិដែលមិនអាចធ្វើបដិប្បញ្ញត្តិបាន (មានន័យថាមិនពាក់ព័ន្ធនឹងស្ថានភាពណាទាំងអស់ សិទ្ធិទាំងនេះត្រូវតែគោរព)។ សិទ្ធិដែលមិនអាចធ្វើបដិប្បញ្ញត្តិបានរួមមានសេរីភាពរួចផុតពីទារុណកម្ម និងទាសភាព សិទ្ធិសាសនា ការមិនរើសអើង និងសិទ្ធិក្នុងការទទួលស្គាល់បុគ្គលចំពោះមុខច្បាប់។

ដំណើរការនៃការបដិប្បញ្ញត្តិលើសិទ្ធិចាប់ផ្តើម នៅពេលដែលរដ្ឋជឿជាក់ថាស្ថានភាពមួយបានកើតឡើង ដែលទាមទារឲ្យមានការប្រកាសរដ្ឋស្ថិតក្នុងភាពអាសន្ន។ ឧទាហរណ៍កាលពីពេលថ្មីៗនេះនៅក្នុងតំបន់ រួមមានបាងកកក្នុងអំឡុងពេលការតវ៉ា របស់ពួកអាវក្រហម ក្នុងឆ្នាំ ២០១០ ប្រទេសហ្វីលីពីនបន្ទាប់ពីព្យុះស៊ីក្លូន និងខេត្តវៀតណាម

**សិទ្ធិដែលអាចធ្វើបដិប្បញ្ញត្តិបាន**

នៅក្នុងលក្ខខណ្ឌធ្ងន់ធ្ងររដ្ឋាភិបាលអាចប្រកាសរដ្ឋស្ថិតក្នុងភាពអាសន្នដែលអនុញ្ញាតឲ្យខ្លួនជៀសវាងក្នុងការអនុលោមតាមនូវសិទ្ធិមួយចំនួន ( ធ្វើបដិប្បញ្ញត្តិលើសិទ្ធិមួយចំនួន)។ ក្នុងន័យម្យ៉ាងទៀត សម្រាប់អំឡុងពេលខ្លីនេះ សិទ្ធិខ្លះនឹងមិនចងកាតព្វកិច្ចទៀតនោះទេ។ នៅក្នុងរដ្ឋដែលស្ថិតក្នុងភាពអាសន្ន សិទ្ធិសេរីភាពក្នុងការដើរហើរជារឿយៗត្រូវបានដកហូតដើម្បីអនុញ្ញាតឲ្យរដ្ឋាភិបាលអនុវត្តបម្រាម។ យ៉ាងណាមិញ សិទ្ធិដទៃទៀតនៅតែចងកាតព្វកិច្ចមិនពាក់ព័ន្ធនឹងស្ថានភាពនេះនោះទេ។ ទាំងនេះហៅថាសិទ្ធិដែលមិនអាចធ្វើបដិប្បញ្ញត្តិបាន ហើយរួមមានសេរីភាពរួចផុតពីទារុណកម្ម សិទ្ធិក្នុងការរស់រានមានជីវិត សេរីភាពក្នុងការគិត មានមនសិការ និងសាសនា។

មួយចំនួនបន្ទាប់ពីមានការរាតត្បាតនៃផ្តាសាយបក្សីក្នុងឆ្នាំ ២០០៩។ ក៏មានរដ្ឋស្ថិតក្នុងស្ថានភាពអាសន្នដោយសារមានជម្លោះផងដែរ ដូចជាខេត្តភាគខាងត្បូងទាំងបីរបស់ប្រទេសថៃ ឬលើដែនកោះមិនដាណាវក្នុងប្រទេសហ្វីលីពីន។ នៅក្នុងករណីនីមួយៗ រដ្ឋាភិបាលត្រូវបានអនុញ្ញាតក្នុងការធ្វើបដិប្បញ្ញត្តិលើសិទ្ធិខ្លះ៖ ជាឧទាហរណ៍ប្រជាជនមិនត្រូវបានអនុញ្ញាតឲ្យប្រមូលផ្តុំ ឬការដើរហើររបស់ពួកគេត្រូវបានកម្រិត ឬពួកគេអាចត្រូវបានចាប់ខ្លួន ឬឃុំខ្លួនសម្រាប់រយៈពេលវែងតាមទំនើងចិត្តជាដើម។ នៅពេលប្រកាសភាពអាសន្នមួយ រដ្ឋាភិបាលគួរតែប្រាប់ផងដែរពីសិទ្ធិអ្វី ដែលត្រូវបានធ្វើបដិប្បញ្ញត្តិ ដូចជាការកម្រិតលើការដើរហើរ ពង្រីកអំណាចប៉ូលីសដើម្បីបង្ការការលួចប្លន់ ឬអនុញ្ញាត្តឲ្យឃុំជនសង្ស័យបានយូរ។ ភាពអាសន្នសាធារណៈ ពិតជាអនុញ្ញាតឲ្យរដ្ឋមានអំណាចខ្លាំង ហើយជារឿយៗមានការត្អូញត្អែរថា ពេលខ្លះពួកគេ រំលោភអំណាចរបស់ខ្លួននេះតាមរយៈការចាប់ខ្លួនក្រុមបក្សប្រឆាំង ឬឃុំខ្លួនជនសង្ស័យជាច្រើនខែដោយមិនមានការចោទប្រកាន់។

## ការពិភាក្សា និងការជជែកវែកញែក

### រដ្ឋស្ថិតក្នុងភាពអាសន្ន

នៅដើមឆ្នាំ ២០១៤ រដ្ឋាភិបាលថៃបានប្រកាសរដ្ឋស្ថិតក្នុងភាពអាសន្នសម្រាប់ទីក្រុងបាងកក និងតំបន់ជុំវិញឆ្លើយតបនឹងការកើនឡើងនូវការតវ៉ានយោបាយដែលបានបិទផ្លូវ ការិយាល័យរដ្ឋាភិបាល និងមធ្យោបាយដឹកជញ្ជូន។ ក្រិតប្រកាសភាពអាសន្នមានរយៈពេល ៦០ថ្ងៃ។ ក្រិតប្រកាសភាពបណ្តោះអាសន្នផ្តល់មន្ត្រីសមត្ថកិច្ចនូវអំណាចបន្ថែម។ ក្រលេកមើលលើអំណាចខាងក្រោម តើអ្នកគិតថាបដិប្បញ្ញត្តិទាំងនេះសមហេតុផលក្នុងការរក្សាសណ្តាប់ធ្នាប់សាធារណៈដែរឬទេ? (កំណត់ចំណាំ៖ នេះមិនមែនជាតារាងពេញលេញនៃបដិប្បញ្ញត្តិនោះទេ)។

១. ដើម្បីចាប់ខ្លួន និងឃុំខ្លួនបុគ្គលដែលត្រូវបានសង្ស័យថាមានតួនាទីក្នុងការបង្កើតមានស្ថានភាពអាសន្ន៖ បដិប្បញ្ញត្តិសេរីភាពរួចផុតពីការចាប់ខ្លួន និងការឃុំខ្លួនតាមទំនើងចិត្ត។

២. ត្រួតពិនិត្យសំបុត្រ សៀវភៅ ឯកសារដែលបានព្រីន ទំនាក់ទំនងតាមទូរស័ព្ទ ឬមធ្យោបាយដទៃទៀតនៃការទំនាក់ទំនង៖ បដិប្បញ្ញត្តិសិទ្ធិឯកជន។

៣. ហាមឃាត់ការរារាំង និងបិទផ្លូវធ្វើដំណើរ៖ បដិប្បញ្ញត្តិសិទ្ធិក្នុងការជួបប្រជុំ

៥. ហាមឃាត់សិទ្ធិក្នុងការចាកចេញពីប្រទេស នៅពេលដែលមានមូលដ្ឋានហេតុផលក្នុងការជឿជាក់ថាពួកគេជាអ្នកគាំទ្រ ក្នុងការបង្កឲ្យមានស្ថានភាពអាសន្នះ បដិប្បញ្ញត្តិសិទ្ធិសម្រាប់ប្រជាជនក្នុងការចាកចេញពីប្រទេស។

៦. បញ្ជាឲ្យជនបរទេសចាកចេញពីប្រទេស នៅពេលដែលមានមូលដ្ឋានហេតុផលក្នុងការជឿជាក់ថាពួកគេ ជាអ្នកគាំទ្រក្នុងការបង្កឲ្យមានស្ថានភាពអាសន្នះ បដិប្បញ្ញត្តិពីសេរីភាពរួចផុតពីការនិរទេស។

## ៣.៥ ICESCR

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌បានចូលជាធរមាននៅថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៦។ គិតត្រឹមខែមករា ឆ្នាំ២០១២ ICESCR មានសមាជិកជាង ១៦០រដ្ឋ ដែលតិចជាងរដ្ឋដែលបានផ្តល់សច្ចាប័នលើ ICCPR ដែលមានចំនួន១៦៨។ នៅអាស៊ីអាគ្នេយ៍រដ្ឋភាគីនៃសន្ធិសញ្ញារួមមានកម្ពុជា ឡាវ ឥណ្ឌូនេស៊ី ហ្វីលីពីន ថៃ ទីម័រខាងកើត និងវៀតណាម។ ប្រ៊ុយណេ មីយ៉ាន់ម៉ា ម៉ាឡេស៊ី និងសិង្ហបុរីមិនទាន់បានផ្តល់សច្ចាប័ននៅឡើយទេ។ រដ្ឋដំបូងបំផុតដែលផ្តល់សច្ចាប័នគឺហ្វីលីពីនដែលជារដ្ឋមួយក្នុងចំណោមរដ្ឋដំបូងបំផុតដែលបានផ្តល់សច្ចាប័ន ក្នុងឆ្នាំ១៩៧៦។ កាលពីពេលថ្មីៗនេះឥណ្ឌូនេស៊ី និងឡាវបានផ្តល់សច្ចាប័នលើសន្ធិសញ្ញានេះ គឺក្នុងឆ្នាំ២០០៦ និង២០០៧។ ផ្នែកនេះនឹងគ្រប់ដណ្តប់ទស្សនៈចម្បងនៃសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ESCR) ដោយបញ្ជាក់លម្អិតនៃសិទ្ធិចម្បងៗក្នុងសន្ធិសញ្ញា និងត្រួតពិនិត្យផងដែរនូវសិទ្ធិស្តង់ដារជីវភាព។

ដូចដែលជំពូកទីមួយបានបញ្ជាក់ ប្រភេទទាំងបីនៃសិទ្ធ សេដ្ឋកិច្ចសង្គម និងវប្បធម៌ គឺពាក់ព័ន្ធគ្នាប៉ុន្តែជាប្រភេទដែលខុសគ្នា។ ដូចនេះ ស្ថាប័នផ្សេងៗក្នុងប្រព័ន្ធUN ធ្វើការក្នុងការលើកកម្ពស់ និងការពារសិទ្ធិទាំងនេះ។ ជាឧទាហរណ៍សិទ្ធិសេដ្ឋកិច្ច គ្រប់ដណ្តប់លើសិទ្ធិជុំវិញការងារ ហើយសិទ្ធិទាំងនេះត្រូវបានចងក្រងជាឯកសារ និងកំណត់និយមន័យដោយ ILO។ ស្ថាប័នេះ ដែលមានវត្តមានមុន UN បានបង្កើតអនុសញ្ញាជិត ២០០អនុសញ្ញាស្តីពីស្តង់ដារការងារ គ្រប់ដណ្តប់ប្រធានបទដូចជាប្រាក់កម្រៃស្មើភាពគ្នា លក្ខខណ្ឌការងារ សម្រាកមាតុភាព និងសុវត្ថិភាពលើទូកនេសាទជាដើម។

សិទ្ធិសង្គម ដែលរួមមានសិទ្ធិទទួលបានការថែទាំសុខភាព ការអប់រំ ចំនីអាហារ ទឹក និងទីលំនៅ ត្រូវបានការពារ និងលើកកម្ពស់ដោយស្ថាប័ន UN ជាក់លាក់ ជាមួយនឹងស្ថាប័នសិទ្ធិមនុស្សដទៃទៀត។ សិទ្ធិក្នុងការទទួលបានការថែទាំសុខភាពត្រូវបានលើកកម្ពស់ និងការពារដោយអង្គការសុខភាពពិភពលោក (WHO) ដែលមានស្តង់ដារស្តីពីលក្ខខណ្ឌសុខភាពអប្បរមា។ ការអប់រំ និងវប្បធម៌ត្រូវបានគាំទ្រដោយអង្គការអប់រំវិទ្យាសាស្ត្រ និងវប្បធម៌របស់អង្គការសហប្រជាជាតិផងដែរ (UNESCO)។ សិទ្ធិក្នុងការទទួលបានចំណីអាហារត្រូវបានទទួលខុសត្រូវដោយ អង្គការស្បៀងអាហារ និងកសិកម្មពិភពលោក (FAO) ផងដែរ។ ដូចនេះនៅក្នុងករណីមួយចំនួន ទ្រឹស្តី និងទស្សនៈទាំងនេះស្តីពីសិទ្ធិ លេចចេញពីផ្នែកផ្សេងៗគ្នានៃប្រព័ន្ធ UN។

ការបែងចែករវាងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (CPR) និង ESCR នៅតែមានឥទ្ធិពលលើការការពារសិទ្ធិមនុស្សរហូតដល់ពេលបច្ចុប្បន្ននេះ។ អ្នកមួយចំនួនគិតថា ESCR មានសារៈសំខាន់ជាង ដោយសារសិទ្ធិទាំងនេះធានាដល់ជីវិតរស់នៅ៖ មនុស្សត្រូវការចំណីអាហារ ទឹក និងសុខភាពដើម្បីរស់នៅ។ អ្នកមួយចំនួនទៀតអះអាងថា ដោយសារមានចរិកលក្ខណៈខុសគ្នា ESCR មិនមែនជាសិទ្ធិនោះទេ ប៉ុន្តែជាសេចក្តីចង់បាន ឬបំណងប្រាថ្នា។ ការអះអាងនេះផ្តុំលើទស្សនៈចំនួនពីរនៃ ESCR។ ទីមួយជាការអះអាងថាសិទ្ធិសេដ្ឋកិច្ច និងសង្គមមិនភ្លាមៗនោះទេ ប៉ុន្តែសិទ្ធិជាសិទ្ធិដែលអាចនឹងត្រូវបានឆ្លើយតបក្នុងពេលអនាគត។ ដូចនេះ សិទ្ធិទាំងនេះជាសេចក្តីចង់បាន និងបំណងប្រាថ្នាជាជាងសិទ្ធិដែលមានភ្លាមៗបច្ចុប្បន្ននេះដូចជា CPR។ ការអះអាងនេះផ្តោតលើវិធីសាស្ត្រដែលសិទ្ធិត្រូវបានសម្រេចបានជាបណ្តើរៗ និងលើវិធីសាស្ត្រក្នុងការកំណត់ពីសិទ្ធិ និងការរំលោភបំពានក្នុងទស្សនៈនេះ។ ការអះអាងទីពីរពាក់ព័ន្ធនឹងថាតើត្រូវការពារ និងចាប់បង្ខំអនុវត្តសិទ្ធិមនុស្សយ៉ាងដូចម្តេច ដូចដែលអ្នកខ្លះបានអះអាងថាជាការពិបាកក្នុងការបញ្ជាក់ភ័ស្តុតាង នៃការរំលោភបំពានលើESCR។ ប្រសិនបើបុគ្គលមួយរូបមិនមានផ្ទះសម្បែង តើត្រូវរដ្ឋាភិបាលទទួលខុសត្រូវក្នុងការស្វែងរកផ្ទះសម្បែងសម្រាប់ជាទីលំនៅដល់បុគ្គលនេះមែនទេ? តើពួកគេអាចធ្វើតាមរយៈតុលាការមែនទេ? នេះជាការអះអាងពីយុត្តាធិការ (ឬលទ្ធភាពក្នុងការកំណត់ពីសិទ្ធិ និងកាតព្វកិច្ចក្នុងប្រព័ន្ធយុត្តិធម៌)។ ទស្សនៈទាំងពីរនេះនៃការសម្រេចបានជាបណ្តើរៗ និងយុត្តាធិការនឹងត្រូវបានពិភាក្សាបន្ទាប់។

## ៣.៤.១ ការសម្រេចបានជាបណ្តើរៗ

នៅពេលដែលប្រទេសមួយក្លាយជារដ្ឋភាគីនៃ ICESCR ខ្លួនត្រូវការពារ និងគោរពសិទ្ធិមួយចំនួនភ្លាមៗនៅពេលផ្តល់សច្ចាប័ន។ សិទ្ធិទាំងនេះត្រូវបានហៅថាជាសិទ្ធិស្នូល

អប្បរមា។ សិទ្ធិស្នូលអប្បរមា ដូចជាការអប់រំថ្នាក់បឋមសិក្សា ឬលទ្ធភាពដែលមិនមានការរើសអើងក្នុងការចូលរៀននៅវិទ្យាល័យ គឺត្រូវចងកាតព្វកិច្ចនៅពេលដែលសន្ធិសញ្ញាចូលជាធរមាន។ យ៉ាងណាមិញសិទ្ធិដទៃទៀត មិនបង្កើតកាតព្វកិច្ចភ្លាមៗដល់រដ្ឋនោះទេ។ សិទ្ធិជាច្រើនក្នុង ESCR ស្ថិតក្នុងប្រភេទនៃការសម្រេចបានជាបណ្តើរៗ ដែលមានន័យថាជា ជាងសម្រេចបានភ្លាមៗនូវសិទ្ធិទាំងនេះ រដ្ឋមានកាតព្វកិច្ចមួយក្នុងការធ្វើកិច្ចការឆ្ពោះទៅកាន់ការបំពេញបាននូវសិទ្ធិទាំងនេះ នាពេលខាងមុខយ៉ាងខ្លី។ កាតព្វកិច្ចនេះសម្រាប់រដ្ឋក្នុងការបង្ហាញពី វឌ្ឍនភាពឆ្ពោះទៅកាន់ការបំពេញនូវសិទ្ធិទាំងនេះ។ ជាឧទាហរណ៍ រដ្ឋក្រីក្រ និងកំពុងអភិវឌ្ឍន៍ដែលមិនអាចផ្តល់នូវការថែទាំសុខភាព សុខមាលភាពសង្គម ឬវិទ្យាល័យគ្រប់គ្រាន់ភ្លាមៗដល់មនុស្សគ្រប់រូប ត្រូវតែបង្ហាញពីគោលនយោបាយ និងផែនការដែលបំពេញកិច្ចការឆ្ពោះទៅកាន់គោលដៅទាំងនេះ។ ការបញ្ជាក់លម្អិតនៃការសម្រេចបានជាបណ្តើរៗមាននៅក្នុងមាត្រា ២ នៃសន្ធិសញ្ញានេះ ។ ពាក្យពេចន៍នៅក្នុងមាត្រា១ ជាដំបូងមានភាពស្មុគ្រស្មាញ ជាន់គ្នា និងភ័ន្តច្រឡំ ប៉ុន្តែមានវិធីត្រឹមត្រូវក្នុងការកំណត់ខ្លឹមសាររបស់មាត្រានេះ។ ជាពិសេសមាត្រានេះបញ្ជាក់ពិស្តារពីសកម្មភាពដែលរដ្ឋត្រូវអនុវត្ត។

ពន្យល់ដោយសាមញ្ញ ការសម្រេចបានជាបណ្តើរៗតម្រូវឲ្យរដ្ឋតែងតែឈានទៅមុន ឬមានដំណើរការទៅមុខ ដើម្បីសម្រេចបាននូវកាតព្វកិច្ចរបស់ពួកគេក្នុងការផ្តល់នូវការថែទាំសុខភាព ការអប់រំ ការងារ និងចំណីអាហារ។ល។ ខណៈពេលដែលការវាស់វែងច្បាស់លាស់នៃថាតើអ្វីជាវឌ្ឍនភាព មានការបត់បែន ក៏មាននូវស្តង់ដារដែលបានទទួលស្គាល់មួយចំនួនផងដែរ។ ឯកសារចំនួនពីរស្រាយបំភ្លឺពីកាតព្វកិច្ចនៃការសម្រេចបានបណ្តើរៗ ដែលត្រូវបានហៅថាគោលការណ៍ Limburg និងគោលការណ៍ណែនាំ Maastricht។ ខណៈពេលដែលឯកសារទាំងពីរនេះមិនមែនជាសន្ធិសញ្ញា ដូចនេះមិនចងកាតព្វកិច្ចផ្លូវច្បាប់នោះទេ យ៉ាងណាមិញឯកសារទាំងនេះ អាចត្រូវបានពិចារណាថាជាគោលការណ៍ទូទៅនៃច្បាប់អន្តរជាតិ។ ឯកសារទាំងនេះពន្យល់ថាតើ ESCR ត្រូវបានវាស់វែងពាក់ព័ន្ធនឹងលទ្ធផលនៃកាតព្វកិច្ច មិនមែនកាតព្វកិច្ចគ្រាន់តែធ្វើសកម្មភាពនោះទេ។ មានន័យថាការវាស់វែង ESCR ចោទសួរថាប្រជាជនប៉ុន្មាននាក់ដែលមានលទ្ធភាពប្រើប្រាស់ទឹក ឬទទួលបានការអប់រំ ហើយមិនមែនថារដ្ឋាភិបាលបានខិតខំប្រឹងប្រែងខ្លាំងយ៉ាងណាក្នុងការផ្តល់ទឹក ឬការអប់រំនោះទេ។

លើសពីនេះទៀត រដ្ឋចងកាតព្វកិច្ចក្នុងការមិនដកហូត ESCR របស់បុគ្គលណាម្នាក់នោះទេ (ត្រូវបានហៅថាគោលការណ៍នៃមិនថយក្រោយ)។ ប្រសិនជាសិទ្ធិរបស់អ្នកណាម្នាក់ត្រូវបានឆ្លើយតប (ជាឧទាហរណ៍ សិទ្ធិក្នុងការទទួលបានលំនៅដ្ឋាន) នេះមិនត្រូវបានដកហូតតាមកាលៈទេសៈណាមួយនោះទេ ទោះបីជាពួកគេរស់នៅក្នុងលំនៅដ្ឋានខុសច្បាប់ក៏ដោយ។ ប្រសិនជារដ្ឋាភិបាលចង់បណ្តេញប្រជាជនទាំងនេះ

រដ្ឋាភិបាលធ្វើដូចនេះបាន លុះត្រាណាតែពួកគេត្រូវបានផ្តល់នូវលំនៅដ្ឋានផ្សេង។ មានន័យម្យ៉ាងទៀតថា ប្រសិនអ្នកណាម្នាក់កំពុងរស់នៅក្នុងផ្ទះមួយ ពួកគេមិនអាចត្រូវបានបណ្តេញចេញ បើមិនដូចច្នេះទេពួកគេនឹងមិនមានលំនៅដ្ឋានក្នុងការជ្រកកោននោះទេ។ នេះជាភាពជាក់ស្តែងនៃគោលការណ៍មិនថយក្រោយ។ ជាការរំលោភបំពានមួយ ប្រសិនជារដ្ឋបង្កឲ្យមានការបាត់បង់ផ្ទះសម្បែង ឬភាពអត់ឃ្លានដល់បុគ្គលណាម្នាក់ ដោយមិនពាក់ព័ន្ធនឹងស្ថានភាពណាមួយនោះទេ។ យ៉ាងណាមិញ កាតព្វកិច្ចរបស់រដ្ឋ និង បុគ្គលមានភាពស្មុគ្រស្មាញជាងនេះ។ ជាកាតព្វកិច្ចរបស់បុគ្គលក្នុងការបំពេញនូវ ESCR ដោយខ្លួនឯង ហើយប្រសិនជាគេមិនអាចធ្វើបាន ឧបមាថាគាត់ពិការ ពួកគេរស់នៅក្នុងភាពក្រីក្រ ឬពួកគេរស់នៅក្នុងតំបន់មានជម្លោះ នោះរដ្ឋត្រូវតែជួយដល់ពួកគេ។

## ៣.៤.២ យុត្តិកម្ម

មតិរិះគន់ទូទៅមួយលើ ESCR គឺថាវាជាការពិបាកក្នុងការបង្ហាញភស្តុតាងពីកាតព្វកិច្ច ឬការរំលោភបំពានរបស់រដ្ឋ ឬជាសិទ្ធិជាក់លាក់។ នេះជាបញ្ហានៃយុត្តាធិការ ឬលទ្ធភាពក្នុងការចំណាត់ការលើការរំលោភបំពានលើ ESCR តាមរយៈប្រព័ន្ធយុត្តិធម៌។ មានធាតុផ្សំជាច្រើនដែលមានឥទ្ធិពលលើថាតើ ESCR អាចត្រូវបានបញ្ជូនទៅចំពោះមុខតុលាការយ៉ាងដូចម្តេច។ ជាបឋម គួរតែមានច្បាប់ស្តីពី ESCR និងច្បាប់ដែលតុលាការទទួលស្គាល់ និង ប្រើប្រាស់។ ដូចដែលបានកត់សម្គាល់ខាងលើ ប្រទេសនៃអាស៊ីអាគ្នេយ៍មួយចំនួនខ្វះខាតនូវច្បាប់មូលដ្ឋាន ក្នុងការការពារសិទ្ធិទទួលបានចំណីអាហារ និងទឹក។ សិទ្ធិការពារលំនៅដ្ឋាន ឬលទ្ធភាពក្នុងការទទួលបានការថែទាំសុខភាពប្រហែលជាមានភាពទន់ខ្សោយ។ បន្ថែមពីលើនេះទៀត ធម្មនុញ្ញភាគច្រើននៅអាស៊ីអាគ្នេយ៍ បានត្រឹមតែផ្តល់ការការពារដែលមានកម្រិតលើ ESCR ប៉ុណ្ណោះ។

ទីពីរ ទាក់ទងនឹងការពិភាក្សាលើការសម្រេចបានជាបណ្តើរៗ យើងអង្កេតឃើញថាការចាប់បង្ខំផ្លូវច្បាប់ដើម្បីឲ្យរដ្ឋបង្ហាញពីវឌ្ឍនភាព មានការពិបាក្នុងតំបន់មួយចំនួន ហើយសំណួរមួយចំនួនលេចឡើង៖ តើរដ្ឋទទួលបានវឌ្ឍនភាពលឿនគ្រប់គ្រាន់ក៏អត់? តើរដ្ឋមានចាត់វិធានការដែរឬទេ? តើរដ្ឋអាចទទួលបានលទ្ធផលក្នុងការបង្ហាញថាប្រជាជនរបស់ខ្លួនកំពុងទទួលបានសិទ្ធិរបស់ខ្លួនឬក៏អត់?

ភាពស្មុគ្រស្មាញបន្ថែមទៀតកើតឡើង ដោយសារធាតុផ្សំជាច្រើននៃ ESCR ចាត់ទុកអ្នកកាន់កាប់សិទ្ធិថាជាអ្នកមានកាតព្វកិច្ច។ មានន័យថា ជាបឋមបុគ្គល ដែលពាក់ព័ន្ធត្រូវតែខិតខំដើម្បីឆ្លើយតបទៅនឹងសិទ្ធិទទួលបានការងារ ចំណីអាហារ លំនៅដ្ឋាន

។ល។ បុគ្គលមួយរូបមិនអាចទាមទារសិទ្ធិទទួលបានចំណីអាហារ ទឹក និងលំនៅដ្ឋានទាំងអស់ពីរដ្ឋាភិបាលនោះទេ ប្រសិនបើមិនមានការបង្ហាញច្បាស់ ថាពួកគេមិនអាចមានលទ្ធភាពក្នុងការទទួលបានរបស់ទាំងអស់នេះដោយខ្លួនឯងទេនោះ។

# ការពិភាក្សា និងការជជែកវែកញែក

## តើអ្នកណាគេទទួលខុសត្រូវចំពោះការធានា ESCR៖ រដ្ឋាភិបាល ឬបុគ្គល?

ដូចដែលបានបញ្ជាក់ខាងលើ ជាដំបូងបុគ្គលត្រូវបំពេញ ESCR ដោយខ្លួនឯង។

សំណួរ៖ ប៉ុន្តែមានអ្វីកើតឡើងប្រសិនបើអ្នកណាម្នាក់ជិតក្លាយទៅជនអនាថាអត់ផ្ទះសម្បែងដោយសារតែបំណុលល្បែងរបស់ខ្លួន? តើកាតព្វកិច្ចអ្វីដែលរដ្ឋមានចំពោះបុគ្គលអភ័ព្វរូបនេះ? ជាធម្មតា រដ្ឋាភិបាលមិនអនុញ្ញាតឲ្យអ្នកណាម្នាក់ ក្លាយជាជនអត់ផ្ទះសម្បែងនោះទេ ដោយសារថានេះស្មើនឹងការមិនសម្រេចបាននូវសិទ្ធិជាបណ្ដើរៗរបស់ពួកគេ។ យ៉ាងណាមិញ រដ្ឋាភិបាលគួរតែទទួលខុសត្រូវចំពោះជនណាម្នាក់ដែលបាត់បង់ផ្ទះសម្បែងដោយសារកំហុសផ្ទាល់ខ្លួនគេដែរឬទេ? នៅក្នុងករណីទាំងនេះច្បាស់ណាស់បុគ្គលខ្លួនឯងផ្ទាល់បង្កឲ្យមានបញ្ហា (ដោយសារការជក់បារី ឬល្បែង) ប៉ុន្តែរដ្ឋាភិបាល (ដោយអនុញ្ញាតឲ្យមានការជកបារី និងលេងល្បែង) ត្រូវទទួលខុសត្រូវខ្លះដែរឬទេ?

ភាពស្មុគ្រស្មាញបន្ថែមទៀត សួរថាភ្នាក់ងារណាមួយរបស់រដ្ឋាភិបាលគួរគ្រប់គ្រងកាតព្វកិច្ចទាំងនេះ។ សិទ្ធិការងារ ចំណីអាហារ លំនៅដ្ឋាន និងការអប់រំត្រូវបានគ្រប់គ្រងដោយក្រសួងរដ្ឋាភិបាល (ដូចជាក្រសួងការងារ សុខាភិបាល ឬអប់រំ)។ ប៉ុន្តែការដែលមានច្បាប់ក្នុងវិស័យនេះ បង្កប់ន័យថាតុលាការនឹងសម្រេចតើថាគោលនយោបាយមានប្រសិទ្ធិភាពឬក៏អត់ ដែលនេះធ្វើឲ្យមានជម្លោះរវាងក្រសួង និងតុលាការ។ ជាឧទាហរណ៍ បុគ្គលមួយរូបដែលមានមហារីក ដែលទាមទារការព្យាបាលដែលត្រូវចំណាយច្រើន ប៉ុន្តែមន្ទីរពេទ្យរដ្ឋាភិបាលទទូចថាការព្យាបាលនេះថ្លៃពេក ក្នុងការផ្ដល់ជូនមនុស្សគ្រប់រូប។ តើអ្នកណាគួរកំណត់បញ្ហានេះ៖ មន្ត្រីសុខាភិបាលដែលដឹងពីការចំណាយ ជម្ងឺ និងសមត្ថភាពរបស់មន្ទីរពេទ្យ ឬតុលាការដែលធានាថាប្រជាជនមានសិទ្ធិក្នុងការទទួលបាននូវការថែទាំសុខភាពរបស់ពួកគេ?

មានឧទាហរណ៍គ្រប់គ្រាន់ក្នុងការបង្ហាញថា ESCR អាចត្រូវបានកាត់ក្ដីដោយតុលាការបាន។ ជាពិសេសនេះជាការពិតក្នុងវិស័យការងារ ដូចដែលប្រទេសនៅអាស៊ី

អាគ្នេយ៍ភាគច្រើនមានច្បាប់ការងារ និងតុលាការការងារដែលមានប្រសិទ្ធិភាព។ ដូចគ្នាផងដែរចំពោះលំនៅដ្ឋាន ដោយសារប្រទេសនៅអាស៊ីអាគ្នេយ៍ភាគច្រើន បច្ចុប្បន្ននេះមានច្បាប់ស្តីពីសិទ្ធិទ្រព្យសម្បត្តិ និងច្បាប់ភតិសន្យា។ ច្បាប់ និងតុលាការទាំងនេះមិនធានាថា សិទ្ធិទាំងនេះរបស់ប្រជាជនត្រូវបានបំពេញនោះទេ ប៉ុន្តែពួកគេបង្ហាញពីយុត្តាធិការរបស់ខ្លួន។

# ករណីសិក្សា

## ការកាត់ក្ដីលើសិទ្ធិលំនៅដ្ឋាន

មានជម្លោះជាច្រើនពាក់ព័ន្ធនឹងសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋានទូទាំងអាស៊ីអាគ្នេយ៍។ ចំពោះរដ្ឋកំពុងអភិវឌ្ឍន៍ ទាមទារឲ្យមានការរឹបអូសដីធ្លី ដូចនេះអាចបង្កើតផ្លូវឧស្សាហកម្ម និងសេវាកម្ម។ យ៉ាងណាមិញ វិធីក្នុងការអនុវត្តក្នុងប្រទេសជាច្រើនមិនមានយុត្តិធម៌៖ មានសំណងតិចតួចដល់ម្ចាស់ដី ជារឿយៗផលប្រយោជន៍បានដល់អាជីវកម្ម ហើយប្រជាជនដែលត្រូវបានបណ្ដេញចេញមិនដឹងត្រូវទៅណា។

ជម្លោះដីធ្លីក្នុងប្រទេសកម្ពុជាបានលេចចេញក្នុងប្រព័ន្ធផ្សព្វផ្សាយជាច្រើន។ ហេតុផលនេះមានឫសគល់តាំងពីអំឡុងពេលខ្មែរក្រហម នៅពេលដែលឯកសារលំនៅដ្ឋានទាំងអស់ត្រូវបានបំផ្លាញ ហើយប្រជាជនជាច្រើនមិនមានឯកសារកម្មសិទ្ធិស្របច្បាប់ដើម្បីបង្ហាញថាជាម្ចាស់កម្មសិទ្ធិលើទ្រព្យសម្បត្តិរបស់ខ្លួន។ ជាលទ្ធផលមានករណីកើតឡើងដែលរដ្ឋាភិបាល ឬ ក្រុមហ៊ុនឯកជនបានរឹបអូសទ្រព្យសម្បត្តិទាំងនេះ។ ឧទាហរណ៍កាលពីពេលថ្មីៗនេះករណីសហគមន៍បឹងកក់ក្នុងប្រទេសកម្ពុជាបានដាក់ពាក្យបណ្ដឹងជាមួយនឹងគណៈកម្មាធិការអធិការកិច្ច របស់ធនាគារពិភពលោកក្នុងខែកញ្ញា ឆ្នាំ២០០៩ ដែលឈានដល់ការស៊ើបអង្កេតមួយលើគម្រោង ដែលធនាគារពិភពលោកមានកិច្ចសហការជាមួយនឹងរដ្ឋាភិបាលកម្ពុជា។ ក្នុងខែមិនា ឆ្នាំ ២០១១ ធនាគារពិភពលោកបានព្រមព្រៀងជាមួយនឹងអង្គការសិទ្ធិលំនៅដ្ឋានមួយ គឺមជ្ឈមណ្ឌលសិទ្ធិលំនៅដ្ឋាន និងការបណ្ដេញចេញ ថាអ្នករស់នៅបឹងកក់ត្រូវបានបដិសេធ ក្នុងការចុះបញ្ជិការដីធ្លីរបស់ខ្លួន ហើយបានព្រមព្រៀងក្នុងការចាត់វិធានការក្នុងការកាត់បន្ថយផលប៉ះពាល់ ដែលកើតមានឡើងរបស់គម្រោងលើប្រជាជនទាំងនេះ។ នៅខែសីហា ឆ្នាំ២០១១ ធនាគារពិភពលោកបានប្រកាសថាខ្លួន នឹងព្យួរកម្ចីដល់រដ្ឋាភិបាលកម្ពុជា រហូតដល់មានការដោះស្រាយជម្លោះលើការបណ្ដេញចេញទ្រង់ទ្រាយធំមួយនៃគ្រួសារនៅសហគមន៍បឹងកក់ ក្នុងទីក្រុងភ្នំពេញ។

មានករណីជាច្រើនដែលស្រដៀងគ្នាទូទាំងអាស៊ីអាគ្នេយ៍ ដែលការអភិវឌ្ឍបានបំលាស់ទីប្រជាជនក្នុងប្រទេសវៀតណាម មីយ៉ាន់ម៉ា ឥណ្ឌូនេស៊ី និងថៃ។ កង្វល់ដែលពាក់ព័ន្ធមួយ គឺការបំពុលបរិស្ថានពីការអភិវឌ្ឍទាំងនេះ ធ្វើឲ្យលំនៅដ្ឋានរបស់ប្រជាជនក្លាយទៅជាកន្លែងដែលមិនអាចរស់នៅបាន។

# ៣.៨ សិទ្ធិក្នុង ICESCR

សិទ្ធិក្នុង ESCR អាចត្រូវបានសង្ខេបជាបីប្រភេទ៖ សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។

## ផ្តោតសំខាន់លើ

សង្ខេប ESCR

| | |
|---|---|
| មាត្រា១ | សិទ្ធិស្វ័យសម្រេច |
| មាត្រា២ | សិទ្ធិឲ្យមានការសម្រេចទៅមុខ |
| មាត្រា៣ | ភាពស្មើគ្នារវាងបុរស និងស្ត្រី |
| មាត្រា៤ & ៥ | ការកំណត់នៅពេលដែលចាំបាច់ |
| មាត្រា៦ | សិទ្ធិធ្វើការងារ |
| មាត្រា៧ | សិទ្ធិទទួលបានលក្ខខណ្ឌការងារល្អ |
| មាត្រា៨ | សិទ្ធិសហជីព |
| មាត្រា៩ | សិទ្ធិទទួលបានសន្តិសុខសង្គម |
| មាត្រា១០ | ការការពារគ្រួសារ ជាពិសេសសម្រាប់ម្តាយ និងកុមារ |
| មាត្រា១១ | សិទ្ធិរស់នៅ រួមមានទាំងអាហារ សម្លៀកបំពាក់ និវេសនដ្ឋាន |
| មាត្រា១២ | សិទ្ធិទទួលបានសុខភាពទាំងខាងរាងកាយ និងខាងស្មារតី |
| មាត្រា១៣ | សិទ្ធិទទួលបានការអប់រំ |
| មាត្រា១៤ | សិទ្ធិជាកាតព្វកិច្ច និងទទួលបានការអប់រំកម្រិតបឋម |
| មាត្រា១៥ | សិទ្ធិចូលរួមក្នុងវប្បធម៌ |

## ៣.៨.១ សិទ្ធិសេដ្ឋកិច្ច

សិទ្ធិសេដ្ឋកិច្ចជួយក្នុងការធានានូវសន្តិសុខសេដ្ឋកិច្ចដល់បុគ្គលមួយរូប ដែលនេះអាចសម្រេចបានតាមមធ្យោបាយបីយ៉ាង។ ដំបូង សិទ្ធិទាំងនេះគ្របដណ្តប់សិទ្ធិការងារ និងសិទ្ធិនៅកន្លែងការងារ។ ស្តង់ដារកន្លែងការងារជាច្រើនត្រូវបានកំណត់ដោយ ILO

ដែលបានលើកកម្ពស់ទស្សនៈ ដូចជាអាយុអប្បរមា ប្រាក់ឈ្នួលអប្បរមា និងម៉ោងការងារអតិបរមាក្នុងមួយសប្តាហ៍។ សិទ្ធិគន្លឹះដទៃទៀតរួមមានការមិនរើសអើងនៅកន្លែងការងារ ពេលសម្រាក និងការផ្តល់នូវលក្ខខណ្ឌការងារដែលមានសុវត្ថិភាព និងសុខភាព។ ទីពីរ សិទ្ធិក្នុងការធ្វើការរួមមានសិទ្ធិក្នុងការទទួលបានសុខមាលភាព ឬសន្តិសុខសង្គម មានន័យថាប្រសិនបើបុគ្គលមួយរូបមិនអាចបំពេញការងារ ឬស្វែងរកស្តង់ដារជីវភាពសេដ្ឋកិច្ចរបស់ខ្លួន រដ្ឋាភិបាលត្រូវផ្តល់ជូនពួកគេនូវប្រាក់សោធនមួយចំនួន។ ទីបី សិទ្ធិសេដ្ឋកិច្ចរួមមានសិទ្ធិក្នុងការបង្កើតសហជីព ដែលអាចបង្កើតអង្គការក្នុងការការពារសិទ្ធិរបស់ពួកគេ ប្រសិនបើកម្មករមួយរូបត្រូវបានប្រព្រឹត្តមកលើមិនគប្បី។

## ៣.៩.២ សិទ្ធិសង្គម

សិទ្ធិសង្គមរួមមានសិទ្ធិក្នុងការទទួលបានការថែទាំសុខភាព ការអប់រំ ចំណីអាហារ ទឹក និងលំនៅដ្ឋាន។ គោលបំណងសំខាន់មួយនៃសិទ្ធិទាំងនេះ គឺដើម្បីធានានូវស្តង់ដារជីវភាពគ្រប់គ្រាន់។ សិទ្ធិក្នុងការទទួលបានចំណីអាហារ ទឹក និងលំនៅដ្ឋាន (សិទ្ធិស្តង់ដារជីវភាព) មិនត្រូវបានផ្តល់ជូនដោយផ្ទាល់ដោយរដ្ឋាភិបាលនោះទេ។ ហើយក៏មិនមែនជាការរំពឹងដែលរដ្ឋាភិបាលគួរតែផ្តល់ជូនមនុស្សគ្រប់រូបនូវផ្ទះ និងអាហារនោះទេ។ យ៉ាងណាមិញ នៅពេលដែលប្រជាជនមិនអាចផ្គត់ផ្គង់ភាពចាំបាច់នេះដោយខ្លួនឯង (ដោយសារសង្គ្រាម បាតុភូតធម្មជាតិ ឬដោយសារពួកគេឈឺ ពិការ ឬមិនដូចនេះទេពួកគេមិនអាចធ្វើការបាន) ជាការរំពឹងថារដ្ឋាភិបាលនឹងផ្តល់ជូនពួកគេ។ សិទ្ធិទទួលបានការអប់រំ និងការថែទាំសុខភាពត្រូវបានស្រាវជ្រាវទូលំទូលាយដោយ UNESCO និង WHO។

**សិទ្ធិស្តង់ដារជីវភាព**

*សិទ្ធិស្តង់ដារជីវភាពជាសិទ្ធិក្នុងការទទួលបានស្តង់ដារអប្បរមានៃការរស់នៅ។ ទាំងនេះធានាថាមនុស្សមានលទ្ធភាពក្នុងការទទួលបានជីវជាតិគ្រប់គ្រាន់រួមមានទឹកគ្រប់គ្រាន់ សម្លៀកបំពាក់ និងលំនៅដ្ឋានគ្រប់គ្រាន់។ដូចនេះ សិទ្ធិស្តង់ដារជីវភាពគឺជាការធានាថាស្តង់ដារអប្បរមានៃវត្តមានមនុស្សត្រូវបានឆ្លើយតប។*

**សិទ្ធិស្តង់ដារជីវភាព** ជាធម្មតាត្រូវបានចែងចេញជាចំណីអាហារ ទឹក និងជម្រក។ យ៉ាងណាមិញ ICESCR បញ្ជាក់ថាមានចំណីអាហារ សម្លៀកបំពាក់ និងលំនៅដ្ឋាន។ មានហេតុផលសម្រាប់ការបែងចែកនេះ។ ជាដំបូង មានមនុស្សមួយចំនួនតូច ដែលសិទ្ធិរបស់ពួកគេក្នុងការទទួលបានសម្លៀកបំពាក់ត្រូវបានគម្រាមកំហែង។ ជាការកម្រក្នុងការរកឧទាហរណ៍ នៃស្ថានភាពដែលប្រជាជនមិនមានលទ្ធភាពក្នុងការទទួលបានសម្លៀកបំពាក់ ទោះបីជាអាចកើតមានឡើង ក្នុងប្រទេសដែលមានអាកាសធាតុត្រជាក់មួយចំនួនក៏ដោយ ដែលក្នុងប្រទេសនោះ ប្រជាជនក្រីក្រមិនអាចមានលទ្ធភាពក្នុងការទទួលបានសម្លៀកបំពាក់កក់ក្តៅក្នុងអំឡុងពេលរដូវរងារឡើយ។ ប៉ុន្តែរដ្ឋាភិបាល និង NGOs ភាគច្រើនអាចដោះស្រាយបញ្ហានេះបាន។ យ៉ាងណាមិញមានប្រជាជនដែលគ្មានផ្ទះសម្បែង ឬប្រជាជនក្រីក្រគោកយ៉ាកដែលមិនអាចស្លៀកពាក់

ប្រកបដោយភាពថ្លៃថ្នូរ ប៉ុន្តែបញ្ហាចម្បងភាគច្រើននៅទីនេះមិនមែនសម្លៀកបំពាក់នោះទេ ប៉ុន្តែគឺលំនៅដ្ឋាន ចំណីអាហារ ទឹក និងសុខភាព។

ទឹកទើបតែក្លាយជាបញ្ហាសិទ្ធិកាលពីពេលថ្មីៗនេះ ដោយសារអស់អំឡុងពេលជាយូរយាមកហើយ ដែលទឹកជាធនធានដែលមានច្រើន និងមិនចាំបាច់ចំណាយលុយហើយមានមនុស្សតិចតួចប៉ុណ្ណោះដែលមានបញ្ហាក្នុងការទទួលបានទឹកស្អាត។ យ៉ាងណាមិញ ដូចដែលទីក្រុង និងឧស្សាហកម្មត្រូវការទឹកច្រើន ខណៈពេលនេះផងដែរពួកគេក៏បានបំពុលប្រព័ន្ធទឹក ដែលធ្វើឲ្យទឹកក្លាយជាធនធានមានកំណត់។ ជាការឆ្លើយតប រដ្ឋាភិបាលបានចាប់ផ្តើមគិតថ្លៃសេវាសម្រាប់ការប្រើប្រាស់ទឹក ហើយប្រជាជនជាច្រើនបានបាត់បង់ការទទួលបានទឹកដោយមិនចាំបាច់បង់ថ្លៃ។ ស្ថានភាពពីទឹកក្នុងកតិកាសញ្ញាមិនមានភាពច្បាស់លាស់នោះទេ។ ទោះបីជាមិនត្រូវបានសរសេរជាក់លាក់ក្នុងកតិកាសញ្ញាក៏ដោយ អ្នកខ្លះអះអាងថាសិទ្ធិក្នុងការទទួលបានទឹកស្ថិតក្នុងផ្នែកមួយនៃសិទ្ធិក្នុងការទទួលបានចំណីអាហារ។ ដើម្បីបញ្ជាក់ពីស្ថានភាពនេះ មានការចេញនូវវិចារណកថាមួយ ដែលបានបញ្ជាក់ថាសិទ្ធិក្នុងការទទួលបានទឹកត្រូវបានបញ្ចូលក្នុង ICESCR និងត្រូវបានបញ្ជាក់ថាជាសិទ្ធិក្នុងការទទួលបានទឹកដែលគ្រប់គ្រាន់ មានសុវត្ថិភាព ទទួលយកបាន អាចបានទទួលជារូបវន្ត និងអាចផ្គត់ផ្គង់បាន។

## ផ្តោតសំខាន់លើ

### ការធានាស្តង់ដារនៃសិទ្ធិស្តង់ដារជីវភាព

ចំពោះបុគ្គលមួយរូប ដើម្បីទទួលបានស្តង់ដារជីវភាពរបស់ខ្លួនមិនមែនគ្រាន់តែផ្តល់ជូននូវចំនួនកាឡូរី ទឹកផឹកប៉ុន្មានលីត្រក្នុងមួយថ្ងៃនោះទេ ។ ស្តង់ដារជីវភាពត្រូវធានាផងដែរថាសិទ្ធិ និងភាពថ្លៃថ្នូររបស់បុគ្គលត្រូវបានគោរព។ ដើម្បីជួយដល់រដ្ឋក្នុងការធានាស្តង់ដារទាំងនេះ វិចារណកថាទូទៅមួយនៃសន្និសញ្ញានេះបង្ហាញពីធាតុផ្សំថារដ្ឋមួយត្រូវពិចារណាដើម្បីធានានូវការអនុលោមតាម ICESCR។ ធាតុផ្សំបួនសំខាន់ដែលមានចំពោះសុខភាព ការអប់រំ ចំណីអាហារ និងទឹកគឺ៖

- មាន៖ ត្រូវមានការផ្គត់ផ្គង់គ្រប់គ្រាន់នូវទំនិញទាំងនេះសម្រាប់មនុស្សគ្រប់រូប។ ជាឧទាហរណ៍ ត្រូវមានសាលាគ្រប់គ្រាន់ក្នុងការផ្តល់ដល់កុមារគ្រប់រូបបានចូលរៀន អាហារគ្រប់គ្រាន់សម្រាប់មនុស្សគ្រប់រូបក្នុងការបរិភោគបានគ្រប់ចំនួន ទឹកគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់របស់បុគ្គល និងក្រុមគ្រួសារ (ដូចជាសម្រាប់ទទួលទាន សម្អាត និងចំអិនចំណីអាហារ) និងគ្លីនិកសុខភាពគ្រប់គ្រាន់ដូចនេះប្រជាជនគ្រប់រូបអាចមានលទ្ធភាពក្នុងការជួបជាមួយនឹងពេទ្យ។

- អាចទទួលបាន៖ ទោះបីជាមានក៏ដោយ អ្វីដែលសំខាន់នោះគឺថាប្រជាជនអាចទទួលបាន។ វាមិនមែនជារឿងចំលែកនោះទេ ដែលមានចំណីអាហារគ្រប់គ្រាន់ ប៉ុន្តែប្រជាជននៅតែខ្វះជីវជាតិ។ ជាឧទាហរណ៍ ប្រហែលជាពួកគាត់មានឧបសគ្គក្នុងការទទួលបាននូវសេវាកម្មទាំងនេះ ដោយសារគាត់ក្រពេលត្រូវបានរើសអើង ឬគ្រោះថ្នាក់ពេកក្នុងការធ្វើដំណើរទៅទទួលសេវាទាំងនោះ។ ជាទូទៅមានរូបភាពបីយ៉ាងក្នុងការទទួលបាន៖ ទទួលបានជារូបវ័ន (តើសេវាកម្មជិត និងមានសុវត្ថិភាពក្នុងការធ្វើដំណើរទៅយកដែរឬទេ ? ) ទទួលបានផ្នែកសេដ្ឋកិច្ច (តើបុគ្គលមានលទ្ធភាពក្នុងការបង់សេវាដែរឬទេ?) និងមិនរើសអើង (តើការទទួលយកបានត្រូវបានហាមឃាត់ដោយសារយែនឌ័រ ពូជសាសន៍ ឬឋានៈផ្សេងដែរឬទេ?។ ចំណីអាហារអាចថ្លៃពេក ក្មេងស្រីប្រហែលជាមិនត្រូវបានអនុញ្ញាតឲ្យទៅសាលារៀន ឬប្រជាជនដែលមានឋានៈសង្គមមួយចំនួន មិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ទឹកអណ្តូងក្នុងមូលដ្ឋាន។
- អាចទទួលយកបាន៖ ទំនិញ/សេវាត្រូវតែមានគុណភាពជាក់លាក់។ ចូលរៀនមិនគ្រប់គ្រាន់នោះទេ សាលាត្រូវបង្រៀនកុមារពីអ្វីដែលពួកគេគួរតែដឹងផងដែរ។ ចំណីអាហារ និងទឹកត្រូវតែជាទឹកស្អាតក្នុងកម្រិតដែលអាចទទួលយកបាន និងមិនមានការបំពុល។ លំនៅដ្ឋានមិនត្រូវបានចាត់ទុកថាជាប្រអប់រទេះដែលនៅក្រោមស្ពាននោះទេ ដោយសារត្រូវធ្វើការធានាថាបុគ្គលមានសុវត្ថិភាព ដែលត្រូវបានការពារពីបរិស្ថានជុំវិញ និងនៅជិតសេវាកម្ម។
- សមរម្យ៖ ទំនិញ/សេវាត្រូវតែសមរម្យផងដែរដើម្បីឆ្លើយតបនឹងតម្រូវការជាក់លាក់។ នេះអាចសមរម្យតាមវប្បធម៌នីមួយៗ និងសាកសមចំពោះជនពិការផងដែរ។ សិទ្ធិក្នុងការទទួលបានចំណីអាហារមិនគ្រាន់តែឆ្លើយតបនឹងការផ្តល់នូវចំណីអាហារដែលមាន ២២០០ កាឡូរីនោះទេដែលមានក្នុងកន្ត្រកប៉ុណ្ណោះទេ សិទ្ធិក្នុងការទទួលបានចំណីអាហារត្រូវធានាផងដែរថាបុគ្គលទទួលទានដូចជាមនុស្សទូទៅ។ នេះអាចមានន័យថាចំណីអាហារគួរតែសាកសមនឹងតម្លៃវប្បធម៌របស់ពួកគេ ( ជាឧទាហរណ៍ ប្រសិនពួកគេជាអ្នកញ៉ាំបន្លែ) ហើយនឹងទទួលទានតាមវិធីដែលមនុស្សទូទៅញ៉ាំដែរ (ឧទាហរណ៍ ជាមួយនឹងមិត្តភ័ក្រ និងក្រុមគ្រួសារ)។

សេចក្តីបញ្ជាក់លម្អិតពីធាតុផ្សំនៃសិទ្ធិស្តង់ដារជីវភាពទាំងនេះ មាននៅក្នុងមតិយោបល់ទូទៅជាក់លាក់មួយចំនួនក្នុងឯកសារដូចខាងក្រោម៖

- ចំណីអាហារ៖ វិចារណកថាទូទៅលេខ ១២
- ទឹក៖ វិចារណកថាទូទៅលេខ ១៥

- លំនៅដ្ឋានៈ វិចារណកថាទូទៅលេខ ៤ និង៧
- ការអប់រំៈ វិចារណកថាទូទៅលេខ ១៣
- សុខភាពៈ វិចារណកថាទូទៅលេខ ១៤

## ៣.៦ វប្បធម៌ និងសិទ្ធិមនុស្ស

សិទ្ធិវប្បធម៌នៅតែជាសិទ្ធិមនុស្សដែលមានភាពចម្រូងចម្រាសមួយ។ សិទ្ធិវប្បធម៌នៅក្នុង ESCR ស្ទើរតែស្មើនឹងសិទ្ធិជនជាតិភាគតិចក្នុងមាត្រា ២៧ នៃCCPR ។ មាននូវការបែងចែកច្បាស់លាស់មួយចំនួន ដោយសារថាគ្រប់វប្បធម៌ទាំងអស់មិនមែនជនជាតិភាគតិចនោះទេ។ យ៉ាងណាមិញមាត្រាទាំងពីរ ប្រឈមនឹងការពិបាកក្នុងការកំណត់និយមន័យឲ្យបានច្បាស់លាស់ថាអ្វីជា "ជីវិតវប្បធម៌" នោះទេ។ ដោយសារថាមិនមានស្តង់ដារវប្បធម៌ច្បាស់លាស់ ការការពារសិទ្ធិនេះក្លាយទៅជាប្រភពនៃការជជែកវែកញែកមួយ។ អាចជាការសន្មតថាជីវិតវប្បធម៌រួមមានពិធីវប្បធម៌ពាក់ព័ន្ធនឹងការកើត ការស្លាប់ និងអាពាហ៍ពិពាហ៍។ សិទ្ធិវប្បធម៌ ក៏រួមបញ្ចូលផងដែរនូវសិទ្ធិពាក់ព័ន្ធនឹងចំណីអាហារ ការអប់រំ អាពាហ៍ពិពាហ៍ និងច្បាប់ទំនៀមទំលាប់។ នៅតែមានការជជែកវែកញែកច្រើនតើថាសម្លៀកបំពាក់ ព្រឹត្តិការណ៍សង្គម ប្រព័ន្ធផ្សព្វផ្សាយការកំសាន្ត និងស្មារតីមិនមែនសាសនាអាចត្រូវបានរួមបញ្ចូលឬក៏អត់នោះទេ។ ជាពិសេសបញ្ហាសម្លៀកបំពាក់ ដែលជាឧទាហរណ៍នៃរបាំងមុខជនជាតិឥស្លាម ត្រូវបានជជែកវែកញែកយ៉ាងផុសផុលទូទាំងពិភពលោក។ មានការអភិវឌ្ឍមួយចំនួននៃទស្សនៈនៃសេដ្ឋកិច្ចវប្បធម៌តាមរយៈយន្តការច្បាប់រដ្ឋ ថ្នាក់តំបន់ និងអន្តរជាតិ។ នៅក្នុងករណីទាំងនេះសេដ្ឋកិច្ចវប្បធម៌ ដូចជាការឃ្វាលសត្វ ការប្រមាញ់ ឬកសិកម្ម (ជាឧទាហរណ៍សិទ្ធិនេសាទរបស់ជនជាតិម៉ៅរី (Maori) ក្នុងប្រទេសញ៉ូវហ្ស៊ីឡែន ឬការឃ្វាលសត្វរមាំងទឹកកក reindeer របស់ជនជាតិសាមី (Sami) នៅប្រទេសហ្វាំងឡង់ និងស៊ុយអែដ និងសិទ្ធិក្នុងការប្រមាញ់របស់ជនជាតិដើមកាណាដា) ត្រូវបានការពារថាជាសិទ្ធិវប្បធម៌។ យ៉ាងណាមិញ មិនមានរដ្ឋអាស៊ីអាគ្នេយ៍ណាមួយ ដែលបានទទួលស្គាល់សិទ្ធិទាំងនេះនោះទេ។

ប្រហែលជាមានហេតុផលនយោបាយមួយចំនួន ដែលធ្វើឲ្យខ្វះភាពច្បាស់លាស់ជុំវិញសិទ្ធិវប្បធម៌។ រដ្ឋាភិបាលមួយចំនួនព្យាយាមក្នុងការធានាថាវប្បធម៌ដែលគ្របដណ្តប់នៅតែគ្រប់ដណ្តប់ដដែល ឬថាវប្បធម៌ជនជាតិភាគតិចមិនទទួលបានអំណាចច្រើន។ ប្រហែលជាមានការប៉ះទង្គិចរវាងសិទ្ធិវប្បធម៌ និងគោលនយោបាយវប្បធម៌របស់រដ្ឋាភិបាល ដោយសាររដ្ឋមួយចំនួននៅក្នុងតំបន់មានទស្សនៈអភិរក្សខ្លាំងចំពោះវប្បធម៌

របស់ពួកគេ ដូចជារបាំប្រពៃណី និងចំរៀងប្រពៃណី ហើយទម្រង់ផ្សេងទៀតនៃវប្បធម៌សហសម័យដូចជាសិល្បៈទំនើប មិនទទួលបានលើកកម្ពស់ និងការពារដូចគ្នានោះទេ។ មូលដ្ឋាននៃសិទ្ធិវប្បធម៌គួរតែពាក់ព័ន្ធនឹងទស្សនៈនៃពហុវប្បធម៌និយម ឬថារដ្ឋគួរតែអនុញ្ញាតឲ្យមានវប្បធម៌ច្រើន និងមិនគាំទ្រតែវប្បធម៌ដែលគ្របដណ្តប់តែមួយគត់នោះទេ។ យ៉ាងណាមិញ ទូទាំងអាស៊ីអាគ្នេយ៍ រដ្ឋាភិបាលភាគច្រើនយកចិត្តទុកដាក់ទាំងដោយផ្ទាល់ និងដោយប្រយោលលើវប្បធម៌ និងសាសនាភាគច្រើន។

# ករណីសិក្សា

## ការលោតមុងសាយចិននៅក្នុងប្រទេសឥណ្ឌូនេស៊ី

ការលោតមុងសាយចូលមកប្រទេសឥណ្ឌូនេស៊ីក្នុងសតវត្សឆ្នាំ ១៩០០ នៅពេលដែល Tiong Hoa Hwe Koan (ឬជាសមាគមចិនឥណ្ឌូនេស៊ី) បានបង្កើតឡើង។ យ៉ាងណាមិញ អតីតប្រធានាធិបតី ស៊ូហាតូ (កាន់អំណាចពីឆ្នាំ១៩៦៥ ដល់១៩៩៨) បានអនុវត្តគោលនយោបាយឯកភាពលើមនោគមវិជ្ជារដ្ឋ វប្បធម៌ សង្គម និងនយោបាយ និងបានអនុវត្តទស្សនៈនៃគ្រប់ទិដ្ឋភាពទាំងអស់នៃសង្គមឥណ្ឌូនេស៊ី។ មួយក្នុងចំណោមគោលនយោបាយទាំងនេះបានហាមឃាត់ 'វប្បធម៌បរទេស' គ្រប់ប្រភេទទាំងអស់។ វប្បធម៌ចិនជាវប្បធម៌មួយដែលត្រូវបានហាមឃាត់ ដូចដែលបានចែងក្នុងបទបញ្ជាប្រធានាធិបតីលេខ ១៤ (១៩៦៧)។ ផ្អែកលើស្ថានភាពនេះ លទ្ធិខុងជឺ ឬ Khonghucu មិនត្រូវបានទទួលស្គាល់ថាជាសាសនានោះទេ ជាលទ្ធផលក្នុងអគារជាច្រើនបានហាមឃាត់វិហារខុងជឺ ហាមមិនឲ្យប្រើប្រាស់ឈ្មោះចិនដែលបង្ខំឲ្យជនជាតិចិនប្តូរទៅជាឈ្មោះចាវ៉ា ឬម៉ាឡេ និងហាមឃាត់ការលោតមុងសាយនៅទីសាធារណៈ។

ស្ថានភាពនេះបានផ្លាស់ប្តូរ បន្ទាប់ពីការធ្លាក់ពីតំណែងរបស់ស៊ូហាតូក្នុងឆ្នាំ១៩៩៨។ Abdurrahman Wahid (ប្រធានាធិបតីឥណ្ឌូនេស៊ីពីឆ្នាំ១៩៩៩ ដល់ ២០០២) បានដកបទបញ្ជាប្រធានាធិបតីលេខ ១៤ ចេញ និងដាក់ឲ្យប្រើនូវក្រិតប្រធានាធិបតីលេខ ១៩ (២០០១) ដើម្បីទទួលស្គាល់ 'Imlek' (ចូលឆ្នាំចិន) ថាជាថ្ងៃឈប់សម្រាកដែលមានការអនុញ្ញាត (សម្រាប់អ្នកដែលមានបំណងក្នុងការប្រារព្ធពិធីនេះ)។ ក្នុងឆ្នាំ២០០២ ប្រធានាធិបតី Megawati Soekarnoputri បានប្រកាសបន្ថែមទៀតថា 'Imlek' ត្រូវបានទទួលស្គាល់ថាជាថ្ងៃឈប់សម្រាកជាតិ។ ចូលជាធរមាន ក្រិតរបស់ប្រធានាធិបតីលេខ ១៩ (២០០១) បានលុបពាក្យប្រជាជន និងវប្បធម៌ 'ជនជាតិដើម' និង 'មិនមែនជនជាតិដើម' ឥណ្ឌូនេស៊ីចេញ។ ប្រកាសថា 'Imlek' ជាថ្ងៃបុណ្យជាតិឥណ្ឌូនេស៊ីដែលបានទទួលស្គាល់ លទ្ធិខុងជឺ ថាជាសាសនា ដែលបានអនុញ្ញាតឲ្យមានការសាងសង់វិហារ និងអនុញ្ញាតឲ្យមានការលោតមុងសាយនៅទីសាធារណៈ ជាថ្មីម្តងទៀតជាលើកដំបូងក្នុងសតវត្ស។

បញ្ហាទីពីរ សួរថាតើសិទ្ធិវប្បធម៌ជាសិទ្ធិរួម ឬបុគ្គល។ សិទ្ធិរួមជាសិទ្ធិរបស់ក្រុមមួយ ឬសហគមន៍មួយ (ដូចដែលផ្ទុយនឹងសិទ្ធិរបស់បុគ្គលម្នាក់) ។ ចំពោះអ្នកខ្លះ នេះស្មើនឹងការញែកដោយស្វ័យប្រវត្តិនៃសិទ្ធិវប្បធម៌ពីសិទ្ធិមនុស្ស ដោយសារវាវិវត្តន៍ជុំវិញការការពារចង្កោមតម្លៃសង្គម ឬស្ថាប័នសង្គម ជាជាងមនុស្សម្នាក់ៗ។ យ៉ាងណាមិញ ការពិនិត្យឲ្យបានដិតដល់ពីវិធីសាស្ត្រដែលសិទ្ធិទាំងនេះ ត្រូវបានសរសេរដូចម្តេចនៅក្នុងសន្ធិសញ្ញាបង្ហាញថាសិទ្ធិទាំងនេះ ត្រូវបានបញ្ជាក់ថាជាសិទ្ធិបុគ្គលជាចម្បង ដែលនេះជាសិទ្ធិរបស់បុគ្គលក្នុងការចូលរួមក្នុងវប្បធម៌មួយ ហើយមិនមែនជាសិទ្ធិរបស់វប្បធម៌ណាមួយនោះទេ។

"ឯកសារទាំងបីនេះ UDHR ICCPR និង ICESCR ចែងថាសិទ្ធិវប្បធម៌ជាសិទ្ធិរបស់បុគ្គល ឬមនុស្សគ្រប់រូប ដើម្បីអនុវត្តវប្បធម៌ ឬដើម្បី "មិនត្រូវបានបដិសេធសិទ្ធិ...ក្នុងការរីករាយនឹងវប្បធម៌របស់ខ្លួន"។

ក្នុងការលើកកម្ពស់ និងការការពារសិទ្ធិវប្បធម៌ អ្នកការពារសិទ្ធិមនុស្សមិនពឹងផ្អែកលើ ESCR តែមួយនោះទេ ប៉ុន្តែជារឿយៗប្រើប្រាស់ការមិនរើសអើង និងសិទ្ធិជនជាតិភាគតិចក្នុង ICESCR សេរីភាពក្នុងការបញ្ចេញមតិនៃការអនុវត្តវប្បធម៌ និងសេរីភាពសាសនា បង្ហាញថាសិទ្ធិវប្បធម៌គឺពឹងផ្អែកគ្នាទៅវិញទៅមក និងពាក់ព័ន្ធគ្នាទៅវិញទៅមករវាងសន្ធិសញ្ញាទាំងពីរ។

## ក. សេចក្តីសង្ខេបពីជំពូក និងចំនុចគន្លឹះ

### សេចក្តីផ្តើម

ដំណើរការនៃការផ្លាស់ប្តូរសិទ្ធិនៅក្នុង UDHR ទៅជាសន្ធិសញ្ញាអន្តរជាតិមួយ ជាលទ្ធផលចេញជាកតិកាសញ្ញាចំនួនពីរ៖ ICCPR (ដែលគ្រប់ដណ្តប់មាត្រា១-២១ របស់ UDHR) និង ICESCR (គ្រប់ដណ្តប់មាត្រា ១-២ និង ២២-២៧ នៃ UDHR)។ ហេតុផលសម្រាប់ការបែងចែក UDHR ជាសន្ធិសញ្ញាដាច់ចេញពីគ្នា ជាលទ្ធផលនៃការបែងចែកតាមផ្លូវច្បាប់ (រវាង CPR ដែលអាចធ្វើបដិប្បញ្ញត្តិបាន និងការសម្រេចបានជាបណ្តើរៗនៃESCR) ហើយមតិមួយចំនួនអះអាងថា ដោយសារភាពខុសគ្នាផ្នែកនយោបាយ (រដ្ឋលោកខាងលិចដែលផ្តោតលើCPR ហើយរដ្ឋកុម្មុយនិស្តផ្តោតលើESCR)។ នៅពេលសន្ធិសញ្ញាទាំងពីរចូលជាធរមានក្នុងឆ្នាំ១៩៧៦ ភាគច្រើននៃ UDHR បានក្លាយទៅជា

ចងកាតព្វកិច្ចផ្លូវច្បាប់ ដែលអនុវត្តចំពោះប្រជាជនគ្រប់រូបក្នុងយុត្តាធិការរបស់រដ្ឋ មិនពាក់ព័ន្ធនឹងភាពជាពលរដ្ឋរបស់គេនោះទេ។

## កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

ICCPR ការពារសិទ្ធិជាមូលដ្ឋាន ជាឧទាហរណ៍សិទ្ធិស្វ័យសម្រេច សិទ្ធិក្នុងការរួចផុតពីការរើសអើង និងសិទ្ធិក្នុងការរស់រានមានជីវិត។ លក្ខណៈពិសេសនៃសិទ្ធិរស់រានមានជីវិតជាដែនកំណត់លើការប្រើប្រាស់ទោសប្រហារជីវិត។ សិទ្ធិសំខាន់ៗដទៃទៀតរួមមានសិទ្ធិដែលមានក្នុងប្រព័ន្ធច្បាប់ ដូចជាសិទ្ធិពាក់ព័ន្ធនឹងការចាប់ខ្លួន និងការឃុំខ្លួន និងនៅក្នុងតុលាការ។ CPR ក៏រួមមានផងដែរនូវសិទ្ធិមនុស្សក្នុងឆាកនយោបាយ និងជីវិតក្នុងសង្គមស៊ីវិល ដូចជាសេរីភាពសាសនា សេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិក្នុងការបោះឆ្នោត។

ICCPR អនុញ្ញាតឲ្យមានដែនកំណត់លើសិទ្ធិទាំងនេះ តាមមធ្យោបាយបីយ៉ាង៖ ជាដំបូង រាល់សិទ្ធិទាំងអស់ត្រូវបានកម្រិតដែលតាមរយៈនេះសិទ្ធិទាំងនេះមិនអាចត្រូវបានប្រើប្រាស់ដើម្បីរំលោភបំពានសិទ្ធិអ្នកដទៃ ទីពីរសិទ្ធិជាក់លាក់អាចត្រូវបានកម្រិតដោយច្បាប់ប្រសិននេះជាការចាំបាច់ក្នុងការរក្សាសណ្តាប់ធ្នាប់សាធារណៈ សុខភាពសាធារណៈ សន្តិសុខជាតិ ឬសម្រាប់ហេតុផលសីលធម៌។ ទីបី រដ្ឋអាចត្រូវបានអនុញ្ញាតក្នុងការធ្វើបដិប្បញ្ញត្តិលើសិទ្ធិមួយ ក្នុងរយៈពេលកំណត់មួយក្នុងកាលៈទេសៈជាក់លាក់មួយចំនួននៃភាពអាសន្នសាធារណៈ ។ មានសិទ្ធិមួយចំនួនដែលមិនអាចធ្វើបដិប្បញ្ញត្តិបាន ហើយសិទ្ធិទាំងអស់នេះត្រូវបានអង្កេតគ្រប់ពេលវេលាទាំងអស់មិនពាក់ព័ន្ធនឹងស្ថានភាពណាមួយនោះទេ។

## កតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌

ដូចគ្នានឹង ICCPR ដែរ ICECSR ការពារសិទ្ធិជាមូលដ្ឋានដូចជាសិទ្ធិស្វ័យសម្រេច និងសមភាពរវាងបុរស និងស្ត្រី។ លើសពីនេះទៀត ICESCR រួមបញ្ចូលសិទ្ធិពាក់ព័ន្ធនឹងការងារ ការអប់រំ ការការពារគ្រួសារ សុខភាព ការអប់រំ និងលំនៅដ្ឋាន។ សិទ្ធិនៅក្នុង ICESR ពេលខ្លះត្រូវបានកំណត់ និងស្រាវជ្រាវដោយស្ថាប័នរបស់UN ដែលពាក់ព័ន្ធ ដូចជា WHO សម្រាប់សុខភាព និង ILO សម្រាប់ការងារ។

ECSR ខុសគ្នាពី CPR ដោយសារសិទ្ធិមួយចំនួនត្រូវបាន*សម្រេចបានជាបណ្តើរៗ* ឬដែលរដ្ឋមិនមានកាតព្វកិច្ចភ្លាមៗ ប៉ុន្តែជាកាតព្វកិច្ចក្នុងការធ្វើកិច្ចការឆ្ពោះទៅកាន់ការ

សម្រេចបានសិទ្ធិនេះ។ រដ្ឋត្រូវមានគោលនយោបាយ និងផែនការដែលត្រូវអនុវត្ត និងប្រើប្រាស់*ធនធានអតិបរមា* លើការអនុវត្តគោលនយោបាយ និងផែនការទាំងនេះ។ អ្នកខ្លះអះអាងថា ESCR មិនមែនជាសិទ្ធិពិតប្រាកដដូច CPR នោះទេ ដោយសារវាជា*គោលបំណង ឬមហិច្ឆតា* ជាជាងសិទ្ធិ។ ដោយសារតែមានការពិបាកក្នុងការកំណត់កាតព្វកិច្ចរដ្ឋឆ្ពោះទៅកាន់ការសម្រេចបានជាបណ្តើរៗ ជាពិបាកក្នុងការកំណត់ពីការរំលោភបំពានលើ ESCR ណាស់។ ចំពោះសិទ្ធិខ្លះដូចជាការងារ សុខភាព និងចំណីអាហារ *បុគ្គលត្រូវទទួលខុសត្រូវជាចម្បង* ដើម្បីឆ្លើយតបនឹង ESCR ប៉ុន្តែនៅក្នុងករណីខ្លះដែលរដ្ឋមានកាតព្វកិច្ចក្នុងការបំពេញសិទ្ធិទាំងនេះ ប្រសិនបុគ្គលនោះមិនអាចបំពេញសិទ្ធិរបស់ពួកគេដោយខ្លួនឯងបាន។ សម្រាប់ហេតុផលនេះជាការអះអាងថា ESCR មិនអាចត្រូវបាន*កាត់សេចក្តីដោយតុលាការបាននោះទេ* ឬពួកគេពិបាកក្នុងការដាក់ចូលក្នុងប្រព័ន្ធយុត្តិធម៌។ ប្រភេទសំខាន់មួយនៃ ESCR គឺ *សិទ្ធិស្តង់ដារជីវភាព* ឬសិទ្ធិក្នុងការទទួលបានចំណីអាហារ ទឹក លំនៅដ្ឋាន ការអប់រំ និងសុខភាព។ រដ្ឋត្រូវតែធានាថាសិទ្ធិទាំងនេះ *មាន ទទួលបាន មានស្តង់ដារដែលអាចទទួលយកបាន និងសមរម្យ* ចំពោះតម្រូវការរបស់ប្រជាជន។

## វប្បធម៌ និងសិទ្ធិមនុស្ស

សិទ្ធិវប្បធម៌ត្រូវបានជជែកវែកញែកជាច្រើនដងច្រើនសារ ក្នុងវិស័យនៃការការពារសិទ្ធិមនុស្ស។ និយមន័យនៃវប្បធម៌គឺមិនច្បាស់ ហើយវប្បធម៌ជារឿយៗត្រូវបានធ្វើឲ្យក្លាយជារឿងនយោបាយដោយរដ្ឋ។ សិទ្ធិវប្បធម៌មានបញ្ជាក់ក្នុងផ្នែកជាច្រើននៃ ICESCR និង ICCPR ជាឧទាហរណ៍ ក្នុងសិទ្ធិសាសនា សិទ្ធិជនជាតិភាគតិច និងសេរីភាពរួចផុតពីការរើសអើង។

## ខ. សំណួរប្រលងនិងសំណួរងាយស្រួល

- តើនៅពេលណាដែលប្រទេសរបស់អ្នកបានផ្តល់សច្ចាប័នលើICCPR និង ICESCR? តើអ្នកអាចស្វែងរកហេតុផលបានដែរឬទេ ថាហេតុអ្វីរដ្ឋរបស់អ្នកជ្រើសរើសក្នុងការផ្តល់សច្ចាប័នលើកតិកាសញ្ញានេះ?
  ឬ

- ហេតុអ្វីបានជាប្រទេសអ្នកមិនបានផ្តល់សច្ចាប័នលើ ICCPR និង/ឬ ICESCR? តើការអះអាងអ្វីដែលបានផ្តល់ជូនដោយរដ្ឋាភិបាល និងអ្នកគិតថាហេតុផលទាំងនេះមានសុពលភាពកម្រិតណា?

- ស្វែងរកខលក្ខខណ្ឌ ឬការយល់ដឹងពីសន្និសញ្ញាដែលរដ្ឋាភិបាលរបស់អ្នកប្រហែលជាបានដាក់លើ ICCPR ឬ ICESCR។ តើខលក្ខខណ្ឌទាំងនេះចាំបាច់ដែរឬទេ? តើធ្លាប់មានខលក្ខខណ្ឌ ដែលត្រូវបានលុបចោលដោយប្រទេសអ្នកដែរឬទេ?

- តើអ្វីជាស្ថានភាព ឬបញ្ហាដែលជាកង្វល់ខ្លាំងបំផុតដល់សិទ្ធិពលរដ្ឋ នយោបាយ និង/ឬសេដ្ឋកិច្ច និងសង្គមរបស់ប្រជាជនក្នុងប្រទេសអ្នក?

- ធ្វើការពិចារណាលើករណីទោសប្រហារជីវិត តើមានការជជែកវែកញែកជាសាធារណៈពីបញ្ហានេះនៅក្នុងប្រទេសរបស់អ្នកដែរឬទេ? តើអ្វីជាហេតុផលដែលប្រទេសរបស់អ្នកបានជ្រើសរើសក្នុងការប្រើប្រាស់ ឬលុបចោលទោសប្រហារជីវិត ហើយតើអ្នកគិតថាហេតុផលនេះត្រឹមត្រូវដែរឬទេ?

- តើធ្លាប់មានស្ថានភាពអាសន្នសាធារណៈនៅក្នុងប្រទេសអ្នកដែរឬទេ? ពិនិត្យមើលអំឡុងពេលដែលស្ថានភាពនេះត្រូវបានប្រើប្រាស់ និងបញ្ជាក់តើសិទ្ធិអ្វីខ្លះត្រូវបានធ្វើបដិប្បញ្ញត្តិ ហើយតើថាបដិប្បញ្ញត្តិទាំងនេះចាំបាច់ដែរឬទេ ក្នុងការស្តារសណ្តាប់ធ្នាប់?

- បញ្ជាក់ឧទាហរណ៍ក្នុងប្រទេសរបស់អ្នក ដែលរដ្ឋាភិបាលធ្វើកិច្ចការយ៉ាងសស្រាក់សស្រាំឆ្ពោះទៅកាន់ការសម្រេចបានជាបណ្តើរៗនៃ ESCR។ តើគោលនយោបាយ ផែនការ និងលទ្ធផលអ្វីដែលរដ្ឋាភិបាលបានទទួល ?

- តើមានឧទាហរណ៍នៃសិទ្ធិវប្បធម៌ក្នុងប្រទេសរបស់អ្នក ដែលមិនត្រូវបានគោរពដែរឬទេ? តើអ្វីជាលទ្ធផលនៃការរំលោភបំពាននេះ?

# គ. ឯកសារពិគ្រោះបន្ថែម

## ICCPR និង ICESCR

ខ្លឹមសារដែលបានផ្ដល់ជូននៅចុងជំពូកទីមួយជាចំនុចចាប់ផ្ដើមដ៏ល្អ។ អ្នកគួរតែអាចស្វែងរកសៀវភៅទាំងនេះមួយចំនួននៅក្នុងបណ្ណាល័យសាកលវិទ្យាល័យ។

## កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

សៀវភៅពុម្ពល្អៗស្ដីពី ICCPR រួមមាន៖

- Sarah Joseph, Jenny Schultz, Melissa Castan. *កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ* ៖ករណីសិក្សា វិចារណកថា & និងឯកសារ (Oxford: Oxford University Press).
- Manfred Novak. *កតិកាសញ្ញា UN ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖* វិចារណកថា CCPR NP Engel, 2005.

ទោសប្រហារជីវិត ជាប្រធានបទនៃការស្រាវជ្រាវសម្រាប់អង្គការលើកលែងទោសអន្តរជាតិ (Amnesty International )ដែលបានដាក់ចេញនូវរបាយការណ៍ប្រចាំឆ្នាំមួយ ដែលអាចរកឃើញនៅលើគេហទំព័ររបស់ អង្គការលើកលែងទោសអន្តរជាតិ Amnesty International ។ មានអង្គការដទៃទៀតដែលធ្វើការប្រឆាំងនឹងទោសប្រហារជីវិតដូចជា៖

- សម្ព័ន្ធពិភពលោកប្រឆាំងនឹងទោសប្រហារជីវិត
- បណ្ដាញប្រឆាំងទោសប្រហារជីវិតនៅអាស៊ី
- គណៈកម្មាធិការអន្តរជាតិប្រឆាំងទោសប្រហារជីវិត។

ព័ត៌មានស្ដីពីរដ្ឋស្ថិតក្នុងភាពអាសន្នមាននៅក្នុងវិចារណកថាលេខ ២៩ (២០០១) ដោយគណៈកម្មាធិការសិទ្ធិមនុស្ស ដែលមាននៅលើគេហទំព័ររបស់ OHCHR។

## កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌

NGOESCR-Net ផ្ដល់មានទំព័រមានសារៈប្រយោជន៍ដែលមានតំណភ្ជាប់ទៅនឹងបញ្ហាសំខាន់ៗស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។

ប្រភពមានសារៈសំខាន់ភាគច្រើនគឺស្តីពីអំពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ដោយសារវាមាននៅលើអ៊ិនធឺណែត និងអាចស្វែងរកបានដោយងាយស្រួលតាមការស្រាវជ្រាវលើបណ្តាញអ៊ិនធឺណែត)៖

- វេដ្ឋនៃសិទ្ធិ៖ សកម្មភាពសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌៖ ប្រភពធនធានបណ្តុះបណ្តាល។

សៀវភៅពុម្ពដទៃទៀតរួមមាន៖

- Asbjørn Eide, Catarina Krause, and Allan Rosas, eds. *សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌៖ សៀវភៅពុម្ព។* Dordrect: Martinus Nijhoff, ២០០១។
- Manisuli Ssenyonjo. សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ក្នុងច្បាប់. Hart បោះពុម្ពឆ្នាំ ២០០៩។.
- Olivier de Schutter. *សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ជាសិទ្ធិមនុស្ស។* Edward Elgar, ២០១៣

សម្រាប់ព័ត៌មានបន្ថែមស្តីពីយុត្តិកម្មនៃ ESCR មានឯកសារណែនាំប្រភពឯកសារនៅ ESCR- Net។ បោះពុម្ពផ្សាយដោយ៖

- គណៈកម្មាធិការអ្នកច្បាប់អន្តរជាតិ។ ភាពអាចកាត់សេចក្តីបានដោយតុលាការលើសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ៖បទពិសោធន៍ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ (២០០៨)
- OHCHR. សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។ សៀវភៅណែនាំស្ថាប័នសិទ្ធិមនុស្សជាតិ។ United Nations: New York and Geneva, ២០០៥។

ចំពោះការសិក្សាលើសិទ្ធិស្តង់ដារជីវភាពជាក់លាក់ អង្គការខាងក្រោមមានប្រភពឯកសារនៅលើគេហទំព័ររបស់ខ្លួន៖

ចំណីអាហារ

- អង្គការស្បៀងអាហារ និងកសិកម្មពិភពលោក(FAO) មានធនធានឯកសារជាច្រើន។
- អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិក្នុងការទទួលបានចំណីអាហារ លោក Olivier de Schutter ....មានគេហទំព័រមួយដែលមានឯកសារពាក់ព័ន្ធនឹងអង្គការសហប្រជាជាតិ។

ទឹក

- Peter Gleick មានអត្ថបទជាច្រើនស្តីពីសិទ្ធិក្នុងការទទួលបានទឹក

- អ្នករាយការណ៍ពិសេសពីសិទ្ធិមនុស្សក្នុងការទទួលបានទឹកបរិភោគដែលមានសុវត្ថិភាព និងអនាម័យ មានគេហទំព័រមួយដែលមានឯកសារពាក់ព័ន្ធនឹងអង្គការសហប្រជាជាតិ
- អង្គការសុខភាពពិភពលោក(WHO) មានប្រភពធនធានឯកសារស្តីទឹក អនាម័យ និងសុខភាព។

លំនៅដ្ឋាន

- ”អ្នករាយការណ៍ពិសេសពីលំនៅដ្ឋានគ្រប់គ្រាន់មានគេហទំព័រមួយដែលមានចំណងជើងថា”លំនៅដ្ឋានជាសិទ្ធិមនុស្ស”
- UN-Habitatមានធនធានឯកសារលើគេហទំព័ររបស់ខ្លួន។
- The NGO COHRE (មជ្ឈមណ្ឌលដើម្បីសិទ្ធិលំនៅដ្ឋាន និងការបណ្តេញចេញ) ធ្លាប់ជា NGO អន្តរជាតិសំខាន់មួយធ្វើការក្នុងវិស័យនេះ ប៉ុន្តែអង្គការនេះបានបិទអស់រយៈពេលប៉ុន្មានឆ្នាំហើយ។ គេហទំព័ររបស់អង្គការនេះនៅតែអាចចូលមើលបាន ហើយមានធនធានឯកសារច្បាប់ និងតស៊ូមតិជាច្រើន។

4

# ការការពារសិទ្ធិមនុស្សនៅអាស៊ីអាគ្នេយ៍

ជំពូកមុនពិនិត្យមើលលើ សន្ធិសញ្ញាសិទ្ធិមនុស្សសំខាន់ៗ និងខ្លឹមសារនៃសន្ធិសញ្ញាទាំងនេះ ជំពូកមុន ក៏បានពិនិត្យពីវិធីសាស្ត្រក្នុងការយល់ដឹង ពីស្តង់ដារទាំងនេះនៅអាស៊ីអាគ្នេយ៍ផងដែរ។ ជំពូកនេះវាយតម្លៃពីវិធីសាស្ត្រ ដែលសិទ្ធិទាំងនេះត្រូវបានការពារ និងចាប់បង្ខំអនុវត្តនៅក្នុងប្រទេសនៅអាស៊ីអាគ្នេយ៍។

ដើម្បីការពារសិទ្ធិមនុស្ស គឺត្រូវធានាថាមនុស្សគ្រប់រូប ដែលមានសិទ្ធិ ក្នុងការទទួលបានសិទ្ធិ ជាការពិតជាក់ស្តែងអាចទទួលសិទ្ធិទាំងនេះប្រាកដមែន។ ជាឧទាហរណ៍ កុមារដែលមានសិទ្ធិក្នុងការចូលរៀន អាចត្រូវបានទៅសាលារៀនពិតប្រាកដមែន ឬក៏អ្នកកាសែតអាចសេរសេរព័ត៌មានរបស់ខ្លួនបានដោយសេរី។ ការការពារសិទ្ធិមនុស្សត្រូវបានធ្វើឡើងដោយស្ថានប័នផ្សេងៗគ្នា ក្នុងវិធីសាស្ត្រផ្សេងៗគ្នា។ នៅថ្នាក់ជាតិ ប៉ូលីស ចៅក្រម តុលាការ និងមេធាវីបំពេញការងារដើម្បីចាប់បង្ខំអនុវត្ត សិទ្ធិមនុស្ស ដូចគ្នាទៅនឹងអង្គការសង្គមស៊ីវិល និងមន្ត្រីរដ្ឋាភិបាលផងដែរ។ ពួកគេអាចការពារសិទ្ធិមនុស្សតាមរយៈចាប់បង្ខំអនុវត្តច្បាប់ លើកកម្ពស់ការអត់ឱនគ្នា អប់រំ ប្រជាជនផ្តល់សេវាកម្ម ។ល។ ក្នុងវិធីសាស្ត្រស្រដៀងគ្នានេះ ស្ថាប័ននៅថ្នាក់តំបន់ ក៏បំពេញការងារដើម្បីការពារសិទ្ធិមនុស្សផងដែរ។ ការការពារមានន័យថាលើសពីអ្វីដែលរដ្ឋាភិបាលគ្រាន់តែធានាថាមិនរំលោភបំពានសិទ្ធិមនុស្ស ហើយក៏អាចមានន័យផងដែរក្នុងការធានាថាក្រុមហ៊ុន ឬ សាលារៀនអនុវត្តតាមច្បាប់ ដូចនេះសិទ្ធិបុគ្គលត្រូវបានការពារពីការរំលោភបំពាន។

វិធីសាស្ត្រដទៃទៀតក្នុងការគិតគូរអំពីការការពារសិទ្ធិមនុស្ស គឺធ្វើការពិចារណាថា ហេតុអ្វីបានជាប្រជាជនភាគច្រើននៅអាស៊ីអាគ្នេយ៍ មិនប្រឈមនឹងការរំលោភបំពានសិទ្ធិមនុស្សក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ? មិនថាទៅសាលារៀន ឬធ្វើការងារនោះទេ សិទ្ធិរបស់ពួកគេមិនត្រូវបានប៉ះពាល់ឡើយ។ អ្នកអានសៀវភៅពុម្ពនេះភាគច្រើនមិនប្រឈមនឹងការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរនោះទេ។ ពួកគេមិនត្រូវបានរំលោភបំពាន ប្រមាថមើលងាយ ឬប្រព្រឹត្តឆ្គងមកលើ បង្ខំឲ្យស្ថិតក្នុងទាសភាព ឬត្រូវបានធ្វើទារុណកម្ម។ ហេតុអ្វី? ដោយសារការការពារសិទ្ធិមនុស្សពិតជាមានដំណើរការប្រកបដោយប្រសិទ្ធិភាព។ ចំពោះប្រជាជនទាំងនេះ ប្រព័ន្ធការពាររបស់ប៉ូលីសរដ្ឋ (ដែលជាអ្នកថែរក្សាច្បាប់ និងសណ្តាប់ធ្នាប់) មានដំណើរការ ប្រជាជនក្នុងសង្គមនោះមានតម្លៃដែលសិទ្ធិមនុស្ស និងបុគ្គលមិនរំលោភបំពានគ្នាទៅវិញទៅមក។ បន្ថែមពីលើនេះទៀត ប្រជាជនដឹងពីសិទ្ធិរបស់ពួកគេ ហើយមិនអនុញ្ញាតឲ្យមានការរំលោភបំពានកើតឡើង។ ក្នុងគោលបំណងធានាឲ្យមានស្ថានភាពដូចនេះ ទាំងរដ្ឋាភិបាល និងប្រជាជនរបស់ខ្លួនត្រូវមានកិច្ចការជាច្រើនត្រូវបំពេញ។ ពួកគេត្រូវតែះ មានច្បាប់ដែលធ្វើឲ្យការរំលោភបំពានខុសច្បាប់ អប់រំប្រជាជន ដូចនេះពួកគេដឹងពីសិទ្ធិរបស់ខ្លួន បណ្តុះបណ្តាលមន្ត្រីរដ្ឋាភិបាល (ដូចជាមន្ត្រីប៉ូលីស) ដូចនេះពួកគេមិនរំលោភបំពានសិទ្ធិមនុស្ស ហើយនិងអនុវត្តប្រព័ន្ធក្នុងការតាមដាន និងកំណត់ពីការរំលោភបំពាន និងដោះស្រាយបញ្ហា។

ជំពូកនេះពិភាក្សាពីការការពារនៅកម្រិតថ្នាក់ជាតិ ដែលសិទ្ធិមនុស្សគួរតែត្រូវបានការពារដោយប៉ូលីស ប្រព័ន្ធតុលាការ ស្ថាប័នរដ្ឋាភិបាល និងដោយប្រជាជនរស់នៅ

ក្នុងសង្គមនោះ។ ចុងក្រោយ ជំពូកនេះនឹងពិនិត្យលើ NGOs ដែលធ្វើការលើបញ្ហាសិទ្ធិមនុស្ស ដែលយ៉ាងហោចណាស់សម្រាប់អាស៊ីអាគ្នេយ៍នេះ ជាយន្តការរីកដុះដាល និងមានភាពជោគជ័យមួយក្នុងការការពារសិទ្ធិមនុស្ស។

# ៤.១ ស្ថានភាពនៃការការពារសិទ្ធិមនុស្សនៅអាស៊ីអាគ្នេយ៍

ដើម្បីកំណត់ថាការការពារមានប្រសិទ្ធិភាពកម្រិតណា ជាការចាំបាច់ក្នុងការពិភាក្សាពីស្ថានភាពបច្ចុប្បន្ននៃការការពារសិទ្ធិមនុស្សក្នុងតំបន់។ យ៉ាងណាមិញ សំណួរនេះបង្កឲ្យការពិបាក។ តើអាចទៅរួចដែរឬទេក្នុងការកំណត់ថាប្រទេសមួយមានកំណត់ត្រាសិទ្ធិមនុស្សល្អ ឬអាក្រក់នោះ? នេះជាការប្រឈមពីព្រោះមិនមានវិធីសាស្ត្រ សាមញ្ញក្នុងការវាស់វែងសិទ្ធិមនុស្សនោះទេ។ ទ្រព្យសម្បត្តិ និងការអភិវឌ្ឍរបស់រដ្ឋមួយត្រូវបានវាស់វែងដោយងាយស្រួល ជាឧទាហរណ៍ ធនាគារពិភពលោក ឬ NDPP ចេញចំណាត់ថ្នាក់នៃប្រទេសតាមរយៈទ្រព្យសម្បត្តិ ឬការអភិវឌ្ឍជារៀងរាល់ឆ្នាំ។ ប៉ុន្តែព្យាយាមក្នុងការកំណត់ពីស្ថានភាពនៃសិទ្ធិមនុស្សជាការស្មុគ្រស្មាញ។ ខណៈពេលដែលសិទ្ធិខ្លះដូចជាបទឧក្រិដ្ឋ និងភាពអត់ឃ្លានអាចត្រូវបានវាស់វែង សិទ្ធិដទៃដូចជាសេរីភាពក្នុងការបញ្ចេញមតិ ឬការចូលរួមក្នុងឆាកនយោបាយមានការពិបាកក្នុងការកំណត់ណាស់។ មានបញ្ហាថាតើសិទ្ធិណាមួយត្រូវធ្វើការវាស់វែង (ដោយសារមានសិទ្ធិចំនួនរាប់រយឯណោះ)។ តើសិទ្ធិទាំងនេះអាចត្រូវបានវាស់វែងយ៉ាងដូចម្តេច ហើយអ្នកណាជាអ្នកធ្វើការវាស់វែង?

ជាការសាមញ្ញក្នុងការពិនិត្យលើប្រទេសនីមួយៗដាច់ដោយឡែកពីគ្នា ដែលត្រូវបានវាស់វែងដោយអង្គការលើកលែងទោសអន្តរជាតិ អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តជាតិ និងក្រសួងការបរទេសអាមេរិក។ របាយការណ៍ទាំងអស់នេះមាននៅលើបណ្តាញអ៊ិនធឺណែត។ ការសិក្សាទាំងនេះជារបាយការណ៍ប្រចាំឆ្នាំរបស់ប្រទេស ហើយរបាយការណ៍ទាំងនេះពិនិត្យប្រទេសនីមួយៗដាច់ដោយឡែកពីគ្នា ហើយមិនការប្រៀបធៀបរវាងប្រទេសនោះទេ។ យ៉ាងណាមិញ អង្គការមួយចំនួនពិតជាព្យាយាមក្នុងឲ្យចំណាត់ថ្នាក់លើស្តង់ដារសិទ្ធិមនុស្សទាំងនេះ។ ជាឧទាហរណ៍ ផ្ទះសេរីភាព (Freedom House) ដែលជាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមួយ មានទីតាំងនៅសហរដ្ឋអាមេរិកបានផ្តល់នូវចំណាត់ថ្នាក់ប្រចាំឆ្នាំលើកម្រិតប្រជាធិតេយ្យ និងសេរីភាពនយោបាយក្នុងប្រទេសមួយ ហើយប្រទេសទាំងអស់ត្រូវបានផ្តល់ចំណាត់ថ្នាក់ពី ១ (ប្រទេសដែលសេរីបំផុត) ដល់៧ (ប្រទេសដែលមិនសេរី) ពាក់ព័ន្ធនឹងសេរីភាពរបស់ពលរដ្ឋ និងនយោបាយរបស់ប្រទេសទាំងនេះ។ មាត្រា ១៩ ជាអង្គការមិនមែនរដ្ឋាភិបាលមួយ

ដែលធ្វើការត្រួតពិនិយ្យសេរីភាពនៃការបញ្ចេញមតិ ក៏បានផ្តល់ចំណាត់ថ្នាក់ទូទាំងពិភពលោកដល់សេរីភាពប្រព័ន្ធផ្សព្វផ្សាយផងដែរ។ តាមរយៈការពិនិត្យលើចំណាត់ថ្នាក់ និងក្រលេកមើលលើមតិយោបល់នៅក្នុងរបាយការណ៍លើប្រទេសនីមួយៗ យើងអាចទទួលបាននូវចម្លើយមួយថាសិទ្ធិមនុស្ស ត្រូវបានប្រៀបធៀបយ៉ាងដូចម្តេចរវាងប្រទេសនៅអាស៊ីអាគ្នេយ៍ ហើយថាតើរដ្ឋអាស៊ានមានការឆ្លើយតបកម្រិតណាទៅនឹងបញ្ហាសិទ្ធិមនុស្ស។ តារាងខាងក្រោមបង្ហាញពីចំណាត់ថ្នាក់របស់រដ្ឋនៅអាស៊ាន។

តារាង ៤-១ - ស្ថានភាពនៃការការពារសិទ្ធិមនុស្ស

| ប្រទេស | សេរីភាព ចំណាត់ថ្នាក់* | ការអភិវឌ្ឍមនុស្ស សន្ទស្សន៍** | សេរីភាពសារព័ត៌មាន ចំណាត់ថ្នាក់*** | សិទ្ធិមនុស្ស ការផ្តល់សច្ចាប័ន# |
|---|---|---|---|---|
| ប្រ៊ុយណេ | អត់មានសេរីភាព | ខ្ពស់ខ្លាំង | លំបាក | ៣/២២ |
| កម្ពុជា | អត់មានសេរីភាព | មធ្យម | លំបាក | ១១/២២ |
| ទីម័រខាងកើត | សេរីភាពខ្លះ | មធ្យម | ជាទីពេញចិត្ត | ១១/២២ |
| ឥណ្ឌូនេស៊ី | សេរីភាពខ្លះ | មធ្យម | លំបាក | ១១/២២ |
| ឡាវ | អត់មានសេរីភាព | មធ្យម | ធ្ងន់ធ្ងរខ្លាំងណាស់ | ៩/២២ |
| ម៉ាឡេស៊ី | សេរីភាពខ្លះ | ខ្ពស់ | លំបាក | ៥/២២ |
| មីយ៉ាន់ម៉ា | អត់មានសេរីភាព | ទាប | លំបាក | ៤/២២ |
| ហ្វីលីពីន | សេរីភាពខ្លះ | មធ្យម | លំបាក | ១៤/២២ |
| សិង្ហបុរី | សេរីភាពខ្លះ | ខ្ពស់ខ្លាំង | លំបាក | ៣/២២ |
| ថៃ | សេរីភាពខ្លះ | ខ្ពស់ | លំបាក | ១១/២២ |
| វៀតណាម | អត់មានសេរីភាព | មធ្យម | ធ្ងន់ធ្ងរខ្លាំងណាស់ | ៧/២២ |

* ចំណាត់ថ្នាក់សេរីភាពក្នុងពិភពលោក ឆ្នាំ២០១៤ របស់ Freedom House ។ មានការផ្តល់ចំណាត់ថ្នាក់ចំនួនបី៖ សេរីភាព សេរីភាពខ្លះ ឬអត់មានសេរីភាព។

** តាមរយៈសន្ទស្សន៍ការអភិវឌ្ឍមនុស្ស ឆ្នាំ២០១៤ របស់ UNDP រដ្ឋអាចមានការអភិវឌ្ឍមនុស្សខ្ពស់ខ្លាំង ខ្ពស់ មធ្យម ឬទាប.

** តាមរយៈសន្ទស្សន៍សេរីភាពសារព័ត៌មានរបស់អ្នកកាសែតគ្មានព្រំដែន។ ស្ថានភាពអាច ល្អ ពេញចិត្ត មានបញ្ហា គួរឲ្យកត់សម្គាល់ លំបាក ឬធ្ងន់ធ្ងរខ្លាំងណាស់។

# ចំនួននៃសន្ធិសញ្ញាសិទ្ធិមនុស្សទាំង ៩ ពិធីសារបន្ថែម ៩ និងនីតិវិធីបណ្តឹង ៤ ដែលរដ្ឋបានផ្តល់សច្ចាប័ន ឬព្រមព្រៀង។ តារាងលម្អិតមាននៅឧបសម្ព័ន្ធ។

តាមរយៈតារាងខាងលើ ស្ថានភាពនៃការការពារសិទ្ធិមនុស្ស គឺមានភាពចម្រុះ។ ជាឧទាហរណ៍ ប្រទេសមានបំផុតរបស់អាស៊ាន មានកំណត់ត្រានៃការផ្តល់សច្ចាប័នលើសន្ធិសញ្ញាអន់ជាងគេ ប្រទេសដែលមានការផ្តល់សច្ចាប័នច្រើនក៏មានកង្វល់ច្រើនផងដែរ ប្រទេសដែលមានសេរីភាពពលរដ្ឋទាប មានការអភិវឌ្ឍល្អ អំពើពុករលួយទាបមិនមែនមានន័យថាកំណត់ត្រាសិទ្ធិមនុស្សល្អនោះទេ។ ប្រទេសភាគច្រើននៅអាស៊ានមានវិស័យមួយចំនួនដែលមានការគោរពសិទ្ធិមនុស្សល្អប្រសើរ ហើយវិស័យផ្សេង

ទៀតមិនល្អប្រសើរនោះទេ។ បញ្ហាមួយចំនួនជារឿងទូទៅដល់ប្រទេសនៅអាស៊ីអាគ្នេយ៍ទាំងអស់ ដូចជាសិទ្ធិពលករទេសន្តប្រវេសន៍ និង សិទ្ធិជនជាតិដើមភាគតិច។ បញ្ហាដទៃទៀតដូចជាភាពក្រីក្រ សេរីភាពក្នុងការបញ្ចេញមតិ ការអប់រំ និងសុខភាពមានភាពខុសគ្នាខ្លាំងមែនទែនទូទាំងតំបន់។ ទិដ្ឋភាពទូទៅមួយនៃតំបន់នេះបានបង្ហាញថាស្ថានភាពសិទ្ធិមនុស្ស គឺជារឿយៗជាក់លាក់សម្រាប់ប្រទេសនីមួយៗ ហើយជាការពិបាក និងមិនមានសារៈសំខាន់ក្នុងការព្យាយាមក្នុងការធ្វើចំណាត់ថ្នាក់ ឬផ្តល់ពិន្ទុលើប្រទេសនីមួយៗតាមរយៈស្តង់ដារសិទ្ធិមនុស្សរបស់ពួកគេ។ ស្ថានភាពសេដ្ឋកិច្ច ពូជសាសន៍ ភូមិសាស្ត្រ ប្រវត្តិនយោបាយរបស់ប្រទេសនីមួយៗ រួមចំនែកលើស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសនោះ។

# ការពិភាក្សា និងការជជែកវែកញែក

## តើសិទ្ធិមនុស្ស ការអភិវឌ្ឍ និងប្រជាធិបតេយ្យមានការពាក់ព័ន្ធគ្នាដែរឬទេ?

ក្រលេកមើលលើតារាង តើមានការពាក់ព័ន្ធគ្នារវាងការអភិវឌ្ឍជឿនលឿន លទ្ធិប្រជាធិបតេយ្យល្អប្រសើរ និងការការពារសិទ្ធិមនុស្សដែរឬទេ? មានការអះអាងចំនួនពីរលើសំណួរនេះ៖

១. សិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍមានការគាំទ្រគ្នាទៅវិញទៅមក

ជាការសន្មតថាប្រទេសអ្នកមានការងាយស្រួល ក្នុងការការពារសិទ្ធិមនុស្សដោយសារពួកគេមានប៉ូលីស និងមេធាវីដែលឆ្លងការបណ្តុះបណ្តាលបានដិតដល់ និងមានថវិកាច្រើនសម្រាប់សេវាកម្មរដ្ឋាភិបាល។ តើការពាក់ព័ន្ធគ្នានេះពិតដែរឬទេតាមរយៈតារាងខាងលើ? តើវាជាការពិតដែរឬទេចំពោះប្រទេសរបស់អ្នក?

២. មិនមានការពាក់ព័ន្ធគ្នានោះទេ ហើយការការពារសិទ្ធិមនុស្សគឺពឹងផ្អែកលើរដ្ឋ។

ប្រទេសមាន និងប្រទេសក្រ ឬប្រជាធិបតេយ្យ និងមិនប្រជាធិបតេយ្យ ប្រទេសទាំងអស់នេះមានលទ្ធភាពដូចគ្នាក្នុងការការពារសិទ្ធិមនុស្ស។ ការវិនិយោគលើការការពារសិទ្ធិមនុស្សជាជម្រើសមួយដែលរដ្ឋបានជ្រើសរើស។ គ្រប់សង្គមស៊ីវិលទាំងអស់ជារឿយៗអាចកំណត់ពីការប្តេជ្ញាចិត្តរបស់ខ្លួនលើសិទ្ធិមនុស្ស។ តើនេះត្រូវបានអង្កេតឃើញក្នុងតារាងដែរឬទេ? តើនេះជាការត្រឹមត្រូវដែរឬទេសម្រាប់ប្រទេសរបស់អ្នក?

*តើអ្វីជាហេតុផលនៃកំណត់ត្រាចម្រុះនៃការការពារសិទ្ធិមនុស្សក្នុងអាស៊ីអាគ្នេយ៍?*

# ៤.២ ការអនុវត្តសិទ្ធិមនុស្សថ្នាក់ជាតិ

ក្នុងគោលបំណងស្វែងយល់ពីតើថាសិទ្ធិមនុស្ស ត្រូវបានការពារយ៉ាងដូចម្ដេចនៅក្នុងរដ្ឋ ជំពូកនេះនឹងជាដំបូងក្រលេកមើលលើថាសិទ្ធិមនុស្សអ្វីដែលមានវត្តមាននៅក្នុងច្បាប់របស់ប្រទេស។ មានវិធីសាស្ត្របីយ៉ាងដែលសិទ្ធិមនុស្សត្រូវបានបញ្ចូលក្នុងច្បាប់ជាតិ៖

- ជាដំបូង សិទ្ធិមនុស្សជាច្រើនត្រូវបានក្លាយជាផ្នែកមួយនៃច្បាប់ជាតិ។ ច្បាប់ដែលការពារប្រជាជនពីអំពើហិង្សា និងចោរកម្ម ឬ ច្បាប់ផ្ដល់ការអប់រំ ជាឧទាហរណ៍ មានវត្តមាននៅក្នុងប្រទេសអាស៊ីអាគ្នេយ៍ភាគច្រើន។ ជំពូកនេះនឹងមិនធ្វើការបញ្ជាក់លម្អិតថាអាចរកច្បាប់ទាំងអស់ ដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្សនៅកន្លែងណានោះទេ ផ្ទុយទៅវិញជំពូកនេះនឹងផ្ដោតសំខាន់លើច្បាប់ដែលមានសារៈសំខាន់បំផុត និងតើថាសិទ្ធិមនុស្សត្រូវបានការពារយ៉ាងដូចម្ដេច។

- ទីពីរ សន្ធិសញ្ញាសិទ្ធិមនុស្សអាចត្រូវបានបញ្ចូលទៅក្នុងច្បាប់។ សន្ធិសញ្ញាមានសារៈសំខាន់ដោយសារសន្ធិសញ្ញាទាំងនេះ រក្សាច្បាប់របស់ប្រទេសមួយឲ្យមានបច្ចុប្បន្នភាពជាមួយនឹងសិទ្ធិមនុស្ស ហើយសន្ធិសញ្ញាទាំងនេះពង្រីកការការពារដល់ប្រជាជន។ ជាឧទាហរណ៍ ច្បាប់ផ្ដល់ដល់ស្ត្រីនូវសិទ្ធិស្មើគ្នានៅកន្លែងការងារ និងក្នុងអាពាហ៍ពិពាហ៍ ឬការការពារកុមារពីអំពើហិង្សាមិនមែនជារឿងទូទៅ ក្នុងអាស៊ីអាគ្នេយ៍នោះទេកាលពី២០ឆ្នាំមុន។ ប៉ុន្តែដោយសារប្រទេសទាំងអស់បានព្រមព្រៀងលើសិទ្ធិស្ត្រី និងសិទ្ធិកុមារ សិទ្ធិទាំងនេះមាននៅក្នុងស្ទើរតែគ្រប់ប្រទេសទាំងអស់នៅអាស៊ីអាគ្នេយ៍ ។
- ទីបី សិទ្ធិមនុស្សជាទូទៅ (មិនគ្រប់ករណីនោះទេ) មានវត្តមាននៅក្នុងរដ្ឋធម្មនុញ្ញ។ ដោយសារថារដ្ឋធម្មនុញ្ញជាឯកសារច្បាប់ជាមូលដ្ឋានរបស់ប្រទេសមួយ ច្បាប់នេះផ្ដល់អាទិភាពខ្ពស់ដល់ការការពារសិទ្ធិមនុស្ស។

ជាដំបូងផ្នែកនេះ នឹងក្រលេកមើលលើវិធីសាស្ត្រក្នុងការបញ្ចូលសិទ្ធិមនុស្សនៅក្នុងប្រទេសនៃអាស៊ីអាគ្នេយ៍។ បន្ទាប់មក ផ្នែកនេះនឹងពិនិត្យលើគណៈកម្មាការសិទ្ធិមនុស្សជាតិ ដែលជាស្ថាប័នមានភារកិច្ចចម្បង ក្នុងការធានាថារដ្ឋកំពុងការពារសិទ្ធិមនុស្សដែលពួកគេបានព្រមព្រៀង។

## ៤.២.១ ស្តង់ដារអន្តរជាតិនៅក្នុងច្បាប់ជាតិ

ជំហានដំបូងក្នុងការពិនិត្យថាតើរដ្ឋាភិបាលមួយ កំពុងអនុវត្តសិទ្ធិមនុស្សឬក៏អត់ គឺត្រូវអង្កេតមើលលើកម្រិតដែលរដ្ឋបានព្រមព្រៀងលើស្តង់ដារអន្តរជាតិ តាមរយៈការចែងក្នុងច្បាប់។ ចំនួនសន្ធិសញ្ញាសិទ្ធិមនុស្សដែលរដ្ឋនៅអាស៊ីអាគ្នេយ៍បានព្រមព្រៀង រដ្ឋខ្លះបានផ្តល់សច្ចាប័នស្ទើរតែគ្រប់សន្ធិសញ្ញាទាំងអស់ ចំនែករដ្ឋខ្លះបានផ្តល់សច្ចាប័នចំនួនបីតែប៉ុណ្ណោះ។ ប៉ុន្តែយ៉ាងណាមិញ ការផ្តល់សច្ចាប័នតែឯកឯងមិនមែនជាសូចនាករណ៍ល្អមួយ ដើម្បីបញ្ជាក់ថារដ្ឋមួយបំពេញតាមការប្តេជ្ញាចិត្តរបស់ខ្លួនឬក៏អត់នោះទេ។ សិទ្ធិមនុស្សគួរតែមានដល់ប្រជាជនទាំងអស់នៅក្នុងប្រទេសដើម្បីប្រើប្រាស់។ នេះកើតឡើងនៅក្នុងដំណើរការ ដែលយើងហៅថាជាការអនុវត្តសិទ្ធិមនុស្សថ្នាក់ជាតិ ដែលកើតមានឡើងបន្ទាប់ពីនីតិវិធីផ្តល់សច្ចាប័ន។ ការអនុវត្តរួមមានការកែប្រែច្បាប់ជាតិ និងសរសេរច្បាប់ថ្មីដើម្បីធានាថាសិទ្ធិមនុស្សស្របច្បាប់នៅក្នុងប្រទសមួយ។ នីតិវិធីអនុវត្តផ្ទាល់ជារឿយៗជាក់លាក់ចំពោះប្រទេស និងប្រភេទនៃសិទ្ធិ។ ការប្រឈមនៅអាស៊ីអាគ្នេយ៍គឺថាប្រទេសជាច្រើនមិនមានវិធាន និងបទដ្ឋានគតិយុត្តច្បាស់លាស់ពីថាតើសន្ធិសញ្ញាត្រូវបានអនុវត្តយ៉ាងណានោះទេ។ សម្រាប់ប្រទេសខ្លះ (ដូចជាកម្ពុជា ថៃ និងវៀតណាម) វិធានទាំងនេះអាចមាននៅក្នុងរដ្ឋធម្មនុញ្ញ។ ចំពោះប្រទេសដទៃ វាជានីតិវិធីមួយរបស់រដ្ឋាភិបាល។ យ៉ាងណាមិញ មានវិធីសាស្រ្តចម្បងបីយ៉ាងដែលសិទ្ធិត្រូវបានអនុវត្តក្នុងនាមជាច្បាប់ជាតិ៖

១. ប្រទេសមួយអាចបញ្ចូលសន្ធិសញ្ញាទាំងមូល ហើយសន្ធិសញ្ញានេះក្លាយជាច្បាប់ក្នុងប្រទេស។ នេះមានអនុវត្តនៅក្នុងប្រទេសមួយចំនួនតូច ជាពិសេសនៅអឺរ៉ុប ប៉ុន្តែគ្មានរដ្ឋណាមួយនៅអាស៊ីអាគ្នេយ៍អនុវត្តប្រព័ន្ធនេះនោះទេ។ នៅក្នុងនីតិវិធីនេះ សន្ធិសញ្ញាក្លាយជាច្បាប់ថ្មី។

២. សន្ធិសញ្ញាអាចក្លាយជាច្បាប់ជាតិ តាមរយៈការធ្វើច្បាប់មួយ(ឬចង្កោមនៃច្បាប់) ដែលសរសេរឡើងវិញនូវស្តង់ដារនៅក្នុងសន្ធិសញ្ញា។ សន្ធិសញ្ញាអាចត្រូវបានសរសេរឡើងវិញជាច្បាប់មួយរបស់ជាតិ ដែលអាចត្រូវបានបង្ហាញថាជាច្បាប់មួយ ៖ ជាឧទាហរណ៍ សន្ធិសញ្ញាស្តីពីជនពិការបានក្លាយជាច្បាប់មួយនៅក្នុងប្រទេសហ្វីលីពីន (ច្បាប់សាធារណៈរដ្ឋលេខ ៧២៧៧ ឬមានឈ្មោះថា″ ម៉ាហ្គាកាតា (Magna Carta) សម្រាប់ជនពិការ″)។

សិទ្ធិនៅក្នុងសន្ធិសញ្ញាអាចត្រូវបានបំបែកជាច្បាប់ផ្សេងៗគ្នា ជាឧទាហរណ៍ សិទ្ធិកុមារនៅក្នុងប្រទេសហ្វីលីពីនត្រូវបានបែងចែកជាច្បាប់ដូចជា ច្បាប់សុខមាលភាព និងយុត្តិធម៌អនីតិជន ច្បាប់អប់រំកុមារ និងច្បាប់ពលកម្មកុមារ ដែលច្បាប់ទាំងអស់

នេះធ្វើឲ្យច្បាប់របស់ហ្វីលីពីនអនុលោមតាមស្តង់ដារ CRC។ ស្រដៀងគ្នានេះផង ដែរ ប្រទេសថៃបានបែងចែកសន្ធិសញ្ញា ICPRD ជាច្បាប់ចំនួនបី៖ ច្បាប់ផ្តល់អំណាចដល់ជនពិការ ច្បាប់លើកកម្ពស់គុណភាពជីវិតជនពិការ និងច្បាប់អប់រំជនពិការ។

៣. ប្រទេសអាចធ្វើការកែប្រែច្បាប់។ នៅក្នុងករណីនេះ ច្បាប់ពាក់ព័ន្ធនឹងសន្ធិសញ្ញា (ដែលអាចចេញពីវិស័យផ្សេងៗនៃច្បាប់) ត្រូវបានធ្វើបច្ចុប្បន្នភាពដើម្បីបំពេញតាមស្តង់ដារ។ ឧទាហរណ៍សម្រាប់ករណីនេះ គឺ CEDAW ដែលតាមរយៈនេះច្បាប់គ្រួសារ (ដូចជាការលែងលះ) ច្បាប់ការងារ (ដូចជាប្រាក់ស្មើគ្នា) និងច្បាប់ពលរដ្ឋនឹងត្រូវបានផ្លាស់ប្តូរដើម្បីអនុលោមតាម CEDAW។

ពាក់ព័ន្ធនឹងវិធីសាស្ត្រខាងលើ មិនមានវិធីសាស្ត្រមួយណាល្អជាងមួយណានោះទេ។ មានសារៈប្រយោជន៍ ក្នុងការមានច្បាប់ដាច់ដោយឡែកដោយសារថាច្បាប់ទាំងអស់នេះធ្វើឲ្យប្រជាជនមានភាពងាយស្រួលក្នុងការស្វែងយល់ពីវា។ យ៉ាងណាមិញការកែប្រែច្បាប់ក្នុងវិស័យផ្សេងៗគ្នាធានាថាច្បាប់ជាតិមានបច្ចុប្បន្នភាព ហើយនឹងមិនមានជម្លោះរវាងផ្នែកផ្សេងៗនៃច្បាប់។ ជាការពិតវត្តមាននៃច្បាប់មិនមែនមានន័យថាច្បាប់ត្រូវបានគោរពនោះទេ។ មានការប្រឈមជាច្រើនក្នុងការធានានូវការការពារសិទ្ធិមនុស្ស។ អាជ្ញាធរពាក់ព័ន្ធត្រូវតែចាប់បង្ខំអនុវត្តច្បាប់។ ប្រជាជនត្រូវដឹងពីច្បាប់ ដូចនេះពួកគេអាចអនុវត្តបាន។ ចៅក្រមត្រូវដឹងពីច្បាប់ដូចនេះពួកគេអាចធ្វើការសម្រេចចិត្តដោយផ្អែកលើច្បាប់។ ហើយរដ្ឋាភិបាលត្រូវបង្កើតផែនការសកម្មភាពជាតិ ឬគោលនយោបាយជាតិ ដូចនេះប្រជាជនដែលគួរតែត្រូវបានការពារដោយច្បាប់ ត្រូវបានការពារពិតប្រាកដ។

## ៤.២.២ សិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញនៅអាស៊ីអាគ្នេយ៍

ស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ អាចមានវត្តមាននៅក្នុងឯកសារជាច្រើនក្នុងប្រព័ន្ធច្បាប់របស់រដ្ឋមួយក្រៅពីច្បាប់ និងគោលនយោបាយជាតិ (ដូចដែលបានពិភាក្សា) ។ ស្តង់ដារទាំងនេះអាចជាផ្នែកមួយនៃរដ្ឋធម្មនុញ្ញផងដែរ។ សិទ្ធិរដ្ឋធម្មនុញ្ញត្រូវបានចាត់ទុកថាមានប្រសិទ្ធិភាព និងជាមូលដ្ឋាន ហើយគ្រប់រដ្ឋធម្មនុញ្ញនៅអាស៊ីអាគ្នេយ៍ទាំងអស់ពិតជាមានសិទ្ធិនៅក្នុងនោះ (ទោះបីជារដ្ឋធម្មនុញ្ញប្រ៊ុយណេមិនមានផ្នែកណាមួយចែងពីសិទ្ធិមនុស្សក៏ដោយ ក៏ច្បាប់នេះទទួលស្គាល់ថាប្រជាជនមានសិទ្ធិដែរ)។
រដ្ឋធម្មនុញ្ញជាឯកសារដែលបញ្ជាក់ពីវិធី ដែលរដ្ឋាភិបាលត្រូវគ្រប់គ្រងប្រទេសមួយ។ ច្បាប់នេះបញ្ជាក់ពីរចនាសម្ព័ន្ធរបស់រដ្ឋាភិបាល នីតិវិធីក្នុងការធ្វើច្បាប់ នីតិវិធីក្នុងការបោះឆ្នោតជ្រើសរើសអ្នកនយោបាយ និងពីអ្វីដែលរដ្ឋាភិបាលត្រូវតែធ្វើ។ បន្ថែមពីលើ

នេះទៀត រដ្ឋធម្មនុញ្ញបញ្ជាក់ពីកាតព្វកិច្ចរបស់រដ្ឋចំពោះប្រជាជនរបស់ខ្លួន និងកាតព្វកិច្ចរបស់ប្រជាជនចំពោះរដ្ឋរបស់ខ្លួន។ ផ្នែកនេះក្រលេកមើលលើរដ្ឋធម្មនុញ្ញបច្ចុប្បន្ននៅអាស៊ីអាគ្នេយ៍ដើម្បីបញ្ជាក់លម្អិតពីខ្លឹមសារ នៃសិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញទាំងនេះ។ យ៉ាងណាមិញ ទោះបីជារដ្ឋធម្មនុញ្ញមួយមានចែងពីសិទ្ធិមនុស្សក៏ដោយ ប៉ុន្តែមិនមែនជារឿងទូទៅនោះទេ សម្រាប់ប្រជាជននៅអាស៊ីអាគ្នេយ៍ក្នុងការពិភាក្សាពី ‘សិទ្ធិធម្មនុញ្ញ’ របស់ពួកគេ ដោយសារតែមិនមានមនុស្សច្រើននោះទេដែលដឹងពីសិទ្ធិទាំងនេះ ឬមិនដឹងថាសិទ្ធិធម្មនុញ្ញរបស់ពួកគេត្រូវបានការពារប្រកបដោយប្រសិទ្ធិភាព ឬក៏អត់នោះទេ។ មានហេតុផលជាច្រើនចំពោះបញ្ហានេះ៖ សិទ្ធិធម្មនុញ្ញរបស់ប្រទេសមួយចំនួនជារឿយៗទាបជាងស្តង់ដារអន្តរជាតិ ដូចនេះជាការល្អប្រសើរជាងក្នុងការប្រើប្រាស់សន្ធិសញ្ញាអន្តរជាតិសម្រាប់ការការពារ រដ្ឋធម្មនុញ្ញអាចត្រូវបានផ្លាស់ប្តូរកាលពីពេលថ្មីៗនេះ ដូចនេះប្រជាជនអាចមិនដឹងពីសិទ្ធិនៅក្នុងរដ្ឋធម្មនុញ្ញដែលមានបច្ចុប្បន្នភាពបំផុត ហើយសាលារៀនប្រហែលជាមិនបានបង្រៀនពីសិទ្ធិទាំងនេះ ឬប្រហែលមានចំនេះច្រើនលើសិទ្ធិមនុស្សអន្តរជាតិ។ យ៉ាងណាមិញ ហេតុផលចម្បងគឺថាជារឿយៗប្រជាជនមិនដឹងពីអ្វីដែលមាននៅក្នុងរដ្ឋធម្មនុញ្ញរបស់ខ្លួន ដោយសារតែមិនមានការបង្រៀនពីរដ្ឋធម្មនុញ្ញនៅតាមសាលា ហើយរដ្ឋធម្មនុញ្ញមិនត្រូវបាន ផ្សព្វផ្សាយជាសាធារណៈនោះទេ។ រដ្ឋនៅអាស៊ីអាគ្នេយ៍បង្រៀនប្រជាជនរបស់ខ្លួនពីសិទ្ធិរដ្ឋធម្មនុញ្ញមិនបានដិតដល់នោះទេ។

## ការពិភាក្សា និងការជជែកវែកញែក

### ចំនេះដឹងពីសិទ្ធិមនុស្ស

តើអ្នកដឹងដែរឬទេថាសិទ្ធិអ្វីខ្លះដែលអ្នកអាចទទួលបានពីរដ្ឋធម្មនុញ្ញរបស់អ្នក? តើអ្នកធ្លាប់រៀនពីរដ្ឋធម្មនុញ្ញអ្នកដែរឬទេ? តើមានមិត្តភ័ក្រ្ត ឬសមាជិកក្រុមគ្រួសារណាម្នាក់ដឹងពីរដ្ឋធម្មនុញ្ញដែរឬទេ?

ចំពោះសិស្សភាគច្រើននៅអាស៊ីអាគ្នេយ៍ ចំលើយលើសំណួរទាំងនេះគឺថា ទេ។ ហេតុអ្វីបានជាចឹង? ហេតុអ្វីបានជារដ្ឋាភិបាលមិនបង្រៀនពីរដ្ឋធម្មនុញ្ញដល់ប្រជាជនឲ្យបានដិតដល់? ប្រហែលជាដោយសារគ្រូ និងឪពុកម្តាយគិតថាគណិតវិទ្យា វិទ្យាសាស្រ្ត និងតែងសេចក្តីមានសារៈសំខាន់ជាង។ ប្រហែលជាមិនមានថ្នាក់ក្នុងការបង្រៀនរដ្ឋធម្មនុញ្ញនោះទេ។ ឬប្រហែលជារដ្ឋាភិបាលមិនសកម្មក្នុងការបង្រៀនពលរដ្ឋរបស់ខ្លួនថាពួកគេមានសិទ្ធិអ្វីខ្លះ។

## ករណីសិក្សា

### តុលាការកំពូលហ្វីលីពីនប្រើប្រាស់ UDHR និងICCPR

ហ្វីលីពីនបានបញ្ចូលច្បាប់អន្តរជាតិទំនៀមទំលាប់តាមស្មារតី នៃមាត្រា២ ផ្នែកទី២ នៃរដ្ឋធម្មនុញ្ញរបស់ពួកគេ ដែលមានចំណងជើងថា ″សេចក្តីប្រកាសពីគោលការណ៍ និងគោលនយោបាយរដ្ឋ′ និងមាត្រា៧ ផ្នែកទី២១ ដែលចែងថាគ្រប់សន្ធិសញ្ញា ឬកិច្ចព្រមព្រៀងទាំងអស់ ដែលហ្វីលីពីនបានផ្តល់សច្ចាប័នត្រូវបានប្រែក្លាយជាច្បាប់ក្នុងទឹកដីរបស់ខ្លួន ដែលមានការចាប់បង្ខំ និងសុពលភាពដូចគ្នាទៅនឹងច្បាប់។

ការអនុវត្ត UDHR និងសន្ធិសញ្ញាដែលបានផ្តល់សច្ចាប័នដទៃទៀតត្រូវបានអង្កេតឃើញក្នុងរឿងក្តីមួយចំនួនដែលបានសម្រេចដោយតុលាការកំពូលហ្វីលីពីន។ នៅក្នុងរឿងក្តី Kant Kwong និង Yim Kam Shing vs គណៈកម្មាធិការប្រធានាធិបតីស្តីពីអភិបាលកិច្ចល្អ (GR No L-79484 ថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៨៧) ដែលចែងពីសិទ្ធិក្នុងការធ្វើដំណើរ និងដើរហើរដោយសេរី តុលាការកំពូលសម្រេចថា ″ សិទ្ធិក្នុងការធ្វើដំណើរ និងសេរីភាពក្នុងការដើរហើរជាសិទ្ធិមូលដ្ឋានដែលបានធានាដោយរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៨៧ និងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស″ និង″ មនុស្សគ្រប់រូបមានសិទ្ធិក្នុងការទទួលបានសំណងប្រកបដោយប្រសិទ្ធិភាព ដោយអង្គជំនុះជម្រះជាតិដែលមានសមត្ថកិច្ចចំពោះអំពើដែលរំលោភបំពានសិទ្ធិជាមូលដ្ឋាន ដែលត្រូវបានធានាដល់ពួកគេដោយរដ្ឋធម្មនុញ្ញ ឬច្បាប់′។

នៅក្នុងរឿងក្តីមួយទៀត (Ferdinand E Marcos, et al v Raul Manlapus, et al, GR No 88211, ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៨៩)តុលាការកំពូលបានយោងលើទាំង UDHR និង ICCPR ដោយធ្វើការគូសបញ្ជាក់ថាទោះបីជាសិទ្ធិក្នុងការវិលត្រលប់ទៅកាន់ប្រទេសមួយ មិនមែនក្នុងចំណោមសិទ្ធិដែលបានធានាជាក់លាក់ដោយច្បាប់សិទ្ធិមនុស្សរបស់ហ្វីលីពីនក៏ដោយ សិទ្ធិនេះគួរតែត្រូវបានចាត់ទុកថាជាគោលការណ៍ដែលមានការទទួលស្គាល់ជាទូទៅនៃច្បាប់អន្តរជាតិ ហើយនឹងក្នុងរដ្ឋធម្មនុញ្ញរបស់ហ្វីលីពីនដែលជាផ្នែកមួយនៃច្បាប់ក្នុងប្រទេស។

ដូចដែលបានអង្កេតពីខ្លឹមសារនៃរដ្ឋធម្មនុញ្ញ រដ្ឋធម្មនុញ្ញក្រោយអាណានិគមភាគច្រើននៅអាស៊ីអាគ្នេយ៍បានបញ្ចូលស្តង់ដារ និងគោលការណ៍ជាច្រើននៃសិទ្ធិមនុស្ស។ តាមពេលវេលាជាក់ស្តែង រដ្ឋធម្មនុញ្ញត្រូវបានផ្លាស់ប្តូរ ឬសរសេរឡើងវិញដើម្បីធ្វើឲ្យមានសង្គតភាពជាមួយនឹងស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ។ ដូចដែលបានបញ្ជាក់ពិស្តារ

ខាងលើ នៅពេលដែលរដ្ឋក្លាយជាភាគីនៃលិខិតូបករណ៍សិទ្ធិមនុស្ស គឺតម្រូវឲ្យពួកគេផ្លាស់ប្តូរក្រុបខណ្ឌច្បាប់ និងប្រព័ន្ធដែលមានស្រាប់របស់ខ្លួនដើម្បីឲ្យស្របជាមួយនឹងស្តង់ដារទាំងនោះ។ នៅក្នុងករណីមួយចំនួន ប្រសិនជាអាច នេះមានន័យថាធ្វើការសម្របសម្រួលរដ្ឋធម្មនុញ្ញ។ ការសម្របសម្រួលអាចជាវិសោធនកម្ម (ជាឧទាហរណ៍ វិសោធនកម្មលើរដ្ឋធម្មនុញ្ញឥណ្ឌូនេស៊ីដើម្បីគាំទ្រសិទ្ធិនយោបាយ) ឬអាចធ្វើការបកស្រាយរដ្ឋធម្មនុញ្ញដើម្បីអនុលោមតាមស្តង់ដារអន្តរជាតិ។ នេះអាចធ្វើទៅបានតាមរយៈការបញ្ចូលស្តង់ដារសិទ្ធិមនុស្ស ដែលមានស្រាប់មួយចំនួនទៅក្នុងច្បាប់រដ្ឋធម្មនុញ្ញថ្មី (ដូចជាប្រទេសថៃបានធ្វើក្នុងរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៨ និង ឆ្នាំ២០០៧ របស់ខ្លួន)។ ធម្មនុញ្ញឆ្នាំ១៩៨៧ របស់ប្រទេសហ្វីលីពីនបានកំណត់ពីសិទ្ធិមនុស្សផ្សេងៗ ហើយចែងថាសន្ធិសញ្ញាដែលបានផ្តល់សច្ចាប័នត្រូវតែបញ្ចូលទៅក្នុងច្បាប់។ នេះជាឧទាហរណ៍ល្អមួយបង្ហាញពីវិធីសាស្ត្រ ដែលរដ្ឋធម្មនុញ្ញកំណត់ពីវិធីដែលសន្ធិសញ្ញាអាចត្រូវបានអនុវត្តនៅថ្នាក់ជាតិ។ លទ្ធផលគឺថាតុលាការកំពូលហ្វីលីពីនបានអនុវត្ត UDHR ដើម្បីជាផ្នែកមួយនៃប្រព័ន្ធច្បាប់ហ្វីលីពីន។ គួរឲ្យស្តាយ យ៉ាងណាមិញការអនុវត្តច្បាប់សិទ្ធិមនុស្សរបស់ប្រទេសហ្វីលីពីនជាការលើកលែងមួយ ដែលមិនដូចទៅនឹងវិធានក្នុងការប្រើប្រាស់ច្បាប់អន្តរជាតិក្នុងអាស៊ីអាគ្នេយ៍នោះឡើយ។

## តារាង ៤-២: រដ្ឋធម្មនុញ្ញនៅអាស៊ីអាគ្នេយ៍

| ប្រទេស | រដ្ឋធម្មនុញ្ញទី១ | ចំនួននៃរដ្ឋធម្មនុញ្ញ | រដ្ឋធម្មនុញ្ញបច្ចុប្បន្ន | ផ្នែកសិទ្ធិមនុស្ស និងឧទាហរណ៍នៃច្បាប់សិទ្ធិមនុស្ស |
|---|---|---|---|---|
| ប្រ៊ុយណេ DS | ១៩៥៩ | ១ (ជាមួយវិសោធនកម្ម) | ២០០៨ | គ្មានផ្នែកណាមួយនិយាយពីសិទ្ធិមនុស្ស |
| កម្ពុជា | ១៩៩៣ | ១ (ជាមួយវិសោធនកម្ម) | ១៩៩៩ | ជំពូក៣៖ សិទ្ធិ និងកាតព្វកិច្ចប្រជាពលរដ្ឋខ្មែរ (មាត្រា ៣១-៥០) |
| ឡាវ | ១៩៩១ | ១ (ជាមួយវិសោធនកម្ម) | ២០០៣ | ជំពូក៤៖ មូលដ្ឋានសិទ្ធិ និងកាតព្វកិច្ចនៃប្រជាពលរដ្ឋ(មាត្រា ៣៤-៥១) |
| ឥណ្ឌូនេស៊ី | ១៩៤៥ | វិសោធនកម្ម ៤ដង ១៩៥៥ រដ្ឋធម្មនុញ្ញបណ្តោះអាសន្ន | ១៩៤៥/២០០២ | ជំពូក X(A)៖ ទៅលើសិទ្ធិមានការងារ សាសនា ការអប់រំ និងសន្តិសុខសង្គម (មាត្រា២៨-២៨ (J) មាត្រា ២៧, ២៨, ៣១, ៣២, ៣៤) |
| ម៉ាឡេស៊ី | ១៩៥៧ | ១ | ១៩៥៧ | ផ្នែកទី២៖ មូលដ្ឋាននៃសេរីភាព (ភាពស្មើគ្នា បំលាស់ទី មតិ ការជួបប្រជុំ) |
| មីយ៉ាន់ម៉ា | ១៩៤៨ | ៣ | ២០០៨ | ជំពូក៨៖ ប្រជាពលរដ្ឋ,មូលដ្ឋាននៃសិទ្ធិ និងតួនាទីរបស់ប្រជា ពលរដ្ឋ |
| ហ្វីលីពីន | ១៩៣៥/១៩៨ | ៤ | ១៩៨៧ | មាត្រា៣៖ កម្រងសិទ្ធិឯកជន មាត្រា១៣៖យុត្តិធម៌សង្គម |
| សិង្ហបុរី | ១៩៦៥/១៩៦៣ | ១ (វិសោធនកម្ម៣ដង) | ១៩៩១ | ផ្នែកទី៤៖ មូលដ្ឋានសេរីភាព (មាត្រា ៩-១៦) |
| ថៃ* | ១៩៣២ | ១៩ | ២០០៧ | ជំពូក៣៖ សិទ្ធិ និងសេរីភាពរបស់ប្រជាជនថៃ |
| វៀតណាម | ១៩៤៦ | ៥ (វិសោធនកម្ម១ដង) | ២០១៣ | ជំពូក II៖ សិទ្ធិមនុស្ស, មូលដ្ឋាននៃសិទ្ធិពលរដ្ឋ និងកាតព្វកិច្ចជាពលរដ្ឋ (មាត្រា ១៤-៤៩) |
| ទីម័រខាងកើត | ២០០២ | ១ | ២០០២ | ផ្នែក II៖ មូលដ្ឋានសិទ្ធិ, ករណីកិច្ច, សេរីភាព និងការធានា (មាត្រា១៦-២៨) |

*ធម្មនុញ្ញថៃបច្ចុប្បន្នមិនមានសុពលដោយ បន្ទាប់ពីរដ្ឋប្រហារយោធាក្នុងឆ្នាំ ២០១៤។ រដ្ឋធម្មនុញ្ញថ្មី កំពុងតែព្រាង។

ការបញ្ចូលសិទ្ធិមនុស្សទៅក្នុងរដ្ឋធម្មនុញ្ញ ជាព្រឹត្តការណ៍ដែលកើតមានពេលថ្មីៗនេះ។ រដ្ឋធម្មនុញ្ញដើមរបស់ប្រទេសមួយចំនួន មិនមានសិទ្ធិមនុស្សនៅក្នុងនោះទេ។ សិទ្ធិត្រូវបានបញ្ចូលពេលក្រោយជាវិសោធនកម្ម ឬ សិទ្ធិមានវត្តមាននៅក្នុងរដ្ឋធម្មនុញ្ញដែលបានសរសេរឡើងវិញ។ ហើយអ្វីដែលត្រូវបានពិចារណាដើម្បីកំណត់ថាសិទ្ធិមនុស្សស្មើនឹងស្តង់ដារអន្តរជាតិកើតមានកាន់តែថ្មីៗជាងនេះទៀត។ សម្រាប់ប្រទេសឥណ្ឌូ

នេស៊ី ក្នុងឆ្នាំ២០០២ ប្រទេសថៃ ១៩៩៧ និង២០០៨ ចំពោះប្រទេសមីយ៉ាន់ម៉ា។ នៅអាស៊ីអាគ្នេយ៍ មានករណីជាច្រើនដែលរដ្ឋធម្មនុញ្ញដាក់ដែនកំណត់លើសិទ្ធិ ជាជាងធានានូវសិទ្ធិ។ រដ្ឋធម្មនុញ្ញហាក់បីដូចជាផ្តោតសំខាន់លើអធិបតេយ្យភាព និងការអភិវឌ្ឍរបស់រដ្ឋ ជាជាងសិទ្ធិរបស់ប្រជាជនខ្លួន។ មានឧទាហរណ៍ដែលសិទ្ធិមួយត្រូវបានធានា ប៉ុន្តែត្រូវមានគុណវុឌ្ឍិ និងដែនកំណត់ជទៃប៉ុណ្ណោះ។ ជាទូទៅ គុណវុឌ្ឍិ និងដែនកំណត់ទាំងនេះសំដៅលើកាតព្វកិច្ចរបស់ពលរដ្ឋ ដែលមាននៅក្នុងស្ទើរតែគ្រប់រដ្ឋធម្មនុញ្ញទាំងអស់។ តាមរយៈការពិចារណាថាសិទ្ធិត្រូវភ្ជាប់ជាមួយនឹងកាតព្វកិច្ច ជាការផ្ទុយទៅនឹងគោលការណ៍ជាមូលដ្ឋានដែលថាសិទ្ធិទាំងអស់ភ្ជាប់ពីកំណើត និង មិនអាចដកហូតបាន។ មិនគួរណាមានកាតព្វកិច្ចចាំបាច់ក្នុងការទទួលបានសិទ្ធិមួយនោះទេ។ ដែនកំណត់ទូទៅមួយទៀតគឺថាសិទ្ធិត្រូវបានកម្រិតដោយច្បាប់ជាតិ។ នេះជាបញ្ហាមួយ ដោយសារវាបង្កប់ន័យថារដ្ឋធម្មនុញ្ញគឺជាច្បាប់កំពូលរបស់ជាតិ ដូចនេះយើងត្រូវគោរពច្បាប់ជាតិ។ ជាចុងក្រោយ សិទ្ធិត្រូវបានកម្រិតតាមរយៈការចាត់ទុកជាទោសព្រហ្មទណ្ឌលើអ្វីៗគ្រប់យ៉ាង ដែលប្រឆាំងនឹងភាពថ្លៃថ្នូររបស់រដ្ឋាភិបាល។ ដូចនេះរដ្ឋមានអំណាចមួយក្នុងការដាក់ដែនកំណត់ ឬបដិសេធសិទ្ធិមួយ ប្រសិនខ្លួនគិតថាជាការគម្រាមកំហែងដល់រដ្ឋ (ហើយការគម្រាមកំហែងត្រូវបានបកស្រាយប្រកបដោយភាពទូលំទូលាយ)។ ឧទាហរណ៍ច្បាស់លាស់ គឺច្បាប់ស្តីពីសន្តិសុខជាតិ (ISA) របស់សឹង្ហបូរី និងម៉ាឡេស៊ី ដែលផ្តល់សិទ្ធិដល់រដ្ឋាភិបាល ក្នុងការចាប់ខ្លួន និងឃុំខ្លួនដើម្បីជាការបង្ការ ដោយមិនមានការជំនុំជម្រះ (ក្នុងប្រទេសសឹង្ហបូរីរហូតដល់ពីរឆ្នាំ តាមមាត្រា ៨(១) (ក))។

រដ្ឋធម្មនុញ្ញនៅអាស៊ីអាគ្នេយ៍ គួរឲ្យកត់សម្គាល់ផងដែរក្នុងការផ្តល់អាទិភាពដល់ក្រុមសាសនា ឬអំបូរជាក់លាក់។ ជាឧទាហរណ៍ មាត្រា២៩ នៃរដ្ឋធម្មនុញ្ញឥណ្ឌូនេស៊ី ប្រកាសថារដ្ឋគួរតែផ្អែកលើជំនឿលើព្រះជាម្ចាស់ ហើយមានព្រះជាម្ចាស់តែមួយគត់។ ក្នុងរដ្ឋធម្មនុញ្ញប្រ៊ុយណេ មីយ៉ាន់ម៉ា និងម៉ាឡេស៊ី មានសាសនាមួយចំនួនតូចប៉ុណ្ណោះដែលត្រូវបានទទួលស្គាល់ ដូចនេះមានដែនកំណត់លើសេរីភាពសាសនា។

## ការពិភាក្សា និងការជជែកវែកញែក

### រដ្ឋធម្មនុញ្ញមីយ៉ាន់ម៉ា

ពិនិត្យមើលមាត្រាពីរខាងក្រោមនៃរដ្ឋធម្មនុញ្ញមីយ៉ាន់ម៉ាជាភាសាអង់គ្លេស។

៣៥១. ម្តាយ កូន និងស្ត្រីមានផ្ទៃពោះត្រូវទទួលបានសិទ្ធិស្មើគ្នាដូចដែលបានចែងដោយច្បាប់។

៣៥២. នៅពេលដែលគុណវុឌ្ឍិជាក់លាក់ត្រូវបានបំពេញ ក្នុងការតែងតាំង ឬដាក់កាតព្វកិច្ចលើបុគ្គលិកបម្រើសេវាស៊ីវិល សហភាពមិនត្រូវរើសអើងលើ ឬប្រឆាំងនឹងពលរដ្ឋណាម្នាក់នៃសាធារណៈរដ្ឋសហភាពមីយ៉ាន់ម៉ាដោយផ្អែកលើពូជសាសន៍ ដើមកំណើត សាសនា និងភេទនោះទេ។ យ៉ាងណាមិញ គ្មានអ្វីនៅក្នុងផ្នែកនេះត្រូវហាមឃាត់ការតែងតាំងបុរសឲ្យចូលកាន់តំណែងដែលសាកសមសម្រាប់តែបុរសនោះទេ។ អ្វីជាដែនកំណត់លើសិទ្ធិក្នុងមាត្រាទាំងនេះ តើអ្នកគិតថាមាត្រាទាំងនេះគោរពសិទ្ធិមនុស្សពេញលេញដែរឬទេរវាងបុរស និងស្ត្រី? មានបញ្ហាមួយចំនួនៈ

១. យោងទៅតាមមាត្រា ៣៥១ សិទ្ធិស្មើគ្នាមានតែចំពោះសិទ្ធិដែលបាន"ចែងដោយច្បាប់ប៉ុណ្ណោះ។ ដូចនេះជាឧទាហរណ៍ ប្រសិនជាគ្មានច្បាប់ផ្តល់ដល់ស្ត្រីនូវសិទ្ធិស្មើគ្នាក្នុងការលែងលះ ពួកគេមិនអាចទទួលបានភាពស្មើគ្នានោះទេ។
២. កត់ចំណាំ មាត្រា ៣៥១ សម្រាប់ម្តាយ កុមារ និងស្ត្រីមានផ្ទៃពោះតែប៉ុណ្ណោះ ប៉ុន្តែមាត្រា ៣៥២ សម្រាប់ពលរដ្ឋតែប៉ុណ្ណោះ។ ដូចនេះកន្លែងការងារអាចរើសអើងលើអ្នកដែលមិនមែនជាពលរដ្ឋ?

៣. មានការងារមួយចំនួនដែលទុកជូនតែបុរសប៉ុណ្ណោះតាមមាត្រា ៣៥២ តើការងារទាំងនេះជាអ្វី? ការងារអ្វីដែលមានតែបុរសអាចធ្វើបាន? មាត្រានេះមិនច្បាស់លាស់ដែលអាចអនុញ្ញាតឲ្យរដ្ឋាភិបាលរើសអើងលើស្ត្រី ដោយសម្រេចចិត្តតាមទំនើងចិត្តថាអ្វីដែល'មិនសាកសម'ចំពោះស្ត្រី។

## ៤.៣ ស្ថាប័នសិទ្ធិមនុស្សជាតិ

ស្ថាប័នសិទ្ធិមនុស្សជាតិ (NHRI) ជាស្ថាប័នផ្លូវការរបស់រដ្ឋដែលត្រូវបានបង្កើតឡើងដោយច្បាប់ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្សនៅក្នុងប្រទេសមួយ។ NHRI បម្រើការងារដើម្បីបំពេញបន្ថែមដល់ស្ថាប័នដទៃទៀតរបស់រដ្ឋាភិបាល ដូចជាតុលាការ ប៉ុន្តែស្ថាប័ននេះមានលក្ខណៈពិសេស ត្រង់ថាខ្លួនដើរតួនាទីជាស្ពានសំខាន់មួយរវាងរដ្ឋាភិបាល និងសហគមន៍ ហើយរវាងប្រទេសរបស់ខ្លួន និងប្រព័ន្ធសិទ្ធិមនុស្សរបស់ UN។ លក្ខណៈពិសេសដទៃទៀតនៃ NHRI គឺស្ថាប័ននេះស្វ័យយ័តពីរដ្ឋាភិបាល។ ឯករាជ្យភាពមានសារៈសំខាន់ ដើម្បីធានានូវការអនុវត្តមុខងាររបស់ខ្លួនប្រកបដោយប្រសិទ្ធិភាព។

## ៤.៣.១ ដើមកំណើតនៃ NHRIs

NHRIs ដំបូងត្រូវបានបង្កើតឡើងក្នុងទសវត្សឆ្នាំ ១៩៧០ និង១៩៨០ នៅក្នុងប្រទេសកុំមុនវែលដូចជាកាណាដា អូស្ត្រាលី និងញូវហ្ស៊ីឡែន។ យ៉ាងណាមិញ ឆ្នាំ១៩៩៣ ជាឆ្នាំនៃការចាប់ផ្តើមនៃចលនា NHRI នៅពេលដែលសេចក្តីប្រកាស និងផែនការសកម្មភាពទីក្រុងវៀនបានផ្តល់ការទទួលយកជាសកលជាដំបូងលើ NHRIs។ សេចក្តីប្រកាសនេះបានបញ្ជាក់ឡើងវិញថា "តួនាទីសំខាន់ និងប្រកបដោយស្មារតីស្ថាបនារបស់ស្ថានប័នជាតិសម្រាប់ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស"។ ហើយសេចក្តីប្រកាសនេះលើកទឹកចិត្តដល់រដ្ឋនីមួយៗក្នុងការបង្កើត NHRI (ក្នុងផ្នែកទី១ កថាខណ្ឌ ៣៦ នៃសេចក្តីប្រកាស)។ ទីពីរ មហាសន្និបាត UN បានអនុម័ត "គោលការណ៍ពាក់ព័ន្ធនឹងឋានៈនៃស្ថាប័នថ្នាក់ជាតិសម្រាប់ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស" (ត្រូវបានហៅថាជាគោលការណ៍ប៉ារីស) ជាស្តង់ដារអប្បរមាអន្តរជាតិ។ ទីបី ឆ្នាំ១៩៩៣ ក៏ជាការចាប់ផ្តើមនៃគណៈកម្មាធិការសម្របសម្រួលអន្តរជាតិនៃស្ថាប័នថ្នាក់ជាតិដើម្បីការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស (ICC- សូមកុំច្រឡំជាមួយនឹងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ដែលហៅកាត់ ICC ដូចគ្នា) ជាបណ្តាញ NHRI អន្តរជាតិ។ ចាប់តាំងពីឆ្នាំ១៩៩៣ មក មានការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួន NHRIs។ ក្នុងឆ្នាំ ១៩៩០ ទូទាំងពិភពលោកមាន NHRIs តិចជាង ១០ ប៉ុណ្ណោះ។ ពេលបច្ចុប្បន្ននេះមានជាង១០០ ប្រហែលជា ៧០ បំពេញតាមស្តង់ដារដែលបានកំណត់ក្នុងគោលការណ៍ទីក្រុងប៉ារីស។ ត្រឹមឆ្នាំ ២០១៤ ប្រទេសអាស៊ានចំនួន ៦ មាន NHRI៖ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន ថៃ និងទីម័រខាងកើត។

## ៤.៣.២ ប្រភេទនៃ និងមុខងាររបស់ NHRIs

ខណៈពេលដែលប្រទេសមួយមាន NHRI ជាផ្លូវការតែមួយប៉ុណ្ណោះ ប្រទេសសាមីអាចសម្រេចលើតួនាទីជាក់លាក់ដែលស្ថាប័ននេះត្រូវបំពេញដោយសេរី។ សេចក្តីសម្រេចនេះនឹងផ្អែកលើការពិចារណាលើស្ថានភាពមួយចំនួន រួមមានទាំងលើក្របខណ្ឌការពារសិទ្ធិមនុស្ស ប្រព័ន្ធច្បាប់ នយោបាយ និងវប្បធម៌ និងធនធានមនុស្ស និងហិរញ្ញវត្ថុដែលមានស្រាប់របស់ប្រទេសនោះ។ បន្ថែមពីលើនេះទៀត តួនាទីជាក់លាក់ដែលប្រទេសមួយបានសម្រេចក្នុងការផ្តល់ជូនដល់ NHRI របស់ខ្លួននឹងកំណត់ពីប្រភេទនៃ NHRI ដែលសាកសមបំផុត។ មាន NHRI ចំនួនបួនប្រភេទចម្បងៗ៖

## គណៈកម្មាធិការសិទ្ធិមនុស្ស

គណៈកម្មាធិការសិទ្ធិមនុស្សដែលជាប្រភេទទូទៅ និងទូលំទូលាយនៃ NHRI ទាំងទំហំ និងមុខងារ។ រចនាសម្ព័ន្ធរបស់ NHRI រួមមានចំនួនសមាជិកគណៈកម្មាធិការ ( ហើយចំនួនមានភាពខុសគ្នាដែលមានចន្លោះពីហ្វីលីពីនមានចំនួន ៥ ដល់ ១៥នៅមីយ៉ាន់ម៉ា) ដែលជាអ្នកជំនាញមានកាតព្វកិច្ចមួយចំនួនជុំវិញការការពារ និងការលើកកម្ពស់សិទ្ធិមនុស្ស។ គណៈកម្មាធិការសិទ្ធិមនុស្សរបស់របស់ហ្វីលីពីនជាន NHRI ធំជាងគេនៅអាស៊ីអាគ្នេយ៍ ដែលមានបុគ្គលិកជាង ៦០០ នាក់។

គណៈកម្មាធិការសិទ្ធិមនុស្សជាទូទៅត្រូវបានដឹកនាំដោយ ប្រធានមួយរូប ឬច្រើនរូប ដែលធ្វើការពេញម៉ោង ដែលត្រូវបានតែងតាំងសម្រាប់អាណត្តិមានពេលវេលាកំណត់មួយ។ សមាជិកគណៈកម្មាធិការជាតំណាងជាសាធារណៈ និងជាសម្លេងរបស់ NHRIs ។ ការតែងតាំងសមាជិកគណៈកម្មាធិការត្រូវធ្វើឡើង ដោយនីតិវិធីដែលមានតម្លាភាព ដែលរួមបញ្ចូលការពិគ្រោះយោបល់ពីសហគមន៍។ ជាការសំខាន់ដូចគ្នាផងដែរក្នុងការធានានូវភាពចម្រុះក្នុងការតែងតាំងគណៈកម្មាធិការ ក្នុងនាមជាក្រុមមួយ ពួកគេគួរតែឆ្លុះបញ្ចាំងពីផ្នែកផ្សេងៗគ្នានៃសង្គមព្រមទាំងតុល្យភាពយេនឌ័រផងដែរ ហើយនេះមានន័យថារួមមានអ្នកច្បាប់ អ្នកសិក្សាស្រាវជ្រាវ សកម្មជនសង្គមស៊ីវិល មន្ត្រីរដ្ឋាភិបាល ។ល។

## ស្ថាប័នប្រឹក្សាយោបល់ និងពិគ្រោះយោបល់

ស្ថាប័នប្រឹក្សាយោបល់ និងពិគ្រោះយោបល់គឺជា NHRIs ដែលផ្តល់ដំបូន្មាន និងអនុសាសន៍ស៊ីជម្រៅដល់រដ្ឋាភិបាលលើបញ្ហាសិទ្ធិមនុស្សជាច្រើន។ ស្ថាប័នផ្តល់ប្រឹក្សាយោបល់ និងពិគ្រោះយោបល់ក៏រួមចំនែកក្នុងការការងាររបស់យន្តការសិទ្ធិមនុស្សថ្នាក់តំបន់ និងអន្តរជាតិផងដែរ។ ពួកគេមិនធ្វើការស៊ើបអង្កេតលើបណ្តឹង ឬផ្តល់ជាជំនួយក្នុងនីតិវិធីតុលាការនោះទេ។ ជារឿងសាមញ្ញនៅក្នុងតុលាការអឺរ៉ុប ប៉ុន្តែមិនមែនជាការអនុវត្តក្នុងអាស៊ីអាគ្នេយ៍នោះទេ។

## ស្ថាប័នស្រាវជ្រាវ

ស្ថាប័នស្រាវជ្រាវជា "ក្រុមការងារ" សិទ្ធិមនុស្ស។ ពួកគេផ្តល់សំខាន់លើការសិក្សាស្រាវជ្រាវ ដែលជម្រុញដល់ពួកគេធ្វើការរួមចំនែកពីអ្នកជំនាញការលើការសិក្សានៃបញ្ហាសិទ្ធិមនុស្សជាក់លាក់។ ដូចគ្នាទៅនឹងស្ថាប័នប្រឹក្សាយោបល់ និងពិគ្រោះយោបល់ដែរ ស្ថាប័នស្រាវជ្រាវជាទូទៅខ្វះសមត្ថភាពក្នុងការទទួលនូវបណ្តឹងដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្សពីបុគ្គល។ មិនមានស្ថាប័នស្រាវជ្រាវដូចជា NHRI ក្នុងតំបន់អាស៊ីអាគ្នេយ៍នោះទេ។

## ស្ថាប័នកូនកាត់

NHRIs មួយចំនួនរួមមានប្រភេទផ្សេងៗគ្នានៃតួនាទីផ្សេងគ្នា ហើយដូចនេះ មិនមានប្រភេទដូចគ្នាតែមួយនោះទេ។ មានស្ថាប័នកូនកាត់មួយចំនួន។ ស្ថាប័នខ្លះមានអាណត្តិដូចជាស្ថាប័នដោះស្រាយបណ្តឹង (ដែលជាកន្លែងដែលបុគ្គលអាចផ្តល់ការសម្របសម្រួលជាអាជ្ញាកណ្តាល ឬស៊ើបអង្កេតវិវាទពីសិទ្ធិមនុស្ស ជាឧទាហរណ៍ការរើសអើងនៅកន្លែងការងារ) ជាមួយនឹងមុខងារមួយចំនួន ឬទាំងអស់នៃគណៈកម្មាធិការសិទ្ធិមនុស្ស។ ការិយាល័យអ្នកផ្តល់សិទ្ធិមនុស្ស និងយុត្តិធម៌របស់ទីម័រខាងកើតជាឧទាហរណ៍មួយនៃ NHRI កូនកាត់។ តួនាទីរបស់ស្ថាប័ននេះរួមមានធ្វើការស៊ើបអង្កេត និងដោះស្រាយបណ្តឹងពីបុគ្គល ផ្តល់ដំបូន្មានពីសិទ្ធិមនុស្សដល់រដ្ឋាភិបាល ទស្សនៈកិច្ចកន្លែងឃុំខ្លួន និងមានវត្តមាននៅចំពោះមុខតុលាការ អង្គជំនុះជម្រះ និងគណៈកម្មាធិការស៊ើសួររដ្ឋបាល។ ដូចដែល UN បានចង្អុលបង្ហាញ ស្ថាប័នកូនកាត់អាចផ្តល់សេវា "ច្រកចេញចូលតែមួយ"។ ដូចនេះអនុញ្ញាតឲ្យធនធានផ្តុំនៅស្ថាប័នតែមួយជាជាងរាយប៉ាយលើស្ថាប័នមួយចំនួន។

ដូចដែលមានបង្ហាញនៅតារាងខាងក្រោម NHRIs នៅអាស៊ីអាគ្នេយ៍ភាគច្រើនជាគណៈកម្មាធិការ។

តារាង ៤-៣: NHRIs នៅអាស៊ីអាគ្នេយ៍

| ប្រទេស | ឈ្មោះ | ប្រភេទ | ឆ្នាំបង្កើត |
|---|---|---|---|
| ឥណ្ឌូនេស៊ី | គណៈកម្មការជាតិសិទ្ធិមនុស្សរបស់ឥណ្ឌូនេស៊ី (Komnas HAM) | គណៈកម្មការសិទ្ធិមនុស្ស | ១៩៩៣ |
| ម៉ាឡេស៊ី | គណៈកម្មការសិទ្ធិមនុស្សរបស់ប្រទេសម៉ាឡេស៊ី (SUHAKAM) | គណៈកម្មការសិទ្ធិមនុស្ស | ១៩៩៩ |
| មីយ៉ាន់ម៉ា | គណៈកម្មការជាតិសិទ្ធិមនុស្សរបស់មីយ៉ាន់ម៉ា | គណៈកម្មការសិទ្ធិមនុស្ស | ២០១១ |
| ហ្វីលីពីន | គណៈកម្មការសិទ្ធិមនុស្សរបស់ហ្វីលីពីន | គណៈកម្មការសិទ្ធិមនុស្ស | ១៩៨៧ |
| ថៃ | គណៈកម្មការជាតិសិទ្ធិមនុស្សរបស់ថៃ | គណៈកម្មការសិទ្ធិមនុស្ស | ១៩៩៩ |
| ទីម័រខាងកើត | Provedoria សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌ | ស្ថាប័នកូនកាត់ | ២០០៤ |

## ៤.៣.៣ សកម្មភាព NHRIs

គោលបំណងនៃ NHRI គឺជាការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សនៅថ្នាក់ជាតិ។ ស្ថាប័ននេះមានអំណាចក្នុងការអនុវត្តមុខងារនេះ តាមច្បាប់ដែលបង្កើតស្ថាប័នរបស់ខ្លួន។ ដើម្បីលើកកម្ពស់ និងការពារសិទ្ធិ NHRI មានតួនាទីទូលំទូលាយមួយចំនួនរួមមាន៖

- ធ្វើការជាមួយនឹងរដ្ឋាភិបាល និងសហគមន៍ក្នុងការលើកកម្ពស់ការអប់រំ និងការយល់ដឹងសិទ្ធិមនុស្ស
- ជាការជាមួយរដ្ឋាភិបាលក្នុងការជួយបង្កើតគោលនយោបាយនិងកម្មវិធីសិទ្ធិមនុស្ស
- ធ្វើការជាមួយស្ថាប័ននីតិបញ្ញត្តិក្នុងការជួយធានាថាសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមានអាចឆ្លើយតបនឹងបញ្ហាសិទ្ធិមនុស្សនៅក្នុងប្រទេស
- ចូលរួមចំនែកក្នុងនីតិវិធីតុលាការ ដែលមានការលើកឡើងពីសំណួរទាក់ទងនឹងសិទ្ធិមនុស្ស (amicus curiae)
- ធ្វើការស៊ើបអង្កេត ឬការសាកសួរលើបញ្ហាសិទ្ធិមនុស្សជាប្រព័ន្ធ
- ទទួល និងដោះស្រាយបណ្តឹងដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ពីបុគ្គលរួមមានតាមរយៈការផ្សះផ្សា និងមជ្ឈត្តកម្ម។
- ធ្វើការអង្កេត និងតាមដានកន្លែងឃុំខ្លួន និង

- ធ្វើការរួមចំនែកលើការងាររបស់យន្តការសិទ្ធិមនុស្សរបស់ UN។

NHRI នីមួយៗមានតារាងជាក់លាក់នៃសកម្មភាពអ្វីដែលខ្លួនអាចធ្វើបាន។ សកម្មភាពទាំងនេះមានបញ្ជាក់លម្អិតក្នុងច្បាប់ដែលបង្កើតស្ថាប័ននេះ ដែលពេលខ្លះអាចផ្នែកមួយនៅក្នុងរដ្ឋធម្មនុញ្ញ ហើយពេលខ្លះអាចជាច្បាប់ដាច់ដោយឡែកមួយ។ សកម្មភាពដែលអាចធ្វើបានដោយ NHRI អាចត្រូវបានកម្រិតដោយធនធានរបស់ខ្លួន និងតម្រូវការដើម្បីឲ្យស្ថាប័ននេះឆ្លើយតប។ ប្រសិនបើ NHRI តូច និងមិនមានថវិកាគ្រប់គ្រាន់ គឺមានការពិបាកក្នុងការសម្រេចបានកម្មវត្ថុរបស់ខ្លួនណាស់។ ឬប្រសិនបើស្ថាប័ននេះធ្វើការក្នុងប្រទេសមួយ ដែលមានបញ្ហាសិទ្ធិមនុស្សជាច្រើនដើម្បីដោះស្រាយ ស្ថាប័ននេះនឹងមានការការច្រើនពេក។ តាមរយៈតារាងខាងក្រោម យើងអាចអង្កេតឃើញថា NHRIs ទាំងអស់ពាក់ព័ន្ធនឹងការអប់រំ ការស្រាវជ្រាវ ការស៊ើបអង្កេត និងការទទួលបណ្តឹងពីសិទ្ធិមនុស្ស។ NHRIs ខ្លះមានអំណាចពិសេសក្នុងការចូលទៅពន្ធនាគារ ឬធ្វើការលើបណ្តឹងដែលដាក់ជូនតុលាការ។

តារាង ៤-៤: អំណាចនៃស្ថាប័នសិទ្ធិមនុស្សនៅអាស៊ីអាគ្នេយ៍

| | Komnas HAM គណៈកម្មការជាតិសិទ្ធិមនុស្ស (ឥណ្ឌូនេស៊ី) | SUHAKAM គណៈកម្មការសិទ្ធិមនុស្សរបស់ម៉ាឡេស៊ី | គណៈកម្មការជាតិសិទ្ធិមនុស្សរបស់មីយ៉ាន់ម៉ា | គណៈកម្មការសិទ្ធិមនុស្សរបស់ហ្វីលីពីន | គណៈកម្មការជាតិសិទ្ធិមនុស្សរបស់ថៃ | Provedori សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌ទីម័រខាងកើត |
|---|---|---|---|---|---|---|
| ទទួលបណ្ដឹង | √ | √ | √ | √ | √ | √ |
| ធ្វើការស៊ើបអង្កេត/ស៊ើបសួរ | √ | √ | √ | √ | √ | √ |
| កោះហៅសាក្សី | √ | √ | √ | | √ | √ |
| ចូលក្នុងគុក | | √ | √ | √ | | √ |
| មជ្ឈត្តកម្ម | √ | | | √ | √ | √ |
| ជំនួយក្នុងដំណើរការតុលាការ | | | | √ | | √ |
| ផ្ដល់ដំបូន្មានដល់រដ្ឋាភិបាល | √ | √ | √ | √ | √ | √ |
| ធ្វើការស្រាវជ្រាវ | √ | √ | √ | √ | √ | √ |
| ការអប់រំសិទ្ធិមនុស្ស | √ | √ | √ | √ | √ | √ |

បន្ថែមពីលើទំនួលខុសត្រូវកម្រិតជាតិ NHRIs ក៏ដើរតួនាទីជាស្ពានដ៏សំខាន់មួយរវាងប្រទេសរបស់ខ្លួន និងប្រព័ន្ធសិទ្ធិមនុស្ស UN។ NHRIs ទទួលបានឋានៈជាអ្នកអង្កេតការណ៍ និងបុព្វសិទ្ធិក្នុងការចូលរួមរបស់ខ្លួនជាមួយនឹងយន្តការសិទ្ធិមនុស្សរបស់ UN មួយចំនួន ដោយរួមមានក្រុមប្រឹក្សាសិទ្ធិមនុស្ស និងស្ថាប័នតាមដានសន្ធិសញ្ញាសិទ្ធិមនុស្ស (ដែលនឹងពិភាក្សានៅជំពូកបន្ទាប់)។ សំខាន់ជាងនេះទៀត ឱកាសនៃការចូលរួមទាំងនេះភាគច្រើន រួមមានលទ្ធភាពក្នុងការចូលរួម និងធ្វើបទបង្ហាញនៅក្នុងកិច្ចប្រជុំរបស់ UN ត្រូវបានកម្រិតដោយពិន្ទុ "A" (ឬគោលការណ៍ទីក្រុងប៉ារីស បណ្ដឹងដែលត្រូវបានបញ្ជាក់ក្នុងផ្នែកបន្ទាប់) NHRIs។ ក្នុងនាមជាស្ថាប័នឯករាជ្យដែលមានអ្នកជំនាញការថ្នាក់ជាតិ NHRIs បញ្ជូនព័ត៌មាន និងទស្សនៈវិស័យសំខាន់ៗដល់ការងាររបស់ UN និងចំពោះដំណើរការសម្រេចចិត្តរបស់UN ផងដែរ។ តាមរយៈការលើកកម្ពស់ការយល់ដឹង និងការអនុវត្តសេចក្ដីសម្រេចរបស់ UN នៅក្នុងសង្គមរបស់ពួកគេ NHRIs ក៏ជួយផងដែរក្នុងការបកស្រាយសេចក្ដីសម្រេចរបស់ UN ទៅជាការផ្លាស់ប្ដូរវិជ្ជមាន។

## ៤.៣.៤ ស្តង់ដារតាមដានរបស់ NHRI

ទោះបីជាតួនាទីរបស់ NHRI មានភាពបត់បែនក៏ដោយ ពួកគេត្រូវអនុលោមតាមស្តង់ដារអន្តរជាតិដែលមាននៅក្នុងគោលការណ៍ទីក្រុងប៉ារីស ដែលបញ្ជាក់ពីឋានៈ រចនាសម្ព័ន្ធ អាណត្តិ សមាសភាព អំណាច និងនីតិវិធីប្រតិបត្តិការរបស់ NHRIs។ ដែលគោលការណ៍តម្រូវឲ្យ NHRIs ក្នុងការៈ

- មានអាណត្តិទូលំទូលាយ និងច្បាស់លាស់មួយដែលផ្អែកលើស្តង់ដារសិទ្ធិមនុស្សជាសកល
- ឯករាជ្យ និងស្វ័យភាពពីរដ្ឋាភិបាលរបស់ពួកគេ
- មានភាពចម្រុះ ដែលមានសមាជិកដែលឆ្លុះបញ្ចាំងទូលំទូលាយពីក្រុមផ្សេងៗគ្នានៅក្នុងសង្គម
- មានធនធានគ្រប់គ្រាន់ដែលបានផ្តល់ជូនដោយរដ្ឋាភិបាលរបស់ពួកគេ
- មានអំណាចគ្រប់គ្រាន់សម្រាប់ធ្វើការស៊ើបអង្កេត
- ផ្តល់លទ្ធភាពងាយស្រួលដល់ប្រជាជន ហើយគួរតែសហការជាមួយសង្គមស៊ីវិល។

NHRIs នីមួយៗត្រូវបានវាយតម្លៃតាមពេលវេលាកំណត់ ដោយគណៈកម្មាធិការមួយក្នុង ICC ដោយមានការគាំទ្រពី OHCHR ដោយប្រើប្រាស់លក្ខខណ្ឌតម្រូវក្នុងគោលការណ៍ទីក្រុងប៉ារីស ហើយត្រូវបានផ្តល់ការទទួលស្គាល់គុណវុឌ្ឍិ។ អង្គការសង្គមស៊ីវិលត្រូវបានអញ្ជើញឲ្យប្រគល់របាយការណ៍ និងព័ត៌មាន លើការត្រួតពិនិត្យលើគុណវុឌ្ឍិ។ ស្ថាប័នសិទ្ធិមនុស្សអាស៊ីអាគ្នេយ៍មានភាពសកម្មគួរឲ្យកត់សម្គាល់ ក្នុងការប្រគល់ជូននូវព័ត៌មានពាក់ព័ន្ធនឹងការត្រួតពិនិយ្យ ជាពិសេសក្រោមការដឹកនាំរបស់បណ្តាញ NGO អាស៊ានស្តីពី NHRIs (ANNI)។

ប្រសិន NHRIs អនុលោមតាមគោលការណ៍ប៉ារីសត្រូវបានផ្តល់ពិន្ទុ "A" ប៉ុន្តែប្រសិន ត្រូវបានវាយតម្លៃថា "មិនអនុលោមបានពេញលេញ" ត្រូវបានផ្តល់ពិន្ទុ "B" ។ NHRIs ដែលមិនអនុលោមតាមត្រូវទទួលពិន្ទុ "C" ។ នៅពេលចេញលទ្ធផល NHRIs ចំនួនប្រាំក្នុងចំណោមប្រាំមួយមានពិន្ទុ "A" ដែលជាករណីលើកលែងចំពោះ គណៈកម្មាធិការសិទ្ធិមនុស្សជាតិរបស់មីយ៉ាន់ម៉ា ដែលជា NHRI ថ្មីមួយដែលមិនទាន់ត្រូវបានវាយតម្លៃនៅឡើយ (គិតត្រឹមឆ្នាំ២០១៤)។ តួនាទីបន្ទាប់បន្សំចម្បងនៅក្នុងដំណើរការនេះជាការបង្កើតនូវ "សេចក្តីអង្កេតទូទៅ" ដែលជារបាយការណ៍បកស្រាយ គោលការណ៍ទីក្រុងប៉ារីស។ សេចក្តីអង្កេតទូទៅ ផ្តល់សេចក្តីបញ្ជាក់ និងលម្អិតលើគោលការណ៍នីមួយៗ។ តាមរយៈការបញ្ចូលនូវឧទាហរណ៍ការអនុវត្តល្អ សេចក្តីអង្កេតទូទៅក៏ផ្តល់សេចក្តីណែ

នាំផងដែរដល់ NHRIs និងរដ្ឋលើភាពចម្បងនៃតួនាទី និងមុខងាររបស់ NHRI ដូចនេះធ្វើការធានាថាគោលការណ៍ទីក្រុងប៉ារីសជាឯកសារមានសក្តានុពល និងរស់រវើក។

បន្ថែមលើ ICC មានស្ថាប័នសម្របសម្រួល NHRI ថ្នាក់តំបន់ចំនួនបួនទៀត គ្របដណ្តប់ការងារនៅទ្វីបអាហ្វ្រិក អាមេរិក អាស៊ីនិងប៉ាស៊ីហ្វិក និងអឺរ៉ុប។ វាទិកាអាស៊ីប៉ាស៊ីហ្វិកនៃស្ថាប័នសិទ្ធិមនុស្សជាតិ (APF) ជាស្ថាប័នសម្របសម្រួលថ្នាក់តំបន់របស់អាស៊ីអាគ្នេយ៍។ APF ផ្តល់ជូន NHRIs ដែលជាសមាជិកនូវសេវាកម្មបណ្តុះបណ្តាល និងការកសាងសមត្ថភាពដើម្បីគាំទ្រ និងពង្រឹងការងាររបស់ពួកគេ។ APF ដើរតួជាបណ្តាញសហប្រតិបត្តិការថ្នាក់តំបន់ស្តីពីបញ្ហាសិទ្ធិមនុស្សផងដែរ និងលើការងារជាមួយនឹងរដ្ឋាភិបាលនិងសង្គមស៊ីវិលក្នុងតំបន់ដើម្បីគាំទ្រការបង្កើត NHRIs ក្នុងប្រទេសដែលមិនទាន់មាន NHRI នៅឡើយ។

## ៤.៣.៩ ដែនកំណត់នៃ NHRIs

NHRIs ដើរតួនាទីយ៉ាងសំខាន់មួយដើម្បីធានាថាមានការលើកកម្ពស់ និងការការពារស្តង់ដារអន្តរជាតិនៅក្នុងប្រទេស។ NHRIs ជារឿយៗជាកន្លែងទំនាក់ទំនងដំបូងសម្រាប់ប្រជាជនក្នុងការដោះស្រាយស្ថានភាពសិទ្ធិមនុស្សមួយ។ យ៉ាងណាមិញ NHRIs ក៏មានដែនកំណត់មួយចំនួនផងដែរ រួមមានដូចខាងក្រោម៖

- អាណត្តិផ្លូវច្បាប់៖ NHRIs ត្រូវបានបង្កើតឡើងដោយច្បាប់ ដូចនេះត្រូវមានប្រតិបត្តិការនៅក្នុងអាណត្តិ និងក្របខណ្ឌច្បាប់របស់ខ្លួន។ អាណិត្តផ្លូវច្បាប់របស់ NHRIs នៅអាស៊ីអាគ្នេយ៍មានភាពខុសៗគ្នា។ ជាឧទាហរណ៍ NHRI ខ្លះអាចធ្វើការពិនិត្យលើបញ្ហាសិទ្ធិមនុស្សជាច្រើនក្នុងសន្ធិសញ្ញាផ្សេងៗគ្នា ខណៈដែល NHRI ផ្សេងទៀតត្រូវបានកម្រិតក្នុងចង្អៀតស្តង់ដារសិទ្ធិមួយចំនួនប៉ុណ្ណោះ។ អំណាចដែលបានផ្តល់ដល់ NHRIs នីមួយៗក្នុងការបំពេញអាណត្តិរបស់ពួកគេមានភាពខុសៗគ្នាផងដែរ ដោយខ្លះមានដែនកំណត់លើអ្វីដែលខ្លួនអាច និងមិនអាចធ្វើ។ យ៉ាងណាមិញ ក្នុងនាមជាវិធានទូទៅ NHRIs មិនមែនជាតុលាការនោះទេ ហើយមិនមានអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តដែលចងកាតព្វកិច្ចផ្លូវច្បាប់នោះទេ។ ផ្ទុយទៅវិញ NHRIs មានអំណាចក្នុងការផ្តល់អនុសាសន៍ថាតើគួរតែមានការចាត់វិធានការអ្វីខ្លះ។ អនុសាសន៍ដែលស្នើដល់រដ្ឋាភិបាលអាចត្រូវបានបដិសេធ ឬមិនត្រូវបានអើពើ។
- ឯករាជ្យភាព៖ ឯករាជ្យភាពរបស់ NHRI មានសារៈសំខាន់ចំពោះប្រតិបត្តិការប្រកបដោយប្រសិទ្ធិភាពរបស់ស្ថាប័ននេះ។ រដ្ឋាភិបាលអាចមានឥទ្ធិពលអវិជ្ជមាន

លើឯករាជ្យភាពរបស់ NHRI ក្នុងវិស័យគន្លឹះចំនួនពីរ៖ ការតែងតាំង និងថវិការ។ ពាក់ព័ន្ធនឹងការតែងតាំង ជាការសំខាន់ដែលថាប្រមុខរបស់ NHRI និងសមាជិកគណៈកម្មាធិការរបស់ខ្លួនត្រូវបានតែងតាំងប្រកបដោយតម្លាភាព ហើយបំពេញមុខងារប្រកបដោយអព្យាក្រិតភាព។ NHRIs មួយចំនួនត្រូវបានរិះគន់ដោយសារប្រមុខរដ្ឋតែងតាំងសមាជិកគណៈកម្មាធិការដោយផ្ទាល់ ហើយពួកគេមិនឯករាជ្យពីរដ្ឋាភិបាលនោះទេ។ ពាក់ព័ន្ធនឹងថវិការបស់ NHRI មានឧទាហរណ៍ នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកពី NHRIs ដែលត្រូវបានកាត់ថវិការពីសំណាក់រដ្ឋាភិបាលដើម្បីជាមធ្យោបាយមួយប៉ះពាល់ដល់ឯករាជ្យភាព និងប្រសិទ្ធិភាពរបស់ស្ថាប័ននេះ។

- ធនធាន៖ NHRIs ជាទូទៅជាស្ថាប័នដែលមិនមានធនធានល្អប្រសើរគ្រប់គ្រាន់នោះទេពាក់ព័ន្ធជាមួយនឹងបុគ្គលិក ឬហិរញ្ញវត្ថុ ជាពិសេស នៅពេលដែលប្រៀបធៀបជាមួយនឹងតួនាទីដែលខ្លួនត្រូវបំពេញ។ កង្វះខាតធនធានកម្រិតដល់លទ្ធភាពរបស់ NHRI ក្នុងការមានភាពសកម្មជាមុន។ នេះក៏ប៉ះពាល់ផងដែរដល់ការងារដែលត្រូវឆ្លើយតបភ្លាមៗ ជាពិសេស ក្នុងការដោះស្រាយនឹងបណ្តឹងស្តីពីការរំលោភបំពានសិទ្ធិមនុស្ស ជារឿយៗធ្វើឲ្យមានការរាំងស្ទះដល់រឿងក្តីទាំងនេះ។ នេះជាករណីដែលកើតមាននៅក្នុង NHRI មីយ៉ាន់ម៉ា ដែលបានទទួលចំនួនបណ្តឹងយ៉ាងច្រើន ប៉ុន្តែខ្លួនមិនមានពេលវេលា ឬធនធានក្នុងការស៊ើបអង្កេតបណ្តឹងទាំងអស់នោះទេ។

# ៤.៤ យន្តការថ្នាក់តំបន់

## របបសិទ្ធិមនុស្សថ្នាក់តំបន់៖ អឺរ៉ុប អាមេរិក និងអាហ្វ្រិក

UN បានគាំទ្រអង្គការប្រចាំតំបន់ដែលធ្វើការក្នុងការអភិវឌ្ឍ សន្តិសុខ និងសិទ្ធិមនុស្សចាប់តាំងពីការចាប់ផ្តើមរបស់ខ្លួន ក្នុងឆ្នាំ១៩៤៥ ។ ជំនឿជឿជាក់គឺថា UN មិនអាចឆ្លើយតបនឹងកង្វល់សិទ្ធិមនុស្សទាំងអស់ជុំវិញពិភពលោកនោះទេ ដូចនេះជាការល្អប្រសើរដែលកង្វល់ទាំងនេះអាចដោះស្រាយបាននៅថ្នាក់ជាតិ (តាមរយៈ NHRIs) ឬនៅថ្នាក់តំបន់។ អង្គការថ្នាក់តំបន់ជាជម្រើសត្រឹមត្រូវមួយដោយសារពួកគេអាចដោះស្រាយកង្វល់ទូទៅនៃសិទ្ធិមនុស្សបានល្អប្រសើរក្នុងតំបន់របស់ខ្លួន។ ជាឧទាហរណ៍ អឺរ៉ុបជាទ្វីបអ្នកមាន និងមានការអភិវឌ្ឍ ហើយកង្វល់សិទ្ធិមនុស្សរបស់ទ្វីបនេះខុសគ្នាយ៉ាងខ្លាំងពីកង្វល់សិទ្ធិមនុស្សនៅក្នុងទ្វីបអាហ្វ្រិកដែលភាពក្រីក្រជាង និងមានការអភិវឌ្ឍតិចជាង។ បន្ទាប់មកយន្តការថ្នាក់តំបន់អាចអភិវឌ្ឍន៍យន្តការពិសេសក្នុងការឆ្លើយតបនឹងស្ថានភាពតំបន់។ លក្ខណៈពិសេសជាច្រើននៃការការពារ និងការលើកកម្ពស់សិទ្ធិមនុស្ស ជាដំបូងមានប្រភពភពពីប្រព័ន្ធថ្នាក់តំបន់។ ពេលបច្ចុប្បន្ន អង្គការ

សិទ្ធិមនុស្សថ្នាក់តំបន់ដែលមានការអភិវឌ្ឍចំនួនបី និងស្ថាប័នថ្នាក់អនុតំបន់តូចៗមួយចំនួនទៀត។ តំបន់នីមួយៗបានអភិវឌ្ឍកម្រងស្តង់ដាររបស់ខ្លួន និងយន្តការការពាររបស់ខ្លួនផងដែរ។ ផ្នែកនេះនឹងបញ្ជាក់លម្អិតដោយសង្ខេបពីស្តង់ដារនិងវិធីដែលស្តង់ដារទាំងនេះត្រូវបានការពារ មុននឹងធ្វើការពិភាក្សាពីស្តង់ដារ និងយន្តការការពារអាស៊ានដែលស្ថិតក្នុងដំណាក់កាលអភិវឌ្ឍន៍។ អង្គការប្រចាំតំបន់ចម្បងគឺៈ

## អឺរ៉ុប

ស្តង់ដារអឺរ៉ុបបានចាប់ផ្តើម ជាមួយនឹងវត្តមាននៃអនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន (ECHR) ដែលបានចូលជាធរមានក្នុងឆ្នាំ ១៩៥៣ ដែលមានដំណើរការមុន ICCPR ជាង២០ឆ្នាំ។ ECHR គ្រប់ដណ្តប់ជាសំខាន់លើសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ អឺរ៉ុបបានបន្ថែមស្តង់ដារមួយចំនួនទៀតដោយរួមមានពិធីសារចំនួន១៥លើ ECHR (ដែលពិធីសារមួយចំនួនបានផ្តល់នូវសិទ្ធិបន្ថែម) សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌មានក្នុងធម្មនុញ្ញសង្គមអឺរ៉ុប (១៩៦១) ព្រមទាំងសន្ធិសញ្ញាស្តីពីទារុណកម្ម និងសិទ្ធិជនជាតិភាគតិច។

បច្ចុប្បន្ននេះសិទ្ធិក្នុងសន្ធិសញ្ញាទាំងនេះត្រូវបានការពារ តាមរយៈតុលាការសិទ្ធិមនុស្សអឺរ៉ុប (ECtHR)។ ECtHR ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៥៩ និងមានដំណើរការពេញលេញក្នុងឆ្នាំ ១៩៩៨។ តុលាការនេះធ្វើការវិនិច្ឆ័យលើបុគ្គល និងបណ្តឹងរវាងរដ្ឋពីការរំលោភបំពានលើសិទ្ធិដែលបានកំណត់ដោយ ECHR ។ បណ្តឹងទាំងនេះត្រូវបានប្តឹងដោយផ្ទាល់ទៅតុលាការ។ តុលាការគ្រប់ដណ្តប់ជាង ៤៧ ប្រទេសនៅទ្វីបអឺរ៉ុប ហើយកាលពីពេលថ្មីៗនេះ មានភាពមមាញឹកខ្លាំងមែនទែនដោយសារតែទទួលបានបណ្តឹងប្រហែលជា ១០០ ០០០ ករណីក្នុងមួយឆ្នាំ ប៉ុន្តែតុលាការនេះអាចជំនុះជម្រះមួយផ្នែកតូចនៃរឿងក្តីនេះប៉ុណ្ណោះ។ ករណីនេះភាគច្រើនត្រូវបានប្រកាសថាមិនត្រូវបានទទួលយកដោយតុលាការដើម្បីធ្វើការជំនុះជម្រះ (មានន័យថាតុលាការនឹងមិនជំនុះជម្រះ) ដោយសារតែបណ្តឹងទាំងនេះមិនត្រូវបានចាត់ទុកថាធ្ងន់ធ្ងរនោះទេ ដោយសារបណ្តឹងខ្លះពាក់ព័ន្ធនឹងបុគ្គលត្អូញត្អែរពីសំបុត្រចតឡាន និងម៉ូតូ ឬសេវាកម្មរដ្ឋបាលថ្នាក់មូលដ្ឋានមិនល្អជាដើម។

ប្រព័ន្ធអឺរ៉ុបត្រូវបានគ្រប់គ្រងដោយក្រុមប្រឹក្សាអឺរ៉ុប (ដែលមានទំហំធំ និងដាច់ចេញពីសហភាពអឺរ៉ុប) ទោះបីជាសហភាពអឺរ៉ុប និងអង្គការដើម្បីសន្តិសុខ និងកិច្ចសហប្រតិបត្តិការអឺរ៉ុប (OSEC) មានស្តង់ដារ និងយន្តការការពារសិទ្ធិមនុស្សដែលមានការពាក់ព័ន្ធគ្នាដោយខ្លួនឯងក៏ដោយ។

## ទ្វីបអាមេរិក

អង្គការរដ្ឋនៅទ្វីបអាមេរិក (OAS) ជាអង្គការអន្តរជាររដ្ឋាភិបាលដែលគ្រប់គ្រងប្រព័ន្ធសិទ្ធិមនុស្សនៅទ្វីបអាមេរិក។ សិទ្ធិទាំងនេះផ្អែកលើសេចក្តីប្រកាសទ្វីបអាមេរិក ឆ្នាំ ១៩៤៨ ស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់មនុស្ស និងកតិកាសញ្ញាទ្វីបអាមេរិកស្តីពីសិទ្ធិមនុស្សដែលចងកាតព្វកិច្ចផ្លូវច្បាប់ (ACHR) ដែលបានចូលជាធរមានក្នុងឆ្នាំ ១៩៧៨។ មានសន្ធិសញ្ញាមួយចំនួនស្តីពីជនភៀសខ្លួន ទារុណកម្ម ការបាត់ខ្លួន ហិង្សាលើស្ត្រី សេដ្ឋកិច្ច សង្គម និងវប្បធម៌ ជនពិការ ប្រជាជនជនជាតិដើមភាគតិច និងបរិស្ថាន។ សិទ្ធិនៅក្នុងសន្ធិសញ្ញាទាំងនេះអាចត្រូវបានការពារដោយតាមរយៈ គណៈកម្មាធិការអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស (IACHR) ។ IACHR ធ្វើការក្នុងការពង្រឹងច្បាប់ និងស្ថាប័នថ្នាក់តំបន់ និងជំនុះជម្រះលើបណ្តឹង ហើយ IACtHR បង្កើតយុត្តិសាស្ត្រស្តីពីសិទ្ធិមនុស្ស។ ស្ថាប័នទាំងនេះគ្រប់ដណ្តប់ប្រទេសចំនួន ១៩ ក្នុងទ្វីបអាមេរិកខាងត្បូង និងខាងជើង និងការ៉ាប់បៀន។

ប្រព័ន្ធក្នុងទ្វីបអាមេរិកខុសគ្នាច្រើនពីប្រព័ន្ធអឺរ៉ុប។ ជាបឋម រាល់បណ្តឹងទាំងអស់ប្រឆាំងនឹងរដ្ឋ ត្រូវឆ្លងកាត់គណៈកម្មាធិការសិន (ដែលជាស្ថាប័នមួយមានសមាជិកចំនួនប្រាំពីររូប)។ គណៈកម្មាធិការត្រូវបានចាត់ទុកថាជាស្ថាប័ន ʻមានសមត្ថកិច្ចជំនុះជម្រះʼ មួយ ដែលមានមុខងារដូចតុលាការ ប៉ុន្តែមិនមានអំណាចចងកាតព្វកិច្ចផ្លូវច្បាប់ដូចគ្នាជាមួយនឹងតុលាការនោះទេ។ សន្មតថារដ្ឋបានផ្តល់សច្ចាប័នលើសន្ធិសញ្ញាដែលចាំបាច់ គណៈកម្មាធិការនឹងព្យាយាមក្នុងការស្វែងរក ʻដំណោះស្រាយប្រកបដោយមិត្តភាពʼ ចំពោះភាគីទាំងសងខាង។ មានតែនីតិវិធីត្រូវបានបញ្ចប់ ទើបបណ្តឹងអាចបញ្ជូនទៅតុលាការ ប្រសិនបើភាគីម្ខាងមិនពេញចិត្តនឹងលទ្ធផល។ បណ្តឹងអាចត្រូវបានបញ្ជូនទៅតុលាការផងដែរប្រសិនបើរដ្ឋផ្តល់ការអនុញ្ញាត។ ជាជាងបណ្តឹងរាប់ម៉ឺន ស្ថាប័ននេះបានជំនុះជម្រះ មានបណ្តឹងរាប់រយបណ្តឹងប៉ុណ្ណោះ (ស្ថាប័ននេះបានចេញសេចក្តីសម្រេច ២៨០ គិតត្រឹមឆ្នាំ ២០១៤ ប៉ុន្តែអាចធ្វើការជំនុះជម្រះបន្ថែមទៀត)។

## ទ្វីបអាហ្វ្រិក

ប្រព័ន្ធថ្នាក់តំបន់ដែលទើបតែបានបង្កើតថ្មីបំផុត ជាប្រព័ន្ធសិទ្ធិមនុស្សថ្នាក់តំបន់អាហ្វ្រិក។ ប្រព័ន្ធថ្នាក់តំបន់នេះផ្អែកលើធម្មនុញ្ញអាហ្វ្រិកឆ្នាំ ១៩៨១ ស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន។ យន្តការសំខាន់ចំពោះសហភាពអាហ្វ្រិកគឺគណៈកម្មាធិការសិទ្ធិមនុស្ស និងសិទ្ធិប្រជាជនអាហ្វ្រិក ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៨៦ ដែលមានសមាជិកចំនួន ១១ រូប។ វាស្រដៀងគ្នាទៅនឹងគណៈកម្មាធិការអន្តរអាមេរិកដែរ ដោយសារតែវាជាស្ថាប័នដែលមានសមត្ថកិច្ចជំនុះជម្រះមួយ ដែលមានកាតព្វកិច្ចក្នុងការ

លើកកម្ពស់សិទ្ធិមនុស្ស និងមានអំណាចក្នុងការជំនុះជម្រះ និងស៊ើបអង្កេតការរំលោភបំពានសិទ្ធិមនុស្ស។ ស្ថាប័ននេះមានអ្នករាយការណ៍ពិសេស និងក្រុមការងាររបស់ខ្លួន (ដូចគ្នានឹង UNដែរ)។ គណៈកម្មាធិការទ្វីបអាហ្វ្រិកក៏រៀបចំផងដែរនូវបណ្តឹងសម្រាប់តុលាការសិទ្ធិមនុស្ស និងសិទ្ធិប្រជាជនអាហ្វ្រិកដែលទើបតែបង្កើតថ្មី ដែលបានចាប់ផ្តើមក្នុងឆ្នាំ ២០០៤ ហើយបានបញ្ចប់រឿងក្តីដំបូងក្នុងឆ្នាំ ២០០៩។ តុលាការអាចចេញវិធានដែលចងកាតព្វកិច្ចផ្លូវច្បាប់ ស្តីពីបណ្តឹងរំលោភសិទ្ធិមនុស្សក្នុងតំបន់ ទោះបីជាមកដល់ពេលបច្ចុប្បន្ននេះ ស្ថាប័ននេះទើបតែបានបញ្ចប់រឿងក្តីមួយចំនួនតូចក៏ដោយ (ប្រហែលជា៣០) បើប្រៀបធៀបទៅនឹងគណៈកម្មាធិការបានចេញសេចក្តីសម្រេចប្រហែលជា ១៧០ មកហើយ។ អ្វីដែលធ្វើឲ្យប្រព័ន្ធអាហ្វ្រិកខុសពីគេ គឺថាប្រព័ន្ធនេះផ្តល់លទ្ធភាពច្រើនដល់សង្គមស៊ីវិល ក្នុងការរួមចំនែកជាមួយនឹងតុលាការដោយធ្វើការអនុញ្ញាត NGOs ក្នុងការដាក់ញត្តិទៅតុលាការដើម្បីសុំមតិយោបល់ មានន័យថា NGO មួយអាចសួរតុលាការប្រសិនបើគោលនយោបាយ ឬសកម្មភាពរបស់រដ្ឋមួយអនុលោមតាមធម្មនុញ្ញអាហ្វ្រិកឬក៏អត់។

## ទិដ្ឋភាពទូទៅនៃប្រព័ន្ធថ្នាក់តំបន់

ប្រព័ន្ធសិទ្ធិមនុស្សថ្នាក់តំបន់នីមួយៗ មានលក្ខណៈពិសេសរៀងខ្លួនពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ និងមុខងារ។ ប្រព័ន្ធទាំងបីនេះមានលក្ខណៈដូចគ្នាមួយចំនួន។ ជាបឋម ប្រព័ន្ធថ្នាក់តំបន់ទាំងអស់រួមមានតុលាការមួយ អនុសញ្ញា និងគណៈកម្មាការ ឬគណៈកម្មាធិការ។ នៅក្នុងតំបន់ខ្លះ ដូចជាអឺរ៉ុប តុលាការមានភាពសកម្មភាព ហើយបានចេញដីកាលើបណ្តឹងរាប់ពាន់។ តុលាការដទៃដូចជា តុលាការអាហ្វ្រិក ទើបបង្កើតថ្មីៗ និងបានធ្វើសេចក្តីសម្រេចរាប់រយបណ្តឹងប៉ុណ្ណោះ។ សន្ធិសញ្ញាអឺរ៉ុបពឹងផ្អែកយ៉ាងខ្លាំងលើសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចំនែកឯសន្ធិសញ្ញាសិទ្ធិសេដ្ឋកិច្ច និងសង្គម (ក្នុងធម្មនុញ្ញសង្គមអឺរ៉ុប) មិនខ្លាំងក្លានោះទេ។ ដែលនេះផ្ទុយនឹងសន្ធិសញ្ញាអាហ្វ្រិក ដែលទទួលស្គាល់សិទ្ធិ "ប្រជាជន" (ចងចាំថាចំណងជើងដែលរួមមានពាក្យសិទ្ធិ "មនុស្ស និងប្រជាជន" )។ សិទ្ធិប្រជាជនរួមមានស្វ័យសម្រេច សន្តិភាព និងសន្តិសុខ និងការអភិវឌ្ឍ។ តំបន់នីមួយៗក៏ខុសគ្នាផងដែរពាក់ព័ន្ធនឹងកង្វល់សិទ្ធិមនុស្សដែលលេចធ្លោ។ ដោយសារតែទ្វីបអឺរ៉ុបជាទ្វីបអ្នកមាន និងមានលទ្ធិប្រជាធិបតេយ្យទូលំទូលាយ មានបណ្តឹងសិទ្ធិមនុស្សជាច្រើនពីការគ្រប់គ្រងរបស់រដ្ឋាភិបាល ឬការរើសអើង។ ផ្ទុយទៅវិញ ទ្វីបអាមេរិក ដែលមានប្រព័ន្ធនយោបាយពីមុនភាគច្រើន ក្រោមថ្នាក់ដឹកនាំយោធាផ្តាច់ការ មានកង្វល់ចម្បងពាក់ព័ន្ធនឹងការបាត់ខ្លួន ការឃុំខ្លួនតាមទំនើងចិត្ត និងទារុណកម្ម។ ទ្វីបអាហ្វ្រិក ជាតំបន់ក្រីក្រជាងគេលើលោក មានបញ្ហាជាច្រើនពាក់ព័ន្ធនឹងភាពក្រីក្រ និងការអភិវឌ្ឍ ប៉ុន្តែដោយសារប្រព័ន្ធតំបន់នេះនៅក្មេងខ្ចី និងទន់ខ្សោយ មានការអភិវឌ្ឍបន្តិចបន្តួចប៉ុណ្ណោះក្នុងយន្តការនេះ។

គម្លាតច្បាស់លាស់មួយក្នុងយន្តការថ្នាក់តំបន់គឺនៅអាស៊ី។ មានការអះអាងជាច្រើន លើថាហេតុអ្វីទ្វីបអាស៊ីមិនបានបង្កើតយន្តការថ្នាក់តំបន់មួយ ដែលនេះយោងទៅតាមភាពចម្រុះនៃប្រទេសនៅអាស៊ី ទំហំទ្វីបអាស៊ី និងកង្វះនៃអត្តសញ្ញាណតំបន់។ មានការផ្តួចផ្តើមថ្នាក់អនុតំបន់មួយចំនួន ដោយរួមមានអាស៊ានផងដែរ ដែលជាជំហានមួយឆ្ពោះទៅកាន់ការបង្កើតការការពារសិទ្ធិមនុស្សនៅកម្រិតថ្នាក់តំបន់។ ដែលនេះរួមមានធម្មនុញ្ញអារ៉ាប់ស្តីពីសិទ្ធិមនុស្ស ដែលត្រូវបានប្រើប្រាស់ដោយសម្ព័ន្ធរដ្ឋអារ៉ាប់ (ដែលមានសមាជិកចំនួន ២២ ប្រទេស) ប៉ុន្តែមិនមានអង្គការក្នុងការធានានូវការការពារនោះទេ។ មានសន្ធិសញ្ញាមួយចំនួនផងដែរដោយសមាគមអាស៊ីខាងត្បូងសម្រាប់កិច្ចសហប្រតិបត្តិការប្រចាំតំបន់ (SAARC) ដូចជាអនុសញ្ញា SAARC ស្តីពីការប្រឆាំង និងការបង្ការការជួញដូរស្ត្រី និងកុមារដើម្បីពេស្យាកម្ម និងអនុសញ្ញាស្តីពីការលើកកម្ពស់សុខមាលភាពកុមារ។ យ៉ាងណាមិញ ដូចគ្នានឹងធម្មនុញ្ញអារ៉ាប់ មានស្ថាប័នជាពិសេសក្នុងការធានានូវអនុលោមជាមួយនឹងសន្ធិទាំងនេះនោះទេ។ ការអភិវឌ្ឍធំបំផុតឆ្ពោះទៅកាន់យន្តការថ្នាក់តំបន់នៅតំបន់អាស៊ី ជាគណៈកម្មការអន្តររដ្ឋាភិបាលស្តីពីសិទ្ធិមនុស្ស (AICHR)។

## ការពិភាក្សា និងការជជែកវែកញែក

### តើប្រព័ន្ធអាស៊ានគួរតែមានរូបរាងដូចម្តេច?

បន្ទាប់ពីអានពីមូលដ្ឋាននៃប្រព័ន្ធអឺរ៉ុប អាមេរិក និងអាហ្វ្រិក តើមេរៀនអ្វីដែលអាចរៀនសូត្រពីប្រព័ន្ធនេះក្នុងការអភិវឌ្ឍប្រព័ន្ធអាស៊ាន? គួរតែអាស៊ានទទួលយកវិធីសាស្ត្រអឺរ៉ុប និងមានតុលាការរឹងមាំមួយដែលអាចជំនុះជម្រះគ្រប់បណ្តឹង ប៉ុន្តែប្រឈមនឹងហានិភ័យក្នុងការទទួលបាននូវបណ្តឹងច្រើនហួសហេតុពេល? ឬគួរតែទទួលយកនូវវិធីសាស្ត្រមួយដែលស្រដៀងនឹងទ្វីបអាហ្វ្រិក និងអាមេរិក ដែលគណៈកម្មការជាបឋមជំនុះជម្រះលើវិវាទ និងព្យាយាមក្នុងការចរចាដើម្បីស្វែងរកដំណោះស្រាយមួយ ហើយប្រហែលជាជៀសវាងនូវបណ្តឹងតាមប្រព័ន្ធតុលាការ? ប្រព័ន្ធគណៈកម្មការអាចងាយស្រួល និងអំណោយផលដល់រដ្ឋ ប៉ុន្តែប្រហែលជាទន់ខ្សោយ និងមិនអាចធ្វើឲ្យរដ្ឋអនុលោមតាមកាតព្វកិច្ចសិទ្ធិមនុស្សរបស់ពួកគេ។

តើស្ថាប័ននេះគួរតែការពារការរំលោភបំពានប្រភេទអ្វីដល់ប្រជាជន? តើបញ្ហានេះអាចត្រូវបានដោះស្រាយដោយតុលាការដែរឬទេ ឬក៏មានតម្រូវការក្នុងការមានអ្នកស៊ើបអង្កេតជាពិសេសដែរឬទេ? តុលាការអាចមានភាពយឺតយ៉ាវក្នុងការជួយបន្ធូរបញ្ហា

ប្រសិនបើការរំលោភបំពានបានកើតឡើងរួចមកហើយ មិនអាចជួយអ្វីបានច្រើននោះទេប្រសិនបើបុគ្គលណាម្នាក់បានបាត់បង់ជីវិតរួចទៅហើយ។ អ្នកស៊ើបអង្កេតអាចជួយក្នុងការផ្តល់ពន្លឺដល់ស្ថាប័នរដ្ឋាភិបាលទន់ខ្សោយ។

(អាចនិយាយបានថាពន្ធនាគារដែលមានទារុណកម្ម ឬ សាលារៀនដែលមិនមានដំណើរការ) ប៉ុន្តែពួកគេមានអំណាចមិនរឹងមាំក្នុងការចាប់បង្ខំរដ្ឋឲ្យធ្វើការផ្លាស់ប្តូរវិធីសាស្ត្ររបស់ពួកគេ។

# ៤.៥ យន្តការសិទ្ធិមនុស្សអាស៊ាន

មានការជម្រុញក្នុងការបង្កើតយន្តការអនុតំបន់មួយ សម្រាប់សិទ្ធិមនុស្សនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ចាប់តាំងពីដើមទសវត្សឆ្នាំ១៩៩០។ មានចំណាប់ជាថ្មីម្តងទៀតលើបញ្ហាសិទ្ធិមនុស្សបន្ទាប់ពីការបញ្ចប់នៃសង្គ្រាមត្រជាក់ ដែលបានកំណត់យ៉ាងច្បាស់នៅក្នុងសន្និសិទពិភពលោកស្តីពីសិទ្ធិមនុស្សក្នុងទីក្រុងវៀនឆ្នាំ ១៩៩៣។ នៅក្នុងបរិបទនៃសន្និបាតពិភពលោកនេះ អាស៊ានបានថ្លែងថាខ្លួននឹងក្រលេកមើលក្នុងការបង្កើតស្ថាប័នអន្តរដ្ឋាភិបាលមួយ។ យ៉ាងណាមិញអាស៊ានមានដំណើរការយឺតយ៉ាវក្នុងការឆ្ពោះទៅកាន់ការសម្រេចបាននូវគោលបំណងនេះ។ ដើម្បីជាការឆ្លើយតបមួយ សង្គមស៊ីវិលបានបង្កើតក្រុមការងារមួយសម្រាប់យន្តការសិទ្ធិមនុស្សអាស៊ាន ក្នុងឆ្នាំ១៩៩៥ ដែលត្រូវបានទទួលស្គាល់ដោយអាស៊ានក្នុងឆ្នាំ១៩៩៨។ ក្នុងអំឡុងពេលមួយទសវត្សក្រោយមកមានកិច្ចប្រជុំ និងការពិគ្រោះយោបល់ដោយក្រុមការងារជាមួយនឹងអាស៊ានក្រុមសង្គមស៊ីវិល និងអង្គការអន្តរជាតិ។ ចំណាប់អារម្មណ៍ពីសំណាក់អង្គការសង្គមស៊ីវិលទាំងនេះ និងការជួយជ្រោមជ្រែងពីរដ្ឋដែលគាំទ្រទស្សនៈនូវស្ថាប័នថ្នាក់តំបន់នាំឲ្យមានការបង្កើតស្ថាប័នសិទ្ធិមនុស្សថ្នាក់តំបន់មួយ ដែលត្រូវបានហៅថាគណៈកម្មការសិទ្ធិមនុស្សអន្តរដ្ឋាភិបាលអាស៊ាន (AICHR) ក្នុងឆ្នាំ ២០០៩។ នេះជាស្ថាប័នសិទ្ធិមនុស្សថ្នាក់តំបន់រដ្ឋាភិបាលដំបូងក្នុងទ្វីបអាស៊ី។ ចំនួននៃស្ថាប័នថ្នាក់តំបន់ទូទាំងពិភពលោកមានការកើនឡើងយឺតយ៉ាវ ក្នុងរយៈពេលហាសិបឆ្នាំកន្លងទៅនេះ។ ស្ថាប័នទាំងនេះភាគច្រើនចាប់ផ្តើមដោយមានភាពទន់ខ្សោយ និងធ្វើការអភិវឌ្ឍយន្តការការពាររបស់ពួកគេ ដូចដែលរដ្ឋ និងសង្គមស៊ីវិលបានផ្តល់អំណាច និងផ្តោតចំណាប់អារម្មណ៍ច្រើនលើស្ថាប័នទាំងនេះ។ នៅពេលចាប់ផ្តើមដំបូង មានកង្វល់ជាច្រើនពីអំណាចទន់ខ្សោយរបស់អាស៊ាន ខណៈពេលដែលអ្នកដទៃអះអាងថាមានសក្តានុពលសម្រាប់ការលូតលាស់របស់ AICHR។

AICHR ត្រូវបានបង្កើតឡើងនៅពេលក្របខណ្ឌការងាររបស់ស្ថាប័ននេះ(TOR) ត្រូវបានព្រមព្រៀងដោយរដ្ឋាភិបាលដែលជាសមាជិករបស់អាស៊ាន។ ហេតុផលដែលរដ្ឋាភិបាលព្រមព្រៀងលើការបង្កើតស្ថាប័ននេះ ដោយសារការប្តេជ្ញាចិត្តដែលបានធ្វើឡើងក្នុងផែនការសហគមន៍នយោបាយ និងសន្តិសុខអាស៊ាន (APSC) ដែលជាឯកសារគោលនយោបាយពីអភិបាលកិច្ចពេលអនាគតរបស់អាស៊ាន ប៉ុន្តែជាសំខាន់ដោយសារប្រជាពលរដ្ឋអាស៊ាន ដែលតាមរយៈសង្គមស៊ីវិលបានហៅថាជាស្ថាប័នមនុស្សមួយ។ TOR របស់ AICHR គឺជាស្តង់ដារសម្រាប់គណៈកម្មាការថ្នាក់តំបន់ដែលតាមរយៈនេះស្ថាប័ននេះ នឹងអនុវត្តសកម្មភាពដូចជាពិគ្រោះយោបល់ជាមួយរដ្ឋាភិបាល បង្កើតស្តង់ដារសិទ្ធិមន្យសម្រាប់ប្រទេសអាស៊ាន និងលើកកម្ពស់សិទ្ធិមនុស្សក្នុងតំបន់។ ក្នុងចំណោមតារាងនៃគោលបំណងរបស់ AICHR គឺដើម្បីៈ

- លើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានរបស់ប្រជាជនអាស៊ាន
- គោរពសិទ្ធិប្រជាជនរបស់អាស៊ានដើម្បីរស់នៅក្នុងសន្តិភាព ភាពថ្លៃថ្នូរ និងភាពរីកចំរើន
- ដើម្បីលើកកម្ពស់ស្ថេរភាព សុខដុមនីយកម្ម មិត្តភាព និងកិច្ចសហប្រតិបត្តិការក្នុងចំណោមសមាជិកអាស៊ាន
- ដើម្បីលើកកម្ពស់សិទ្ធិមនុស្សនៅក្នុងបរិបទតំបន់
- ដើម្បសម្រេចបាននូវកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ និង
- ដើម្បគោរពស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ

AICHR ត្រូវបានបង្កើតឡើងដោយអ្នកតំណាងដែលបានតែងតាំងមួយរូបពីរដ្ឋាភិបាលនីមួយៗ ( ធ្វើឲ្យស្ថាប័ននេះមានតំណាងចំនួន ១១ រូប)។ អ្នកតំណាងទាំងនេះបម្រើអាណត្តិដែលមានរយៈពេលបីឆ្នាំ ហើយអាចត្រូវបានតែងតាំងសារជាថ្មីបានចំនួនម្តង។ អ្នកតំណាងផ្ទាល់មានប្រវត្តិផ្សេងៗគ្នា។

អ្នកខ្លះជាអ្នកសិក្សាស្រាវជ្រាវ អ្នកខ្លះទៀតជាអ្នកការទូត និងអ្នកខ្លះទៀតមកពី NGOs។ ការងារដំបូងរបស់សមាជិកគណៈកម្មាការ គឺធ្វើការរៀបចំសេចក្តីព្រាងសេចក្តីអាស៊ានស្តីពីសិទ្ធិមនុស្ស។ ក្នុងការបំពេញកិច្ចការនេះ ពួកគេត្រូវតែងតាំងស្ថាប័នសេចក្តីព្រាងឯករាជ្យមួយដែលចេញសេចក្តីប្រកាសក្នុងឆ្នាំ២០១២ នៅពេលដែលសមាជិកអាស៊ានបានអនុម័តជាឯកច្ឆ័ននូវសេចក្តីប្រកាសនេះ។

ចំពោះអ្នកខ្លះ ការអភិវឌ្ឍមួយចំនួននៃ AICHR ជាជំហានដ៏សំខាន់ឆ្ពោះទៅកាន់ការការពារសិទ្ធិមនុស្សក្នុងតំបន់។ យ៉ាងណាមិញ ចំនែកអ្នកខ្លះទៀត គិតថានៅមានភាពទន់ខ្សោយជាច្រើនទៀតដើម្បីជំនះ។ មានការរិះគន់លើ TOR។ ជាពិសេស AICHR មានគោលបំណងក្នុងការគោរពគោលការណ៍ ″ការមិនជ្រៀតជ្រែកក្នុងកិច្ចការអន្តរជាតិរបស់រដ្ឋសមាជិកអាស៊ាន″ ដែលអំពាវនាវឲ្យមានការគោរពអធិបតេយ្យជាជាងស្តង់ដារអន្តរជាតិ។ TOR បានសង្កត់ធ្ងន់លើបញ្ហានេះជាមួយនឹងសេចក្តីថ្លែងការណ៍ថា AICHR គួរតែគោរព ″សិទ្ធិរបស់រដ្ឋនីមួយៗក្នុងការដឹកនាំជាតិរបស់ខ្លួនដោយមិនមានការជ្រៀតជ្រែកពី វិទ្ធង្សនា និងការបង្ខំពីខាងក្រៅ″។ ការរិះគន់មួយដទៃទៀត គឺថាស្ថាប័នសិទ្ធិមនុស្សអន្តររដ្ឋាភិបាលជាកម្មវត្ថុនៃនយោបាយ។ ឯករាជ្យភាពរបស់អ្នកតំណាងមានសារៈសំខាន់ណាស់។ សមាជិកគណៈកម្មាការដែលមិនឯករាជ្យប្រហែលជាអាចមានចំណាប់អារម្មណ៍ ក្នុងការការពាររដ្ឋរបស់ពួកគេពីការរិះគន់ពីកំណត់ត្រាសិទ្ធិមនុស្សរបស់ពួកគេ។ សេណារីយ៉ូដែលអាក្រក់បំផុតនោះគឺថារដ្ឋាភិបាលអាចប្រើប្រាស់ស្ថាប័នថ្នាក់តំបន់ក្នុងការការពារពួកគេ ពីការត្រួតពិនិត្យពាក់ព័ន្ធនឹងកង្វល់សិទ្ធិមនុស្ស។ ការចេញផ្សាយពីសេចក្តីព្រាងសេចក្តីប្រកាសក៏បានទទួលនូវការឆ្លើយតបចម្រុះមួយ។ ចំពោះអ្នកខ្លះ វាជាជំហានមួយឆ្ពោះទៅកាន់ការការពារកាន់តែល្អប្រសើរទៀតនៅថ្នាក់តំបន់។ សេចក្តីប្រកាសទទួលស្គាល់សិទ្ធិរបស់ពលករទេសន្តប្រវេសន៍ ធ្វើឲ្យការបោះឆ្នោតក្លាយទៅជាសិទ្ធិមួយ និងសិទ្ធិក្នុងការទទួលបានសន្តិភាព ដែលពង្រីកការការពារដល់ប្រជាជនក្នុងរដ្ឋអាស៊ានជាច្រើន។ ចំពោះអ្នកដទៃ វាជាការធ្វើឲ្យទន់ខ្សោយដល់ស្តង់ដារអន្តរជាតិ។ សេចក្តីព្រាងសេចក្តីប្រកាសស្នើឲ្យមានតុល្យភាពនៃសិទ្ធិ និងកាតព្វកិច្ច ដែលផ្ទុយនឹងគោលការណ៍ស្នូលនៃសិទ្ធិមនុស្ស ហើយបានផ្តល់អំណាចខ្លាំងថែមទៀតដល់ច្បាប់ជាតិក្នុងការកែប្រែសិទ្ធិមនុស្ស ដែលធ្វើឲ្យទន់ខ្សោយដល់ស្តង់ដារអន្តរជាតិ។ ច្បាស់ណាស់ មានការជជែកវែកញែកជាច្រើនពីថាតើ AICHR នឹងមានប្រសិទ្ធិភាពកម្រិតណា។

## ការពិភាក្សា និងការជជែកវែកញែក

### តើ TOR របស់ AICHR មានចំនុចខ្លាំងកម្រិតណា?

TOR របស់ AICHR ចែងថាគោលបំណងមួយក្នុងចំណោមគោលបំណងដទៃទៀតគឺ៖

១.៤ ដើម្បីលើកកម្ពស់សិទ្ធិមនុស្សនៅក្នុងបរិបទថ្នាក់តំបន់ ដែលត្រូវចងចាំក្នុងចិត្តពីភាពចរិកលក្ខណៈជាតិ និងថ្នាក់តំបន់ និងការគោរពទៅវិញទៅមកលើប្រវត្តិសាស្ត្រ វប្បធម៌ និងសាសនា និងធ្វើការពិចារណាលើតុល្យភាពរវាងសិទ្ធិ និងការទទួលខុសត្រូវ។

តើនេះនឹងការពារសិទ្ធិមនុស្សដែរឬទេ? តាមរយៈការនិយាយថា AICHR ត្រូវពិចារណាពីចរិកលក្ខណៈជាតិ និងគោរពប្រវត្តិសាស្ត្រ បង្កប់ន័យថាសិទ្ធិមនុស្សមិនមានលក្ខណៈជាសកលនោះទេ ប៉ុន្តែជាក់លាក់ចំពោះប្រទេសនីមួយៗ។ ជាឧទាហរណ៍ តើមាត្រានេះនឹងអនុញ្ញាតឲ្យរដ្ឋមានលេស ក្នុងការការពារសិទ្ធិមនុស្សដោយសារខ្លួនស្ថិតក្រោមអាណានិគមដែរឬទេ? ឬដោយសារពួកគេក្រីក្រ? បន្ថែមពីលើនេះទៀត តើតុល្យភាពរវាងសិទ្ធិ នឹងការទទួលខុសត្រូវមានន័យដូចម្តេច? ប្រសិនបើសិទ្ធិមនុស្សត្រូវបានភ្ជាប់ពីកំណើត និងមិនអាចដកហូតបាន ប្រជាជនមិនចាំបាច់ស្វែងរកសិទ្ធិមនុស្សរបស់ពួកគេនោះទេ។ យ៉ាងណាមិញ ប្រជាជនត្រូវគោរពសិទ្ធិរបស់អ្នកដទៃ និងនេះអាចរួមបញ្ចូលការគោរពច្បាប់របស់ប្រទេសផងដែរ។

ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សទាមទារនូវសមត្ថភាពមួយចំនួន សមត្ថភាពសំខាន់បំផុតជាការទទួលបណ្តឹងពីបុគ្គល ដែលសិទ្ធិរបស់ពួកគេត្រូវបានរំលោភបំពាន។ បច្ចុប្បន្ននេះ AICHR ត្រូវបានប្រគល់ភារកិច្ចក្នុងការលើកកម្ពស់សិទ្ធិមនុស្ស ប៉ុន្តែមិនមែនធ្វើការការពារសិទ្ធិមនុស្សនោះទេ។ ស្ថាប័ននេះមិនទាន់ត្រូវបានអនុញ្ញាតឲ្យទទួលបណ្តឹងនៅឡើយទេ។ ដោយគ្មានការទទួលបណ្តឹង សមាជិកគណៈកម្មាការមិនអាចឆ្លើយតបនឹងការរំលោភបំពាន តាមរយៈការដោះស្រាយបញ្ហាជាប្រព័ន្ធដែលធ្វើឲ្យប្រជាជនគ្មានការការពារបាននោះទេ។ អវត្តមាននៃសមត្ថភាពបែបនេះបានធ្វើឲ្យមានមតិជាច្រើនលើកឡើងថា AICHR ជា ʹខ្លាអត់ចង្កូមʹ។ គ្រាន់តែជាស្ថាប័នប្រឹក្សាយោបល់អាច ឬមិនអាចទប់ស្កាត់ជនល្មើស ឬមានឥទ្ធិពលដោយផ្ទាល់លើបញ្ហាសិទ្ធិមនុស្ស។ យ៉ាងណាមិញ ស្ទើរតែគ្រប់ស្ថាប័នសិទ្ធិមនុស្សទាំងអស់ ចាប់តាំងពី UN រហូតដល់ស្ថាប័នថ្នាក់តំបន់ ភាគច្រើនចាប់ផ្តើមជាមួយនឹងការងារលើកកម្ពស់ និងអភិ

វឌ្ឍន៍ខ្លួនឆ្ពោះទៅកាន់ការការពារសិទ្ធិ។ ដោយសារស្ថាប័ននេះនៅក្មេងខ្ចីនៅឡើយ AICHR អាចធ្វើការបញ្ជាក់ថាការរិះគន់គឺមិនត្រឹមត្រូវបាន។

# ៤.៦ តួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាល(NGOs)

ប្រហែលជាស្ថាប័នដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិភាគច្រើន ដែលធ្វើការលើសិទ្ធិមនុស្សគឺជា NGOs។ គ្រប់តំបន់ទាំងអស់ក្នុងពិភពលោក មាន NGOs ដែលមានភាពសកម្ម ហើយជារឿយៗពួកគេជាកន្លែងដំបូងបំផុតដែលប្រជាជននឹងទៅនៅពេលដែលពួកគេជួបប្រទះការរំលោភបំពានសិទ្ធិមនុស្ស។ NGOs ធ្វើការនៅគ្រប់កម្រិត ពីឆាកអន្តរជាតិដែលមានអង្គការធំៗដូចជាអង្គការលើកលែងទោសអន្តរជាតិ (AI) និងអង្គការឃ្លាំមើលសិទ្ធិមនុស្ស ដល់អង្គការនៅមូលដ្ឋានដែលធ្វើការក្នុងសហគមន៍។ ផ្នែកនេះនឹងពិនិត្យទិដ្ឋភាពទូទៅពីប្រភេទនៃ NGOs សិទ្ធិមនុស្ស និងពិភាក្សាលើការងារប្រភេទអ្វីដែលពួកគេធ្វើ។ ចរិកលក្ខណៈនៃអង្គការសង្គមស៊ីវិល (CSO) មានន័យថាការងារដែល NGOs ធ្វើមានភាពខុសៗគ្នា និងពិបាកក្នុងការចំណាត់ប្រភេទ។ អង្គការទាំងនេះមានភាពខុសគ្នាផងដែរលើរចនាសម្ព័ន្ធ។ មិនពាក់ព័ន្ធនឹងស្ថានភាពនេះនោះទេ NGOs ដែលធ្វើការលើសិទ្ធិមនុស្សទាំងអស់មានសកម្មភាពស្រដៀងៗគ្នាក្នុងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស។

ជាបឋម ជាការសំខាន់ក្នុងការញែកឲ្យដាច់ NGO ពី CSO។ គ្រប់NGOទាំងអស់គឺជា CSOs ប៉ុន្តែCSOs ជាច្រើនមិនមែនជា NGOs នោះទេ។ CSO ជាស្ថាប័នមួយដែលមានលក្ខណៈដូចខាងក្រោម៖

- មិនមែនជាផ្នែកមួយរបស់រដ្ឋាភិបាល
- មិនស្វែងរកប្រាក់ចំណេញ (ដូចនេះមិនមេនជាក្រុមហ៊ុន ឬអាជីវកម្ម)
- ការងាររបស់ខ្លួនគឺដើម្បីរួមចំនែកក្នុងសង្គម ការងារស៊ីវិល និងសណ្ដាប់ធ្នាប់សង្គម (ដូចនេះ មិនមែនជាស្ថាប័នឧក្រិដ្ឋនោះទេ)។

អ្វីដែលធ្វើឲ្យ NGOs ខុសពី CSOs គឺថាពួកគេធ្វើការក្នុងវិស័យដែលជាចំណាប់អារម្មណ៍រដ្ឋាភិបាល។ CSOs អាចជាក្រុមអ្នកគាំទ្រ សមាគមកីឡា សង្គមសិល្បៈ ក្រុមនិស្សិតដែលធ្វើការមិនពាក់ព័ន្ធនឹងរដ្ឋាភិបាលផងដែរ។ យ៉ាងណាមិញ NGOs ធ្វើការ ពាក់ព័ន្ធ នឹងរដ្ឋាភិបាលដូចជាផ្ដល់សេវាកម្មសុខភាព ឬការអប់រំ ការការពារបរិស្ថាន ឬជួយក្នុងការអភិវឌ្ឍសហគមន៍។ ទាំងនេះជាសកម្មភាពដែលរដ្ឋាភិបាលមានចំណាប់អារម្មណ៍ ឬ មានតួនាទីក្នុងនោះ។

មិនមានស្តង់ដារអន្តរជាតិលើថាអ្វីដែលត្រូវបានចាត់ទុកថាជា NGO នោះទេ ឬថាលក្ខខណ្ឌអ្វីដែលត្រូវបំពេញដើម្បីចាត់ទុកថាជា NGO នោះទេ។ ស្ថាប័នមួយចំនួនអះអាងថាខ្លួនជា NGOs នៅពេលដែលមានការជជែកវែកញែកលើថាតើនេះជាការពិតឬក៏អត់។ ជាឧទាហរណ៍រដ្ឋាភិបាលអាចបង្កើតស្ថាប័នដែលពួកគេអះអាងថាជា NGOs ប៉ុន្តែជាការពិតពួកគេជាផ្នែកមួយរបស់រដ្ឋាភិបាល។ នេះក៏ដូចគ្នាចំពោះអាជីវកម្មផងដែរ ដែលមានក្រុមបញ្ចុះបញ្ចូលក្នុងការគាំទ្រពួកគេ (ដូចជាក្រុមអ្នកជក់បារីជាដើម) ប៉ុន្តែពួកគេជាផ្នែកមួយនៃអាជីវកម្ម ហើយមិនមែនជាសង្គមស៊ីវិលនោះទេ។ ស្ថាប័នមួយចំនួនមានការពិបាកក្នុងការកំណត់៖ វិហារ គណៈបក្សប្រឆាំង ឬសហជីពថាតើជាអង្គការ NGO ឬរដ្ឋាភិបាល ឬជាអ្វីផ្សេងណាស់?

ស្ថាប័នដូចជា UN មានលក្ខន្តិកៈសម្រាប់ NGOs ដែលចង់ទទួលបានការទទួលស្គាល់ដោយ UN (និងដូចនេះអាចចូលរួមក្នុងការចូលរួមក្នុងវេទិកា និងការពិភាក្សា)។ ខណៈមានការពិចារណាថា NGO ត្រូវតែមានទម្រង់រចនាសម្ព័ន្ធ និងការិយាល័យជាក់លាក់ មានការជជែកវែកញែកមួយអំពី ថាតើបទប្បញ្ញត្តិកម្រិតណាដែល NGO គួរតែមាន តើ NGO ត្រូវមានឯករាជ្យភាពយ៉ាងដូចម្តេចពីរដ្ឋាភិបាល និងថាតើពួកគេទទួលបានមូលនិធិយ៉ាងដូចម្តេច។

# ការពិភាក្សា និងការជជែកវែកញែក

## តើ NGO គួរតែបានគ្រប់គ្រងយ៉ាងដូចម្តេច?

ប្រទេសជាច្រើននៅអាស៊ីអាគ្នេយ៍កំពុងបង្កើតច្បាប់ថ្មីតម្រូវឲ្យ NGOs ក្នុងការចុះបញ្ជីជាមួយនឹងរដ្ឋាភិបាល។ មានហេតុផលចំពោះគំនិតនេះ៖ រដ្ឋាភិបាលអាចដឹងពីតើថា NGOs ចំនួនប៉ុន្មានកំពុងធ្វើការនៅក្នុងប្រទេសរបស់ខ្លួន ហើយការចុះបញ្ជីនឹងបញ្ឈប់សកម្មភាពដែលមិនស្របច្បាប់ និងសកម្មភាពឧក្រិដ្ឋផ្សេងៗ។ យ៉ាងណាមិញ ការចុះបញ្ជីអាចជាឧបសគ្គក្នុងបញ្ឈប់ NGOs ក្នុងការអនុវត្តការងាររបស់ពួកគេ ហើយបង្កើនការត្រួតពិនិត្យរបស់រដ្ឋាភិបាលលើ NGOs អាចត្រូវបានប្រើប្រាស់ក្នុងការហាមឃាត់មិនឲ្យ NGO ធ្វើការក្នុងប្រទេសមួយ។ អ្នករិះគន់បាននិយាយថានេះជាមធ្យោបាយមួយសម្រាប់រដ្ឋាភិបាលក្នុងការគ្រប់គ្រង NGOs និងបញ្ឈប់ពួកគេពីការការពារប្រជាជនពីការរំលោភបំពានពីសំណាក់រដ្ឋាភិបាល។

ឧទាហរណ៍មួយ គឺក្នុងប្រទេសកម្ពុជា ដែលមាន NGOs ប្រហែលជា ៣៥០០ កំពុងមានប្រតិបត្តិការក្នុងប្រទេស។ ចំនួនដ៏ច្រើននៃនេះធ្វើឲ្យមានការកើនឡើងនូវប្រាក់ខែ (ដោយសារNGOs អន្តរជាតិអាចផ្តល់ប្រាក់ខែច្រើន)។ NGOs រើសអង្គាសមូលនិធិពី

ប្រទេសរបស់ខ្លួនដើម្បីធ្វើសកម្មភាពក្នុងប្រទេសកម្ពុជា ប៉ុន្តែលុយភាគច្រើនត្រូវបានចំណាយលើប្រាក់ខែរបស់ពួកគេ។ ម្យ៉ាងវិញទៀតការងារមានតម្លៃភាគច្រើនក្នុងការអភិវឌ្ឍ និងសិទ្ធិត្រូវបានបំពេញដោយវិស័យ NGO។ រដ្ឋាភិបាលបានបង្កើតសេចក្តីព្រាងច្បាប់ស្តីពីការចុះបញ្ជី NGO ដែលតម្រូវឲ្យអង្គការក្នុងការចុះកិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាលដើម្បីធ្វើការក្នុងប្រទេស។ NGOs មានកង្វល់ថាច្បាប់នេះនឹងត្រូវបានប្រើប្រាស់ដើម្បីបញ្ឈប់ NGOs ក្នុងការជួយដល់ពលរដ្ឋក្នុងសកម្មភាពដែលប្រឆាំងរដ្ឋាភិបាល អាចនិយាយបានថាក្នុងវិវាទដីធ្លី។

តើការចុះបញ្ជីជាការចាំបាច់ដែរទេ? តើវានឹងជួយក្នុងការដោះស្រាយបញ្ហាក្នុងវិស័យ NGO ដែលមិនមានការគ្រប់គ្រងត្រឹមត្រូវដែរឬទេ?

លក្ខណៈពិសេសរបស់ NGO គឺជាវិស័យ ឬបញ្ហាដែលខ្លួនធ្វើការ។ NGOs មួយចំនួនមានអាណត្តិទូលំទូលាយដែលគ្រប់ដណ្តប់សិទ្ធិ ជាឧទាហរណ៍ HRW និង Amnesty International ឬពួកគេអាចធ្វើការក្នុងវិស័យជាក់លាក់ ដូចជាសិទ្ធិជនពិការ ឬសិទ្ធិជនជាតិដើមភាគតិច។ NGOs ជារឿយៗជាផ្នែកមួយនៃបណ្តាញធំៗដែលពួកគេមានទំនាក់ទំនងជាមួយនឹងអង្គការស្រដៀងគ្នានៅថ្នាក់ជាតិ និងអន្តរជាតិ។

មានទ្រង់ទ្រាយរចនាសម្ព័ន្ធទូទៅមួយចំនួននៃ NGOs សិទ្ធិមនុស្សដែលធ្វើការក្នុងតំបន់អាស៊ីអាគ្នេយ៍។ កម្មវិធីត្រូវបានផ្សាភ្ជាប់ជាមួយនឹងចង្កោមសកម្មភាពដែលមានកម្មវត្ថុជាក់លាក់មួយចំនួន។

កម្មវិធីអាចពាក់ព័ន្ធនឹងបញ្ហា ឬប្រធានបទមួយ (ដូចជាការអប់រំសិទ្ធិមនុស្ស ទារុណកម្មស្ត្រី និងច្បាប់) ឬអាចក្នុងប្រទេសមួយ (ជាឧទាហរណ៍ HRW មានកម្មវិធីប្រចាំប្រទេសហើយក៏ធ្វើការតាមវិស័យផងដែរ)។ ក្រៅពីកម្មវិធីសកម្មភាពទាំងនេះ NGOs នឹងមានផ្នែករដ្ឋបាល ដូចជាប្រព័ន្ធផ្សព្វផ្សាយ និងទំនាក់ទំនង ដែលពួកគេផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ ឬធ្វើការតស៊ូមតិតាមប្រព័ន្ធផ្សព្វផ្សាយ។ ផ្នែកដទៃរួមមានហរិញ្ញវត្ថុ បណ្តាញផ្សព្វផ្សាយ និងស្រាវជ្រាវ។

## ករណីសិក្សា

វេទិកា-អាស៊ី (FORUM-ASIA)

វេទិកា-អាស៊ី គឺជាអង្គការសមាជិកសិទ្ធិមនុស្សថ្នាក់តំបន់មួយដែលប្តេជ្ញាចិត្តក្នុងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សទាំងអស់តាមរយៈកិច្ចសហប្រតិបត្តិការ និងកិច្ចសហការក្នុងចំណោមអង្គការ និងអ្នកការពារសិទ្ធិមនុស្សនៅអាស៊ី។

វេទិកា-អាស៊ី ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩១ នៅទីក្រុង ម៉ានីល ជាផ្នែកមួយក្នុងការឆ្លើយតបនឹងការកើនឡើងចំណាប់អារម្មណ៍របស់សង្គមស៊ីវិល ក្នុងបញ្ហាសិទ្ធិមនុស្ស ការកើនឡើងនៃការសម្របសម្រួលអន្តរជាតិលើសកម្មភាពសិទ្ធិមនុស្ស និងតម្រូវការក្នុងការគាំទ្រសង្គមស៊ីវិលដែលធ្វើការក្នុងប្រទេស ដែលមិនមានប្រជាធិបតេយ្យ ដោយសារអាស៊ីអាគ្នេយ៍នាពេលនោះ មានតែប្រទេសពីរបីប៉ុណ្ណោះមានប្រជាធិបតេយ្យពេញលេញ (ប្រហែលមានតែហ្វីលីពីនប៉ុណ្ណោះ ដែលទើបតែបានរួចផុតពីរបបដឹកនាំផ្តាច់ការម៉ាកូស)។

វេទិកា-អាស៊ី មានសមាជិក ៤៦អង្គការទូទាំងអាស៊ីដែលជា NGOs ទាំងអស់ដែលមកពី៖ បង់ក្លាដេស (៤) ភូមា(១) កម្ពុជា(២) ឥណ្ឌា (៨) ឥណ្ឌូនេស៊ី(៧) ជប៉ុន (១) ម៉ាឡេស៊ី(២) ម៉ុងហ្គោលី(២) នេប៉ាល់ (៣) ប៉ាគីស្ថាន (៣) ហ្វីលីពីន(៦) សឹង្ហបុរី (១) កូរ៉េខាងត្បូង(២) ស្រីលង្កា (៣) តៃវ៉ាន់ (១) ថៃ(១) ទីម័រខាងកើត (២)។

រចនាសម្ព័ន្ធកម្មវិធីនៅ វេទិកា-អាស៊ី មាន
**កម្មវិធីតាមវិស័យ៖** កម្មវិធីតស៊ូមតិអាស៊ាន តស៊ូមតិ SAARCX កម្មវិធីការពារសិទ្ធិមនុស្ស កម្មវិធីបណ្តុះបណ្តាលសិទ្ធិមនុស្ស កម្មវិធីតស៊ូមតិ
**កម្មវិធីប្រចាំប្រទេស៖** កម្មវិធីប្រចាំអាស៊ីខាងកើត កម្មវិធីប្រចាំប្រទេសអាស៊ីខាងត្បូង។

## ៤.៦.១ សកម្មភាព NGO

NGOs សិទ្ធិមនុស្សអាចអនុវត្តសកម្មភាពមួយចំនួន។ សកម្មភាពដែលបានបញ្ជាក់ខាងក្រោមមិនមែនជាសកម្មភាពទាំងអស់ដែលបានអនុវត្តដោយ NGOs នោះទេ ដោយសារពួកគេអាចចូលរួមក្នុងការផ្តល់មតិយោបល់លើគោលនយោបាយ តាមដានប្រព័ន្ធច្បាប់ បង្កើតបណ្តាញ ។ល។ ខាងក្រោមនេះជាសកម្មភាពទូទៅមួយចំនួនរបស់ NGOs។

## ការអប់រំសិទ្ធិមនុស្ស

ទោះបីជារដ្ឋអនុវត្តកាតព្វកិច្ចក្នុងការអប់រំសិទ្ធិមនុស្ស (យោងទៅតាមការប្ដេជ្ញាចិត្តរបស់ខ្លួនក្នុង ICCPR និងCRC) ចំនេះដឹងពីសិទ្ធិនៅក្នុងតំបន់នៅតែស្ថិតក្នុងកម្រិតមូលដ្ឋាន។ ដោយសារហេតុផលនេះ NGOs ជាច្រើនមានយុទ្ធនាការអប់រំដើម្បីធ្វើឲ្យប្រជាជនជ្រាបពីសិទ្ធិមនុស្ស ទាំងនេះអាចគ្រប់ដណ្ដប់លើសិទ្ធិទូទៅ ឬសិទ្ធិជាក់លាក់សម្រាប់ប្រជាជនជាក់លាក់ (ជាឧទាហរណ៍ សិទ្ធិស្ត្រី ឬសិទ្ធិជនពិការ)។ សកលវិទ្យាល័យក៏ដើរតួនាទីសំខាន់ផងដែរក្នុងសកម្មភាពទាំងនេះ ទោះបីជាពួកគេមិនអាចត្រូវបានហៅថាជា NGO ក៏ដោយ ដោយសារពួកគេជាភ្នាក់ងាររបស់រដ្ឋាភិបាល។ ជាឧទារហណ៍មួយ បណ្ដាញការពារការងារក្នុងប្រទេសថៃ មានសកម្មភាពដែលផ្ដល់ការអប់រំដល់កុមារដែលធ្វើការទេសន្តប្រវេសន៍ និងអប់រំពលករទេសន្តប្រវេសន៍ពីសិទ្ធិមនុស្សរបស់ពួកគេផងដែរ។

## តស៊ូមតិសិទ្ធិមនុស្ស

ពាក្យតស៊ូមតិមានន័យថាបន្ថែមសំលេងទៅលើ ឬក៏និយាយពីអ្វីមួយ។ NGOs អាចនិយាយតំណាងឲ្យក្រុមមួយដែលមិនមានអំណាច ឬធនធានក្នុងការប្រឈមនឹងរដ្ឋាភិបាល។ NGOs អាចតស៊ូមតិផងដែរដើម្បីការទទួលស្គាល់ ឬការយល់ដឹងពីសិទ្ធិមួយបន្ថែមទៀត។ ជាឧទាហរណ៍ ដូចជាការតស៊ូមតិដើម្បីសិទ្ធិជនភៀសខ្លួននៅអាស៊ីអាគ្នេយ៍។ អង្គការជនភៀសខ្លួនចង់ឲ្យសាធារណៈ និងរដ្ឋាភិបាលដឹងលឺពីស្ថានភាពអាក្រក់កើតមានលើជនភៀសខ្លួនដែលត្រូវបានចាក់សោរក្នុងបន្ទប់ឃុំឃាំង លាក់ខ្លួននៅកណ្ដាលទីក្រុងដោយភាពភ័យខ្លាច ក្នុងការបណ្ដេញចេញទៅប្រទេសខ្លួនវិញ។ តាមរយៈការប្រើប្រាស់ការតស៊ូមតិ ពួកគេអាចកែប្រែទស្សនៈសាធារណៈលើជនភៀសខ្លួនពីការចាត់ទុកថាជាបន្ទុកទៅជាប្រជាជន ដែលទាមទារសន្តិសុខ និងសិទ្ធិ។ ពួកគេអាចតស៊ូមតិទៅរដ្ឋាភិបាលក្នុងការបញ្ឈប់ការឃុំខ្លួនកុមារ ដោយសារតែការឃុំខ្លួនកុមារក្នុងពន្ធនាគារជាការមិនល្អមើលដល់រដ្ឋាភិបាល។ ការតស៊ូមតិជារឿយៗប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ប៉ុន្តែអាចតាមរយៈការអប់រំ បញ្ចាំងកុនតាមផ្លូវ ប្រព័ន្ធផ្សព្វផ្សាយសង្គមដូចជាយុទ្ធនាការ Facebook ឬធ្វើជាខ្សែភាពយន្តឯកសារជាដើម។

## តាមដាន និងស៊ើបអង្កេត

ប្រជាជនមួយចំនួនមានភាពងាយរងគ្រោះ ពីការរំលោភបំពានសិទ្ធិមនុស្សជាងអ្នកដទៃដោយសារមិនមានវត្តមានយន្តការការពាររបស់រដ្ឋតាមទំនៀមទំលាប់ ឬពួកគេមិនបំពេញការងាររបស់ខ្លួនឲ្យបានសមរម្យ។ នេះជាករណីកើតមានចំពោះអ្នកទោសជាប់ពន្ធនាគារ ឬក្រុមជនជាតិដើមភាគតិចដែលរស់នៅឆ្ងាយពីទីក្រុង។ NGOs សិទ្ធិមនុស្ស

អាចតាមដាន និងរាយការណ៍ពីស្ថានភាពទាំងនេះ ហើយនឹងស្នើឲ្យមានការចាត់វិធានការដើម្បីបញ្ឈប់ការរំលោភបំពាន។ NGOs ដែលធ្វើការកិច្ចនេះជាទូទៅនឹងចេញរបាយការណ៍ និងធ្វើសន្និសិទសារព័ត៌មានដើម្បីធ្វើបច្ចុប្បន្នភាពដល់ប្រព័ន្ធផ្សព្វផ្សាយ និងភាគីដែលមានចំណាប់អារម្មណ៍ដទៃទៀតលើស្ថានភាពនេះ។ អង្គការដែលល្បីល្បាញក្នុងសកម្មភាពនេះគឺ HRW ដែលចេញរបាយការណ៍ប្រចាំឆ្នាំចំនួន ៥០ ស្ដីពីអាស៊ី។ របាយការណ៍កាលពីពេលថ្មីៗមួយចំនួនដែលទទួលបានការចាប់អារម្មណ៍រួមមាន៖

- 'ប្រាប់ពួកគេថាយើងចង់សម្លាប់ពួកគេ' ៖ ពីរទសវត្សនៃនិទណ្ឌភាពក្រោមការដឹកនាំរបស់លោកហ៊ុន សែនក្នុងប្រទេសកម្ពុជា

- ជាបណ្ដោះអាសន្ន និងភាពមិនគ្រប់គ្រាន់៖ ការប្រព្រឹត្តលើជនភៀសខ្លួនដោយប្រទេសថៃ និងអ្នកសុំសិទ្ធិជ្រកកោន
- រដ្ឋាភិបាលគួរតែអាចត្រូវបានបញ្ឈប់ស្ថានការណ៍នេះ៖ អំពើហិង្សាលើនិកាយ និងការបើកឲ្យមានការរំលោភបំពានក្នុងរដ្ឋអារ៉ាខាន (Arakan) ក្នុងប្រទេសភូមា

- ទារុណកម្មជ្រកក្រោមពាក្យការប្រព្រឹត្តមកលើ៖ ការរំលោភបំពានសិទ្ធិមនុស្សក្នុងប្រទេសវៀតណាម ចិន កម្ពុជា និងឡាវ។

## ផ្ដោតសំខាន់លើ

HRW លើប្រទេសវៀតណាម

***របាយការណ៍របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស***

ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៧៨ HRW មានតាមដានស្ថានភាពជុំវិញពិភពលោកតាមរយៈរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ដែលរួមមានការវិភាគលើហេតុការណ៍ដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្សក្នុងប្រទេសនីមួយៗលើពិភពលោក។ របាយការណ៍ប្រចាំឆ្នាំបន្ថែមព័ត៌មានលើរបាយការណ៍ពីព្រឹត្តការណ៍ជាក់លាក់ជាច្រើនទៀត។

ជាឧទាហរណ៍ របាយការណ៍ប្រចាំឆ្នាំ២០១២ បានគ្រប់ដណ្ដប់លើការរំលោភបំពានសិទ្ធិមនុស្សជាច្រើនក្នុងប្រទេសវៀតណាមដូចជា៖ ការទប់ស្កាត់សេរីភាពក្នុងការបញ្ចេញមតិ សមាគម និងការជួបប្រជុំដោយសន្តិវិធី ការបំភិតបំភ័យ ការបៀតបៀន និងការឃុំខ្លួនអ្នកតវ៉ា ការដាក់កម្រិតដោយរដ្ឋាភិបាលលើការអនុវត្តសាសនាតាមរយៈច្បាប់ តម្រូវការចុះបញ្ជី ឬការតាមដានជាដើម។ ជាពិសេស អ្នកទោសនយោបាយ និង

សាសនាជារឿយៗប្រឈមនឹងអំពើព្រៃផ្សៃពីសំណាក់ប៉ូលីស ដោយរួមមានទាំងទារុណកម្មក្នុងអំឡុងពេលសួរចម្លើយ មិនឲ្យមានទំនាក់ទំនងជាមួយអ្នកខាងក្រៅមុនពេលសវនការ ការបដិសេធមិនឲ្យក្រុមគ្រួសារសួរសុខទុក្ខ មិនមានមេធាវីការពារ និងវាយដំរហូតដល់ស្លាប់។

រដ្ឋាភិបាលជារឿយៗប្រកែកនឹងការរកឃើញនៃរបាយការណ៍ប្រចាំឆ្នាំទាំងនេះ ហើយអះអាងថា NGO មិនបានប្រើប្រាស់ព័ត៌មានត្រឹមត្រូវ ឬមានភាពលំអៀងប្រឆាំងនឹងរដ្ឋាភិបាល។ ខណៈពេលដែលក្នុងករណីខ្លះ អាចមានការពិតមួយចំនួនក្នុងការចោទប្រកាន់របស់រដ្ឋាភិបាលក៏ដោយ ពួកគេគួរតែអនុញ្ញាតឲ្យប្រជាជនអានរបាយការណ៍ទាំងនេះ និងធ្វើការសម្រេចចិត្តដោយខ្លួនឯង។

## ការប្រមូលឯកសារ HR

ជនរងគ្រោះនៃការរំលោភបំពានដែលស្វែងរកយុត្តិធម៌ ត្រូវតែអាចធ្វើការបង្ហាញថាមានការរំលោភបំពានកើតឡើង។ ដំណើរការនៃការប្រមូលភស្តុតាងនៃការរំលោភបំពានត្រូវបានហៅថាការប្រមូលឯកសារ។ ការងារជាក់លាក់នេះរួមមានការប្រមូលទិន្នន័យប្រកបដោយភាពសុក្រិត ដើម្បីអាចប្រើក្នុងការតស៊ូមតិ និងក្នុងតុលាការ។ ការប្រមូលឯកសារអាចជារបាយការណ៍សាក្សី របាយការណ៍វេជ្ជសាស្ត្រ រូបភាពកន្លែងកើតហេតុ ដំណើររឿងនៃព្រឹត្តការណ៍។ល។ ការប្រមូលឯកសារត្រូវតែមានភាពសុក្រិត ហើយត្រូវតែបង្ហាញថាមានការរំលោភបំពានច្បាស់លាស់មួយ ដែលបានកើតឡើង។ ជនរងគ្រោះជាច្រើនប្រហែលជាមិនអាចមានឱកាសដទៃ ក្នុងការទទួលបាននូវយន្តការការពារ ដោយសាររដ្ឋរបស់ពួកគេមិនបានផ្តល់សច្ចាប័នលើសន្ធិសញ្ញាចាំបាច់ដែលព្រមព្រៀងលើបណ្តឹងបុគ្គល ឬមិនមានវត្តមាននៃស្ថាប័នថ្នាក់តំបន់ដើម្បីដំណើរការបណ្តឹងរបស់ពួកគេនោះទេ។ នៅក្នុងករណីនេះ ការប្រមូលឯកសារមិនអាចជាជំនួយនៅក្នុងបណ្តឹងនៅតុលាការនោះទេ ប៉ុន្តែជាជួយក្នុងការតស៊ូមតិសម្រាប់ការផ្លាស់ប្តូរការអនុវត្តរបស់រដ្ឋាភិបាល ឬសម្រាប់ការតស៊ូមតិនៅឆាកអន្តរជាតិ។ បន្ថែមពីលើនេះទៀត ការប្រមូលឯកសារច្រើនអាចមានសារៈប្រយោជន៍ ដើម្បីបង្ហាញពីទ្រង់ទ្រាយនៃការរំលោភបំពាន។ ប្រសិនបើ NGO អាចបង្ហាញថាការរំលោភបំពានមួយកំពុងកើតឡើងជារឿយៗ មានឯកសារទាំងអស់ជាច្រើនបង្ហាញនូវការរំលោភបំពានស្រដៀងគ្នានេះ ឧបមាថាប្រជាជនត្រូវបានរំលោភបំពាននៅក្នុងគុក ឬមិនមានការផ្តល់សេវាកម្មរដ្ឋាភិបាលដល់ជនជាតិភាគតិច ដូចនេះប្រហែលជាអាចបង្ហាញថាការរំលោភមានការសាយភាយ និងលក្ខណៈជាប្រព័ន្ធ ដែលអាចត្រូវបានប្រើប្រាស់ជាហេតុផលក្នុងការជម្រុញឲ្យស្ថាប័ន UN ចូលខ្លួនពាក់ព័ន្ធ។

# ករណីសិក្សា

## ការប្រមូលឯកសារលើការរំលោភសេពសន្ថវៈជាប្រព័ន្ធ

នៅក្នុងអំឡុងពេលសង្គ្រាមស៊ីវិលនៅក្នុងប្រទេសមីយ៉ាន់ម៉ា NGOs ជាច្រើន មានកង្វល់ពាក់ព័ន្ធជាមួយនឹងអំពើហិង្សាប្រឈមដោយស្ត្រី។ អង្គការផ្សេងៗបានរៀបចំរបាយការណ៍ ដោយផ្អែកលើការប្រមូលភ័ស្តុតាង ដើម្បីបង្ហាញថាយោធាមីយ៉ាន់ម៉ារំលោភសេពសន្ថវៈលើស្ត្រីជាប្រព័ន្ធ។ ការបង្ហាញថាការរំលោភសេពសន្ថវៈជាប្រព័ន្ធអាចមានសារៈសំខាន់ក្នុងការការពារស្ត្រី។ ការរំលោភសេពសន្ថវៈជាប្រព័ន្ធជាបទឧក្រិដ្ឋអន្តរជាតិ។ នេះក៏អាចបង្ហាញពីយុត្តិកម្មនៃការអន្តរាគមន៍ដោយក្រុមប្រឹក្សាសន្តិសុខរបស់ UN ឬតុលាការអន្តរជាតិ ផងដែរ (ទោះបីជាក្នុងករណីនេះ មិនមានស្ថាប័នណាមួយក្នុងចំណោមស្ថាប័នទាំងពីរនេះបានចូលខ្លួនពាក់ព័ន្ធក៏ដោយ)។

មានរបាយការណ៍ជាច្រើនស្តីពីអំពើហិង្សានេះដោយរួមមាន សាលាសម្រាប់រំលោភសេពសន្ថវៈ (១៩៩៨) ដោយ EarthRights អន្តរជាតិ និងអាជ្ញាប័ណ្ណក្នុងការរំលោភដោយបណ្តាញសកម្មភាពដើម្បីស្ត្រីជនជាតិសាន (SAN) ដែលបានប្រមូលឯកសារនៃការរំលោភសេពសន្ថវៈចំនួន ១៧៣ ករណី។ ការប្រមូលឯកសារនេះជាភ័ស្តុតាងនៃការរំលោភសេពសន្ថវៈលើស្ត្រីក្នុងស្ថានភាពជម្លោះគឺមានលក្ខណៈជាប្រព័ន្ធ ហើយទាមទារឲ្យមាននូវការដោះស្រាយជាបន្ទាន់។

## បណ្តឹង និងការប្តឹងផ្តល់

NGOs អាចដើរតួនាទីមួយក្នុងនីតិវិធីបណ្តឹង។ ឧទាហរណ៍ គឺ NGOs ដែលធ្វើការក្នុងវិស័យយុត្តិធម៌ ជាអ្នកការពារ និងផ្តល់សេវាផ្លូវច្បាប់ជាសាធារណៈ។ NGOs បានជួយបុគ្គលក្នុងការធ្វើបណ្តឹងប្រឆាំងរដ្ឋាភិបាល និងផ្តួចផ្តើមនូវអ្វីដែលត្រូវបានហៅថា 'ការប្តឹងផ្តល់ជាយុទ្ធសាស្ត្រ' ឬឈ្មោះរឿងក្តីអាចត្រូវបានប្រើប្រាស់ដើម្បីផ្លាស់ប្តូរច្បាប់ និងការអនុវត្តរបស់រដ្ឋាភិបាល។ ឧទាហរណ៍កាលពីពេលថ្មីៗពាក់ព័ន្ធនឹងបញ្ហានេះ ជា NGO សិទ្ធិលំនៅដ្ឋានដែលមានឈ្មោះថា COHRE (ដែលបានបិទសកម្មភាពក្នុងឆ្នាំ ២០១២) បានផ្តួចផ្តើមនូវបណ្តឹងមួយចំនួនតំណាងឲ្យប្រជាជនដែលត្រូវបានបណ្តេញចេញដោយបង្ខំក្នុងប្រទេសកម្ពុជា និងហ្វីលីពីន។ កម្មវត្ថុនៃការប្តឹងផ្តល់នេះគឺដើម្បីធានាថាវាជាការខុសច្បាប់ក្នុងការបង្ខំឲ្យប្រជាជនចេញពីផ្ទះរបស់ពួកគេ។ រឿងក្តីល្បីល្បាញដទៃទៀតរួមមានរឿងក្តី UNOCAL ដែលភូមិមួយចំនួននៅក្នុងប្រទេសភូមាត្រូវបានជម្លៀសចេញដោយការសាងសង់បំពង់ទុយោដោយ UNOCAL បន្ទាប់មកក្រុមហ៊ុននេះត្រូវបានប្តឹងទៅតុលាការនៅសហរដ្ឋអាមេរិក តាមច្បាប់ស្តីពីបណ្តឹងរដ្ឋប្បវេ

ណីរបស់ជនបរទេស (ដែលអនុញ្ញាតឲ្យជនបរទេសដាក់បណ្ដឹងរដ្ឋប្បវេណី ប្រសិនជាពួកគេគិតថាជនជាតិអាមេរិកបានរំលោភបំពានសិទ្ធិរបស់ពួកគេ)។ រឿងក្ដីនេះត្រូវបានដោះស្រាយក្រៅផ្លូវតុលាការ ហើយចំនួនសំណងដែលមិនត្រូវបានបញ្ជាក់ឲ្យដឹងមួយត្រូវបានប្រគល់ជូនអ្នកភូមិដែលត្រូវបានជម្លៀសចេញ។

## ៨.៦.២ NGOs នៅតាមមូលដ្ឋាន

NGOs ខុសៗគ្នាដោយផ្អែកលើទំហំ និងកន្លែងដែលពួកគេបំពេញការងារ។ NGOs តូចៗ និងតាមមូលដ្ឋានជារឿយៗត្រូវបានហៅថា NGOs "មូលដ្ឋាន" ដែលបង្កប់ន័យថាពួកគេធ្វើការដោយផ្ទាល់ជាមួយនឹងប្រជាជនក្នុងបរិស្ថានមូលដ្ឋានរបស់ពួកគេ។

NGOs មូលដ្ឋានមានសមាជិកដែលជាប្រជាជនតាមមូលដ្ឋាន ដែលនិយាយភាសាតំបន់នោះ និងដឹងពីបរិបទតាមមូលដ្ឋាននោះ។ ពួកគេកម្រនឹងធ្វើការជាមួយរដ្ឋាភិបាលណាស់ ប៉ុន្តែមានទំនាក់ទំនងជាមួយនឹងមន្ត្រីរដ្ឋាភិបាលក្នុងមូលដ្ឋានរបស់ពួកគេ។

NGOs ថ្នាក់ជាតិអាចមានកម្មវិធីក្នុងទីតាំងផ្សេងៗគ្នា ប៉ុន្តែមានការិយាល័យកណ្ដាលនៅក្នុងទីក្រុង។ NGOs ទាំងនេះក៏មានទំនាក់ទំនងផងដែរជាមួយនឹងរដ្ឋាភិបាល ឬក្រសួងរបស់រដ្ឋាភិបាលនៅក្នុងវិស័យជំនាញរបស់ពួកគេ។ យ៉ាងណាមិញ NGO ថ្នាក់ជាតិមួយអាចអនុវត្តសកម្មភាពតាមមូលដ្ឋាន ឬអាចចងក្រងបណ្ដាញជាមួយនឹង NGOs តូចៗតាមមូលដ្ឋានមួយចំនួន។

NGOs កម្រិតថ្នាក់តំបន់ធ្វើការក្នុងប្រទេសមួយចំនួន ហើយនឹងមានកម្មវិធី ឬធ្វើការតស៊ូមតិក្នុងប្រទេសច្រើនជាងមួយ។ នៅក្នុងអាស៊ីអាគ្នេយ៍ NGOs ថ្នាក់តំបន់ធ្វើការលើបញ្ហាជាច្រើនដូចជាពលករទេសន្តប្រវេសន៍ ឬសិទ្ធិស្ត្រី។ ខណៈពេលដែលពួកគេមានការិយាល័យកណ្ដាលមួយ ពួកគេក៏អាចមានការិយាល័យនៅប្រទេសដទៃទៀតផងដែរ។ សារៈសំខាន់នៃ NGOs ថ្នាក់តំបន់គឺថាពួកគេអាចដោះស្រាយបញ្ហាសិទ្ធិមនុស្សដែលមិនចាំបាច់ជាក់លាក់សម្រាប់តំបន់មួយ (ដូចជាបញ្ហាជុំវិញទេសន្តប្រវេសន៍ ឬជនភៀសខ្លួន) ហើយពួកគេអាចធ្វើការតស៊ូមតិកាន់តែខ្លាំងក្លានៅកម្រិតថ្នាក់តំបន់ និងអន្តរជាតិ។ នៅក្នុងអាស៊ីអាគ្នេយ៍ ចំនួន NGOs ថ្នាក់តំបន់មួយចំនួនបានធ្វើការតស៊ូមតិនៅមូលដ្ឋានអាស៊ាន។

NGOs សិទ្ធិមនុស្សកម្រិតអន្តរជាតិធ្វើការតស៊ូមតិក្នុងតំបន់ផ្សេងៗគ្នា៖ អង្គការទាំងនេះមានភាពសកម្មនៅកម្រិត UN ប៉ុន្តែមានការគាំទ្រពី NGOs មូលដ្ឋាន និងថ្នាក់ជាតិផងដែរដោយធ្វើការជួយដល់ការតស៊ូមតិរបស់ពួកគេ ឬអភិវឌ្ឍសមត្ថភាពរបស់ពួកគេ ហើយស្របពេលតែមួយអាចធ្វើការនៅក្នុងប្រទេសជាច្រើន។ មានអង្គការប្រភេទនេះធំៗចំនួនពីរ គឺHRW (ដែលមានមូលដ្ឋាននៅញូវយ៉ក) និង Amnesty International (ដែលមានមូលដ្ឋាននៅឡុង់) ដែលទន្ទឹមនឹងនេះក៏មាន FIDH Article 19 Human Rights First និង Witness ផងដែរដែលមានភាពល្បីល្បាញ ហើយនៅមាន NGOs អន្តរជាតិជាច្រើនទៀតក្រៅពីអង្គការប៉ុន្មានដែលបានបញ្ជាក់ខាងលើនេះ។ ជាពិសេសរដ្ឋាភិបាលជារឿយៗត្អូញត្អែរពី NGOs ទាំងអស់នេះ ដោយនិយាយថាពួកគេមានប្រភពចេញពីលោកខាងលិច ហើយជាអង្គការបរទេស ហើយទទូចថាពួកគេមិនគួរត្រូវបានអនុញ្ញាតឲ្យធ្វើការក្នុងប្រទេសខ្លួនឡើយ។ ការរិះគន់ទាំងនេះជាការយល់ខុស ហើយរដ្ឋមានភាពស្ទាក់ស្ទើរក្នុងការដែលអនុញ្ញាតឲ្យ NGOs ល្បីឈ្មោះ ធ្វើការតាមដានកាតព្វកិច្ចសិទ្ធិរបស់ខ្លួនដោយជិតស្និត។

## អ្នកការពារសិទ្ធិមនុស្ស

បុគ្គលិកដែលធ្វើការនៅ NGOs អាចត្រូវបានចាត់ទុកថាជាអ្នកការពារសិទ្ធិ មនុស្ស (HRD)។ HRD មួយរូបត្រូវបានកំណត់ថាជាបុគ្គលដែលធ្វើការលើកកម្ពស់ និងការពារសិទ្ធិមនុស្សដែលរួមបញ្ចូលនូវនិយមន័យទូលំទូលាយ ដោយរួមមានអ្នកអប់រំសិទ្ធិមនុស្ស មន្ត្រីរដ្ឋាភិបាលដែលធ្វើការក្នុងវិស័យសិទ្ធិមនុស្ស និងបុគ្គលិក NGO ដែលធ្វើការលើបញ្ហាសិទ្ធិមនុស្ស។ ការងាររបស់ HRD ជាពិសេសនៅតំបន់អាស៊ីអាគ្នេយ៍ អាចប្រឈមនឹងគ្រោះថ្នាក់។ ក្នុងរយៈពេលប្រាំឆ្នាំកន្លងទៅនេះ មាន HRDs មួយចំនួនបានបាត់បង់ជីវិត ឬជាប់ពន្ធនាគារដោយសារការងារក្នុងវិស័យសិទ្ធិមនុស្សរបស់ខ្លួន។ ឧទាហរណ៍ដែលល្បីល្បាញរួមមានការស្លាប់របស់មុយនៀ Munir ដែលជា HRD ជនជាតិឥណ្ឌូនេស៊ី ដែលត្រូវបានបំពុលដោយសារជាតិអាសេនិក នៅលើជើងយន្តហោះទៅកាន់ទីក្រុងអាំស្ទែរដាំ ក្នុងឆ្នាំ២០០៤។ មនុស្សចំនួនបីរូបដែលមានទំនាក់ទំនងនឹងរដ្ឋាភិបាលត្រូវបានជាប់ពន្ធនាគារដោយករណីសម្លាប់នេះ។ ប្រទេសហ្វីលីពីនមានកំណត់ត្រាមិនល្អពាក់ព័ន្ធនឹងការការពារ HRDs ដោយមានការសម្លាប់សកម្មជនសិទ្ធិមនុស្សជាច្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ជាពិសេសដោយសារការការពារភូមិ និងក្រុមជនជាតិដើមភាគតិចរបស់ពួកគេពីការយកដីធ្លីដើម្បីជាផលប្រយោជន៍អាជីវកម្ម។

ការកើនឡើងនៃហានិភ័យក្នុងការងារសិទ្ធិមនុស្សនេះ បានធ្វើឲ្យ UN អនុម័តសេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្ស។ ខណៈពេលដែលមិនមានការចងកាតព្វកិច្ចនៅឡើយនោះ សេចក្តីប្រកាសនេះបានកំណត់នូវស្តង់ដារមួយចំនួនដែលសកម្មភាពរបស់ HRD ត្រូវបានការពារដោយសេរីភាពនៃការបញ្ចេញមតិ និងសមាគម។ សេចក្តី

ប្រកាសដែលត្រូវបានអនុម័ត ក្នុងឆ្នាំ១៩៩៨ ត្រូវបានតាមដានបន្ត ក្នុងឆ្នាំ២០០០ ដោយអ្នករាយការណ៍ពិសេសលើ HRDs។ មិនខ្វល់នឹងការការពារនេះ HRDs នៅអាស៊ីអាគ្នេយ៍នៅតែត្រូវបានវាយប្រហារ សម្លាប់ ដាក់ពន្ធនាគារ និងគម្រាមកំហែងដោយបណ្តឹងតុលាការដោយការសកម្មភាពការពារសិទ្ធិមនុស្សរបស់ពួកគេ។

## ក. សេចក្តីសង្ខេបពីជំពូក និងចំនុចគន្លឹះ

ការការពារសិទ្ធិមនុស្សត្រូវបានធ្វើឡើងដោយស្ថាប័ន ប្រជាជន និងអង្គការដទៃទៀតមួយចំនួន ដែលអាចការពារប្រជាជនពីការរំលោភបំពាន ដែលនេះរួមមានប៉ូលីស តុលាការ សង្គមស៊ីវិល និងអង្គការអន្តរជាតិ។ មានការពិបាកក្នុងការកំណត់ពីស្ថានភាពនៃការបំពេញកិច្ចការសិទ្ធិមនុស្សនៅក្នុងប្រទេសមួយ ដោយសារតែវាពឹងផ្អែកលើកម្រិតនៃការអភិវឌ្ឍ ប្រព័ន្ធនយោបាយ និងតើថារដ្ឋាភិបាលបានទទួលស្គាល់សិទ្ធិមនុស្សចំនួនប៉ុន្មាន។ នៅអាស៊ីអាគ្នេយ៍ រដ្ឋភាគច្រើនបានស្ថានភាពជម្រុះ ដែលវិស័យមួយចំនួនមានភាពល្អប្រសើរ ហើយផ្សេងទៀតមិនល្អប្រសើរ។

ការការពារអាចត្រូវបានត្រួតពិនិត្យ ដោយក្រលេកមើលថាមានវត្តមាននៃស្តង់ដារអន្តរជាតិស្តីពីសិទ្ធិមនុស្សនៅក្នុងប្រទេសដែរឬទេ។ ដែលនេះអាចកើតមានដូចជាសិទ្ធិបានក្លាយជាផ្នែកមួយនៃច្បាប់ ឬសិទ្ធិមានវត្តមាននៅក្នុងរដ្ឋធម្មនុញ្ញ។ កាលពីពេលថ្មីៗនេះគ្រប់រដ្ឋអាស៊ីអាគ្នេយ៍ទាំងអស់មានបញ្ញត្តិស្តីពីសិទ្ធិមនុស្ស ក្នុងរដ្ឋធម្មនុញ្ញរបស់ខ្លួន លើកលែងតែប្រទេសប្រ៊ុយណេ។ សិទ្ធិមនុស្សនៅក្នុងប្រព័ន្ធច្បាប់របស់អាស៊ីអាគ្នេយ៍ ប៉ុន្តែសិទ្ធិមនុស្សទាំងនេះមាននៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗជាច្រើន។

NHRI ជាអង្គការមួយដែលប្តេជ្ញាចិត្តក្នុងការការពារសិទ្ធិមនុស្សនៅថ្នាក់ជាតិ។ បច្ចុប្បន្ននេះមាន NHRIs ចំនួនប្រាំមួយនៅក្នុងអាស៊ីអាគ្នេយ៍។ NHRI ទាំងនេះផ្អែកលើគំរូជាគណៈកម្មាការ (លើកលែងតែប្រទេសទីម័រខាងកើតដែលមានគំរូកូនកាត់) ដែលផ្តល់នូវអាណត្តិទូលំទូលាយដល់ពួកគេក្នុងការលើកកម្ពស់ ការពារ ស៊ើបអង្កេត និង

តាមដានស្ថានភាពសិទ្ធិមនុស្ស។ NHRIs អាចជួបប្រទះនឹងការប្រឈមដោយសារពួកគេមិនបានទទួលមូលនិធិគ្រប់គ្រាន់ ឬពួកគេមិនមានឯករាជ្យភាពពីរដ្ឋាភិបាល ដែលទាំងនេះអាចកម្រិតនូវមុខងាររបស់ពួកគេ។ NHRIs ត្រូវបានវាយតម្លៃដោយស្ថាប័ន UN ហើយ NHRIs ដែលឆ្លើយតបនឹងស្តង់ដាររបស់ NHRI ដោយផ្អែកលើគោលការណ៍ទីក្រុងប៉ារីស (ដែលជាឯកសារមួយបញ្ជាក់ពីមុខងារ និងសកម្មភាពរបស់ NHRI) ត្រូវបានផ្តល់ជូនលទ្ធភាពក្នុងការធ្វើសកម្មភាពជាមួយ UN ។ NHRIs របស់អាស៊ីអាគ្នេយ៍ទាំងអស់ (លើកលែងតែមីយ៉ាន់ម៉ា) មានពិន្ទុ A ដែលទទួលស្គាល់ថាពួកគេអនុលោមតាមគោលការណ៍ទីក្រុងប៉ារីស។ យន្តការថ្នាក់តំបន់ការពារសិទ្ធិមនុស្សក្នុងប្រទេសដែលស្ថិតក្នុងតំបន់ភូមិសាស្ត្ររបស់ខ្លួន។ មានស្ថាប័នថ្នាក់តំបន់ចំនួនបី ដែលមាននៅអឺរ៉ុប អាហ្វ្រិក និងអាមេរិក។

អាស៊ានបានបង្កើតនូវស្ថាប័នអនុតំបន់មួយដែលមានឈ្មោះថា AICHR ក្នុងឆ្នាំ ២០០៩ ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស។ AICHR ត្រួតពិនិត្យលើការព្រាងសេចក្តីប្រកាស និងធ្វើការជាមួយនឹងរដ្ឋាភិបាលអាស៊ានដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស។ នៅមានការជជែកវែកញែកក្នុងចំណោមសង្គមស៊ីវិល និងរដ្ឋាភិបាលអំពីចំនុចខ្លាំង និងប្រសិទ្ធិភាពរបស់ស្ថាប័ននេះនៅឡើយ។

NGOs ជារឿយៗត្រូវបានអង្កេតឃើញថាជាអង្គការចម្បង ដែលធ្វើការសម្រាប់ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស។ ចំនួន NGOs មានការកើនឡើងជាលំដាប់នៅក្នុងតំបន់។ NGOs អនុវត្តសកម្មភាពដូចជាការអប់រំសិទ្ធិមនុស្ស ការតស៊ូមតិសិទ្ធិមនុស្ស សកម្មភាពតាមដាន និងស៊ើបអង្កេត ចងក្រងឯកសារសិទ្ធិមនុស្ស បណ្តឹង និងការប្តឹងផ្តល់ ធាតុចូលក្នុងការបង្កើតច្បាប់ និងគោលនយោបាយ។ កង្វល់ពេលបច្ចុប្បន្ននេះជាការការពារបុគ្គលិក NGO និងអ្នកការពារសិទ្ធិមនុស្សដទៃទៀតពីអំពើហិង្សា និងការវាយប្រហារ។

## ខ.សំណួរ

- តើអ្វីជាការលំបាកក្នុងការវាស់វែងស្ថានភាព ការការពារសិទ្ធិមនុស្សនៅក្នុងប្រទេសមួយ? តើអាចធ្វើទៅបាន ឬក៏អត់ក្នុងការវាស់វែងថាសិទ្ធិមនុស្សល្អ ឬអាក្រក់នៅក្នុងប្រទេសមួយ?
- រដ្ឋអាចផ្តល់សច្ចាប័នលើសន្ធិសញ្ញាជាច្រើន ប៉ុន្តែអាចមានការការពារសិទ្ធិមនុស្សទន់ខ្សោយ។ តើនេះកើតឡើងបានយ៉ាងដូចម្តេច?

- តើមានសិទ្ធិមនុស្សណាមួយជាក់លាក់ ដែលមិនមាននៅក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសអ្នកដែរឬទេ?
- តើសកម្មភាពអ្វីដែលបានបំពេញដោយ NHRI នៅក្នុងប្រទេសរបស់អ្នក? តើពួកគេអាចធ្វើឲ្យមានការផ្លាស់ប្តូរចំពោះការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សដែរឬទេ?
- តើUN ធ្វើការវាយតម្លៃប្រសិទ្ធិភាពនៃ NHRIs មួយយ៉ាងដូចម្តេច? តើដំណើរការនេះត្រឹមត្រូវ និងយុត្តិធម៌ដែរឬទេ?
- ហេតុអ្វីបានជាអាស៊ីជាតំបន់តែមួយគត់ដែលមិនមានប្រព័ន្ធសិទ្ធិមនុស្សថ្នាក់តំបន់?
- តើ AICHR ជាខ្លាអត់ចង្កូមមែនទេ ឬស្ថាប័ននេះអាចអភិវឌ្ឍន៍ក្លាយជាស្ថាប័នដែលមានឥទ្ធិពលខ្លាំងក្លាដូចជាស្ថាប័នសិទ្ធិមនុស្សអឺរ៉ុប?
- តើអ្វីខ្លះជាចំនុចខ្លាំង និងចំនុចខ្សោយរបស់ NGOs ដែលធ្វើការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស?
- សូមស្វែងរកឧទាហរណ៍មួយនៃសកម្មភាព ឬកម្មវិធីរបស់ NGO មួយនៅក្នុងប្រទេសរបស់អ្នកដែលធ្វើការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស។ តើកម្មវិធីនេះជោគជ័យដែរឬទេ? ហេតុអ្វីជាជោគជ័យ ឬហេតុអ្វីបានជាមិនជោគជ័យ?

# គ. ឯកសារពិគ្រោះបន្ថែម

## ស្ថានភាពនៃសិទ្ធិមនុស្ស

ព័ត៌មានពីស្ថានភាពសិទ្ធិមនុស្សនៅប្រទេសអាស៊ីអាគ្នេយ៍មាននៅក្នុង៖

- UNDP មានរបាយការណ៍អភិវឌ្ឍន៍ធនធានមនុស្សប្រចាំឆ្នាំ ដែលបញ្ជាក់ពីលេខរៀងនៃការអភិវឌ្ឍ។
- Freedom house មានរបាយការណ៍ប្រចាំឆ្នាំស្តីពីសេរីភាពលើពិភពលោក។
- តម្លាភាពអន្តរជាតិមានតារាងវាយតម្លៃពុករលួយរបស់ខ្លួន។

- The OHCHR មានទិន្នន័យស្ថាប័នសន្ធិសញ្ញាមួយដែលមានព័ត៌មានបច្ចុប្បន្នភាព ពីស្ថានភាពនៃការផ្តល់សច្ចាប័ន។

របាយការណ៍ទាំងនេះអាចរកបានតាមរយៈការស្រាវជ្រាវតាមអ៊ិនធឺណែត និងមិនចាំបាច់បង់សេវា។

រដ្ឋធម្មនុញ្ញរបស់រដ្ឋទាំងអស់មាននៅលើអ៊ិនធឺណែតជាភាសាអង់គ្លេស និងភាសាជាតិ។

អាចជាការពិបាកក្នុងការស្រាវជ្រាវព័ត៌មានពីប្រព័ន្ធច្បាប់នៅក្នុងប្រទេសមួយ។ ដោយសារតែឯកសារមិនមែនជាភាសាអង់គ្លេសទាំងអស់នោះទេ។ មានសារៈប្រយោជន៍ផងដែរក្នុងការពិនិត្យមើលរបាយការណ៍ មិនមែនចេញដោយរដ្ឋាភិបាលស្តីពីច្បាប់ និងការវាយតម្លៃរបស់ពួកគេលើតើថាច្បាប់ទាំងនេះមានមុខងារដូចម្តេច។

NHRIs

សម្រាប់ព័ត៌មានបន្ថែមស្តីពី NHRIs រួមមានទាំងស្ថាប័ន UN ដែលគ្រប់គ្រងគុណវុឌ្ឍិ សូមស្រាវជ្រាវបន្ថែមពី៖

- វេទិកាអាស៊ីប៉ាស៊ីហ្វិករបស់ស្ថាប័នសិទ្ធិមនុស្សជាតិ
- គណៈកម្មាធិការសម្របសម្រួលអន្តរជាតិដើម្បីសិទ្ធិមនុស្សជាតិ
- គោលការណ៍ទីក្រុងប៉ារីស៖ សេចក្តីសម្រេចមហាសន្និបាតអង្គការសហប្រជាជាតិ លេខ៤៨/១៣៤, ថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣

ស្ថាប័នទាំងនេះមានបញ្ជាក់លម្អិតពីរបាយការណ៍ស្តីពី NHRIs នៅអាស៊ីអាគ្នេយ៍។ អ្នកនិពន្ធដែលបានសរសេរពី NHRIs ដើម្បីជាការស្រាវជ្រាវបន្ថែមរួមមាន៖

- Brian Burdekin
- Catherine Renshaw
- Sonia Cardenas

## អាស៊ាន

ស្ថាប័នថ្នាក់តំបន់អឺរ៉ុប អាហ្វ្រិក និងអាមេរិកមានគេហទំព័រដែលមានព័ត៌មានជាច្រើន។ សម្រាប់ព័ត៌មានពីការផ្តួចផ្តើមការពារសិទ្ធិមនុស្សអាស៊ាន សូមធ្វើការស្រាវជ្រាវ៖

- គណៈកម្មាការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស
- ក្រុមការងារស្តីពីយន្តការសិទ្ធិមនុស្សអាស៊ាន
- សេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន

- ផែនការសហគមន៍សង្គម វប្បធម៌អាស៊ាន អ្នកនិពន្ធដែលបានសរសេរពីយន្តការអាស៊ាន ដើម្បីជាការស្រាវជ្រាវរួមមាន៖
- Yuyun Wahyuningrum
- Dr. Sriprapha Petcharamesree
- Hsien-Li Tan

## សង្គមស៊ីវិលអាស៊ីអាគ្នេយ៍

មាន NGOs ថ្នាក់តំបន់ជាច្រើននៅអាស៊ីអាគ្នេយ៍។ ដើម្បីជាការចាប់ផ្តើម អ្នកអាចក្រលេកមើលលើអង្គការខាងក្រោមដើម្បីស្វែងយល់ពីវិសាលភាព និងសកម្មភាពរបស់អង្គការទាំងនេះ។

- វេទិកាប្រជាជនអាស៊ាន៖ APF
- កិច្ចព្រមព្រៀងលើប្រជាជនជនជាតិដើមភាគតិចអាស៊ី៖ AIPP
- វេទិកាអាស៊ីប៉ាស៊ីហ្វិកស្តីពស្ត្រី ច្បាប់ និងការអភិវឌ្ឍ
- សន្និសិទសង្គមស៊ីវិលអាស៊ាន
- វេទិកាយុវជនអាស៊ាន
- បណ្តាញអាស៊ីស្តីពីការបោះឆ្នោតដោយសេរី៖ ANFREL
- វេទិកាអាស៊ីFORUM-ASIA

5

# ការការពារសិទ្ធិមនុស្សៈ អង្គការសហប្រជាជាតិ និងប្រព័ន្ធអន្តរជាតិ

ស្ថាប័នអន្តរជាតិសំខាន់បំផុតដែលធ្វើការការពារសិទ្ធិមនុស្ស គឺអង្គការសហប្រជាជាតិ (UN) ។ អាណត្តិរបស់ UN ធ្វើការលើកកម្ពស់ និងការពារសិទ្ធិមនុស្សជាសកល។ UN មានទំហំធំ ស្មុគ្រស្មាញ ហើយកាតព្វកិច្ច និងសកម្មភាព ពេលខ្លះជាន់គ្នា ដែលមានន័យថាមិនមានមធ្យោបាយសាមញ្ញ ក្នុងការសង្ខេបពីអ្វីគ្រប់យ៉ាងដែល UN ធ្វើដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្សនោះទេ។

ជំពូកនេះនឹងពិនិត្យមើលលើសិទ្ធិមនុស្សនៅ UN តាមវិធីសាស្ត្របីយ៉ាង។ ផ្នែកទីមួយនឹងពិនិត្យថាតើស្ថាប័ន និងកម្មវិធីរបស់ UN និងផ្នែកសិទ្ធិមនុស្សមិនជាក់លាក់ដទៃទៀតរបស់ស្ថាប័ននេះធ្វើការលើកកម្ពស់ និងការពារសិទ្ធិមនុស្សយ៉ាងដូចម្ដេច។ ផ្នែកទីពីរនឹងអង្កេតមើលលើក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលជាស្ថាប័ននយោបាយសំខាន់ធ្វើការគ្រប់គ្រងសិទ្ធិមនុស្សនៅ UN ។ ផ្នែកទីបីនឹងពិនិត្យលើស្ថាប័នសន្ធិសញ្ញា ដែលជាគណៈកម្មាធិការគ្រប់គ្រងសន្ធិសញ្ញាសិទ្ធិមនុស្សនីមួយៗ។

មុនពេលអង្កេតមើល UN ជាការសំខាន់ក្នុងការពិចារណាពីសារៈប្រយោជន៍របស់ UN ដល់ប្រទេសនៅអាស៊ីអាគ្នេយ៍។ ទោះបីជា UN ជាអង្គការអន្តរជាតិដែលមានភាពលេចធ្លោដែល ធ្វើការគ្រប់គ្រងទំនាក់ទំនងរវាងរដ្ឋក៏ដោយ អ្នកមួយចំនួនធ្វើការអះអាងថាស្ថាប័ននេះទន់ខ្សោយ ហើយមានឥទ្ធិពលតិចតួចលើសកម្មភាពរដ្ឋ។ នេះជាការពិតក្នុងន័យម្យ៉ាងដែលថាជាការពិបាកសម្រាប់ UN ក្នុងការបង្ខំរដ្ឋ ក្នុងការធ្វើសកម្មភាពតាមមធ្យោបាយជាក់លាក់ណាមួយ ហើយជាពិសេស ជាការពិត នៅក្នុងករណីក្នុងការធ្វើឲ្យរដ្ឋអនុលោមតាមកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួន។ យ៉ាងណាមិញ រដ្ឋពិតជាចូលរួមក្នុងការកិច្ចការរបស់ UN យ៉ាងយកចិត្តទុកដាក់។ ប្រទេសនៅអាស៊ីអាគ្នេយ៍មួយចំនួនមានតួនាទីយូរអង្វែង និងសកម្មក្នុងការសកម្មភាពជាច្រើនរបស់ UN ជាពិសេសហ្វីលីពីន ថៃ និងឥណ្ឌូនេស៊ី។ ហ្វីលីពីនជាប្រជាជាតិអាស៊ីអាគ្នេយ៍តែមួយគត់ដែលជាសមាជិកស្ថាបនិករបស់ UN ទោះបីជាថៃ និងមីយ៉ាន់ម៉ាបានចូលរួមជាសមាជិកភ្លាមៗបន្ទាប់ពីពេលនោះក៏ដោយ។ ប្រទេសនៅអាស៊ីអាគ្នេយ៍បានដើរតួនាទី យ៉ាងសកម្មក្នុងសកម្មភាពជាច្រើនរបស់ UN មិនថាតាមរយៈការទទួលជំនួយ អនុវត្តតួនាទីការទូត ធ្វើជាសមាជិករបស់គណៈកម្មាការ ឬស្ថាប័ន ឬព្រមព្រៀងលើសន្ធិសញ្ញា និងសេចក្ដីសម្រេចរបស់ UN នោះទេ។ សេចក្ដីសង្ខេបមួយនៃសកម្មភាពទាំងនេះមានបង្ហាញជូននៅក្នុងតារាងលេខ ៧.១ ខាងក្រោម។

សមាជិកភាពរបស់អង្គការសហប្រជាជាតិ ជាជំហានសំខាន់ដំបូងសម្រាប់រដ្ឋមួយឆ្ពោះទៅកាន់ការទទួលស្គាល់សិទ្ធិមនុស្ស ពីព្រោះដោយសារការចុះហត្ថលេខាលើធម្មនុញ្ញ UN រដ្ឋព្រមព្រៀងក្នុងការលើកកម្ពស់សិទ្ធិមនុស្ស និងចងកាតព្វកិច្ចដោយច្បាប់អន្តរជាតិ។ បន្ថែមពីលើនេះទៀត UN ជាកន្លែងដែលរដ្ឋអាចរួមចំនែកក្នុងការអភិវឌ្ឍសិទ្ធិមនុស្ស ដូចដែលបានអង្កេតឃើញជាក់ស្ដែង ជាឧទាហរណ៍ ដូចជាការណែនាំពីសិទ្ធិមនុស្សជុំវិញបញ្ហាផ្លូវភេទ។ UN ជាកន្លែងដែលរដ្ឋនៅអាស៊ីអាគ្នេយ៍ត្រូវតែការពារកំណត់ត្រាសិទ្ធិមនុស្សរបស់ពួកគេផងដែរ។ សម្រាប់ហេតុផលនេះ យើងអាចធ្វើការតទល់ជាមួយនឹងការអះអាងដែលថា UN មានអំណាច ឬឥទ្ធិពលតិចតួច។

## តារាង ៥-១: ប្រទេសអាស៊ីអាគ្នេយ៍នៅអង្គការសហប្រជាជាតិ

| ប្រទេស | ចូលរួម | ប្រវត្តិដ៏គួរឲ្យចាប់អារម្មណ៍ |
|---|---|---|
| ហ្វីលីពីន | ១៩៤៥ | • ធ្លាប់ជាសមាជិកនៃគណៈកម្មការសិទ្ធិមនុស្ស<br>• សមាជិកនៃក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិ ២០០៤-២០០៥ |
| ថៃ | ១៩៤៦ | • សមាជិកនៃក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិ (១៩៨៥-៨៦)។<br>• ម្ចាស់ផ្ទះ UNESCAP (គណៈកម្មការប្រចាំតំបន់អាស៊ី ប៉ាស៊ីភិច)<br>• ប្រធាននៃក្រុមប្រឹក្សាសិទ្ធិមនុស្ស (២០១០-២០១២)។ |
| មីយ៉ាន់ម៉ា | ១៩៤៨ | អគ្គលេខាធិការសហប្រជាជាតិពីឆ្នាំ ១៩៦១-១៩៧១ គឺ U Thant អ្នកការទូតភូមា |
| ឥណ្ឌូនេស៊ី | ១៩៥០ | • បានដកខ្លួនមួយរយៈខ្លីពីសហប្រជាជាតិនៅឆ្នាំ ១៩៦៥<br>• ប្រធាននៃគណៈកម្មការសិទ្ធិមនុស្ស (២០០៥)<br>• សមាជិកក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិ (២០០៧-២០០៨) |
| កម្ពុជា | ១៩៥៥ | • ធ្លាប់ជាតំណាងនៃខ្មែរក្រហមនៅដើមទសវត្សរ៍ទី ៨០<br>• ផ្នែកមួយនៃកម្មវិធីរក្សាសន្តិភាពសហប្រជាជាតិធំបំផុត (UNTAC) ត្រូវបានគេអនុវត្តនៅប្រទេសកម្ពុជាពីឆ្នាំ ១៩៩២-១៩៩៣<br>• វត្តមានដំបូងនៃ OHCHR ដែលមានការិយាល័យនៅក្នុងកម្ពុជានៅឆ្នាំ១៩៩៣ |
| ឡាវ | ១៩៥៥ | • មានកម្មវិធីសហប្រជាជាតិប្រហែល១១តាំងនៅប្រទេសកម្ពុជា រួមមាន UNDP, UNFPA, UNICEF, UNODC<br>• សកម្មក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍនៅជាប់សមុទ្រ(LLDCs) |
| ម៉ាឡេស៊ី | ១៩៥៧ | • ប្រធាននៃគណៈកម្មការសិទ្ធិមនុស្ស (១៩៩៥)<br>• សមាជិករដ្ឋនៃគណៈកម្មការសិទ្ធិមនុស្ស (២០០៥) |
| សិង្ហបុរី | ១៩៦៥ | • ជាសមាជិកក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិ ២០០១-២០០២<br>• គឺសកម្មក្នុងវគ្គទម្រង់របស់សហប្រជាជាតិ<br>• ជំនួយពីក្រុមអភិបាលកិច្ចសកលដែលមានរដ្ឋអាមេរិកតូច មធ្យម៣០ដែលធានាថាសម្លេងរបស់រដ្ឋតូចត្រូវបានដឹងលឺនៅសហប្រជាជាតិ |
| វៀតណាម | ១៩៧៧ | • ចូលរួមសហប្រជាជាតិបន្ទាប់ពីសង្គ្រាមអាមេរិក<br>• សមាជិកក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិ (២០០៨-២០០៩)<br>• មានភ្នាក់ងារសហប្រជាជាតិប្រហែល១៥ធ្វើការនៅក្នុងប្រទេស |
| ប្រ៊ុយណេ | ១៩៨៤ | • ជាសមាជិកនៃ OIC នៅសហប្រជាជាតិ<br>• មិនបាននៅជាក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិ ឬគណៈកម្មការសិទ្ធិមនុស្ស |
| ទីម័រខាងកើត | ២០០២ | • ចូលរួមជាសមាជិកទី១៩២ (បច្ចុប្បន្នមានសមាជិក១៩៣)<br>• ត្រូវបានគ្រប់គ្រងដោយសហប្រជាជាតិតាមរយៈ UNTAET (១៩៩៩-២០០២) |

# ៨.១ សិទ្ធិមនុស្សនៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិដ៏ធំទូលាយ

សិទ្ធិមនុស្សត្រូវបានលើកកម្ពស់ និងការពារក្នុងសកម្មភាពជាច្រើនរបស់ UN។ ខណៈពេលដែលរចនាសម្ព័ន្ធរបស់ UN មានទំហំធំ និងមានភាពស្មុគ្រស្មាញ គឺមានឋានៈនុក្រមលើប្រព័ន្ធនេះ។ មែកធាងសំខាន់ៗបំផុតរបស់ UN គឺ 'ស្ថាប័ន' ទាំងប្រាំមួយ។ ទោះបីជាមិនមានស្ថាប័នណាមួយ ក្នុងចំណោមស្ថាប័នទាំងនេះ មានអាណត្តិសិទ្ធិមនុស្សជាក់លាក់ក៏ដោយ ក៏ស្ថាប័នទាំងនេះធ្វើការពាក់ព័ន្ធនឹងបញ្ហាសិទ្ធិមនុស្សជាទៀងទាត់។ ស្ថាប័ន UN ចំនួនប្រាំនឹងត្រូវបានលើកយកមកពិភាក្សានៅក្នុងឯកសារនេះ (ចាប់តាំងពីទឹកដីក្រោមអាណាព្យាបាលចុងក្រោយបានក្លាយជាប្រទេសនៅក្នុងទសវត្សឆ្នាំ ១៩៩០ ក្រុមប្រឹក្សាអាណាព្យាបាលមិនមានសកម្មភាពទៀតនោះទេ)៖

- ក្រុមប្រឹក្សាសន្តិសុខ (UNSC)
- មហាសន្និបាត (UNGA)
- តុលាការយុត្តិធម៌អន្តរជាតិ (ICJ)
- អគ្គលេខាធិការដ្ឋាន UN ដែលត្រូវបានដឹកនាំដោយអគ្គលេខាធិការ (UNSG)
- ក្រុមប្រឹក្សាសេដ្ឋកិច្ចនឹងសង្គម (ECOSOC)

## ក្រុមប្រឹក្សាសន្តិសុខ

UNSC មានសមាជិកចំនួន១៥៖ សមាជិកអចិន្ត្រៃយ៍ចំនួន ៥ (ចិន បារាំង សហភាពសូវៀត ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក) និងសមាជិកមិនអចិន្ត្រៃយ៍ចំនួន១០ ដែលត្រូវបានជ្រើសរើសសម្រាប់អាណត្តិពីរឆ្នាំដោយមហាសន្និបាត។ មុខងាររបស់ NUSC គឺធ្វើការធានានូវសន្តិភាព និងសន្តិសុខអន្តរជាតិ ហើយស្ថាប័ននេះ អាចចូលខ្លួនពាក់ព័ន្ធនឹងក្នុងស្ថានភាព ដែលត្រូវបានចាត់ទុកថាជា "ការគម្រាមកំហែងដល់សន្តិភាព និងសន្តិសុខអន្តរជាតិ" ប៉ុណ្ណោះ។ ក្រុមប្រឹក្សាសន្តិសុខជាស្ថាប័នដែលមានអំណាចមួយ ដោយសារស្ថាប័ននេះអាចចេញសេចក្ដីសម្រេចដែលចងកាតព្វកិច្ចផ្លូវច្បាប់ ហើយមានអំណាចក្នុងការដាក់ទណ្ឌកម្មលើរដ្ឋដែលមិនអនុលោមតាមសេចក្ដីសម្រេចរបស់ខ្លួន។ អំណាចទាំងនេះរួមមានការដាក់ទណ្ឌកម្មលើរដ្ឋ ការប្រើប្រាស់កងកម្លាំងរក្សាសន្តិភាព និងការប្រើប្រាស់កងកម្លាំង។ ខណៈពេលដែលសេចក្ដីសម្រេចទាំងនេះភាគច្រើនពាក់ព័ន្ធនឹងបញ្ហាសន្តិភាព និងជម្លោះ UNSC ពិតជារួមចំនែកក្នុងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សប្រាកដមែន។ មិនមានស្ថាប័នណាផ្សេងមានអំណាចបែបនេះនោះទេ។

ដោយហេតុថាជម្លោះតែងតែពាក់ព័ន្ធនឹងការគម្រាមកំហែងដល់សិទ្ធិមនុស្ស UNSC តែងតែដោះស្រាយបញ្ហាកង្វល់សិទ្ធិមនុស្ស។ សកម្មភាពដំបូងស្ដីពីសិទ្ធិមនុស្សរួមមាន

ការដាក់ទណ្ឌកម្មលើរ៉ូដេស៊ី Rhodesia ក្នុងឆ្នាំ១៩៦៦ និងអាហ្វ្រិកខាងត្បូងក្នុងទសវត្សឆ្នាំ ១៩៧០ ដោយសារតែប្រទេសទាំងនេះប្រើប្រាស់ច្បាប់អាប៉ាថេត ដែលបានរើសអើងលើប្រជាជនស្បែកខ្មៅដែលជាប្រជាជនភាគច្រើនក្នុងប្រទេស។ UNSC មានភាពសកម្មក្នុងការរក្សាសន្តិភាព (ក្នុងប្រទេសដូចជាកុងហ្គោ សាយប្រ៉ស និងព្រំដែនឥណ្ឌា និងប៉ាគីស្ថាន) ពីទសវត្សឆ្នាំ ១៩៥០ ដល់ ១៩៧០ ប៉ុន្តែទើបតែបន្ទាប់ពីឆ្នាំ១៩៩០ ប៉ុណ្ណោះដែល UNSC បានចាប់ផ្តើមធ្វើការដោះស្រាយការរំលោភបំពានសិទ្ធិមនុស្សក្នុងសេចក្តីសម្រេចរបស់ខ្លួន។ អ្វីដែលស្ថាប័ននេះបានធ្វើលើបញ្ហាសិទ្ធិមនុស្សគឺធ្វើការពិចារណាថា "ការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ និងជាប្រព័ន្ធណាមួយ" ជាការគម្រាមកំហែងដល់សន្តិភាព និងសន្តិសុខអន្តរជាតិ ដូចនេះក្រុមប្រឹក្សាអាចបញ្ចេញសកម្មភាពបាន។ ការផ្លាស់ប្តូរនិយមន័យនេះមានន័យថា UNSC អាចចូលទៅកាន់ប្រទេសដោយមិនចាំបាច់មានការអនុញ្ញាត ពីប្រទេសទាំងនោះ ប្រសិនជាការរំលោភបំពានធ្ងន់ធ្ងរ និងជាប្រព័ន្ធកំពុងតែកើតមានឡើង។ ឧទាហរណ៍ពាក់ព័ន្ធករណីនេះ រួមមានសកម្មភាពក្នុងប្រទេសអ៊ីរ៉ាក់ សូម៉ាលី និងអតីតយូហ្គោស្លាវី (សកម្មភាពទាំងអស់នេះកើតឡើងក្នុងទសវត្សឆ្នាំ ១៩៩០) ដែល UNSC បានអនុញ្ញាតឲ្យមានការប្រើប្រាស់កម្លាំងយោធា។ ការផ្លាស់ប្តូរសកម្មភាព UNSC ជាលទ្ធផលនៃសង្គ្រាមត្រជាក់ដែលបញ្ឈប់នូវភាពអសកម្មក្នុងការធ្វើសេចក្តីសម្រេចចិត្ត ដោយសារតាំងពីមុនសហភាពសូវៀត ឬ សហរដ្ឋអាមេរិកតែងតែ វេតូ លើការផ្តួចផ្តើមរបស់ប្រទេសដទៃ។ ការផ្លាស់ប្តូរកាន់តែសំខាន់ជាងនេះ ដោយសារ UNSC កាន់តែមានភាពសកម្មក្នុងអំឡុងពេលប្រាំឆ្នាំបន្ទាប់ពីសង្គ្រាមត្រជាក់ (ពីឆ្នាំ១៩៩១-១៩៩៦) ដែលសកម្មជាងអំឡុងពេល ៤៥នៃសង្គ្រាមត្រជាក់ទាំងមូល។ យ៉ាងណាមិញ សកម្មភាពដែលមានការកើនឡើងនេះ មិនតែងតែទទួលបានជោគជ័យនោះទេ ដោយសារតែបេសកកម្មទៅកាន់យូហ្គោស្លាវី និងសូម៉ាលីបរាជ័យក្នុងការបង្កើតសន្តិភាព និងការពារដល់ជនស៊ីវិល ហើយនឹងការឆ្លើយតបទៅនឹងអំពើប្រល័យពូជសាសន៍នៅរ្វ៉ាន់ដា មានភាពយឺតយ៉ាវពេកក្នុងការជួយសង្គ្រោះជីវិតប្រជាជន។ កាលពីពេលថ្មីៗនេះ UNSC មានភាពសកម្មតិចជាងមុនក្នុងការអនុញ្ញាតឲ្យមានការឆ្លើយតបយោធា លើការរំលោភបំពានសិទ្ធិមនុស្សដែលមានការរីករាលដាល ដែលអាចបញ្ជាក់ ដោយសារកង្វះខាតនូវការឆ្លើយចំពោះសង្គ្រាមស៊ីវិលដែលកំពុងកើតមានឡើងក្នុងប្រទេសស៊ីរី។

## ការពិភាក្សា និងការជជែកវែកញែក

### តើនយោបាយបញ្ឈប់ការការពារសិទ្ធិមនុស្សដោយ UNSC មែនដែរឬទេ?

ជាការល្បីដែលថាសមាជិកអចិន្ត្រៃយ៍ទាំងប្រាំ មានសិទ្ធិវេតូលើសេចក្តីសម្រេចណាមួយក៏ដោយ។ សេចក្តីសម្រេចស្តីពីបញ្ហាអ៊ីស្រាអែលត្រូវបានវេតូ ដោយសហរដ្ឋអាមេរិកជាទៀងទាត់ ក៏ដូចជាសេចក្តីសម្រេចលើបញ្ហាស៊ីរី ត្រូវបានវេតូដោយរុស្ស៊ី និងចិនដែរ។ វេតូអនុញ្ញាតឲ្យប្រទេសទាំងនេះជួយដល់សម្ព័ន្ធមិត្តរបស់ខ្លួន ឬជៀសវាងសំណួរសិទ្ធិមនុស្សពិបាកៗមកលើពួកគេ។ លើសពីនេះទៀត ចំណេះដឹងពីវេតូមានន័យថាបញ្ហាជាច្រើនដូចជាឆែកនីយ៉ា (Chechnya) ឬ អ៊ុយហ្គួរ (Uyghurs) នឹងមិនត្រូវបានសូម្បីតែពិភាក្សា។ មានការជជែកវែកញែកជាច្រើនពីអំណាចវេតូ។ ម្យ៉ាង ហាក់បីដូចជាអយុត្តិធម៌ដោយសារមានតែសមាជិកអចិន្ត្រៃយ៍ទើបទទួលបានសិទ្ធិវេតូ ដោយសារតែពួកគេជាអ្នកឈ្នះសង្គ្រាមលោកលើកទីពីរ ហើយរដ្ឋមហាអំណាចដទៃមិនមានបុព្វសិទ្ធិនេះ។ ម្យ៉ាងវិញទៀត សមាជិកអចិន្ត្រៃយ៍ ជាមហាអំណាចប្រចាំតំបន់ខ្លាំងក្លា ហើយមានការពាក់ព័ន្ធនឹងជម្លោះ និងការរក្សាសន្តិភាពជាងរដ្ឋភាគច្រើន។

យ៉ាងណាមិញ មិនមានការប្រើប្រាស់វេតូញឹកញ៉ាប់នោះទេ៖ មានតែចំនួន ១៩ប៉ុណ្ណោះក្នុងរយៈពេលដប់ឆ្នាំកន្លងមកនេះ ហើយ ៩ ក្នុងចំណោមនេះពាក់ព័ន្ធនឹងប៉ាឡេស្ទីន ឬស៊ីរី។ នេះបើប្រៀបធៀបទៅនឹងសេចក្តីសម្រេចដែលបានចេញចំនួន ៧០០ ដោយគ្មានវេតូនោះ នៅក្នុងអំឡុងពេលតែជាមួយគ្នានេះ មានន័យថាវេតូមានត្រឹមតែ ២% នៃសេចក្តីសម្រេចទាំងអស់ប៉ុណ្ណោះ។ លើសពីនេះទៀត ជាវិធាន រដ្ឋមិនចូលចិត្តវេតូលើសេចក្តីសម្រេចនោះទេ ហើយព្យាយាមជៀសវាងវេតូ ដែលមានន័យថាពួកគេត្រូវបានបង្ខំឲ្យធ្វើដូចនេះដែលជាជម្រើសចុងក្រោយ ហើយមិនមានការគាំទ្រទូលំទូលាយនោះទេ។

***តើវេតូធ្វើឲ្យ UNSC មិនមានឥទ្ធិពលលើការការពារសិទ្ធិមនុស្សមែនដែរឬទេ?***

UNSC អាចឆ្លើយតបនឹងការរំលោភបំពានសិទ្ធិមនុស្សក្នុងស្ថានភាពជម្លោះតាមរយៈការផ្តល់កងរក្សាសន្តិភាព អនុញ្ញាតឲ្យមានការប្រើប្រាស់កងកម្លាំង ឬបង្កើតអាជ្ញាធរអន្តរកាលក្នុងការគ្រប់គ្រងការឆ្លងកាត់របស់ប្រទេសមួយ ពីជម្លោះមកសន្តិភាព។ UNSC អាចការពារសិទ្ធិមនុស្សផងដែរ តាមរយៈបញ្ជូនរឿងក្តីមក តុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC) ដែលអាចកាត់ក្តីលើបុគ្គលដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរដូចជាបទឧក្រិដ្ឋប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឬបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ។ ដូចដែលនឹង

ត្រូវបានពិភាក្សានៅក្នុងជំពូកក្រោយ UNSC មានអំណាចក្នុងការបញ្ជាដល់ ICC ដើម្បីធ្វើការស៊ើបអង្កេតលើបទឧក្រិដ្ឋធ្ងន់ធ្ងរក្នុងអំឡុងពេលជម្លោះ។ ជាពិសេស នេះគួរតែកម្រិតលើមធ្យោបាយដែលបុគ្គល កងកម្លាំងយោធា ឬរដ្ឋក្នុងការធ្វើសង្គ្រាម។ UNSC ឆ្លើយតបនឹងការរំលោភបំពានតាមរយៈការចេញសេចក្តីសម្រេច ដែលទទួលស្គាល់ ឬធ្វើឲ្យប្រសើរឡើងនូវការការពារក្រុមងាយរងគ្រោះ។ ឧទាហរណ៍ រួមមានសេចក្តីសម្រេចស្តីពីការការពារស្ត្រីនៅក្នុងជម្លោះ (ដែលមានបញ្ជាក់លម្អិតក្នុងប្រអប់ខាងក្រោម) ស្តីពីទាហានជាកុមារ (ក្នុងចំណោមសេចក្តីសម្រេចជាច្រើនស្តីពីប្រធានបទនេះមានដូចជា សេចក្តីសម្រេចលេខ ១២៦១ ស្តីពីទាហានជាកុមារ និងលេខ ១៦១២ ស្តីពីយន្តការរាយការណ៍) និងជនស៊ីវិលដែលត្រូវបានចាប់ខ្លួនក្នុងស្ថានភាពជម្លោះ (ក្នុងចំណោមសេចក្តីសម្រេចជាច្រើនស្តីពីប្រធានបទនេះមានដូចជា សេចក្តីសម្រេចលេខ ១២៦៥ ស្តីពីការការពារជនស៊ីវិល និងលេខ ១៦៧៤ ស្តីពីការបង្ការជម្លោះតាមរយៈប្រជាធិបតេយ្យ។

# ផ្តោតសំខាន់លើ

## សេចក្តីសម្រេចក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ១៣២៥ និងរបាយការណ៍អាជ្ញាប័ណ្ណក្នុងការរំលោភសេពសន្ថវៈ

សេចក្តីសម្រេច UNSC លេខ ១៣២៥ ត្រូវបានអនុម័តជាឯកឆ័ននៅថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០០០ ដែលអំពាវនាវ ″គ្រប់ភាគីទាំងអស់នៃជម្លោះ ប្រដាប់អាវុធក្នុងការគោរពពេញលេញលើច្បាប់អន្តរជាតិដែលអនុវត្តចំពោះសិទ្ធិ និងការការពារស្ត្រី និងកុមារី ជាពិសេសជាជនស៊ីវិល ជាពិសេសកាតព្វកិច្ចរបស់ពួកគេក្នុង អនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩″។

បញ្ហាចម្បងចំនួនបួនដែលបានដោះស្រាយដោយសេចក្តីសម្រេចលេខ ១៣២៥ គឺ៖ (១) ការកើនឡើងនៃការចូលរួម និងតំណាងនៃស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត (២) យកចិត្តទុកដាក់លើតម្រូវការការពារជាក់លាក់របស់ស្ត្រី (៣) សារៈសំខាន់នៃការមានទស្សនៈយែនឌ័រលើការចរចារក្រោយជម្លោះនិង (៤)សារៈសំខាន់នៃការបណ្តុះបណ្តាលចំនេះដឹងយែនឌ័រ។

ពីខាងក្រៅ សេចក្តីសម្រេចនេះហាក់បីដូចជាមិនទទួលបានជោគជ័យនោះទេ ដោយសារស្ត្រីបន្តប្រឈមនឹងអំពើហិង្សានៅក្នុងជម្លោះ ហើយពួកគេនៅតែរងគ្រោះនៅក្នុងការអភិវឌ្ឍក្រោយជម្លោះ។ យ៉ាងណាមិញ បច្ចុប្បន្ននេះសន្តិសុខ របស់ស្ត្រីបានក្លាយជាប្រធានបទស្នូលនៅលើរបៀបវារៈរបស់ UNSC។ វាជាផ្លូវវែងឆ្ងាយដើម្បីឲ្យមានការការពារដល់ស្ត្រីក្នុងស្ថានភាពជម្លោះ ប៉ុន្តែសេចក្តីសម្រេចលេខ ១៣២៥ និងសេចក្តីសម្រេចបន្តបន្ថែមឲ្យសេចក្តីសម្រេចនេះ ដែលគ្របដណ្តប់បញ្ហាដូចជាការប្រើប្រាស់រំលោភសេពសន្ថវៈជាអាវុធនៃសង្គ្រាម (សេចក្តីសម្រេចលេខ ១៨២០) បង្ហាញថាមានការអភិវឌ្ឍមួយចំនួនលើវិស័យនេះ។

ឧទាហរណ៍៖ ទោះបីជាភូមាជាសមាជិកមួយរបស់ UN និងជារដ្ឋហត្ថលេខីលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ក៏ដោយ ក៏របាយការណ៍ "អាជ្ញាប័ណ្ណក្នុងការរំលោភសេពសន្ថវៈ″ ដោយមូលនិធិសិទ្ធិមនុស្សជនជាតិសាន និងបណ្តាញសកម្មភាពដើម្បីស្ត្រីជនជាតិសាន បានបង្ហាញថារបបនេះមិនបានអនុវត្តច្បាប់ទាំងនេះក្នុងចំណោមទាហានរបស់ខ្លួននោះទេ។ របាយការណ៍នេះបញ្ជាក់លម្អិតពីការរំលោភសេពសន្ថវៈជាប្រព័ន្ធ និងមានការរាលដាលដែលបានប្រព្រឹត្តដោយយោធាភូមា រវាងឆ្នាំ ១៩៩៦ និង២០០១។ បទឧក្រិដ្ឋទាំងនេះនៅតែមិនត្រូវបានកាត់ទោស ទោះបីជារបាយការណ៍

អះអាងថាពួកគេប្តេជ្ញាចិត្តក្នុងការបង្រ្កាប និងបំភិតបំភ័យ ជនជាតិភាគតិចរដ្ឋសានក៏ដោយ។ របាយការណ៍នេះបង្ហាញយ៉ាងច្បាស់ថាការការពារស្ត្រី (ដូចដែលបានបញ្ជាក់ក្នុងសេចក្តីសម្រេចលេខ ១៣២៥ និង១៨២០) មិនត្រូវបានឆ្លើយតបដោយកម្លាំងយោធារបស់មីយ៉ាន់ម៉ានោះទេ។

## មហាសន្និបាត

UNGA គឺជាស្ថាប័នតំណាងសំខាន់បំផុតរបស់ UN ហើយដើរតួនាទីជាកន្លែងមួយដែលសមាជិកទាំងអស់របស់ UN (១៩៣ប្រទេសគិតត្រឹមឆ្នាំ២០១៩) អាចជួបប្រជុំ។ សមាជិកជួបប្រជុំនៅខែកញ្ញារៀងរាល់ឆ្នាំ រយៈពេលពីបីទៅបួនខែសម្រាប់ការពិភាក្សាលើបញ្ហាទាំងអស់ពាក់ព័ន្ធនឹង UN។ ប្រធានបទដែលអាចត្រូវបានពិភាក្សាមានចាប់ពីបរិស្ថាន ដល់សេដ្ឋកិច្ច ការអប់រំ និងសកម្មភាព UN ដទៃទៀត។ UNGA អាចមានឥទ្ធិពលលើសិទ្ធិមនុស្សតាមមធ្យោបាយជាច្រើន។ UNGA អាចចេញសេចក្តីសម្រេចស្តីពីសិទ្ធិមនុស្ស ប៉ុន្តែដោយសារស្ថាប័ននេះមិនមានអំណាចដូចគ្នានឹងជាមួយនឹង UNSC ដើម្បីចេញសេចក្តីសម្រេចដែលចងកាតព្វកិច្ចផ្លូវច្បាប់នោះ សេចក្តីសម្រេចទាំងនេះត្រូវបានចាត់ទុកថាជាអនុសាសន៍។ សេចក្តីសម្រេចទាំងនេះអាចស្នើឡើងថាតើសិទ្ធិមនុស្សប៉ុន្មាននឹងគួរតែត្រូវបានលើកកម្ពស់ និងការពារដោយ UN ហើយអាចខុសៗគ្នាតាមប្រធានបទ ដោយជាពេជ្យឃាម ភតិការី និងដើម្បីបញ្ចប់ទោសប្រហារជីវិតជាដើម។ សេចក្តីសម្រេចត្រូវបានចេញជាទូទៅដោយការគាំទ្រជាឯកច្ឆន្ទ ប៉ុន្តែសេចក្តីសម្រេចមួយចំនួនពីបញ្ហាធ្ងន់ធ្ងរ ត្រូវឆ្លងកាត់ការបោះឆ្នោតដោយសម្លេងពីរភាគបីនៃអ្នកដែលមានវត្តមាន ហើយបោះឆ្នោតដើម្បីអនុញ្ញាតលើសេចក្តីសម្រេច។ UNGA អាចធ្វើរដ្ឋខ្មាសគេដោយសារកំណត់ត្រាសិទ្ធិមនុស្សមិនល្អ តាមរយៈការចេញសេចក្តីសម្រេចក្នុងការរិះគន់ពួកគេ។ ស្រដៀងគ្នានេះផងដែរ សេចក្តីសម្រេចនេះអាចអំពាវនាវដល់ UNSC ឬស្ថាប័នដទៃក្នុង UN ក្នុងការធ្វើការស្រាវជ្រាវបន្ថែម ឬសកម្មភាពបន្ថែមលើប្រទេស ដែលមានកំណត់ត្រាសិទ្ធិមនុស្សមិនល្អទាំងនោះ។ ជាចុងក្រោយ UNGA ជាកន្លែងដែលសន្ធិសញ្ញាសិទ្ធិមនុស្សត្រូវបានអនុញ្ញាត និងជាកន្លែងដែលសន្ធិសញ្ញាទាំងនេះ ត្រូវបានបើកឲ្យចុះហត្ថលេខាដោយរដ្ឋសមាជិក។ ដូចនេះ ខណៈពេលដែល UNGA មិនមានអំណាចដូចនឹង UNSC ស្ថាប័ននេះអាចមានឥទ្ធិពល និងបង្ហាញផ្លូវដល់គោលនយោបាយនៅកម្រិតអន្តរជាតិ។

## តុលាការយុត្តិធម៌អន្តរជាតិ

ICJ ពេលខ្លះត្រូវបានហៅថាជាតុលាការពិភពលោក មានកាតព្វកិច្ចគ្រប់គ្រងច្បាប់អន្តរជាតិ ហើយជាស្ថាប័នសូលក្នុងការសម្រេចថាតើច្បាប់អន្តរជាតិត្រូវបានស្វែងយល់

និងកាត់សេចក្តីយ៉ាងដូចម្តេច។ ជាទូទៅតាមរយៈវិធីសាស្ត្រពីរយ៉ាង៖ ជាបឋមតាមរយៈការចេញ មតិផ្តល់យោបល់ ជាទូទៅក្នុងឆ្លើយតបនឹងសំណួរដែលបានចោទសួរដោយស្ថាប័នមួយនៅ UN (ជាឧទាហរណ៍ មហាសន្និបាតរបស់ UNSC) និងទីពីរតាមរយៈការដោះស្រាយវិវាទរវាងប្រទេស។ ជាមួយនឹងប្រវត្តិជាង ៩០ ឆ្នាំរបស់ខ្លួន (ICJ ដំបូងឡើយជាតុលាការអចិន្ត្រៃយ៍យុត្តិធម៌អន្តរជាតិនៅក្នុងសង្គមប្រជាជាតិ) តុលាការនេះបានចេញសេចក្តីសម្រេចពីរបីស្តីពីសិទ្ធិមនុស្ស។ ចាប់តាំងពីសង្គ្រាមលោកលើកទីពីរមួយ តុលាការនេះបានសម្រេចរឿងក្តីជាង ១៦០ ករណី មានប្រហែលជាមួយភាគបីនៃរឿងក្តីនោះប៉ុណ្ណោះ (ដោយផ្អែកលើវិធីសាស្ត្រនៃការរាប់រឿងក្តីទាំងនេះ) បានក្រលេកមើលលើបញ្ហាសិទ្ធិមនុស្ស។ យ៉ាងណាមិញដូចគ្នានឹង UNSC ផងដែរ តុលាការនេះកាលពីពេលថ្មីៗនេះមានភាពសកម្មក្នុងវិស័យនេះ។ នេះមិនអាចនិយាយបានថាវាមិនពាក់ព័ន្ធនោះទេ ដោយសារតែការរកឃើញរបស់ខ្លួន (ជាឧទាហរណ៍ និត្យានុកូលភាពនៃខលក្ខខណ្ឌ) មានការបង្កប់ន័យលើថាតើសិទ្ធិមនុស្សត្រូវបានស្វែងយល់ និងការពារយ៉ាងដូចម្តេច។

ICJ បានរួមចំនែកលើការស្វែងយល់ពីសិទ្ធិមនុស្សតាមសេចក្តីសម្រេចរបស់ខ្លួនលើស្វ័យសម្រេច។ នៅក្នុងរឿងក្តីមួយដែលបានធ្វើការសម្រេចចិត្តនៅក្នុងឆ្នាំ ១៩៩៥ ប៉័ទុយហ្គាល់(អ្នកគ្រប់គ្រងអាណានិគមលើទីម័រខាងកើត) បានដាក់ពាក្យបណ្តឹងលើប្រទេសអូស្ត្រាលី សម្រាប់ការចុះកិច្ចព្រមព្រៀងជាមួយនឹងប្រទេសឥណ្ឌូនេស៊ីពាក់ព័ន្ធនឹងសិទ្ធិរបស់ខ្លួនលើរណ្តៅឧស្ម័ននៅក្នុងទឹកដីទីម័រខាងកើត។ ប៉័ទុយហ្គាល់បានអះអាងថាប្រជាជនទីម័រខាងកើត (និងប៉័ទុយហ្គាល់) គួរតែជាអ្នកទទួលបានផលប្រយោជន៍ពីរណ្តៅឧស្ម័នមិនមែនអូស្ត្រាលីនោះទេ។ រឿងក្តីមួយទៀតពាក់ព័ន្ធនឹងសិទ្ធិមនុស្សលើនិត្យានុកូលភាពរបស់ជញ្ជាំងរបស់អ៊ីស្រាអែលជុំវិញទឹកដីប៉ាឡេស្ទីន។ ICJ បានរកឃើញថាជញ្ជាំងនេះ ជាការរំលោភបំពានលើកាតព្វកិច្ចអន្តរជាតិផ្សេងៗដោយរួមមានសេរីភាពក្នុងការដើរហើរ ដែលជាសិទ្ធិមួយក្នុងចំណោមសិទ្ធិផ្សេងទៀត។ មានរឿងក្តីសំខាន់ៗស្តីពីការប្រល័យពូជសាសន៍ក្នុងប្រទេសយូហ្គោស្លាវី ឧក្រិដ្ឋសង្គ្រាមក្នុងប្រទេសកុងហ្គោ និងនិត្យានុកូលភាពនៃអាវុធនុយក្លេអ៊ែរ។ ICJ មានភាពសកម្មក្នុងអាស៊ីអាគ្នេយ៍លើបណ្តឹងពីបញ្ហាទឹកដី ដូចជាករណីប្រាសាទលើព្រំដែនប្រទេសថៃ និងកម្ពុជា (ប្រាវីហានដោយប្រទេសថៃ និងព្រះវិហារដោយប្រទេសកម្ពុជា) និងលើជម្លោះអធិបតេយ្យលើកោះរវាងម៉ាឡេស៊ី និងឥណ្ឌូនេស៊ី និងរវាងម៉ាឡេស៊ី និងសឹង្ហបូរី។

## អគ្គលេខាធិការ UN

អគ្គលេខាធិការ UN ជាស្ថាប័នដែលគ្រប់គ្រងការងាររបស់ UN ស្ថាប័ននេះធ្វើឲ្យ UN បំពេញមុខងាររបស់ខ្លួនបាន ប្រកបដោយភាពរលូនដោយធ្វើការត្រួតពិនិត្យកាតព្វកិច្ចជាមូលដ្ឋាន ដូចជាចាប់ពីការសម្អាតបន្ទប់ រហូតដល់ការងារដែលមានការប្រឈមដូច

ជាការរៀបចំកងរក្សាសន្តិភាពជាដើម។ អគ្គលេខាធិការរបស់ UN ត្រូវបានគ្រប់គ្រងដោយអគ្គលេខាធិការ UN (UNSG) ដែលជាបុគ្គលត្រូវបានបោះឆ្នោតជ្រើសរើសដើម្បីដឹកនាំ UN។ UNSG បច្ចុប្បន្នគឺលោក បាន គីមូន ជនជាតិកូរ៉េខាងត្បូង។ អតីត UNSG មួយរូបមកពីអាស៊ីអាគ្នេយ៍ គឺលោក យូ ថាន់ (ភូមា) ដែលកាន់តំណែងជាអគ្គលេខាធិការពីឆ្នាំ ១៩៦១ ដល់ ១៩៧១។ តួនាទីរបស់ UNSG ក្នុងបញ្ហាសិទ្ធិមនុស្សអាចខុសៗគ្នាខ្លាំង។ UNSGs មួយចំនួនមានឥទ្ធិពលជាដុំកំភួនះ ជាឧទាហរណ៍ លោកកូហ្វីអាណាន់បានធ្វើវគ្គយ៉ាងទូលំទូលាយនៅក្នុង UN ដែលមានឥទ្ធិពលវិជ្ជមានលើតួនាទីរបស់សិទ្ធិមនុស្ស។ គាត់ដើរតួយ៉ាងសំខាន់ក្នុងការផ្លាស់ប្តូរពីគណៈកម្មាការសិទ្ធិមនុស្សទៅជាក្រុមប្រឹក្សាសិទ្ធិមនុស្ស (ដែលមានបញ្ជាក់លម្អិតនៅផ្នែកបន្ទាប់) ។ អាណាន់ជាអ្នកតស៊ូមតិដ៏ខ្លាំងក្លា ក្នុងការធ្វើឲ្យសិទ្ធិក្លាយជាបញ្ហាអន្តរវិស័យនៅក្នុងការដឹកនាំ UN ដែលត្រូវបានបញ្ជ្រៀបក្នុងវិស័យដូចជាកិច្ចការ មនុស្សធម៌ ការអភិវឌ្ឍ និងសន្តិភាព និងសន្តិសុខ។ UNSGs ពីមុនៗមានភាពអកម្មក្នុងការគាំទ្រលើសិទ្ធិមនុស្ស។

អគ្គលេខាធិការ UN មានអំណាចមួយពាក់ព័ន្ធនឹងសិទ្ធិមនុស្សក្នុងការធ្វើការតែងតាំងអ្នកតំណាងពិសេស ដែលត្រូវបានតែងតាំងដើម្បីគាំទ្រ UNSG លើកង្វល់សិទ្ធិមនុស្ស ។ អ្នកតំណាងទាំងនេះអាចផ្តោតសំខាន់លើបញ្ហាសិទ្ធិមនុស្សតាមប្រធានបទ ឬភូមិសាស្ត្រដោយផ្អែកលើអាណត្តិរបស់ខ្លួន និងអាចសម្របសម្រួលការចរចារ និងស៊ើបអង្កេតការរំលោភបំពានសិទ្ធិមនុស្សជំនួសឲ្យអគ្គលេខាធិការ UN។ មានអ្នកតំណាងពិសេសមួយរូបត្រូវបានតែងតាំងដើម្បីរាយការណ៍ពីប្រទេសមីយ៉ាន់ម៉ា។

## ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម

ខណៈពេលដែលវិស័យចម្បងនៃការងាររបស់ ECOSOC គឺការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ស្ថាប័ននេះអាចបង្កើតភ្នាក់ងារក្នុងការគ្រប់គ្រងសិទ្ធិមនុស្ស ដែលភ្នាក់ងារសំខាន់បំផុតគឺគណៈកម្មាការសិទ្ធិមនុស្ស។ ជាមួយនឹងគណៈកម្មាការនេះមានគណៈកម្មាការស្តីពីស្ត្រី និងវេទិកាអចិន្ត្រៃយ៍ស្តីពីបញ្ហាជនជាតិដើមភាគតិច ដែលធ្វើការលើសិទ្ធិមនុស្ស។ គណៈកម្មាការសិទ្ធិមនុស្ស (ត្រូវបានជំនួសដោយក្រុមប្រឹក្សាសិទ្ធិមនុស្សក្នុងឆ្នាំ ២០០៦) នឹងត្រូវបានពិភាក្សាក្នុងផ្នែកបន្ទាប់។

## ស្ថាប័នដទៃទៀត

UN មានមូលនិធិ និងកម្មវិធីជាច្រើនដែលធ្វើការលើបញ្ហាសិទ្ធិមនុស្ស។ តារាងនៃមូលនិធិ និងកម្មវិធីនេះមានច្រើនដែលមិនអាចបញ្ជាក់បានអស់ ប៉ុន្តែមូលនិធិ និងកម្មវិធីសំខាន់ៗរួមមាន៖

- UNICEF៖ មូលនិធិបន្ទាន់សម្រាប់កុមារអន្តរជាតិរបស់អង្គការសហប្រជាជាតិ (UNICEF) ជាភ្នាក់ងាររបស់ UN មួយដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៤៦ ហើយមានមូលដ្ឋានក្នុងទីក្រុងញូវយ៉ក។ ជាដំបូង មានគោលបំណងក្នុងការជួយដល់កុមារបន្ទាប់ពីសង្គ្រាមលោកលើកទីពីរ សកម្មភាពរបស់ភ្នាក់ងារនេះមានភាពចម្រុះដូចជាលើផ្នែកសុខភាព ការអប់រំ និងសិទ្ធិកុមារ។

- UN-Women៖ អង្គការសហប្រជាជាតិដើម្បីស្ត្រី (ស្ថាប័នអង្គការសហប្រជាជាតិដើម្បីសមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រី) ជាអង្គការថ្មីមួយដែលបានលេចចេញពីអង្គការស្ត្រីរបស់ UN ជាច្រើនដូចជា UNIFEM (មូលនិធិអភិវឌ្ឍរបស់ UN ដើម្បីស្ត្រី) និងDAW (ការិយាល័យសម្រាប់ការអភិវឌ្ឍរបស់ស្ត្រី)។ UN-Women លើកកម្ពស់ការផ្តល់អំណាចដល់ស្ត្រីតាមរយៈសកម្មភាព លើការប្រឆាំងអំពើហិង្សាលើស្ត្រី សន្តិភាព ភាពជាអ្នកដឹកនាំ និងការផ្តល់អំណាចសេដ្ឋកិច្ច។

- UNHCR ៖ ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សទទួលបន្ទុកជនភៀសខ្លួន ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៥០ ដោយ UNGA ដើម្បីការពារ និងលើកកម្ពស់សិទ្ធិជនភៀសខ្លួនទូទាំងពិភពលោក។ UNHCR មានសកម្មភាពជាច្រើនក្នុងការលើកកម្ពស់ និងការការពារសិទ្ធិជនភៀសខ្លួន។

## ផ្តោតសំខាន់លើ

### តាមដានព័ត៌មានពីសកម្មភាពរបស់UN

ដូចដែលជំពូកនេះបានបញ្ជាក់ច្បាស់ យន្តការលើសិទ្ធិមនុស្សនៅ UN មានការវិវត្តន៍ និងបច្ចុប្បន្នភាពជាបន្តបន្ទាប់។ ព័ត៌មាននៅក្នុងជំពូកនេះនឹងពិនិត្យមើលលើ UN រហូតដល់ឆ្នាំ២០១៥ ប៉ុន្តែសូម្បីតែក្នុងអំឡុងពេលនោះមានការអភិវឌ្ឍជាចម្បងជាមួយនឹងការបង្កើតនីតិវិធីទំនាក់ទំនងនឹងបណ្តឹងសម្រាប់កុមារ ការបោះឆ្នោតនៅក្រុមប្រឹក្សាសិទ្ធិមនុស្ស ស្ថាប័នសន្ធិសញ្ញាពលករទេសន្តប្រវេសន៍ជម្រះបណ្តឹងលើកទីមួយរបស់ខ្លួន ហើយនឹងជម្លោះសាសនា វប្បធម៌ប្រពៃណី ផ្លូវភេទ និងអាជីវកម្មភេទត្រូវបានពិភាក្សាវែកញែកដោយស្ថាប័នសិទ្ធិមនុស្សរបស់UN។

កិច្ចការការពារសិទ្ធិមនុស្សជាអន្តរជាតិបានកើតឡើង កាលពីពេលថ្មីៗនេះប៉ុណ្ណោះ ហើយការអភិវឌ្ឍភាគច្រើនកំពុងតែកើតមាន។ ជំពូកនេះគូសបញ្ជាក់អ្វីដែលបានកើតឡើងមួយចំនួនតាំងពីដើមមកដល់ពេលបច្ចុប្បន្ន ប៉ុន្តែសិស្សនិស្សិតត្រូវចងចាំថាព័ត៌មានផ្លាស់ប្តូររាល់ៗ ហើយដើម្បីតាមដានព័ត៌មានជាមួយនឹងសកម្មភាពរបស់ UN គឺត្រូវពិនិត្យមើលលើការរាយការណ៍របស់ស្ថាប័នពីព្រឹត្តការណ៍នៅ UN មិនថាតាមរយៈប្រព័ន្ធផ្សព្វផ្សាយ UN របាយការណ៍ NGOs លើសិទ្ធិមនុស្សនៅUN (ដូចជា ISHR)

ឬការតាមដានជាទៀងទាត់លើគេហទំព័រ OHCHR សម្រាប់ព័ត៌មានដែលមានបច្ចុប្បន្នភាពនោះទេ។

# ៥.២ ស្ថាប័នសិទ្ធិមនុស្សរបស់ UN

ស្ថាប័ន UN ត្រូវបានបែងចែកជាពីរប្រភេទ៖ (១) ស្ថាប័នធម្មនុញ្ញ (ស្ថាប័នដែលត្រូវបានបង្កើតឡើងដោយធម្មនុញ្ញរបស់UN) និង (២) ស្ថាប័នសន្ធិសញ្ញា (ស្ថាប័នដែលភ្ជាប់ជាមួយនឹងសន្ធិសញ្ញាសិទ្ធិមនុស្ស)។ ការបែងចែកនេះមានការចាំបាច់ ដោយសារប្រភេទទាំងពីរនេះមានសមាសភាព និងគោលបំណងខុសៗគ្នា។ ភាពខុសគ្នាសំខាន់មួយគឺថាស្ថាប័នធម្មនុញ្ញទទួលបានអំណាចរបស់ពួកគេពីធម្មនុញ្ញរបស់ UN ហើយដូចនេះស្ថាប័នទាំងនេះពាក់ព័ន្ធនឹងរដ្ឋសមាជិកទាំងអស់របស់ UN ដែលត្រូវអនុវត្តតាមធម្មនុញ្ញ។ ស្ថាប័នសន្ធិសញ្ញាពាក់ព័ន្ធនឹងរដ្ឋ ដែលបានផ្តល់សច្ចាប័នលើសន្ធិសញ្ញាតែប៉ុណ្ណោះ។ សន្ធិសញ្ញានីមួយៗមានស្ថាប័នរបស់ខ្លួន ហើយធ្វើកិច្ចការដាច់ដោយឡែកពីគ្នា។ ជាបឋមជំពូកនេះនិងក្រលេកមើលលើស្ថាប័នធម្មនុញ្ញសំខាន់ៗ មុននឹងធ្វើការពិភាក្សាពីស្ថាប័នសន្ធិសញ្ញា។

## តារាង ៥-២: ភាពខុសគ្នាជាចម្បងរវាងស្ថាប័នធម្មនុញ្ញនិងស្ថាប័នសន្ធិសញ្ញា

| | ស្ថាប័នធម្មនុញ្ញ | ស្ថាប័នសន្ធិសញ្ញា |
|---|---|---|
| បង្កើតដោយ | ធម្មនុញ្ញសហប្រជាជាតិ | សន្ធិសញ្ញាសិទ្ធិមនុស្ស |
| វិសាលភាព | សិទ្ធិមនុស្សយោងតាមធម្មនុញ្ញសហប្រជាជាតិ | សិទ្ធិមនុស្សដូចដែលបានគូសបញ្ជាក់នៅក្នុងសន្ធិសញ្ញា |
| រដ្ឋអនុលោមច្បាប់ | សមាជិករបស់សហប្រជាជាតិ | រដ្ឋដែលបានផ្តល់សច្ចាប័នទៅលើសន្ធិសញ្ញា |
| យន្តការនៃការពិនិត្យ | នីតិវិធីពិសេស៖ អ្នករាយការណ៍ពិសេស<br>ការពិនិត្យតាមពេលវេលាកំណត់ជាសកល នីតិវិធីបណ្តឹង | របាយការណ៍រដ្ឋភាគី បណ្តឹងបុគ្គល<br>ដំណើរទស្សនកិច្ច |
| សមាសភាព | តំណាងពីរដ្ឋជាសមាជិករបស់សហប្រជាជាតិ | អ្នកជំនាញបុគ្គលដែលត្រូវបានតែងតាំងដោយរដ្ឋ |

## ៤.២.១ ស្ថាប័នធម្មនុញ្ញ៖ ក្រុមប្រឹក្សាសិទ្ធិមនុស្ស

ស្ថាប័នរបស់ UN ដែលបានបញ្ជាក់លម្អិតខាងលើអាចត្រូវបានចាត់ទុកថាជាស្ថាប័នធម្មនុញ្ញ។ យ៉ាងណាមិញ ស្ថាប័នដែលបានបញ្ជាក់ខាងលើ មានសកម្មភាពខុសគ្នាយ៉ាងច្រើន និងមិនធ្វើការតែលើសិទ្ធិមនុស្សប៉ុណ្ណោះនោះទេ។ ស្ថាប័នធម្មនុញ្ញចម្បងដែលធ្វើការជាពិសេសលើសិទ្ធិមនុស្សគឺ HRC ។ នៅពេលបង្កើតដំបូងនៅឆ្នាំ ១៩៤៦ ស្ថាប័ននេះមានឈ្មោះថាគណៈកម្មាការសិទ្ធិមនុស្ស ហើយបានក្លាយជាក្រុមប្រឹក្សាក្នុងឆ្នាំ ២០០៦។ នៅការិយាល័យនៃក្រុមប្រឹក្សា រដ្ឋជួបប្រជុំ និងពិភាក្សាលើបញ្ហាសិទ្ធិមនុស្ស ចេញសេចក្ដីសម្រេច និងផ្ដួចផ្ដើមសកម្មភាពមួយចំនួនដើម្បីការពារសិទ្ធិមនុស្ស។ ពេលបច្ចុប្បន្ននេះ រដ្ឋជួបប្រជុំយ៉ាងតិចបីដងក្នុងមួយឆ្នាំ។ ជាធម្មតាមានចំនុចជាច្រើនលើរបៀបវារៈដោយរួមមាន៖ ការពិភាក្សាលើការការពារសិទ្ធិមនុស្ស (ដែលបានបញ្ជាក់ខាងលើ) ពិភាក្សាកង្វល់សិទ្ធិមនុស្សជាពិសេស (ដូចជាបញ្ហាមនុស្សចាស់ ឬអំពើប្រល័យពូជសាសន៍) និងស្ដាប់របាយការណ៍ពីអ្នកជំនាញការ ដែលបានតែងតាំងដោយ HRC។

HRC ជាស្ថាប័ននយោបាយ ដោយសារបុគ្គល ៤៧ រូបនៅក្នុងស្ថាប័នេះតំណាងឲ្យរដ្ឋរបស់ខ្លួន និងមិនធ្វើការវាយតម្លៃបុគ្គលនោះទេ ដែលនេះខុសពីបុគ្គលក្នុងស្ថាប័នជំនាញដោយសារពួកគេធ្វើសេចក្ដីសម្រេច ដោយផ្អែកលើជំនាញការរបស់ពួកគេមិនដោយសារតំណាងឲ្យរដ្ឋដែលពួកគេតំណាងនោះទេ។ ដោយសារ HRC មានលក្ខណៈនយោបាយ នោះធ្វើឲ្យមានដែនកំណត់ និងសារៈប្រយោជន៍។ ជាការសំខាន់សម្រាប់រដ្ឋក្នុងការផ្ដល់ទស្សនៈខ្លួន លើសិទ្ធិមនុស្សដោយសាររដ្ឋទាំងនោះត្រូវបានចងកាតព្វកិច្ចដោយសន្ធិសញ្ញាដែលពួកគេបានផ្ដល់សច្ចាប័ន ហើយពួកគេជាក្រុមដឹកមុខដែលមានកាតព្វកិច្ចចំពោះសិទ្ធិប្រជាជន។ ជាការពិត រដ្ឋនឹងជួបជុំដើម្បីធ្វើការពិភាក្សាពីវិធីក្នុងការការពារសិទ្ធិមនុស្ស ទំនាក់ទំនងនឹងរដ្ឋដែលបានរំលោភសិទ្ធិមនុស្ស និងចាប់បង្ខំអនុវត្តស្តង់ដារសិទ្ធិមនុស្ស។ យ៉ាងណាមិញ រដ្ឋមួយចំនួនមានជំនាញក្នុងការជៀសវាងកង្វល់សិទ្ធិមនុស្ស ហើយធ្វើឲ្យនយោបាយមានឥទ្ធិពលលើអាកប្បកិរិយារបស់ពួកគេលើសិទ្ធិមនុស្ស។ ឧទាហរណ៍ ជារឿយៗរដ្ឋ ជៀងវាងការរិះគន់គ្នាទៅវិញទៅមកលើកំណត់ត្រាសិទ្ធិមនុស្សរបស់ពួកគេ ដោយដឹងថា ប្រសិនជាពួកគេធ្វើការរិះគន់ពួកគេនឹងត្រូវបានរិះគន់វិញជាក់ជាមិនខាន។ ស្រដៀងគ្នានេះដែរ នយោបាយរដ្ឋមួយជារឿយៗមានឥទ្ធិពលលើសេចក្ដីសម្រេច ស្ដីពីសិទ្ធិមនុស្ស ជាពិសេសជុំវិញកង្វល់ដែលមានលក្ខណៈនយោបាយ ដូចជាបញ្ហាប៉ាឡេស្ទីន ឬសិទ្ធិរបស់ស្រីស្រឡាញ់ស្រី និងប្រុសស្រឡាញ់ប្រុសជាដើម។ បញ្ហានេះជាច្រើនបានកើតឡើងក្នុងគណៈកម្មាការសិទ្ធិមនុស្ស ដែលត្រូវបានជំនួសដោយក្រុមប្រឹក្សា។ អតីត UNSG លោក កូហ្វី អាណាន់ បាននិយាយថាគណៈកម្មាការមិនបំពេញមុខងាររបស់ខ្លួន និងមានលក្ខណៈ

នយោបាយខ្លាំង ដូចដែលភស្តុតាងបានបង្ហាញដោយតួនាទីរបស់លីប៊ីជាប្រធាននៃគណៈកម្មាការ និងកង្វះក្នុងការឆ្លើយតបបន្ទាន់លើការរំលោភបំពានក្នុងប្រទេសហ្ស៊ីមបាវេ ឆេកនីយ៉ា និងស៊ូដង់។ ស្ថានភាពទាំងនេះមានការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ និងជាប្រព័ន្ធ ប៉ុន្តែមិនមានការឆ្លើយយ៉ាងយកចិត្តទុកដាក់ដោយគណៈកម្មាការនោះទេ។ អ្នកជំនាញជាន់ខ្ពស់នៅ UN ដោយរួមមានលោក កូហ្វី អាណាន់ បានស្នើឲ្យមានការជំនួសគណៈកម្មាការនេះដោយស្ថាប័នថ្មីមួយ ដែលអាចមានរចនាសម្ព័ន្ធ និងសកម្មភាពថ្មី។ ក្រុមប្រឹក្សាដែលត្រូវបានកែទម្រង់ព្យាយាមក្នុងការជៀសវាងការបរាជ័យរបស់គណៈកម្មាការដោយធ្វើការបង្ហាញនូវការផ្លាស់ប្តូរថ្មី៖

១. បោះឆ្នោត៖ សមាជិកត្រូវបានបោះឆ្នោតជ្រើសរើសដោយមហាសន្និបាតដោយការបោះឆ្នោតសម្ងាត់។ ការបោះឆ្នោតជាសម្ងាត់មានការចាំបាច់ ក្នុងការជម្រុញឲ្យប្រទេសដទៃពីតំបន់តែមួយ មិនបោះឆ្នោតឲ្យប្រទេសដែលមានកំណត់ត្រាសិទ្ធិមនុស្សមិនល្អ ទោះបីជាពួកគេជា 'ប្រទេសជាមិត្ត' ក្នុងតំបន់ក៏ដោយ។ ការបោះឆ្នោតជាសម្ងាត់មានភាពជោគជ័យ ក្នុងការបង្ការប្រទេសដែលមានកំណត់ត្រាសិទ្ធិមនុស្សមិនល្អ (ដូចជាស៊ូដង់ ស៊ីរី បេឡារូស ស្រីលង្កា និងអាហ្សឺបៃដែន) ពីការជ្រើសរើសដោយសារតែមិនមានការគាំទ្រគ្រប់គ្រាន់ពីតំបន់របស់ពួកគេ។

២. ត្រួតពិនិត្យលើកំណត់ត្រាសិទ្ធិមនុស្ស៖ ក្រុមប្រឹក្សាបានចាប់ផ្តើមដំណើរការត្រួតពិនិត្យកំណត់ត្រាសិទ្ធិមនុស្សរបស់សមាជិកខ្លួនទាំងអស់ ដែលត្រូវបានហៅថាជាការត្រួតពិនិត្យតាមពេលវេលាកំណត់ (ដែលមានបញ្ជាក់លម្អិតខាងក្រោម)។ ពីមុន រដ្ឋអាចជៀសវាងការរិះគន់ណាមួយលើកំណត់ត្រាសិទ្ធិមនុស្សរបស់ពួកគេ ប៉ុន្តែបច្ចុប្បន្ននេះមិនអាចទៅរួចនោះទេ។

៣.ចំនួនសមាជិក៖ មានគំរូ និងយុទ្ធសាស្ត្រផ្សេងៗគ្នាដែលបានស្នើឡើងសម្រាប់ក្រុមប្រឹក្សាថ្មីនេះ។ អ្នកខ្លះចង់បានក្រុមប្រឹក្សាដែលមានលក្ខណៈជាសកលដែលមានសមាជិកទាំងអស់នៃ UN ។ អ្នកខ្លះទៀតចង់បានទ្រង់ទ្រាយតូចជាងនេះ (ហើយអ្នកនិយាយថាមានគុណភាពខ្ពស់ជាងមុន) នៃសមាជិកភាព ដោយមានត្រឹមតែ ១៥ សមាជិកបានហើយ។ នៅចុងបញ្ចប់ ទំហំត្រូវបានកាត់បន្ថយពី ៥៣ មកត្រឹម ៤៧ មានការកាត់បន្ថយចំនួនបន្តិចបន្តួច ដែលជាការពិតជាក់ស្តែងមិនមានភាពខុសគ្នាជាដុំកំភួននោះទេ។

៤. ឋានៈរបស់ក្រុមប្រឹក្សា៖ មានការអះអាងថាក្រុមប្រឹក្សាគួរតែមានតួនាទីខ្ពស់ជាងរចនាសម្ព័ន្ធ UN។ ជាជាងនៅពីក្រោមការគ្រប់គ្រងរបស់ស្ថាប័ន ECOSOC បច្ចុប្បន្ននេះក្រុមប្រឹក្សារាយការណ៍ដោយផ្ទាល់ដល់ UNGA ធ្វើឲ្យស្ថាប័ននេះកាន់

តែមានទំនួលខុសត្រូវដោយសារ UNGA តំណាងឲ្យសមាជិកទាំងអស់របស់ UN ជាជាង ECOSOC ដែលមានសមាជិកត្រឹមតែ ៥៤ ប៉ុណ្ណោះ។

## សមាជិកភាពរបស់ក្រុមប្រឹក្សា

HRC មានសមាជិកចំនួន ៤៧ ប្រទេស ដែលត្រូវបានតែងតាំងសម្រាប់អាណត្តិរយៈពេលបីឆ្នាំ ដែលប្រហែលជាមួយភាគបី (១៦ប្រទេស) ត្រូវបានជ្រើសរើសរៀងរាល់ឆ្នាំ។ តំបន់នីមួយៗត្រូវបានផ្តល់ជូននៅកន្លែងមួយចំនួនដើម្បីបំពេញ៖

- អាស៊ី និងអាហ្វ្រិក៖ ១៣ កន្លែងសម្រាប់តំបន់នីមួយៗ
- អាមេរិកឡាទីន៖ ៨កន្លែង
- អឺរ៉ុបខាងលើ៖ ៨ កន្លែង
- អឺរ៉ុបខាងកើត៖ ៧ កន្លែង

ប្រទេសអាស៊ីអាគ្នេយ៍ជាច្រើនបានប្តូរវេនធ្វើជាសមាជិក HRC។

### ទស្សនៈទាន

### ប្លុកប្រចាំតំបន់របស់អង្គការសហប្រជាជាតិ

ស្ថាប័ននយោបាយនៅ UN ជារឿយៗតែងតាំងប្រទេសដោយផ្អែកលើកូតាប្រចាំតំបន់។ សម្រាប់គោលបំណងនេះ ពិភពលោកត្រូវបានបែងចែក ចេញជាតំបន់ភូមិសាស្ត្រចំនួនប្រាំតំបន់ដែលមានទំហំខុសៗគ្នា៖ អាហ្វ្រិក (៥៤ប្រទេស) អាស៊ីប៉ាស៊ីហ្វិក (៥៣ប្រទេស) អាមេរិកឡាទីន និងការ៉ាប់បៀន (៣៣ប្រទេស) អឺរ៉ុបខាងលិច (២៨ ប្រទេស) និងអឺរ៉ុបខាងកើត (២៣ប្រទេស)។ ក្រុមអឺរ៉ុបខាងកើតរួមមានអូស្ត្រាលី កាណាដា អាមេរិក និងញូវហ្ស៊ីឡែន។

ឯកភាពនយោបាយនៃក្រុមទាំងនេះមានភាពខុសៗគ្នា។ ប្រទេសអាហ្វ្រិកជារឿយៗបោះឆ្នោតដូចគ្នា ហើយអាចបង្កើតជាប្លុកប្រចាំតំបន់ដ៏ខ្លាំងមួយ។ ផ្ទុយទៅវិញ អាស៊ីមានឯកភាពតិចជាង។ កោះនៅប៉ាស៊ីហ្វិក ដែលមានប្រហែលជា ២០% នៃក្រុមជារឿយៗមិនយល់ស្របជាមួយប្រទេសអាស៊ីដទៃទៀត។ អាស៊ីខាងត្បូង កណ្ដាល និងខាងកើត ជារឿយៗមានគោលជំហរខុសៗគ្នាលើបញ្ហាផ្សេងៗ។ ប្លុកបោះឆ្នោតដទៃទៀត ដូចជា OIC (អង្គការសហប្រតិបត្តិការអ៊ីស្លាម) មានឯកភាពជាងគេក្នុងក្រុមប្រចាំតំបន់។

## ៨.២.២ សកម្មភាពក្រុមប្រឹក្សាសិទ្ធិមនុស្សក្នុងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស

HRC មានយន្តការមួយចំនួនដែលខ្លួនអាចប្រើប្រាស់សម្រាប់ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស។ ជាឧទាហរណ៍ 'នីតិវិធីពិសេស' ឬប្រជាជនដែលអាចរាយការណ៍ពីកង្វល់សិទ្ធិមនុស្ស ជារឿយៗត្រូវបានប្រើប្រាស់ដើម្បីតាមដានសិទ្ធិមនុស្ស។ យន្តការដទៃទៀតរួមមានការត្រួតពិនិត្យតាមពេលវេលាកំណត់ជាសកល និងនីតិវិធីបណ្ដឹងប្រឆាំងនឹងរដ្ឋដែលបានរំលោភបំពានសិទ្ធិមនុស្សជាប្រព័ន្ធ។ សកម្មភាពទាំងនេះត្រូវបានបញ្ជាក់លម្អិតដូចខាងក្រោម៖

# ការត្រួតពិនិត្យតាមពេលវេលាកំណត់ជាសកល

ការត្រួតពិនិត្យតាមពេលវេលាកំណត់ជាសកល (UPR) ប្រហែលជាយន្តការត្រួតពិនិត្យដែលមានវិសាលភាព និង (យន្តការនេះត្រួតពិនិត្យគ្រប់ប្រទេសទាំងអស់) អាណត្តិធំជាងគេ (យន្តការនេះត្រួតពិនិត្យគ្រប់វិស័យស្នូលនៃសិទ្ធិមនុស្ស)។ UPR ជាដំណើរការត្រួតពិនិត្យដែលជាការតម្រូវចាំបាច់មួយ ដែលតាមរយៈនេះកំណត់ត្រាសិទ្ធិមនុស្សរបស់រដ្ឋសមាជិក UN នីមួយៗត្រូវបានធ្វើការត្រួតពិនិត្យរៀងរាល់បួនឆ្នាំម្តង។ ការត្រួតពិនិត្យគ្របដណ្តប់លើសិទ្ធិមនុស្ស ដូចដែលបានបញ្ជាក់ក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស សន្ធិសញ្ញាសិទ្ធិមនុស្សដែលបានព្រមព្រៀងដោយរដ្ឋ និងការប្តេជ្ញា និងការសន្យាដោយស្ម័គ្រចិត្តផ្សេងទៀតដោយរដ្ឋ។ UPRបានចាប់ផ្តើមនៅខែមេសា ឆ្នាំ២០០៨ ដែលវដ្តទីពីរចាប់ផ្តើមនៅក្នុងឆ្នាំ ២០១២។ មកដល់ពេលបច្ចុប្បន្ននេះ ប្រទេសនីមួយមានការត្រួតពិនិត្យយ៉ាងតិចណាស់ម្តង ហើយគិតត្រឹមឆ្នាំ២០១៤ ប្រទេសជាង ១០០ ត្រូវបានត្រួតពិនិត្យចំនួនពីរដង ក្នុងអំឡុងពេលនៃការត្រួតពិនិត្យរដ្ឋពិភាក្សាជាសាធារណៈ ពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសរបស់ខ្លួន និងធ្វើការឆ្លើយតបនឹងមតិយោបល់ និងការរិះគន់ពីរដ្ឋដទៃ។ ដំណើរការត្រួតពិនិត្យចាប់ផ្តើមជាមួយនឹងការប្រគល់ជូនឯកសារចំនួនបី៖

១. ព័ត៌មាន UN៖ ជាឯកសារចងក្រងដែលមានចំនួន ដប់ ទំព័រនៃព័ត៌មានពី UN ដែលបានរៀបចំដោយ OHCHR ដែលគូសបញ្ជាក់ពីស្ថានភាពសិទ្ធិមនុស្សរបស់ប្រទេសពីទស្សនៈរបស់UN ។ នេះអាចរួមបញ្ចូលព័ត៌មានពីអ្នករាយការណ៍ពិសេស ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស និងស្ថាប័ន UN ដទៃទៀតដូចជា UNICEF ឬ UN-Women។

២. របាយការណ៍ភាគីពាក់ព័ន្ធ៖ របាយការណ៍១០ទំព័រពីសង្គមស៊ីវិល ( និងក្នុងករណីខ្លះពី NHRIs) ដែលជាទូទៅត្រូវបានធ្វើឡើងដោយ NGOs និងស្ថាប័នស្រដៀងគ្នានេះ។ ជារឿយៗ NGOs នឹងជួបប្រជុំដើម្បីធ្វើការៀបចំខ្លឹមសារនៃរបាយការណ៍ និងធ្វើការសម្រេចពីបញ្ហាគន្លឹះដើម្បីបញ្ចូលក្នុងសេចក្តីសង្ខេប១០ទំព័រ។ របាយការណ៍នេះនឹងត្រូវបានផ្ញើជូន OHCHR ដែលនឹងបញ្ចូលក្នុងរបាយការណ៍ចុងក្រោយ។ ប្រទេសតូចៗប្រហែលជាមិនមានការលំបាកខ្លាំង ក្នុងការរៀបចំឲ្យសង្គមស៊ីវិលក្នុងការបញ្ជូនរបាយការណ៍នោះទេ ប៉ុន្តែប្រទេសធំៗ និងមានភាពចម្រុះ (ដូចជាឥណ្ឌា) ប្រហែលជាមានការប្រឈមខ្លាំងក្នុងការច្របាច់ចូលគ្នានូវ NGOs រាប់ពាន់ទៅជាឯកសារដែលមាន១០ទំព័រ។

៣. របាយការណ៍រដ្ឋ៖ របាយការណ៍២០ទំព័រ ដែលបានរៀបចំដោយរដ្ឋដែលស្ថិតក្រោមការត្រួតពិនិត្យ ដែលជា ‘របាយការណ៍ជាតិ’ ។

ដំណើរការត្រួតពិនិត្យជាក់ស្តែង នឹងធ្វើឡើងនៅក្រុមប្រឹក្សាសិទ្ធិមនុស្សនៅទីក្រុងហ្សឺណែវ។ ជាបឋម រដ្ឋដែលស្ថិតក្រោមការត្រួតពិនិត្យបញ្ជូនប្រតិភូទៅកាន់ទីក្រុងហ្សឺណែវ ជាកន្លែងដែលធ្វើការបង្ហាញពីរបាយការណ៍ជាតិ។ រដ្ឋនឹងធ្វើបទបង្ហាញស្តីពីស្ថានភាពសិទ្ធិមនុស្សរបស់ខ្លួនដូចដែលបានពិភាក្សាក្នុងរបាយការណ៍ និងទទួលការចោទសួរ និងសេចក្តីថ្លែងការណ៍មួយចំនួនពីរដ្ឋដទៃនៅក្នុងកិច្ចប្រជុំដែលមានរយៈពេលបីម៉ោងដែលត្រូវបានហៅថាជា ‘កិច្ចសន្ទនាសកម្ម’ ។ ពាក្យនេះបង្កប់ន័យថាការត្រួតពិនិត្យ មិនមែនមានន័យថាដើម្បីធ្វើការរិះគន់ ឬដាក់ទោសទណ្ឌលើរដ្ឋនោះទេ ប៉ុន្តែជាការពិភាក្សាប្រកបដោយស្ថាបនា លើវិធីក្នុងការធ្វើឲ្យប្រសើរឡើងនូវសិទ្ធិមនុស្ស។ មិនមែនជាការចំលែកនោះទេ ដែលប្រទេសចំនួន ៥០ ធ្វើការចោទសួរលើប្រទេសមួយចំនួន។ បន្ទាប់ពីកិច្ចសន្ទនា ឯកសារលទ្ធផលត្រូវបានធ្វើឡើងដែលផ្តល់ជាអនុសាសន៍ដល់រដ្ឋ។ អនុសាសន៍មិនចងកាតព្វកិច្ចនោះទេ ប៉ុន្តែអាចមានទម្ងន់នយោបាយ។ រដ្ឋអាចជ្រើសរើសផងដែរក្នុងការទទួល ឬបដិសេធ (ដែលត្រូវបានហៅថា ‘កំណត់សម្គាល់’) លើអនុសាសន៍។ ទោះបីជាសមាជិក សង្គមស៊ីវិលអាចចូលរួមពួកគេមិនត្រូវបានអនុញ្ញាតក្នុងការសួរសំណួរនោះទេ។ យ៉ាងណាមិញ ពួកគេអាចចូលរួមដោយធ្វើការតស៊ូមតិជានឹងរដ្ឋគាំទ្រ ដើម្បីឲ្យទទួលយកនូវទស្សនៈ និងសំណើររបស់ពួកគេ។

## ផ្តោតសំខាន់លើ

### ដំណើរការ UPR ជាក់ស្តែង- ករណីសិក្សានៃការត្រួតពិនិត្យលើកទីមួយរបស់ឥណ្ឌូនេស៊ីក្នុងខែមេសា ឆ្នាំ២០០៨

ឥណ្ឌូនេស៊ីជាប្រទេសមួយក្នុងចំណោមប្រទេសដំបូង ដែលត្រូវបានត្រួតពិនិត្យ។ នៅក្នុង ‘របាយការណ៍ជាតិ’ របស់ខ្លួន ឥណ្ឌូនេស៊ីបាននិយាយថាខ្លួនចាត់ទុកសេរីភាពសាសនាជាការសំខាន់ និងត្រូវបានការពារតាមរយៈ ICCPR (ដែលខ្លួនជាភាគី) ហើយរដ្ឋធម្មនុញ្ញរបស់ខ្លួនបានធានាការលើកកម្ពស់ និងការការពារសិទ្ធិនេះ។ យ៉ាងណាមិញ នៅក្នុងរបាយការណ៍ពីស្ថាប័ន UN ដោយរួមមានអ្នករាយការណ៍ពិសេសស្តីពីសេរីភាពសាសនា ឬជំនឿ ថាមានការកត់សម្គាល់លើកង្វល់មួយចំនួន ដូចជា៖

- ហាមឃាត់ការស្មុំកូនរវាងសាសនា

- មានច្បាប់មួយដែលបានកំណត់ថាការគោរពអាចធ្វើទៅបាន លុះត្រាណាមានការអនុញ្ញាតពីរដ្ឋាភិបាលប៉ុណ្ណោះ
- ការលំបាកដែលបានជួបប្រទះដោយបុរស និងស្ត្រីនៃសាសនាខុសគ្នាក្នុងការចុះសំបុត្រអាពាហ៍ពិពាហ៍
- មិនមានការផ្តល់ជូនសំបុត្រដល់កុមារនៃអាពាហ៍ពិពាហ៍អន្តរសាសនា និង
- វាយប្រហារ និងគម្រាមកំហែងលើគ្រួសារ អាម៉ាឌីយ៉ាស Ahmadiy yah។

បន្ថែមពីលើនេះទៀត របាយការណ៍ NGO ដែលត្រូវបានសរសេរដោយក្រុមចំនួន ១៧ ដោយរួមមានទាំង NGO ពីប្រទេសឥណ្ឌូនេស៊ី NGOs អន្តរជាតិ និង NHRI របស់ឥណ្ឌូនេស៊ី បានកត់សម្គាល់ពីការអនុគ្រោះត្រូវបានផ្តល់ជូនដល់សាសនាផ្លូវការ ច្បាប់ប្លាសភីម (Blaspheme) (ដែលចាត់ទុកជាបទឧក្រិដ្ឋនូវសកម្មភាពសាសនាមួយចំនួន) និងការវាយប្រហារលើ (Armadiyahs)។ ដូចនេះ ច្បាស់ណាស់មានភាពខុសគ្នាលើស្ថានភាពនៃសិទ្ធិសាសនារវាងរបាយការណ៍ទាំងបី។ ក្នុងអំឡុងពេលធ្វើការចោទសួរលើរដ្ឋ ភាពខុសគ្នាត្រូវបានលើកឡើងដោយអ៊ីតាលី ដែលបានសួរថាតើឥណ្ឌូនេស៊ីមានបំណងក្នុងការផ្លាស់ប្តូរច្បាប់របស់ខ្លួនស្តីពីសាសនា ដើម្បីឲ្យមានសង្គតភាពជាមួយនឹងស្តង់ដារ ICCPR ដែរឬទេ។ លើសពីនេះទៀត ចក្រភពអង់គ្លេសបានសួរទៅឥណ្ឌូនេស៊ីដើម្បីផ្តល់មតិយោបល់លើការវាយប្រហារប្រឆាំងនឹង Armadiyahs។

នៅក្នុងឯកសារលទ្ធផល មិនមានអនុសាសន៍ជាក់លាក់ពីសេរីភាពសាសនានោះទេ។ ផ្ទុយទៅវិញ អនុសាសន៍មួយបាននិយាយដោយសង្ខេបថា ៖ ″ ខណៈពេលដែលទទួលស្គាល់ការខិតខំប្រឹងប្រែងដោយរដ្ឋាភិបាលឥណ្ឌូនេស៊ី ជាអនុសាសន៍កិច្ចខិតខំប្រឹងប្រែងនេះគួរតែបន្តធានាការលើកកម្ពស់ និងការការពារគ្រប់ផ្នែកទាំងអស់នៃប្រជាជនឥណ្ឌូនេស៊ី″។

ពីការបញ្ជាក់ដោយសង្ខេបនៃដំណើរការនេះ យើងអាចសង្កេតឃើញថា UPR ពិតជាអនុញ្ញាតឲ្យធ្វើការកំណត់អត្តសញ្ញាណ និងការពិភាក្សាលើបញ្ហាសិទ្ធិមនុស្ស ហើយវាផ្តល់ការជម្រុញទឹកចិត្តដល់រដ្ឋាភិបាលក្នុងការដោះស្រាយកង្វល់ទាំងនេះ។ ប៉ុន្តែការឆ្លើយតបអាចទន់ខ្សោយ និងមិនតម្រូវសកម្មភាពដោយផ្ទាល់នោះទេ ដោយសារដំណើរការនេះមិនចងកាតព្វកិច្ច។ យ៉ាងណាមិញ ក្នុងអំឡុងពេលការត្រួតពិនិត្យលើកទីពីររបស់ប្រទេស (២០១២) ឥណ្ឌូនេស៊ីបានត្រលប់ទៅកាន់ចំនុចនេះវិញ ហើយបានបង្ហាញពីវឌ្ឍនភាពឆ្ពោះទៅកាន់សេរីភាពសាសនា។

ប្រសិទ្ធភាពនៃដំណើរការ UPR ត្រូវបានជជែកវែកញែកជាច្រើន។ មានចំនុចខ្លាំងដែលស្តែងចេញច្បាស់មួយចំនួនៈ (១) គ្រប់រដ្ឋទាំងអស់ត្រូវបានត្រួតពិនិត្យ ហើយពួកគេមិនអាចលាក់បាំងពីកំណត់ត្រាសិទ្ធិមនុស្សរបស់ខ្លួនបាននោះទេ (២) នីតិវិធីរួមបញ្ចូលទស្សនៈពីអង្គការសង្គមស៊ីវិល ដោយធ្វើការធានាបញ្ហាមិនអាចត្រូវបានកប់បាត់នោះទេ (៣) នីតិវិធីគ្រប់ដណ្តប់វិស័យទូលំទូលាយមួយនៃសិទ្ធិមនុស្ស ហើយក៏មានការពាក់ព័ន្ធផងដែរក្នុងការក្រលេកមើលលើសិទ្ធិមួយចំនួនតូច។ យ៉ាងណាមិញមានចំនុចខ្សោយចំនួនពីរៈ (១) នីតិវិធីជាការត្រួតពិនិត្យលើរដ្ឋដោយរដ្ឋ ដែលមានន័យថាកម្រិតនៃការរិះគន់ជារឿយៗមានលក្ខណៈទន់ភ្លន់ គួរសម និងមិនមានការតទល់ជាពិសេស និង(២) នីតិវិធីនេះមិនចងកាតព្វកិច្ចតាមវិធីសាស្ត្រណាមួយនោះទេ ដូចនេះទោះបីជាការត្រួតពិនិត្យមានភាពស៊ីជម្រៅខ្ពស់ ក៏រដ្ឋអាចមិនអើពើ ឬបដិសេធការឆ្លើយតបបានដែរ។ ជាឧទាហរណ៍ មីយ៉ាន់ម៉ាបានទទួលអនុសាសន៍ចំនួន១៩០ នៅពេលត្រូវបានពិនិត្យក្នុងឆ្នាំ ២០១១ ហើយបានបដិសេធចំនួន ៤៦ ក្នុងចំណោមនេះដោយអះអាងថាអនុសាសន៍ទាំងនេះ រំលោភលើសិទ្ធិអធិបតេយ្យរបស់ខ្លួន។ ឧទាហរណ៍នៃអនុសាសន៍ដែលបានបដិសេធទាំងនេះ រួមមានការអនុញ្ញាតឲ្យមានអ្នករាយការណ៍ពិសេសដើម្បីធ្វើទស្សនៈកិច្ច (ដូចដែលបានស្នើដោយប្រទេសអាហ្សង់ទីន) ការដោះលែងអ្នកទោសនយោបាយ (ដូចដែលបានស្នើឡើងដោយប្រទេសបែលហ្សិក) និងស្វែងរកដំណោះស្រាយលើចំនួនជនភៀសខ្លួនមីយ៉ាន់ម៉ាក្នុងតំបន់ (ដូចដែលបានស្នើឡើងដោយប្រទេសម៉ាឡេស៊ី)។

មានសារៈប្រយោជន៍ និងការអភិវឌ្ឍខាងក្រៅដំណើរការនេះ។ UPR ផ្តល់នូវឧបករណ៍យ៉ាងវិសេសមួយដើម្បីជួយដល់អង្គការសង្គមស៊ីវិលឆ្លើយតប និងសម្របសម្រួលការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស។ វាជាវេទិកាមួយដែលអាចអភិវឌ្ឍយុទ្ធសាស្ត្រលើអាទិភាព និងការសម្រួលដល់ការតស៊ូមតិ។ បន្ថែមពីលើនេះទៀត អង្គការសង្គមស៊ីវិលជាច្រើនប្រើប្រាស់ UPR ជាវេទិកាមួយក្នុងការរៀបចំទស្សនៈរបស់ពួកគេពីសិទ្ធិមនុស្ស ដូចនេះផ្តល់និត្យានុកូលដល់ពួកគេនៅ UN។ ទោះបីជាមិនត្រូវបានអនុញ្ញាតឲ្យនិយាយ យ៉ាងហោចណាស់ពួកគេអាចនិយាយទៅកាន់រដ្ឋដែលអាណិត ឬប្រព័ន្ធផ្សព្វផ្សាយពីបញ្ហានេះ។

## នីតិវិធីពិសេស

នីតិវិធីពិសេសជាឈ្មោះមួយ ដែលបានដាក់ជូនដល់ចង្កោមនៃយន្តការការពារដែលបានប្រើប្រាស់ស្រាប់ការតាមដាន និងរាយការណ៍សិទ្ធិមនុស្ស។ នីតិវិធីពិសេសអាចមានទម្រង់មួយចំនួន ប៉ុន្តែទម្រង់ទាំងអស់រួមមានការតែងតាំងបុគ្គល ឬក្រុមប្រជាជនដើម្បីស៊ើបអង្កេតកង្វល់សិទ្ធិមនុស្សជាក់លាក់។ នេះអាចជាការស៊ើបអង្កេតលើប្រទេសមួយជាក់លាក់ ឬជាការស៊ើបអង្កេតលើប្រភេទជាក់លាក់នៃការរំលោភសិទ្ធិមនុស្ស។

ការស៊ើបអង្កេតអាចត្រូវបានធ្វើឡើងដោយបុគ្គលមួយរូប (អ្នកជំនាញការជាបុគ្គល ឬអ្នករាយការណ៍ពិសេស) ឬអាចបញ្ចូលមនុស្សមួយក្រុម (ក្រុមការងារ)។

# ផ្តោតសំខាន់លើនីតិវិធីពិសេស

## អ្នករាយការណ៍ពិសេស

អ្នករាយការណ៍ពិសេសជាបុគ្គលដែលមានអាណត្តិ ក្នុងការស៊ើបអង្កេតកង្វល់សិទ្ធិមនុស្សជាក់លាក់ តាមប្រធានបទ ឬតាមប្រទេស។ មានអ្នករាយការណ៍ប្រហែលជា ៤០ រូប រួមមាន៖

អ្នករាយការណ៍តាមប្រធានបទ៖ លំនៅដ្ឋានគ្រប់គ្រាន់ សិទ្ធិក្នុងការទទួលបានការអប់រំ ការកាត់ទោសក្រៅប្រព័ន្ធតុលាការ ដោយសង្ខេប និងតាមទំនើងចិត្ត សិទ្ធិចំណីអាហារ សេរីភាពក្នុងការបញ្ចេញមតិ ឬជំនឿ សុខភាព សិទ្ធិរបស់ជនជាតិដើមភាគតិច។
ប្រទេសដែលមានអ្នករាយការណ៍ ឬអ្នកជំនាញការផ្ទាល់ខ្លួន៖ បេឡារុស កម្ពុជា អេរីទ្រា អ៊ីរ៉ង់ មីយ៉ាន់ម៉ា កូរ៉េខាងជើង ទឹកដីប៉ាឡេស្ទីន សូម៉ាលី ស៊ូដង់ និងស៊ីរី។

## អ្នកជំនាញការឯករាជ្យ

អ្នកជំនាញការឯករាជ្យគឺស្រដៀងគ្នានឹងអ្នករាយការណ៍ពិសេស ប៉ុន្តែពួកគេផ្តោតលើការស្រាវជ្រាវជាជាងការតាមដាន និងចុះទស្សនៈកិច្ច។ ទាំងនេះរួមបញ្ចូលអ្នកជំនាញការលើ៖ សំណួរពីសិទ្ធិមនុស្ស និងភាពក្រីក្រខ្លាំង បញ្ហាជនជាតិភាគតិច សិទ្ធិមនុស្ស និងសាមគ្គីភាពជាអន្តរជាតិ ផលប៉ះពាល់នៃគោលនយោបាយកំណែទម្រង់សេដ្ឋកិច្ច និង បំណុលបរទេសលើការទទួលបានសិទ្ធិមនុស្សពេញលេញ ការលើកកម្ពស់សណ្តាប់ធ្នាប់អន្តរជាតិប្រកបដោយប្រជាធិបតេយ្យ និងសមភាព។

## ក្រុមការងារ

ក្រុមការងារមានសមាជិកប្រាំរូប មួយរូបសម្រាប់តំបន់នីមួយៗ ហើយពួកគេរាយការណ៍ពីកង្វល់សិទ្ធិមនុស្សជាសកល ដូចជា៖ ការបាត់ខ្លួនដោយបង្ខំ ឬមិនស្ម័គ្រចិត្ត ការឃុំខ្លួនតាមទំនើងចិត្ត ការប្រើប្រាស់ភតិការី ការរើសអើងលើស្ត្រីក្នុងច្បាប់ និងការអនុវត្ត សាជីវកម្មពហុជាតិ។ ត្រូវចងចាំ៖អ្នកតំណាងពិសេសតំណាងឲ្យ UNSG។ ពួកគេអាចជាអ្នកជំនាញការពិសេស ឬអ្នកតំណាងជាន់ខ្ពស់។ អាណត្តិរបស់ពួកគេជាច្រើនស្រដៀងគ្នានឹងអ្នករាយការណ៍ពិសេស ប៉ុន្តែមិនមែនរាល់ការងារទាំងអស់ក្នុងវិស័យសិទ្ធិមនុស្សទេ ហើយក៏មិនរាយការណ៍ដល់ស្ថាប័នសិទ្ធិមនុស្សដែរ។

អ្នករាយការណ៍ពិសេស អ្នកជំនាញការ និងក្រុមការងាររបស់ HRC មានឯករាជ្យភាព ហើយមិនតំណាងប្រទេសណាមួយនោះទេ ជាស្វ័យភាពនឹងធ្វើឲ្យមានទាំងក្រេឌីដ និងការប្រឈម។ របាយការណ៍របស់ពួកគេត្រូវបានយកចិត្តទុកដាក់ខ្ពស់ ដោយសារអ្នកជំនាញការត្រូវបានដឹងថាមានឯករាជ្យភាព និងមិនពាក់ព័ន្ធនឹងបញ្ហានយោបាយ។ យ៉ាងណាមិញ ឯករាជ្យភាពទាំងនេះរបស់អ្នកកាន់កាប់នីតិវិធីធ្វើឲ្យមានការពិបាកដល់ពួកគេក្នុងការទទួលបានការអញ្ជើញដើម្បីទស្សនៈកិច្ច ក្នុងប្រទេសដែលខ្លួនចង់ស៊ើបអង្កេត។ ជាការអនុវត្ត ត្រូវមានការស្នើជាលាយលក្ខអក្សរដល់រដ្ឋ ហើយប្រសិនជារដ្ឋព្រមព្រៀង រដ្ឋនឹងចេញលិខិតអញ្ជើញ។ បញ្ហាចំពោះនីតិវិធីនេះអាចត្រូវបានបញ្ជាក់ដោយករណីប្រទេសកូរ៉េខាងជើង និងមីយ៉ាន់ម៉ាដែលអ្នករាយការណ៍ របស់ប្រទេសទាំងនេះត្រូវបានអនុញ្ញាតប៉ុន្មាន (ឬគ្មានតែម្តង) ដងប៉ុណ្ណោះដើម្បីធ្វើទស្សនៈកិច្ច ក្នុងប្រទេសនេះក្នុងអំឡុងពេលមួយទសវត្សមុន។ ម្យ៉ាងវិញទៀត ប្រទេសជិត១០០ បានចេញ ′លិខិតអញ្ជើញបើកចំហ′ បង្ហាញពីការបើកចំហររបស់ខ្លួន ក្នុងការទទួលការទស្សនៈកិច្ចពីអ្នកកាន់កាប់អាណត្តិនីតិវិធីពិសេសតាមប្រធានបទណាមួយ។

ដូចគ្នានឹងអ្នករាយការណ៍ ឬអ្នកស្រាវជ្រាវដែរ អ្នករាយការណ៍ពិសេសប្រមូលព័ត៌មាន និងសរសេររបាយការណ៍ដោយធ្វើទស្សនៈកិច្ចក្នុងប្រទេស ដើម្បីការស៊ើបអង្កេតបន្ថែម។ លើសពីនេះទៀត ពួកគេអាចវាយតម្លៃ និងផ្តល់ដំបូន្មានស្តីពីស្ថានភាពសិទ្ធិមនុស្ស។ អាណត្តិរបស់ពួកគេអនុញ្ញាតឲ្យមានការត្រួតពិនិត្យ ការតាមដាន ផ្តល់ដំបូន្មាន និង ធ្វើរបាយការណ៍សាធារណៈលើស្ថានភាពស្ថិតក្រោមនីតិវិធី។ ពួកគេអាចឆ្លើយតបនឹងបណ្តឹងបុគ្គល ធ្វើការសិក្សាស្រាវជ្រាវ ចាប់ផ្តើមសកម្មភាពលើកកម្ពស់ និង ការយល់ដឹង និងផ្តល់ជំនួយបច្ចេកទេសនៅពេលដែលត្រូវការ។

ជាការអនុវត្ត នីតិវិធីពិសេសជាទូទៅត្រូវបានប្រើប្រាស់ដើម្បីឆ្លើយតបនឹងការតវ៉ាបន្ទាន់ ដោយសារថានីតិវិធីទាំងនេះ ជាមធ្យោបាយដ៏ឆាប់រហ័សបំផុតក្នុងការឆ្លើយតបនឹងបញ្ហាសិទ្ធិជាបន្ទាន់ដូចជាបុគ្គលមួយរូបបាត់ខ្លួន ឬការគម្រាមកំហែងដល់ជីវិតអ្នកណាម្នាក់។ នីតិវិធីពិសេសជារឿយៗត្រូវបានចាត់ទុកថាជាអំណាចជាសកលស្តីពីស្ថានភាព ឬប្រធានបទសិទ្ធិមនុស្ស ហើយដូចនេះ របាយការណ៍របស់នីតិវិធីនេះទទួលបានការចាប់អារម្មណ៍។ នីតិវិធីពិសេសទាំងនេះមានភាពថ្មីថ្មោង ដែលនីតិវិធីទីមួយ គឺជាក្រុមការងារស្តីពីការបាត់ខ្លួនដែលបានចាប់ផ្តើមក្នុងឆ្នាំ១៩៨០ ហើយមានការកើនឡើងពីចំនួនតិចជាងដប់ក្នុងដើមទសវត្សឆ្នាំ១៩៩០ ដល់ប្រហែលជាសែសិបពេលបច្ចុប្បន្ន។

នៅអាស៊ីអាគ្នេយ៍ មានអ្នកតំណាងពិសេសនៅក្នុងប្រទេសកម្ពុជា ទោះបីជានេះមិនមែនដាច់ណាត់ថាជានីតិវិធីពិសេស ប៉ុន្តែអ្នកតំណាង UNSG តាមការពិតជាក់ស្តែង

អ្នកតំណាងពិសេស និងនីតិវិធីពិសេស មានលក្ខណៈស្រដៀងគ្នា។ មីយ៉ាន់ម៉ាមានទាំងអ្នករាយការណ៍ពិសេស (ចាប់តាំងពីឆ្នាំ១៩៩៣)និងទីប្រឹក្សាពិសេសនៃអគ្គលេខាធិការ (ចាប់តាំងពីឆ្នាំ២០០០)។ ការជ្រើសរើសអ្នករាយការណ៍ពិសេស គឺផ្អែកលើតុល្យភាពតំបន់ ដូចនេះមានចំនួនជាក់លាក់មកពីអាស៊ី។ អ្នកជំនាញការពីប្រទេសថៃ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី និងហ្វីលីពីនធ្លាប់ធ្វើជាអ្នករាយការណ៍ពិសេស។

អ្នករាយការណ៍ពិសេសតាមប្រធានបទមួយចំនួន បានធ្វើការវាយតម្លៃលើប្រទេសនៅអាស៊ីអាគ្នេយ៍ដែលបានទទួលចំណាប់អារម្មណ៍លើប្រព័ន្ធផ្សព្វផ្សាយ។ នៅពេលដែលអ្នករាយការណ៍ពិសេសសម្រាប់កិច្ចការកាត់ទោសក្រៅប្រព័ន្ធតុលាការ ដោយសង្ខេប ឬតាមទំនើងចិត្ត Philip Alston បានទស្សនៈប្រទេសហ្វីលីពីនក្នុងឆ្នាំ ២០០៧ របាយការណ៍របស់គាត់បានទទួលបានចំណាប់អារម្មណ៍យ៉ាងច្រើនក្នុងតំបន់។ នៅក្នុងរបាយការណ៍នេះ គាត់បានបញ្ជាក់ថា ″កម្លាំងយោធាមានគោលជំហរបដិសេធលើការកាត់ក្តីក្រៅប្រព័ន្ធតុលាការដែលមានការចូលដៃជើងពីទាហានរបស់ខ្លួន″ ជាមតិយោបល់មួយដែលមានលក្ខណៈស៊ីជម្រៅលើកងកម្លាំងយោធាហ្វីលីពីន ហើយធ្វើឲ្យមានការជជែកវែកញែកច្រើនពីបញ្ហានេះ។

## ផ្តោតសំខាន់លើ

### ទស្សនៈកិច្ចរបស់ Alston ទៅកាន់ប្រទេសហ្វីលីពីនក្នុងនាមជាអ្នករាយការណ៍ពិសេសលើការសម្លាប់រង្គាលក្រៅប្រព័ន្ធតុលាការ

ហ្វីលីព អាល់ស្តុន (Philip Alston) គឺជាអ្នករាយការណ៍ពិសេសលើការកាត់ទោសក្រៅប្រព័ន្ធតុលាការ ដោយសង្ខេប ឬតាមទំនើងចិត្ត ចាប់តាំងពីឆ្នាំ២០០៤។ ក្នុងឆ្នាំ ២០០៧ គាត់មានបេសកកម្មទៅកាន់ប្រទេសហ្វីលីពីន។ នៅក្នុងរបាយការណ៍របស់គាត់មួយឆ្នាំក្រោយមក គាត់បានបង្ហាញថាចាប់តាំងពីឆ្នាំ ២០០១ មកប្រជាជនប្រហែលជា ៨០០ នាក់ ជាពិសេសសកម្មជនឆ្វេងនិយមត្រូវបានសម្លាប់ ដោយរួមមានទាំងអ្នកតស៊ូមតិកំណែទម្រង់ដីធ្លី និងអ្នកការពារសិទ្ធិមនុស្ស។ ការស្លាប់ទាំងនេះភាគច្រើនដោយសារបុគ្គលយោធា។

រដ្ឋាភិបាលបានឆ្លើយតបថាការស្លាប់ទាំងនេះ ភាគច្រើនត្រូវបានប្រព្រឹត្តដោយជនកុំម្មុយនិសដែលជាផ្នែកមួយនៃ ′ការជម្រះចោល′ ឬការលុបបំបាត់គិញសម្ងាត់ ដែលនេះ Alston ហៅថាជា″ ការព្យាយាមដោយអត់មានការអៀនខ្មាស (ដោយរដ្ឋាភិបាល)

ក្នុងការបង្វែរការទទួលខុសត្រូវ"។ Alston ក៏បានបញ្ជាក់ដែរថាតុលាការ "ផ្តោតសំខាន់លើការកាត់ទោសមេដឹកនាំសង្គមស៊ីវិល ជាជាងអ្នកសម្លាប់មេដឹកនាំទាំងនោះ" ។ ជាលទ្ធផលនាំឲ្យមាននិទណ្ឌភាពកម្រិតខ្ពស់។ បន្ទាប់ពីរបាយការណ៍បានចេញក្នុងឆ្នាំ ២០០៨ចំនួននៃការសម្លាប់រង្គាលក្រៅប្រព័ន្ធតុលាការបានធ្លាក់ចុះពីជាង២០០ មកត្រឹម ៦៨។ ទោះបីជាការសម្លាប់ចំនួន ៦៨ នៅតែខ្ពស់ក៏ដោយ ការធ្លាក់ចុះគួរឲ្យកត់សម្គាល់នេះបង្ហាញពីលទ្ធភាពនីតិវិធីពិសេស ក្នុងការផ្លាស់ប្តូរស្ថានការសិទ្ធិមនុស្សក្នុងស្ថានភាពមួយចំនួន។

## នីតិវិធីបណ្តឹង

HRC អាចប្រើប្រាស់នីតិវិធីដទៃក្នុងការស៊ើបអង្កេតប្រទេសដែលមានកំណត់ត្រាសិទ្ធិមនុស្សមិនល្អផងដែរ។ ចាប់តាំងពីឆ្នាំ ២០០៧ មក ក្នុងករណីដែលខ្លួនយល់ឃើញថាមាន "ការរំលោភបំពានធ្ងន់ធ្ងរ និងអាចធ្វើការបញ្ជាក់ភស្តុតាងបានលើសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន" HRC នឹងទទួលយកបណ្តឹងបុគ្គល ហើយបន្ទាប់មកនឹងធ្វើការស៊ើបអង្កេតសម្ងាត់មួយ។ នីតិវិធីនេះមានវត្តមានច្រើនទសវត្សមកហើយ ហើយពីមុនត្រូវបានស្គាល់ថាជានីតិវិធី ១៥០៣។ នៅក្នុងអន្តរកាលពីគណៈកម្មាការទៅជាក្រុមប្រឹក្សា នីតិវិធីនេះត្រូវបានពិនិត្យឡើងវិញ ហើយមានការផ្លាស់ប្តូររចនាសម្ព័ន្ធបន្តិចបន្តួច និងត្រូវបានផ្លាស់ឈ្មោះទៅជានីតិវិធីបណ្តឹង។ ការស៊ើបអង្កេតនេះក៏អនុវត្តចំពោះការរំលោភបំពានដែល 'ធ្ងន់ធ្ងរ' ដែលមានន័យថាការរំលោភបំពានត្រូវតែមានសភាពធ្ងន់ធ្ងរ។ HRC នឹងមិនស៊ើបអង្កេតលើការរំលោភបំពានលើបុគ្គល ឬស្ថានភាពដែលមិនច្បាស់ថារដ្ឋបានដើរតួនាទីក្នុងនោះទេ។ បន្ថែមពីលើនេះទៀត ដំណើរការនេះជាការសម្ងាត់ មានន័យថា HRC ត្រូវបានតម្រូវឲ្យធ្វើការស៊ើបអង្កេតនៅក្នុងបន្ទប់បិទជិត ហើយការពិភាក្សាមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈនោះទេ។ មិនធ្លាប់មានការស៊ើបអង្កេតលើប្រទេសអាស៊ីអាគ្នេយ៍ណាមួយនោះទេ ដោយយន្តការនេះ ទោះបីជាប្រទេសម៉ាល់ឌីវ ដែលជាប្រទេសជិតខាងនៅអាស៊ីខាងត្បូង ត្រូវបានស៊ើបអង្កេតនៅក្នុងឆ្នាំ ២០០៨ ក៏ដោយ។ នៅក្នុងយន្តការពីមុន ដែលត្រូវបានស្គាល់ថាជានីតិវិធី ១៥០៣ (ដោយសារនីតិវិធីនេះត្រូវបានបង្កើតដោយសេចក្តីសម្រេច ECOSOC លេខ ១៥០៣) ប្រទេសអាស៊ីអាគ្នេយ៍ជាច្រើនត្រូវបានស៊ើបអង្កេតដូចមានបង្ហាញក្នុងតារាងខាងក្រោម៖

តារាង ៥-៣: ការស៊ើបអង្កេតរបស់រដ្ឋដោយគណៈកម្មការសិទ្ធិមនុស្សនីតិវិធីបណ្ដឹង

| ប្រទេស | ពេលពិនិត្យក្រោមការដោះស្រាយឆ្នាំ ១៥០៣ |
|---|---|
| ប្រ៊ុយណេ | មិនធ្លាប់ |
| កម្ពុជា | ១៩៧៩ (ដូចកម្ពុជា) |
| ឡាវ | ១៩៩៥ |
| ឥណ្ឌូនេស៊ី | ១៩៧៨-១៩៨១<br>១៩៨៣-១៩៨៥ |
| ម៉ាឡេស៊ី | ១៩៨៤ |
| មីយ៉ាន់ម៉ា | ១៩៧៩-១៩៨០<br>១៩៩០-១៩៩២ |
| ហ្វីលីពីន | ១៩៨៤-១៩៨៦ |
| សិង្ហបុរី | មិនធ្លាប់ |
| ថៃ | ១៩៩៥, ១៩៩៦ |
| វៀតណាម | ១៩៩៩ |
| ទីម័រខាងកើត | មិនដូចប្រទេសឯករាជ្យប៉ុន្តែជាផ្នែកមួយរបស់ឥណ្ឌូនេស៊ី |

HRC ដើរតួនាទីសំខាន់មួយក្នុងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សនៅក្នុងប្រព័ន្ធ UN។ ខណៈពេលដែលស្ថាប័នមួយដែលមានតែសមាសភាពរដ្ឋធ្វើការតាមដានស្តង់ដារសិទ្ធិមនុស្សរបស់រដ្ឋដទៃនឹងមានការប្រុងប្រយ័ត្ន និងមានដែនកម្រិតដោយសារហេតុផលនយោបាយ សកម្មភាពរបស់ HRC ដែលអាចអនុវត្តនីតិវិធីដូចជានីតិវិធីពិសេស UPR និងនីតិវិធីបណ្ដឹងបានចាប់ផ្ដើមក្នុងការបង្ហាញពីភាពខុសគ្នាលើស្តង់ដារសិទ្ធិមនុស្ស។ អ្នករាយការណ៍ពិសេសនៅតែបន្តក្នុងការធ្វើការងារសំខាន់របស់ខ្លួនក្នុងការឆ្លើយតបនឹងការរំលោភបំពានជុំវិញពិភពលោក ហើយចាត់វិធានការភ្លាមៗលើបណ្ដឹងនៃការរំលោភបំពានធ្ងន់ធ្ងរលើសិទ្ធិមនុស្ស។

# ៥.៣ ការិយាល័យឧត្ដមស្នងការទទួលបន្ទុកកិច្ចការសិទ្ធិមនុស្ស

កិច្ចការគ្រប់គ្រងសកម្មភាពសិទ្ធិមនុស្សនៅ UN និងការវាយតម្លៃរដ្ឋដើម្បីអនុលោមតាមកាតព្វកិច្ចរបស់ខ្លួននៅ UN ត្រូវបានបំពេញដោយ OHCHR។ ដំបូងឡើយត្រូវបានហៅថាជាមជ្ឈមណ្ឌលសិទ្ធិមនុស្ស OHCHR ត្រូវបានបង្កើតឡើងបន្ទាប់ពីក្រុមផ្សេងៗនៅដើមទសវត្សឆ្នាំ១៩៩០ បញ្ចុះបញ្ចូលឲ្យមានស្ថាប័នជាន់ខ្ពស់ជាងមុន ក្នុងការគ្រប់គ្រងបញ្ហាសិទ្ធិមនុស្សនៅ UN។ ទស្សនៈនេះត្រូវបានទទួលយកនៅក្នុងសន្និសិទពិភព

លោកស្តីពីសិទ្ធិមនុស្សក្នុងឆ្នាំ១៩៩៣ និងសេចក្តីសម្រេចដែលបានចេញក្នុងការបង្កើត OHCHR។

សកម្មភាពដែលមាននៅក្នុង OHCHR រួមមានចលនាក្នុងការបញ្ជ្រៀបសិទ្ធិមនុស្សក្នុងប្រព័ន្ធ UN និងដើម្បីផ្តល់នូវសម្លេងដ៏ខ្លាំងមួយក្នុងការការពារសិទ្ធិមនុស្ស។ លើសពីនេះទៀត ស្ថាប័ននេះផ្តល់ជំនួយដល់រដ្ឋាភិបាល ដូចជាជំនាញការ និងការបណ្តុះបណ្តាលបច្ចេកទេស ដើម្បីជម្រុញឲ្យពួកគេឆ្លើយតបនឹងកាតព្វកិច្ចសិទ្ធិមនុស្សរបស់ពួកគេ។ ស្ថាប័ននេះក៏សម្របសម្រួលសកម្មភាពសិទ្ធិមនុស្សនៅក្នុង UN និងគាំទ្រដល់ស្ថាប័នសន្ធិសញ្ញាផងដែរ ជាឧទាហរណ៍តាមរយៈការសម្របសម្រួល UPR។ OHCHR ក៏អនុវត្តសកម្មភាពអប់រំ ព័ត៌មានសាធារណៈ និងការតស៊ូមតិតំណាងឲ្យ UN ផងដែរ។ មិនដូចគ្នានឹង HRC នោះទេ OHCHR មិនមានសមាសភាពជាតំណាងរដ្ឋនោះទេ ប៉ុន្តែមានសមាសភាពជាបុគ្គលដែលមានជំនាញការក្នុងវិស័យសិទ្ធិមនុស្ស។

OHCHR ត្រូវបានស្គាល់ថាមានវត្តមាននៅតាមប្រទេសច្រើន ដោយមានការិយាល័យប្រចាំប្រទេស និងថ្នាក់តំបន់ចំនួន ២៥ ជុំវិញពិភពលោក។ នៅអាស៊ីអាគ្នេយ៍ ការិយាល័យប្រចាំតំបន់មាននៅទីក្រុងបាងកក នៅការិយាល័យកណ្តាល ESCAP។ នៅដើមទសវត្សឆ្នាំ ១៩៩០ OHCHR មានបញ្ហាក្នុងការទទួលបានការទទួលស្គាល់ដោយសារការមិនចុះសម្រុងគ្នា និងការិយាធិបតេយ្យរបស់ UN ធ្វើឲ្យ OHCHR ទន់ខ្សោយ និងមិនមានប្រសិទ្ធិភាព។ យ៉ាងណាមិញ ជាមួយនឹងភាពចម្រុះនៃសមាជិកគណៈកម្មាការដែលខ្លាំងក្លា និងមានការទទួលស្គាល់នូវអាណត្តិទូលំទូលាយលើ សិទ្ធិមនុស្សទូទាំង UN OHCHR បានចាប់ផ្តើមទទួលបានភាពលេចធ្លោក្នុងការងាររបស់ខ្លួន។ OHCHR ត្រូវបានដឹកនាំដោយឧត្តមស្នងការ ដែលត្រូវបានតែងតាំងដោយអគ្គលេខាធិការ។ ចាប់ផ្តើមក្នុងឆ្នាំ ១៩៩៤ តួនាទីនេះតម្រូវឲ្យសមាជិកគណៈកម្មាការបំពេញអាណត្តិរយៈពេលបួនឆ្នាំ។ ត្រឹមឆ្នាំ ២០១៤ មានសមាជិកគណៈកម្មាធិការចំនួនប្រាំពីររូបមកពីអឺរ៉ុប អាមេរិកឡាទីន និងអាហ្វ្រិក ប៉ុន្តែមិនមានមកពីអាស៊ីនោះទេ។

# ៩.៤ ស្ថាប័នសន្ធិសញ្ញា

ដូចដែលបានប្រៀបធៀបនឹងស្ថាប័នធម្មនុញ្ញ ស្ថាប័នសន្ធិសញ្ញាជាប្រភេទដែលត្រូវបានបែងចែកដាច់ដោយឡែកពីស្ថាប័នសិទ្ធិមនុស្ស។ ស្ថាប័នសន្ធិសញ្ញាត្រូវបានបង្កើតឡើងពីសន្ធិសញ្ញាសិទ្ធិមនុស្ស ហើយការបង្កើត អាណត្តិ និងវិធានត្រូវបានបញ្ជាក់លម្អិតក្នុងសន្ធិសញ្ញាផ្ទាល់តែម្តង។ សន្ធិសញ្ញាសិទ្ធិមនុស្សនីមួយៗ (និងពិធីសារបន្ថែមស្តីពីទារុណកម្ម) មានស្ថាប័នសន្ធិសញ្ញារបស់ខ្លួន ដែលមានស្ថាប័នចំនួនដប់ គិតត្រឹមឆ្នាំ ២០១៤។ នៅពេលដែលសន្ធិសញ្ញាចូលជាធរមាន លទ្ធផលសំខាន់បំផុតមួយគឺជា

ការបង្កើតគណៈកម្មាធិការ ដែលមានសមាជិកពី ១០-២៣ រូប (យោងតាមសន្ធិសញ្ញា) ដែលមានការងារក្នុងការត្រួតពិនិត្យការអនុលោមរបស់រដ្ឋភាគី។ ខណៈពេលដែលស្ថាប័នធម្មនុញ្ញជារឿយៗមានសមាសភាពជាតំណាងរដ្ឋ ស្ថាប័នសន្ធិសញ្ញាមានសមាសភាពជាអ្នកជំនាញការឯករាជ្យ។ ជាធម្មតា សមាជិកស្ថាប័នសន្ធិសញ្ញា ជាអ្នកជំនាញការសិទ្ធិមនុស្ស អាចជាអ្នកច្បាប់ អ្នកការទូត ឬបុគ្គលិក NGOs។ ពួកគេត្រូវបានតែងតាំងដោយរដ្ឋភាគីនៃសន្ធិសញ្ញា ប៉ុន្តែមុខតំណែងរបស់ពួកគេ ឯករាជ្យពីរដ្ឋ (ដូចនេះធានាថារដ្ឋាភិបាលមិនគ្រប់គ្រងពួកគេ)។ ស្ថាប័នទាំងនេះអនុវត្តនូវសកម្មភាពមួយចំនួន ដែលមានភាពខុសគ្នាពីសន្ធិសញ្ញាមួយទៅសន្ធិសញ្ញាមួយ ហើយត្រូវបានសង្ខេបក្នុងតារាងខាងក្រោម៖

## តារាង ៥-៤: សង្ខេបស្ថាប័នសន្ធិសញ្ញា

| ស្ថាប័នសន្ធិសញ្ញា | ចំនួនគណៈកម្មការ | របាយការណ៍រដ្ឋ | បណ្ដឹងបុគ្គល | របាយការណ៍រយៈពេល* | សំណួរ និង/ឬ បេសកកម្ម |
|---|---|---|---|---|---|
| CCPR | ១៨ | មាន | មានពិធីសារបន្ថែម | ២ និងសំណើ | អត់ |
| CESCR | ១៨ | មាន | មានពិធីសារបន្ថែម | ២ និង ៥ | មាន ពិធិសារបន្ថែម** |
| CEDAW | ២៣ | មាន | មានពិធីសារបន្ថែម | ១ និង ៤ | មាន ពិធីសារបន្ថែម |
| CRC*** | ១៨ | មាន | មានពិធីសារបន្ថែម | ២ និង ៥ | មាន ពីធីសារបន្ថែម** |
| ICERD | ១៨ | មាន | មាន មាត្រា១៤ | ១ និង ២ | អត់ |
| CAT+ | ១០ | មាន | មាន មាត្រា២២ | ១ និង ៤ | មាន មាត្រា២០ |
| CMW | ១៤ | មាន | មាន មាត្រា៧៧ | ១ និងសំណើ៥ | អត់ |
| CRPD | ១៨ | មាន | មាន ពិធីសារបន្ថែម | ២ និង ៤ | មាន ពិធីសារបន្ថែម |
| ICED | ១០ | មាន | មាន មាត្រា៣១ | ២ ++ | មាន មាត្រា៣៣ |

OP = ពិធីសារបន្ថែម

* ចំនួនឆ្នាំរហូតដល់របាយការណ៍បឋម/ ចំនួនឆ្នាំរវាងរបាយការណ៍បន្ទាប់

** នៅពេលដែល OP ចូលជាធរមាន

***ពិធីបន្ថែមទាំងពីរនៃ CRC ទាមទាររបាយការណ៍រដ្ឋភាគីផងដែរ ជាបឋមក្នុងរយៈពេល ២ឆ្នាំ បន្ទាប់មករៀងរាល់ប្រាំឆ្នាំ

\+ តាម CAT មាន ***អនុគណៈកម្មាការស្តីពីការបង្ការទារុណកម្ម និងការប្រព្រឹត្តមកលើ ឬទណ្ឌកម្មដទៃទៀតដែលសាហាវ អមនុស្សធម៌ និងបន្ទាបបន្ថោកផងដែរ*** ឬ (SPT)
++ មិនទាន់បានសម្រេចនៅឡើយ

ស្ថាប័នសន្ធិសញ្ញានីមួយៗខុសគ្នាបន្តិចបន្តួចដោយសារអាណត្តិ និងអំណាចរបស់ខ្លួន។ ផ្នែកចុងក្រោយនៃផ្នែកនេះនឹងបញ្ជាក់លម្អិតពីសកម្មភាពស្ថាប័នសន្ធិសញ្ញា និងពិភាក្សាពីវិធីដែលពួកគេការពារសិទ្ធិមនុស្ស។

# របាយការណ៍រដ្ឋភាគី

នៅពេលដែលរដ្ឋមួយព្រមព្រៀងលើសន្ធិសញ្ញាមួយ រដ្ឋក៏ប្តេជ្ញាផងដែរក្នុងការសរសេររបាយការណ៍តាមពេលវេលាកំណត់ (ពេលវេលាជាក់លាក់ផ្អែកលើសន្ធិសញ្ញា ប៉ុន្តែប្រហែលជាបួនទៅប្រាំឆ្នាំ ជារយៈពេលទូទៅ) ដែលរដ្ឋបញ្ជាក់លម្អិតពីវិធីដែលខ្លួនឆ្លើយតបនឹងកាតព្វកិច្ចសន្ធិសញ្ញារបស់ខ្លួន។ រដ្ឋត្រូវតែរៀបរាប់ពីជំហាន ដូចជាវិធានការច្បាប់ តុលាការ គោលនយោបាយ និងវិធានការដទៃ ដែលត្រូវអនុវត្តដើម្បីធានាថាសិទ្ធិក្នុងសន្ធិសញ្ញាត្រូវបានការពារ។ របាយការណ៍រដ្ឋភាគី ជាទូទៅជាឯកសារច្រើនទំព័រ ពេលខ្លះជិតពីររយទំព័រ ដែលឆ្លើយតបនឹងសន្ធិសញ្ញា មួយមាត្រាម្តងៗ។ របាយការណ៍គួរតែពន្យល់ពីតើថាសិទ្ធិក្នុងសន្ធិសញ្ញា ត្រូវបានបញ្ចូលក្នុងច្បាប់ជាតិយ៉ាងដូចម្តេច តើប្រជាជនប៉ុន្មាននាក់ដែលបានទទួលសិទ្ធិក្នុងប្រទេសនោះ ហើយសកម្មភាពដទៃទៀតដែលខ្លួនបានធ្វើដើម្បីធានាការការពារសិទ្ធិ។

ជាទូទៅ រដ្ឋត្រូវប្រគល់ជូនរបាយការណ៍បឋម ក្នុងរយៈពេលមួយ ឬពីរឆ្នាំបន្ទាប់ពីការផ្តល់សច្ចាប័ន បន្ទាប់ពីពេលនោះការធ្វើរបាយការណ៍ត្រូវបានកំណត់តាមពេលវេលា (ជាទូទៅបួន ឬប្រាំឆ្នាំ)។ យ៉ាងណាមិញ នេះជាកិច្ចការដែលអត់ធ្មតមួយ និងមិនមែនជាការភ្ញាក់ផ្អើលនោះទេ ដែល រដ្ឋជាច្រើនមានការស្ទាក់ស្ទើរក្នុងការធ្វើការស្រាវជ្រាវ និងសារភាពនូវកង្វះខាតនៃការអនុលោមតាមសន្ធិសញ្ញាដោយរដ្ឋខ្លួន។ លទ្ធផលគឺថារដ្ឋជាច្រើនមានភាពយឺតយ៉ាវ ក្នុងការប្រគល់ជូនរបាយការណ៍របស់ខ្លួន។ រដ្ឋភាគច្រើនយ៉ាងហោចណាស់នៅជំពាក់របាយការណ៍យ៉ាងតិចមួយ ហើយរដ្ឋជាច្រើនទៀតជំពាក់របាយការណ៍ចំនួនពីរ ឬច្រើនជាងនេះ។ ប្រទេសប្រ៊ុយណេមិនដែលបានប្រគល់ជូនរបាយការណ៍ដល់ CEDAW ទាល់តែសោះចាប់តាំងពីការផ្តល់សច្ចាប័នរបស់ខ្លួនក្នុងឆ្នាំ ២០០៧ ឥណ្ឌូនេស៊ីជំពាក់របាយការណ៍ចំនួនបីដល់ CERD ហើយប្រទេសឡាវបានជំពាក់របាយការណ៍ដល់ស្ថាប័នសន្ធិសញ្ញាចំនួនប្រាំ។ នេះមិនមែនមានន័យថាអាស៊ីអាគ្នេយ៍មិនបំពេញកាតព្វកិច្ច ក្នុងការប្រគល់របាយការណ៍នោះទេ ដោយសារមានរដ្ឋជាច្រើនក៏ជំពាក់របាយការណ៍ផងដែរ ហើយតាមការប៉ាន់ប្រមាណ មានការជំពាក់របាយការណ៍ជាង ១០០០ ដល់ស្ថាប័នសន្ធិសញ្ញាទាំងអស់។

## ការពិភាក្សា និងការជជែកវែកញែក

### តើរបាយការណ៍រដ្ឋភាគីជាមធ្យោបាយមានសារៈសំខាន់មួយក្នុងការកំណត់ស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសមួយមែនដែរឬទេ?

មានការរិះគន់ជាច្រើនលើប្រព័ន្ធរបាយការណ៍របស់រដ្ឋ។ ប្រទេសអាស៊ីអាគ្នេយ៍តែមួយគត់ដែលមិនជំពាក់របាយការណ៍គឺប្រទេសសឹង្ហបូរី (ទោះបីជាប្រទេសនេះបានផ្តល់សច្ចាប័នលើសន្ធិសញ្ញាចំនួនតែពីរក៏ដោយ)។ លើសពីនេះទៀត ដំណើរការនេះមិនមានសារៈសំខាន់ចំពោះរដ្ឋ ដែលមិនបានផ្តល់សច្ចាប័នលើសន្ធិសញ្ញានោះទេ។ ចំពោះរដ្ឋដែលបានជំពាក់របាយការណ៍ ស្ថាប័នសន្ធិសញ្ញាអាចត្រឹមតែផ្តល់ការលើកទឹកចិត្តប៉ុន្តែតែទំហំ និងវិសាលភាពនៃរបាយការណ៍ និងការទាមទារឲ្យមានការចំណាយធនធានរបស់រដ្ឋ មិនមានអ្វីច្រើនដែលស្ថាប័នសន្ធិសញ្ញាអាចធ្វើដើម្បីធានានូវការអនុលោមនោះទេ។ ទោះបីជានៅពេលដែលត្រូវបានប្រគល់ជូនក៏ដោយ ក៏របាយការណ៍ជាច្រើនផ្តល់ជូនតែពីទស្សនៈរបស់រដ្ឋ និងលុបចោលនូវបញ្ហាសិទ្ធិមនុស្សសំខាន់ៗ។

ដោយសារតែកង្វល់ទាំងនេះមានការផ្តួចផ្តើមដំណើការពិគ្រោះយោបល់ដោយ OHCHR ដែលត្រូវបានហៅថា ‵ដំណើរការពង្រឹងស្ថាប័នសន្ធិសញ្ញា′។ ដំណើរការនេះបានគូសបញ្ជាក់ពី ″ឧបសគ្គជាចម្បងនៃរបាយការណ៍រដ្ឋ និងការទំនាក់ទំនងជាមួយរដ្ឋ ធនធានមិនគ្រប់គ្រាន់រ៉ាំរ៉ៃនៃស្ថាប័នសន្ធិសញ្ញា និងការអនុលោមតាមមិនមានប្រសិទ្ធិភាពដោយរដ្ឋភាគីលើកាតព្វកិច្ចរបាយការណ៍របស់ពួកគេ″ ។ ការពិគ្រោះយោបល់បានផ្តល់នូវដំណោះស្រាយដែលអាចទៅរួចមួយចំនួន រួមមានរបាយការណ៍ទោលដែលគ្រប់ដណ្តប់លើសន្ធិសញ្ញាទាំងអស់ ឬត្រឹមតែស្នើសុំរបាយការណ៍ពីរដ្ឋដែលមានកំណត់ត្រាមិនល្អប៉ុណ្ណោះ។

*តើអាចធ្វើអ្វីបានដើម្បីដោះស្រាយបញ្ហានេះ? តើអាចទៅរួចដែរឬទេក្នុងការរំពឹងថារដ្ឋនឹងឮរាយការណ៍ដោយសន្ទានុម័តលើស្ថានភាពសិទ្ធិមនុស្សរបស់ពួកគេ ឬនេះជាជម្រើសល្អប្រសើរបំផុតសម្រាប់អង្គការសង្គមស៊ីវិល?*

*តើមានតម្រូវការចាំបាច់ក្នុងការរាយការណ៍រៀងរាល់ ៤-៥ឆ្នាំម្តងសម្រាប់សន្ធិសញ្ញានីមួយៗ ដែលមានន័យថាប្រទេសខ្លះត្រូវធ្វើរបាយការណ៍ស្ទើរតែពីររបាយការណ៍ក្នុងមួយឆ្នាំដែរឬទេ? កាតព្វកិច្ចនេះជាបន្ទុកធ្ងន់ធ្ងរ ដោយសារពួកគេត្រូវស្រាវជ្រាវ និងសរសេររបាយការណ៍ទាំងនេះ បញ្ជូនប្រតិភូទៅទីក្រុងហ្សឺណែវ និងបន្ទាប់មកទៀតតាមដានបន្តពីលទ្ធផល។*

*តើមិនមានជាការល្អនោះទេឬក្នុងការប្រើប្រាស់នីតិវិធី UPR? (ប៉ុន្តែ UPR មិនគ្រប់ដណ្តប់សិទ្ធិច្រើនដូចដែលបានបញ្ជាក់ក្នុងសន្ធិសញ្ញាផ្សេងៗនោះទេ)។*

នៅពេលដែលរបាយការណ៍ត្រូវបានប្រគល់ជូន សមាជិកស្ថាប័នសន្ធិសញ្ញានឹងអាន ហើយជួបប្រជុំជាមួយជាមួយនឹងរដ្ឋ ដើម្បីពិភាក្សាពីដំណើរការនៃរបាយការណ៍នេះ។ ដោយសារតែរបាយការណ៍ជាទម្រង់មួយនៃការវាយតម្លៃខ្លួនឯង រដ្ឋជារឿយៗលុបចោលនូវព័ត៌មាននៃការរំលោភបំពានសិទ្ធិមនុស្ស ឬធ្វើការអះអាងពីស្តង់ដារខ្ពស់ដែលមិនឆ្លុះបញ្ចាំងពីស្ថានភាពនៅមូលដ្ឋានោះទេ។ ដោយសារតែហេតុផលនេះ ស្ថាប័នសន្ធិសញ្ញាអនុញ្ញាតឲ្យមានស្ថាប័នឯករាជ្យមួយ ដូចជា NGOs ដើម្បីប្រគល់របាយការណ៍ផ្ទាល់របស់ពួកគេ (ហៅថា 'របាយការណ៍ស្រមោល' ) ដើម្បីផ្តល់នូវទស្សនៈឯករាជ្យមួយ។ ការត្រួតពិនិត្យជាក់ស្តែងនឹងកើតមានឡើងនៅក្នុងកិច្ចប្រជុំមួយដែលក្នុងនោះស្ថាប័នសន្ធិសញ្ញានឹងជួបអ្នកតំណាងពីរដ្ឋភាគី នៅការិយាល័យ OHCHR ក្នុងទីក្រុងហ្សឺណែវ ហើយប្រតិភូរដ្ឋនឹងឆ្លើយសំណួរពីស្ថាប័នសន្ធិសញ្ញាក្នុង 'កិច្ចសន្ទនាក្នុងន័យស្ថាបនា'។ ជារឿយៗស្ថាប័នសន្ធិសញ្ញាលើកបញ្ហាដែលកើតមានក្នុងរបាយការណ៍ស្រមោល ហើយរដ្ឋអាចត្រូវបានស្នើដើម្បីផ្តល់ព័ត៌មានបន្ថែមពីការរំលោភបំពានដែលកើតមានឡើងនៅក្នុងប្រទេស។ នីតិវិធីទូទៅមួយគឺ (ជាសំខាន់ ជំហានទីមួយៗនៃនីតិវិធីនេះត្រូវបានចងក្រងជាឯកសារ និងមានជាសាធារណៈ)៖

១. ការប្រគល់ 'របាយការណ៍រដ្ឋ' (ឯកសារក្រាស់ដែលមានជាង ១០០ ទំព័រ)
២. ស្ថាប័នសន្ធិសញ្ញាដាក់បញ្ចូលគ្នានូវ 'តារាងបញ្ហា' ដែលខ្លួនចង់ឲ្យរដ្ឋធ្វើការពិភាក្សា ដែលមួយចំនួននៃបញ្ហាទាំងនេះ អាចត្រូវបានលើកឡើងដោយរបាយការណ៍ស្រមោល (ជាធម្មតាប្រហែលជាពី១០-២០ បញ្ហា)
៣. រដ្ឋភាគីឆ្លើយតបលើតារាងនៃបញ្ហា
៤. ស្ថាប័នសន្ធិសញ្ញាចេញ 'របាយការណ៍សង្ខេប' ដែលបញ្ជាក់លម្អិតពីកិច្ចប្រជុំ
៥. ស្ថាប័នសន្ធិសញ្ញាចេញ'សេចក្តីសន្និដ្ឋានអង្កេត' ដែលអាចបញ្ចូលនូវអនុសាសន៍ដល់រដ្ឋផងដែរ។

## ការពិភាក្សា និងការជជែកវែកញែក

### តើប្រទេសនឹងធ្វើការផ្លាស់ប្តូរដោយសារតែនីតិវិធីរបាយការណ៍របស់រដ្ឋដែរឬទេ?

របាយការណ៍រដ្ឋមានឥទ្ធិពលតិចតួចលើការអនុលោមតាមសិទ្ធិមនុស្ស។ យ៉ាងណាមិញ របាយការណ៍ទាំងនេះអាចត្រូវបានប្រើប្រាស់តាមមធ្យោបាយជាច្រើនដើម្បីធ្វើឲ្យប្រសើរឡើងនូវបញ្ហាសិទ្ធិមនុស្ស ហើយមាននូវឧទាហរណ៍ជាច្រើនក្នុងតំបន់។ ជាឧទាហរណ៍ ប្រទេសថៃបានផ្លាស់ប្តូរច្បាប់អាពាហ៍ពិពាហ៍សម្រាប់ស្រ្តីរបស់ខ្លួន ហើយជាលទ្ធផលធ្វើឲ្យមានការអនុលោមតាមទាំង ICCPR និង CEDAW។ ស្ថាប័នសន្ធិសញ្ញា CEDAW បានបញ្ជាក់ថាច្បាប់អាពាហ៍ពិពាហ៍របស់ប្រទេសថៃបានរើសអើងលើស្រ្តីៈ ជាការពិបាកជាង សម្រាប់ស្រ្តីក្នុងការលែងលះបុរស ដោយពួកគាត់ត្រូវបង្ហាញថាបុរសផិតក្បត់ ឬបុរសបានបាត់ខ្លួនរយៈពេលពីរឆ្នាំ ខណៈពេលដែលបុរសមានជម្រើសក្នុងការលែងលះដោយមិនមានកំហុស។ លើសពីនេះទៀតស្រ្តីត្រូវតែប្តូរត្រកូលដាក់ត្រកូលប្តី។ ក្នុងឆ្នាំ ២០០៥ ប្រទេសថៃបានផ្លាស់ប្តូរច្បាប់នេះ។

## បណ្តឹងបុគ្គល

បន្ថែមពីលើការទទួលបណ្តឹងបុគ្គល ស្ថាប័នសន្ធិសញ្ញាមួយចំនួនក៏ទទួលបណ្តឹងពីបុគ្គល និងរដ្ឋភាគីផងដែរ។ ខណៈពេលដែលស្ថាប័នសន្ធិសញ្ញាចំនួនបួនធ្វើការទទួលបណ្តឹងរវាងរដ្ឋ កន្លងមកមិនមានបណ្តឹងបែបនេះនោះទេ ហើយដូចនេះនីតិវិធីនេះនឹងមិនត្រូវបានពិភាក្សានោះទេ។ ជាការគ្រប់គ្រាន់ក្នុងការចងចាំថា ដូចគ្នានឹងHRC ដែរ រដ្ឋជារឿយៗមានការស្ទាក់ស្ទើរផ្នែកនយោបាយក្នុងការផ្តួចផ្តើមបណ្តឹងដោយផ្ទាល់លើរដ្ឋដទៃដោយខ្លាចការសងសឹក ដែលមានន័យថាទុកឱកាសឲ្យបុគ្គល និងសង្គមស៊ីវិលក្នុងការធ្វើកិច្ចការនេះ ដើម្បីប្តឹងពីការរំលោភបំពានសិទ្ធិមនុស្សជាក់លាក់។ ម្យ៉ាងវិញទៀត បណ្តឹងបុគ្គលត្រូវបានប្រើប្រាស់ត្រូវបានប្រើប្រាស់ច្រើនជាង ដោយមានបណ្តឹងប្រហែលជា ២៥០០ ដែលបានដាក់ជូនស្ថាប័នសន្ធិសញ្ញាកាលពីពេលកន្លងមកនេះ។ សន្ធិសញ្ញាទាំងអស់មានយន្តការបណ្តឹង យ៉ាងណាមិញៈ

- CMW ៖ អនុសញ្ញាពលករទេសន្តប្រវេសន៍ត្រូវការរដ្ឋចំនួនដប់ ក្នុងការផ្តល់សច្ចាប័នមាត្រា ៧៧ នៃអនុសញ្ញាដើម្បីនីតិវិធីបណ្តឹងអាចចាប់ផ្តើមបាន។ ត្រឹមឆ្នាំ ២០១៩ មានតែរដ្ឋចំនួនពីរតែប៉ុណ្ណោះដែលបានផ្តល់សច្ចាប័ន។

- CRC ៖ នីតិវិធីបណ្តឹងសម្រាប់ CRC ត្រូវបានផ្តួចផ្តើមឡើងក្នុងដើមឆ្នាំ ២០១៤ នៅពេលដែលពិធីសារជម្រើសទីបីរបស់អនុសញ្ញានេះ ទទួលបានការផ្តល់សច្ចាប័នចាំបាច់ចំនួនដប់។ គិតត្រឹមឆ្នាំ២០១៤ មិនទាន់មានការដឹងបណ្តឹងនៅឡើយទេ។

- ICESCR ៖ នីតិវិធីបណ្តឹងសម្រាប់ ICESCR ត្រូវបានផ្តួចផ្តើមក្នុងខែឧសភា ឆ្នាំ ២០១៣ នៅពេលដែលពិធីសារបន្ថែមទទួលបានការផ្តល់សច្ចាប័នដែលចាំបាច់ចំនួនដប់។ យ៉ាងណាមិញមិនទាន់មានការកាត់សេចក្តីលើបណ្តឹងបុគ្គលនៅឡើយទេ។
- ICED ៖ សន្ធិសញ្ញាការបាត់ខ្លួនដោយ បង្ខំតម្រូវឲ្យរដ្ឋធ្វើការប្រកាសតាមមាត្រា ៣១ ថាពួកគេអនុញ្ញាតឲ្យមានបណ្តឹង។ មកដល់ពេលបច្ចុប្បន្ន រដ្ឋភាគីចំនួន១៦ បានធ្វើសេចក្តីប្រកាសនេះ។ មិនមានចំនួនអប្បបរមាចាំបាច់សម្រាប់ស្ថាប័នសន្ធិសញ្ញាក្នុងការទទួលបណ្តឹងបុគ្គលនោះទេ ហើយគិតត្រឹមឆ្នាំ ២០១៤ នេះមិនមានការដាក់បណ្តឹងនោះទេ។

សន្ធិសញ្ញាដែលសេសសល់ចំនួន ៥ ទៀតមាននីតិវិធីបណ្តឹងដែលត្រូវបានប្រើប្រាស់ ទោះបីជាបណ្តឹងបុគ្គលត្រូវតែមានការព្រមព្រៀងដោយស្ម័គ្រចិត្ត ដោយរដ្ឋក៏ដោយ។ ពិនិត្យមើលលើកំណត់ត្រានៃប្រទេសអាស៊ីអាគ្នេយ៍ មានប្រទេសមួយចំនួនបានអនុញ្ញាតលើបណ្តឹងបុគ្គល៖ ប្រទេសថៃ និង ហ្វីលីពីនអនុញ្ញាតឲ្យបុគ្គលក្នុងការដាក់បណ្តឹងទៅស្ថាប័នសន្ធិសញ្ញាចំនួនពីរ ហើយទីម័រខាងកើតអនុញ្ញាតឲ្យមានការដាក់បណ្តឹងដល់ CEDAW។ ក្នុងន័យម្យ៉ាង នេះមិនមែនជាកំណត់ត្រាអាក្រក់នោះទេ ដោយសារជាទូទៅប្រទេសភាគច្រើនមិនអនុញ្ញាតឲ្យមានបណ្តឹងបុគ្គលនោះទេ ទោះបីជានេះមានន័យថានីតិវិធីកម្រត្រូវបានប្រើប្រាស់ក្នុងតំបន់ក៏ដោយ។ ករណីលើកលែងចំពោះបណ្តឹងដែលបានប្តឹងទៅស្ថាប័នសន្ធិសញ្ញា ICCPR ប្រឆាំងប្រទេសហ្វីលីពីន (១៦ បណ្តឹង) និងបណ្តឹងមួយពីបុគ្គលមួយរូបដែលបានប្តឹងទៅ CEDAW ពីប្រទេសហ្វីលីពីន។ ថៃ និងទីម័រខាងកើតមិនដែលប្រឈមនឹងបណ្តឹងបុគ្គលនោះទេ។

តារាង ៥-៥៖ ប្រទេសនៅអាស៊ីអាគ្នេយ៍អនុញ្ញាតឲ្យមានបណ្ដឹងបុគ្គល

| សន្ធិសញ្ញា | អនុញ្ញាតឲ្យមានបណ្ដឹង | ចុះហត្ថលេខាមិនផ្ដល់សច្ចាប័ន |
|---|---|---|
| ICERD | អត់មាន | |
| ICESCR | អត់មាន | ទីម័រខាងកើត |
| ICCPR | ហ្វីលីពីន | កម្ពុជា |
| CEDAW | ហ្វីលីពីន ថៃ ទីម័រខាងកើត | ឥណ្ឌូនេស៊ី |
| CAT | អត់មាន | ឡាវ |
| CRC | ថៃ | អត់មាន |
| CMW | អត់មាន | កម្ពុជា |
| ICED | អត់មាន | ឥណ្ឌូនេស៊ី ឡាវ និងថៃ |
| CRPD | អត់មាន | កម្ពុជា |

# នីតិវិធីក្នុងការដាក់ពាក្យបណ្ដឹង

នីតិវិធីបណ្ដឹងបុគ្គល គឺនីតិវិធីដូចនឹងនីតិវិធីច្បាប់ ដែលតាមរយៈនេះ ស្ថាប័នសន្ធិសញ្ញាប្រមូលព័ត៌មានពីបុគ្គល ដែលគិតថាសិទ្ធិរបស់ពួកគេត្រូវបានរំលោភបំពាន។ ទាមទារឲ្យមានការអនុវត្តតាមនីតិវិធីលម្អិត និងបច្ចេកទេសដើម្បីដាក់ពាក្យបណ្ដឹង។ នីតិវិធីខុសៗគ្នាបន្តិចបន្តួចរវាងស្ថាប័នសន្ធិសញ្ញា ប៉ុន្តែជាមូលដ្ឋានត្រូវអនុវត្តតាមវិធីខាងក្រោមនេះ៖

**បណ្ដឹងបុគ្គល**
នៅពេលដែលបុគ្គលមួយរូបគិតថាសិទ្ធិមនុស្សរបស់ពួកគេត្រូវបានរំលោភបំពាន នៅក្នុងករណីមួយចំនួនពួកគេអាចដាក់បណ្ដឹងទៅ UN។ មានលក្ខខណ្ឌជាច្រើន៖ (១) រដ្ឋត្រូវតែបានផ្ដល់សច្ចាប័នលើសន្ធិសញ្ញា (២) អនុញ្ញាតឲ្យបុគ្គលដាក់បណ្ដឹង និង (៣) បុគ្គលត្រូវបានឆ្លងកាត់ប្រព័ន្ធច្បាប់រដ្ឋ ឬនីតិវិធីដែលមានតម្លៃស្មើ។

១. ដើមបណ្ដឹង (ឬអ្នកណាម្នាក់ដែលតំណាងឲ្យដើមបណ្ដឹង) បញ្ជូនអង្គហេតុពីព្រឹត្តការណ៍ ព័ត៌មានពាក់ព័ន្ធដទៃទៀត និងគូសបញ្ជាក់ពីហេតុផលដែលគាត់មិនអាចទទួលបានយុត្តិធម៌ក្នុងប្រទេសរបស់ខ្លួនជាលាយលក្ខអក្សរទៅស្ថាប័នសន្ធិសញ្ញា។ សិទ្ធិដែលត្រូវបានរំលោភ និងការខកខានក្នុងការទទួលបានយុត្តិធម៌ត្រូវតែបញ្ជាក់លម្អិតក្នុងការប្រគល់ជូនបណ្ដឹងដំបូង។

២. គណៈកម្មាធិការសម្រេចថាតើខ្លួនមានសមត្ថកិច្ច ក្នុងការទទួលបណ្ដឹងនេះឬក៏អត់ នេះត្រូវបានហៅថាជាការសម្រេចក្នុងការទទួលបណ្ដឹង។ ដើម្បីឲ្យស្ថាប័នសន្ធិសញ្ញាធ្វើការពិចារណាលើបណ្ដឹងមួយ (មានន័យថាដើម្បីឲ្យបណ្ដឹងអាចទទួលយកបានត្រូវបំពេញតាមលក្ខន្តិកៈមួយចំនួន)៖

   ក. សន្ធិសញ្ញាត្រូវបានផ្ដល់សច្ចាប័ន ហើយរដ្ឋភាគីត្រូវតែបានព្រមព្រៀងក្នុងការអនុញ្ញាតឲ្យមានបណ្ដឹងបុគ្គល។

ខ. បណ្តឹងមិនអនាមិក ដូចនេះបុគ្គលដែលសិទ្ធិរបស់គាត់ត្រូវបានរំលោភអាចត្រូវបានកំណត់អត្តសញ្ញាណច្បាស់លាស់។

គ. មានការរំលោភបំពានលើមាត្រានៃសន្ធិសញ្ញា ដែលនេះត្រូវបានបញ្ជាក់ច្បាស់លាស់។

ឃ. បុគ្គលបានដាក់ពាក្យបណ្តឹងទៅរដ្ឋ ប៉ុន្តែមិនមានលទ្ធផលនោះទេ។ នេះត្រូវបានហៅថាជា ʻការបញ្ចប់នីតិវិធីបណ្តឹងថ្នាក់ជាតិʼ។ ក្នុងន័យម្យ៉ាងទៀតមានន័យថា បុគ្គលមិនអាចស្វែងរកយុត្តិធម៌ពីរដ្ឋ។ ស្ថាប័នសន្ធិសញ្ញានឹងធ្វើការពិចារណាលើបណ្តឹងប្រសិនបើនីតិវិធីដទៃទាំងអស់ត្រូវបានបញ្ចប់ប៉ុណ្ណោះ។

៣. ស្ថាប័នសន្ធិសញ្ញាផ្ញើបណ្តឹងដល់រដ្ឋភាគី

៤. រដ្ឋភាគីឆ្លើយតបនឹងការប្តឹងមកលើខ្លួន

៥. ការឆ្លើយតបរបស់រដ្ឋត្រូវបានផ្ញើជូនដើមបណ្តឹងដើម្បីអនុញ្ញាតឲ្យពួកគេឆ្លើយតប។ នៅក្នុងករណីខ្លះ ការផ្ញើទៅវិញទៅកមនេះត្រូវធ្វើពីរដង។

៦. នៅពេលព័ត៌មានទាំងអស់នេះត្រូវបានប្រមូល បន្ទាប់មកគណៈកម្មាធិការនឹងពិនិត្យលក្ខណៈសម្បត្តិនៃបណ្តឹង ដើម្បីសម្រេចថាតើមានការរំលោភបំពានឬក៏អត់ ហើយអ្វីគួរតែជាលទ្ធផល។ ប្រសិនបើពួកគេរកឃើញថាមានការរំលោភបំពានកើតឡើង ពួកគេអាចស្នើដល់រដ្ឋក្នុងការដោះស្រាយបញ្ហា ផ្តល់សំណងជូនបុគ្គល និងផ្លាស់ប្តូរច្បាប់ ឬការអនុវត្តដើម្បីកុំឲ្យកើតមានឡើងម្តងទៀត។

## ទស្សនៈទាន

### ការបញ្ចប់នីតិវិធីបណ្តឹងថ្នាក់ជាតិ

វិធានបញ្ចប់ឧបាស្រ័យផ្តល់ឱកាសដល់រដ្ឋ (ជាពិសេសតុលាការ) ក្នុងការដោះស្រាយការរំលោភបំពាន ដូចនេះដើម្បីជៀសវាងការចូលខ្លួនពាក់ព័ន្ធដោយស្ថាប័នសន្ធិសញ្ញា។ ជាពិសេស នេះមានន័យថាជនរងគ្រោះមានកាតព្វកិច្ចជាដំបូងក្នុងការទាមទារសិទ្ធិរបស់ខ្លួននៅក្នុងប្រព័ន្ធយុត្តិធម៌ថ្នាក់ជាតិ (តុលាការរដ្ឋប្បវេណី ព្រហ្មទណ្ឌ និង/ឬរដ្ឋបាលថ្នាក់ជាតិ)។ ប្រសិនបើបុគ្គលមិនអាចមានលទ្ធភាពក្នុងការទទួលបានសេវាពីប្រព័ន្ធនេះ ឬប្រសិនបើប្រព័ន្ធយុត្តិធម៌ធ្វើការរំលោភបំពានសិទ្ធិ ឬប្រសិនបើឧបាស្រ័យដែលបានផ្តល់ជូនមិនគ្រប់គ្រាន់ នោះបុគ្គលអាចប្រើប្រាស់យន្តការស្ថាប័នសន្ធិសញ្ញា។

## ការបញ្ចប់នីតិវិធីបណ្តឹងថ្នាក់ជាតិធានាថាបុគ្គលមិនចាត់ទុកថា UN ជាអ្នកឆ្លើយតបបឋមលើការរំលោភបំពាន។

នីតិវិធីនេះមានភាពយឺតយ៉ាវ ហើយប្រហែលជាចំណាយពេលមួយឆ្នាំមុនពេលធ្វើការសម្រេចចិត្ត។ បណ្តឹងបន្ទាន់ ជារឿយៗត្រូវបានបញ្ជូនតាមនីតិវិធីផ្សេង (ដូចជាអ្នករាយការណ៍ពិសេស) ដែលវិធានការត្រូវបានចាត់ក្នុងរយៈពេលតែប៉ុន្មានថ្ងៃប៉ុណ្ណោះ មិនមែនឆ្នាំនោះទេ។ នីតិវិធីនេះយឺតដោយសារពេលខ្លះរដ្ឋមិនឆ្លើយតប ដែលនេះធ្វើឲ្យបណ្តឹងត្រូវបានដាក់ដោយមិនមានធាតុចូលពីរដ្ឋ។ ស្ថាប័នសន្ធិសញ្ញាអាចជួបប្រជុំត្រឹមពីរបីដងក្នុងមួយឆ្នាំប៉ុណ្ណោះ (ប្រហែលជាប្រាំមួយទៅដប់សប្តាហ៍ក្នុងមួយឆ្នាំប៉ុណ្ណោះ)។ ដោយសារគណៈកម្មាធិការមិនមានអំណាចចងកាតព្វកិច្ច ខ្លួនមិនអាចចាប់បង្ខំអនុវត្តលទ្ធផលនូវអ្វីដែលខ្លួនបានរកឃើញនោះទេ។ នៅក្នុងករណីជាច្រើន ស្ថាប័នសន្ធិសញ្ញាអាចរកឃើញថាការរំលោភបំពានកើតមានឡើង ហើយស្នើដល់រដ្ឋក្នុងការផ្តល់សំណង ត្រឹមតែបានធ្វើឲ្យរដ្ឋមិនអើពើលើសំណើររបស់ខ្លួនប៉ុណ្ណោះ។

ខណៈពេលដែលដែនកំណត់ទាំងនេះ បង្កប់ន័យថានីតិវិធីបណ្តឹងមានភាពទន់ខ្សោយ និងមិនមានប្រសិទ្ធិភាព នីតិវិធីមានការរួមចំនែកសំខាន់ៗមួយចំនួន។ ការរកឃើញរបស់ស្ថាប័នសន្ធិសញ្ញាអាចឈានដល់ការធ្វើវិសោធនកម្មច្បាប់ ដើម្បីធានាថាសិទ្ធិមនុស្សត្រូវបានការពារ (ជាឧទាហរណ៍ ស្ថាប័នមួយបានរកឃើញថាច្បាប់ ដែលចាត់ទុកការរួមភេទដូចគ្នាគឺជាបទឧក្រិដ្ឋ គឺជាការរំលោភបំពានសិទ្ធិក្នុងរឿងក្តី Toonen v. អូស្ត្រាលី (១៩៩២)។ នីតិវិធីនេះអាចផ្អាកនីតិវិធីក្នុងការសម្លាប់ជនណាម្នាក់ដែលស្ថិតក្នុងបញ្ជីពិឃាត រហូតដល់ការបញ្ចប់ការស៊ើបអង្កេតសមស្របមួយ (ជាឧទាហរណ៍ Piandiong v. ហ្វីលីពីន ឆ្នាំ១៩៩៩ និងករណីដទៃទៀតក្នុងប្រទេសហ្សាម៉ៃកា បេឡារូស និងគីហ្សីស្ថាន)។ លើសពីនេះទៀត ស្ថាប័នសន្ធិសញ្ញាអាចបង្ហាញនូវស្តង់ដារសិទ្ធិមនុស្សថ្មីដើម្បីជួយដល់រដ្ឋក្នុងការស្វែងយល់ និងបកស្រាយពីសិទ្ធិមនុស្ស (ជាឧទាហរណ៍ នៅក្នុងរឿងក្តីកាលពីពេលថ្មីៗនេះ បានបញ្ជាក់ថាស្ថានភាពដែលមានលទ្ធភាពក្នុងការរំលូតកូន ត្រូវបានចាត់ទុកថាជាសិទ្ធិក្នុង Huaman v. ប៉េរូ ២០០៣-៥)។

ជាទូទៅ បណ្តឹងភាគច្រើនត្រូវបានប្តឹងទៅ ICCPR ដោយសារតែកតិកាសញ្ញានេះមានការផ្តល់សច្ចាប័នច្រើនជាងគេ និងចំណាស់ជាងគេ ហើយជាសន្ធិសញ្ញាទូលំទូលាយបំផុតដែលអនុញ្ញាតឲ្យមានបណ្តឹង។ មានបណ្តឹងមួយចំនួនតូចដែលត្រូវបានប្តឹងទៅ CEDAW ជាការគួរឲ្យភ្ញាក់ផ្អើលដោយសារតែអនុសញ្ញានេះមានការផ្តល់សច្ចាប័នជាសកល ហើយមិនមានប្រទេសណាមួយបានទទួលសមភាពពេញលេញសម្រាប់ស្ត្រីនោះទេ។ យ៉ាងណាមិញ កង្វះខាតនៃបណ្តឹងប្រហែលជាដោយសារតែការពិតដែលថាយន្តការដទៃមានប្រសិទ្ធិភាពជាង។ បណ្តឹងជាច្រើនត្រូវបានប្តឹងទៅ CAT ដោយសារ

តែបណ្ដឹងនេះ អាចត្រូវបានប្រើប្រាស់ដោយបុគ្គលធ្វើការទាមទារឋានៈជាជនភៀសខ្លួនរបស់ពួកគេ ដោយសារតែសន្ធិសញ្ញាមិនអនុញ្ញាតឲ្យធ្វើនិរទេសនោះទេ ប្រសិនពួកគេអាចប្រឈមនឹងទារុណកម្ម ដូចនេះបណ្ដឹងភាគច្រើនមានប្រភពចេញពីប្រទេសដែលមានជនភៀសខ្លួន។ នេះមិនមែនជាករណីចំពោះប្រទេសដូចជាស៊ុយអែត និងស្វីសនោះទេ ដោយសារតែប្រទេសទាំងពីរនេះមិនមានការធ្វើទារុណកម្មនោះទេ។

តារាង ៥-៦: ការប្ដេជ្ញាក្នុងនីតិវិធីបណ្ដឹង

| | ICCPR | ICERD | CAT | CEDAW |
|---|---|---|---|---|
| រដ្ឋភាគី | ១១៣ | ៥៨ | ៦៩ | ១០៦ |
| ចំនួនករណី | ២០៣៩ | ៩៥ | ៩៦២ | ២៧ |
| ករណីដែលមានការរំលោភបំពាន | ៧១៨ | ១០ | ៦០ | ៦ |
| ប្រទេសដែលមានបណ្ដឹងច្រើន | ហ្សាម៉ៃកា(១៧៧)<br>កាណាដា (១៥៨)<br>អេស្ប៉ាញ (១១៧)<br>កូរ៉េ (១២៥) | | ស៊ុយអែត (១០៨)<br>ស្វីស (១១៨)<br>កាណាដា (៧៣)<br>អូស្ត្រាលី (៣០) | |

# វិចារណកថាទូទៅ

សកម្មភាពដទៃទៀតរបស់ស្ថាប័នសន្ធិសញ្ញា ជួយដល់រដ្ឋក្នុងការស្វែងយល់ពីសន្ធិសញ្ញា ដែលនេះត្រូវបានធ្វើឡើងតាមរយៈមតិយោបល់ជាលាយលក្ខអក្សរ ដែលភាគច្រើនលើសិទ្ធិជាក់លាក់ក្នុងសន្ធិសញ្ញា។ សន្ធិសញ្ញានីមួយៗបានចេញវិចារណកថាមួយចំនួន ហើយដែលសន្ធិសញ្ញាថ្មីមានវិចារណកថាមួយឬពីរប៉ុណ្ណោះ ICCPR មានចំនួន ៣២ ហើយ ICESCR មានចំនួន ២១។ វិចារណកថាទូទៅអនុញ្ញាតឲ្យមានបញ្ជាក់ពីចរិកលក្ខណៈពិតប្រាកដនៃកាតព្វកិច្ចរដ្ឋចំពោះសន្ធិសញ្ញា។ ជាឧទាហរណ៍ ស្ថាប័នសន្ធិសញ្ញានៃ ICESCR បានចេញវិចារណកថាមានសារៈសំខាន់លើសិទ្ធិស្តង់ដារជីវភាពដូចជាចំណីអាហារ ទឹក និងលំនៅដ្ឋាន (បញ្ជាក់លម្អិតក្នុងជំពូកទីបីស្ដីពី ESCR) ។ វិចារណកថាទូទៅក៏បានផ្ដល់ធាតុផ្សំជាក់លាក់ផងដែរលើសិទ្ធិជីវភាពដូចជា ការដែលមាន ការដែលអាចទទួលបាន និងការដែលអាចទទួលយកបាន។ លើសពីនេះទៀត ពាក់ព័ន្ធនឹងសិទ្ធិលំនៅដ្ឋាន មានធាតុផ្សំបន្ថែមដូចជាសន្តិសុខនៃកម្មសិទ្ធិ ការដែលអាចផ្គត់ផ្គង់បាន និងទីតាំង។ វិចារណកថាទូទៅមួយចំនួនពីមាត្រា

ជាក់លាក់ ដូចជាវិចារណកថាលើមាត្រា ១៩ (សេរីភាពនៃការបញ្ចេញមតិ) នៃ ICCPR ឬមាត្រា ២៤ ស្តីពីសុខភាពកុមារក្នុង CRC។ មានវិចារណកថាដទៃទៀតលើបញ្ហាតាមប្រធានបទផងដែរ ដូចជាកុមារក្នុងយុត្តិធម៌អនីតិជន កុមារពិការ តួនាទីរបស់ NHRIs និងកាតព្វកិច្ចផ្លូវច្បាប់របស់រដ្ឋជាដើម។

ជាចម្បង វិចារណកថាទូទៅអាចពង្រីកវិសាលភាពនៃសិទ្ធិមួយ។ ជាឧទាហរណ៍ ទឹកជាសិទ្ធិមនុស្សត្រូវបានបញ្ចូលក្នុងវិចារណកថាទូទៅ ដោយសារតែវាមិនត្រូវបានសរសេរច្បាស់លាស់ក្នុងសន្ធិសញ្ញា។ យ៉ាងណាមិញ ការកែសម្រួលលើសិទ្ធិនេះក្នុងសន្ធិសញ្ញាអាចឈានទៅដល់ការទាស់គ្នាក្នុងចំណោមរដ្ឋភាគីខ្លះ។ ជាពិសេស សំណួរដែលបានចោទសួរភាគច្រើន៖ តើវិចារណកថាចងកាតព្វកិច្ចដែរឬទេ? កម្មវត្ថុចម្បងនៃវិចារណកថាទូទៅជួយដល់រដ្ឋក្នុងការស្វែងយល់ពីសិទ្ធិ ហើយដូចនេះដើម្បីបំពេញកាតព្វកិច្ច និងភារកិច្ច នៅពេលដល់ពេលវេលាដែលខ្លួនត្រូវធ្វើរបាយការណ៍ដល់ស្ថាប័នសន្ធិសញ្ញា។

## ការពិភាក្សា និងការជជែកវែកញែក

### តើវិចារណកថាចងកាតព្វកិច្ចផ្លូវច្បាប់ដែរឬទេ?

នៅពេលរដ្ឋមួយផ្តល់សច្ចាប័នលើសន្ធិសញ្ញាមួយ រដ្ឋនោះព្រមព្រៀងក្នុងការចងកាតព្វកិច្ចដោយសិទ្ធិនៅក្នុងសន្ធិសញ្ញានេះ។ បន្ទាប់មកប្រសិនបើស្ថាប័នសន្ធិសញ្ញាពង្រីកសិទ្ធិទាំងអស់នោះដើម្បីបញ្ចូលធាតុផ្សំថ្មីដូចជាសិទ្ធិក្នុងការទទួលបានទឹក តើរដ្ឋត្រូវតែចងកាតព្វកិច្ចផ្លូវច្បាប់លើកាតព្វកិច្ចនេះដែរឬទេ? រដ្ឋមិនព្រមព្រៀងនឹងវិចារណកថាទូទៅនៅពេលដែលខ្លួនផ្តល់សច្ចាប័នលើសន្ធិសញ្ញា ហើយខ្លួនមិនអាចបកស្រាយការយល់ដឹងពីសន្ធិសញ្ញាទេ មែនទេ?

ម្យ៉ាងវិញទៀត វិចារណកថាទូទៅមិនបង្កើតសិទ្ធិថ្មីនោះទេ ប៉ុន្តែជាសាមញ្ញគ្រាន់តែបញ្ជាក់ពីវិសាលភាពនៃសិទ្ធិជាក់លាក់ប៉ុណ្ណោះ ដូចនេះទឹកត្រូវបានចាត់ទុកថាជាផ្នែកមួយនៃចំណីអាហារ ហើយដូចនេះជាការមិនសមហេតុផលនោះទេក្នុងការគិតថាសិទ្ធិចំណីអាហារមិនរួមបញ្ចូលទឹកនោះទេ? ស្ថាប័នសន្ធិសញ្ញាធានាថារដ្ឋភាគីមាន(ឬយ៉ាងហោចណាស់) ការបកស្រាយដូចគ្នាលើថាសិទ្ធិជាក់លាក់ណាមួយមានន័យដូចម្តេច។

វិចារណកថាទូទៅស្ថិតនៅពាក់កណ្តាលរវាងឯកសារចងកាតព្វកិច្ច និងទស្សនៈមួយ។ រដ្ឋខ្លះមិនចាត់វិចារណកថាជាការចងកាតព្វកិច្ចនោះទេ និងផ្តោតការយកចិត្តទុកដាក់ខុសៗគ្នាតាមសន្ធិសញ្ញាផ្ទាល់ ដោយជឿថាពួកគេចងកាតព្វកិច្ចចំពោះសន្ធិសញ្ញា

ដែលខ្លួនបានផ្តល់សច្ចាប័នប៉ុណ្ណោះ។ ប៉ុន្តែស្ថាប័នភាគច្រើន ពិតជាផ្តល់ទម្ងន់ផ្លូវច្បាប់ដល់វិចារណកថាទូទៅ ដោយសារពួកគេធ្វើការកំណត់និយមន័យនៃសន្ធិសញ្ញា និងអ្វីដែលចងកាតព្វកិច្ចនៅក្នុងសន្ធិសញ្ញានេះ។ ដូចនេះ ខណៈពេលដែលវិចារណកថាមិនចងកាតព្វកិច្ច វិចារណកថាទាំងនេះមានការអំណាចបកស្រាយលើសន្ធិសញ្ញា ហើយដូចនេះធ្វើការកំណត់ថាតើរដ្ឋចងកាតព្វកិច្ចចំពោះអ្វីខ្លះ។

## នីតិវិធីដទៃទៀត

ស្ថាប័នសន្ធិសញ្ញាអាចអនុវត្តសកម្មភាពមួយចំនួនទៀតក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស។ ស្ថាប័នសន្ធិសញ្ញាចំនួនបួន (CAT CRPD CEDAW និង ICED នៅពេលដែលពិធីសារចូលជាធរមាន) អាចផ្តួចផ្តើមការសាកសួរលើការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ និងរាលដាលក្នុងប្រទេសមួយ។ នីតិវិធីនេះជាការសម្ងាត់ ហើយទាមទារឲ្យការទទួលយកដោយរដ្ឋ ដែលច្បាស់ណាស់នឹងកម្រិតដល់អំណាចរបស់ស្ថាប័នក្នុងការស៊ើបអង្កេត។ ជំពូកស្តីពីស្ត្រីបញ្ជាក់លម្អិតពីការសាកសួរមួយចំនួនដែលបានធ្វើឡើងក្នុងអនុសញ្ញា CEDAW។ CAT បានធ្វើការសាកសួរជាសម្ងាត់ចំនួនប្រាំបីលើក (រួមមានប្រទេសនៅអាស៊ីចំនួនពីរផងដែរ នេប៉ាល់ក្នុងឆ្នាំ ២០១២ និងស្រីលង្កាក្នុងឆ្នាំ ២០០២។ ខណៈពេលដែល CRPD និង CED មិនទាន់បានធ្វើការសាកសួរនៅឡើយទេ។ រដ្ឋតែមួយគត់នៅអាស៊ីអាគ្នេយ៍ដែលអនុញ្ញាតនីតិវិធីនេះគឺហ្វីលីពីន និងសឹង្ហបូរីចំពោះ CEDAW ហើយកម្ពុជាចំពោះសន្ធិសញ្ញាជនពិការ (ទោះបីជាខ្លួនទើបតែបានចុះហត្ថលេខា ប៉ុន្តែមិនទាន់ផ្តល់សច្ចាប័នលើពិធីសារនៃនីតិវិធីនេះក៏ដោយ)។

ជាការសំខាន់ក្នុងការចងចាំថាស្ថាប័នសន្ធិសញ្ញា នឹងធ្វើការស៊ើបអង្កេតតែលើស្ថានភាពនៃការរំលោភបំពានធ្ងន់ធ្ងរប៉ុណ្ណោះ។ ស្ថាប័ននេះមិនធ្វើការស៊ើបអង្កេតលើលើព្រឹត្តការណ៍តែមួយនោះទេ។ លើសពីនេះទៀត តម្រូវឲ្យមានភ័ស្តុតាងកម្រិតខ្ពស់។ ដែលនេះត្រូវបានបំពេញដោយការត្រួតពិនិត្យរបាយការណ៍ និងដំណើររឿងហេតុនៅក្នុងកិច្ចប្រជុំស្ថាប័នសន្ធិសញ្ញាប៉ុណ្ណោះ។ ប្រសិនជាស្ថាប័នត្រូវបានអញ្ជើញ ពួកគេអាចទស្សនៈកិច្ចដល់ប្រទេស។ លទ្ធផលនៃនីតិវិធីក្នុងទម្រង់ជារបាយការណ៍នេះ នឹងត្រូវបានប្រគល់ជូនរដ្ឋភាគី ហើយបន្ទាប់មកនឹងត្រូវបានផ្សព្វផ្សាយលើគេហទំព័រស្ថាប័នសន្ធិសញ្ញា។

យន្តការដទៃរួមមាននីតិវិធី'ការព្រមានបឋម និងសកម្មភាពបន្ទាន់'។ ការព្រមានបឋម និង សកម្មភាពបន្ទាន់ត្រូវបានប្រើប្រាស់ដោយស្ថាប័នសន្ធិសញ្ញាក្នុងការលុបបំបាត់ការរើសអើងពូជសាសន៍។ កម្មវត្ថុគឺដើម្បីអន្តរាគមន៍ក្នុងការបញ្ឈប់ការរំលោភបំពានធ្ងន់ធ្ងរដែលអាចកើតឡើងជាលទ្ធផលនៃការកើនឡើងភាពតានតឹងពូជសាសន៍ (ដូចជាអំពើប្រល័យពូជសាសន៍ អំពើហិង្សាទ្រង់ទ្រាយធំតាមមូលដ្ឋាន ឬការជម្រះពូជសាសន៍)។

មានរបាយការណ៍ប្រហែលជា ១៨ តាមរយៈនីតិវិធីនេះ ហើយប្រទេសប្រហែលជា ៤០ បានទទួលសំបុត្រជាការព្រមានបឋម។ ពីអាស៊ីអាគ្នេយ៍ ប្រទេសថៃបានទទួលសំបុត្រពាក់ព័ន្ធនឹងការប្រព្រឹត្តលើក្រុមជនជាតិភាគតិចការ៉េន (Karen) ឥណ្ឌូនេស៊ីពាក់ព័ន្ធនឹងក្រុមជនជាតិដើមភាគតិចក្នុងតំបន់ប៉ាប៉ា Papua ខាងលិច ឡាវពីជនជាតិហ្មុង Hmong និងហ្វីលីពីនពីក្រុមជនជាតិដើមភាគតិចស៊ូប៉ាណន់(Subanon)។

## ក. សេចក្តីសង្ខេបពីជំពូក និងចំនុចគន្លឹះ

### អង្គការសហប្រជាជាតិ និងសិទ្ធិមនុស្ស

UN ជាស្ថាប័នសំខាន់បំផុតនៅកម្រិតអន្តរជាតិក្នុងការការពារសិទ្ធិមនុស្ស។ ស្ថាប័ននេះបានបង្កើតប្រព័ន្ធជាផ្លូវការមួយក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្សជាសកល។ រដ្ឋប្តេជ្ញាចិត្តក្នុងការគោរពសិទ្ធិមនុស្សនៅពេលក្លាយជាសមាជិករបស់ UN ទោះបីជាការការពារសិទ្ធិមនុស្សក្នុងករណីខ្លះពិបាកក្នុងការអនុវត្តក៏ដោយ។

### សិទ្ធិមនុស្សនៅក្នុងប្រព័ន្ធ UN ដ៏ទូលំទូលាយ

ក្នុងនាមជាស្ថាប័ននយោបាយអន្តរជាតិមួយ UN មានលក្ខណៈបច្ចេកទេសខ្ពស់ និងរចនាសម្ព័ន្ធចម្រុះ។ សិទ្ធិមនុស្សត្រូវបានការពារដោយស្ថាប័នរបស់ UN ដែលជាផ្នែកសំខាន់បំផុតរបស់ UN។ UNSC ដើរតួនាទីសំខាន់បំផុតក្នុងការចាប់បង្ខំការអនុវត្ត ជាពិសេសពាក់ព័ន្ធនឹង "ការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ និងជាប្រព័ន្ធ"។

UNGA ផ្តល់សម្លេងស្មើគ្នាដល់រដ្ឋសមាជិក UN ទាំងអស់ស្តីពីបញ្ហាសិទ្ធិមនុស្ស ហើយជាកន្លែងដែលសន្ធិសញ្ញាសិទ្ធិមនុស្សត្រូវបានអនុម័ត និងចុះហត្ថលេខាដោយរដ្ឋ។ ICJ ផ្តល់មតិយោបល់ និងការបកស្រាយលើច្បាប់អន្តរជាតិ ដោយរួមមានច្បាប់សិទ្ធិមនុស្ស វិវាទរដ្ឋរវាងនឹងរដ្ឋ លើច្បាប់អន្តរជាតិ។ អគ្គលេខាធិការ UN ដើរតួនាទីរដ្ឋបាលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស។ ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមលើកកម្ពស់សិទ្ធិមនុស្សតាមរយៈធម្មនុញ្ញ UN ជាចម្បងដោយធ្វើការបង្កើតស្ថាប័នសិទ្ធិមនុស្ស។ រាល់ប្រទេសអាស៊ីអាគ្នេយ៍ទាំងអស់មានភាពសកម្មក្នុង UN ហើយកាន់កាប់តួនាទីជាច្រើនក្នុងស្ថាប័នរបស់ UN។

## ស្ថាប័នធម្មនុញ្ញនៃសិទ្ធិមនុស្សក្នុង UN

ស្ថាប័នធម្មនុញ្ញទទួលបាននិត្យានុកូលភាពរបស់ខ្លួនតាមរយៈធម្មនុញ្ញរបស់ UN ។ ស្ថាប័នមួយដែលជាក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលបានជំនួសឲ្យគណៈកម្មាការសិទ្ធិមនុស្សក្នុងឆ្នាំ ២០០៦ ដោយសារគណៈកម្មាការមិនមានសមត្ថកិច្ច និងមានភាពចម្រូងចម្រាស់។ HRC មានសមាជិកចំនួន ៤៧ រដ្ឋដែលជួបប្រជុំជាទៀងទាត់ដើម្បីពិភាក្សាកង្វល់សិទ្ធិមនុស្ស ហើយអនុវត្តនីតិវិធីពិសេស។ នេះរួមមានយន្តការរាយការណ៍ស្តីពីបញ្ហាសិទ្ធិមនុស្ស ដូចជាអ្នករាយការណ៍ពិសេស និងក្រុមការងារ។ យន្តការសំខាន់ដទៃទៀតជាការត្រួតពិនិត្យតាមពេលវេលាកំណត់ ដែលកំណត់ត្រាសិទ្ធិមនុស្សរបស់រដ្ឋនៅ UN ទាំងអស់ត្រូវបានត្រួតពិនិត្យដោយក្រុមប្រឹក្សា។

ស្ថាប័នធម្មនុញ្ញចម្បងដទៃទៀតគឺ ការិយាល័យឧត្តមស្នងការទទួលបន្ទុកកិច្ចការសិទ្ធិមនុស្ស ដែលធ្វើការលើការលើកកម្ពស់សិទ្ធិមនុស្សតាមរយៈការអប់រំ ការស្រាវជ្រាវសិទ្ធិមនុស្ស លើកកម្ពស់ការយល់ដឹង ការតស៊ូមតិ និងការគាំទ្របច្ចេកទេស និងជំនាញបច្ចេកទេសដល់រដ្ឋាភិបាល។

## ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សរបស់UN

ស្ថាប័នសន្ធិសញ្ញាត្រូវបានបង្កើតឡើង នៅពេលដែលសន្ធិសញ្ញាចូលជាធរមាន។ ស្ថាប័នមានសមាជិកពី ១០-២៣ រូប យោងទៅតាមសន្ធិសញ្ញា ដែលស្ថាប័ននេះនឹងផ្តល់យោបល់អ្នកជំនាញដល់រដ្ឋលើមធ្យោបាយ ក្នុងការអនុលោមតាមសន្ធិសញ្ញា។ ស្ថាប័នអាចបំពេញកិច្ចការនេះតាមវិធីសាស្ត្រមួយចំនួន ដោយរួមមានការពិនិត្យរបាយការណ៍ធ្វើឡើងដោយរដ្ឋភាគីលើការអនុវត្តសន្ធិសញ្ញា បញ្ជាក់អត្ថន័យ និងមុខងារនៃសន្ធិសញ្ញាដោយសរសេរវិចារណកថាទូទៅ និងក្នុងរណីខ្លះជំនុះជម្រះលើរឿងក្តីពីបុគ្គលឬធ្វើការស៊ើបអង្កេត។

## ខ. សំណួរប្រលង ឬសំណួរងាយស្រួល

- តើមានការផ្លាស់ប្តូរជាដុំកំភួនលើវិធីសាស្ត្រដែលស្ថាប័ន UN ជាក់លាក់បានឆ្លើយតបនឹងការរំលោភបំពានសិទ្ធិមនុស្សដែរឬទេ? ហេតុអ្វីបានជាការផ្លាស់ប្តូរនេះកើតមានឡើង ហើយអ្វីជាលទ្ធផលនៃការលើកម្ពស់ និងការការពារសិទ្ធិមនុស្ស?

- ហេតុអ្វីបានជាគណៈកម្មាការសិទ្ធិមនុស្សត្រូវបានជំនួសដោយក្រុមប្រឹក្សា? តើនេះពិព័ណនាពីអ្វីអំពីអាកប្បកិរិយារបស់រដ្ឋមួយចំនួន ឆ្ពោះទៅកាន់ការការពារសិទ្ធិមនុស្សនៅកម្រិត UN?

- តើការត្រួតពិនិត្យតាមពេលវេលាកំណត់ជាសកល ជាយន្តការដ៏មានប្រសិទ្ធិភាពមួយដែរឬទេ? តើវានឹងមានប្រសិទ្ធភាពជាងនីតិវិធីរាយការណ៍នៅស្ថាប័ន សន្ធិសញ្ញាទៀតមែនដែរឬទេ? តើអ្នកអាចផ្តល់អនុសាសន៍ដើម្បីធ្វើឲ្យនីតិវិធី UPR កាន់តែមានប្រសិទ្ធិភាពជាងនេះដែរឬទេ?
- តើអ្វីជាភាពខុសគ្នាជាចម្បងរវាងស្ថាប័នធម្មនុញ្ញ និងស្ថាប័នសន្ធិសញ្ញា?
- នៅពេលដែលបុគ្គលមួយរូបប្តឹងទៅស្ថាប័នសន្ធិសញ្ញា អ្វីដែលពួកគេគួរតែបង្ហាញដើម្បីឲ្យបណ្តឹងរបស់គាត់ត្រូវបានទទួលយក?

- ប្រសិនបើសន្ធិសញ្ញាមួយត្រូវបានពង្រីក ឬផ្លាស់ប្តូរនិយមន័យនៃសិទ្ធិមួយក្នុងសន្ធិសញ្ញា ជាឧទាហរណ៍រួមបញ្ចូលសិទ្ធិក្នុងការទទួលបានទឹក តើអ្នកគិតថារដ្ឋគួរតែត្រូវបានចងកាតព្វកិច្ចផ្លូវច្បាប់ចំពោះការបកស្រាយនេះដែរឬទេ? ឬរដ្ឋគួរតែមានសេរីភាពពេញលេញក្នុងការបកស្រាយសន្ធិសញ្ញាដូចដែលខ្លួនគិតថាសាកសម?

## គ. ឯកសារពិគ្រោះបន្ថែម

មានព័ត៌មានជាច្រើនលើប្រព័ន្ធទិន្នន័យ UN ។ គេហទំព័រសំខាន់ៗមាន៖

- OHCHR មានសៀវភៅណែនាំសាមញ្ញៗសំខាន់ៗមួយចំនួនស្តីពីនីតិវិធី ។
- គេហទំព័រ OHCHR ក៏មានព័ត៌មាន និងរបាយការណ៍ស្តីពីក្រុមប្រឹក្សា នីតិវិធីពិសេស និងស្ថាប័នសន្ធិសញ្ញាផងដែរ។

- ចំពោះឯកសារស្ថាប័នសន្ធិសញ្ញាសូមពិនិត្យមើល "ទិន្នន័យស្ថាប័នសន្ធិសញ្ញា" ដែលចងក្រងឯកសារនៃរបាយការណ៍ទាំងអស់ពីស្ថាប័នសន្ធិសញ្ញា។ ឯកសារទាំងអស់អាចស្រាវជ្រាវបានតាមប្រទេស ហើយតាមប្រភេទនៃឯកសារ ជាឧទាហរណ៍របាយការន៍រដ្ឋត្រូវបានចងក្រង ហើយបណ្ដឹងបុគ្គលមាននៅក្នុង 'យុត្តិសាស្ត្រ'។
- ឯកសារស្តីពីដំណើរការពង្រឹងស្ថាប័នសន្ធិសញ្ញា មាននៅទំព័រពិសេសនៅ OHCHR ដែលអាចរកបានដោយធ្វើការស្រាវជ្រាវលើអ៊ិនធឺណែតតាមរយៈ ដំណើរការពង្រឹងស្ថាប័នសន្ធិសញ្ញា' ។

- ចំពោះ UPRប្រើប្រាស់គេហទំព័រ "UPR info"។ គ្រប់ឯកសារទាំងអស់ រួមមានរបាយការណ៍ទាំងបី (រដ្ឋUN និងដៃគូពាក់ព័ន្ធ) និងតារាងនៃអនុសាសន៍អាចរកបាននៅគេហទំព័រនេះផងដែរ។

- ជាការពិបាកក្នុងការស្វែងរកឯកសារពីUNGA UNSC និង ICJ លើបញ្ហាសិទ្ធិមនុស្ស ដោយសារឯកសារទាំងនេះត្រូវបានរៀបចំតាមលេខសម្គាល់របស់ UN ហើយមិនមានជាប្រភេទត្រឹមត្រូវនោះទេ។ ស្ថាប័ននីមួយៗមានគេហទំព័ររៀងៗខ្លួន ដែលបញ្ចូលនូវឯកសារទាំងនេះ ប៉ុន្តែសិស្សនិស្សិតត្រូវតែដឹងពីឯកសារជាក់លាក់មុននឹងចូលមើលគេហទំព័រ។

ការធ្វើបច្ចុប្បន្នភាពទៀងទាត់ស្តីពី UN មាននៅ 'សេវាកម្មអន្តរជាតិដើម្បីសិទ្ធិមនុស្ស' ដែលមានព្រឹត្តការណ៍ប្រចាំសប្តាហ៍ និងខែនៃសកម្មភាពសិទ្ធិមនុស្សទាំងអស់ដោយរួមមានកិច្ចប្រជុំក្រុមប្រឹក្សា កិច្ចប្រជុំស្ថាប័នសន្ធិសញ្ញា និងសិទ្ធិមនុស្សក្នុងប្រព័ន្ធទូលំទូលាយ។

អ្នកនិពន្ធដែលបានសរសេរពីនយោបាយនៃប្រព័ន្ធUN រួមមាន៖

- Julie Mertus
- Bertrand Ramcharan
- Philip Alston
- Thomas Weiss
- David Forsythe

6

# សិទ្ធិរបស់ជនមិនមែនជាពលរដ្ឋ៖ ជនភៀសខ្លួន និងជនគ្មានសញ្ជាតិ

ប្រជាជនមានភាពងាយរងគ្រោះជាពិសេស នៃការរំលោភបំពានសិទ្ធិមនុស្ស នៅពេលដែលពួកគេនៅក្រៅរដ្ឋនៃសញ្ជាតិ របស់ខ្លួន ឬពួកគេមិនអាចត្រូវបានទទួលស្គាល់ថា ជាពលរដ្ឋដោយរដ្ឋណាមួយដែលក្នុងករណីនេះពួកគេជាប្រជាជនគ្មានសញ្ជាតិ។

បុគ្គលដែលរស់នៅក្នុងរដ្ឋរបស់ពួកគេ ជារឿយៗទទួលបានសេវាកម្មពីរដ្ឋាភិបាល ត្រូវបានការពារដោយច្បាប់ និងជាទូទៅនិយាយភាសាតំបន់ ដែលទាំងនេះផ្តល់ជូនពួកគេនូវការពារកាន់តែល្អប្រសើរ។ យ៉ាងណាមិញ ប្រសិនបើបុគ្គលនោះ មិនត្រូវបានទទួលស្គាល់ថាជាពលរដ្ឋ (ហើយជាពិសេសប្រសិនពួកគេមិនស្របច្បាប់នៅក្នុងប្រទេសនោះ) ពួកគេនឹងមានភាពងាយរងគ្រោះពីការរំលោភបំពាន។ ភាពងាយរងគ្រោះនៃប្រជាជនទាំងនេះ បានឈានទៅដល់ការណែនាំនូវស្តង់ដារសិទ្ធិមនុស្សក្នុងការ បង្កើនការការពារដល់ពួកគេ។ ជំពូកបន្ទាប់នឹងធ្វើការពិនិត្យលើថាតើប្រជាជនដែលកំពុងរស់នៅក្រៅរដ្ឋរបស់ពួកគេ ប្រជាជនដែលធ្វើដំណើររវាងរដ្ឋនឹងរដ្ឋ និងជនគ្មានសញ្ជាតិគួរតែត្រូវបានការពារតាមរយៈការត្រួតពិនិត្យលើប្រភេទសំខាន់ៗ នៃជនមិនមែនពលរដ្ឋ៖ នៅក្នុងជំពូកនេះប្រជាជនគ្មានសញ្ជាតិ និងជនភៀសខ្លួន ចំនែកពលករទេសន្តប្រវេសន៍ និងមនុស្សដែលត្រូវបានជួញដូរនៅក្នុងជំពូកបន្ទាប់។ ទាំងនេះ មិនមែនគ្រប់ដណ្តប់លើប្រជាជនមិនមែនពលរដ្ឋទាំងអស់នោះទេ ប៉ុន្តែពួកគេជាអ្នកដែលងាយរងគ្រោះជាងគេ។

ប្រសិនបើអ្នកណាម្នាក់មិនមានឯកសារពលរដ្ឋ ហើយចំណាក់ស្រុកមិនស្របច្បាប់ ឬមិនមានឯកសារគ្រប់គ្រាន់ (មានន័យថាមិនមានឯកសារដូចជាទិដ្ឋាការ ឬលិខិតឆ្លងដែន) ពួកគេនឹងងាយរងគ្រោះដោយសារការប្រព្រឹត្តមកលើមិនសមស្រប ការរើសអើង ការកេងប្រវ័ញ្ច បទឧក្រិដ្ឋ និងការគម្រាមកំហែងដទៃទៀត។ ពួកគេងាយរងគ្រោះពីការរំលោភបំពាន ជាឧទាហរណ៍ ពលករទេសន្តប្រវេសន៍ភាគច្រើនមិនទទួលបានការប្រព្រឹត្តមកលើដូចគ្នានឹងពលករក្នុងស្រុកនោះ ពួកគេមិនទទួលបានសេវាកម្មដែលពួកគេត្រូវការ មានដូចជាសុខភាព និងការអប់រំ។ ហេតុផលគឺថាពួកគេមិនអាចត្រូវបានការពារគ្រប់គ្រាន់ដោយច្បាប់ជាតិនោះទេ ហើយនៅក្នុងករណីខ្លះ មិនអាចត្រូវបានការពារសូម្បីតែដោយស្ថានកុងស៊ុលរបស់ពួកគេ (សេវាកុងស៊ុលត្រូវបានផ្តល់ជូនដោយស្ថានទូតដើម្បីជួយពលរដ្ឋពួកគេក្នុងការប្រទេសដទៃ) ធ្វើឲ្យពួកគេមិនមានទម្រង់ណាមួយនៃការការពារនោះទេ ប្រសិនបើពួកគេមិនមានលទ្ធភាពក្នុងការទទួលបានសិទ្ធិមនុស្សរបស់ពួកគេនោះ។ នៅក្នុងករណីខ្លះទៀត សិទ្ធិមនុស្សរបស់ពួកគេជាការការពារផ្លូវច្បាប់តែមួយគត់ដែលពួកគេអាចទទួលបាន ទោះបីជាមានការប្រឈមខ្លាំងក្នុងការទទួលស្គាល់សិទ្ធិមនុស្សរបស់ប្រជាជនមិនមែនជាពលរដ្ឋទាំងនេះក៏ដោយ។

ពិតជាមានស្តង់ដារ យន្តការ និងស្ថាប័នអន្តរជាតិដែលធ្វើការជាពិសេសក្នុងការការពារសិទ្ធិប្រជាជនមិនមែនជាពលរដ្ឋទាំងនេះ។ គ្រប់ប្រជាជនមិនមែនជាពលរដ្ឋទាំងអស់នៅតែអាចទទួលបានសិទ្ធិរបស់ខ្លួន ដោយសារថាពួកគេជាមនុស្ស ប៉ុន្តែប្រទេសភាគច្រើននៅអាស៊ីអាគ្នេយ៍ព្យាយាមក្នុងការមិនអើពើ ឬយ៉ាងហោចណាស់លាក់បាំង ការរំលោភបំពាន ការគម្រាមកំហែងដែលប្រឈមដោយជនទេសន្តប្រវេសន៍ជនភៀសខ្លួន

និងពលករទេសន្តប្រវេសន៍។ ជាការឆ្លើយតបនឹងភាពងាយរងគ្រោះទាំងនេះ ពលករទេសន្តប្រវេសន៍ ជនភៀសខ្លួន និងអ្នកសុំជ្រកកោន បុគ្គលជាមនុស្សដែលត្រូវបានជួញដូរ និងគ្មានសញ្ជាតិ មានសិទ្ធិពិសេសក្នុងការទទួលបានការការពារដល់ពួកគេ ដោយសារសហគមន៍អន្តរជាតិទទួលស្គាល់តម្រូវការការពាររបស់ពួកគេ។

# ការពិភាក្សា និងការជជែកវែកញែក

## វិធីសាស្ត្រក្នុងការការពារប្រជាជនមិនមែនជាពលរដ្ឋពីការរើសអើង និងការកេងប្រវ័ញ្ច

ការរើសអើង និងការកេងប្រវ័ញ្ចលើប្រជាជនមិនមែនជាពលរដ្ឋអាចមានទម្រង់ផ្សេងៗគ្នា។ ជាឧទាហរណ៍ វាអាចមានទម្រង់ជាការប្រមាថផ្ទាល់មាត់ ការគម្រាមកំហែង និងការរំលោភបំពានរាងកាយ ឬទម្រង់ដែលមិនច្បាស់លាស់នៃការរើសអើងដូចជាការប្រព្រឹត្តមកលើមិនស្មើភាព ឬបង្កើនការពិបាកក្នុងការទទួលបានសេវា។ អ្នកអាចអង្កេតឃើញការកេងប្រវ័ញ្ចលើប្រជាជនដែលមិនមែនជាពលរដ្ឋ ដោយខ្លួនអ្នកទាំងអស់គ្នាផ្ទាល់ ទោះបីជាវាកើតមានឡើងក្នុងបន្ទប់បិទជិតក្នុងរោងចក្រ លើទូលចំការដាច់ពីគេ ឬក្នុងចង្ក្រាននៃភោជនីយដ្ឋានក្នុងស្រុក។ អ្នកទាំងអស់គ្នាអាចអង្កេតឃើញពលករនៅទីតាំងការដ្ឋាន ហើយសង្ស័យថាពួកគេទទួលបានប្រាក់ឈ្នួលគ្រប់គ្រាន់ឬក៏អត់ ថាតើពួកគេមានកន្លែងគេងប្រកបដោយសុវត្ថិភាពឬក៏អត់ ឬប្រសិនបើពួកគេអាចចាកចេញពីទីតាំងការដ្ឋានឬក៏អត់។

យ៉ាងណាមិញ ពលរដ្ឋមិនអាចត្រូវបានកេងប្រវ័ញ្ចដូចប្រជាជនដែលមិនមែនជាពលរដ្ឋនោះទេ ដូចនេះមិនច្បាស់នោះទេថាតើប្រជាជនមិនមែនជាពលរដ្ឋត្រូវបានបំបែកចេញឬក៏អត់នោះទេ។ អ្នកប្រហែលជាមិនអាចដឹងថាបុគ្គលមួយរូបជាពលរដ្ឋ ឬមិនមែនជាពលរដ្ឋនោះទេ ដរាបណាអ្នកបានឃើញពីអត្តសញ្ញាណប័ណ្ណរបស់ពួកគេ។ ដូចនេះ ការរើសអើង និងការកេងប្រវ័ញ្ចលើប្រជាជនមិនមែនជាពលរដ្ឋជារឿយៗត្រូវបានលាក់បាំងក្នុងទិដ្ឋភាពធម្មតា។

*តើយើងអាចធ្វើអ្វីបានខ្លះដើម្បីផ្តល់ការការពារ ការគោរពកាន់តែប្រសើរឡើងលើសិទ្ធិរបស់ប្រជាជនមិនមែនជាពលរដ្ឋ? តើព័ត៌មានអ្វីដែលប្រជាជនគួរតែដឹង ដូចនេះពួកគេបញ្ឈប់ការរើសអើងលើពលករទេសន្តប្រវេសន៍?*

# ៦.១ ទេសន្តប្រវេសន៍នៅអាស៊ីអាគ្នេយ៍

## ៦.១.១ ពាក្យពេចន៍

មុនពេលពិនិត្យមើលលើបរិបទសិទ្ធិមនុស្ស ជាដំបូងជាការសំខាន់ក្នុងការក្រលេកមើលលើទស្សនៈ និងពាក្យពេចន៍សំខាន់នៃទេសន្តប្រវេសន៍។ ទាំងនេះប្រហែលជាមានការភ័ន្តច្រឡំ និងជាបញ្ហា ប៉ុន្តែជារឿយៗតែងតែមានហេតុផលមួយថាហេតុអ្វីបានជាពាក្យពេចន៍ទាំងនេះត្រូវបានយកមកប្រើប្រាស់។ សៀវភៅពុម្ពនេះប្រើប្រាស់ពាក្យ ‘មិនមែនជាពលរដ្ឋ’ ដើម្បីសំដៅលើប្រជាជនដែលនៅក្នុងរដ្ឋមួយដែលពួកគេមិនមែនជាពលរដ្ឋ។ នេះរួមមានប្រជាជនដែលជាជនភៀសខ្លួន អ្នកសុំការជ្រកកោន (ដែលការញែកដាច់ពីគ្នានឹងត្រូវបានបញ្ជាក់ខាងក្រោម) ជនអន្តោប្រវេសន៍ ពលករទេសន្តប្រវេសន៍ អ្នកទេសចរ អ្នកការទូត ជនបរទេស ជនគ្មានសញ្ជាតិ និងមនុស្សដែលត្រូវបានជួញដូរ (ទោះបីជាមនុស្សដែលត្រូវបានជួញដូរ អាចជាពលរដ្ឋនៃរដ្ឋដែលពួកគេត្រូវបានជួញដូរក៏ដោយ ទោះបីជានេះប្រហែលជាមិនអាចកើតមានឡើងក៏ដោយ)។ ពាក្យ ‘មិនមែនជាពលរដ្ឋ’ ត្រូវបានប្រើប្រាស់ដោយសារតែវាទូលំទូលាយជាង និងគ្រប់ដណ្តប់ពាក្យទាំងអស់ខាងលើ ហើយវាជាឋានៈដែលមិនមែនជាពលរដ្ឋ ដែលឈានដល់ភាពងាយរងគ្រោះ និងការគម្រាមកំហែងដល់សន្តិសុខរបស់បុគ្គល។

ពាក្យថាទេសន្តប្រវេសន៍ (គឺជាដំណើរការនៃការផ្លាស់ទីពីប្រទេសមួយទៅប្រទេសដទៃទៀត) អាចដោយមិនទៀងទាត់ ទៀងទាត់ ដោយចាប់បង្ខំ ឬដោយស្ម័គ្រចិត្ត។ ទៀងទាត់បង្កប់ន័យថាបានដល់ប្រទេសមួយតាមមធ្យោបាយទៀងទាត់ ដែលត្រូវបានរៀបចំដោយរដ្ឋ ហើយមានភាពស្របច្បាប់ត្រឹមត្រូវ ដូចជាតាមរយៈអាកាសយានដ្ឋាន ហើយមានទិដ្ឋាការ និងលិខិតឆ្លងដែន។ ការមកដល់មិនទៀងទាត់អនុវត្តចំពោះបុគ្គលដែលរំលងច្រកត្រឹមត្រូវ ហើយដូចនេះមិនមានឯកសារចាំបាច់នោះទេ ដូចជាត្រាមកដល់លើលិខិតឆ្លងដែនរបស់ពួកគេ ឬមិនមានទិដ្ឋាការនោះទេ ឬពួកគេមិនបានឆ្លងកាត់កន្លែងត្រួតពិនិត្យអន្តោប្រវេសន៍នៅពេលមកដល់។ ទេសន្តប្រវេសន៍ដោយបង្ខំកើតមានឡើងនៅពេលដែលអ្នកណាម្នាក់ ត្រូវបានបង្ខំឲ្យចាកចេញពីប្រទេសពួកគេដោយសារត្រូវបានបង្ខំឲ្យចេញដោយសារជម្លោះ ឬការគម្រាមកំហែងនៃអំពើហិង្សា ដែលជាទូទៅជាករណីនៃជនភៀសខ្លួន។

ជនទេសន្តប្រវេសន៍ត្រូវបានប្រើប្រាស់ពាក្យថាទៀងទាត់ ឬមិនទៀងទាត់ មានឯកសារ ឬមិនមានឯកសារ និងស្របច្បាប់ ឬមិនស្របច្បាប់។ ពាក្យពេចន៍ទាំងនេះបង្កប់នូវន័យដូចគ្នា៖ ថាតើបុគ្គលមានឯកសារត្រឹមត្រូវដើម្បីមានវត្តមានក្នុងប្រទេសមួយឬក៏អត់។

ប្រសិនបើជនទេសន្តប្រវេសន៍មានឯកសារទាំងនេះដូចជាលិខិតឆ្លងដែន និងទិដ្ឋាការ ពួកគេត្រូវបានចាត់ទុកថាទៀងទាត់ មានឯកសារ ឬស្របច្បាប់នៅក្នុងប្រទេសមួយ។ មានកត្តានយោបាយយ៉ាងសំខាន់ពីខាងក្រោយពាក្យពេចន៍ទាំងនេះ ដោយសារពួកគេធ្វើការបែងចែកប្រភេទផ្សេងគ្នានៃប្រជាជនមិនមែនជាពលរដ្ឋ។ អ្នកដែលមិនមានឯកសារត្រឹមត្រូវបានចាត់ទុកថាដូចបានប្រព្រឹត្តបទល្មើសដែរ ហើយនឹងត្រូវបានចាត់ទុកថាជាជនទេសន្តប្រវេសន៍មិនស្របច្បាប់។ គ្រប់រដ្ឋនៅក្នុងអាស៊ីអាគ្នេយ៍ទាំងអស់ប្រើប្រាស់ពាក្យ ′ជនទេសន្តប្រវេសន៍មិនស្របច្បាប់′ ដើម្បីដាក់ឈ្មោះឲ្យប្រជាជនទាំងនេះក្នុងប្រទេសរបស់ពួកគេ ដែលជាអ្នកដែលមិនមានឯកសារត្រឹមត្រូវ។ ហៅអ្នកណាម្នាក់ថា ′មិនស្របច្បាប់′ មានន័យថាពួកគេពាក់ព័ន្ធនឹងសកម្មភាពឧក្រិដ្ឋណាមួយ ហើយដូចនេះពួកគេអាចត្រូវបានចាប់ខ្លួន។ ប៉ុន្តែតើក្មេងអាយុមួយឆ្នាំដែលជាកូនរបស់ពលករទេសន្តប្រវេសន៍ដែលមិនមានឯកសារ អាចត្រូវបានចាត់ទុកថាជាឧក្រិដ្ឋជនដែរមែនទេ? ពាក្យពេចន៍ដែលត្រូវបានប្រើប្រាស់នៅក្នុងស្ថានភាពនេះគឺ ″មិនមានឯកសារ″ ដោយសារតែយកចេញនូវការសន្មតថាជាបទឧក្រិដ្ឋ។ លើសពីនេះទៀត ស្ថានភាពគតិយុត្តិអាចមានភាពមិនច្បាស់លាស់។ ជាឧទាហរណ៍ ប្រសិនបើអ្នកណាម្នាក់ស្នាក់នៅហួសពេលវេលាកំណត់នៃទិដ្ឋាការរបស់ខ្លួនដោយចៃដន្យ តើពួកគេក្លាយជាឧក្រិដ្ឋជនដោយស្វ័យប្រវត្តិដែរមែនទេ? យ៉ាងណាមិញ រដ្ឋបានប្រើប្រាស់ការញែកដាច់ពីគ្នារវាងពលករទេសន្តប្រវេសន៍មិនស្របច្បាប់ និងស្របច្បាប់ដើម្បីមានការគ្រប់គ្រងកាន់តែប្រសើរឡើងលើប្រជាជនមិនមែនជាពលរដ្ឋ៖ ក្នុងន័យម្យ៉ាងទៀត ចាត់ទុកប្រជាជនដែលមិនមានឯកសារថាមិនស្របច្បាប់ ផ្តល់លេសដល់រដ្ឋក្នុងការចាប់ខ្លួន និងបណ្តេញបុគ្គលណាមួយដែលមិនអាចធ្វើឯកសារត្រឹមត្រូវចេញពីប្រទេសខ្លួន។

កង្វល់ចម្បង គឺថាតាមរយៈការរិតត្បិតផ្នែកច្បាប់លើឱកាសរបស់ប្រជាជនក្នុងការចូលទៅកាន់ប្រទេសមួយដោយស្របច្បាប់ នឹងជម្រុញឲ្យប្រជាជនបង្ខំចិត្តចូលទៅកាន់ប្រទេសនេះដោយមិនស្របច្បាប់។ និន្នាការក្នុងការចាប់យកនូវគោលនយោបាយទេសន្តប្រវេសន៍ដែលតឹងរឹងនៅក្នុងតំបន់ មិនមានលទ្ធផលល្អប្រសើរក្នុងការមានជនទេសន្តប្រវេសន៍តិច និងចំនួនជនទេសន្តប្រវេសន៍ដែលមានឯកសារច្រើននោះទេ ប៉ុន្តែផ្ទុយទៅវិញអាចផ្លាស់ប្តូរពីជនទេសន្តប្រវេសន៍មានឯកសារ ទៅជាអត់មានឯកសារ។ ផលប៉ះពាល់ដទៃទៀតក្នុងការដាក់កម្រិតតឹងរឹងលើទេសន្តប្រវេសន៍ គឺនាំឲ្យមានកំណើនអង្គការ ដែលពាក់ព័ន្ធនឹងការរត់ពន្ធមនុស្សក្រៅផ្លូវការសម្រាប់កម្លាំងពលកម្ម។ ការរត់ពន្ធ ឯកសារក្លែងក្លាយ និងការសូកប៉ាន់មន្ត្រីរាជការ ជាមធ្យោបាយដែលបានប្រើប្រាស់ដើម្បីឆ្លងកាត់ព្រំដែនដោយមិនស្របច្បាប់។ តាមរយៈការចូលដោយមិនស្របច្បាប់ ឬមិនទៀងទាត់ក្នុងប្រទេសមួយនឹងបង្កើន ផងដែរនូវភាពងាយរងគ្រោះរបស់ប្រជាជនពីការរំលោភបំពានសិទ្ធិមនុស្ស។ អត្រាខ្ពស់នៃទេសន្តប្រវេសន៍មិនទៀងទាត់ក្នុងតំបន់មានបណ្តាញឧក្រិដ្ឋធ្ងន់ធ្ងរ។ ទេសន្តប្រវេសន៍មិនទៀងទាត់ពាក់ព័ន្ធនឹងប្រព័ន្ធអត្តសញ្ញាណកម្ម និងឯកសារដែលមិនសុក្រិត និងមានការកើនឡើងនូវ

សហគ្រាសឧក្រិដ្ឋកម្ម ជាលទ្ធផលធ្វើឲ្យមានអសន្តិសុខ។ ចំពោះបុគ្គលដែលធ្វើទេសន្តប្រវេសន៍ក្នុងមធ្យោបាយមិនទៀងទាត់ មានភាពងាយរងគ្រោះពីការរំលោភបំពានសិទ្ធិមនុស្ស ការកេងប្រវ័ញ្ច និងការជួញដូរ។

## ទស្សនៈទាន

### ការហៅបុគ្គលណាម្នាក់ថាមិនស្របច្បាប់

អ្នកការពារសិទ្ធិមនុស្សចូលចិត្តប្រើពាក្យថា ‘មិនទៀងទាត់’ ឬ ‘មិនមានឯកសារ’ ជាជាង ‘មិនស្របច្បាប់’ ។ ការហៅបុគ្គលណាម្នាក់ថាមិនស្របច្បាប់បង្កប់ន័យអវិជ្ជមាន។ វាបង្កប់ន័យថាពួកគេអាក្រក់ ឬជាបិសាច។ យ៉ាងណាមិញ ស្ថានភាពនៃការមិនមានឯកសារ កើតមានជាទូទៅដោយសាររដ្ឋាភិបាលជារឿយៗធ្វើឲ្យឯកសារស្របច្បាប់ពិបាកខ្លាំង ឬថ្លៃក្នុងការធ្វើ បង្ខំឲ្យជនទេសន្តប្រវេសន៍ទទួលយកឋានៈមិនមានឯកសារ។ នៅពេលដែលនិយាយពីទេសន្តប្រវេសន៍ ប្រជាជនមួយចំនួនតូចបំពានច្បាប់ដោយសារតែពួកគេចង់បំពាន ជាជាងគោរពតាមច្បាប់ដោយសារតែខ្វះមធ្យោបាយក្នុងការ (ដូចជាឯកសារ ឬលុយ) អនុលោមតាមច្បាប់។

## ៦.១.២ បរិបទប្រវត្តិសាស្ត្រ និងសេដ្ឋកិច្ចនៃទេសន្តប្រវេសន៍នៅអាស៊ីអាគ្នេយ៍

តាមរយៈទេសន្តប្រវេសន៍ ប្រជាជនអាចគេចចេញពីការធ្វើទុក្ខបុកម្នេញ។ ពលករដែលបានធ្វើទេសន្តប្រវេសន៍រាប់លាននាក់បានធ្វើឲ្យស្តង់ដារជីវភាពរបស់ពួកគេ និងក្រុមគ្រួសាររបស់ពួកគេប្រសើរឡើង។ ប្រជាជនធ្វើទេសន្តប្រវេសន៍ទៀងទាត់ដើម្បីការអប់រំ ហើយជនទេសន្តប្រវេសន៍បានធ្វើដំណើរ ដើម្បីបង្កើតសហគមន៍ថ្មីក្នុងប្រទេសដែលនៅឆ្ងាយ។ ជាការពិត មានប្រវត្តិសាស្ត្រយូរអង្វែងនៃទេសន្តប្រវេសន៍នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ចូលក្នុងតំបន់នេះពីខាងក្រៅតំបន់។ ជាឧទាហរណ៍ ប្រជាជនមកពីឥណ្ឌា និងចិនបានធ្វើទេសន្តប្រវេសន៍ទៅកាន់ ប្រទេសក្នុងអាស៊ីអាគ្នេយ៍អស់រយៈពេលជាច្រើនសតវត្សមកហើយ។ ទេសន្តប្រវេសន៍ជាបទដ្ឋាន មិនមែនជាការលើកលែងលើមធ្យោបាយដែលប្រជាជនរស់នៅក្នុងតំបន់នោះទេ។

ព្រំដែនដែលងាយឆ្លងកាត់ ជម្លោះប្រដាប់អាវុធ កំណើនសេដ្ឋកិច្ចដែលមានភាពចម្រុះ ហេដ្ឋារចនាសម្ព័ន្ធច្បាប់ដែលមិនមានសង្គតភាព គំរូទេសន្តប្រវេសន៍តាមប្រវត្តិសាស្ត្រយូរអង្វែង អន្តរកាលប្រជាសាស្ត្រ និងច្រកទេសន្តប្រវេសន៍ផ្លូវការដែលមានកម្រិត បានរួមផ្សំធ្វើឲ្យមានទេសន្តប្រវេសន៍មិនមានឯកសារច្រើន និងទំនាក់ទំនងមិនល្អរវាងរដ្ឋាភិបាល និងជនទេសន្តប្រវេសន៍នៅអាស៊ីអាគ្នេយ៍។ ការផ្លាស់ប្តូរទីកន្លែងរបស់ប្រជាជនមានភាពចម្រុះ ដូចនេះធ្វើឲ្យមានលំហូរស្មុគ្រស្មាញរវាងប្រទេស។ ទេសន្តប្រវេសន៍ភាគច្រើនក្នុងទសវត្សឆ្នាំ ១៩៧០ និង ឆ្នាំ១៩៨០ បានកើតឡើងជាលទ្ធផលនៃជម្លោះទ្រង់ទ្រាយធំ ដូចជាសង្គ្រាមអាមេរិក នៅប្រទេសវៀតណាម (ដែលកើតមានឡើងនៅព្រំដែនឡាវ និងកម្ពុជាផងដែរ) និងជម្លោះដែលនៅតែមានក្នុងប្រទេសមីយ៉ាន់ម៉ា។ ដូចគ្នានេះផងដែរ "អភូតហេតុអាស៊ី" ក្នុងទសវត្សឆ្នាំ ១៩៨០ នៅពេលដែលវិស័យកម្មសាល និងធនាគារក្នុងតំបន់មានការរីកចំរើនខ្លាំងក្លា ធ្វើឲ្យមានទេសន្តប្រវេសន៍ទ្រង់ទ្រាយធំក្នុងការស្វែងរកការងារផងដែរ។

តម្រូវការយ៉ាងច្រើនលើកម្លាំងពលកម្ម ពីប្រទេសកំពុងអភិវឌ្ឍន៍ដូចជាប្រទេសថៃ ម៉ាឡេស៊ី និងសឹង្ហបូរី ជម្រុញឲ្យស្ត្រី បុរស និងសូម្បីតែគ្រួសារទាំងមូលធ្វើទេសន្តប្រវេសន៍។ សេដ្ឋកិច្ចក្នុងតំបន់រួមចំនែកក្នុងទេសន្តប្រវេសន៍ទ្រង់ទ្រាយធំតាមមធ្យោបាយពីរយ៉ាង។ ដំបូង មានប្រជាជាតិដែលក្រ ហើយជាប់ព្រំដែនជាមួយនឹងប្រទេសដែលមាន (ជាឧទាហរណ៍ មីយ៉ាន់ម៉ា និងថៃ) ដែលពលករជាច្រើននឹងធ្វើដំណើរទៅកាន់ប្រទេសនោះដើម្បីឆ្លើយតបនឹងតម្រូវការរកពលករ។ ទីពីរ អំឡុងពេលនៃការអភិវឌ្ឍសេដ្ឋកិច្ចឆាប់រហ័សជារឿយៗ ទាមទារប្រជាជនដែលមានវ័យបម្រើការងារច្រើន ដែលនេះមិនអាចត្រូវបានឆ្លើយតប ដោយកំណើនប្រជាជនលក្ខណៈធម្មជាតិតែមួយគត់បាននោះទេ។ ការសិក្សាកាលពីពេលថ្មីៗនេះ ដោយអង្គការដូចជា ILO និង IOM បញ្ជាក់ថាទេសន្តប្រវេសន៍ជាលទ្ធផលនៃកំណើនឆាប់រហ័សនៃតម្រូវការរកពលករទេសន្តប្រវេសន៍ដែលមានជំនាញ និងជំនាញទាប សមាមាត្រាភាគច្រើននៃស្ត្រីចូលក្នុងកម្លាំងពលកម្មទេសន្តប្រវេសន៍ និងឧស្សាហកម្មជ្រើសរើសដែលមានលក្ខណៈពាណិជ្ជកម្ម។

ពលករទេសន្តប្រវេសន៍ធ្វើចំណាកស្រុកតាមច្រកជាច្រើន។ ពលករដែលធ្វើទេសន្តប្រវេសន៍ចេញពីតំបន់ គឺមកពីឥណ្ឌូនេស៊ី ហ្វីលីពីន ថៃ ទៅកាន់មជ្ឈឹមបូព៌ា និងអាស៊ីខាងកើត។ ពាក់ព័ន្ធនឹងការងារជាក់ស្តែង បុរសភាគច្រើនធ្វើការក្នុងវិស័យសំណង់ ខណៈពេលដែលស្ត្រីបម្រើការងារក្នុងកិច្ចការផ្ទះ និងរោងចក្រ។ ពលករទេសន្តប្រវេសន៍ភាគច្រើនដែលចាកចេញពីតំបន់ជាពលករមានឯកសារ។ នៅក្នុងតំបន់ ពលករទេសន្តប្រវេសន៍មានឯកសារ និងមិនមានឯកសារភាគច្រើនគឺទៅកាន់ប្រទេសជិតខាងជាប់ព្រំដែន។ លំហូរធំបំផុតគឺពីប្រទេសហ្វីលីពីន ឥណ្ឌូនេស៊ី ភូមាទៅកាន់ប្រទេសដែលមានការអភិវឌ្ឍជាងដូចជាសឹង្ហបូរី ថៃ និងម៉ាឡេស៊ី។ មានចំនួនតិចជាងនេះ ប៉ុន្តែក៏

ជាចំនួនច្រើនផងដែរ គឺពីប្រទេសឡាវ និងកម្ពុជាទៅកាន់ប្រទេសទាំងបីខាងលើ។ យ៉ាងណាមិញ បញ្ហាមួយដែលត្រូវបានជួបប្រទះជារឿយៗនៅពេលដែលធ្វើការសិក្សាពីទេសន្តប្រវេសន៍ គឺថាទិន្នន័យពិតជាពិបាកក្នុងការប្រមូលដោយសារតែមានចំនួនពលករដែលមិនមានឯកសារច្រើនពេក។ ភាពស្មុគ្រស្មាញបន្ថែមទៀតក្នុងការស្វែងយល់ពីទេសន្តប្រវេសន៍ គឺថាមាគ៌ាមានលក្ខណៈច្រលូកច្រលំគ្នា ជាមួយនឹងពលករជនភៀសខ្លួន មនុស្សដែលត្រូវបានជួញដូរ និងសូម្បីតែអ្នកទេសចរ ដែលអ្នកទាំងអស់នេះជាផ្នែកមួយនៃលំហូរនេះ ហើយជារឿយៗត្រូវបានចម្រុះចូលគ្នា។ ការញែកដាច់ពីគ្នារវាងទេសន្តប្រវេសន៍ដោយបង្ខំ និងមិនបង្ខំជាការពិបាក៖ ច្បាប់សន្មតថាអ្នកដែលចាកចេញពីប្រទេសរបស់ខ្លួន ដោយផ្ទាល់ដោយសារហេតុផលនយោបាយគឺជាជនទេសន្តប្រវេសន៍ដោយបង្ខំ ខណៈពេលដែលអ្នកដទៃដែលផ្លាស់ប្តូរទីកន្លែង ដោយសារជម្លោះ ជាប្រយោលធ្វើឲ្យពួកគេក្រីក្រ (ជាឧទាហរណ៍ ប្រសិនបើទាហានបានរឹបអូសទិន្នផលស្បៀងអាហាររបស់ពួកគេ) មិនចាំបាច់ត្រូវបានចាត់ទុកថាជាការបង្ខំនោះទេ។ ការបំលាស់ទីខ្លះកើតមានឡើងជាក់ស្តែងដើម្បីហេតុផលសេដ្ឋកិច្ច (ដូចជាពលករក្នុងស្រុកហ្វីលីពីនទៅប្រទេសសឹង្ហបូរី) ហើយការបំលាស់ទីខ្លះជាក់ស្តែងណាស់ជាការបង្ខំ (ដូចជាជនភៀសខ្លួននយោបាយពីប្រទេសមីយ៉ាន់ម៉ា)។ យ៉ាងណាមិញ ភាពចម្រុះនៃទេសន្តប្រវេសន៍កាន់តែមានភាពស្មុគ្រស្មាញនៅមូលដ្ឋានជាក់ស្តែង។ ជនភៀសខ្លួនអាចក្លាយជាជនទេសន្តប្រវេសន៍សេដ្ឋកិច្ច ជនទេសន្តប្រវេសន៍សេដ្ឋកិច្ចអាចក្លាយជារងគ្រោះនៃការជួញដូរ និងជនរងគ្រោះនៃការជួញអាចសុំឋានៈជាជនភៀសខ្លួន។ល។ នៅក្នុងស្ថានភាពមួយចំនួន ជាបញ្ហាក្នុងការសន្មតថាបញ្ហាសេដ្ឋកិច្ចអាចត្រូវបានញែកដាច់ពីបញ្ហានយោបាយ ដូចដែលហេតុផលរបស់បុគ្គលក្នុងការស្វែងរកសន្តិសុខសេដ្ឋកិច្ចជារឿយៗផ្សាភ្ជាប់នឹងភាពងាយរងគ្រោះផ្នែកនយោបាយ។

អស់រយៈពេលប៉ុន្មានទសវត្ស ទេសន្តប្រវេសន៍មានដំណើរការដោយមិនមានយន្តការការពារថ្នាក់តំបន់នោះទេ។ គោលនយោបាយទេសន្តប្រវេសន៍ក្នុងតំបន់នៅមានភាពបែកខ្ញែក មិនត្រូវបានអភិវឌ្ឍត្រឹមត្រូវ និងមិនអាចអនុវត្តបាននៅឡើយ ដោយសារតែកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ក្នុងការគ្រប់គ្រងទេសន្តប្រវេសន៍មិនមានប្រសិទ្ធិភាព ឬជាជម្រើសក្នុងការឆ្លើយតបនឹងតម្រូវការវិស័យឯកជន។ កិច្ចខិតខំប្រឹងប្រែងដំបូងដូចជា សេចក្តីប្រកាសទីក្រុងបាងកកស្តីពីទេសន្តប្រវេសន៍មិនទៀងទាត់ (១៩៩៩) ដែលបានទទួលស្គាល់វត្តមាននៃទេសន្តប្រវេសន៍មិនទៀងទាត់ និងការទាមទារឲ្យរដ្ឋចាត់វិធានការលើបញ្ហានេះ មានសារៈសំខាន់ក្នុងការគូសបញ្ជាក់ពីបញ្ហាជាក់ស្តែង ប៉ុន្តែជាចុងបញ្ចប់មិនអាចអនុវត្តបាន ដូចនេះមិនអាចការពារជនទេសន្តប្រវេសន៍នោះទេ។ កាលពីពេលថ្មីៗនេះ មានការកើនឡើងនូវលិខិតូបករណ៍ទេសន្តប្រវេសន៍ថ្នាក់តំបន់ជាមួយនឹងកិច្ចព្រមព្រៀងជាផ្លូវការ ដូចជាកិច្ចព្រមព្រៀងទ្វេភាគីស្តីពីពលករទេសន្តប្រវេសន៍ដែលបានចុះហត្ថលេខារវាងប្រទេសថៃ និងកម្ពុជា ឡាវ និងមីយ៉ានម៉ាជាដើម មានក៏មានកិច្ចប្រជុំកម្រិតតំបន់ ដូចជានីតិវិធីបាលីស្តីពីការរត់ពន្ធមនុស្ស ការ

ជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនដែលពាក់ព័ន្ធ ដែលមានគោលបំណងក្នុងការបង្កើនការយល់ដឹង និងកិច្ចសហប្រតិបត្តិការក្នុងការប្រឆាំងសកម្មភាពជួញដូរ រវាងរដ្ឋ និងអង្គការអន្តរជាតិដូចជា UNHCR និង IOM។ យ៉ាងណាមិញ កំណើននៃលិខិតូបករណ៍មានឥទ្ធិពលជាមធ្យម លើការការពារប្រជាជនដែលមិនមែនជាពលរដ្ឋប៉ុណ្ណោះ។

រដ្ឋាភិបាលជារឿយៗចូលចិត្តគោលនយោបាយ ដែលព្យាយាមក្នុងការកំណត់ពីចំនួន និងប្រភេទនៃជនទេសន្តប្រវេសន៍ ប៉ុន្តែគោលនយោបាយទាំងនេះមិនអាចអនុវត្តបាននោះទេ ដោយសារទេសន្តប្រវេសន៍គឺផ្អែកខ្លាំងលើកត្តាសង្គម វប្បធម៌ និងសេដ្ឋកិច្ច។ ជាឧទាហរណ៍ ទេសន្តប្រវេសន៍នៅក្នុងតំបន់ត្រូវបានផ្លាស់ប្តូរបន្ទាប់ពីការវាយប្រហារដោយភេរវកម្មនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១។ រដ្ឋាភិបាលបានចាប់ផ្តើមគិតថាទេសន្តប្រវេសន៍ជាកង្វល់សន្តិសុខ ហើយបានប្រើប្រាស់ច្បាប់ថ្មីជុំវិញការជួញដូរ និងរត់ពន្ធក្នុងគោលបំណងកាត់បន្ថយទេសន្តប្រវេសន៍ដោយមិនទៀងទាត់។ ប្រទេសមួយចំនួនមិនអើពើលើប្រជាជនជាពលករទេសន្តប្រវេសន៍របស់ពួកគេនោះទេ។ ភាគច្រើននៃទសវត្ស ឆ្នាំ១៩៩០ និង ២០០០ មីយ៉ាន់ម៉ានបានបង្កើតគោលនយោបាយមួយសម្រាប់ពលកររបស់ខ្លួនមួយចំនួនតូចនៅមជ្ឈឹមបូព៌ា ប៉ុន្តែអស់រយៈពេលជាច្រើនទសវត្ស មិនមានគោលនយោបាយ (ឬសូម្បីការទទួលស្គាល់) ដែលគ្រប់គ្រងពលរដ្ឋមីយ៉ាន់ម៉ាប្រមាណជា២លាននាក់ដែលកំពុងធ្វើការក្នុងប្រទេសថៃ។

ភាពងាយរងគ្រោះពាក់ព័ន្ធនឹងទេសន្តប្រវេសន៍នៅអាស៊ីអាគ្នេយ៍ គឺជាការកើនឡើងនៃការរើសអើងលើជនទេសន្តប្រវេសន៍ដោយពលរដ្ឋ។ ប្រជាជនភ័យខ្លាចថាជនទេសន្តប្រវេសន៍បង្កឲ្យមានការកើនឡើងនូវឧក្រិដ្ឋកម្ម។ កម្លាំងពលកម្មក្នុងស្រុកអាចគិតថា កម្លាំងពលកម្មទេសន្តប្រវេសន៍ជាការគម្រាមកំហែងចម្បងដល់ការងារ និងប្រាក់ឈ្នួលរបស់ពួកគេ។ លើសពីនេះទៀត រដ្ឋាភិបាលអាស៊ីអាគ្នេយ៍ចាត់ទុកបញ្ហាទេសន្តប្រវេសន៍ថាជាបញ្ហាសន្តិសុខ ដោយប្រៀបធៀបនឹងបទឧក្រិដ្ឋឆ្លងដែន។ មិនគួរឲ្យភ្ញាក់ផ្អើលនោះទេ នេះបង្កើតនូវស្ថានភាពមួយដែលជនទេសន្តប្រវេសន៍ ត្រូវបានចាត់ទុកថាជាការគម្រាមកំហែងដល់សហគមន៍ក្នុងតំបន់ សុខដុមនីយកម្មសង្គម និងសន្តិសុខជាតិ។ លើសពីនេះទៀត រដ្ឋអាចផ្តោតសំខាន់តែលើផលប្រយោជន៍ពីទេសន្តប្រវេសន៍ប៉ុណ្ណោះ ជាជាងផ្តោតសំខាន់លើការការពារសិទ្ធិមនុស្ស។ ដូចនេះ នៅក្នុងករណីខ្លះ ជនទេសន្តប្រវេសន៍អាចក្លាយជាជនរងគ្រោះនៃអំពើពុករលួយ និងការកេងប្រវ័ញ្ច សូម្បីតែមុនពេលពួកគេចាកចេញពីប្រទេសខ្លួន។ បន្ទាប់មកទៀត នៅពេលទៅដល់ប្រទេសដែលខ្លួនបម្រើការងារ ពួកគេអាចប្រឈមនឹងច្បាប់ និងការអនុវត្តច្បាប់ដែលមានការរើសអើង បទឧក្រិដ្ឋដែលគួរឲ្យស្អប់ខ្ពើម ការជួញដូរ និងការរំលោភបំពានដទៃទៀត។

# ការពិភាក្សា និងការជជែកវែកញែក

## តើការភ័យខ្លាចរបស់ប្រជាជនលើជនទេសន្តប្រវេសន៍មានភាពត្រឹមត្រូវកម្រិតណា?

តើអ្វីជាវិធីសាស្ត្រទូទៅបំផុត ដែលជនទេសន្តប្រវេសន៍ត្រូវបានរិះគន់នៅក្នុងប្រទេសរបស់អ្នក? តើការរិះគន់ទាំងនេះមានភាពត្រឹមត្រូវកម្រិតណា? ខាងក្រោមនេះជាការរិះជាទូទៅមួយចំនួនដែលបានធ្វើឡើង៖

- ជនទេសន្តប្រវេសន៍នាំមកនូវឧក្រិដ្ឋកម្ម
- ប្រសិនបើយើងប្រព្រឹត្តិលើជនទេសន្តប្រវេសន៍ល្អខ្លាំងពេក ពួកគេនឹងហូរចូលមកប្រទេសយ៉ាងគំហុក និងដណ្ដើមយកប្រទេសរបស់ខ្លួន
- ជនទេសន្តប្រវេសន៍ដណ្ដើមការងាររបស់ពួកគេ
- ពលករនាំមកនូវជម្ងឺ
- ជនទេសន្តប្រវេសន៍ប្រើប្រាស់សេវាកម្មសង្គមសង្គមរបស់យើងទាំងអស់ ដូចជាសេវាសុខភាពជាដើម
- ជនទេសន្តប្រវេសន៍មិនគោរពវប្បធម៌របស់ពួកយើងនោះទេ

តើអ្នកគួរតែឆ្លើយតបនឹងការអះអាងទាំងនេះយ៉ាងដូចម្ដេច? ខណៈពេលដែលមិនមានការស្រាវជ្រាវច្រើនលើបញ្ហាទាំងនេះ ការអះអាងទាំងនេះមិនត្រឹមត្រូវនោះទេ។ ជាឧទាហរណ៍ ជនទេសន្តប្រវេសន៍មានអត្រាសកម្មភាពឧក្រិដ្ឋទាបជាង។ ជនទេសន្តប្រវេសន៍រួមចំនែកយ៉ាងច្រើនដល់សេដ្ឋកិច្ច តាមរយៈការងាររបស់ពួកគេជាងអ្វីដែលពួកគេទទួលបានពីសេវាកម្មសង្គម។ ពលករទេសន្តប្រវេសន៍មិនដែលហូរចូលយ៉ាងគំហុកក្នុងប្រទេសមួយ ហើយដណ្ដើមយកប្រទេសនោះទេ យ៉ាងច្រើនណាស់ពួកគេក្លាយទៅជាជនជាតិភាគតិច បន្ទាប់ពីរស់នៅជាច្រើនជំនាន់នៅក្នុងប្រទេសនោះ។ លើសពីនេះទៀត ប្រវត្តិគ្រួសារភាគច្រើន (រួមមានទាំងសិស្សនិស្សិតភាគច្រើនដែលកំពុងអានសៀវភៅពុម្ពនេះផងដែរ) ជាផលិតផលនៃទេសន្តប្រវេសន៍។

*ឧបមាថាអ្នកជួបអ្នកណាម្នាក់តាមផ្លូវដែលបានបង្ហាញនូវទស្សនៈខាងលើ តើអ្វីជាវិធីសាស្ត្រល្អបំផុតក្នុងការឆ្លើយតបនឹងការភ័យខ្លាចរបស់ពួកគេលើទេសន្តប្រវេសន៍? តើអ្នកអាចបញ្ចុះបញ្ចូលអ្នកណាម្នាក់ថាទេសន្តប្រវេសន៍ល្អ ជាជាងអាក្រក់ចំពោះប្រទេសមួយយ៉ាងដូចម្ដេច?*

## ៦.២ ប្រភេទសិទ្ធិទាំងបួនរបស់ប្រជាជនមិនមែនជាពលរដ្ឋ ៖ទិដ្ឋភាពទូទៅ

មានសិទ្ធិចំនួនបួនប្រភេទរបស់ប្រជាជនមិនមែនជាពលរដ្ឋ ដែលសៀវភៅពុម្ពនេះនឹងពិភាក្សា៖ សិទ្ធិទាំងនេះមាន៖ (១) ជនភៀសខ្លួន (២) អ្នកគ្មានសញ្ជាតិ (៣) ពលករទេសន្តប្រវេសន៍ និង(៤) មនុស្សដែលត្រូវបានជួញដូរ។ ប្រភេទនីមួយៗមានឋានៈច្បាស់លាស់ មានចង្កោមនៃសិទ្ធិជាក់លាក់ និងកង្វល់ពាក់ព័ន្ធនឹងការការពារ។ ប្រភេទនីមួយៗអាចត្រូវបានស្វែងយល់តាមរយៈការពិនិត្យជាដំបូងលើច្បាប់អន្តរជាតិ និងសន្ធិសញ្ញាដែលពាក់ព័ន្ធនឹងការការពារប្រជាជនដែលមានឋានៈនេះ ហើយបន្ទាប់មកនឹងក្រលេកមើលលើការប្រឈមក្នុងការការពារដល់ពួកគេ។ មុនពេលធ្វើការបញ្ជាក់លម្អិត ជាការសំខាន់ក្នុងការផ្តល់នូវទិដ្ឋភាពទូទៅមួយនៃសន្ធិសញ្ញាដែលពាក់ព័ន្ធ និងនិយមន័យនៃប្រភេទទាំងបួននៃប្រជាជនដែលមិនមែនជាពលរដ្ឋ។

### ជនភៀសខ្លួន

ឋានៈជនភៀសខ្លួនត្រូវបានកំណត់ដោយអនុសញ្ញាអង្គការសហប្រជាជាតិឆ្នាំ ១៩៥១ ពាក់ព័ន្ធនឹងឋានៈនៃជនភៀសខ្លួន (កែសម្រួលដោយពិធីសារឆ្នាំ ១៩៦៧ ពាក់ព័ន្ធនឹងឋានៈជនភៀសខ្លួន)។ ជនភៀសខ្លួនជាបុគ្គលដែល៖

> ដោយសារតែភាពភ័យខ្លាច ដែលមានក្នុងខ្លួនពីការធ្វើទុក្ខបុកម្នេញដោយសារហេតុផលពូជសាសន៍ សាសនា សញ្ជាតិ សមាជិកនៃក្រុមការងារសង្គម ឬគំនិតនយោបាយជាក់លាក់ ស្នាក់នៅខាងក្រៅប្រទេសជាតិរបស់ខ្លួន ហើយមិនអាច ឬដោយសារតែភាពភ័យខ្លាចនេះ មិនមានឆន្ទៈក្នុងការប្រថុយខ្លួនក្នុងការទទួលការការពារពីប្រទេសនោះ។

ដូចដែលនិយមន័យបានបង្ហាញ ឋានៈជនភៀសខ្លួនអនុវត្តលើប្រជាជនដែលត្រូវបានធ្វើទុក្ខបុកម្នេញក្នុងប្រទេសកំណើតរបស់ខ្លួន ហើយមិនអាចត្រឡប់មកវិញ។ សិទ្ធិទាំងនេះធានាថាបុគ្គលនោះអាចរស់នៅដោយសុវត្ថិភាព និងមនុស្សធម៌ខាងក្រៅប្រទេសរបស់ខ្លួន រហូតដល់ពួកគេមានបំណងក្នុងការត្រលប់មកផ្ទះវិញ។

### គ្មានសញ្ជាតិ

គ្មានសញ្ជាតិត្រូវបានកំណត់និយមន័យក្នុងអនុសញ្ញាឆ្នាំ១៩៥៤ ពាក់ព័ន្ធនឹងឋានៈជនគ្មានសញ្ជាតិថា៖

បុគ្គលមួយរូបមិនត្រូវបានចាត់ទុកថាជាសញ្ជាតិដោយរដ្ឋណាមួយក្រោមដែនកំណត់នៃច្បាប់របស់ខ្លួននោះទេ។

ទោះបីជាប្រជាជនគ្មានសញ្ជាតិភាគច្រើន រស់នៅក្នុងប្រទេសដែលពួកគេកើត ជារឿយៗ ពួកគេខ្វះនូវបុព្វសិទ្ធិ សេវាកម្ម និងការការពារដែលបានរក្សាទុកសម្រាប់ពលរដ្ឋ ឬសញ្ជាតិ ។ ច្បាប់ការពារជនគ្មានសញ្ជាតិធានាពួកគេនឹងទទួលបានការទទួលស្គាល់ និងការការពារ។

## ពលករទេសន្តប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ

ពលករទេសន្តប្រវេសន៍ត្រូវបានកំណត់និយមន័យក្នុងអនុសញ្ញាអន្តរជាតិរបស់ UN ក្នុងឆ្នាំ១៩៩០ ស្តីពីការការពារសិទ្ធិពលករទេសន្តប្រវេសន៍គ្រប់រូប និងសមាជិកក្រុមគ្រួសាររបស់ពួកគេ ដូចខាងក្រោម៖

បុគ្គលដែលនឹងចូលរួម កំពុងចូលរួម ឬធ្លាប់ចូលរួមក្នុងសកម្មភាពដែលទទួលបានកម្រៃក្នុងរដ្ឋដែលគាត់មិនមែនជាសញ្ជាតិ។

ពលករទេសន្តប្រវេសន៍រស់នៅខាងក្រៅប្រទេសកំណើតរបស់ខ្លួន ដើម្បីគោលបំណងការងារ។ ពលករទេសន្តប្រវេសន៍ជាទៀងទាត់មិនបានទទួលសិទ្ធិ និងការការពារដូចគ្នាដូចពលករជាតិនោះទេ ហើយពួកគេមានភាពងាយរងគ្រោះពីការកេងប្រវ័ញ្ចទាំងនៅកន្លែងការងារ និងក្នុងសហគមន៍ដែលពួកគេរស់នៅ ប្រសិនជាពួកគេមិនមានឯកសារត្រឹមត្រូវនោះទេ។

## មនុស្សដែលត្រូវបានជួញដូរ

ការជួញដូរមនុស្សត្រូវបានកំណត់និយមន័យដោយពិធីសារឆ្នាំ ២០០៣ ក្នុងការបង្ការ ទប់ស្កាត់ និងដាក់ទោសលើការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (ពិធីសារប៉ាលឺម៉ូ) និងសំដៅលើ៖

សកម្មភាពនៃការជ្រើសរើស ដឹកជញ្ជូន ផ្ទេរ ដាក់លើទូក ឬទទួលបុគ្គល តាមរយៈមធ្យោបាយនៃការគម្រាមកំហែង ឬប្រើប្រាស់ទម្រង់ដទៃនៃការបង្ខំ ការចាប់ពង្រត់ បោកបន្លំ បោកប្រាស់ ឬការរំលោភអំណាច ឬស្ថិតក្នុងស្ថានភាពនៃភាពរងគ្រោះ ឬដោយសារការផ្តល់ ឬទទួលប្រាក់ ឬផលប្រយោជន៍ដើម្បីទទួលបានការព្រមព្រៀង ពីបុគ្គលមួយរូបដែលមានការគ្រប់គ្រងលើបុគ្គលដទៃទៀត ដើម្បី

គោលបំណងនៃការកេងប្រវ័ញ្ច។ ការកេងប្រវ័ញ្ចរួមមាន ជាអប្បរមាន ជាការកេងប្រវ័ញ្ចពេស្យាកម្មលើអ្នកដទៃ ឬទម្រង់ណាមួយនៃការកេងប្រវ័ញ្ចផ្លូវភេទ ពលកម្ម ឬសេវាកម្មដោយបង្ខំ ទាសភាព ឬការអនុវត្តដែលស្រដៀងគ្នានឹងទាសភាព សេវភាព ឬការយកចេញនូវសរីរាង្គ។

មិនដូចទៅនឹងអនុសញ្ញាខាងលើនោះទេ ពិធីសារប៉ាលីម៉ូ កំណត់ថាជាបទឧក្រិដ្ឋជាជាងឋាន:។ មនុស្សដែលត្រូវបានជួញដូរជាជនរងគ្រោះនៃបទឧក្រិដ្ឋដែលបានរៀបរាប់ខាងលើ។ បុគ្គលដែលត្រូវបានជួញដូរមានសិទ្ធិជាក់លាក់ក្នុងការបង្ការការធ្លាក់ខ្លួនជាជនរងគ្រោះម្តងទៀត និងដើម្បីជួយដល់ពួកគេដើម្បីស្តារសម្បទាឡើងវិញ។

គួរកត់សម្គាល់ថាសន្ធិចំនួនបួនដែលបានរៀបរាប់នៅទីនេះ មានប្រភពចេញពីអំឡុងពេលប្រវត្តិសាស្ត្រខុសៗគ្នា ដែលមានន័យថាសន្ធិសញ្ញាទាំងនេះចាត់ទុកសិទ្ធិមនុស្សផ្សេងៗគ្នា ហើយដោះស្រាយបញ្ហាតាមមធ្យោបាយផ្សេងៗគ្នា។ សន្ធិជនភៀសខ្លួន និងគ្មានសញ្ជាតិ ជាសន្ធិសញ្ញាក្រោយសង្គ្រាមលោកលើកទីពីរ សន្ធិសញ្ញាទាំងពីរនេះត្រូវបានអនុម័តនៅដើមទសវត្សឆ្នាំ ១៩៥០។ ការការពារសិទ្ធិមនុស្សដោយសន្ធិសញ្ញាទាំងនេះមិនមានភាពខ្លាំងក្លានោះទេ ដោយសារក្របខណ្ឌសិទ្ធិមនុស្សអន្តរជាតិមិនទាន់មានការអភិវឌ្ឍ។ រហូតដល់ទសវត្សឆ្នាំ ១៩៦០ ទើបសន្ធិសញ្ញាសិទ្ធិមនុស្សទីមួយត្រូវបានអនុម័ត។ អនុសញ្ញាពលករទេសន្តប្រវេសន៍ ដែលត្រូវបានព្រាងក្នុងទសវត្សឆ្នាំ ១៩៨០ ហើយត្រូវបានអនុម័តក្នុងឆ្នាំ ១៩៩០ ប៉ុន្តែរហូតដល់ឆ្នាំ ២០០៣ ទើបចូលជាធរមាន សន្ធិសញ្ញានេះជាសន្ធិសញ្ញាដែលមានការពង្រីកវិសាលភាព ហើយជាសន្ធិសញ្ញាធំបំផុតក្នុងចំណោមសន្ធិសញ្ញាទាំងបួន។ សន្ធិសញ្ញានេះក៏ជាសន្ធិសញ្ញាតែមួយគត់ ដែលត្រូវបានចាត់ទុកថាជាសន្ធិសញ្ញាសិទ្ធិមនុស្សក្នុងប្រព័ន្ធ UN។ អំឡុងពេលវែងរវាងការព្រាង និងការចូលជាធរមានត្រូវបានឆ្លុះបញ្ចាំងលើអត្រានៃការផ្តល់សច្ចាប័នទាប ហើយជាសន្ធិសញ្ញាដែលមានការផ្តល់សច្ចាប័នតិចជាងគេក្នុងចំណោមសន្ធិសញ្ញាទាំងបួន។ ជាចុងក្រោយ ពិធីសារលើអនុសញ្ញាជួញដូរមានវត្តមានក្នុងទសវត្សឆ្នាំ ២០០០ ដើម្បីជាការឆ្លើយតបនឹងចលនាទេសន្តប្រវេសន៍ជាសកល និងជាការឆ្លើយតបមួយនឹងសកម្មភាពបទឧក្រិដ្ឋដែលមានការកើនឡើង។ សន្ធិសញ្ញានេះការពារសិទ្ធិរបស់បុគ្គលដែលត្រូវបានជួញដូរ ប៉ុន្តែសំខាន់ជាងនេះទៅទៀតក៏កំណត់ថាការជួញដូរជាបទឧក្រិដ្ឋអន្តរជាតិផងដែរ។ ដោយសារតែផ្តល់អំណាចដល់រដ្ឋតាមរយៈការចាត់ទុកសកម្មភាពនេះជាបទឧក្រិដ្ឋ វាទទួលបានការផ្តល់សច្ចាប័នយ៉ាងទូលំទូលាយ។

## ៦.២.១ គំលាត និងភាពជាន់គ្នានៃការការពារផ្លូវច្បាប់

ប្រភេទទាំងបួនខាងលើនៃប្រជាជនមិនមែនពលរដ្ឋ មិនគួរត្រូវបានចាត់ទុកថាដាច់ដោយឡែក និងមិនពាក់ព័ន្ធគ្នានោះទេ ប៉ុន្តែពួកគេក៏មិនដូចគ្នា និងមិនបំពេញបន្ថែមឲ្យគ្នាទៅវិញទៅមកនោះទេ។ ផ្ទុយទៅវិញ គួរតែទទួលស្គាល់ថាមនុស្សអាចផ្លាស់ប្តូររវាងប្រភេទទាំងនេះយ៉ាងឆាប់រហ័យ ឬស្ថិតនៅក្រោមប្រភេទលើសពីមួយ។ អាចនិយាយបានថា (ទោះបីជាមិនទំនងក៏ដោយ) ជនគ្មានសញ្ជាតិអាចភ្ញាក់ឡើងនៅពេលព្រឹកស្អែកហើយក្លាយជាពលករទេសន្តប្រវេសន៍ ហើយត្រូវបានបង្ខំឲ្យស្ថិតក្នុងស្ថានភាពជួញដូរ ហើយនឹងមានឋានៈជាជនភៀសខ្លួននៅពេលយប់នោះ។ លទ្ធផលគឺថាការការពារលើប្រជាជនមិនមែនពលរដ្ឋ ពោរពេញទៅដោយគំលាត ភាពជាន់គ្នា និងប្រជេះដែលធ្វើឲ្យការកំណត់អត្តសញ្ញាណ និងការការពារមានការពិបាក។ ករណីមួយក្នុងអាស៊ីអាគ្នេយ៍គឺជនជាតិ Rohingya នៃប្រទេសមីយ៉ាន់ម៉ាដែលអាចស្ថិតក្រោមប្រទេសទាំងបួន។

# ផ្តោតសំខាន់លើ

## ជនជាតិរ៉ូហ៊ីងញ៉ា Rohingya

រឿងរ៉ាវរបស់ Rohingyas ក្នុងប្រទេសមីយ៉ាន់ម៉ា បង្ហាញពីភាពងាយរងគ្រោះរបស់ប្រជាជនគ្មានសញ្ជាតិ។ Rohingyas ត្រូវបានដកហូតសញ្ជាតិ នៅពេលដែលរដ្ឋាភិបាលមីយ៉ាន់ម៉ាបានដាក់ឲ្យប្រើប្រាស់នូវបទដ្ឋានសញ្ជាតិថ្មីតាមច្បាប់សញ្ជាតិឆ្នាំ ១៩៨២។ ច្បាប់ទាំងនេះ មិនបានបញ្ចូលក្រុមនេះក្នុងក្រុមពូជសាសន៍ដែលត្រូវបានទទួលស្គាល់ជាផ្លូវការទាំង ១៣៥ នោះទេ។ ចំពោះរដ្ឋាភិបាលមីយ៉ាន់ម៉ា Rohingyas ការពិតជាជនជាតិបង់ក្លាដេស (ហើយជារឿយត្រូវបានហៅថា បង់ហ្គាលីសក្នុងឯកសារផ្លូវការ និងប្រព័ន្ធផ្សព្វផ្សាយ (ទោះបីជាកំណត់ត្រាប្រវត្តិសាស្ត្របង្ហាញពួកគេបានរស់នៅក្នុងតំបន់យ៉ាងហោចណាស់ ៣០០ឆ្នាំមកហើយ។

ច្បាប់មីយ៉ាន់ម៉ាកម្រិតយ៉ាងធ្ងន់ធ្ងរលើសិទ្ធិរបស់ Rohingyas។ ដោយសារពួកគេគ្មានសញ្ជាតិ ពួកគេមិនអាចមានលទ្ធភាពទទួលបានសេវាអប់រំ ឬសុខភាពនោះទេ។ ពួកគេត្រូវការការចុះបញ្ជី និងការអនុញ្ញាតជាពិសេសដើម្បីរៀបអាពាហ៍ពិពាហ៍ ឬដើរហើរដោយសេរីក្នុងប្រទេស។ ការរំខានលើជនស៊ីវិលកាលពីពេលថ្មីៗនេះបានធ្វើឲ្យ Rohingya ត្រូវបានសម្លាប់ក្នុងអំពើហិង្សាជាក្រុម។ ប្រសិនជាពួកគេព្យាយាមចាកចេញពីការរើសអើងជាប្រព័ន្ធ ដែលពួកគេជួបប្រទះក្នុងប្រទេសរបស់ពួកគេ ពួកគេនឹងត្រូវបានកេងប្រវ័ញ្ចក្នុងនាមជាពលករទេសន្តប្រវេសន៍ ហើយពួកគេត្រូវបានជួញដូរជាទៀងទាត់។

ដោយសារលក្ខខណ្ឌទាំងនេះ Rohingya ជាច្រើនបានចាកចេញពីប្រទេសមីយ៉ាន់ម៉ាដើម្បីស្វែងរកការងារ។ មានជនជាតិ Rohingya រាប់សែននាក់កំពុងរស់នៅជាជនភៀសខ្លួនក្នុងប្រទេសបង់ក្លាដេស។ ជនជាតិ Rohingya ជាច្រើនបានធ្វើដំណើរទៅប្រទេសថៃ និងម៉ាឡេស៊ី ដើម្បីធ្វើការជាពលករទេសន្តប្រវេសន៍មិនមានឯកសារ នៅពេលពួកគេកំពុងធ្វើដំណើរ មានករណីមួយចំនួនដែលជនជាតិនេះត្រូវបានជួញដូរ ឬលក់ជាកម្លាំងពលកម្មរវាងប្រទេសម៉ាឡេស៊ី និងថៃ។

មន្ត្រីរដ្ឋក្នុងប្រទេសមីយ៉ាន់ម៉ា និងប្រទេសជិតខាងបានប្រើប្រាស់ឋានៈមិនច្បាស់លាស់របស់ជនជាតិនេះ ជាមធ្យោបាយក្នុងការជៀសវាងការទទួលខុសត្រូវណាមួយលើពួកគេ។ មីយ៉ាន់ម៉ាអះអាងថាពួកគេជាជនជាតិបង់ក្លាដេស ហើយបង់ក្លាដេសថាពួកគេជាជនជាតិមីយ៉ាន់ម៉ា ចំនែកឯថៃ និងម៉ាឡេស៊ីគិតថាពួកគេជាពលករទេសន្តប្រវេសន៍ខុសច្បាប់។ ជនជាតិ Rohingyas ទាមទារឋានៈជាជនភៀសខ្លួនក្នុងប្រទេសដូចជាអូស្ត្រាលី ប៉ុន្តែដើម្បីទៅទីនោះដើម្បីទាមទារឋានៈជាជនភៀសខ្លួនជាផ្លូវដ៏វែងឆ្ងាយ និងគ្រោះថ្នាក់។

មានគំលាតជាច្រើនក្នុងការការពារប្រជាជនមិនមែនជាប្រជាពលរដ្ឋ។ ជារៀងរាល់ថ្ងៃ ពលករទេសន្តប្រវេសន៍ ដែលភាគច្រើនជំពាក់បំណុលលើភ្នាក់ងារ ឬនិយោជក ត្រូវបានដឹកជញ្ជូនទីតាំងការងារ ហើយទទួលបានប្រាក់កម្រៃតិច និងធ្វើការដែលពិបាក ហើយគ្រោះថ្នាក់ ថាតើពួកគេត្រូវបានកេងប្រវ័ញ្ច ឬក៏អត់ គឺផ្អែកលើបរិបទ និងទស្សនៈ។ ប្រសិនជាបុគ្គលម្នាក់ត្រូវបានចាត់ទុកថាជាទេសន្តប្រវេសន៍ដែលត្រូវបានបង្ខំ ពលករទេសន្តប្រវេសន៍ ឬជនរងគ្រោះនៃការជួញដូរគឺមិនច្បាស់នោះទេ។ លើសពីនេះទៀត ជនភៀសខ្លួនដែលទាមទារសិទ្ធិការងាររបស់ពួកគេក៏ងាយរងគ្រោះចំពោះការកេងប្រវ័ញ្ចដែលស្មើនឹងការជួញដូរផងដែរ។ ដោយផ្នែក បញ្ហាទាំងនេះបង្កដោយសារតែមិនមានវិធានច្បាស់លាស់លើវិធីសាស្រ្ត ក្នុងការកំណត់អត្តសញ្ញាណ និងចាត់ប្រភេទប្រជាជនមិនមែនជាពលរដ្ឋ ដែលត្រូវការការពារ។ រដ្ឋាភិបាលអាចនឹងកំណត់អត្តសញ្ញាណប្រជាជនដែលមិនមានឯកសារទាំងអស់ថាមិនស្របច្បាប់ ហើយគួរតែត្រូវបាននិរទេស។ រដ្ឋចាត់ទុកអ្នកណាម្នាក់ជាជនរងគ្រោះនៃការជួញដូរ ជាជាងជនភៀសខ្លួន ដោយសារតែរដ្ឋអាចធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះនៃការជួញដូរ ប៉ុន្តែមិនអាចបញ្ជូនជនភៀសខ្លួន ត្រឡប់ទៅកន្លែងដែលពួកគេអាចប្រឈមនឹងការធ្វើទុក្ខបុកម្នេញបាននោះទេ។

## ៦.៣ អនុសញ្ញាជនភៀសខ្លួន

បុគ្គលដែលស្វែងរកការការពារពីរដ្ឋរបស់ខ្លួន ដោយធ្វើការគេចខ្លួនពីប្រទេសរបស់ពួកគេ ដោយរត់គេចពីប្រទេសរបស់ខ្លួន ហើយធ្វើដំណើរទៅកន្លែងផ្សេង បានទទួលការការពាររាប់ពាន់ឆ្នាំមកហើយ ទោះបីជាការការពារទើបតែមានក្នុងច្បាប់អន្តរជាតិក៏ដោយ។ UDHR ជាឯកសារអន្តរជាតិដំបូងទទួលស្គាល់សិទ្ធិ ក្នុងការស្វែងរក និងទទួលបានការជ្រកដើម្បីគេចផុតពីការធ្វើទុក្ខបុកម្នេញ ទោះបីជាកាលពីមុន សង្គមប្រជាជាតិពិតជាបានផ្តល់ការការពារស្របច្បាប់ សម្រាប់ក្រុមខ្លះដែលធ្វើការគេចខ្លួនចេញពីការធ្វើទុក្ខបុកម្នេញក៏ដោយ (ជាឧទាហរណ៍ពីរុស្ស៊ី និងអាឡឺម៉ង់)។ ខណៈពេលដែល UDHR ជាលិខិតូបករណ៍សកលក្នុងការការពារក្នុងស្ថានភាពនេះ និងផ្អែកលើការការពារជនភៀសខ្លួនលើបុគ្គល និងមិនមែនជាក្រុមនោះទេ សេចក្តីប្រកាសចែងពីបញ្ហានេះមិនច្បាស់លាស់នោះទេ "មនុស្សនីមួយៗមានសិទ្ធិក្នុងការស្វែងរក និងទទួលបានការជ្រកកោនក្នុងប្រទេសដទៃដើម្បីគេចផុតពីការធ្វើទុក្ខបុកម្នេញ"។ សេចក្តីថ្លែងការណ៍នេះមិនបញ្ជាក់ជាក់លាក់ពីជនភៀសខ្លួននោះទេ (ផ្ទុយទៅវិញនិយាយពី "អ្នក

ដែលស្វែងរកការជ្រកកោន”) ហើយមានលក្ខណៈទន់ភ្លន់ក្នុងប្រើពាក្យពេចន៍ក្នុងការការពារ។ ជាឧទាហរណ៍ សេចក្តីប្រកាសនេះ មិនបានបញ្ជាក់ពីកាតព្វកិច្ច ឬភារកិច្ចរបស់រដ្ឋនោះទេ ផ្ទុយទៅវិញ បុគ្គលមានសិទ្ធិក្នុងការ “ស្វែងរក និងទទួលបាន” ការការពារ។ នៅពេលនោះ នៅក្នុងចុងទសវត្សឆ្នាំ ១៩៤០ ជនភៀសខ្លួនជាកង្វល់ចម្បង ដោយសារតែមានចលនាប្រជាជនដ៏ធំមួយ នៅចុងបញ្ចប់នៃសង្គ្រាមលោកលើកទីពីរ ដែលធ្វើឲ្យមានចំនួនជនភៀសខ្លួនច្រើន ជាងពេលណាៗទាំងអស់ដែលពិភពលោកធ្លាប់ជួបប្រទះ។ នេះទាមទារឲ្យមានការចាត់វិធានការ ដូចនេះក្នុងឆ្នាំ ១៩៥០ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) ត្រូវបានបង្កើតឡើង។ បន្ទាប់មកក្នុងឆ្នាំ១៩៥១ អនុសញ្ញា UN ដែលពាក់ព័ន្ធនឹងឋានៈរបស់ជនភៀសខ្លួន (ដែលជាទូទៅត្រូវបានស្គាល់ថាជាអនុសញ្ញាជនភៀសខ្លួន) ត្រូវបានអនុម័ត។ អនុសញ្ញាជនភៀសខ្លួន កំណត់និយមន័យពាក្យ “ជនភៀសខ្លួន” ហើយនិយមន័យនេះនៅតែត្រូវបានប្រើប្រាស់ជាទូទៅពេលបច្ចុប្បន្ននេះ។ និយមន័យនេះមានសារៈសំខាន់ ដោយសារ វាបានកំណត់ពីលក្ខខណ្ឌជាក់លាក់ ដែលត្រូវបំពេញមុនពេលបុគ្គលម្នាក់អាចទាមទារឋានៈជាជនភៀសខ្លួនរបស់ខ្លួន។ ដើម្បីទទួលបានការការពារ នៃសិទ្ធិជនភៀសខ្លួនពីការអនុសញ្ញា ជាការចាំបាច់សម្រាប់មនុស្សទាំងអស់ ដើម្បីស្ថិតក្នុងនិយមន័យនេះ។

## ៦.៣.១ និយមន័យនៃជនភៀសខ្លួន

ជនភៀសខ្លួន យោងទៅតាមអនុសញ្ញាជនភៀសខ្លួន គឺជាបុគ្គលដែល៖

> ការភ័យខ្លាចមានមូលដ្ឋានច្បាស់លាស់ ចំពោះការធ្វើទុក្ខបុកម្នេញ ដោយហេតុផលពូជសាសន៍ សាសនា សញ្ជាតិ សមាជិកភាពនៃក្រុមសង្គមណាមួយ ឬដោយសារមតិនយោបាយនៅក្រៅប្រទេសដែលខ្លួនមានសញ្ជាតិ និងមិនអាច ឬដោយសារការភ័យខ្លាចនេះ មិនចង់ប្រើប្រាស់ការការពាររបស់ប្រទេសនោះ ឬជាជនដែលមិនមានសញ្ជាតិ និងកំពុងរស់នៅក្រៅប្រទេសដែលជាអតីតនិវេសនដ្ឋានប្រក្រតីរបស់ខ្លួនដោយ សារព្រឹត្តិការណ៍នេះ និងដែលមិនអាច ឬដោយការភ័យខ្លាចបែបនោះមិនចង់វិលត្រឡប់ទៅកាន់ប្រទេសដើមរបស់ខ្លួនវិញ។

ដើម្បីចាត់ទុកថាបុគ្គលម្នាក់ថាជាជនភៀសខ្លួន បុគ្គលនោះត្រូវបំពេញតាមធាតុផ្សំទាំងអស់នៃនិយមន័យថានេះ។ នីតិវិធីនៃការធ្វើការកំណត់នេះ ត្រូវបានហៅថាការកំណត់ឋានៈជនភៀសខ្លួន (RSD)។ នៅពេលរដ្ឋមួយ ឬអង្គការមួយដូចជា UNHCR មាន

បំណងទទួលស្គាល់អ្នកណាម្នាក់ជាជនភៀសខ្លួន ពួកគេនឹងពិចារណាថាមានការបំពេញតាមធាតុផ្សំនីមួយៗនៃធាតុផ្សំទាំងអស់ដែរឬទេ។ ធាតុផ្សំគន្លឹះនៃនិយមន័យនេះគឺ៖

- **ការភ័យខ្លាចដែលមានមូលដ្ឋានច្បាស់លាស់៖** បុគ្គលត្រូវតែស្ថិតក្នុងភាពភ័យខ្លាចនៃការធ្វើទុក្ខបុកម្នេញ ហើយភាពភ័យខ្លាចនេះត្រូវតែមាននីត្យានុកូលភាព មានន័យថាត្រូវតែមាន "ឱកាសពិតប្រាដក" នៃការធ្វើទុកបុកម្នេញដែលមានភ័ស្តុតាងបញ្ជាក់។ នៅក្នុងករណីជាច្រើន បុគ្គលត្រូវបានធ្វើទុក្ខបុកម្នេញដោយរដ្ឋ ប៉ុន្តែនេះអាចត្រូវបានប្រព្រឹត្តឡើងស្ថាប័នមិនមែនជារដ្ឋផងដែរ។

  ការភ័យខ្លាចមានធាតុផ្សំចំនួនពីរ៖ ធាតុផ្សំអត្តនោម័ត ឬប្រសិនបើបុគ្គលនេះមានការភ័យខ្លាចពិតប្រាកដ និងធាតុផ្សំសត្យានុម័ត ឬប្រសិនបើមានហេតុផលត្រឹមត្រូវដើម្បីជឿជាក់ថា បុគ្គលមានអ្វីដែលធ្វើឲ្យគាត់ខ្លាច។ ធាតុផ្សំទាំងពីរនេះត្រូវបញ្ជាក់ដោយភស្តុតាង។ ជាទូទៅ ការទាមទារឋានៈជនភៀសខ្លួនត្រូវបានចាត់ទុកថាមានភ័ស្តុតាងគ្រប់គ្រាន់ ប្រសិនជាបុគ្គលមានការភ័យខ្លាចជាអត្តនោម័តពីការធ្វើទុក្ខបុកម្នេញ។ ដើម្បីកំណត់ថាតើការភ័យខ្លាចរបស់បុគ្គលសត្យានុម័តឬក៏អត់ប្រហែលជាទាមទារឲ្យមានការស៊ើបអង្កេតមួយជា ទូទៅធ្វើឡើងដោយ UNHCR ដើម្បីស្វែងរកថាមានហានិភ័យពិតប្រាកដឬក៏អត់ ដែលជាទូទៅត្រូវបានកំណត់ដោយការសាកសួរ NGOs ឬអ្នកជំនាញការ ដែលអាចជឿទុកចិត្តបានតាមរយៈការផ្ទៀងផ្ទាត់ជាមួយនឹងព័ត៌មានពីប្រទេសដើម ដែលអាចជឿទុកចិត្តបានដូចជាព័ត៌មានដែលបានមកពីរបាយការណ៍សិទ្ធិមនុស្ស ឬប្រព័ន្ធផ្សព្វផ្សាយដែលអាចជឿទុកចិត្តបាន និងតាមរយៈការកំណត់ថាតើមានការធ្វើទុក្ខបុកម្នេញពីមុនឬក៏អត់ ឬមានការធ្វើទុក្ខបុកម្នេញលើបុគ្គលដែលមានស្ថានភាពស្រដៀងគ្នានេះឬក៏អត់។

- **ការធ្វើទុក្ខបុកម្នេញ៖** ការធ្វើទុក្ខបុកម្នេញ ត្រូវស្ថិតនៅកម្រិតស្មើនឹងការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ (ទម្រង់នៃការរើសអើង ការបដិសេធនូវសេវាកម្មមូលដ្ឋានដូចជា ចំណីអាហារ ទឹក ឬការថែទាំសុខភាព ឬការចាប់ខ្លួនតាមទំនើងចិត្ត អាចជាការធ្វើទុក្ខបុកម្នេញ យោងទៅតាមភាពធ្ងន់ធ្ងរនៃស្ថានភាពទាំងនេះ ការគម្រាមកំហែងដល់ជីវិត ទារុណកម្ម និងការឃុំខ្លួនគឺជាការធ្វើទុក្ខបុកម្នេញ)។ ខណៈពេលដែលមិនមាននិយមន័យ ដែលបានព្រមព្រៀងថាអ្វីជាការធ្វើទុក្ខបុកម្នេញ ដូចជាការធ្វើដំណើរឆ្ងាយពេកដើម្បីទៅកាន់មន្ទីរពេទ្យ មិនមែនជាបញ្ហាធ្ងន់ធ្ងរនោះទេ ប៉ុន្តែច្បាប់ដែលហាមឃាត់ ក្នុងការទទួលបានការថែទាំសុខភាពដោយសារតែសាសនារបស់បុគ្គល អាចត្រូវបានចាត់ទុកថាជាការធ្វើទុក្ខបុកម្នេញ។
- **មូលដ្ឋានទាំងប្រាំ៖** ហានិភ័យនៃការធ្វើទុក្ខបុកម្នេញអាចដោយសារ៖

  ក. ពូជសាសន៍

  ខ. សាសនា

គ. សញ្ជាតិ

ឃ. ជំនឿនយោបាយ

ង. ឬ 'សមាជិកនៃក្រុមសង្គមណាមួយជាក់លាក់ នេះសំដៅលើក្រុមបុគ្គលដែលមានចរិកលក្ខណៈដូចគ្នាដែលជាមូលដ្ឋានសម្រាប់ពួកគេ ដូចជាស្ត្រី អ្នករួមភេទដូចគ្នា ឬសមាជិកវណ្ណៈសង្គមណាមួយ។ កំណត់និយមន័យក្រុមសង្គមអាចមានការពិបាក យ៉ាងហោចណាស់តុលាការកាត់សេចក្តីថាជាឧទាហរណ៍ អ្នករត់តាក់ស៊ីមិនមែនជាក្រុមសង្គមនោះទេ ដោយសារបុគ្គលអាចផ្លាស់ប្តូរមុខរបររបស់ខ្លួន ហើយមិនមែនជាមូលដ្ឋាននៃចរិកលក្ខណៈរបស់ពួកគេនោះទេ ប៉ុន្តែអ្នកដទៃទៀតគិតថា អ្នកកាសែត ឬអ្នកការពារសិទ្ធិមនុស្សប្រហែលអាចជាក្រុមសង្គម។ ស្ត្រី ឬមនុស្សដែលត្រូវបានជួញដូរមិនអាចផ្លាស់ប្តូរឋានៈរបស់ខ្លួនបាននោះទេ (ស្ត្រីមិនអាចក្លាយជាបុរស ហើយមនុស្សដែលត្រូវបានជួញដូរក៏មិនអាចក្លាយជា 'មិនត្រូវបានជួញដូរ' នោះដែរ)។ ប្រភេទនៃក្រុមសង្គមនេះទូទៅ និងមានភាពបត់បែនជាងប្រភេទផ្សេង ហើយត្រូវបានប្រើប្រាស់កាលពីពេលថ្មីនេះ ដើម្បីការពារស្ត្រីដែលប្រឈមនឹងការធ្វើទុក្ខបុកម្នេញ (ពីការរំលូតកូនដោយបង្ខំ អំពើហិង្សា ឬការសម្លាប់ដើម្បីបូជា)។ យ៉ាងណាមិញ ត្រូវចងចាំថាក្រុមសង្គមត្រូវតែ "ជាក់លាក់" មិនទូទៅនោះទេ។ ជាឧទាហរណ៍ "ស្ត្រី" ជារឿយៗមានភាពទូទៅពេកក្នុងការចាត់ទុកថាជាក្រុមសង្គម ហើយត្រូវតែស្ថិតក្នុងក្នុងស្ថានភាពដែលមានភាពជាក់លាក់ "ស្ត្រីវ័យក្មេងនៃកុលសម្ព័ន្ធដែលមិនមែនជាអ្នកប្រឈមនឹងការកាត់ប្រដាប់ភេទស្ត្រី ហើយប្រឆាំងនឹងការអនុវត្តនេះ"។

- **ទំនាក់ទំនង៖**

ជាការសំខាន់ដែលការធ្វើទុក្ខបុកម្នេញ ដោយសារតែបុគ្គលស្ថិតក្នុងយ៉ាងហោចណាស់មួយនៃប្រភេទទាំងនេះ ទោះបីជាទូទៅបុគ្គលអាចស្ថិតក្នុងប្រភេទច្រើនជាងមួយ ហើយការធ្វើទុក្ខបុកម្នេញអាចចម្រុះផងដែរ។ នេះត្រូវបានហៅថាជាលក្ខខណ្ឌទំនាក់ទំនង៖ ការធ្វើទុក្ខបុកម្នេញត្រូវពាក់ព័ន្ធនឹងប្រភេទ។

- **ជនបរទេស៖** បុគ្គលត្រូវតែនៅខាងក្រៅប្រទេសរបស់ពួកគេដើម្បីទាមទារឋានៈជាជនភៀសខ្លួន។ តម្រូវការនេះ ដែលត្រូវបានហៅថា'ជាជនបរទេស' គឺចាំបាច់ដោយសារជនភៀសខ្លួនត្រូវតែស្នើសុំការការពារពីរដ្ឋដទៃ។ ស្នើសុំឋានៈជនភៀសខ្លួនទៅស្ថានទូត នៅក្នុងប្រទេសកំណើតរបស់បុគ្គលមិនគ្រប់គ្រាន់នោះទេ ទោះបីជាប្រហែលជាមានទម្រង់នៃការការពារខ្លះដែលស្ថានទូតអាចផ្តល់ជូនក៏ដោយ។
- **មិនមានការការពារដោយរដ្ឋ៖** បុគ្គលត្រូវភៀសខ្លួនចេញពីរដ្ឋដោយសារពួកគេមិនអាច ឬ ដោយសារតែភ័យខ្លាចនឹងការធ្វើទុក្ខបុកម្នេញ មិនមានបំណងក្នុង

ការស្វែងរកការការពារនៅក្នុងរដ្ឋរបស់ខ្លួននោះទេ។ ប្រសិនបើរដ្ឋាភិបាលរបស់ពួកគេអាចការពារពួកគេ ពួកគេមិនចាំបាច់សុំឋានៈជាជនភៀសខ្លួននោះទេ។ ជាទូទៅ ប្រជាជនសុំការការពារជនភៀសខ្លួន ដោយសារតែរដ្ឋដែលធ្វើការកាត់ទោសពួកគេជាដំបូង ឧទាហរណ៍រដ្ឋាភិបាលចាប់អ្នកប្រឆាំងនយោបាយរបស់ខ្លួនដាក់ពន្ធនាគារ ប៉ុន្តែសូម្បីតែអ្នកធ្វើទុក្ខបុកម្នេញមិនមែនជាស្ថាប័នរដ្ឋ ហើយរដ្ឋមិនអាចការពារបុគ្គលពីស្ថាប័ននោះ បុគ្គលនេះអាចសុំការការពារជនភៀសខ្លួនបាន។

## ការពិភាក្សា និងការការជជែកវែកញែក

### ការកំណត់ឋានៈជនភៀសខ្លួន

*តើស្ត្រីដែលភៀសខ្លួនពីប្រទេសរបស់គាត់ដោយសារគាត់ប្រឈមអំពើហិង្សាក្នុងគ្រួសារ អាចទទួលបានឋានៈជាជនភៀសខ្លួនដែរឬទេ?*

ចំនុចដំបូងដែលត្រូវធ្វើការពិចារណា គឺថាតើប្រទេសដែលគាត់បានភៀសខ្លួនទៅកាន់បានផ្តល់សច្ចាប័នលើអនុសញ្ញាជនភៀសខ្លួនឬក៏អត់។ ប្រសិនជារដ្ឋនោះបានផ្តល់សច្ចាប័ន ប្រទេសជាបឋមត្រូវធ្វើការសម្រេចចិត្តដោយផ្អែកលើលក្ខន្តិកៈខាងលើ។ ប្រសិនជាប្រទេសនេះមិនបានផ្តល់សច្ចាប័នលើអនុសញ្ញានេះនោះទេ គាត់អាចសុំជំនួយពី UNHCR។ នៅពេលដែលអាចសន្មតថាប្រទេសបានព្រមព្រៀងលើអនុសញ្ញា ហើយមានភស្តុតាងគ្រប់គ្រាន់នៃអំពើហិង្សាដែលគាត់ប្រឈម (ជាឧទាហរណ៍ កំណត់ត្រាវេជ្ជសាស្ត្រ ឬរបាយការណ៍ពីគ្រួសាររបស់គាត់) បន្ទាប់មកអាចទទួលយកបានថាគាត់ពិតជាប្រឈមនឹងការធ្វើទុក្ខបុកម្នេញពិតប្រាកដមែន។ លើសពីនេះទៀតគាត់អាចត្រូវបានចាត់ទុកជាសមាជិកនៃក្រុមសង្គមផងដែរ (ជាស្ត្រី ឬស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍)។ យ៉ាងណាមិញ ត្រូវធ្វើការសាកសួរថាតើស្ត្រីរូបនោះបានស្វែងរកការការពារពីរដ្ឋដែលគាត់បានភៀសខ្លួនចេញឬក៏អត់។ ប្រសិនជារដ្ឋពិតជាបានផ្តល់ការការពារប្រភេទនេះ (ជាឧទាហរណ៍ ការការពារផ្លូវច្បាប់ ផ្តល់ជម្រកដល់ស្ត្រី ការពារដោយប៉ូលីសដែលទទួលបានការបណ្តុះបណ្តាល) មិនមានហេតុផលសម្រាប់គាត់ក្នុងការសុំការជ្រកកោននោះទេ។ ប្រសិនជារដ្ឋរបស់គាត់មិនអាចផ្តល់ការការពារ (ជាឧទាហរណ៍ មិនមានច្បាប់ប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ ឬប៉ូលីសមិនព្យាយាមក្នុងការការពារខ្លួនគាត់ពីអំពើហិង្សា) នោះមានហេតុផលគ្រប់គ្រាន់សម្រាប់គាត់ក្នុងការត្រូវបានចាត់ទុកថាជាជនភៀសខ្លួន។ ច្បាស់ណាស់ដែលថាចរិកលក្ខណៈអត្តនោម័តនៃការវាយតម្លៃធាតុផ្សំចម្បង នឹងមានន័យថារដ្ឋផ្សេងៗគ្នាអាចផ្តល់ការរកឃើញខុសៗគ្នាលើករណីដូចគ្នា។

នៅកម្រិតបុគ្គល ដំណើរការនៃការត្រូវបានកំណត់ថាជាជនភៀសខ្លួនមួយរូប ចាប់ផ្តើមនៅពេលដែលបុគ្គលស្វែងរកឋានៈជាជនភៀសខ្លួន ស្វែងរកការការពារ។ ចាប់ផ្តើមពីពេលនោះមក ពួកគេគួរតែត្រូវបានផ្តល់ការការពារដោយអនុសញ្ញាជនភៀសខ្លួនរហូតដល់រដ្ឋកំណត់ថាថាពួកគេស្ថិតក្នុងក្នុងនិយមន័យឬក៏អត់។ មាននិន្នាការមួយដែលរដ្ឋហៅប្រជាជនដែលស្ថិតក្នុងដំណើរការ សុំទទួលស្គាល់ឋានៈរបស់ខ្លួនថា 'អ្នកសុំការជ្រកកោន' ដែលជាពាក្យលេចឡើងក្នុងទសវត្សឆ្នាំ ១៩៧០ ប៉ុណ្ណោះ ទោះបីជាវាត្រូវបានប្រើប្រាស់ជាទូទៅពេលបច្ចុប្បន្នក៏ដោយ។ ក្នុងន័យម្យ៉ាង ពាក្យ 'អ្នកសុំជ្រកកោន' ត្រូវបានប្រើប្រាស់ដើម្បីបដិសេធជនភៀសខ្លួនក្នុងការទទួលបាននូវសិទ្ធិពេញលេញរបស់ពួកគេដដយមិនហៅពួកគេថាជាជនភៀសខ្លួន។ ប្រសិនជាការទាមទារមិនត្រូវបានទទួលស្គាល់ដោយរដ្ឋ បន្ទាប់មករដ្ឋអាចសម្រេចក្នុងការបញ្ជូនជនភៀសខ្លួនត្រឡប់ទៅប្រទេសដើមរបស់ពួកគេវិញ ឬស្នើឲ្យពួកគេចាកចេញពីប្រទេសខ្លួន។ ទោះបីជាការទទួលស្គាល់ការទាមទារនេះមានលក្ខណៈបច្ចេកទេសក៏ដោយ ការសម្រេចចិត្តអាចត្រូវបានរងឥទ្ធិពលពីកត្តានយោបាយ ឬសង្គម (ទោះបីជាមិនគួរធ្វើដូច នេះក៏ដោយ)។ រដ្ឋនីមួយៗមាននីតិវិធី និងស្តង់ដាររៀងៗខ្លួនសម្រាប់ការទទួលស្គាល់ជនភៀសខ្លួន។ ប្រទេសខ្លះបានដាក់ស្តង់ដារដែលពិបាកៗ។ ជាឧទាហរណ៍ ប្រទេសជប៉ុនជាបន្តបន្ទាប់ទទួលស្គាល់តិចជាង ១% នៃការទាមទារសុំការជ្រកកោនដែលបានស្នើសុំរៀងរាល់ឆ្នាំ។ ក្នុងឆ្នាំ ២០១៣ ប្រទេសជប៉ុនបានផ្តល់ឋានៈជាជនភៀសខ្លួនតែប្រាំមួយករណីប៉ុណ្ណោះ ទោះបីជាមានការដាក់ពាក្យសុំចំនួន ៣០០០ ក៏ដោយ ហើយមនុស្សកាន់តែច្រើនទៅៗក្នុងប្រទេសជប៉ុន ដែលជាអ្នកគួរតែត្រូវបានចាត់ទុកថាជាជនភៀសខ្លួន មិនអនុវត្តនីតិវិធីក្នុងការសុំនោះទេ ដោយសារតែមានឱកាសតិចតួចបំផុតដែលពួកគេនឹងត្រូវបានទទួលស្គាល់។ ពេលខ្លះរដ្ឋនឹងទទួលជនភៀសខ្លួនភ្លាមៗពីប្រទេសដែលជាគូបដិបក្ខ (សហរដ្ឋអាមេរិកទទួលស្គាល់ជនភៀសខ្លួនពីចិន និងរុស្ស៊ីភ្លាមៗក្នុងអំឡុងពេលសង្គ្រាម ហើយដូចគ្នាចំពោះចិន និងរុស្ស៊ីផងដែរ)។ រដ្ឋជាច្រើនបានបង្កើតអង្គជំនុះជម្រះជនភៀសខ្លួនឯករាជ្យ ដើម្បីវាយតម្លៃលើពាក្យសុំទាំងនេះ។ ប្រភេទផ្សេងទៀតនៃការការពាររួមមានប្រជាជនដែលត្រូវបានជម្លៀសខ្លួន នេះសំដៅលើប្រជាជនដែលបានជម្លៀសខ្លួនដោយសារសង្គ្រាម ឬបាតុភូតធម្មជាតិ។ ទោះបីជាព្រឹត្តការណ៍ទាំងពីរនេះ មិនត្រូវបានគ្រប់ដណ្តប់ដោយអនុសញ្ញាជនភៀសខ្លួនក៏ដោយជារឿយៗស្ថាប័នជនភៀសខ្លួន (ដូចជា UNHCR) បានគិតថាខ្លួនមានកាតព្វកិច្ចមួយក្នុងការការពារជនរងគ្រោះទាំងនេះផងដែរ។ កង្វល់ធំបំផុតគឺប្រជាជនដែលជម្លៀសខ្លួនក្នុងប្រទេស (IDPs) គឺជាប្រជាជនដែលត្រូវបានបង្ខំឲ្យផ្លាស់ទីពីផ្ទះរបស់ខ្លួនប៉ុន្តែមិនបានឆ្លងកាត់ព្រំដែនអន្តរជាតិ។ DIPs ខ្លះអាចជាជនភៀសខ្លួន ប្រសិនជាពួកគេទៅដល់ព្រំដែន ប៉ុន្តែពួកគេនៅតែស្ថិតក្នុងស្ថានភាពធ្វើការជម្លៀសខ្លួននៅក្នុងប្រទេសរបស់ខ្លួន។ ដូចនេះដោយសារមិនមានការឆ្លងដែន ពួកគេមិនអាចស្វែងរកការពារតាមអនុសញ្ញាឆ្នាំ ១៩៥១ បាននោះទេ។ ជុំវិញពិភពលោកក្នុងឆ្នាំ ២០១៤ មានប្រជាជនប្រហែល ៣៣ លាននាក់ត្រូវបានជម្លៀសខ្លួនក្នុងប្រទេស។ នៅអាស៊ីអាគ្នេយ៍ មាន

ប្រទេសដែលមានប្រជាជន IDP ទ្រង់ទ្រាយធំ។ ប្រទេសទាំងនេះរួមមានមីយ៉ាន់ម៉ា ដែលប្រជាជនត្រូវបានជម្លៀសដោយជម្លោះពូជសាសន៍ក្នុងរដ្ឋ កាជិន (Kachin) ការ៉ែន (Karen) អារ៉ាខាន(Arakan) និង សាន (Shan)។ ប្រទេសហ្វីលីពីនមានប្រជាជន IDP នៅកោះភាគខាងត្បូងនៃមីនដាណាវ (Mindanao)។ មានជនជាតិហ្មុង (Hmong) ដែលត្រូវបានជម្លៀសក្នុងប្រទេសឡាវ និងមានប្រជាជនដែលត្រូវបានជម្លៀសក្នុងខេត្តភាគខាងត្បូងទាំងបីក្នុងប្រទេសថៃផងដែរ។

មានរដ្ឋភាគីចំនួន១៤៧ នៃអនុសញ្ញាជនភៀសខ្លួន ទោះបីជារដ្ឋក្នុងតំបន់អាស៊ីអាគ្នេយ៍មានតែហ្វីលីពីន កម្ពុជា និងទីម័រខាងកើតប៉ុណ្ណោះដែលបានផ្តល់សច្ចាប័នលើអនុសញ្ញានេះ។ សូម្បីតែទូទាំងអាស៊ី មានប្រទេសមួយចំនួនតូចប៉ុណ្ណោះដែលជាភាគីនៃអនុសញ្ញានេះ។ មានប្រទេសតែមួយប៉ុណ្ណោះនៅតំបន់អាស៊ីខាងត្បូងដែលបានចុះហត្ថលេខាលើអនុសញ្ញានេះ ទោះបីជាប្រទេសនេះជាប្រទេសដែលមានជនភៀសខ្លួនច្រើនជាងគេក៏ដោយក្នុងតំបន់។ ចំនួនតិចនៃរដ្ឋដែលបានផ្តល់សច្ចាប័ន មួយផ្នែកគឺដោយសារពាក្យពេចន៍ដើមនៃសន្ធិសញ្ញាឆ្នាំ ១៩៥១ ដែលដែនកំណត់ភូមិសាស្ត្រ និងពេលវេលា៖ ជាមូលដ្ឋាន ជនភៀសខ្លួននៅក្នុងអនុសញ្ញានេះកំណត់លើប្រជាជនដែលត្រូវបានជម្លៀសក្នុងតំបន់អឺរ៉ុបដោយសារសង្គ្រាមលោកលើកទីពីរ។ ច្បាស់ណាស់ជនភៀសខ្លួនទាំងនេះមានទំនាក់ទំនងតិចតួចជាមួយនឹងទ្វីបអាស៊ី ដូចជាឥណ្ឌា ដូចនេះមិនមានការជម្រុញទឹកចិត្តក្នុងការព្រមព្រៀងលើសន្ធិសញ្ញានេះនោះទេ។ ដើម្បីប៉ះប៉ូវលើស្ថានភាពនេះ ពិធីសារឆ្នាំ ១៩៦៧ ពាក់ព័ន្ធនឹងឋានៈជនភៀសខ្លួនបានពង្រីកនិយមន័យដោយធ្វើការលុបចោល នូវដែនកំណត់ភូមិសាស្ត្រ និងពេលវេលា ដោយធ្វើការកំណត់ជនភៀសខ្លួនថាជាអ្នកណាម្នាក់ដែលស្ថិតក្នុងនិយមន័យប៉ុណ្ណោះ។ យ៉ាងណាមិញ រដ្ឋនៅអាស៊ីជាទូទៅមានអត្តចរិកអភិរក្សនិយម និងប្រុងប្រយ័ត្ន ប្រហែលជាដោយសារប្រទេសខ្លះប្រឈមនឹងលំហូរចូលនៃជនភៀសខ្លួនច្រើន ដូចជាប៉ាគីស្ថាន អ៊ីរ៉ង់ និងថៃ ដែលបានទទួលជនភៀសខ្លួនរាប់សែននាក់ ហើយក្នុងករណីខ្លះរហូតដល់រាប់លាននាក់ឯណោះ។

មានយន្តការការពារជនភៀសខ្លួនថ្នាក់តំបន់មួយចំនួន ដូចជាយន្តការដែលបានផ្តល់ជូនដោយសហភាពអាហ្វ្រិក។ យន្តការនេះមាននិយមន័យទូលំទូលាយជាងអនុសញ្ញាជនភៀសខ្លួនដោយសារ យន្តការនេះរួមបញ្ចូលប្រជាជនដែលរត់ភៀសខ្លួនពី "ព្រឹត្តការណ៍ដែលរំខានធ្ងន់ធ្ងរដល់អសណ្តាប់ធ្នាប់សាធារណៈ"។ បន្ថែមពីលើនេះទៀត សេចក្តីប្រកាសកាតាជីណា Cartagena ស្តីពីជនភៀសខ្លួន របស់អង្គការរដ្ឋនៅទ្វីបអាមេរិក ត្រូវបានធ្វើឡើងដោយផ្អែកលើនិយមន័យជនភៀសខ្លួន របស់សហភាពអាហ្វ្រិកដោយរួមបញ្ចូលការគម្រាមកំហែងនៃអំពើហិង្សាទូទៅ ការឈ្លានពានពីបរទេស ជម្លោះផ្ទៃក្នុង និងការរំលោភបំពានធ្ងន់ធ្ងរលើសិទ្ធិមនុស្ស ទាំងនេះជាហេតុផលសម្រាប់ការផ្តល់ឋានៈជាជនភៀសខ្លួន។

## ការពិភាក្សា និងការជជែកវែកញែក

### ជនភៀសខ្លួនបរិស្ថាន

ទោះបីជាពាក្យថា "ជនភៀសខ្លួនបរិស្ថាន" មិនទាន់មាននិយមន័យតាមផ្លូវច្បាប់នៅឡើយក៏ដោយ ជាទូទៅវាសំដៅលើបុគ្គលដែលត្រូវបានជម្លៀសខ្លួនដោយសារការផ្លាស់ប្តូរនៃបរិស្ថាន។ ខណៈពេលដែលនេះមិនមែនជាអ្វីដែលតែងតែកើតឡើងជាទូទៅ វាកើតមានឡើងកាន់តែញឹកញ៉ាប់។ ជាឧទាហរណ៍ ទឹកជំនន់ក្នុងទីក្រុងបាងកក (២០១១) ម៉ានីល (២០១១) និងហ្សាកាតា (២០១៣) បានជម្លៀសប្រជាជនរាប់លាននាក់ក្នុងរយៈដ៏ខ្លីមួយប៉ុណ្ណោះ។ ពេលបច្ចុប្បន្ននេះ មានការទទួលស្គាល់ថា ដោយសារការបម្រែបម្រួលបរិយាកាស និងការកើនឡើងនៃកម្ពស់ទឹកសមុទ្រ ប្រជាជនរាប់លាននាក់នឹងត្រូវបានបង្ខំឲ្យចាកចេញពីតំបន់ទំនាបដូចជាដីសណ្តរមេគង្គ និង អ៊ីរ៉ាវ៉ាឌី និងបាងកកជាដើម។ ប៉ុន្តែពួកគេនឹងទៅណា?

*តើអ្នកចាត់ទុកថាប្រជាជនទាំងនេះជាជនភៀសខ្លួនដែរឬទេ ហើយនឹងផ្តល់សិទ្ធិដល់ពួកគេក្នុងការស្វែងរកការការពារក្នុងប្រទេសជិតខាង ឬក៏អត់? ប្រសិនជាអត់ តើការការពារ និងសេវាកម្មអ្វីដែលប្រជាជនទាំងនេះអាចទទួលបាន?*

*តើប្រជាជនជម្លៀសខ្លួនដោយសារបាតុភូតធម្មជាតិ ត្រូវបានចាត់ទុកថាជាជនភៀសខ្លួនដែរឬទេ? តើពួកគេគួរតែត្រូវបានគ្រប់ដណ្តប់ដោយអនុសញ្ញាជនភៀសខ្លួនឬក៏អត់? ឬក៏ត្រូវការអនុសញ្ញាដទៃដើម្បីការពារពួកគេ?*

## ៦.៣.២ ស្តង់ដារអនុសញ្ញាជនភៀសខ្លួន

អនុសញ្ញាជនភៀសខ្លួនផ្តល់នូវការការពារខ្លាំង ពាក់ព័ន្ធនឹងសន្តិសុខរបស់បុគ្គលនៅក្នុងរដ្ឋដែលទទួល។ ទោះបីជាអនុសញ្ញាត្រូវបានព្រាងមុនពេលសិទ្ធិស្តង់ដារជីវភាព និងសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ជាមូលដ្ឋានត្រូវបានកំណត់ថាជាសិទ្ធិមនុស្សក៏ដោយ ការអនុសញ្ញានេះនៅតែផ្តល់នូវការការពារជាសារវ័នផងដែរ។ ទាំងនេះរួមមានបញ្ចូលនូវតម្រូវការជាមូលដ្ឋាន (ចំណីអាហារ និងលំនៅដ្ឋាន) ការការពារផ្លូវច្បាប់ (រួមមានសិទ្ធិក្នុងពេលជាប់ឃុំ) នឹងសូម្បីតែសិទ្ធិការងារផងដែរ។ យ៉ាងណាមិញ សិទ្ធិទាំងនេះគឺផ្អែកតម្រូវការជាមូលដ្ឋាន (ផ្តល់ជូនគ្រប់គ្រាន់សម្រាប់បុគ្គលណាម្នាក់ក្នុង

ការរស់រានមានជីវិត) ហើយមិនមែនលើលក្ខខណ្ឌសិទ្ធិមនុស្ស ដែលធ្វើការធានានូវភាពថ្លៃថ្នូររបស់បុគ្គលនោះទេ។ កង្វល់ជាក់លាក់គឺពាក់ព័ន្ធនឹងការការពារសិទ្ធិសេដ្ឋកិច្ចរបស់ជនភៀសខ្លួន ដូចជាការងារជាដើម។ រដ្ឋបារម្ភថាការទាមទាររបស់ជនភៀសខ្លួនខ្លះគឺផ្អែកសេដ្ឋកិច្ចតែមួយមុខគត់ មានន័យថាពួកគេរត់ភៀសខ្លួនពីប្រទេសរបស់ខ្លួន ក្នុងគោលបំណងធ្វើការ ក្នុងប្រទេសដទៃសម្រាប់ផលប្រយោជន៍សេដ្ឋកិច្ចតែប៉ុណ្ណោះ។ ដោយសារហេតុផលនេះ ជាការកម្រចំពោះជនភៀសខ្លួនក្នុងការផ្តល់ជូនសិទ្ធិការងារពេញលេញណាស់។

ស្តង់ដារជនភៀសខ្លួនជាមូលដ្ឋានដែលមានក្នុងមាត្រា ៣៣ ឬគោលការណ៍នៃ ការមិនបញ្ជូនត្រលប់ទៅវិញ ដែលមានន័យថាមិនបញ្ជូនបុគ្គលណាមួយទៅប្រទេសដើមវិញ (បញ្ជូនពួកគេទៅវិញ) នោះទេ។ បច្ចុប្បន្ននេះ គោលការណ៍នេះត្រូវបានចាត់ទុកថាជាច្បាប់ទំនៀមទំលាប់ មានន័យថាទោះបីជារដ្ឋមិនបានផ្តល់សច្ចាប័នអនុសញ្ញាជនភៀសខ្លួនដែលបញ្ជាក់ពីគោលការណ៍នេះក៏ដោយ ក៏រដ្ឋត្រូវតែគោរពគោលការណ៍នេះដែរ។ យ៉ាងណាមិញ រដ្ឋអាចបញ្ជូនអ្នកសុំជ្រកកោនឬជនភៀសខ្លួនទៅប្រទេសទីបីដែលជីវិត និងសេរីភាពរបស់ពួកគេត្រូវបានធានា។ លើសពីនេះទៀត រដ្ឋមិនអាចបដិសេធ ឬមិនអនុញ្ញាតឲ្យបុគ្គលដែលសុំការជ្រកកោនចូលក្នុងប្រទេសខ្លួននោះទេ។ រដ្ឋមិនមានកាតព្វកិច្ចក្នុងការអនុញ្ញាតការសុំជ្រកកោន ប៉ុន្តែពួកគេមិនអាចបដិសេធលទ្ធភាពក្នុងការសុំការជ្រកកោនបាននោះទេ។

## ផ្តោតសំខាន់លើ

### មាត្រា ៣៣ នៃការហាមឃាត់ការបណ្តេញចេញ ឬបញ្ជូនទៅវិញ ("ការមិនបញ្ជូនត្រលប់ទៅវិញ")

- មិនមានរដ្ឋជាប់កាតព្វកិច្ចណាមួយធ្វើការបណ្តេញ ឬបញ្ជូន ("ជនដែលត្រូវបានបញ្ជូនទៅវិញ") ជនភៀសខ្លួនទៅវិញ តាមរយៈមធ្យោបាយណាមួយនោះទេ ទៅកាន់ទឹកដីដែលជីវិត ឬសេរីភាពរបស់គាត់ត្រូវបានគម្រាមកំហែងដោយមូលដ្ឋានពូជសាសន៍ សាសនា សញ្ជាតិ សមាជិកនៃក្រុមសង្គម ឬទស្សនៈនយោបាយណាមួយជាក់លាក់។

- យ៉ាងណាមិញផលប្រយោជន៍នៃប្បញ្ញត្តិនេះ ប្រហែលជាមិនអាចទាមទារបានដោយជនភៀសខ្លួន ដែលចាត់ទុកថាជាគ្រោះថ្នាក់មួយដល់សហគមន៍នៃប្រទេសនេះនោះទេ ដោយមានមូលហេតុសមស្របក្នុងការកំណត់ថាបុគ្គលនេះអាចប៉ះពាល់ដល់សន្តិសុខនៃប្រទេស ដែលគាត់ត្រូវបានកាត់ទោសដោយសាលក្រមចុង

ក្រោយពីបទឧក្រិដ្ឋធ្ងន់ធ្ងរជាក់លាក់។

ការមិនបញ្ជូនត្រលប់ទៅវិញជានាថាបុគ្គល មិនត្រូវបានបញ្ជូនត្រលប់ទៅប្រទេសខ្លួនវិញដោយបង្ខំដែលជាកន្លែងដែលគាត់នឹងប្រឈមនឹងការធ្វើទុក្ខបុកម្នេញ ដោយមិនពាក់ព័ន្ធនឹងស្ថានភាពគតិយុត្តនៃការការពារជនភៀសខ្លួន នៅទីកន្លែងដែលគាត់មានវត្តមាននោះទេ។ សូម្បីតែរដ្ឋមួយមិនបានចុះហត្ថលេខាលើអនុសញ្ញាជនភៀសខ្លួន ឬសន្ធិសញ្ញាសិទ្ធិមនុស្សដទៃក៏ដោយ រដ្ឋនៅតែត្រូវបានហាមឃាត់ក្នុងការនិរទេសបុគ្គលនោះទៅប្រទេសគាត់វិញនោះទេ។ នេះមិនមែនមានន័យថាការបញ្ចូលត្រលប់ទៅវិញមិនកើតឡើងនោះទេ។ ក្នុងអាស៊ីអាគ្នេយ៍ មានករណីដែលជនជាតិ Hmong ត្រូវបានបញ្ជូនត្រលប់ទៅប្រទេសឡាវវិញ Ugiyars ទៅប្រទេសចិនវិញ និងជនជាតិកូរ៉េខាងជើងទៅកាន់កូរ៉េខាងជើងវិញ ទោះបីជាមានការសង្ស័យថាប្រជាជនទាំងនេះនឹងប្រឈមនឹងការធ្វើទុក្ខមុកម្នេញក៏ដោយ។

## ៦.៨ ប្រជាជនដែលជាជនភៀសខ្លួន និងការការពារនៅអាស៊ីអាគ្នេយ៍

មានប្រជាជនដែលជាជនភៀសខ្លួនពីរប្រភេទជាចម្បងនៅអាស៊ីអាគ្នេយ៍។ ទីមួយ មានជនភៀសខ្លួនដែលមកពីតំបន់ខាងក្រៅ ពីប្រទេសដូចជាស្រីលង្កា អាហ្វហ្គានីស្ថាន ប៉ាគីស្ថាន និងសូម៉ាលី។ ពួកគេស្វែងរកជម្រកភៀសខ្លួនក្នុងតំបន់អាស៊ីអាគ្នេយ៍មុនពេលព្យាយាម ក្នុងការស្វែងរកការតាំងទីលំនៅនៅកន្លែងផ្សេងទៀត។ ជាការពិបាកក្នុងការប៉ាន់ប្រមាណ ពីទំហំនៃប្រជាជនប្រភេទនេះដោយសារភាគច្រើនពួកគេស្ថិតក្នុងឋានៈជាជនមិនមានឯកសារ និងជាជនភៀសខ្លួននៅទីក្រុង ធ្វើការលាក់ខ្លួនក្នុងទីក្រុងធំៗដូចជាបាងកក ហ្សាកាតា និងកូឡាឡាំពួ។ ប្រទេសនៅក្នុងតំបន់ដែលមានប្រជាជនភៀសខ្លួនច្រើនពីខាងក្រៅតំបន់ដូចជាប្រទេសថៃ ដែលតាមការប៉ាន់ប្រមាណមានជនភៀសខ្លួននៅទីក្រុងបាងកកប្រហែលជា ១០០០ នាក់ភាគច្រើនមកពីអាហ្វហ្គានីស្ថាន ស្រីលង្កា ប៉ាគីស្ថាន និងតំបន់ជម្លោះក្នុងទ្វីបអាហ្វ្រិកដូចជាសូម៉ាលី និងស៊ូដង់ជាដើម។ មានចំនួនច្រើនជាងនេះនៅឥណ្ឌូនេស៊ី ដែលប្រជាជនមកពីអាហ្វហ្គានីស្ថានស្រីលង្កា និងប៉ាគីស្ថានស្វែងរកឱកាសដើម្បីទៅប្រទេសអូស្ត្រាលី ឬស្វែងរកទីលំនៅថ្មីក្នុងតំបន់អឺរ៉ុបខាងលិចជាដើម។ ម៉ាឡេស៊ីក៏មានជនភៀសខ្លួនមួយចំនួនពីប្រទេសទាំងនេះផងដែរ។

ប្រភេទទីពីរ នៃប្រជាជនដែលជាជនភៀសខ្លួនគឺអ្នកដែលនៅក្នុងតំបន់។ អាស៊ីអាគ្នេយ៍មានប្រវត្តិយូរអង្វែងនៃលំហូរជនភៀសខ្លួន ដូចជាសង្គ្រាមអាមេរិកវៀតណាម និងសង្គ្រាមកុំម្មុយនិសក្នុងអំឡុងទសវត្សឆ្នាំ ១៩៦០ និង ១៩៧០ ដែលធ្វើឲ្យមានប្រជាជនជាជនភៀសខ្លួនពីប្រទេសវៀតណាម និងកម្ពុជាទៅប្រទេសថៃ ហុងកុង និងរដ្ឋនៅអាស៊ីអាគ្នេយ៍ច្រើនទៀត។ បច្ចុប្បន្ននេះ លំហូរជនភៀសខ្លួនធំបំផុតគឺលំហូរនៃប្រជាជនមីយ៉ាន់ម៉ាទៅប្រទេសម៉ាឡេស៊ី និងថៃ ទោះបីជាមានលំហូរតូចជាងនេះដូចជាជនជាតិហ្មុង Hmong (ពីឡាវ) ម៉ុងតេញ៉ា (Montangards) (ពីវៀតណាម) និងបាពួន (Papuans) (ពីឥណ្ឌូនេស៊ី) ក៏ដោយ។

ជនភៀសខ្លួនរស់នៅក្នុងស្ថានភាពពីរយ៉ាង នៅក្នុងជំរុំភៀសខ្លួន និងជនភៀសខ្លួននៅទីក្រុង។ ជនភៀសខ្លួននៅក្នុងជំរុំរស់នៅក្នុងជំរុំដែលពួកគេរំពឹងថានឹងស្នាក់នៅរហូតដល់ស្ថានភាពមានការផ្លាស់ប្តូរ ហើយពួកគេអាចត្រលប់ទៅកាន់ប្រទេសខ្លួនវិញ។ ឧទាហរណ៍គឺជនភៀសខ្លួនមីយ៉ាន់ម៉ា ដែលរស់នៅក្នុងជំរុំនៅបណ្តោយព្រំដែនថៃ ភូមា និងនៅក្នុងជំរុំបង់ក្លាដេស និងឥណ្ឌាផងដែរ។ ទាំងនេះជាជំរុំជនភៀសខ្លួនដែលមាននៅក្នុងអាស៊ីអាគ្នេយ៍។ ដោយសាររដ្ឋាភិបាលថៃមិនបានផ្តល់សច្ចាប័នលើអនុសញ្ញាជនភៀសខ្លួន ហើយមិនបានទទួលស្គាល់សិទ្ធិជនភៀសខ្លួន ប្រទេសនេះមិនបានហៅកន្លែងទាំងនេះថាជា 'ជំរុំជនភៀសខ្លួន' នោះទេ ប៉ុន្តែផ្ទុយទៅវិញប្រើពាក្រថា 'ជម្រកបណ្តោះអាសន្ន' ដែលបង្កប់ន័យថាពេលណាមួយឆាប់ៗ ជំរុំនឹងបិទ ហើយជនភៀសខ្លួននឹងត្រលប់ទៅកាន់ប្រទេសខ្លួនវិញ។ តាមរយៈការអង្កេតលើអាយុកាលនៃជំរុំទាំងនេះ (ជំរុំភាគច្រើនក្នុងប្រទេសថៃមានអាយុកាលប្រហែលជា ៣០ឆ្នាំ) ដែលនេះមិនបានបញ្ជាក់ថាជាដំណោះស្រាយបណ្តោះអាសន្ននោះទេ។ មានក្រុមគ្រួសារដែលបានរស់នៅក្នុងជំរុំរហូតដល់ទៅបីជំនាន់ ដែលកូនរបស់ពួកគេបានកើត ធំឡើង រៀបការ និងមានកូននៅក្នុងជំរុំ។

នៅក្នុងជំរុំ ប្រជាជនភាគច្រើនមានតម្រូវការជាមូលដ្ឋានរបស់ខ្លួនដែលបានផ្តល់ជូនដោយអង្គការមនុស្សធម៌ ប៉ុន្តែសិទ្ធិផ្សេងៗត្រូវបានបដិសេធដូចជាសេរីភាពនៃការដើរហើរ និងសិទ្ធិការងារ ធ្វើឲ្យស្តង់ដារជីវភាពសេដ្ឋកិច្ចរបស់ពួកគេមានការពិបាក ដោយសារពួកគេត្រូវតែពឹងផ្អែកលើអំណោយសប្បុរស ពីអង្គការអ្វីក៏ដោយដែលផ្តល់តម្រូវការជាមូលដ្ឋានដល់ពួកគេ។ ជនភៀសខ្លួនក្នុងជំរុំដែលបានចាកចេញពីជំរុំដើម្បីស្វែងរកការងារដោយមិនមានឯកសារ ហើយមានហានិភ័យនៃការនិរទេសប្រសិនជាត្រូវបានរកឃើញ។ ម្យ៉ាងវិញទៀត ប្រសិនជាពួកគេស្វែងរកការងារ ពួកគេនឹងមានហានិភ័យពីការកេងប្រវ័ញ្ច ឬសូម្បីតែធ្លាក់ខ្លួនចូលក្នុងការជួញដូរ ដោយសារការងារអ្វីក៏ដោយដែលពួកគេអាចរកបាន នឹងស្ថិតក្នុងវិស័យមិនរៀបរយ។ នៅពេលដែលកូនរបស់ពួកគេបញ្ចប់ថ្នាក់បឋមសិក្សា (ដែលមានផ្តល់ជូន) ពួកគេមិនមានលទ្ធភាពក្នុងការសិក្សាថ្នាក់វិទ្យាល័យ ឬមហាវិទ្យាល័យនោះទេ។ យ៉ាងណាមិញ ជនភៀសខ្លួន

ដោយផ្ទាល់បានធ្វើការឆ្លើយតបយ៉ាងសកម្មនឹងកង្វល់ទាំងនេះ។ ពេលបច្ចុប្បន្ននេះ ជំរុំភាគច្រើនមានគណៈកម្មាធិការ និងក្រុមយុវជនដែលមានភាពសកម្មក្នុងការបណ្តុះបណ្តាល និងការអប់រំ។ មានឧស្សាហកម្មតាមផ្ទះ និងកម្មវិធីអប់រំក្រៅផ្លូវការជាច្រើន ដើម្បីធ្វើឲ្យប្រសើរឡើងនូវភាពថ្លៃថ្នូររបស់ជីវិតប្រចាំថ្ងៃរបស់ពួកគេ។ រដ្ឋាភិបាលថៃមានភាពតឹងរឹងចំពោះជំរុំ ដោយសារខ្លួនមានជំនឿថាប្រសិនជាលក្ខខណ្ឌល្អប្រសើរពេក វានឹងអាចទាក់ទាញជនភៀសខ្លួនកាន់តែច្រើនទៀតមកក្នុងជំរុំ។ លើសពីនេះទៀត រដ្ឋាភិបាលមានកង្វល់ថាប្រជាជនក្នុងជំរុំនឹងស្នាក់នៅប្រទេសថៃ ជាជាងតាំងទីលំនៅក្នុង ឬធ្វើមាតុភូមិនិវត្តន៍ទៅកាន់ប្រទេសភូមាវិញ។

ក្រុមជនភៀសខ្លួនប្រភេទទីពីរ មានជនភៀសខ្លួននៅទីក្រុង។ ប្រជាជនទាំងនេះជាទូទៅមកពីខាងក្រៅតំបន់ ហើយរស់នៅក្នុងទីក្រុង។ ដោយសាររដ្ឋនៅតំបន់អាស៊ីអាគ្នេយ៍មួយចំនួនតូចប៉ុណ្ណោះ ដែលបានផ្តល់សច្ចាប័នលើអនុសញ្ញាជនភៀសខ្លួន ជនភៀសខ្លួននៅទីក្រុងភាគច្រើនកំពុងរងចាំការទទួលស្គាល់ពី UNHCR ក្នុងក្តីសង្ឃឹមក្នុងការតាំងទីលំនៅនៅតតិយប្រទេស ទោះបីជានីតិវិធីនេះត្រូវចំណាយពេលរាប់ឆ្នាំក៏ដោយ។ ខណៈពេលដែលពួកគេរងចាំ ជនភៀសខ្លួនទាំងនេះជារឿយៗរស់នៅក្នុងមន្ទីរឃុំឃាំងស្របច្បាប់ ហើយអាចត្រូវបាននិរទេសចេញពីប្រទេសនៅពេលណាមួយក៏បាន។ ជនភៀសខ្លួនរស់នៅទីក្រុង ជួបប្រទះនឹងការរំលោភបំពានសិទ្ធិមនុស្សជាច្រើន។ ជារឿយៗពួកគេប្រឈមនឹងការគម្រាមកំហែងសន្តិសុខជាចម្បង (ជាឧទាហរណ៍ ពីការចាប់ខ្លួន និងការឃុំខ្លួនដោយមន្ត្រីមូលដ្ឋានដោយសារពួកគេមិនមានឯកសារ)។ ទោះបីជាពួកគេមានប័ណ្ណ "បុគ្គលងាយរងគ្រោះ" ពី UNHCR ក៏ដោយ ក៏នេះមិនអាចធានានូវសេរីភាពរួចផុតពីការចាប់ខ្លួននោះទេ។ បន្ថែមពីនេះទៀត គ្រួសាររបស់ពួកគេមិនមានលទ្ធភាព ក្នុងការទទួលបានការថែទាំសុខភាព ឬការអប់រំនោះទេ។ ខណៈពេលដែលពួកគេអាចស្វែងរកការងារ ការងារទាំងនេះស្ថិតក្នុងវិស័យមិនរៀបរយដែលមានប្រាក់ឈ្នួលទាប និងហានិភ័យខ្ពស់។

### ផ្តោតសំខាន់លើ

(TBC) សម្ព័ន្ធព្រំដែនថៃ

TBC ជាអង្គការមនុស្សធម៌ដែលធ្វើការដើម្បីការការពារ និងលើកកម្ពស់សិទ្ធិជនភៀសខ្លួនតាមបណ្តោយព្រំដែនថៃ និងភូមា។ ព្រំដែនថៃ និងភូមាជាផ្ទះរបស់ជនភៀសខ្លួនដែលបានចុះបញ្ជីចំនួន ៩២ ០០០ នាក់ពីប្រទេសមីយ៉ាន់ម៉ា ព្រមទាំងប្រជាជនដែលត្រូវបានជម្លៀសដែលមិនបានចុះបញ្ជី និងសុំសិទ្ធិជ្រកកោនរាប់ម៉ឺននាក់ទៀតដែលទទួលសេវាកម្មពី TBC។

ត្រូវបានបង្កើតឡើង ដើម្បីឆ្លើយតបនឹងលំហូរនៃជនភៀសខ្លួនភូមារត់ភៀសខ្លួនទៅប្រទេសថៃក្នុងឆ្នាំ ១៩៨៤ TBC ជាសម្ព័ន្ធនៃអង្គការអន្តរជាតិចំនួន ១២ ពីប្រទេសចំនួន ១០ផ្សេងៗគ្នា។ TBC ធ្វើការជាចម្បងក្នុងការគាំទ្រឲ្យមានស្តង់ដារជីវភាពគ្រប់គ្រាន់ក្នុងជំរុំតាមរយៈការផ្តល់សេវាកម្ម និងចំណីអាហារ សម្រួលសេវាកម្មសុខភាព និងការអប់រំ ជួយការអភិវឌ្ឍសហគមន៍ ធ្វើការជាមួយនឹងភ្នាក់ងារជនភៀសខ្លួនក្នុងការតាំងទីលំនៅឡើងវិញរបស់ជនភៀសខ្លួន ខណៈពេលនោះផងដែរក៏ចូលរួមក្នុងការស្រាវជ្រាវផងដែរ។ វត្តមានរបស់ TBC នៅទីកន្លែងនេះ និងបណ្តាញអន្តរជាតិអនុញ្ញាតឲ្យពួកគេធ្វើសកម្មភាពជាបណ្តាញទំនាក់ទំនងក្នុង និងក្រៅជំរុំ។

## ៦.៨.១ អង្គការជនភៀសខ្លួន៖ UNHCR

UNHCR ត្រូវបានបង្កើតឡើងជាមួយនឹងអាណត្តិក្នុងការការពារ ជួយ និងស្វែងរកដំណោះស្រាយដល់ជនភៀសខ្លួន។ អាណត្តិត្រូវបានសេរសរឡើងដំបូងឡើយក្នុងទសវត្សឆ្នាំ ១៩៥០ ហើយបានពង្រីកជាបន្តបន្ទាប់ក្នុងអំឡុងពេលប៉ុន្មានទសវត្សនេះជាឧទាហរណ៍ ដើម្បីរួមបញ្ចូលប្រជាជនគ្មានសញ្ជាតិ និងដើម្បីផ្តល់ជំនួយមនុស្សធម៌។ UNHCR ចូលរួមក្នុងសកម្មភាពចាប់តាំងពីការសហការជាមួយរដ្ឋ និងការតស៊ូមតិរហូតដល់ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព ការផ្តល់ចំណីអាហារ និង

ជម្រកដល់ប្រជាជនដែលមានទុក្ខកង្វល់។ តាមរយៈអាណត្តិបច្ចុប្បន្ននេះ ខាងក្រោមនេះជាសកម្មភាពទូទៅមួយចំនួនរបស់ UNHCR៖

- ស្វែងរកដំណោះស្រាយយូរអង្វែងដល់ស្ថានភាពជនភៀសខ្លួន៖ ស្វែងរកមធ្យោបាយសម្រាប់បុគ្គលក្នុងការចាកចេញពីឋានៈជាជនភៀសខ្លួន ទៅជាទម្រង់ផ្សេងនៃការការពារ។ យោងទៅតាម UNHCR កិច្ចការនេះអាចសម្រេចបានតាមរយៈមួយក្នុងចំណោមមធ្យោបាយខាងក្រោម៖

    - ***សមាហរណកម្មក្នុងមូលដ្ឋាន*** បុគ្គលត្រូវបានធ្វើសមាហរណកម្ម និងក្លាយជាពលរដ្ឋនៃប្រទេស ដែលពួកគេទាមទារឋានៈជាជនភៀសខ្លួន។ ជាឧទាហរណ៍ គ្រួសារប៉ាគីស្ថាន អាម៉ាឌីយ៉ាមួយបានទាមទារឋានៈជាជនភៀសខ្លួនក្នុងប្រទេសអូស្ត្រាលី ដែលត្រូវបានអនុញ្ញាតដោយរដ្ឋាភិបាល បន្ទាប់មកពួកគេក្លាយជាពលរដ្ឋអូស្ត្រាលី បញ្ចប់នូវឋានៈជាជនភៀសខ្លួនរបស់ពួកគេ។ ជាការពិតជាក់ស្តែង នេះជាដំណោះស្រាយយូរអង្វែងដែលកម្រនឹងមាន។ ការធ្វើសមាហរណកម្មមូលដ្ឋាន ប្រហែលជាដំណោះស្រាយយូរអង្វែងដែលត្រូវបានប្រើប្រាស់តិចតួចបំផុត ដោយសារតែមិនមានប្រទេសនៅអាស៊ីអាគ្នេយ៍គាំទ្រដំណោះស្រាយនេះឡើយ។

    - ***ការតាំងទីលំនៅឡើងវិញ៖*** បុគ្គលដែលត្រូវបានតាំងទីលំនៅក្នុងតតិយប្រទេស។ ជាឧទាហរណ៍ ជនភៀសខ្លួនភូមានជាច្រើនក្នុងប្រទេសថៃបានតាំងទីលំនៅឡើងវិញនៅសហរដ្ឋអាមេរិក ស៊ុយអែត ឬណ័រវេស ហើយបានក្លាយជាពលរដ្ឋនៅទីនោះ។

    - ***មាតុភូមិនិវត្តន៍ ៖*** បុគ្គលដែលបានតាំងទីលំនៅឡើងវិញទៅប្រទេសរបស់ខ្លួនបន្ទាប់ពីការគម្រាមកំហែងនៃការធ្វើទុក្ខបុកម្នេញត្រូវបានបញ្ចប់។ ជាឧទាហរណ៍ ស្ថានភាពនេះបានកើតឡើងនៅពេលបញ្ចប់ជម្លោះក្នុងប្រទេសកម្ពុជានៅដើមទសវត្សឆ្នាំ១៩៩០ ហើយជនភៀសខ្លួនដែលរស់នៅក្នុងជំរុំក្នុងប្រទេសថៃត្រូវបានធ្វើមាតុភូមិនិវត្តន៍។ ប្រសិនជាប្រទេសមីយ៉ាន់ម៉ាមានស្ថេរភាពនយោបាយ នៅក្នុងរយៈពេល១០ឆ្នាំទៀត ជនជាតិភូមាដែលរស់នៅក្នុងជំរុំក្នុងប្រទេសថៃនឹងត្រូវបានធ្វើមាតុភូមិនិវត្ត ន៍ទៅប្រទេសមីយ៉ាន់ម៉ាវិញ នៅពេលដែលមានការធានាថាមានសុវត្ថិភាពគ្រប់គ្រាន់។

- ការឆ្លើយតបនឹងស្ថានភាពអាសន្ន នឹងជំនួយមនុស្សធម៌៖ UNHCR មានភាពល្បីល្បាញក្នុងកិច្ចការជួយប្រជាជន ដែលត្រូវបានជម្លៀសខ្លួនដោយសារជម្លោះ ឬបាតុភូតធម្មជាតិ។ ក្នុងអំឡុងពេលបាតុភូតធម្មជាតិនៅអាស៊ីអាគ្នេយ៍ (ជាឧទាហរណ៍

ស៊ូណាមិ ក្នុងឆ្នាំ ២០០៤) UNHCR បានផ្តល់ចំណីអាហារ និងជម្រកដល់ប្រជាជនជាច្រើន។

- ការការពារជនភៀសខ្លួន៖ UNHCR ធ្វើការក្នុងការការពារជនភៀសខ្លួនមិនខ្វល់ថាពួកគេនៅទីណានោះទេ។ ជាទូទៅសម្រាប់អង្គការនេះធ្វើការក្នុងប្រទេសដែលមិនបានផ្តល់សច្ចាប័នលើអនុសញ្ញាជនភៀសខ្លួន ដោយសារខ្លួនមានអាណត្តិដែលអនុញ្ញាតឲ្យអង្គការនេះធ្វើការដើម្បី ទទួលស្គាល់ឋានៈជនភៀសខ្លួន។ ជនភៀសខ្លួនទាំងនេះត្រូវបានហៅថា "ជនភៀសខ្លួនក្រោមអាណត្តិ" ដែលផ្ទុយនឹងជនភៀសខ្លួនតាមអនុសញ្ញា ដែលត្រូវបានការពារដោយអនុសញ្ញាជនភៀសខ្លួន។ យ៉ាងណាមិញ ការទទួលស្គាល់របស់ UNHCR មិនមែនមានន័យថារដ្ឋាភិបាលត្រូវតែទទួលស្គាល់ឋានៈនេះនោះទេ។ ផ្ទុយទៅវិញ ប្រជាជនទាំងនេះនៅតែ "បុគ្គលងាយរងគ្រោះ" ដូចនេះនឹងទទួលបានជំនួយពី UNHCR និងអាចទទួលបានដំណោះស្រាយយូរអង្វែង។

អាណត្តិ និងសកម្មភាពរបស់ UNHCR អាចមានដែនកំណត់អាស្រ័យលើរដ្ឋដែល UNHCR មានវត្តមាន នេះអាចកាត់បន្ថយតួនាទីរបស់អង្គការនេះមកត្រឹមជាប្រឹក្សា និងផ្តល់សេវាកម្មប៉ុណ្ណោះ។ លើសពីនេះទៀត UNHCR មិនអាចទទួលបណ្តឹងបុគ្គលបាននោះទេ ហើយក៏មិនមាននីតិវិធីរបាយការណ៍សម្រាប់ការការពារជនភៀសខ្លួននោះទេ។ យ៉ាងណាមិញ ប៉ុន្មានឆ្នាំកន្លងទៅនេះ UNHCR បានពង្រីកអាណត្តិរបស់ខ្លួនដើម្បីបញ្ចូល បុគ្គលមានស្ថានភាពដូចគ្នានឹងជនភៀសខ្លួន បុគ្គលដែលត្រូវបានជម្លៀសក្នុងប្រទេស ជនគ្មានសញ្ជាតិ អ្នកវិលត្រលប់មកវិញ និង បុគ្គលងាយរងគ្រោះដទៃទៀត។

## ៦.៤.២. អង្គការជនភៀសខ្លួន៖ អង្គការសង្គមស៊ីវិល

រដ្ឋាភិបាលនៅក្នុងតំបន់មិនបានឆ្លើយតបនឹងការទទួលខុសត្រូវរបស់ខ្លួន ក្នុងការផ្តល់ការការពារ និងតម្រូវការដល់ជនភៀសខ្លួននោះទេ។ ដោយសាររដ្ឋភាគច្រើនមិនបានផ្តល់សច្ចាប័នលើអនុសញ្ញាជនភៀសខ្លួន ពួកគេមានភាពស្ទាក់ស្ទើរក្នុងការទទួលស្គាល់សិទ្ធិ មិនមានភាពប្រុងប្រយ័ត្នក្នុងការបង្ហាញ ការគាំទ្រខ្លាំងពេកដោយមានជំនឿថានេះអាចទាក់ទាញជនភៀសខ្លួនកាន់តែច្រើន ឬត្រូវបានចាត់ទុកថាជាការខ្ជះខ្ជាយថវិកាដោយពលរដ្ឋរបស់ខ្លួន ជាលទ្ធផល សេវាគាំទ្រជនភៀសខ្លួនភាគច្រើនធ្លាក់ចូលក្នុងទំនួលខុសត្រូវរបស់តួអង្គសង្គមស៊ីវិល ដូចជា NGOs ក្នុងស្រុក។ មានកិច្ចការជាច្រើនដែលត្រូវបំពេញក្នុងការផ្តល់សេវា ការការពារ និងការលើកកម្ពស់សិទ្ធិជនភៀសខ្លួនក្នុងតំបន់។ ការងារចម្បងៗដែលបំពេញដោយសង្គមតួអង្គស៊ីវិលរួមមាន៖

- ***ផ្តល់ស្តង់ដារជីវភាព៖*** ជនភៀសខ្លួនភាគច្រើនមិនត្រូវបានអនុញ្ញាតឲ្យធ្វើការ ហើយពួកគេត្រូវការចំណីអាហារ លំនៅដ្ឋាន និងសន្តិសុខសេដ្ឋកិច្ច។ NGOs ខ្លះធ្វើការក្នុងវិស័យនេះក្នុងការផ្តល់សេវាកម្មតាមរយៈមានកញ្ចប់ចំណីអាហារ ឬជម្រកដែលជនភៀសខ្លួនអាចស្នាក់នៅ។ សម្រាប់ជនភៀសខ្លួននៅជំរុំក្នុងប្រទេសថៃ TBC ចូលរួមក្នុងការផ្តល់ស្តង់ដារជីវភាពដល់មនុស្សជាង ១០០ ០០០ ជារៀងរាល់ថ្ងៃ។

- ***ជំនួយផ្នែកច្បាប់៖*** ការទាមទារឋានៈជាជនភៀសខ្លួន ជានីតិវិធីច្បាប់ ហើយជនភៀសខ្លួនត្រូវការជំនួយ ក្នុងការធ្វើការទាមទារដោយប្រមូលព័ត៌មានដើម្បីបង្ហាញថាពួកស្ថិតក្នុងក្នុងនិយមន័យនៃអនុសញ្ញា។ ទោះបីជាប្រទេសនៅអាស៊ីអាគ្នេយ៍ភាគច្រើន មិនបានផ្តល់សច្ចាប័នលើអនុសញ្ញាជនភៀសខ្លួនក៏ដោយ ជនភៀសខ្លួននៅតែត្រូវប្រមូលឯកសារ សម្រាប់ការទាមទាររបស់ពួកគេ ដូចនេះពួកគេអាចត្រូវបានទទួលស្គាល់ដោយតតិយប្រទេស (ដូចជាអូស្ត្រាលី ឬកាណាដា) ឬ UNHCR។ លើសពីនេះទៀត ពួកគេអាចត្រូវការជំនួយផ្នែកច្បាប់ដើម្បីធានាថាពួកគេមិនត្រូវបានធ្វើនិរទេសចេញ ពីប្រទេសដែលពួកគេកំពុងមានវត្តមាន ឬប្រសិនបើពួកគេប្រឈមនឹងការឃុំខ្លួន ដោយសារតែឋានៈមិនមានឯកសាររបស់ពួកគេ។

- ***ការតស៊ូមតិ៖*** NGOs មួយចំនួនធ្វើការលើការតស៊ូមតិសម្រាប់ការគោរពជនភៀសខ្លួន និងការទទួលស្គាល់សិទ្ធិរបស់ពួកគេ។ នេះអាចរួមមានទាំងការដាក់សំពាធលើរដ្ឋាភិបាល ក្នុងការគោរពសិទ្ធិរបស់ជនភៀសខ្លួនក្នុងប្រទេសរបស់ខ្លួន ហើយនឹងមិនបញ្ជូនពួកគេត្រលប់ទៅវិញនោះទេ។ នេះមានន័យថាប្រាស្រ័យទាក់ទងជាមួយនឹងសហគមន៍មូលដ្ឋានផងដែរ ដូចនេះពួកគេគាំទ្រសិទ្ធិជនភៀសខ្លួន និងមិនរើសអើងលើពួកគេ។

- ***សុខភាព៖*** ក្រៅពីកង្វល់សុខភាពជាទូទៅពាក់ព័ន្ធនឹងប្រជាជនរស់នៅក្នុងបរិស្ថានដែលមិនមានសុវត្ថិភាព ជនភៀសខ្លួនភាគច្រើនបានជួបប្រទះនឹងការឈឺចាប់។ ពួកគេបានរត់ភៀសខ្លួនពីប្រទេសរបស់ខ្លួន ដោយសារពួកគេបានប្រឈមនឹងការធ្វើទុក្ខបុកម្នេញ។ ដោយសារហេតុផលនេះជនភៀសខ្លួនមួយចំនួនត្រូវការជំនួយសុខភាពផ្លូវចិត្ត។

- ***ការអប់រំ និងការបណ្តុះបណ្តាល៖*** ចំពោះគ្រួសារជនភៀសខ្លួន អាចជាការប្រឈមក្នុងការស្វែងរកការអប់រំសម្រាប់កូនៗរបស់ពួកគេ។ មិនមានសុវត្ថិភាពសម្រាប់កុមារក្នុងការធ្វើដំណើរនោះទេ ការអប់រំគឺក្នុងភាសាផ្សេង ហើយមុខវិជ្ជាដែលបង្រៀនប្រហែលជាខុសគ្នាផងដែរ។ NGOs ខ្លះផ្តល់ការថែទាំកុមារ ឬមេរៀនជាមូលដ្ឋានដល់កុមារ។ ពួកគេអាចធ្វើការជាមួយសាលាក្នុងតំបន់ដើម្បីផ្តល់កន្លែង និងជំនួយពិសេសសម្រាប់កុមារភៀសខ្លួនផងដែរ។

អង្គការទាំងនេះធ្វើការក្នុងបរិបទដែលមានការប្រឈមមួយ។ ពួកគេកំពុងធ្វើការជាមួយប្រជាជនដែលមានឋានៈជាប្រជាជនមិនមានឯកសារ ហើយដូចនេះអាចត្រូវបានចាត់ទុកថាពាក់ព័ន្ធជាមួយនឹងឧក្រិដ្ឋជនដោយរដ្ឋាភិបាលមួយចំនួន។ រដ្ឋាភិបាល និងពលរដ្ឋជាច្រើនរើសអើងលើជនភៀសខ្លួន និង មិនចូលចិត្តដែលអង្គការទាំងនេះចំណាយថវិកាលើពួកគេ។ អង្គការជនភៀសខ្លួនមានធនធានដែលមានកម្រិតក្នុងការដោះស្រាយកិច្ចការធំៗ។

## ករណីសិក្សា

### ការឆ្លើយតបនឹងជនភៀសខ្លួនរស់នៅទីក្រុងក្នុងប្រទេសថៃ

ការពិបាកប្រឈមដោយជនភៀសខ្លួននៅទីក្រុងជារឿយៗ ខុសគ្នាពីអ្វីដែលជាការប្រឈមរបស់ជនភៀសខ្លួននៅជំរុំ ប៉ុន្តែមិនស្រាលជាងនោះទេ។ ជនភៀសខ្លួនដែលរស់នៅទីក្រុងមានតម្រូវការមួយចំនួន ពួកគេមានតម្រូវការស្តង់ដារជាមូលដ្ឋាននៃចំណីអាហារ និងទីលំនៅ។ អង្គការមួយចំនួនអាចរៀបចំទីជម្រកសម្រាប់ជនភៀសខ្លួន និងក្រុមគ្រួសាររបស់ពួកគេ ឬផ្តល់ជូនពួកគេនូវចំណីអាហារ ទោះបីជាក្នុងករណីភាគច្រើន តម្រូវការរបស់សហគមន៍ច្រើនពេកសម្រាប់ធនធានមានកម្រិតនៃអង្គការជនភៀសខ្លួន។

កុមារភៀសខ្លួនមានតម្រូវការការអប់រំ។ ពួកគេគួរតែត្រូវបានផ្តល់ជូននូវការអប់រំថ្នាក់បឋមសិក្សាដោយមិនបង់ថ្លៃ និងជាការតម្រូវដាច់ខាត ប៉ុន្តែនេះមិនតែងតែត្រូវបានផ្តល់ជូននោះទេ។ ការអប់រំភាគច្រើនក្នុងភាសាផ្សេងដែលពួកគេមិនយល់ ហើយការធ្វើដំណើរទៅ និងពីសាលារៀនអាចមានគ្រោះថ្នាក់ប្រសិនជាឪពុកម្តាយកុមារនោះមិនមានឯកសារ។ ជនភៀសខ្លួនដែលរស់នៅទីក្រុងជារឿយៗត្រូវការជំនួយផ្នែកច្បាប់ជាពិសេសក្នុងការរៀបចំការទាមទារឋានៈជាជនភៀសខ្លួនរបស់ពួកគេ។ បន្ថែមពីលើនេះទៀត អង្គការទាំងនេះអាចជួយជនភៀសខ្លួនដែលត្រូវបានឃុំខ្លួន និងប្រឈមនឹងការនិរទេស។

សុខភាពផ្លូវចិត្តជាកត្តាផ្សេងទៀតដែលអាចជាតម្រូវការខ្លាំងក្លា។ ដោយហេតុថាជនភៀសខ្លួនជារឿយៗចាកចេញពីស្ថានភាពដែលជាការឈឺចាប់ បញ្ហាមិនប្រក្រតីដោយសារជម្ងឺស្ត្រេសគឺជារឿងធម្មតាដែលពួកគេតែងតែមាន ធ្វើឲ្យមានជម្ងឺផ្លូវចិត្តធ្ងន់ធ្ងរ។ អង្គការអាចផ្តល់សេវាប្រឹក្សា និងក្នុងករណីខ្លះការថែទាំសុខភាពដល់ប្រជាជនដើម្បីព្យាបាលជម្ងឺផ្លូវចិត្តនេះដល់ពួកគេ។

## ៦.៨ ជនគ្មានសញ្ជាតិ

'គ្មានសញ្ជាតិ' មានន័យថាមិនមានរដ្ឋចាត់ទុកអ្នកថាជាពលរដ្ឋនៅក្នុងច្បាប់របស់រដ្ឋនេះនោះទេ។ ភាពជាពលរដ្ឋ និងសញ្ជាតិ ជាមូលដ្ឋានក្នុងការធានាថាបុគ្គលអាចអនុវត្តសិទ្ធិមនុស្សរបស់ពួកគេ។ មិនមែនជាពលរដ្ឋមានន័យថាបុគ្គលអាចបាត់បង់សេវាកម្មដែលរដ្ឋត្រូវតែផ្តល់ជូន ដូចជាសុខភាព ការអប់រំ ឯកសារដូចជាលិខិតឆ្លងដែន ប័ណ្ណបើកបរ ។ល។ បុគ្គលនេះអាចបាត់បង់នូវការការពារផ្លូវច្បាប់ផងដែរដោយសារពួកគេមិនអាចទៅរកប៉ូលីសដើម្បីជួយពួកគេនោះទេ ដោយសារភ័យខ្លាចប៉ូលីសចាប់។ ប្រជាជនគ្មានសញ្ជាតិអាចប្រឈមការលំបាកក្នុងការធ្វើដំណើរដោយសារពួកគេមិនមានឯកសារ និងអត្តសញ្ញាណចាំបាច់។ សូម្បីតែបន្ទាប់ពីទទួលមរណៈភាព ពួកគេត្រូវបានបដិសេធក្នុងការចេញនូវសំបុត្រមរណៈភាព ដូចនេះអាចកើតមានដែលថាពួកគេមិនមានកំណត់ត្រានៃជីវិតរបស់ពួកគេ។ ដូចដែលឧទាហរណ៍ទាំងនេះបង្ហាញប្រជាជនគ្មានសញ្ជាតិ អាចប្រឈមការរំលោភបំពានមួយជីវិតតែម្តងតាមមធ្យោបាយជាច្រើន។

សិទ្ធិក្នុងការទទួលបានភាពជាពលរដ្ឋមាននៅក្នុងមាត្រា ១៥ នៃ UDHR ដែលបានចែងថា " មនុស្សគ្រប់រូបមានសិទ្ធិមានសញ្ជាតិមួយ" និង"មិនមានជនណាម្នាក់ត្រូវបានដកហូតសញ្ជាតិតាមទំនើងចិត្តនោះទេ"។ យ៉ាងណាមិញ ទោះបីជាបន្ទាប់ពីការអនុម័ត UDHR ក៏ដោយ ពិភពលោកមិនទាន់បានយកចិត្តទុកដាក់ឲ្យបានជិតដល់ដាក់បញ្ហាជនគ្មានសញ្ជាតិនេះនៅឡើយទេ។ ខណៈពេលដែលមានប្រជាជនគ្មានសញ្ជាតិជាច្រើនបន្ទាប់ពីសង្គ្រាមលោកលើកទីពីរ នៅពេលដែលកង្វល់នេះត្រូវបានដោះស្រាយមានសកម្មភាពតិចតួចប៉ុណ្ណោះក្នុងបញ្ហានេះ។ ជាឧទាហរណ៍ អនុសញ្ញាស្តីពីជនគ្មានសញ្ជាតិមិនត្រូវបានអើពើនោះទេ ហើយមានរដ្ឋចំនួនតិចតួចប៉ុណ្ណោះដែលបានផ្តល់សច្ចាប័ន។ ទើបតែកាលពីពេលថ្មីៗនេះ អង្គការមួយចំនួនបានដោះស្រាយបញ្ហានេះ ហើយមានការយកចិត្តទុកដាក់មួយចំនួនលើជនភៀសខ្លួន និងការជួញដូរ។ ហេតុផលគឺសាមញ្ញ ជនគ្មានសញ្ជាតិពិបាកក្នុងការកំណត់អត្តសញ្ញាណណាស់ ហើយដូចនេះទើបមិនត្រូវបានអើពើ។ ប្រជាជនគ្មានសញ្ជាតិភាគច្រើនរស់នៅតាមព្រំដែនដែលរដ្ឋអាចគ្រប់គ្រងបានដោយផ្នែកប៉ុណ្ណោះ ឬពួកគេលាក់ខ្លួនក្នុងសង្គមដោយសារពួកគេមិនចង់ឲ្យឋានៈមិនមានឯកសាររបស់ពួកគេ ត្រូវបានដឹងលឺដោយអាជ្ញាធរមានសមត្ថកិច្ចនោះទេ។ សម្រាប់ហេតុផលនេះ ជាការពិបាកក្នុងការរាប់ចំនួនពិតប្រាកដនៃប្រជាជនគ្មានសញ្ជាតិណាស់។ បច្ចុប្បន្នតាមការប៉ាន់ប្រមាណមានប្រជាជនគ្មានសញ្ជាតិចំនួន ១២លាននាក់ក្នុងពិភពលោក នេះបើយោងទៅតាម UNHCR នៅអាស៊ីអាគ្នេយ៍មានប្រហែលជារាប់សែន ឬជាងមួយលាន់នាក់។ ទើបតែកាលពីពេលថ្មីៗនេះ ទើប

មានចំណាប់អារម្មណ៍ និងការកើនឡើងសកម្មភាពលើការការពារសិទ្ធិរបស់ប្រជាជនគ្មានសញ្ជាតិ។

## ផ្តោតសំខាន់លើ

### ឧទាហរណ៍នៃភាពគ្មានសញ្ជាតិក្នុងអាស៊ីអាគ្នេយ៍

ប្រ៊ុយណេ៖ ភាពគ្មានសញ្ជាតិមានក្នុងចំណោមជនជាតិចិនដែលរស់នៅជាអចិន្ត្រៃយ៍ក្នុងប្រទេសប្រ៊ុយណេ។ គ្រួសារដែលបានរស់នៅក្នុងប្រទេសប្រ៊ុយណេជាច្រើនជំនាន់មកហើយនៅតែមិនត្រូវបានផ្តល់សញ្ជាតិ ដោយសារសញ្ជាតិប្រ៊ុយណេគឺយោងទៅតាមឈាមជ័រ ឬសមត្ថភាពក្នុងការជាប់ការធ្វើតេស្តភាពជាពលរដ្ឋដ៏ពិបាកបំផុតពីវប្បធម៌ ទំនៀទំលាប់ និងភាសា។ ជនជាតិចិននៅប្រ៊ុយណេភាគច្រើននឹងនៅតែគ្មានសញ្ជាតិ ប្រសិនបើមិនមានវិសោធនកម្មច្បាប់ទេនោះ។

មីយ៉ាន់ម៉ា៖ ជនជាតិ Rohingya ជាពលរដ្ឋរបស់មីយ៉ានម៉ារហូតដល់ច្បាប់សញ្ជាតិបានផ្លាស់ប្តូរក្នុងឆ្នាំ ១៩៨២ ដែលបានដកហូតភាពជាពលរដ្ឋរបស់ពួកគេ។ មានជនជាតិ Rohingya គ្មានសញ្ជាតិចំនួន ៦០០ ០០០ នាក់ពេលបច្ចុប្បន្នក្នុងប្រទេសមីយ៉ាន់ម៉ា។

ឥណ្ឌូនេស៊ី៖ កាលពីមុន ប្រសិនជាជនជាតិឥណ្ឌូនេស៊ីរបស់នៅខាងក្រៅប្រទេសដោយមិនត្រលប់មកវិញក្នុងអំឡុងពេលប្រាំឆ្នាំទេនោះ ពួកគេនឹងបាត់បង់សញ្ជាតិរបស់ខ្លួន។ ពលករទេសន្តប្រវេសន៍ឥណ្ឌូនេស៊ីជាច្រើនពាន់នាក់ដែលរស់នៅបរទេសបានក្លាយទៅជាគ្មានសញ្ជាតិដោយសារតែច្បាប់នេះ។ ច្បាប់នេះត្រូវបានផ្លាស់ប្តូរដោយសារកង្វល់ដែលបានលើកឡើងពីជនជាតិឥណ្ឌូនេស៊ីគ្មានសញ្ជាតិ។

ឡាវ មីយ៉ាន់ម៉ា ថៃ៖ សហគមន៍កុលសម្ព័ន្ធភ្នំ បណ្តោយព្រំដែនរវាងថៃ ឡាវ និងមីយ៉ាន់ម៉ាមិនត្រូវបានទទួលស្គាល់ថាជាពលរដ្ឋ របស់រដ្ឋណាមួយក្នុងចំណោមប្រទេសទាំងនេះនោះទេ ទោះបីជាពួកគេបានរស់នៅទីនេះអស់ជាច្រើនជំនាន់មកហើយក៏ដោយ។ កាលពីមុន នៅក្នុងប្រទេសថៃ ប្រជាជនកុមសម្ព័ន្ធលើភ្នំអាចត្រូវបានទទួលស្គាល់លុះត្រាពួកគេអាចបញ្ជាក់ថា ពួកគេនៅក្នុងប្រទេសថៃកាលពីជំរឿនក្នុងឆ្នាំ ១៩៥៦ ប៉ុណ្ណោះ។ ប្រសិនជាពួកគេមិនមានឯកសារពួកគេនឹងក្លាយគ្មានសញ្ជាតិ។ ច្បាប់នេះបានផ្លាស់ប្តូរដោយសារកង្វល់ដែលបានលើកឡើងពីភាពគ្មានសញ្ជាតិ។

ថៃ៖ កូនរបស់ពលករទេសន្តប្រវេសន៍ដែលមិនមានចុះបញ្ជីកំណើតមានការលំបាកនិងពេលខ្លះមិនអាចទាមទារសញ្ជាតិពីប្រទេសមីយ៉ាន់ម៉ាន បានឡើយដោយសារមិនមានសំបុត្រកំណើត។

វៀតណាម៖ ស្ត្រីជនជាតិវៀតណាមដែលរៀបការជាមួយនឹងជនបរទេស ហើយចូលសញ្ជាតិដទៃ ត្រូវតែលាលែង ឬលះបង់សញ្ជាតិវៀតណាមរបស់ខ្លួន (ដោយសារប្រទេសវៀតណាមអនុញ្ញាតឲ្យមានសញ្ជាតិតែមួយប៉ុណ្ណោះ)។ យ៉ាងណាមិញ ប្រសិនជាការរៀបការបរាជ័យ គាត់នឹងបាត់បង់សញ្ជាតិប្តីរបស់គាត់ ប៉ុន្តែមិនទទួលសញ្ជាតិវៀតណាមវិញដោយស្វ័យប្រវត្តិនោះទេ។ បញ្ហានេះបានកើតឡើងជាច្រើនលើកច្រើនសារចំពោះស្ត្រីជនជាតិវៀតណាមដែលបានរៀបការជាមួយប្តីជនជាតិតៃវ៉ាន់ និងក្លាយជាសញ្ជាតិតៃវ៉ាន់។ កាលពីមុនវៀតណាមមិនអនុញ្ញាតឲ្យមានសញ្ជាតិពីរនោះទេ ហើយក៏មិនអនុញ្ញាតប្រជាជនរបស់ខ្លួនដែលបានបាត់បង់សញ្ជាតិខ្លួនហើយ ឲ្យមានសញ្ជាតិវិញនោះទេ។ ស្ថានភាពនេះត្រូវបានផ្លាស់ប្តូរក្នុងឆ្នាំ ២០០៨ ប៉ុណ្ណោះជាមួយនឹងការអនុម័តច្បាប់សញ្ជាតិថ្មី ដោយសារមានការលើកឡើងពីកង្វល់នៃស្ត្រីវៀតណាមគ្មានសញ្ជាតិ។

## ៦.៨.១ កំណត់និយមន័យគ្មានសញ្ជាតិ

គ្មានសញ្ជាតិត្រូវបានកំណត់និយមន័យក្នុងមាត្រា ១ នៃអនុសញ្ញាឆ្នាំ ១៩៥៤ ពាក់ព័ន្ធនឹងឋានៈរបស់ជនភៀសខ្លួនដូចខាងក្រោម៖

> បុគ្គលដែលមិនត្រូវបានចាត់ទុកថាជាសញ្ជាតិដោយរដ្ឋណាមួយតាមដែនកំណត់នៃច្បាប់របស់ខ្លួន។

និយមន័យនេះមានលក្ខណៈសាមញ្ញ ទោះបីជាធាតុផ្សំសំខាន់ខ្លះត្រូវតែធ្វើការស្វែងយល់ក៏ដោយ។ និយមន័យនេះត្រូវបានចាត់ទុកថាជាផ្នែកមួយនៃច្បាប់ទំនៀមទំលាប់ ដូចនេះមិនមានរដ្ឋអាចបដិសេធ នូវវត្តមានរបស់ប្រជាជនគ្មានសញ្ជាតិនោះឡើយ ឬក៏មាននិយមន័យផ្ទុយនោះទេ។ ធាតុផ្សំសំខាន់មាន៖

ជាដំបូង មានតែរដ្ឋប៉ុណ្ណោះដែលអាចផ្តល់សញ្ជាតិ។ ប្រជាជនដែលរស់នៅក្នុងតំបន់ដែលមិនត្រូវបានចាត់ទុកថាជារដ្ឋ ឬរដ្ឋដែលទើបតែបង្កើតថ្មី អាចប្រឈមនឹងការលំបាកក្នុងការទទួលស្គាល់ថាជាពលរដ្ឋ។ ដើម្បីកំណត់ថាតើបុគ្គលម្នាក់គ្មានសញ្ជាតិឬក៏អត់ មិនចាំបាច់ក្នុងការពិនិត្យមើលរដ្ឋទាំងអស់ ១៩៣ ថាពួកគេទទួលស្គាល់បុគ្គលនោះឬក៏អត់នោះទេ។ ផ្ទុយទៅវិញ រដ្ឋនីមួយៗដែលបុគ្គលនោះមានទំនាក់ទំនងតាមរយៈកំណើត ឪពុកម្តាយ លំនៅ ឬអាពាហ៍ពិពាហ៍អាចត្រូវបានពិចារណាដើម្បីផ្តល់សញ្ជាតិដល់បុគ្គលនោះ។ ជាការសំខាន់ផងដែរ ក្នុងការពិនិត្យលើលក្ខខណ្ឌដែលរដ្ឋ

ទទួលស្គាល់ មានន័យថាតើក្រសួងណា ឬឯកសារអ្វីដែលចាំបាច់ដើម្បីឲ្យបុគ្គលត្រូវបានទទួលស្គាល់ថាជាពលរដ្ឋ។ រដ្ឋាភិបាលប្រហែលជាមិនមានធនធាន និងថវិកាគ្រប់គ្រាន់ដើម្បីផ្តល់ឯកសារដូចជាលិខិតឆ្លងដែន ឬសំបុត្រកំណើត ឬសម្រេចក្នុងការផ្តល់ជូនពួកគេដោយមានការរើសអើងណាមួយ។

## ទស្សនៈទាន

### សញ្ជាតិ

ពាក្យ 'សញ្ជាតិ' 'ពលរដ្ឋ' និង 'ប្រធាននីតិ' គឺជាទស្សនៈស្រដៀងគ្នាដែលមានន័យថាដូចគ្នា៖ ពាក្យទាំងនេះបង្កើតនូវការផ្សាភ្ជាប់ទំនាក់ទំនង ទាំងនយោបាយ និងផ្លូវច្បាប់រវាងបុគ្គល និងរដ្ឋ។ សញ្ជាតិអនុញ្ញាតឲ្យបុគ្គលក្នុងការទទួលបានការការពារពីរដ្ឋ ហើយពួកគេមានកាតព្វកិច្ចចំពោះរដ្ឋ។ មានភាពខុសគ្នាមួយចំនួននៅក្នុងរដ្ឋមួយរវាងពលរដ្ឋ និងសញ្ជាតិ ហើយក៏មាននូវប្រភេទសញ្ជាតិផ្សេងៗគ្នាដែលមានសិទ្ធិ បុព្វសិទ្ធិ និងកាតព្វកិច្ចផ្សេងៗគ្នា។ ជាឧទាហរណ៍ នៅក្នុងប្រទេសខ្លះ ប្រជាជនដែលរស់នៅអចិន្ត្រៃយ៍ ឬពលរដ្ឋដែលធ្វើជាតូបនីយកម្មប្រហែលជាមិនអាចទទួលបានសិទ្ធិបោះឆ្នោត ឬសុខមាលភាពដូចគ្នានោះទេ។ យ៉ាងណាមិញ ការបែងចែកទាំងនេះ មិនត្រូវហាមឃាត់អ្នកដែលមានសញ្ជាតិក្នុងការទទួលបានសិទ្ធិមនុស្សរបស់ខ្លួននោះទេ។

ទីពីរ រដ្ឋសម្រេចថាអ្នកណាជាអ្នកមានសញ្ជាតិតាមរយៈច្បាប់របស់ខ្លួន។ នេះជាសំណួរដែលកាន់តែស្មុគ្រស្មាញ ដោយសារវាធ្វើការបញ្ជាក់ពីនីតិវិធីដែលរដ្ឋធ្វើការពិចារណាក្នុងការផ្តល់សញ្ជាតិជូនបុគ្គលណាម្នាក់។ បុគ្គលទទួលបានសញ្ជាតិតាមរយៈ វិធីមួយចំនួនដូចបានបញ្ជាក់ខាងក្រោម៖

១. ឈាម៖ សញ្ជាតិពីម្តាយ ឬឪពុករបស់បុគ្គល
២. ទីកន្លែងកំណើត៖ សញ្ជាតិត្រូវបានផ្តល់ជូនដោយសារបុគ្គលកើតក្នុងប្រទេសណាមួយ
៣. អាពាហ៍ពិពាហ៍៖ សញ្ជាតិត្រូវបានទទួលពីប្តី ឬ ប្រពន្ធ
៤. លំនៅដ្ឋាន៖ សញ្ជាតិត្រូវបានផ្តល់ជូនដោយសារការរស់នៅកន្លែងណាមួយ
៥. សញ្ជាតូបនីយកម្ម៖ បុគ្គលដាក់ពាក្យសុំដល់ប្រទេសមួយដើម្បីក្លាយអ្នកមានសញ្ជាតិ ហើយប្រទេសនោះនឹងផ្តល់សញ្ជាតិជូនបុគ្គលនោះ។

ពេលបច្ចុប្បន្នមធ្យោបាយទូទៅបំផុតនៃការទទួលបានសញ្ជាតិមួយ គឺតាមរយៈឈាម ដោយសារនេះត្រូវបានទទួលស្គាល់ក្នុងគ្រប់រដ្ឋទាំងអស់នៅអាស៊ីអាគ្នេយ៍។ មិនមានរដ្ឋនៅអាស៊ីអាគ្នេយ៍ណាមួយទទួលស្គាល់កន្លែងកំណើតនោះទេ ហើយមានរដ្ឋតិចតួចប៉ុណ្ណោះ (ជាឧទាហរណ៍) សហរដ្ឋអាមេរិកដែលផ្តល់ជូនតាមរយៈមធ្យោបាយនេះ។ ខណៈពេលដែលប្រទេសខ្លះ នៅអាស៊ីអាគ្នេយ៍អនុញ្ញាតសញ្ជាតិតាមរយៈអាពាហ៍ពិពាហ៍ និងសញ្ជាតូបនីយកម្ម លក្ខខណ្ឌអាចមានការលំបាក និងថ្លៃ។ ប្រជាជនត្រូវតែឆ្លងកាត់ការប្រលងភាសា និងវប្បធម៌ រស់នៅរយៈពេលវែង នៅក្នុងប្រទេសនោះ។ ប្រទេសខ្លះល្បីខាងលក់សញ្ជាតិដោយធ្វើឲ្យនីតិវិធីមានការងាយស្រួលចំពោះអ្នកដែលចង់ចំណាយលុយ។ ពេលខ្លះ សញ្ជាតិត្រូវបានទទួលជាស្វ័យប្រវត្តិ ជាពិសេសតាមឈាម និងទីកន្លែងកំណើត ខណៈពេលដែលមធ្យោបាយផ្សេងនៃការទទួលបានសញ្ជាតិមិនស្វ័យប្រវត្តិនោះទេ ហើយបុគ្គលដាក់ពាក្យសុំដល់រដ្ឋដើម្បីទទួលបានសញ្ជាតិរបស់ពួកគេ។ បុគ្គលម្នាក់ជាជនគ្មានសញ្ជាតិ ប្រសិនជាពួកគេមិនអាចទទួលបានសញ្ជាតិតាមវិធីណាមួយខាងលើ។

## ការពិភាក្សា និងការជជែកវែកញែក

### ច្បាប់ស្តីពីសញ្ជាតិរបស់អ្នក

ច្បាប់សញ្ជាតិអាចមានភាពស្មុគ្រស្មាញ។ បញ្ញត្តិពីសញ្ជាតិនេះអាចមាននៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់សញ្ជាតិ និងក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍។ ប្រទេសជាច្រើននៅតំបន់អាស៊ីអាគ្នេយ៍ បានធ្វើបច្ចុប្បន្នភាពច្បាប់សញ្ជាតិរបស់ខ្លួននៅក្នុងអំឡុងពេលប៉ុន្មានទសវត្សចុងក្រោយនេះ។ ច្បាប់ទាំងនេះអាចស្រាវជ្រាវបានតាមគេហទំព័រនៃក្រសួងអន្តប្រវេសន៍ ឬក្រសួងរដ្ឋាភិបាលដែលមានមុខងារដូចគ្នានេះ ឬក្នុងផ្នែកណាមួយនៃរដ្ឋធម្មនុញ្ញ។ បន្ទាប់ពីអ្នកអានច្បាប់ ទាំងនេះ សូមឆ្លើយសំណួរខាងក្រោម៖ ឬ

*តើអ្នកបានទទួលសញ្ជាតិបានយ៉ាងដូចម្តេច? តើនេះដោយសារអ្នកបានកើតក្នុងប្រទេសណាមួយជាក់លាក ឬដោយសារសញ្ជាតិឪពុកម្តាយរបស់អ្នក? តើឪពុកម្តាយរបស់ទទួលបានសញ្ជាតិបានយ៉ាងដូចម្តេច? ចុះចំនែកជីដូន និងជីតារបស់អ្នក?*

*តើអ្នកត្រូវបានអនុញ្ញាតឲ្យមានសញ្ជាតិពីរដែរឬទេ? ប្រសិនជាអ្នករៀបការជាមួយជនបរទេស តើអ្នកអាចផ្តល់សញ្ជាតិជូនប្តីឬប្រពន្ធរបស់អ្នកបានដែរឬទេ? ចុះចំណែកកូនរបស់លោកអ្នកវិញ?*

*តើមានគម្លាតនៅក្នុងច្បាប់ដែរឬទេ? តើអ្នកអាចគិតពីស្ថានភាពដែលមានអ្នកណាម្នាក់អាចនិយាយបានថាគាត់រៀបការ ឬកើតពីពលរដ្ឋរបស់ប្រទេសអ្នក តើគាត់អាចក្លាយជាជនគ្មានសញ្ជាតិដែរឬទេ ដោយសារតែច្បាប់របស់ប្រទេសអ្នកមិនបានទទួលស្គាល់គាត់?*

អនុសញ្ញាទទួលស្គាល់តែអ្នកគ្មានសញ្ជាតិ ដោយសារច្បាប់មិនទទួលស្គាល់ពួកគេប៉ុណ្ណោះ។ ប្រជាជនទាំងនេះគ្មានសញ្ជាតិតាមផ្លូវច្បាប់ (*de jure* stateless) ។ ប្រសិនអ្នកណាម្នាក់គ្មានសញ្ជាតិ ដោយសារពួកគេមិនបានឆ្លងកាត់នីតិវិធីរត់ឯកសារចាំបាច់ (ដូចជាកុមារម្នាក់ដែលបានកើតក្រៅប្រទេស ហើយមិនទាន់បានដាក់ពាក្យសុំសញ្ជាតិ) ហើយច្បាប់ទទួលស្គាល់គេថាជាពលរដ្ឋ ករណីនេះអនុសញ្ញាមិនចាត់ទុកថាពួកគេជាជនគ្មានសញ្ជាតិនោះទេ ទោះបីជាតាមការពិតជាក់ស្តែងពួកគេគ្មានសញ្ជាតិក៏ដោយ។ ប្រជាជនទាំងនោះត្រូវបានហៅថាជាគ្មានសញ្ជាតិតាមអង្គហេតុ មិនមែនអង្គច្បាប់នោះទេ ( de facto  stateless) ។

## ផ្ដោតសំខាន់លើ

### ភាពគ្មានសញ្ជាតិ *តាមផ្លូវច្បាប់ (De Jure)* vs. *តាមអង្គហេតុ (De Facto )*

ភាពគ្មានសញ្ជាតិ *តាមផ្លូវច្បាប់ និងតាមអង្គហេតុ* គឺខុសពីគ្នា។ ភាពគ្មានសញ្ជាតិ *តាមផ្លូវច្បាប់* មានន័យថាបុគ្គលមិនមានសញ្ជាតិតាមផ្លូវច្បាប់។ ភាពគ្មានសញ្ជាតិ *តាមអង្គហេតុ* សំដៅលើបុគ្គលតាមអង្គហេតុមិនមានសញ្ជាតិ ប៉ុន្តែមានលក្ខខណ្ឌតាមផ្លូវច្បាប់ដើម្បីទទួលបានសញ្ជាតិ។ ជនគ្មានសញ្ជាតិ *តាមផ្លូវច្បាប់* និង *តាមអង្គហេតុ* ប្រឈមនឹងភាពងាយរងគ្រោះដូចគ្នា ដោយសារពួកគេមិនបានទទួលការការពារ សេវាកម្ម ឬផលប្រយោជន៍ពីរដ្ឋ។ បញ្ហាមួយក្នុងអនុសញ្ញាតិនៃជនគ្មានសញ្ជាតិគឺថា អនុសញ្ញាទទួលស្គាល់ជនគ្មានសញ្ជាតិ *តាមផ្លូវច្បាប់* មិនទទួលស្គាល់ *អង្គហេតុ* នោះទេ ធ្វើឲ្យជនគ្មានសញ្ជាតិ *អង្គហេតុ* ទទួលបានការការពារតិចជាង ទោះពីជាមានតម្រូវការ និងភាពងាយរងគ្រោះដូចជនគ្មានសញ្ជាតិ *ផ្លូវច្បាប់* ក៏ដោយ។

## ៦.៨.២ ការរំលោភបំពានលើសិទ្ធិរបស់ជនគ្មានសញ្ជាតិ

ជនគ្មានសញ្ជាតិប្រឈមនឹងការរំលោភបំពានសិទ្ធិមនុស្សមួយចំនួន។ ការរំលោភបំពានជាទូទៅចំនួនពីរគឺការរើសអើង និងការឃុំខ្លួន។ ការរើសអើងអាចមានច្រើនទម្រង់។ ជាឧទាហរណ៍ ពួកគេត្រូវបានផាត់ចេញជាលក្ខណ:ប្រព័ន្ធក្នុងការទទួលបានទំនិញ ឬសេវាកម្ម ឬកង្វះលទ្ធភាពក្នុងការទទួលបានការថែទាំសុខភាព ការអប់រំ និងសេវាសាធារណ:ដទៃទៀត។ ពួកគេប្រហែលជាមិនអាចចូលរួមក្នុងនយោបាយនោះទេ។ ពួកគេខ្លះមិនមានលទ្ធភាពក្នុងការទទួលបានការការពារពីប៉ូលីស និងតុលាការធ្វើឲ្យពួកគេមានភាពងាយរងគ្រោះនៅពេលត្រូវបានបំពាន កេងប្រវ័ញ្ច ឬមិនដូចនេះទេត្រូវបានប្រព្រឹត្តមកលើមិនសមរម្យ។ នេះជារឿយៗធ្វើឲ្យជនគ្មានសញ្ជាតិមិនអាចធ្វើការតវ៉ាក្នុងកិច្ចសន្យា ប្រាក់ឈ្នួល ឬលក្ខខណ្ឌរស់នៅ។ លើសពីនេះទៀត កង្វះលទ្ធភាពក្នុងការប្ដឹងទៅប្រព័ន្ធយុត្តិធម៌ធ្វើឲ្យជនគ្មានសញ្ជាតិ មានភាពងាយរងគ្រោះពីការកេងប្រវ័ញ្ច និងបទឧក្រិដ្ឋ។ ដូចគ្នានេះផងដែរ ដីធ្លី និងធនធានរបស់ពួកគេជារឿយៗមិនត្រូវបានការពារនោះទេ។ ធ្វើឲ្យមានភាពងាយស្រួលដល់រដ្ឋ ឬសាជីវកម្មក្នុងការទាមទារ ឬរឹបអូសទ្រព្យសម្បត្តិរបស់ពួកគេ។ ដើម្បីការពារខ្លួន ជនគ្មានសញ្ជាតិអាចត្រូវបានបង្ខំក្នុងការបង់ប្រាក់សំណូក ឬចូលរួមក្នុងសកម្មភាពបំផ្លាញ និងគ្រោះថ្នាក់។ ហើយជាចុងក្រោយ អ្នកចាក់សាំងលើភ្លើង គឺប្រព័ន្ធផ្សព្វផ្សាយដែលចាត់ក្រុមនេះថាជាទន់ខ្សោយ ឬមានឋានៈតូចទាប ដូចនេះបន្ទាបបន្ថោកដល់ពួកគេ ហើយជារឿយៗបង្កើតឲ្យមានភាពស្អប់ខ្ពើមលើក្រុមដែលខ្វះការការពារស្រាប់ទៅហើយ។

ប្រហែលជាករណីដែលអាក្រក់បំផុត គឺនៅពេលដែលជនគ្មានសញ្ជាតិត្រូវបានចាត់ទុកថាជាឧក្រិដ្ឋជន។

ការរើសអើងលើជនគ្មានសញ្ជាតិជារឿយៗនាំឲ្យមានការឃុំខ្លួន ជាពិសេសការឃុំខ្លួនលើជនអន្តោប្រវេសន៍។ ជនគ្មានសញ្ជាតិអាចត្រូវបានឃាត់ខ្លួន នៅពេលធ្វើដំណើរនៅក្នុងរដ្ឋ ដែលពួកគេតែងតែរស់នៅ ហើយត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំង។ ការប្រើប្រាស់ការឃុំខ្លួនគ្មានពេលកំណត់លើជនគ្មានសញ្ជាតិ ជាការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរជាក់លាក់ ហើយត្រូវបានជួបប្រទះដោយបុគ្គលដែលត្រូវបានឃុំខ្លួនរហូតដល់ពួកគេអាចបង្ហាញភ័ស្តុតាងថាពួកគេមកពីណា ដែលជាកិច្ចការពិបាកដោយសារគ្មានឯកសារ។ ឧទាហរណ៍នេះរៀបរាប់ពីសារៈសំខាន់នៃនីតិវិធីច្បាប់ក្នុងប្រព័ន្ធអន្តោប្រវេសន៍ ដោយសារជនគ្មានសញ្ជាតិមានសិទ្ធិ ក្នុងការទទួលបានការការពារជាពិសេស។ នៅពេលដែលប្រព័ន្ធអន្តោប្រវេសន៍មិនផ្តល់ប្រយោជន៍ គ្រប់គ្រាន់ដល់ភាពគ្មានសញ្ជាតិ អ្នកដែលគួរតែទទួលបានការការពារកាន់តែប្រសើរជារឿយៗបាត់បង់ផលប្រយោជន៍របស់ខ្លួន។

## ៦.៨.៣ អនុសញ្ញាស្តីពីភាពគ្មានសញ្ជាតិ

មានអនុសញ្ញាស្តីពីជនគ្មានសញ្ជាតិចំនួនពីរ ៖ អនុសញ្ញាពាក់ព័ន្ធនឹងឋានៈជនគ្មានសញ្ជាតិ (១៩៥៤) និងអនុសញ្ញាស្តិពីការកាត់បន្ថយភាពគ្មានសញ្ជាតិ (១៩៦១)។ អនុសញ្ញាទីមួយមានកម្មវត្ថុជាពិធីសារនៃអនុសញ្ញាស្តីពីជនភៀសខ្លួន ដោយសារអនុសញ្ញាស្តីពីជនភៀសខ្លួន មិនបានការពារប្រជាជនគ្មានសញ្ជាតិនោះទេ។ យ៉ាងណាមិញ មានការសម្រេចចិត្តថាគួរតែចាត់ទុកបញ្ហាភាពគ្មានសញ្ជាតិជាបញ្ហាដាច់ដោយឡែក ដោយមានអនុសញ្ញាផ្ទាល់ពីបញ្ហានេះ។ អនុសញ្ញាទីមួយដើរតួនាទីជាមូលដ្ឋានគ្រឹះក្នុងការកំណត់និយមន័យភាពគ្មានសញ្ជាតិ ហើយអនុសញ្ញានេះក៏បាន បញ្ជាក់ពីការការពារបុគ្គលគ្មានសញ្ជាតិគួរតែទទួលបានផងដែរ។ កម្មវត្ថុចម្បងនៃ អនុសញ្ញាឆ្នាំ ១៩៥៤ គឺដើម្បីអនុញ្ញាតឲ្យជនគ្មានសញ្ជាតិក្នុងការទទួលបាន សិទ្ធិមនុស្សរបស់ខ្លួនកាន់តែច្រើនដូចដែលអាចធ្វើទៅបាន។ សន្ធិសញ្ញានេះកំណត់ពីចំនួននៃសិទ្ធិដែលជនគ្មានសញ្ជាតិរំពឹងថានឹងទទួលបាន។ សិទ្ធិទាំងនេះរួមមាន៖

- ការប្រព្រឹត្តិមកលើ និងសិទ្ធិដូចជនបរទេសដទៃ
- លទ្ធភាពក្នុងការទទួលបានឯកសារ ឬវិញ្ញាបនប័ត្រដែលផ្តល់ជូនជនបរទេសជាទូទៅ
- មិនមានវិធានការលើកលែងដែលត្រូវបានចាត់លើជនគ្មានសញ្ជាតិ ដោយសារសញ្ជាតិពីមុនរបស់គាត់នោះទេ
- ការទទួលស្គាល់ស្ថានភាពគ្រួសារ

- សិទ្ធិក្នុងការប្រព្រឹត្តមកលើដូចសញ្ជាតិពាក់ព័ន្ធនឹងសាសនា ការអប់រំថ្នាក់បឋមសិក្សា ទីលំនៅ ទទួលភាពក្នុងការប្រើប្រាស់ប្រព័ន្ធយុត្តិធម៌ ចំណីអាហារ ច្បាប់ការងារ និងជំនឿសាធារណៈ
- សិទ្ធិលើទ្រព្យសម្បត្តិដូចជនបរទេសដទៃ
- សិទ្ធិសេដ្ឋកិច្ចដូចជាការងារ សមាគម ដូចជនបរទេសដទៃ
- មិនមានការបណ្តេញចេញ លើកលែងតែឈរលើមូលដ្ឋានសន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ

យើងអង្កេតឃើញថាមានចំនុចខ្សោយជាច្រើនក្នុងអនុសញ្ញាឆ្នាំ ១៩៥៤។ ជនគ្មានសញ្ជាតិមិនបានទទួលសិទ្ធិពេញលេញរបស់ខ្លួននោះទេ ដោយសារសិទ្ធិរបស់ពួកគេភាគច្រើនស្មើនឹងប្រជាជនមិនមែនជាពលរដ្ឋដទៃទៀត (ដែលត្រូវបានហៅថាជនបរទេសនៅក្នុងអនុសញ្ញា)។ ទោះបីជាពួកគេបានកើត និងធំឡើងក្នុងប្រទេសនោះក៏ដោយក៏ពួកគេត្រូវបានចាត់ទុកថាជាជនបរទេសដែរ។ អនុសញ្ញាទទួលស្គាល់តែជនគ្មានសញ្ជាតិ *តាមផ្លូវច្បាប់ប៉ុណ្ណោះ* ប៉ុណ្ណោះ។ ចុងបញ្ចប់ មិនមានយន្តការការពារភ្ជាប់នឹងអនុសញ្ញានេះ ដែលអាចតាមមធ្យោបាយណាមួយ ដាស់តឿនដល់រដ្ឋ ប្រសិនជាពួកគេរំលោភបំពានសិទ្ធិរបស់ជនគ្មានដែលសញ្ជាតិនោះទេ។

អនុសញ្ញាឆ្នាំ ១៩៦១ ព្យាយាមក្នុងការកាត់បន្ថយភាពគ្មានសញ្ជាតិតាមរយៈការផ្តល់ការអនុវត្តមួយចំនួនដែលគួរតែធានាថា គ្មានបុគ្គលណាមួយក្លាយទៅជាគ្មានសញ្ជាតិនោះទេះ

- កុមារដែលបានកើតដោយគ្មានលទ្ធភាព ក្នុងការទទួលបានសញ្ជាតិណាមួយនឹងត្រូវបានផ្តល់សញ្ជាតិនៃរដ្ឋដែលកុមារបានកើត
- កុមារដែលបានកើតលើនាវានឹងទទួលបានសញ្ជាតិនៃនាវានោះ
- ទាំងឪពុក និងម្តាយអាចផ្តល់សញ្ជាតិដល់កូនរបស់ពួកគេ
- ការបាត់បង់សញ្ជាតិអាចកើតមានឡើង លុះត្រាតែបុគ្គលមានសញ្ជាតិផ្សេងប៉ុណ្ណោះ
- សញ្ជាតិមិនអាចត្រូវបានកំណត់ដោយសារមូលដ្ឋានពូជសាសន៍ ជាតិសាសន៍ ឬសាសនានោះទេ

អនុសញ្ញាទាំងពីរនេះបង្កើតជាផ្នែកដ៏សំខាន់ នៃក្របខណ្ឌច្បាប់ក្នុងការការពារជនគ្មានសញ្ជាតិ។ គួរឲ្យស្តាយ អនុសញ្ញាទាំងពីរនេះ មិនមានការផ្តល់សច្ចាប័នបានទូលំទូលាយនោះទេ ហើយការផ្តល់សច្ចាប័នពីប្រទេសនៅអាស៊ីអាគ្នេយ៍មានចំនួនតិចបំផុត។ ប្រទេសហ្វីលីពីនជារដ្ឋតែមួយគត់នៅអាស៊ីអាគ្នេយ៍ ដែលធ្វើការផ្តល់សច្ចាប័នលើអនុសញ្ញាពាក់ព័ន្ធនឹងឋានៈជនគ្មានសញ្ជាតិ ហើយទើបតែផ្តល់សច្ចាប័នកាលពីពេល

ថ្មីៗនេះក្នុងឆ្នាំ ២០១១ ប៉ុណ្ណោះ។ មិនមានប្រទេសណាមួយក្នុងតំបន់បានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីការកាត់បន្ថយភាពគ្មានសញ្ជាតិនោះទេ។

ភាពគ្មានសញ្ជាតិត្រូវបានទទួលស្គាល់ផងដែរក្នុងសន្ធិសញ្ញាដទៃ។ អនុសញ្ញាស្តីពីជនភៀសខ្លួនគ្រប់ដណ្តប់ទាំងជនភៀសខ្លួន និងជនគ្មានសញ្ជាតិ។ យ៉ាងណាមិញ ជនគ្មានសញ្ជាតិមួយចំនួន (ជាពិសេសអ្នកដែលនៅក្នុងប្រទេសដែលពួកគេត្រូវបានបដិសេធសញ្ជាតិ) មិនអាចទាមទារការការពារក្នុងនាមជាជនភៀសខ្លួននោះទេ ដូចនេះពួកគេត្រូវតែសំអាងលើអនុសញ្ញាឆ្នាំ ១៩៥៤ ដើម្បីការពារសិទ្ធិរបស់ពួកគេ។ ការការពារពីភាពគ្មានសញ្ជាតិក៏មានក្នុង CRC (មាត្រា៧ និង៨) CEDAW (មាត្រា៩) ICCPR (មាត្រា២៤) និង ICERD (មាត្រា៥) និង ICRMW និង CRPD ផងដែរ។

## ផ្តោតសំខាន់លើ

### សញ្ជាតិដែលមានប្រសិទ្ធិភាព

សញ្ជាតិមិនគ្រាន់តែជាការកាន់កាប់ឯកសារប៉ុណ្ណោះទេ ដែលបញ្ជាក់ថាបុគ្គលជាពលរដ្ឋ ប៉ុន្តែវារួមបញ្ចូលនូវសិទ្ធិ និងការការពារដែលពលរដ្ឋរំពឹងក្នុងការទទួលបានផងដែរ។ ប្រសិនបើបុគ្គលមិនមានសិទ្ធិទាំងនេះ នោះសញ្ជាតិមិនមានប្រសិទ្ធិភាពនោះទេ។ ទស្សនៈនៃសញ្ជាតិដែលមានប្រសិទ្ធិភាព ត្រូវបានស្នើឡើងដោយអង្គការទំនុកចិត្តនៃសិទ្ធិស្មើភាពគ្នា(Equal Rights Trust) ដែលជាអង្គការអន្តរជាតិឯករាជ្យមួយ ដែលជាជម្រើសផ្សេងក្រៅពីពលរដ្ឋ *តាមផ្លូវច្បាប់* និង *តាមអង្គហេតុ* ដើម្បីជាវិធានការកាន់តែប្រសើរឡើងនៃសិទ្ធិពលរដ្ឋ។ អង្គការទំនុកចិត្តនៃសិទ្ធិស្មើភាពគ្នាបង្ហាញការធ្វើតេស្តសាកល្បងប្រាំសំណួរ ដើម្បីកំណត់ថាបុគ្គលមួយរូបមានសញ្ជាតិដែលមានប្រសិទ្ធិភាពឬក៏អត់៖

១. ការទទួលស្គាល់ថាជាសញ្ជាតិ៖ តើបុគ្គលទទួលបានសញ្ជាតិស្របច្បាប់ (ក្នុងនាមគាត់ជា ជនគ្មានសញ្ជាតិ *តាមផ្លូវច្បាប់*)ដែរឬទេ?
២. ការការពាររបស់រដ្ឋ៖ តើបុគ្គលទទួលបានការការពារពីរដ្ឋរបស់គាត់ដែរទេជាពិសេសនៅពេលដែលគាត់នៅខាងក្រៅប្រទេសរបស់គាត់?
៣. លទ្ធភាពក្នុងការទទួលបានសញ្ជាតិ៖ តើបុគ្គលមានលទ្ធភាពក្នុងការទទួលបានឯកសារ (ទាំងកាន់កាប់ដោយរដ្ឋ ឬចេញដោយរដ្ឋ) ដើម្បីទទួលបានសញ្ជាតិដែរឬ

ទេ? លទ្ធភាពនេះអាចតាមរយៈស្ថានកុងស៊ុល ឬតាមរយៈមន្ត្រីរដ្ឋនៅក្នុងប្រទេសដែលត្រូវបានសន្មតថាជាសញ្ជាតិ។

៤. ការធានានូវការវិលត្រលប់ដោយសុវត្ថិភាព៖ មានការធានានៃការវិលត្រលប់ដោយសុវត្ថិភាពទៅកាន់ប្រទេសដែលជាសញ្ជាតិ ឬ ជាទីលំនៅ ឬមានហានិភ័យនៃ "ការឈឺចាប់ដែលមិនអាចប៉ះប៉ូវបាន" ដែរឬទេ? តើការវិលត្រលប់អាចធ្វើទៅបានដែរឬទេ?

៥. ការទទួលបានសិទ្ធិមនុស្ស៖ តើបុគ្គលដែលខ្វះឯកសារ សញ្ជាតិ ឬការទទួលស្គាល់ថាជាសញ្ជាតិ មានឥទ្ធិពលអវិជ្ជមានជាចម្បងលើការទទួលបានសិទ្ធិមនុស្សរបស់គាត់ដែរឬទេ?

## ៦.៤.៤ មូលហេតុនៃភាពគ្មានសញ្ជាតិ

នៅអាស៊ីអាគ្នេយ៍ មានវិធីជាមួយចំនួនដែលបុគ្គលម្នាក់ក្លាយទៅជាគ្មានសញ្ជាតិ។

### ព្រំដែន និងសហគមន៍ក្រីក្រ

ជាទូទៅ ភាពគ្មានសញ្ជាតិកើតមានឡើងនៅពេលដែលបុគ្គលម្នាក់រស់នៅក្នុងតំបន់ព្រំដែនដែលរដ្ឋគ្រប់គ្រងពីចំងាយ ហើយជាកន្លែងដែលមានទំនាក់ទំនងទៀងទាត់តិចតួចជាមួយនឹងរដ្ឋ។ នេះជាការពិតចំពោះក្រុមកុលសម្ព័ន្ធលើភ្នំបណ្តាយព្រំដែនមីយ៉ាន់ម៉ា ថៃ ឡាវ កម្ពុជា និងវៀតណាម។ ហើយនេះក៏ជាស្ថានភាពពិតចំពោះសហគមន៍ជាច្រើនក្នុងប្រទេសហ្វីលីពីន ដែលរស់នៅក្បែរព្រំដែនម៉ាឡេស៊ីលើកោះ Borneo ផងដែរ។ ក្នុងករណីជាច្រើន ប្រជាជនមិនមានសំបុត្រកំណើត ឬឯកសារដទៃទៀតដើម្បីបង្ហាញពីកន្លែងដែលពួកគេរស់នៅ ឬឋានៈរបស់ឪពុកម្តាយរបស់ពួកគេនោះទេ។ ជាលទ្ធផល កូនៗរបស់ពួកគេតែងតែបន្តនូវភាពគ្មានសញ្ជាតិរបស់ពួកគេ។

### ទេសន្តប្រវេសន៍

បញ្ហាកើតមានឡើងប្រសិនជាប្រជាជនធ្វើដំណើរក្នុងរយៈពេលវែង ឬមានកូននៅខាងក្រៅប្រទេសកំណើតរបស់ខ្លួន។ ឧទាហរណ៍ ឥណ្ឌូនេស៊ី កាលពីមុនមានច្បាប់ដែលលុបចោលសញ្ជាតិរបស់អ្នកណាម្នាក់ ដែលរស់នៅក្រៅទឹកដីនៃប្រទេសរបស់ខ្លួនរយៈពេលប្រាំឆ្នាំ។ ច្បាប់នេះត្រូវបានធ្វើវិសោធនកម្មក្នុងឆ្នាំ ២០០៦ ដែលអនុញ្ញាតឲ្យពលរដ្ឋឥណ្ឌូនេស៊ីក្នុងប្រទេសម៉ាឡេស៊ីចំនួន ១០០ ០០០ ទាមទារមកវិញនូវសញ្ជាតិឥណ្ឌូនេស៊ីរបស់ខ្លួន។

ក្នុងករណីជាច្រើន ឪពុកម្តាយដែលរស់នៅក្រៅប្រទេសកំណើតរបស់ខ្លួនមិនអាចបន្តសញ្ជាតិឲ្យកូនរបស់ខ្លួនបាននោះទេ ។ ជាឧទាហរណ៍ ប្រសិនជាកុមារកើតពីឪពុកម្តាយជាពលករទេសន្តប្រវេសន៍មិនបានចុះបញ្ជីកំណើត កុមាររូបនេះអាចប្រឈមនឹងការពិបាកក្នុងការទទួលបានសញ្ជាតិ ដោយសារនៅពេលដែលពួកគេត្រលប់មកប្រទេសពួកគេវិញ ពួកគេនឹងខ្វះឯកសារក្នុងការបង្ហាញពីឈ្មោះ កាលបរិច្ឆេទ ឬទីកន្លែងកំណើតរបស់កុមារ។ នេះជាករណីដែលកើតឡើងជារឿយៗលើកុមារដែលជាកូនពលករមីយ៉ាន់ម៉ាក្នុងប្រទេសម៉ាឡេស៊ី និងថៃ។ លើសពីនេះទៀត កុមារមិនអាចត្រលប់មកប្រទេសខ្លួនវិញនោះទេ ដោយសារហេតុផលសន្តិសុខ និងការចំណាយ មានន័យថាពួកគេជា ជនគ្មានសញ្ជាតិ *តាមអង្គហេតុ*។

## ការផ្ទេរ ឬការបាត់បង់សញ្ជាតិ

ម្តងម្កាល បុគ្គលត្រូវបានបង្ខំឲ្យលះបង់នូវសញ្ជាតិរបស់ពួកគេ ឬអាចព្យាយាមក្នុងការផ្លាស់ប្តូរសញ្ជាតិដែលអាចធ្វើឲ្យក្លាយទៅជាគ្មានសញ្ជាតិ។ ជាឧទាហរណ៍ ប្រទេសខ្លះបង្ខំឲ្យប្រពន្ធលះបង់សញ្ជាតិរបស់ពួកគេ នៅពេលរៀបការជាមួយជនបរទេស ប៉ុន្តែស្ត្រីមិនអាចទទួលសញ្ជាតិនេះមកវិញនោះទេ ប្រសិនជាអាពាហ៍ពិពាហ៍បរាជ័យ។

រដ្ឋខ្លះមានច្បាប់ស្តីពីការលះបង់សញ្ជាតិដោយស្វ័យប្រវត្តិ ប្រសិនជាបុគ្គលបោះឆ្នោតនៅបរទេស ឬចូលជាទាហានបរទេស ដែលអាចធ្វើឲ្យពួកគេក្លាយជាជនគ្មានសញ្ជាតិ។ ប្រទេសខ្លះនៅអាស៊ីអាគ្នេយ៍ រួមមានវៀតណាម សិង្ហបុរី ឥណ្ឌូនេស៊ី និងម៉ាឡេស៊ី អនុញ្ញាតឲ្យមានសញ្ជាតិមួយប៉ុណ្ណោះ។ ដូចនេះ ប្រសិនជាបុគ្គលម្នាក់ទទួលសញ្ជាតិដទៃពីប្រទេសដទៃ បុគ្គលនោះនឹងត្រូវបានបង្ខំឲ្យបោះបង់សញ្ជាតិដើមរបស់ខ្លួន។ ជាការពិតណាស់ បុគ្គលអាចបាត់បង់សញ្ជាតិដើមមុនពេលពួកគេទទួលសញ្ជាតិថ្មី។

## **ឈាមជ័រមិនស្មើភាពគ្នា**

ក្នុងប្រទេសខ្លះ ស្ត្រីមិនមានសិទ្ធិដូចគ្នាក្នុងការបន្តសញ្ជាតិដល់កូនរបស់ខ្លួនដូចបុរសនោះទេ។ ពេលបច្ចុប្បន្ននេះ មានតែប្រទេសម៉ាឡេស៊ីប៉ុណ្ណោះដែលមិនអនុញ្ញាតឲ្យស្ត្រីបន្តសញ្ជាតិ ប្រសិនកុមារកើតក្រៅពីចំណងអាពាហ៍ពិពាហ៍។ យ៉ាងណាមិញប្រហែលជា ១០ ឆ្នាំមុន ភាពមិនស្មើគ្នានៃការផ្តល់សញ្ជាតិនេះមានវត្តមានក្នុងប្រទេសផ្សេងផងដែរ។ ភាពគ្មានសញ្ជាតិអាចកើតមាន ប្រសិនជាម្តាយរបស់កុមារមិនអាចបន្តសញ្ជាតិ ហើយមិនអាចទាមទារសញ្ជាតិរបស់ឪពុក អាចដោយសារឪពុកមិនមានវត្តមានក្នុងការផ្តល់សញ្ជាតិ ឬប្រទេសគាត់ហាមគាត់មិនឲ្យធ្វើដូចនេះ។

### ហេតុផលផ្សេង

ភាពគ្មានសញ្ជាតិអាចកើតមានតាមវិធីដទៃទៀតជាច្រើន ដោយរួមមាន ការផ្លាស់ប្តូរស្ថានភាពរដ្ឋ ការផ្លាស់ប្តូរច្បាប់សញ្ជាតិ ឬតាមរយៈការជួញដូរមនុស្ស។ វិធីសាស្ត្រដែលគួរឲ្យរំខានជាពិសេសកើតមានឡើងតាមរយៈការរើសអើង។ នៅក្នុងករណីទាំងនេះ រដ្ឋជារឿយៗដកហូតសញ្ជាតិពីក្រុមបុគ្គលដោយសារតែជាតិសាសន៍ ឬសាសនារបស់ពួកគេ។ ករណីនេះមានដូចជា ជនជាតិ Rohingya (ដូចដែលបានពិភាក្សាខាងលើ) ជនជាតិភាគតិចម៉ូស្លីមក្នុងប្រទេសមីយ៉ាន់ម៉ាខាងលិច ដែលសញ្ជាតិរបស់ពួកគេត្រូវបានដកហូតជាពិសេសដោយសារតែសាសនា និងជាតិសាសន៍របស់ពួកគេ។

## ៦.៨.៨ សកម្មភាពក្នុងការលុបបំបាត់ភាពគ្មានសញ្ជាតិ

មានការឆ្លើយតបចំនួនបួនដើម្បីដោះស្រាយបញ្ហានៃភាពគ្មានសញ្ជាតិ ដែលត្រូវបានកំណត់ដោយអ្នកជំនាញការ និងអង្គការ ដូចជា UNHCR ដែលធ្វើការលើបញ្ហាភាពគ្មានសញ្ជាតិ។ ទាំងបួននេះជាការ កំណត់អត្តសញ្ញាណ ការបង្ការ ការកាត់បន្ថយ និងការការពារ។ ការឆ្លើយតបនីមួយៗរួមមាននូវសកម្មភាពជាច្រើនសម្រាប់រដ្ឋ និង NGOs ក្នុងការអនុវត្តដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់ជនគ្មានសញ្ជាតិ។

### ការកំណត់អត្តសញ្ញាណ

ទាំងនេះជាសកម្មភាពក្នុងការស្វែងរកទីតាំងនៃជនគ្មានសញ្ជាតិ ហើយដើម្បីកំណត់ពីចំនួននៃជនគ្មានសញ្ជាតិ។ រដ្ឋភាគច្រើនមិនដឹងពីចំនួនជនគ្មានសញ្ជាតិដែលរស់នៅក្នុងទឹកដីខ្លួនឡើយ ហើយដោយសារតែជនគ្មានសញ្ជាតិភាគច្រើនព្យាយាមក្នុងលាក់ភាពមិនមានសញ្ជាតិរបស់ខ្លួន រដ្ឋមានការពិបាកក្នុងការរកទីតាំង និងរាប់ចំនួនណាស់។ នៅពេលមានការស្ទង់មតិជាលើកដំបូងកាលពីមួយទសវត្សមុន មានចំនួនជនគ្មានសញ្ជាតិតិចតួចប៉ុណ្ណោះ ដែលត្រូវបានរកឃើញក្នុងរដ្ឋអាស៊ីអាគ្នេយ៍ដែលព្យាយាមធ្វើការលាក់បាំងពីប្រជាជនគ្មានសញ្ជាតិរបស់ខ្លួន។ យ៉ាងណាមិញ ត្រូវបានរកឃើញថាមនុស្សជាច្រើនមិនបានប្រាប់ការពិត និងបង្ហាញពីឋានៈរបស់ខ្លួនដល់អ្នកស្ទង់មតិនោះទេដោយសារភ័យខ្លាចការឃុំខ្លួន។ NGOs និងរដ្ឋាភិបាលជាច្រើនកំពុងធ្វើការក្នុងការដោះស្រាយបញ្ហានេះដោយធ្វើការស្ទង់មតិ និងកិច្ចប្រជុំដើម្បីលើកកម្ពស់ការយល់ដឹងពីសិទ្ធិសញ្ជាតិរបស់ខ្លួន។ នៅពេលដែលខ្លឹមសារនៃការស្ទង់មតិត្រូវបានដូរ (ជាឧទាហរណ៍ដោយធ្វើការសាកសួរ ថាតើពួកគេនឹងចុះសញ្ជាតិ ឬ ក៏អត់ប្រសិនជារដ្ឋាភិបាលផ្តល់សេវាដោយមិនគិតថ្លៃ និងមិនមានការគម្រាមកំហែងនៃការឃុំខ្លួន ជាជាងសួរថា

(អ្នកជាជនគ្មានសញ្ជាតិមែនទេ?) ចំនួននៃប្រជាជនគ្មានសញ្ជាតិមានការកើនឡើងយ៉ាងច្រើន។ នៅអាស៊ីអាគ្នេយ៍ ឡាវ និងវៀតណាម បានទទួលស្គាល់ជនគ្មានសញ្ជាតិក្នុងច្បាប់សញ្ជាតិរបស់ខ្លួន ហើយយល់ព្រមក្នុងការផ្តល់សញ្ជាតិជូនពួកគេ។ ការផ្តល់ឋានៈជាផ្លូវការនៃភាពគ្មានសញ្ជាតិអាចជួយសម្រួលដល់ការកំណត់អត្តសញ្ញាណ និងជួយផ្តល់ការការពារជាផ្លូវនៅពេលក្រោយ។

## ការបង្ការ

ទាំងនេះជាសកម្មភាពក្នុងការបង្ការភាពគ្មានសញ្ជាតិជាបឋម ហើយអាចរួមបញ្ចូលនូវការផ្លាស់ប្តូរច្បាប់ ការចុះបញ្ជីកុមារ ឬផ្តល់សញ្ជាតិដើម្បីធានាថាប្រជាជនមិនក្លាយទៅជាជនគ្មានសញ្ជាតិ។ ប្រទេសនៅអាស៊ីអាគ្នេយ៍ភាគច្រើន មានភាពសកម្មភាពក្នុងការកិច្ចការនេះដោយធ្វើការផ្លាស់ប្តូរច្បាប់សញ្ជាតិរបស់ខ្លួន។ ជាឧទាហរណ៍ រួមមានការផ្លាស់ប្តូរកាលពីពេលថ្មីៗនេះ នៃច្បាប់ស្តីពីសញ្ជាតិរបស់ឥណ្ឌូនេស៊ី វៀតណាម និងថៃ (រវាងឆ្នាំ ២០០៦ ដល់ ២០០៩) ដើម្បីធានាសិទ្ធិ ដូចធ្វើការចុះបញ្ជីកំណើតជាសកល និងសមភាពយេនឌ័រក្នុងការផ្តល់សញ្ជាតិតាមឈាម។ កំណែទម្រង់ច្បាប់ស្តីពីសញ្ជាតិនៅប្រទេសវៀតណាម (២០០៨) អនុញ្ញាតឲ្យជនជាតិវៀតណាមមួយចំនួនទទួលបានសញ្ជាតិវិញ ទោះបីជាពួកគេបានលះបង់ចោលសញ្ជាតិវៀតណាមរបស់ខ្លួនកាលពីពេលមុនក៏ដោយ ដោយសារតែរៀបការជាមួយជនបរទេស។ ការផ្លាស់ប្តូរច្បាប់នៅក្នុងប្រទេសឥណ្ឌូនេស៊ី (២០០៦) បានទទួលស្គាល់ក្រុមជនជាតិដើមភាគតិចដែលពីមុនមិនត្រូវបានអនុញ្ញាតឲ្យមានសញ្ជាតិ និងផ្តល់ជូនវិញនូវសញ្ជាតិដល់ពលករដែលបានរស់នៅក្រៅប្រទេសយូរល្មម ដែលធ្វើឲ្យបាត់សញ្ជាតិរបស់ពួកគេ។ ច្បាប់ម៉ាឡេស៊ីបច្ចុប្បន្ននេះផ្តល់សញ្ជាតិដល់កុមារ ដែលកើតពីម្តាយ ជនជាតិម៉ាឡេស៊ី ដែលមិនមានលទ្ធភាពក្នុងការទទួលបានសញ្ជាតិដទៃទៀត។ ប្រទេសទាំងអស់ក្នុងតំបន់មានការចុះបញ្ជីកំណើតជាសកល ក្នុងប្រទេសរបស់ខ្លួន មិនខ្វល់ពីឋានៈមិនមានឯកសាររបស់ឪពុកម្តាយរបស់កុមារឡើយ។

ការយល់ដឹងគឺជាទិដ្ឋភាពសំខាន់នៃការបង្ការ។ ដូចនេះរដ្ឋាភិបាល NGOs និងស្ថាប័នអប់រំសិក្សានៅអាស៊ីអាគ្នេយ៍ធ្វើការងារ ដើម្បីផ្សព្វផ្សាយព័ត៌មានអំពីភាពគ្មានសញ្ជាតិក្នុងតំបន់។ នេះមិនត្រឹមតែប្រាប់ព័ត៌មានដល់សាធារណៈជនប៉ុណ្ណោះទេ ប៉ុន្តែក៏ព្យាយាមស្វែងយល់ឲ្យកាន់តែប្រសើរឡើងពីទស្សនៈនេះផងដែរ។

### ករណីសិក្សា

### ការស្ទង់មតិសហគមន៍កុលសម្ព័ន្ធលើភ្នំក្នុងប្រទេសថៃ

នៅក្នុងរបាយការណ៍មួយចេញដោយ UNHCR ដែលមានចំណងជើងថា ការអនុវត្តល្អប្រសើរក្នុងការដោះស្រាយបញ្ហាគ្មានសញ្ជាតិនៅអាស៊ីអាគ្នេយ៍ មានការពិភាក្សាពីការស្ទង់មតិនៃកុលសម្ព័ន្ធលើភ្នំក្នុងប្រទេសថៃ ដែលបានធ្វើឡើងកាលពីឆ្នាំ ២០០៥ ដល់ ២០០៦ ដោយក្រសួងអភិវឌ្ឍសង្គម និងសន្តិសុខមនុស្សរបស់ថៃ និងអង្គការ UNESCO។ ការស្ទង់មតិលើមនុស្សចំនួន ៦៥ ០០០ នាក់គ្រួសារចំនួន ១២០០០ ក្នុងភូមិចំនួន ១៩២ នៅឈៀង មៃ ឈៀងរ៉ៃ និងម៉ែហុងសុន ហើយរបាយការណ៍បង្ហាញថា៖

ការស្ទង់មតិបានបញ្ជាក់ពីចំនួនភាពមិនមានសញ្ជាតិ ក្នុងចំណោមសមាជិកកុលសម្ព័ន្ធលើភ្នំ ដែលមានចំនួន ៣៨% នៃអ្នកផ្តល់ការស្ទង់មតិខ្វះសញ្ជាតិថៃ។ បន្ថែមពីលើការដាក់កម្រិតផ្លូវច្បាប់ ប្រជាជនមិនមែនជាពលរដ្ឋមិនអាចបោះឆ្នោតក្នុងការជ្រើសរើសរដ្ឋាភិបាល ហើយការស្ទង់មតិបង្ហាញពីបញ្ហាញាំញី ដែលប្រជាជនមិនមែនជាពលរដ្ឋជួបប្រទះនៅពេលដែលព្យាយាមក្នុងការទទួលបានសេវាមូលដ្ឋាន។ ការស្ទង់មតិបង្ហាញថា បើប្រៀបធៀបទៅនឹងជនជាតិថៃ ប្រជាជនដែលមិនមែនជាពលរដ្ឋ ៩៩% មិនបានទទួលសេវាសុខភាពសាធារណៈ និង ២៥% មិនមានលទ្ធភាពក្នុងការទទួលបានឥណទានហិរញ្ញវត្ថុ។ ពាក់ព័ន្ធនឹងការអប់រំ ប្រជាជនមិនមែនជាពលរដ្ឋចំនួន៧៣% មិនបានចូលរៀនថ្នាក់បឋមសិក្សា ៩៨% មិនបានចូលរៀនថ្នាក់ឧត្តមសិក្សា។ យ៉ាងណាមិញ ទោះបីជាប្រឈមនឹងបញ្ហានេះក៏ដោយ អត្រានៃការអប់រំក្នុងចំណោមសមាជិកកុលសម្ព័ន្ធលើភ្នំមានភាពប្រសើរឡើងបន្តិចម្តងៗ ពីជំនាន់មួយទៅជំនាន់មួយ។

## ការកាត់បន្ថយ

សកម្មភាពទាំងនេះ មានគោលបំណងក្នុងការផ្តល់សញ្ជាតិដល់ជនគ្មានសញ្ជាតិ។ នេះអាចសម្រេចបានតាមរយៈការចុះបញ្ជីចល័ត ដើម្បីធានាថាកុមារក្នុងតំបន់ជនបទទទួលបានការចុះបញ្ជីកំណើត ឬទទួលបានឯកសារសញ្ជាតិប្រជាជន។ នេះអាចរួមបញ្ចូលការផ្លាស់ប្តូរច្បាប់ដើម្បីស្តារសញ្ជាតិឡើងវិញ ដល់អ្នកដែលបានបាត់បង់។ យុទ្ធនាការរបស់ប្រទេសកម្ពុជាសម្រាប់ការចុះបញ្ជីកំណើតជាសកល ជាឧទាហរណ៍ល្អប្រសើរនៃកិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយចំនួនជនគ្មានសញ្ជាតិ តាមរយៈការសម្រួលនីតិវិធី និងការផ្សព្វផ្សាយ។

### ការការពារ

ប្រជាជនគ្មានសញ្ជាតិគួរតែទទួលបានសិទ្ធិមនុស្សរបស់ពួកគេពេញលេញ ហើយនេះអាចសម្រេចបានតាមរយៈការធានាថាស្ថាប័នការពាររបស់រដ្ឋ (ដូចជា NHRIs ប៉ូលីស និងក្រសួងរបស់រដ្ឋាភិបាល) ទទួលស្គាល់ និងធ្វើការជាមួយនឹងប្រជាជនគ្មានសញ្ជាតិ។ ការការពារសិទ្ធិរបស់ប្រជាជនគ្មានសញ្ជាតិ រួមមានការធានាលទ្ធភាពរបស់ពួកគេក្នុងការទទួលបានការថែទាំសុខភាព និងការអប់រំ ហើយថាពួកគេមានទម្រង់ណាមួយនៃអត្តសញ្ញាណ ដូចនេះពួកគេអាចធ្វើដំណើរ ឬទទួលបានសេវាមូលដ្ឋាន។ ខណៈពេលដែលការការពារសិទ្ធិនៃប្រជាជនជនគ្មានសញ្ជាតិ នៅតែទន់ខ្សោយក្នុងវិស័យជាច្រើនក៏ដោយ ក៏មានការរីកចំរើនជាចម្បងក្នុងអំឡុងពេលទសវត្សចុងក្រោយនេះ ដោយសាររដ្ឋបានដឹងថាប្រជាជនគ្មានសញ្ជាតិមិនបង្កើតបន្ទុក ហើយផ្ទុយទៅវិញតាមរយៈការទទួលស្គាល់ពួកគេជាពលរដ្ឋ ពួកគេអាចរួមចំនែកប្រកបដោយផលិតភាពដល់រដ្ឋ។

## ក. សេចក្តីសង្ខេបពីជំពូក និងចំនុចគន្លឹះ

### ជនមិនមែនជាពលរដ្ឋ និងសិទ្ធិ

ប្រជាជនមានភាពងាយរងគ្រោះជាពិសេសពីការរំលោភបំពានសិទ្ធិមនុស្ស នៅពេលដែលពួកគេនៅក្រៅរដ្ឋដែលជាសញ្ជាតិរបស់ខ្លួន ឬប្រសិនបើពួកគេមិនត្រូវបានទទួលស្គាល់ថាជាពលរដ្ឋរបស់រដ្ឋមួយ នៅក្នុងករណីនៃប្រជាជនគ្មានសញ្ជាតិ។ នៅក្នុងករណីខ្លះ សិទ្ធិមនុស្សរបស់ពួកគេជាការការពារផ្លូវច្បាប់តែមួយគត់ដែលពួកគេមាន ទោះបីជាមានការប្រឈមខ្លាំង ក្នុងការទទួលស្គាល់សិទ្ធិមនុស្សរបស់ពួកគេក៏ដោយ។ ប្រទេសភាគច្រើននៅអាស៊ីអាគ្នេយ៍ហាក់បីដូចជាមិនអើពើ ឬយ៉ាងហោចណាស់លាក់បាំងការរំលោភបំពាន និងការគម្រាមកំហែងដែលប្រឈមដោយជនទេសន្តប្រវេសន៍ ជនភៀសខ្លួន ជនគ្មានសញ្ជាតិ និងពលករទេសន្តប្រវេសន៍។ នៅក្នុងការឆ្លើយតបនឹងភាពងាយរងគ្រោះទាំងនេះ ជនមិនមែនជាពលរដ្ឋមានសិទ្ធិពិសេសដើម្បីជួយការពារពួកគេ។

## ពាក្យពេចន៍

ពាក្យថាជនមិនមែនជាពលរដ្ឋសំដៅលើប្រជាជន ដែលស្ថិតនៅក្នុងរដ្ឋមួយដែលពួកគេមិនមែនជាពលរដ្ឋ ហើយពាក្យនេះត្រូវបានប្រើប្រាស់ដើម្បីក្តោបគ្រប់ប្រភេទទាំងអស់នៃប្រជាជនដែលមិនអាចទទួលបានសិទ្ធិ និងការការពារពីរដ្ឋ។ ទេសន្តប្រវេសន៍អាចទៀងទាត់ មានន័យថាធ្វើដំណើរតាមច្រកដែលបានអនុញ្ញាតជាមួយនឹងឯកសារត្រឹមត្រូវ មិនទៀងទាត់មានន័យថាអ្នកដែលរំលងច្រកត្រឹមត្រូវ ហើយដូចនេះមិនមានឯកសារចាំបាច់នោះទេ ឬទេសន្តប្រវេសន៍ដោយបង្ខំគឺប្រើនៅពេលណាដែលអ្នកណាម្នាក់ត្រូវបានបង្ខំឲ្យចាកចេញពីប្រទេសរបស់ខ្លួនដោយសារជម្លោះ ឬ ការគម្រាមកំហែងពីអំពើហិង្សា។ ជនទេសន្តប្រវេសន៍អាចមានឯកសារ មានន័យថាពួកគេពួកគេកាន់កាប់ឯកសារត្រឹមត្រូវ ឬមិនមានឯកសារ មានន័យថាពួកគេមិនមានឯកសារចាំបាច់នោះទេ។ រដ្ឋអាចចាត់ទុកជនទេសន្តប្រវេសន៍ថាស្របច្បាប់ មានន័យថាពួកគេមិនបានបំពានច្បាប់ដើម្បីចូលមកប្រទេសខ្លួន ឬមិនស្របច្បាប់មានន័យថារដ្ឋាភិបាលចាត់ទុកពួកគេថាបានបំពានច្បាប់។ នៅពេលរដ្ឋប្រើប្រាស់ពាក្យថាជនទេសន្តប្រវេសន៍មិនស្របច្បាប់ ខ្លួនគិតថាពួកគេពាក់ព័ន្ធនឹងសកម្មភាពឧក្រិដ្ឋណាមួយ ហើយគួរតែត្រូវបានចាប់ខ្លួន។ ប៉ុន្តែពេលខ្លះ រដ្ឋាភិបាលជារឿយៗធ្វើឲ្យការទទួលឯកសារស្របច្បាប់មានការពិបាក និងថ្លៃ បង្ខំឲ្យជនទេសន្តប្រវេសន៍យកឋានៈមិនមានឯកសារ។

## ទេសន្តប្រវេសន៍

មានប្រវត្តិដ៏យូរអង្វែងនៃទេសន្តប្រវេសន៍ក្នុងអាស៊ីអាគ្នេយ៍។ ចលនាប្រជាជនក្នុងអាស៊ីអាគ្នេយ៍មានភាពចម្រុះ ដោយសារតែការបើកចំហព្រំដែន កំណើនសេដ្ឋកិច្ចមិនស្មើគ្នា ហើយប្រជាជនរត់គេចខ្លួនពីជម្លោះប្រដាប់អាវុធ។ មានលំហូរធំៗក្នុងតំបន់ និងពីតំបន់ទៅប្រទេសខាងក្រៅដូចជាទៅមជ្ឈឹមបូព៌ា និងអាស៊ីខាងកើត។ ការការពារដល់ជនទេសន្តប្រវេសន៍មានភាពទន់ខ្សោយ ដោយសារមិនមានច្បាប់ក្នុងតំបន់ និងការរើសអើងលើប្រជាជនដែលមិនមានសញ្ជាតិ នៅមានវត្តមាននៅឡើយក្នុងប្រទេសទាំងអស់នៅអាស៊ីអាគ្នេយ៍។ មានគម្លាតផងដែរក្នុងច្បាប់អន្តរជាតិដែលផ្តល់ការការពារដល់ប្រជាជន ដែលមិនមែនជាពលរដ្ឋដោយសារមិនមានវិធានច្បាស់លាស់លើវិធីក្នុងការកំណត់ និងចាត់ប្រភេទប្រជាជនមិនមែនជាពលរដ្ឋដែលត្រូវការការពារ ហើយនិងនិន្នាការរបស់រដ្ឋាភិបាល ក្នុងការកំណត់ប្រជាជនដែលមិនមានឯកសារទាំងអស់ថាមិនស្របច្បាប់។

## ជនភៀសខ្លួន

ជនភៀសខ្លួនជាបុគ្គលដែលស្វែងរកការការពារពីរដ្ឋរបស់ពួកគេ ដែលត្រូវបានទទួលស្គាល់តាមអនុសញ្ញាជនភៀសខ្លួនឆ្នាំ ១៩៥១។ ដើម្បីក្លាយជាជនភៀសខ្លួន ពួកគេត្រូវស្ថិតក្នុងក្នុងនិយមន័យដែលរួមមានការធ្វើទុក្ខបុកម្នេញ ដោយរដ្ឋមួយដោយសារពូជសាសន៍ សាសនា គំនិតនយោបាយ សញ្ជាតិ ឬសមាជិករបស់ក្រុមសង្គមណាមួយរបស់ពួកគេ។ នៅពេលដែលបុគ្គលម្នាក់ស្វែងរកឋានៈជាជនភៀសខ្លួន ប្រកាសថាខ្លួនគេជាជនភៀសខ្លួន ពួកគេគួរតែទទួលបានការការពារដែលបានផ្តល់ជូនតាមអនុសញ្ញាស្តីពីជនភៀសខ្លួន រហូតដល់រដ្ឋធ្វើការកំណត់ថាតើពួកគេស្ថិតក្នុងនិយមន័យនៃជនភៀសខ្លួនឬក៏អត់ ក្នុងនីតិវិធីមួយដែលត្រូវបានហៅថាការកំណត់ឋានៈជនភៀសខ្លួន។ សិទ្ធិរួមមានតម្រូវការជាមូលដ្ឋាន ការការពារផ្លូវច្បាប់ និងសិទ្ធិការងារ។ ការការពារជាមូលដ្ឋានការមិនបញ្ជូនបុគ្គល (បញ្ជូនត្រលប់ទៅវិញ) ត្រលប់ទៅប្រទេសដែលពួកគេព្យាយាមរត់គេចចេញ។ បុគ្គលដែលស្ថិតក្នុងនិយមន័យនេះ ប៉ុន្តែមិនអាចទៅដល់ប្រទេសដទៃអាចត្រូវបានហៅថាជាបុគ្គលដែលត្រូវបានជម្លៀសក្នុងប្រទេស។

មានប្រជាជនជាជនភៀសខ្លួនពីរប្រភេទនៅអាស៊ីអាគ្នេយ៍៖ ជនភៀសខ្លួនដែលមកពីខាងក្រៅតំបន់ ដែលភាគច្រើនជាជនភៀសខ្លួនរស់នៅទីក្រុងដែលមកពីអាស៊ីខាងកើត និងអាហ្វ្រិក និងអ្នកនៅក្នុងតំបន់ ដែលភាគច្រើនជាជនជាតិមីយ៉ាន់ម៉ា ក្នុងប្រទេសម៉ាឡេស៊ី និងថៃ។ ជនភៀសខ្លួនរស់នៅក្នុងស្ថានភាពចំនួនពីរ នៅក្នុងជំរុំ ដែលមាននៅតាមព្រំដែនថៃ មីយ៉ាន់ម៉ា និងជនភៀសខ្លួនដែលរស់នៅទីក្រុងដែលជាប្រជាជនភាគច្រើនមកពីខាងក្រៅតំបន់ហើយរស់នៅក្នុងទីក្រុង ដូចជាបាងកក ហ្សាកាតា កូឡាឡាំពួ ខណៈពេលដែលពួកគេរង់ចាំការទទួលស្គាល់ពី UNHCR ក្នុងក្តីសង្ឃឹមក្នុងការតាំងទីលំនៅឡើងវិញក្នុងតតិយប្រទេស។

## អង្គការជនភៀសខ្លួន

UNHCR ជាភ្នាក់ងាររបស់អង្គការសហប្រជាជាតិដែលធ្វើការជាមួយជនភៀសខ្លួន។ អង្គការនេះមានអាណត្តិក្នុងការការពារ ជួយ និងស្វែងរកដំណោះស្រាយដល់ជនភៀសខ្លួន។ អង្គការនេះមានភារកិច្ចក្នុងការជួយដល់បុគ្គលក្នុងស្ថានភាពដូចគ្នានឹងជនភៀសខ្លួន បុគ្គលដែលត្រូវបានជម្លៀសក្នុងប្រទេស បុគ្គលគ្មានសញ្ជាតិ អ្នកវិលត្រលប់មកវិញ និង បុគ្គលងាយរងគ្រោះ។ អង្គការនេះស្វែងរកដំណោះស្រាយយូរអង្វែងដូចជាការធ្វើមាតុភូមិនិវត្តន៍ ឬការតាំងទីលំនៅឡើងវិញសម្រាប់ប្រជាជនទាំងនេះ។ មាន

គួអង្គសង្គមស៊ីវិលជាច្រើនដូចជា NGOS ដែលផ្តល់សេវាមួយចំនួន ជំនួយផ្នែកច្បាប់ និងការតស៊ូមតិដល់ជនភៀសខ្លួន។

## ភាពគ្មានសញ្ជាតិ

'គ្មានសញ្ជាតិ' មានន័យថាមិនមានរដ្ឋចាត់ទុកបុគ្គលម្នាក់ថាជាពលរដ្ឋតាមច្បាប់របស់ខ្លួនឡើយ។ ប្រជាជនគ្មានសញ្ជាតិអាចប្រឈមការរំលោភបំពានពេញមួយជីវិតតាមវិធីសាស្ត្រជាច្រើន ដូចជាខ្វះលទ្ធភាពក្នុងការទទួលបានសេវាកម្មរដ្ឋាភិបាល និងការគម្រាមកំហែងដល់សន្តិសុខ។ បញ្ហានៃភាពគ្មានសញ្ជាតិមិនត្រូវអើពើ រហូតដល់ពេលថ្មីៗនេះ។ បុគ្គលអាចទទួលបានសញ្ជាតិតាមរយៈឈាម ទីកន្លែងកំណើត អាពាហ៍ពិពាហ៍ និងសញ្ជាតូបនីយកម្ម។ ខណៈពេលដែលប្រទេសភាគច្រើននៅអាស៊ីអាគ្នេយ៍អនុញ្ញាតឲ្យមានសញ្ជាតិតាមរយៈអាពាហ៍ពិពាហ៍ និងសញ្ជាតូបនីយកម្ម លក្ខខណ្ឌអាចមានការពិបាក និងថ្លៃ។ ភាពគ្មានសញ្ជាតិ *តាមច្បាប់* មានន័យថាបុគ្គលមិនមានសញ្ជាតិតាមផ្លូវច្បាប់។ ភាពគ្មានសញ្ជាតិ *តាមអង្គហេតុ* សំដៅលើបុគ្គលដែលជាការពិតមិនមានសញ្ជាតិ ប៉ុន្តែ មានគុណវុឌ្ឍិតាមផ្លូវច្បាប់ក្នុងការទទួលបានសញ្ជាតិ។

## អនុសញ្ញាស្តីពីជនគ្មានសញ្ជាតិ

អនុសញ្ញាស្តីពីជនគ្មានសញ្ជាតិទាំងពីរ គឺអនុសញ្ញាពាក់ព័ន្ធនឹងឋានៈរបស់ជនគ្មានសញ្ជាតិ (១៩៥៤) ដែលផ្តល់និយមន័យនៃភាពគ្មានសញ្ជាតិ និងអនុសញ្ញាស្តីពីការកាត់បន្ថយភាពគ្មានសញ្ជាតិ (១៩៦១) ដែលផ្តល់មធ្យោបាយជាច្រើនដែលរដ្ឋ អាចកាត់បន្ថយការកើតមានឡើងនូវភាពគ្មានសញ្ជាតិ។ ភាពគ្មានសញ្ជាតិត្រូវបានទទួលស្គាល់ផងដែរដោយសន្ធិសញ្ញាដទៃដូចជាអនុសញ្ញាស្តីពីជនភៀសខ្លួន CRC CEDAW និង ICCPR។

## មូលហេតុ និងដំណោះស្រាយលើភាពគ្មានសញ្ជាតិ

ប្រជាជនអាចក្លាយទៅជាគ្មានសញ្ជាតិ ដោយសារពួកគេរស់នៅតាមតំបន់ព្រំដែនដែលរដ្ឋគ្រប់គ្រងពីចំងាយ ហើយជាកន្លែងដែលមានទំនាក់ទំនងទៀងទាត់តិចតួចជាមួយរដ្ឋ។ ពួកគេអាចក្លាយទៅជាគ្មានសញ្ជាតិ នៅពេលដែលពួកគេធ្វើដំណើររយៈពេលវែង ឬមានកូននៅក្រៅប្រទេសកំណើតរបស់ខ្លួន។ ពួកគេអាចបាត់បង់សញ្ជាតិនៅពេលដែលផ្ទេរពីសញ្ជាតិមួយទៅសញ្ជាតិផ្សេង។ ឈាមជ័រមិនស្មើគ្នា គឺនៅពេលដែលម្តាយមិនអាចបន្តសញ្ជាតិរបស់ខ្លួនដល់កូន អាចបង្កឲ្យមានភាពគ្មានសញ្ជាតិផងដែរ។

ចុងក្រោយ ប្រជាជនអាចបាត់បង់សញ្ជាតិ តាមរយៈការរើសអើង ដែលរដ្ឋាភិបាលជ្រើសរើស ក្នុងការមិនទទួលស្គាល់ក្រុមជនជាតិភាគតិចណាមួយថាជាពលរដ្ឋ។

មានការឆ្លើយតបចំនួនបួនក្នុងការដោះស្រាយបញ្ហានៃភាពគ្មានសញ្ជាតិ៖ ការកំណត់អត្តសញ្ញាណ ឬកំណត់ទីតាំងជនដែលគ្មានសញ្ជាតិ ក្នុងគោលបំណងផ្តល់ជូនពួកគេនូវសញ្ជាតិ; បង្ការ ឬធ្វើការផ្លាស់ប្តូរច្បាប់ និងចុះបញ្ជីកុមារដើម្បីបញ្ឈប់ការកើតមានឡើងនៃភាពគ្មានសញ្ជាតិ; កាត់បន្ថយ ឬផ្តល់សញ្ជាតិដល់ប្រជាជនដែលគួរតែមានសញ្ជាតិ និងការពារ ឬ ធ្វើការធានាថាសិទ្ធិ មនុស្សរបស់ប្រជាជន ដែលគ្មានសញ្ជាតិត្រូវបានទទួលស្គាល់។

## ខ. សំណួរប្រលង ឬសំណួរងាយស្រួល

- ធ្វើការស្រាវជ្រាវនៅក្នុងប្រទេសរបស់អ្នក តើមានប្រជាជន (ប្រសិនជាមាន) គ្មានសញ្ជាតិ ជនភៀសខ្លួន ពលករទេសន្តប្រវេសន៍ និងជនរងគ្រោះនៃការជួញដូរដែរឬទេ។ ហេតុអ្វីបានជាប្រទេសរបស់អ្នកមានប្រជាជនទាំងនេះ?

- តើភាពងាយរងគ្រោះ និងការគម្រាមកំហែងអ្វីខ្លះដែលប្រជាជន មិនមែនជាពលរដ្ឋប្រឈមក្នុងប្រទេសរបស់អ្នក? ធ្វើការពិចារណាលើការរើសអើងលើប្រជាជនដែលមិនមែនជាពលរដ្ឋ ហើយមានវិធានការអ្វីដែលត្រូវបានចាត់ ដើម្បីការពារសិទ្ធិរបស់ប្រជាជនមិនមែនជាពលរដ្ឋទាំងនេះដែរឬទេ?
- តើសន្ធិសញ្ញាណាមួយក្នុងចំណោមសន្ធិសញ្ញាទាំងបួន ដែលបានរៀបរាប់ក្នុងផ្នែក ៤.២ ត្រូវបានផ្តល់សច្ចាប័នដោយរដ្ឋាភិបាលរបស់អ្នក? ចំពោះសន្ធិសញ្ញាដែលរដ្ឋាភិបាលអ្នកបានផ្តល់សច្ចាប័ន អ្នកគិតថាហេតុអ្វីបានជារដ្ឋាភិបាល អ្នកផ្តល់សច្ចាប័ន? ចំពោះសន្ធិសញ្ញាដែលរដ្ឋាភិបាលអ្នកមិនបានផ្តល់សច្ចាប័ន តើអ្វីដែលបង្អាក់រដ្ឋាភិបាលអ្នកពីការផ្តល់សច្ចាប័ន?
- តើជនភៀសខ្លួនអាចទាមទារសិទ្ធិរបស់ខ្លួនក្នុងប្រទេសរបស់អ្នកដែរឬទេ? ប្រសិនជាបុគ្គលជាជនភៀសខ្លួន តើសេវាកម្ម និងការការពារអ្វីដែលពួកគេនឹងទទួលបាន?
- តើអ្វីទៅជាច្បាប់ស្តីពីសញ្ជាតិក្នុងប្រទេសរបស់អ្នក ហើយតើច្បាប់នេះផ្តល់សញ្ជាតិស្មើគ្នាដល់ស្ត្រី កុមារ និងក្រុមជនជាតិភាគតិចដែរឬទេ?

- តើប្រទេសអ្នកបានចូលរួមក្នុងការកាត់បន្ថយភាពគ្មានសញ្ជាតិ តាមវិធីដូចម្តេចខ្លះ? តើមានការកែសម្រួលច្បាប់ ឬផ្លាស់ប្តូរគោលនយោបាយកាលពីពេលថ្មីៗនេះដែរឬទេពាក់ព័ន្ធនឹងការផ្តល់សញ្ជាតិ? ឬការផ្លាស់ប្តូរលើគោលនយោបាយក្នុងការផ្តល់សញ្ជាតិដែរឬទេ?

# គ. ឯកសារពិគ្រោះបន្ថែម៖

## ទិដ្ឋភាពទូទៅនៃទេសន្តប្រវេសន៍ ប្រជាជនមិនមែនជាពលរដ្ឋ និងសិទ្ធិនៅអាស៊ីអាគ្នេយ៍

- ការស្ទង់មតិនៃស្ថានភាពបច្ចុប្បន្ន និងប្រវត្តិនៃទេសន្តប្រវេសន៍ក្នុងតំបន់មាននៅក្នុងរបាយការណ៍ស្រាវជ្រាវពីអង្គការអន្តរជាតិទេសន្តប្រវេសន៍ (IOM)
- អង្គការអន្តរជាតិខាងការងារ
- អត្ថបទទេសន្តប្រវេសន៍អាស៊ី និងប៉ាស៊ីហ្វិកពីប្រទេសហ្វីលីពីនចេញរបាយការណ៍ស្រាវជ្រាវជាទៀងទាត់ក្នុងវិស័យនេះ។

មានអត្ថបទតិចតួចបំផុត ដែលធ្វើការសិក្សាពីសិទ្ធិជនមិនមែនជាពលរដ្ឋជាទូទៅ ក្រៅពីកិច្ចការរបស់ David Weissbordt អ្នករាយការណ៍ពិសេសពីប្រជាជនមិនមែនជាពលរដ្ឋដែលមាននៅលើបណ្តាញអ៊ិនធឺណែត។

## ជនភៀសខ្លួន

អ្នកនិពន្ធដូចដែលបានរៀបរាប់ខាងក្រោមបានសរសេរសៀវភៅស្តីពីច្បាប់ និងសិទ្ធិជនភៀសខ្លួន (ហើយស្នាដៃរបស់ពួកគេស្រាវជ្រាវពីអ៊ិនធឺណែតបាន)៖

- Guy Goodwin-Gill and Jane McAdam
- BS Chimni.
- James Hathaway
- Vitit Muntarbhorn មានសៀវភៅសរសេរក្នុងឆ្នាំ ១៩៩២ ដែលមានចំណងជើងថា ឋានៈនៃជនភៀសខ្លួននៅអាស៊ី ជាសៀវភៅពុម្ពអនឡាញ ដែលមិនបង់ថ្លៃស្តីពីច្បាប់ជនភៀសខ្លួន ហើយសៀវភៅនេះមានផ្នែកមួយនិយាយអំពីការការពារជនភៀសខ្លួននៅអាស៊ី។

សម្រាប់ការស្រាវជ្រាវពីបញ្ហាជនភៀសខ្លួន និងសិទ្ធិជនភៀសខ្លួន គេហទំព័ររបស់ UNHCR មានសារៈសំខាន់ណាស់ ជាពិសេសអត្ថបទពី របាយការណ៍សកល

បញ្ហាថ្មីៗក្នុងការស្រាវជ្រាវពីជនភៀសខ្លួន ទស្សនាវដ្តីជនភៀសភៀសខ្លួន និងសៀវភៅណែនាំពីជនភៀសខ្លួន។

ឯកសារភាគច្រើនស្តីពីជនភៀសខ្លួន និងភាពគ្មានសញ្ជាតិមាននៅក្នុងគេហទំព័រ Refworld ។

ការពិនិត្យមើលទេសន្តប្រវេសន៍ដោយបង្ខំ ជាទស្សនាវដ្តីដ៏មានប្រយោជន៍មួយដែលមាននៅលើបណ្តាញអ៊ិនធឺណែត ហើយអាចទាញយកបានដោយមិនបាច់បង់ថ្លៃ។

## ភាពគ្មានសញ្ជាតិ

ការណែនាំ និងអត្ថបទដទៃទៀតរួមមាន៖

- អង្គការទំនុកចិត្តនៃសិទ្ធិស្មើគ្នា៖ អង្គការនេះបញ្ចេញរបាយការណ៍ជាច្រើនរួមមានកាលពីពេលថ្មីនេះគឺ *Unravelling Anamoly*
- ជនភៀសខ្លួនអន្តរជាតិមានកម្មវិធីមួយស្តីពីភាពគ្មានសញ្ជាតិដែលមាន របាយការណ៍ស្រាវជ្រាវ
- Refworld មានឯកសារជាច្រើនស្តិពីអត្ថបទច្បាប់អន្តរជាតិ ស្តីពីភាព គ្មានសញ្ជាតិ
- គេហទំព័ររបស់ UNHCR ស្តីពីភាពគ្មានសញ្ជាតិមានសេចក្តីណែនាំ ការស្រាវជ្រាវ និងតណភ្ជាប់ទៅនឹងអនុសញ្ញាជាច្រើន។

# 7

# សិទ្ធិរបស់ជនមិនមែនជាពលរដ្ឋ៖ ពលករទេសន្តប្រវេសន៍ និងមនុស្សដែលត្រូវបានជួញដូរ

ជំពូកនេះផ្តោតសំខាន់លើក្រុមមិនមែនជាពលរដ្ឋ ដែលជាពលករទេសន្តប្រវេសន៍ និងក្រុមគ្រួសាររបស់ពួកគេ និងមនុស្សដែលត្រូវបានជួញដូរ។ ប្រភេទជនមិនមែនជាពលរដ្ឋទាំងនេះ មានភាពពាក់ព័ន្ធគ្នាទៅវិញទៅមក ហើយពេលខ្លះក្រុមទាំងពីរនេះមិនអាចសូម្បីតែញែកចេញពីគ្នាឲ្យបានច្បាស់លាស់នោះទេ។

ប្រភេទជនមិនមែនជាពលរដ្ឋទាំងនេះមានភាពពាក់ព័ន្ធគ្នាទៅវិញទៅមក ហើយពេលខ្លះក្រុមទាំងពីរនេះមិនអាចសូម្បីតែញែកចេញពីគ្នាឲ្យបានច្បាស់លាស់។ ជាឧទាហរណ៍ ប្រជាជនជាច្រើនដែលត្រូវបានជួញដូរ បានចាប់ផ្តើមដំបូងពីពលករទេសន្តប្រវេសន៍។ នៅពេលដែលពលករទេសន្តប្រវេសន៍ត្រូវបានកេងប្រវ័ញ្ច ហើយមិនអាចដើរហើរដោយសេរី បុគ្គលនោះអាចត្រូវបានចាត់ទុកថាត្រូវបានជួញដូរ។ យ៉ាងណាមិញ ធ្វើការកំណត់ថាពេលណាដែលបុគ្គលត្រូវបានកេងប្រវ័ញ្ច ឬមិនអាចធ្វើការដើរហើរដោយសេរីភាពអាចមានការលំបាក។ ជាពិសេសនេះជាស្ថានភាពពិតជាក់ស្តែងនៅក្នុងអាស៊ីអាគ្នេយ៍ នៅពេលដែលពលករទេសន្តប្រវេសន៍រស់នៅក្នុងភាពភ័យខ្លាចនៃការជួញដូរ ដូចនេះមានសារៈសំខាន់ ក្នុងការធ្វើការដាក់សិទ្ធិរបស់ពលករទេសន្តប្រវេសន៍ឲ្យប្រគៀកគ្នានឹងស្តង់ដារ និងសកម្មភាពដែលដោះស្រាយការជួញដូរមនុស្ស។

## ៧.១ ពលករទេសន្តប្រវេសន៍

ក្នុងប្រវត្តិសាស្រ្ត ប្រជាជនបានចាកចេញពីផ្ទះរបស់ខ្លួន និងធ្វើដំណើរដើម្បីស្វែងរកការងារ។ កំណត់ត្រាបង្ហាញថាជនជាតិចិន និងឥណ្ឌាបានធ្វើចំណាកស្រុកទៅកាន់អាស៊ីអាគ្នេយ៍អស់រយៈពេលរាប់រយឆ្នាំមកហើយ។ នេះអាចជាពលករហត្ថកម្មក្នុងចំការដំណាំចក្រភពអង់គ្លេសក្នុងអំឡុងពេលសតវត្សទី ១៨ និង ១៩ ឬតាមរយៈគ្រួសារផ្សាភ្ជាប់ទៅនឹងប្រទេសដូចជាឥណ្ឌូនេស៊ី និងថៃ។ ពេលបច្ចុប្បន្នគឺជារឿងធម្មតាដែលប្រជាជនធ្វើការបំលាស់ដើម្បីធ្វើការងារ។ ប្រទេសនីមួយៗនៅតំបន់អាស៊ីអាគ្នេយ៍ពាក់ព័ន្ធនឹងដំណើរការទេសន្តប្រវេសន៍ ដែលអាចជាប្រទេសបញ្ជូន ឬប្រទេសទទួល ឬទាំងពីរ។ យោងទៅតាម ILO ចំនួនពាក់កណ្តាលនៃជនទេសន្តប្រវេសន៍ចំនួនប្រហែលជា ១៧៥ លាននាក់ជុំវិញពិភពលោកគឺជាពលករ។ យ៉ាងណាមិញ ទើបតែពេលថ្មីៗនេះប៉ុណ្ណោះ ដែលការការពារពលករទេសន្តប្រវេសន៍ត្រូវបានចាត់ទុកថាជាបញ្ហាសិទ្ធិមនុស្ស។ សិទ្ធិពលករទេសន្តប្រវេសន៍មានតាំងពីមុនសង្គ្រាមលោកលើកទីពីរមកម្ល៉េះ តាមរយៈ ILO ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩១៩ ទោះបីជារហូតដល់ពេលបន្ទាប់ពីសង្គ្រាមលោកលើកទីពីរ ដែលអនុសញ្ញាស្តីពីពលករទេសន្តប្រវេសន៍ត្រូវបានអនុម័ត។ ត្រឹមទសវត្សឆ្នាំ ១៩៧០ ការកើនឡើងនៃពលករទេសន្តប្រវេសន៍មិនទៀងទាត់ (កាលដើមឡើយត្រូវបានហៅថាជាពលករជាភ្ញៀវ) បានក្លាយជាកង្វល់ក្នុងទ្វីបអឺរ៉ុប។ ប្រជាជនជាច្រើនមកពីប្រទេសទួរគី លីបង់ និងប្រទេសមជ្ឈឹមបូព៌ាដទៃទៀតបានធ្វើដំណើរទៅកាន់ប្រទេសអាឡឺម៉ង់ខាងលិច បារាំង និងប្រទេសអឺរ៉ុបដែលមានការអភិវឌ្ឍដទៃទៀត។ ដោយសារពលករទាំងនេះភាគច្រើនជាពលករមិនទៀងទាត់ នាំឲ្យមានការកើនឡើងក្នុងការពារទេសន្តប្រវេសន៍ការងារដែលលួចលាក់ គ្រោះថ្នាក់

និងមិនស្របច្បាប់។ តាមប្រព័ន្ធផ្សព្វផ្សាយ មានរឿងរ៉ាវនៃមនុស្សដែលធ្វើការក្នុងលក្ខខណ្ឌដូចទាសករ ឬត្រូវបានស្លាប់តាមផ្លូវទៅអឺរ៉ុប ដែលពេលដែលទូករបស់ពួកគេបានលិច ឬដោយសារពួកគេថប់ខ្យល់ក្នុងកុងតឺន័របិទជិត (រឿងរ៉ាវស្រដៀងគ្នានេះនៅតែមានលើប្រព័ន្ធផ្សព្វផ្សាយពេលបច្ចុប្បន្នេះ)។ ការកាត់បន្ថយការគម្រាមកំហែងដល់ជីវិតទាំងនេះមិនត្រឹមតែមានសារៈសំខាន់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចាំបាច់ដើម្បីធ្វើឲ្យប្រសើរឡើងនូវស្តង់ដារជីវភាពរបស់ពលករទាំងនេះ។ ជាឧទាហរណ៍ ការបណ្តេញចេញទ្រង់ទ្រាយធំនៃជនជាតិអាស៊ីចេញពីប្រទេសអ៊ុយហ្គេនដា ក្នុងដើមទសវត្សឆ្នាំ ១៩៧០ ជម្រុញឲ្យមានការអំពាវនាវឲ្យ "មានសិទ្ធិដល់ប្រជាជនដែលមិនមែនជាពលរដ្ឋ" (ទោះបីជាការបណ្តេញស្រដៀងគ្នានេះ នៃជនជាតិឥណ្ឌាពីប្រទេសមីយ៉ាន់ម៉ាក្នុងដើមទសវត្សឆ្នាំ ១៩៦០ មិនបានទទួលការចាប់អារម្មណ៍ខ្លាំងក៏ដោយ)។

ការរើសអើង ការកេងប្រវ័ញ្ច និងការធ្លាក់ខ្លួនជាជនរងគ្រោះជាកង្វល់មួយសម្រាប់ទាំងប្រទេសបញ្ជូន និងប្រទេសទទួល។ មានបញ្ហាជាមូលដ្ឋានចំនួនពីរ គឺការរំលោភបំពានលើពលកម្មទេសន្តប្រវេសន៍ និងការជួញដូរ ដែលទាមទារឲ្យមានការដោះស្រាយ ប៉ុន្តែសំណួរគឺថាតើបញ្ហានេះត្រូវបានចាត់ទុកថាជាបញ្ហាតែមួយ ឬត្រូវបានចាត់ទុកថាជាបញ្ហាដាច់ដោយឡែកពីគ្នា។ ការឆ្លើយតបគឺថាចែងបញ្ហានេះជាពីរផ្សេងគ្នា ដូចនេះការការពារពលករទេសន្តប្រវេសន៍ត្រូវបានធ្វើឡើង តាមរយៈអនុសញ្ញាដែលពឹងផ្អែកលើសិទ្ធិ និង ILO ខណៈពេលដែលការជួញដូរត្រូវបានឆ្លើយតបជាទូទៅដោយច្បាប់ព្រហ្មទណ្ឌ។ ថាតើមធ្យោបាយនេះនឹងឈានឆ្ពោះទៅកាន់ការការពារដែលខ្លាំងក្លាមួយនោះ គឺស្ថិតក្រោមការជជែកវែកញែកនៅឡើយ។ ហេតុផលគឺថាបញ្ហាទាំងនេះខុសគ្នាតាមមធ្យោបាយមួយចំនួន ដោយរួមមានទាំងកម្រិត និងចរិកលក្ខណៈនៃការរំលោភបំពាន។ លើសពីនេះទៀត ដូចដែលបានបញ្ជាក់លម្អិតខាងក្រោម មានការសម្រេចចិត្តថាសិទ្ធិពលករទេសន្តប្រវេសន៍ត្រូវបានចាត់ទុកថាជាសិទ្ធិមនុស្ស ហើយការជួញដូរត្រូវបានចាត់ទុកថាជាបញ្ហាព្រហ្មទណ្ឌ។ លទ្ធផលនៃការបែងចែកនេះ គឺធ្វើឲ្យមានសន្ធិសញ្ញាផ្សេងៗគ្នា ដែលបានគ្រប់គ្រងដោយផ្នែកផ្សេងៗគ្នារបស់ UN ហើយមានកម្រិតផ្សេងៗគ្នានៃការគាំទ្រពីប្រជាជាតិជាសមាជិករបស់ UN ដែលមានសន្ធិសញ្ញាស្តីពីការជួញដូរដែលទទួលបានការចាប់អារម្មណ៍ទូលំទូលាយ ហើយសន្ធិសញ្ញាពលករទេសន្តប្រវេសន៍ត្រដាបត្រដួស ក្នុងការទទួលបានការទទួលស្គាល់ដោយមានចំនួនផ្តល់សច្ចាប័នតិចប៉ុណ្ណោះ។

## ផ្តោតសំខាន់លើ

### សេចក្តីផ្តើមពីអង្គការអន្តរជាតិខាងការងារ (ILO)

ILO ត្រូវបានបង្កើតឡើងក្នុងអំឡុងពេលសន្និសិទសន្តិភាពទីក្រុងប៉ារីស ដែលជាផ្នែកមួយនៃសង្គមប្រជាជាតិក្នុងឆ្នាំ ១៩១៩។ កាតព្វកិច្ចចម្បងរបស់អង្គការនេះគឺធ្វើការលើកកម្ពស់ និងការពារស្តង់ការងារអន្តរជាតិ ដែលអង្គការនេះសម្រេចបានតាមរយៈ ការអនុម័តអនុសញ្ញា (១៨៩ នៅឆ្នាំ២០១៤) និងអនុសាសន៍ (២០២ នៅឆ្នាំ២០១៤)។ អង្គការនេះមានរចនាសម្ព័ន្ធពិសេសដែលមានអង្គការចំនួនបីប្រភេទ៖ (១) សមាគមនិងសហជីពកម្មករ (២) សមាគមនិយោជក (៣) រដ្ឋ។ អង្គការនេះមានរដ្ឋសមាជិកចំនួន ១៨៥ រួមមានប្រទេសទាំងអស់នៃប្រទេសអាស៊ីអាគ្នេយ៍ (ទោះបីជាសមាជិកភាពរបស់ប្រទេសមីយ៉ាន់ម៉ាត្រូវបានកម្រិតពីឆ្នាំ ១៩៩៨ ដល់ឆ្នាំ ២០១២ ក៏ដោយ ដោយសារអង្គការនេះមិនបានបំពេញកាតព្វកិច្ចគ្រប់គ្រាន់ ក្នុងការលុបបំបាត់ពលកម្មដោយបង្ខំ)។ ILO បានបង្កើតស្តង់ដារជាច្រើនក្នុងសិទ្ធិការងារ ដោយរួមមានការសម្រាកលំហែមាតុភាព ដែនកំណត់លើពលកម្មកុមារ ស្តង់ដារសុវត្ថិភាពនៅកន្លែងការងារ និងស្តង់ដារប្រាក់ឈ្នួលអប្បរមា។ លើសពីនេះទៀត ILO បាននីតិវិធីរបាយការណ៍ដូចគ្នាច្រើននឹង UN ដែរ ដែលបំពេញដោយយន្តការបណ្តឹង។ ដើម្បីក្លាយជាសមាជិករបស់ ILO រដ្ឋត្រូវតែព្រមព្រៀងលើអនុសញ្ញាស្នូលទាំងប្រាំបី។ អនុសញ្ញាទាំងនេះគ្រប់ដណ្តប់បញ្ហាចំនួនបួន ដែលត្រូវបានចាត់ទុកថាជាកត្តាមូលដ្ឋានក្នុងការការពារពលករ៖ ការការពារពីទាសភាព សិទ្ធិសហជីព សមភាពនៅកន្លែងការងារ (ដែលសំខាន់សម្រាប់ស្ត្រី) និងការការពារស្ត្រី។

១. អនុសញ្ញាលេខ ២៩ ស្តីពីពលកម្មដោយបង្ខំ(១៩៣០)
២. អនុសញ្ញាលេខ ៨៧ ស្តីពីសេរីភាពបង្កើតសមាគម និងការការពារសិទ្ធិនៃការបង្កើតសមាគម(១៩៤៨)
៣. អនុសញ្ញាលេខ ៩៨ ស្តីពីសិទ្ធិក្នុងការ បង្កើតសមាគម និងសិទ្ធិនៃការចរចារជាសមូហភាព(១៩៤៩)
៤. អនុសញ្ញាលេខ ១០០ ស្តីពីប្រាក់ឈ្នួលស្មើគ្នា (១៩៥១)
៥. អនុសញ្ញាលេខ ១០៥ ស្តីពីការលុបបំបាត់ពលកម្មដោយបង្ខំ (១៩៥៧)
៦. អនុសញ្ញាលេខ ១១១ ស្តីពីការរើសអើង (ការងារ និងមុខរបរ) (១៩៥៨)
៧. អនុសញ្ញាលេខ ១៣៨ ស្តីពីអាយុអប្បរមា (១៩៧៣)
៨. អនុសញ្ញាលេខ ១៨២ស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ(១៩៩៩)។

ការការពារដែលមានស្តង់ដារ ត្រូវបានរៀបចំមុនពេលការអនុម័តអនុសញ្ញាអន្តរជាតិរបស់ UN ស្តីពីការការពារសិទ្ធិពលករទេសន្តប្រវេសន៍គ្រប់រូប និងសមាជិកក្រុមគ្រួសាររបស់ពួកគេ (ICRMW) ក្នុងឆ្នាំ ១៩៩០។ ខណៈពេលដែល UN មិនបានចាប់ផ្តើមក្នុងការដោះស្រាយបញ្ហាទេសន្តប្រវេសន៍រហូតដល់ទសវត្សឆ្នាំ ១៩៧០ ជាចម្បងដោយសារការព្រមព្រៀងជាមួយនឹង ILO ក្នុងទសវត្សឆ្នាំ ១៩៤០ ថា ILO នឹងការពារជនទេសន្តប្រវេសន៍ជាពលករ ហើយ UN នឹងការពារដល់ជនទេសន្តប្រវេសន៍ជាជនបរទេស ILO បានចាប់ផ្តើមអនុម័តអនុសញ្ញាពីបញ្ហានេះ។

អនុសញ្ញា ILO ដំបូងបំផុតគឺអនុសញ្ញាលេខ ៦៦ ពាក់ព័ន្ធនឹងទេសន្តប្រវេសន៍សម្រាប់ការងារ ប៉ុន្តែដោយសារមិនមានរដ្ឋណាមួយបានផ្តល់សច្ចាប័នលើអនុសញ្ញានេះនោះទេ ដូចនេះមិនបានចូលជាធរមាននោះទេ។ អនុសញ្ញាជនទេសន្តប្រវេសន៍ចំនួនពីរត្រូវបានអនុម័តក្នុងឆ្នាំក្រោយសង្គ្រាមៈ អនុសញ្ញាលេខ ៩៧ (ដែលពីមុនជាអនុសញ្ញាលេខ ៦៦) និងអនុសញ្ញាលេខ ១៤៣ (ពាក់ព័ន្ធនឹងទេសន្តប្រវេសន៍ក្នុងលក្ខខណ្ឌរំលោភបំពាន និងការលើកកម្ពស់ឱកាស និងការប្រព្រឹត្តមកលើស្មើគ្នាដល់ពលករទេសន្តប្រវេសន៍) ។ អនុសញ្ញាលេខ ១៤៣ ជាទូទៅត្រូវបានស្គាល់ថាជាអនុសញ្ញាពលករទេសន្តប្រវេសន៍របស់ ILO ប៉ុន្តែអនុសញ្ញានេះក៏ទទួលរងនូវការទទួលបានការផ្តល់សច្ចាប័នតិចផងដែរ (២៤រដ្ឋត្រឹមឆ្នាំ ២០១៣ ហើយពីអាស៊ីអាគ្នេយ៍មានតែប្រទេសហ្វីលីពីនប៉ុណ្ណោះ)។ ការរំលោភបំពានដែលមានការកើនឡើងក្នុងទសវត្សឆ្នាំ ១៩៧០ ចុងបញ្ចប់បានបង្ខំឲ្យ UN ចូលខ្លួនពាក់ព័ន្ធ ប៉ុន្តែរហូតដល់ចុងទសវត្សឆ្នាំ ១៩៧០ ប៉ុណ្ណោះដែលមានឆន្ទៈនយោបាយគ្រប់គ្រាន់ ក្នុងការចាប់ផ្តើមសន្ធិសញ្ញាការពារពលករទេសន្តប្រវេសន៍។

ការពិភាក្សាដែលបានធ្វើឡើងរវាង UN និង ILO លើថាតើស្ថាប័នណាគួរតែគ្រប់គ្រងសិទ្ធិពលករទេសន្តប្រវេសន៍ ប៉ុន្តែនៅចុងបញ្ចប់ UN គឺជាស្ថាប័នដែលសាកសមបំផុត។ មានហេតុផលមួយចំនួនចំពោះការសម្រេចចិត្តនេះ។ ជាដំបូង ILO មានកំណត់ត្រាទាបនៃការផ្តល់សច្ចាប័នពីរដ្ឋ ហើយសង្ឃឹមថា UN អាចធ្វើឲ្យចំនួនផ្តល់សច្ចាប័នកើនឡើង (ទោះបីជានេះអាចជាការជជែកវែកញែកបានចំពោះអនុសញ្ញាពលករទេសន្តប្រវេសន៍ក៏ដោយ)។ ទីពីរ UN មានសារៈប្រយោជន៍ដល់ផលប្រយោជន៍របស់ប្រទេសកំពុងអភិវឌ្ឍន៍ ដោយសារមហាសន្និបាតជាកន្លែងដែលបម្រើផលប្រយោជន៍ដល់ប្រទេសកំពុងអភិវឌ្ឍន៍ ដោយសារតែមហាសន្និបាតគាំទ្រនូវការបោះឆ្នោតដោយសម្លេងភាគច្រើន (គឺចំនួន ១៤០ លើ ១៩៣សម្លេង)។ ចុងក្រោយ សន្ធិសញ្ញាសិទ្ធិមនុស្សមួយមានការពង្រីកនូវវិសាលភាពពាក់ព័ន្ធនឹងការការពារជាងសន្ធិសញ្ញារបស់ ILO ដែលសន្ធិ សញ្ញា ILO ផ្តោតសំខាន់លើសិទ្ធិរបស់ពលករតែមួយប៉ុណ្ណោះ។ នេះត្រូវបានបង្ហាញច្បាស់ក្នុងចំណងជើងនៃសន្ធិសញ្ញាតែម្តង ដែលរួមបញ្ចូលសិទ្ធិរបស់គ្រួសារពលករផងដែរ។

ផ្តោតសំខាន់លើ

## អនុសញ្ញា និងអនុសាសន៍ ILO ពាក់ព័ន្ធនឹងពលករទេសន្តប្រវេសន៍

អនុសញ្ញាសំខាន់ៗ ដែលការពារពលករទេសន្តប្រវេសន៍មានដូចខាងក្រោម៖

- អនុសញ្ញាពាក់ព័ន្ធនឹងទេសន្តប្រវេសន៍ការងារ (លេខ ៩៧)
- អនុសញ្ញាពាក់ព័ន្ធនឹងទេសន្តប្រវេសន៍ក្នុងលក្ខខណ្ឌរំលោភបំពាន និងការលើកកម្ពស់ឱកាស និងការប្រព្រឹត្តស្មើភាពគ្នាលើពលករទេសទេសន្តប្រវេសន៍ (លេខ ១៤៣)
- អនុសាសន៍ពាក់ព័ន្ធនឹងទេសន្តប្រវេសន៍ការងារ (លេខ ៨៦)
- អនុសាសន៍ពាក់ព័ន្ធនឹងពលករទេសន្តប្រវេសន៍ (លេខ ១៥១)
- អនុសញ្ញាពាក់ព័ន្ធនឹងពលកម្មដោយបង្ខំ ឬដាច់ខាត (លេខ ២៩)
- អនុសញ្ញាពាក់ព័ន្ធនឹងការលុបបំបាត់ពលកម្មដោយបង្ខំ (លេខ ១០៥)
- អនុសញ្ញាអ្នកជួយកិច្ចការផ្ទះ (លេខ ១៨៩)

## ៧.២ អនុសញ្ញាស្តីពីការការពារសិទ្ធិរបស់ពលករទេសន្តប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ(ICRMW)

ខណៈពេលដែលការព្រាង ICRMW បានចាប់ផ្តើមក្នុងចុងទសវត្សឆ្នាំ១៩៧០ វាចំណាយពេលរហូតដល់ទៅមួយទសវត្ស ដើម្បីសម្រេចបាននូវសេចក្តីព្រាងនេះ ហើយសន្ធិសញ្ញាត្រូវបានអនុម័តដោយមហាសន្និបាតនៅថ្ងៃទី ៨ ខែធ្នូ ឆ្នាំ ១៩៩០។ ICRMW ត្រូវចំណាយពេលដល់ទៅ ១៣ឆ្នាំបន្ថែមទៀតដើម្បីទទួលបានការផ្តល់សច្ចាប័នជាចាំបាច់ចំនួន២០ ដើម្បីឲ្យសន្ធិសញ្ញានេះចូលជាធរមាននៅថ្ងៃទី ១ ខែកក្កដា ឆ្នាំ២០០៣។ ប្រទេសហ្វីលីពីន និងឥណ្ឌូនេស៊ីជារដ្ឋតែពីរគត់ពីអាស៊ីអាគ្នេយ៍ដែលជាភាគីនៃ ICRMW។ រដ្ឋទទួល ឬរដ្ឋដែលមានចំនួនពលករទេសន្តប្រវេសន៍ច្រើនដូចជាប្រទេសថៃ ម៉ាឡេស៊ី និងសឹង្ហបុរី មានភាពស្ទាក់ស្ទើរក្នុងការផ្តល់សច្ចាប័នលើអនុសញ្ញា។ នេះជារឿងអកុសល ដោយសារវាធ្វើឲ្យមានការប៉ះពាល់ដល់ភាពជាសកល និងការអនុវត្តនៃអនុសញ្ញា។ សិទ្ធិមនុស្សរបស់ពលករទេសន្តប្រវេសន៍ មានភាពទន់ខ្សោយនៅកន្លែងដែលភាគច្រើនមានការរំលោភបំពានកើតឡើង។

មានហេតុផលជាច្រើន នៃការទទួលបានការផ្តល់សច្ចាប័នតិចទូទាំងពិភពលោក។ ស្ទើរតែការផ្តល់សច្ចាប័នទាំងអស់គឺមកពីប្រទេស ដែលបញ្ជូនពលករទេសន្តប្រវេសន៍ទៅបរទេស។ ការលើកលែងមួយចំនួនគឺជាប្រទេសដែលមានទាំងលំហូរចូល និងលំហូរចេញនៃពលករទេសន្តប្រវេសន៍ ឬ ដើរតួនាទីជាប្រទេសឆ្លងកាត់ដូចជា ម៉ិចស៊ិចកូ អេហ្ស៊ីប និងអាហ្សង់ទីន។ ជាទូទៅរដ្ឋាភិបាលមានភាពស្ទាក់ស្ទើរក្នុងការផ្តល់សច្ចាប័ន ដោយសារកង្វល់អំពីកាតព្វកិច្ចដែលអនុសញ្ញានឹងដាក់មកលើ ក្នុងការគ្រប់គ្រងវិស័យពលករទេសន្តប្រវេសន៍ ដែលពេលខ្លះអាចមានការងារច្រើន។ ជាឧទាហរណ៍ ប្រទេសដូចជា សហរដ្ឋអាមេរិក រុស្ស៊ី អាឡឺម៉ង់ និងអារ៉ាប៊ីសាអូឌីត ដែលប្រទេសទាំងនេះមានចំនួនពលករទេសន្តប្រវេសន៍ចំនួនប្រាំលាននាក់រៀងៗខ្លួន។ ក្នុងប្រទេសដូចជាសឹង្ហបូរី និងគូវ៉ែត ចំនួនពលករទេសន្តប្រវេសន៍មានចំនួនប្រហែលជា ៥% នៃប្រជាជនបម្រើការងារ។ ការផ្លាស់ប្តូរលក្ខខណ្ឌសម្រាប់ពលករទេសន្តប្រវេសន៍អាចប៉ះពាល់ដល់សេដ្ឋកិច្ចរបស់ពួកគេ។ លក្ខណៈពិតប្រាកដនៃផលប៉ះពាល់អាចជជែកវែកញែកបាន ដោយសារមានផលប្រយោជន៍វិជ្ជមានពីការកើនឡើងនៃការការពារពលករ ជាមួយនឹងការចំណាយផ្នែកសេដ្ឋកិច្ចមួយចំនួន។

អនុសញ្ញាពលករទេសន្តប្រវេសន៍បានពង្រីកការការពារបន្ថែម ពីលើស្តង់ដារពីមុនតាមមធ្យោបាយសំខាន់ៗមួយចំនួន។ ការរួមចំនែកសំខាន់មួយគឺការរួមបញ្ចូលនូវពលករទេសន្តប្រវេសន៍ដែលមិនមានឯកសារក្នុងនិយមន័យនៃពលករទេសន្តប្រវេសន៍។

## ៧.២.១ និយមន័យនៃពលករទេសន្តប្រវេសន៍

និយមន័យនៃពលករទេសន្តប្រវេសន៍ក្នុង ICRMW ត្រូវបានកត់សម្គាល់ដោយសារមានបរិយាប័ន្នៈ ពលករទេសន្តប្រវេសន៍សំដៅលើ "ជាបុគ្គលដែលនឹងចូលរួម កំពុងចូលរួម ឬធ្លាប់បានចូលរួមក្នុងសកម្មភាពដែលទទួលបានប្រាក់កម្រៃក្នុងរដ្ឋមួយដែលមិនមែនជាសញ្ជាតិរបស់គាត់"។

ធាតុផ្សំសំខាន់នៃនិយមន័យនេះរួមមាន៖

១. ពលករទេសន្តប្រវេសន៍ទទួលបានសិទ្ធិមុនពេល អំឡុងពេល និងបន្ទាប់ពីការងារ។ សិទ្ធិរបស់ពលករមិនត្រូវបានបញ្ឈប់ នៅពេលដែលពួកគេបញ្ចប់ការងារនោះទេ (បើមិនដូច្នេះទេ វាជាការងាយស្រួលក្នុងការដកហូតសិទ្ធិណាមួយរបស់ពួកគេ ដោយគ្រាន់តែបញ្ឈប់ពួកគេ)។ លើសពីនេះទៀត គួរតែមានការការពារ

ដល់ពលករទេសន្តប្រវេសន៍ពីការរំលោភបំពាន នៅពេលដែលពួកគេត្រូវបានជ្រើសរើស និងធ្វើដំណើរទៅកន្លែងការងារផងដែរ។

២. ពលករត្រូវទទួលបានប្រាក់ឈ្នួល ដោយគ្រាន់តែដើរតួនាទីជាពលករម្នាក់ប៉ុណ្ណោះ។ មានន័យថា ការងារមិនចាំបាច់ស្របច្បាប់ ឬប្រភេទជាក់លាក់នៃការងារនោះទេ (ទោះបីជាសន្ធិសញ្ញា ពិតជាបានបែងចែកប្រភេទពិសេសមួយចំនួននៃការងារដែលនឹងត្រូវបានពិភាក្សាខាងក្រោមក៏ដោយ)។

៣. មិនមានការបែងចែករវាងពលករទេសន្តប្រវេសន៍ដែលមាន និងមិនមានឯកសារនោះទេ ពលករទេសន្តប្រវេសន៍សំដៅលើប្រជាជនដែលធ្វើការខាងក្រៅរដ្ឋនៃសញ្ជាតិរបស់ខ្លួនតែប៉ុណ្ណោះ។ ដូចនេះ រាល់ពលករទាំងអស់អាចទទួលបានសិទ្ធិទាំងនេះ (ទោះបីជាពលករទេសន្តប្រវេសន៍មានឯកសារ ក៏ដោយក៏ទទួលបានចង្កោមសិទ្ធិបន្ថែមផងដែរ)។

លើសពីនេះទៀត ដូចដែលសន្ធិសញ្ញាបានសង្កត់បញ្ជាក់នៅក្នុងចំណងជើង និងក្នុងមាត្រា ១ ពលករទេសន្តប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ គួរតែមានលទ្ធភាពក្នុងការទទួលបានសិទ្ធិទាំងនេះ។ ដូចនេះសន្ធិសញ្ញាគ្រប់ដណ្តប់ការការពារសម្រាប់ពលករ ប្តី/ប្រពន្ធ និងកូនៗរបស់ពួកគេ។ យ៉ាងណាមិញ នៅក្នុង ICRMW ប្រភេទជាក់លាក់មួយចំនួននៃប្រជាជន មិនត្រូវបានចាត់ទុកថាជាពលករទេសន្តប្រវេសន៍នោះទេ ហើយទាំងនេះរួមមានពលករដើម្បីការអភិវឌ្ឍន៍ អ្នកដែលធ្វើការនៅអង្គការអន្តរជាតិ ដូចជា UN និស្សិត ជនភៀសខ្លួន ជនគ្មានសញ្ជាតិ និងអ្នកវិនិយោគទុន។ សម្រាប់អ្នកទាំងនេះ មានយន្តការការពារផ្សេងសម្រាប់ពួកគេ ជាឧទាហរណ៍ ការការពារពីស្ថានកុងស៊ុលតាមរយៈស្ថានទូត ឬសន្ធិសញ្ញាដទៃដែលគ្រប់ដណ្តប់ស្ថានភាពទាំងនេះ (ដូចជាជនភៀសខ្លួន និងជនគ្មានសញ្ជាតិ)។

## ៧.២.២ សិទ្ធិពលករទេសន្តប្រវេសន៍ក្នុង ICRMW

ក្នុង ICRMW មានសិទ្ធិមនុស្សបីប្រភេទសម្រាប់ពលករទេសន្តប្រវេសន៍។ ជាដំបូង គឺសិទ្ធិមនុស្សដែលមានស្រាប់ដែលពលករទទួលបាន ប៉ុន្តែរដ្ឋាភិបាលខ្លះព្យាយាមមិនអើពើ។ ទីពីរ មានសិទ្ធិជាក់លាក់ថ្មីសម្រាប់ពលករទេសន្តប្រវេសន៍។ ទីបី មានសិទ្ធិសម្រាប់ប្រភេទជាក់លាក់នៃពលករទេសន្តប្រវេសន៍។ ពិនិត្យសិទ្ធិទាំងបីនេះតាមលំដាប់លំដោយ ICRMW បានបញ្ជាក់ឡើងវិញនូវសិទ្ធិមនុស្សដែលមានស្រាប់មួយចំនួនដូចជាសេរីភាពក្នុងការបញ្ចេញមតិ និងសាសនា និងសេរីភាពរួចផុតពីទារុណកម្ម និងទាសភាព។ អនុសញ្ញាក៏មាននូវសិទ្ធិផ្លូវច្បាប់មួយចំនួនដូចជាសិទ្ធិទទួលបានការជំនុះ

ជម្រះក្ដីដោយយុត្តិធម៌ និងសេរីភាពរួចផុតពីការចាប់ខ្លួនតាមទំនើងចិត្ត។ ខណៈពេលដែលប្រហែលជាមានការស្នាក់ស្ទើរ ដោយសារសិទ្ធិទាំងនេះ មាននៅក្នុងសន្ធិសញ្ញាដទៃរួចទៅហើយ ជាការសំខាន់ក្នុងការផ្ដល់ជូនជាពិសេសដល់ពលករទេសន្តប្រវេសន៍ ដើម្បីធានាថារដ្ឋាភិបាលមិនបង្កើតច្បាប់ ឬការអនុវត្តដើម្បីដកហូតសិទ្ធិទាំងនេះ។ ជាឧទាហរណ៍ រដ្ឋាភិបាលប្រហែលជាអាចមានគោល នយោបាយដែលចែងថាជនអន្តោប្រវេសន៍មិនស្របច្បាប់ មិនអាចអាចដាក់ពាក្យបណ្ដឹងទៅប៉ូលីស ច្បាស់ណាស់នេះគឺប្រឆាំងនឹងស្តង់ដារសិទ្ធិមនុស្សនៃការការពារស្មើភាព គ្នាចំពោះមុខច្បាប់។ បន្ថែមពីលើនេះទៀត ក្នុងការចែងឡើងវិញពីសិទ្ធិទាំងនេះ ធាតុផ្សំដែលមានការពាក់ព័ន្ធជាក់លាក់ជាមួយនឹងពលករទេសន្តប្រវេសន៍ ត្រូវបានបញ្ជាក់យ៉ាងច្បាស់ថែមទៀត។ ជាឧទាហរណ៍ ការផ្ទៀងផ្ទាត់នៃអត្តសញ្ញាណត្រូវធ្វើឡើងតាមច្បាប់ ហើយការឃុំខ្លួនជាក្រុមត្រូវបានចាត់ទុកថាជាការរំលោភបំពាន (ទោះបីជាការរំលោភបំពានទាំងពីរនេះជារឿងធម្មតានៅប្រទេសថៃ និងម៉ាឡេស៊ី)។

## ផ្តោតសំខាន់លើ

សិទ្ធិពលករទេសន្តប្រវេសន៍ និងគ្រួសាររបស់ពួកគេមានសិទ្ធិក្នុងការទទួលបាន ដោយមិនគិតពីស្ថានភាពឯកសារ

- ការមិនរើសអើង
- សេរីភាពចាកចេញពីប្រទេស និងទៅប្រទេសដើមកំណើតវិញ
- សិទ្ធិរស់រានមានជីវិត
- សេរីភាពពីការធ្វើទារុណកម្ម និងការព្យាបាលជំងឺ
- សេរីភាពពីទាសភាព ឬពលកម្មបង្ខំ
- សេរីភាពក្នុងការគិត មនសិការ និងសាសនា
- សេរីភាពនៃគំនិត និងការបញ្ចេញមតិ
- សេរីភាពពីការសម្រេចអាជ្ញាកណ្តាល ឬការជ្រៀតជ្រែកមិនស្របច្បាប់ ជាមួយនឹងឯកជន គ្រួសារ លំនៅដ្ឋាន ការឆ្លងឆ្លើយ និងទំនាក់ទំនងដទៃទៀត
- សិទ្ធិអចលនទ្រព្យ
- សិទ្ធិទទួលបានសេរីភាព និងសន្តិសុខបុគ្គល
- សិទ្ធិទទួលបានភាពជាមនុស្សនៅក្រោមច្បាប់នៅពេលមានការចាប់ខ្លួន និងឃុំខ្លួន
- សិទ្ធិទទួលបានព័ត៌មានស្មើគ្នា និងពីសាធារណៈដោយមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង
- ហាមឃាត់កម្មវិធីប្រតិសកម្ម នៃច្បាប់ព្រហ្មទណ្ឌ
- ហាមឃាត់ដាក់ពន្ធនាគារសម្រាប់ការមិនគោរពតាមលក្ខខណ្ឌ
- ហាមឃាត់ការបញ្ឈប់ការធ្វើដំណើរ ឬឯកសារអត្តសញ្ញាណ
- ហាមឃាត់បណ្តេញនៅមូលដ្ឋានរួម ឬដោយគ្មាននីតិវិធីត្រឹមត្រូវ

- សិទ្ធិមានជំនួយការទូត
- សិទ្ធិទទួលស្គាល់ជាបុគ្គលម្នាក់នៅចំពោះមុខច្បាប់
- សមភាពនៃការព្យាបាលរវាងប្រជាជាតិ និងពលករទេសន្តរប្រវេសន៍សម្រាប់លក្ខខណ្ឌការងារខ្លះ និងការបង់ប្រាក់
- សិទ្ធិចូលរួមក្នុងសហជីព
- សមភាពក្នុងការទទួលបានសន្តិសុខសង្គម
- សិទ្ធិទទួលបានការថែទាំវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់
- សិទ្ធិស្ដីពីកុមារទទួលបានឈ្មោះ ការចុះបញ្ជីកំណើត និងសញ្ជាតិ
- សមភាពក្នុងការទទួលបានការអប់រំសាធារណៈ

ICRMW ក៏ផ្ដល់សិទ្ធិជាក់លាក់ដល់ពលករទេសន្តប្រវេសន៍ផងដែរ។ ជាឧទាហរណ៍ មិនត្រូវមានការដកហូត ឬបំផ្លាញឯកសារអត្តសញ្ញាណនោះទេ (មាត្រា ២១)។ ការអនុវត្តទូទៅមួយជាមួយនឹងពលករទេសន្តប្រវេសន៍ គឺសម្រាប់រោងចក្រក្នុងការថែរក្សា ឬដកហូតឯកសារអត្តសញ្ញាណ ឬលិខិតឆ្លងដែនដើម្បីធ្វើឲ្យពួកគេមានការពិបាកក្នុងការចាកចេញពីការងារ ឬស្វែងរកការងារថ្មី។ ការរំលោភបំពាននេះ ធ្វើឲ្យពលករទេសន្តប្រវេសន៍កាន់តែមានភាពងាយរងគ្រោះ ពីការបៀតបៀនដោយប៉ូលីស ដោយសារពួកគេត្រូវបង់ប្រាក់សំណូក ពីព្រោះពួកគេមិនមានឯកសារអត្តសញ្ញាណដែលជាការតម្រូវដោយច្បាប់។ សិទ្ធិដទៃគឺសម្រាប់ពលករទេសន្តប្រវេសន៍ទទួលបានការប្រព្រឹត្តមកលើ និងលក្ខខណ្ឌការងារស្មើនឹងពលរដ្ឋ។ ទាំងនេះជាសិទ្ធិពាក់ព័ន្ធនឹងការស្នាក់នៅក្នុងប្រទេសសម្រាប់អំឡុងពេលមួយបន្ទាប់ ពីពួកគេបញ្ចប់ការងារ នេះនឹងបញ្ឈប់រដ្ឋមួយពីការបណ្ដេញពលករចេញភ្លាមៗ បន្ទាប់ពីការងាររបស់ពួកគេត្រូវបានបញ្ចប់។ សិទ្ធិបន្ថែមពីលើនេះទៀតរួមមាន៖ សេរីភាពរួចផុតពីការនិរទេសចេញជាក្រុម (មាត្រា ២២) សិទ្ធិក្នុងការទទួលបានសេវាកម្មពីស្ថានកុងស៊ុលនៅពេលត្រូវបានចាប់ខ្លួន (មាត្រា ២៣) និង សិទ្ធិសម្រាប់កូនៗរបស់ពលករទេសន្តប្រវេសន៍ក្នុងការមានលទ្ធភាពក្នុងការទទួលបានការអប់រំ (មាត្រា ៣០)។ សិទ្ធិសំខាន់ដទៃទៀតគឺលទ្ធភាពក្នុងការផ្ទេរប្រាក់ចំណូល ឬប្រាក់បញ្ញើរត្រលប់ទៅប្រទេសដើមរបស់ពលករទេសន្តប្រវេសន៍វិញ។

គោលបំណងចម្បងនៃសន្ធិសញ្ញា គឺបង្កើតលក្ខខណ្ឌជាមនុស្សសម្រាប់ពលករទេសន្តប្រវេសន៍ទាំងអស់ ដែលទាំងនេះត្រូវបានបញ្ជាក់លម្អិតក្នុងផ្នែកទីប្រាំមួយនៃអនុសញ្ញា និងរួមបញ្ចូលនូវសេវាកម្មកាន់តែល្អប្រសើរដូចជាសកម្មភាពស្ថានកុងស៊ុល ធានានូវការវិលត្រលប់មកប្រទេសដើមវិញ ដោយងាយស្រួលសម្រាប់ពលករទេសន្តប្រវេសន៍ធ្វើការផ្ដោះទៅកាន់ការលុបបំបាត់ការបំលាស់ទីដោយមិនស្របច្បាប់ និងដោយលួចលាក់ និងការជ្រើសរើសពលករ។

## ទស្សនៈទាន

### ប្រាក់បញ្ញើរ

ប្រាក់បញ្ញើរ គឺជាលុយ និងទំនិញដែលពលករទេសន្តប្រវេសន៍ និងប្រជាជនដទៃទៀតដែលរស់នៅក្រៅរដ្ឋរបស់ខ្លួនផ្ញើមកផ្ទះវិញ។ ប្រាក់បញ្ញើរមានឥទ្ធិពលយ៉ាងសំខាន់លើសហគមន៍ ហើយក្នុងករណីខ្លះទៅដល់សេដ្ឋកិច្ចជាតិផងដែរ។ ប្រាក់បញ្ញើរជាផ្នែកមួយយ៉ាងធំនៃសេដ្ឋកិច្ចប្រទេសហ្វីលីពីន និងធ្វើឲ្យប្រសើរឡើងនូវស្ថានភាពនៃសហគមន៍មួយចំនួនក្នុងប្រទេសមីយ៉ាន់ម៉ា។ ពលករទេសន្តប្រវេសន៍អាចជាប្រភពក្នុងការផ្តល់អំណាចសេដ្ឋកិច្ចមួយ និងជាកម្លាំងជម្រុញនៅពីខាងក្រោយឱកាសថ្មី ទោះបីជាគាត់នៅរដ្ឋ ឬតំបន់ដទៃក៏ដោយ។ ប្រាក់បញ្ញើរក៏ជាកត្តាស្រួបយ៉ាងសំខាន់មួយផងដែរ (អ្វីដែលសំខាន់ក្នុងការជម្រុញឲ្យប្រជាជនចំណាកស្រុក) ក្នុងទេសន្តប្រវេសន៍ក្នុងតំបន់អាស៊ីអាគ្នេយ៍។ ការការពារលើប្រាក់បញ្ញើរ និងលទ្ធភាពក្នុងការផ្ញើប្រាក់បញ្ញើរមកផ្ទះគឺមានសារៈសំខាន់ចំពោះពលករទេសន្តប្រវេសន៍ដែលនេះស្មើនឹងសិទ្ធិមនុស្ស។

សិទ្ធិរបស់ពលករទេសន្តប្រវេសន៍ ត្រូវបានបែងចែកជាបីប្រភេទដាច់ដោយឡែកពីគ្នាៈ (១) សិទ្ធិរបស់ពលករទេសន្តប្រវេសន៍ទាំងអស់ (ដូចដែលមានបញ្ជាក់ខាងលើ) (២) សិទ្ធិបន្ថែមទៀតដែលបានផ្តល់ជូនដល់ពលករទេសន្តប្រវេសន៍ដែលមានឯកសារ (៣) សិទ្ធិសម្រាប់ប្រភេទពិសេសនៃពលករទេសន្តប្រវេសន៍។

ពលករទេសន្តប្រវេសន៍ ទទួលបានចង្កោមនៃសិទ្ធិបន្ថែមទៀតដែលមានក្នុងមាត្រា ២០ ។ សិទ្ធិទាំងនេះរួមមាន សិទ្ធិក្នុងការបង្កើតសហជីព (មាត្រា ៤០) លទ្ធភាពក្នុងការទទួលបានទីលំនៅ និងសេវាសង្គម (មាត្រា ៤៣) និងការផ្ញើសមាហរណកម្មកូនរបស់ពលករទេសន្តប្រវេសន៍ទៅក្នុងស្ថាប័នសិក្សាក្នុងតំបន់ (មាត្រា ៤៥)។ សិទ្ធិបន្ថែមទាំងនេះសម្រាប់ពលករដែលមានឯកសារក្នុងស្ថានភាពទៀងទាត់ ជាការព្យាយាមមួយក្នុងការជម្រុញពលករក្នុងការធ្វើទេសន្តប្រវេសន៍ដោយមានឯកសារ និងទៀងទាត់។

ប្រភេទពិសេសនៃពលករទេសន្តប្រវេសន៍រួមមានៈ ពលករតាមព្រំដែន (ប្រជាជនដែលធ្វើការឆ្លងដែន ជាឧទាហរណ៍ពួកគេរស់នៅក្នុងប្រទេសមួយ តែធ្វើការនៅប្រទេសមួយទៀត) ពលករតាមរដូវ (ប្រជាជនដែលធ្វើការប៉ុន្មានខែក្នុងមួយឆ្នាំ នៅប្រទេសដទៃ) ពលករតាមគម្រោង (អ្នកដែលការងាររបស់គាត់នៅប្រទេសដទៃមាន

ពេលវេលាជាក់លាក់ និងបញ្ចប់នៅពេលដែលគម្រោងបញ្ចប់)។ ពលករទាំងនេះទទួលបានសិទ្ធិស្តង់ដារទាំងអស់ ប៉ុន្តែលទ្ធភាពរបស់ពួកគេក្នុងការទទួលបានសេវាកម្មសង្គម និងការអប់រំរបស់កូនៗរបស់ពួកគេអាចមានកម្រិត ដោយសារតែពួកគេមិនរស់នៅពេញម៉ោងក្នុងប្រទេសដែលពួកគេបម្រើការងារ។

## ៧.២.៣ ការប្រឈមនៃ ICRMW

ខណៈពេលដែលអនុសញ្ញា ឈានជំហានចម្បងឆ្ពោះទៅកាន់ការការពារពលករទេសន្តប្រវេសន៍ ក៏នៅមានចំនុចខ្សោយមួយចំនួនពាក់ព័ន្ធនឹងប្រភេទលេចឡើងថ្មីៗនៃពលករទេសន្តប្រវេសន៍។ ជាឧទាហរណ៍ មិនមានប្បញ្ញត្តិជាក់លាក់សម្រាប់ពលករទេសន្តប្រវេសន៍ជាស្ត្រី ដូចនេះធ្វើឲ្យសន្ធិសញ្ញានេះមានភាពងងឹតងងុលពាក់ព័ន្ធនឹងយែនឌ័រសន្ធិសញ្ញានេះសន្មតថាស្ត្រី និងបុរសនឹងត្រូវការការពារដូចគ្នា។ ជាមួយនឹងសាកលភាវូបនីយកម្ម និងការផ្លាស់ប្តូរការអនុវត្តការងារដែលមានឈ្មោះថា 'ស្ត្រីក្នុងកម្លាំងពលកម្ម' ស្ត្រីពេលបច្ចុប្បន្ននេះរួមចំនែកក្នុងវិស័យពលកម្ម ដែលមានការរីកចំរើនយ៉ាងឆាប់រហ័ស។ ការរំលោភបំពានដែលស្ត្រីជួបប្រទះភាគច្រើន ជាឧទាហរណ៍មានដូចជាការរើងអើងផ្លូវភេទនៅកន្លែងការងារ ប្រាក់ឈ្នួលមិនស្មើភាព មិនត្រូវបានបញ្ជាក់ដោយផ្ទាល់ក្នុងអនុសញ្ញានេះនោះទេ។ យើងអាចធ្វើការអះអាងថាបញ្ហានេះអាចស្ថិតក្នុងការរើសអើងនៅកន្លែងការងារ ប៉ុន្តែជារឿយៗច្បាប់ទាំងនេះមិនបានបញ្ជាក់គ្រប់គ្រាន់ដើម្បីការពារពលករទេសន្តប្រវេសន៍ជាស្ត្រីនោះទេ។ ចំនុចខ្សោយនេះកើតមានជាពិសេសលើពលករទេសន្តប្រវេសន៍ដែលជាអ្នកជួយកិច្ចការផ្ទះ ដែលភាគច្រើនសុទ្ធតែជាស្ត្រី។ ដោយសារការជួយកិច្ចការផ្ទះជារឿយៗ មិនត្រូវបានគ្រប់គ្រងដោយច្បាប់ហើយស្ត្រីធ្វើការក្នុងផ្ទះឯកជន ជាការពិបាកខ្លាំងសម្រាប់ពួកគេក្នុងការលើកជាបណ្តឹងបង្កើតសមាគម ទាមទារប្រាក់ថែមម៉ោង និងស្តង់ដារការងារដទៃទៀត។ នៅក្នុងតំបន់មួយចំនួននៃការរំលោភបំពានដែលល្បីរន្ទឺបំផុតគឺទៅលើពលករជួយកិច្ចការផ្ទះ (ដែលនៅក្នុងករណីមួយចំនួនធ្វើឲ្យមានការបែកបាក់ទំនាក់ទំនងការទូត ជាឧទាហរណ៍ករណី Flor Contemplacion រវាងសឹង្ហបូរី និងហ្វីលីពីន)។ សិទ្ធិក្នុងវិស័យដទៃទៀតដែលមិនត្រូវបានគិតគូរ គឺចំពោះពលករជាយុវជន (កុមារអាយុក្រោម ១៨ ឆ្នាំ ដែលស្វែងរកការងារ) ដែលអាចជាអ្នកត្រូវការការពារជាពិសេ អនុសញ្ញាស្តីពីអាយុអប្បរមា (ILO ១៣៨) ពិតជាបានការពារប្រជាជនដែលស្ថិតក្រោមអាយុអប្បរមាសម្រាប់ប្រទេសដែលពួកគេកំពុងធ្វើការ ( ហើយដែលនេះអាចនៅចន្លោះពី១២ ដល់ ១៥ ឆ្នាំ) ប៉ុន្តែ មិនមានការទទួលស្គាល់ថាប្រជាជនរវាង ១៥ និង ១៨ ឆ្នាំដែលកំពុងធ្វើការអាចត្រូវបានការការពារជាពិសេសនោះទេ។ ពលករទេសន្តប្រវេសន៍ជំនាន់ទីពីរ ដែលជាកូនពេញវ័យរបស់ពលករទេសន្តប្រវេសន៍ ដែលពួកគាត់ជាពលករទេសន្តប្រវេសន៍ផងដែរនោះ

មិនត្រូវបានរៀបរាប់ក្នុងសន្ធិសញ្ញានោះទេ។ នៅក្នុងប្រទេសនៅអាស៊ីអាគ្នេយ៍ភាគច្រើនដែលមានប្រវត្តិនៃការងារទេសន្តប្រវេសន៍ មានពលករ ពីរជំនាន់ ឬពេលខ្លះអាចបីជំនាន់។

## ករណីសិក្សា

### ករណី ផ្លរ ខនថែមផ្លេសិន (Flor Contemplacion )

ជាស្ត្រីជួយកិច្ចការផ្ទះជនជាតិហ្វីលីពីន ដែលកំពុងបម្រើការងារក្នុងប្រទេសសឹង្ហបុរី ដែលត្រូវបានចោទប្រកាន់ នឹងមានទោសពីបទឃាតកម្ម។ នាងត្រូវបានកាត់ទោសប្រហារជីវិតនៅថ្ងៃទី ១៧ ខែមិនា ឆ្នាំ១៩៩៥។ យ៉ាងណាមិញ មនុស្សជាច្រើនអះអាងថាអង្គហេតុនៃរឿងក្តីនេះនៅតែបើកចំហសម្រាប់ការជជែកវែកញែក។ អ្នកជួយកិច្ចការផ្ទះមួយរូបនេះមានស្នាមច្របាច់ក ហើយក្មេងប្រុសអាយុបួនឆ្នាំដែលគាត់មើលបានលង់ទឹកក្នុងធុងមុជទឹក។ Flor Contemplacion បានក្លាយជាជនសង្ស័យ បន្ទាប់ពីប៉ូលីសអានសៀវភៅកំណត់ហេតុប្រចាំថ្ងៃរបស់ស្ត្រីរូបនេះ ហើយ Flor ខ្លួនឯងគាត់បានសារភាពពីបទឧក្រិដ្ឋនេះ។ ការអះអាងពីភាពមិននឹងនរផ្នែកស្មារតី ហើយនិងអំពើដែលឪពុកក្មេងប្រុសច្របាច់កអ្នកជួយកិច្ចការផ្ទះរូបនេះ បន្ទាប់ពីឪពុករូបនោះដឹងថាស្ត្រីបម្រើបានធ្វើឲ្យកូនប្រុសរបស់ខ្លួនលង់ទឹកស្លាប់នោះ មិនត្រូវបានអើពើនោះទេ។

រឿងក្តីនេះបានក្លាយជាចំនុចប្រដែងរបស់ស្ថាប័នជាច្រើន ដែលធ្វើការតស៊ូមតិដើម្បីទាមទារសិទ្ធិរបស់ពលករទេន្តប្រវេសន៍ ជាពិសេសសម្រាប់អ្នកជួយកិច្ចការផ្ទះនៅប្រទេសសឹង្ហបុរី។ ប្រជាជនមានការបារម្ភជាពិសេសថាទោសកំហុសរបស់ស្ត្រីរូបនេះត្រូវបានសន្និដ្ឋានលឿនពេក ហើយថាប៉ូលីសមិនបន្តការស៊ើបអង្កេតលើអង្គហេតុដទៃ។ រដ្ឋាភិបាលហ្វីលីពីនបានផ្តល់ ប្រសិនជាមាននោះ សេវាកុងស៊ុល ឬការពារតិចតួចបំផុតដល់ស្ត្រីជួយកិច្ចការផ្ទះរូបនេះ ទោះបីជាពេលក្រោយមកដោយសារតែ ដឹងថាប្រជាជននៅហ្វីលីពីនមិនសប្បាយចិត្តជាខ្លាំងពីរឿងនេះ រដ្ឋាភិបាលបានតវ៉ាពីទោសប្រហារជីវិតលើស្ត្រីរូបនេះ ហើយបន្ទាប់មកទៀតបានដកទូតរបស់ខ្លួនពីសឹង្ហបុរី និងបានលុបចោលនូវសន្ធិសញ្ញាទ្វេភាគីមួយចំនួនផងដែរ។

ក្រោយមក ប្រទេសសឹង្ហបុរីបានធ្វើឲ្យប្រសើរឡើងនូវការការពារផ្លូវច្បាប់ លើអ្នកជួយកិច្ចការផ្ទះជាបណ្តើរៗ ដោយអនុម័តច្បាប់ "ការរំលោភបំពានលើស្ត្រីជួយកិច្ចការផ្ទះ" (ផ្នែកទី ៧៣ នៃក្រមព្រហ្មទណ្ឌ) ក្នុងឆ្នាំ ១៩៩៨។ លើសពីនេះទៀត ក្រសួងការងាររបស់សឹង្ហបុរីក្នុងឆ្នាំ ២០១២ បានប្រកាសពីការឈប់សម្រាកមួយថ្ងៃក្នុងមួយសប្តាហ៍

សម្រាប់អ្នកជួយកិច្ចការផ្ទះបរទេស។ យ៉ាងណាមិញ កាតព្វកិច្ចនេះអនុវត្តចំពោះតែកិច្ចសន្យាដែលចុះថ្មីប៉ុណ្ណោះដែលចាប់ពីខែមករា ឆ្នាំ២០១៣។ នេះមិនមែនជាករណី នៃស្ត្រីជួយកិច្ចការផ្ទះទទួលទោសប្រហារជីវិត តែមួយគត់នោះទេ។ កាលពីពេលថ្មីៗនេះ ស្ត្រីជួយកិច្ចការផ្ទះស្រីលង្កា និងឥណ្ឌូនេស៊ីបានទទួលទោសប្រហារជីវិតក្នុងប្រទេសអារ៉ាប៊ីសាអ៊ូឌីត ដែលធ្វើឲ្យប្រទេសបញ្ជូនអនុម័តច្បាប់ដើម្បីបង្កើនការការពារដល់អ្នកជួយកិច្ចការផ្ទះ។ ជាឧទាហរណ៍ ឥណ្ឌូនេស៊ីបានហាមឃាត់ទេសន្តប្រវេសន៍នៃអ្នកជួយកិច្ចការផ្ទះទៅកាន់ប្រទេសអារ៉ាប៊ីសាអ៊ូឌីតក្នុងឆ្នាំ ២០១១ ប៉ុន្តែកាលពីពេលថ្មីៗនេះបានចុះហត្ថលេខាជាមួយនឹងរដ្ឋាភិបាលអារ៉ាប៊ីសាអ៊ូឌីត ដើម្បីអនុញ្ញាតឲ្យមានការបញ្ជូនតាមលក្ខខណ្ឌការពារជាក់លាក់ (ជាឧទាហរណ៍ ប្រាក់ឈ្នួលប្រចាំខែ ម៉ោងការងារមានពេលកំណត់ និងការមិនរឹបអូសលិខិតឆ្លងដែនពួកគេជាដើម)។

## ៧.២.៨. ហេតុផលចំពោះការផ្ដល់សច្ចាប័នតិច

មានហេតុផលជាច្រើនចំពោះការផ្ដល់សច្ចាប័នតិចលើសន្ធិសញ្ញានេះ។ ដូចដែលបានរៀបរាប់ មិនមានរដ្ឋភាគីណាមួយពីប្រទេសដែលទទួលពលករទេសន្តប្រវេសន៍នោះទេ។ លើសពីនេះទៀត មិនមានប្រទេសអភិវឌ្ឍណាមួយផ្ដល់សច្ចាប័នលើសន្ធិសញ្ញានោះទេ។ យ៉ាងណាមិញ ហេតុផលជាច្រើនដែលបានផ្ដល់ចំពោះ ការមិនផ្ដល់សច្ចាប័នគឺមិនសុក្រិតនោះទេ។ ជាឧទាហរណ៍ ប្រទេសអភិវឌ្ឍន៍ជាច្រើនគិតថាសន្ធិសញ្ញានឹងផ្ដល់សិទ្ធិច្រើនពេកដល់ពលករទេសន្តប្រវេសន៍។ យ៉ាងណាមិញ សិទ្ធិជារឿយៗមានវត្តមានដោយមិនចាំបាច់មានច្បាប់ជាតិ ហើយនឹងមិនមានបន្ទុកបន្ថែមនោះទេ។ រដ្ឋខ្លះគិតថាប្រសិនបើលក្ខខណ្ឌការងារល្អប្រសើរពេក ពលករនឹង ‘ហូរជន់ជោរ’ ក្នុងប្រទេស ហើយបង្កជាបន្ទុកដល់ប្រព័ន្ធសុខមាលភាព ប៉ូលីស និងសហគមន៍ក្នុងតំបន់។ យ៉ាងណាមិញ ការជោរជន់នេះ មិនដែលកើតមាននោះទេ។ ពលករទេសន្តប្រវេសន៍ទៅកន្លែងណាដែលមានការងារសម្រាប់ខ្លួនធ្វើ ហើយពួកគេមិនធ្វើចំណាកស្រុកដើម្បីក្លាយជាអ្នកគ្មានការងារធ្វើនោះទេ។ ដូចនេះ ចំនួនពលករទេសន្តប្រវេសន៍ឆ្លុះបញ្ចាំងពីតម្រូវការលើកម្លាំងពលកម្ម ហើយមិនមែនលើតើប្រទេសមួយមានស្ថានភាពល្អប្រសើរយ៉ាងណានោះទេ។

រដ្ឋអាចធ្វើការពិចារណាថាសិទ្ធិមួយចំនួនមានភាពចម្រូងចម្រាស។ ជាឧទាហរណ៍ ពលករទេសន្តប្រវេសន៍ គួរតែត្រូវបានប្រព្រឹត្តមកលើស្មើគ្នានឹងពលករក្នុងស្រុកពាក់ព័ន្ធនឹងប្រាក់ឈ្នួល ការងារបន្ថែមម៉ោង ថ្ងៃឈប់សម្រាក និងការបញ្ចប់កិច្ចសន្យា (មាត្រា១៥)។ ជាការពិតណាស់ ក្រុមហ៊ុនមួយចំនួនប្រើប្រាស់ពលកម្មទេសន្តប្រវេសន៍ជាពិសេស ដោយសារពួកគាត់មានតម្លៃពលកម្មទាបជាង ហើយអាចផ្ដល់ជូនប្រាក់

ឈ្នួលដែលទាបជាងប្រាក់ឈ្នួលអប្បរមា។ វិស័យធុរកិច្ចអាចដាក់សំពាធលើរដ្ឋាភិបាលក្នុងការមិនអនុម័តច្បាប់ដែលផ្តល់ជូនពលករនូវសិទ្ធិច្រើនពេក។ សិទ្ធិដទៃទៀតដូចជាសិទ្ធិសញ្ជាតិសម្រាប់កូន ជារឿយៗមិនត្រូវបានព្រមព្រៀងនោះទេ។

ក៏មានកង្វល់ផងដែរដែលថា ICRMW ក៏ទទួលស្គាល់ផងដែរនូវពលករមិនមានឯកសារ។ រដ្ឋភាគច្រើនហៅពលករមិនមានឯកសារជាសាមញ្ញថាពលករមិនស្របច្បាប់ ហើយពួកគេអាចត្រូវបានចាប់ខ្លួន និងនិរទេសដោយងាយស្រួល។ យ៉ាងណាមិញ តាមរយៈការទទួលស្គាល់ពលករថាជាអ្នកកាប់កាន់សិទ្ធិគឺផ្លាស់ប្តូរនូវនីតិវិធីនេះ។ ពួកគេអាចធ្វើការតទល់នឹងការនិរទេសដោយស្របច្បាប់ ឬសូម្បីតែធ្វើការតវ៉ានៅកន្លែងការងារប្រសិនបើច្បាប់ត្រូវបានរំលោភបំពាន។

ជារឿយៗ រដ្ឋមិនខ្វល់ពីផលប្រយោជន៍នៃសន្ធិសញ្ញានេះ។ ដោយសារតែប្រទេសជាច្រើនលើពិភពលោកពឹងផ្អែកលើការងារទេសន្តប្រវេសន៍ ដើម្បីរក្សាកំណើនឧស្សាហកម្មរបស់ពួកគេ ការប្រព្រឹត្តមិនសមរម្យលើពលករទេសន្តប្រវេសន៍អាចនាំឲ្យមានផលអាក្រក់ចំពោះសេដ្ឋកិច្ចរបស់ពួកគេ។ ប្រសិនជាលក្ខខណ្ឌអាក្រក់រិតត្បិតខ្លាំងពេក ពលករទេសន្តប្រវេសន៍នឹងមិនធ្វើដំណើរទីកន្លែងទាំងនេះនោះទេ។ ឬប្រសិនបើមានស្ថានភាពការងារកាន់តែល្អប្រសើរនោះ ពួកគេនឹងចាកចេញទៅប្រទេសដទៃ។ កាលពីពេលថ្មីៗនេះ ជាមួយនឹងការផ្លាស់ប្តូរទៅជាប្រជាធិបតេយ្យនៅក្នុងប្រទេសមីយ៉ាន់ម៉ា វិស័យធុរកិច្ច ដែលពឹងផ្អែកលើពលករទេសន្តប្រវេសន៍ក្នុងប្រទេសម៉ាឡេស៊ី និងថៃមានកង្វល់ថាពលករទេសន្តប្រវេសន៍នឹងចាប់ផ្តើមត្រលប់ទៅផ្ទះវិញ។ រោងចក្រមួយចំនួនបង្កើនប្រាក់ឈ្នួល និងធ្វើឲ្យប្រសើរឡើងនូវលក្ខខណ្ឌដើម្បីជាការជម្រុញទឹកចិត្តដល់ពលករទេសន្តប្រវេសន៍ដើម្បីកុំឲ្យចាកចេញ។

## ៧.៣ ការរំលោភបំពានលើសិទ្ធិរបស់ពលករទេសន្តប្រវេសន៍

ពលករទេសន្តប្រវេសន៍ប្រឈមនឹងការគម្រាមកំហែង និងការរំលោភបំពានមួយចំនួនចាប់តាំងពីការជ្រើសរើសរហូតដល់ការបញ្ចប់ការងាររបស់ពួកគេ។ ពលករទេសន្តប្រវេសន៍ ដែលមិនមានឯកសារ និងក្នុងស្ថានភាពមិនទៀងទាត់ គឺមានភាពងាយរងគ្រោះជាពិសេស។ ពលករទេសន្តប្រវេសន៍ប្រឈមនឹងការគម្រាមកំហែងដោយសារពួកគេរស់នៅក្រៅរដ្ឋរបស់ពួកគេ ហើយដោយសារពួកគេត្រូវបានចាត់ទុកថាជាបន្ទុកដល់សង្គម និងមិនល្អសម្រាប់សេដ្ឋកិច្ច។ ពលករទេសន្តប្រវេសន៍អាចមានការស្ទាក់ស្ទើរក្នុងការរាយការណ៍ពីការគម្រាមកំហែង ឬការរំលោភបំពានដោយសារពួកគេគិតថាប៉ូលីស ឬប្រព័ន្ធយុត្តិធម៌អាចជួយការពារដល់ពួកគេបានតិចតួចបំផុត។ ប្រសិនយន្ត

ការការពារត្រូវបានបាត់បង់នោះ ពួកគេត្រូវសំអាងលើសិទ្ធិមនុស្សដើម្បីធានាដល់សុវត្ថិភាព និងការប្រព្រឹត្តដោយយុត្តិធម៌មកលើពួកគេ។

## ការបោកប្រាស់

ការបោកប្រាស់លើពលករទេសន្តប្រវេសន៍ កើតមានឡើងច្រើននៅក្នុងតំបន់។ នៅក្នុងករណីនេះ ក្រុមហ៊ុន ឬបុគ្គលធ្វើការសន្យាផ្តល់កិច្ចសន្យាការងារដែលទទួលបានផលប្រយោជន៍ក្រាសក្រែល (ជារឿយៗតម្រូវឲ្យបង់ថ្លៃសេវា) ហើយបន្ទាប់មកពលករនឹងដឹងថាមិនមានការងារ ឬប្រសិនជាមានការងារ លក្ខខណ្ឌគឺមិនដូចនឹងអ្វីដែលត្រូវបានសន្យានោះទេ។ ការប្តូរកិច្ចសន្យា នៅពេលដែលកិច្ចសន្យាដើមត្រូវបានផ្លាស់ប្តូរជំនួសដោយកិច្ចសន្យាផ្សេង ដែលនេះតែងតែកើតឡើង ដែលពលករត្រូវបានប្រគល់ដល់ថៅកែដទៃទៀត ហើយធ្វើការងារខុសគ្នាទាំងស្រុងពីអ្វីដែលបានសន្យា នៅពេលដែលពួកគេទៅដល់ប្រទេសទិសដៅ។ ឧទាហរណ៍ដ៏ជូរចត់បំផុតនៃស្ថានការណ៍បោកប្រាស់នេះ គឺការជួញដូរ ដែលពលករជារឿយៗធ្លាក់ចូលស្ថានភាពដូចជាទាសករ។ ពលកម្មដោយបង្ខំក៏អាចកើតមានក្នុងស្ថានភាពនេះផងដែរ ដែលពលករមិនអាចចាកចេញពីការងារ ទោះបីជានៅពេលដែលលក្ខខណ្ឌការងារមិនអាចទ្រាំទ្របាន ដោយសារតែកង្វះនូវឯកសារអត្តសញ្ញាណ និងមិនមានលទ្ធភាពក្នុងការសងបំណុលពីការជ្រើសរើស។ ការរំលោភបំពានដទៃទៀតរួមមានថ្លៃសេវាខ្ពស់ពេក និងការកាត់កងដែលមាននៅក្នុងកិច្ចសន្យា ដូចនេះប្រាក់ឈ្នួលមិនបានច្រើនដូចអ្វីដែលបានសន្យានោះទេ។

## លក្ខខណ្ឌកន្លែងធ្វើការមិនល្អ

នៅកន្លែងការងារ ពលករទេសន្តប្រវេសន៍ (ជាពិសេសពលករដែលមិនឯកសារ) អាស្រ័យលើសណ្តានចិត្តរបស់ថៅកែរបស់ពួកគេ និងមន្ត្រីមូលដ្ឋាន ដោយសារពួកគេមិនអាចទទួលបានការការពារដោយស្មើភាព និងយុត្តិធម៌ពីច្បាប់នោះទេ។ ការរំលោភបំពានជាទូទៅ រួមមានការមិនបើកប្រាក់ឈ្នួល លក្ខខណ្ឌការងារដែលគគ្រិច គ្រោះថ្នាក់ និងមិនមានអនាម័យ និងម៉ោងការងារវែង។ ពេលខ្លះពលករជួយកិច្ចការផ្ទះ ត្រូវបានតម្រូវឲ្យធ្វើការពីម៉ោង ៦ ព្រឹករហូតដល់ (ដើម្បីបញ្ជូនក្មេងៗទៅសាលា) រហូតដល់ពាក់កណ្តាលអាធ្រាតបន្ទាប់ពីពួកគេដុសលៀងបន្ទាប់ពីអាហារពេលល្ងាច។ ម៉ោងការងារជាមធ្យមក្នុងមួយសប្តាហ៍ ដែលខុសគ្នាទូទាំងអាស៊ីអាគ្នេយ៍ (ប៉ុន្តែគួរតែប្រហែលជា៤៥ម៉ោង) អាចមានរហូតដល់ទៅ ៧២ ម៉ោង។

យ៉ាងណាមិញ ករណីដែលធ្ងន់ធ្ងរបំផុតនៃការរំលោភបំពាន គឺមាននៅលើទូកនេសាទ។ ជារឿយៗ កម្មករនេសាទត្រូវធ្វើការ ១៨ ទៅ២២ម៉ោងក្នុងមួយថ្ងៃ ដោយពលកម្មដោយ

ដៃផ្ទាល់ និងប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍។ អាចដេក និងញ៉ាំបានលុះត្រាតែនៅពេលដែលសំណាញ់នៅក្នុងទឹក ហើយពេលថ្មីៗនេះត្រីមិនសូវសំបូរនោះទេ។ អ្នកនេសាទរស់នៅក្នុងបន្ទប់គគ្រិចគួរឲ្យខ្ពើម ខ្វះទឹក ហើយពួកគេត្រូវតែធ្វើការទោះបីជាអស់កម្លាំងល្ហិតល្ហៃ ឬឈឺ ដូចនេះប្រឈមនឹងហានិភ័យសម្រាប់ខ្លួនឯង និងអ្នកដទៃ។

## ការរំលោភបំពាននៅកន្លែងការងារ

ទោះបីជានៅក្រៅកន្លែងធ្វើការ ពលករទេសន្តប្រវេសន៍អាចប្រឈមនឹងការរើសអើងតាមរយៈការរំខានពីប៉ូលីស ការឆែកឆេរម្តងហើយម្តងទៀត មិនអាចបញ្ជូនកូនទៅរៀន និងមិនអាចអនុវត្តជំនឿសាសនា ឬបុណ្យជាតិបាននោះទេ។ពលករទេសន្តប្រវេសន៍អាចប្រឈមការរំលោភបំពាននៅពេលបញ្ចប់ការងាររបស់ពួកគេ។ ចំពោះប្រទេសភាគច្រើននៅអាស៊ីអាគ្នេយ៍ ពលករមិនមានឯកសារត្រូវបានចាត់ទុកថាជាឧក្រិដ្ឋជន ហើយត្រូវបានបណ្តេញភ្លាមៗ។ ករណីអាចកើតមានឡើងនៅពេលដែលម្ចាស់រោងចក្រមិនចង់បើកប្រាក់ឈ្នួលដល់កម្មកររបស់ខ្លួន ហើយបានហៅប៉ូលីសដើម្បីមកយកពលករទេសន្តប្រវេសន៍ដែលមិនមានឯកសារ ហើយបណ្តេញពីចេញពីប្រទេស (ដែលពួកគេមិនអាចប្តឹងដើម្បីទាមទារប្រាក់ឈ្នួលរបស់ខ្លួនបាន)។ ដោយសារស្តង់ដារទាបពាក់ព័ន្ធនឹងការបណ្តេញចេញនៅក្នុងប្រទេសភាគច្រើន ពលករទេសន្តប្រវេសន៍ដឹងថាប្រសិនជាពួកគេព្យាយាមក្នុងការទាមទារសិទ្ធិរបស់ខ្លួនពីមនុស្សខុស ពួកគេអាចត្រូវបានបញ្ជូនមកផ្ទះវិញ ចាប់ខ្លួន ឬវាយធ្វើបាប។ ប្រទេសម៉ាឡេស៊ីមានច្បាប់មួយដែលអនុញ្ញាតឲ្យវាយធ្វើបាប ពលករទេសន្តប្រវេសន៍ដែលមិនមានឯកសារ ហើយចន្លោះឆ្នាំ ២០០៥ និង ២០១០ បានវាយធ្វើបាប ជនបរទេសជិត ៣០ ០០០នាក់។ ឧបសគ្គទាំងនេះមានឥទ្ធិពលក្នុងការបង្អាក់ពលករទេសន្តប្រវេសន៍ ហើយនិងសមត្ថភាពរបស់ពួកគេក្នុងការអនុវត្តសិទ្ធិ។

## ករណីសិក្សា

### ការភ័យខ្លាចរបស់ជនមិនមែនជាពលរដ្ឋ

នៅឈៀងម៉ៃ ទីក្រុងមួយនៃប្រទេសថៃខាងជើង មាននិស្សិតស្រីមហាវិទ្យាល័យវ័យក្មេងមួយរូប ត្រូវបានរំលោភ និងសម្លាប់ក្នុងសយនដ្ឋានរបស់ខ្លួន។ ជនសង្ស័យគឺជាកម្មករសំណង់ជនជាតិសានពីរនាក់ ត្រូវបានចាប់ខ្លួន។ បន្ទាប់ពីការចាប់ខ្លួន និស្សិតចាប់ផ្ដើមដង្ហែរក្បួន ហើយត្រូវបានគាំទ្រដោយប៉ូលីស ស្នើឲ្យបណ្ដេញរាល់កម្មករសំណង់ដែលជាពលករទេសន្តប្រវេសន៍ទាំងអស់នៅឈៀងម៉ៃ។ ការវាយឆ្មក់ និងការបណ្ដេញចេញមួយចំនួនត្រូវបានធ្វើឡើងនៅថ្ងៃបន្ទាប់មក ហើយពលកររាប់រយនាក់ត្រូវបានបណ្ដេញទៅប្រទេសភូមាវិញ។ ការបណ្ដេញចេញគឺខុសច្បាប់ ហើយក្នុងករណីមួយចំនួន ពលរដ្ឋថៃដែលបានចាប់ខ្លួននៅក្នុងការវាយឆ្មក់ត្រូវបានបណ្ដេញចេញពីប្រទេសថៃទៅប្រទេសភូមាផងដែរ។

ប្រទេសម៉ាឡេស៊ី បានធ្វើការបណ្ដេញពលករទេសន្តប្រវេសន៍ចេញទ្រង់ទ្រាយធំ ដែលពលកររាប់ម៉ឺននាក់ត្រូវបានចាប់ខ្លួន និងបណ្ដេញក្នុងរយៈពេលខ្លីប៉ុណ្ណោះ (ទោះបីជាការបណ្ដេញចេញនេះមិនត្រូវបានធ្វើឡើងក្នុងទ្រង់ទ្រាយធំយ៉ាងនេះ ចាប់តាំងពីឆ្នាំ ២០០៥ ក៏ដោយ)។ ការបណ្ដេញចេញទ្រង់ទ្រាយធំ ជាករណីកម្រ ប៉ុន្តែជាការរំលោភបំពានធ៍គ្រោះថ្នាក់លើសិទ្ធិមនុស្ស ហើយសកម្មភាពនេះច្បាស់ណាស់គឺផ្ទុយនឹងសិទ្ធិមនុស្ស និងច្បាប់ជាតិ។ ប៉ុន្តែការភ័យខ្លាចរបស់ប្រជាជនលើឧក្រិដ្ឋជនដែលមិនមែនជាពលរដ្ឋនៅតែមានខ្លាំង ហើយជាលទ្ធផលភាពជាជនរងគ្រោះរបស់ប្រជាជនមិនមែនជាពលរដ្ឋដែលមិនមានកំហុសទទួលការយកចិត្តទុកដាក់មិនបានជិតដល់នោះទេ។

## ពលកម្មដោយបង្ខំ

ពលកម្មដោយបង្ខំជាទម្រង់ដ៏ធ្ងន់ធ្ងរបំផុតនៃការរំលោភបំពានលើពលកម្ម។ អនុសញ្ញា ILO លេខ ២៩ ស្ដីពីពលកម្មដោយបង្ខំ (១៩៣០) កំណត់ថា៖

"រាល់ការងារ ឬសេវាកម្មដែលទទួលបានពីបុគ្គលណាមួយដែលស្ថិតក្នុងស្ថានភាពនៃការដាក់ទណ្ឌកម្មណាមួយ និងដែលការងារ ឬសេវាកម្មនេះមិនត្រូវបានបំពេញដោយបុគ្គលនេះដោយស្ម័គ្រចិត្តនោះទេ."។

## ករណីសិក្សា

### ពលកម្មដោយបង្ខំ

ករណីសិក្សានេះគឺចេញពីកំណត់ត្រាសម្ភាសន៍ ដែលបានធ្វើឡើងក្នុងគម្រោងស្រាវជ្រាវកាលពីពេលថ្មីនេះស្តីពីពលករទេសន្តប្រវេសន៍ក្នុងប្រទេសម៉ាឡេស៊ី។

កំណត់ចំណាំ៖ រាល់ឈ្មោះទាំងអស់ដែលត្រូវបានប្រើប្រាស់ក្នុងឧទាហរណ៍នេះ រួមមានទាំងឈ្មោះមនុស្ស និងក្រុមហ៊ុន គឺជារហ្សនាម។

ដើម្បីឆ្លើយតបនឹងគោលនយោបាយក្រុមហ៊ុន ក្រុមហ៊ុនកម្មន្តសាល (Cyber) ប្រើប្រាស់កម្លាំងពលកម្មទេសន្តប្រវេសន៍ ដែលបានស្នើឲ្យភ្នាក់ងារពលកម្មក្នុងការលើកកម្ពស់លក្ខខណ្ឌការងារដើម្បីឆ្លើយតបនឹងប្រាក់ឈ្នួលអប្បរមាស្របច្បាប់ និងលក្ខខណ្ឌរស់នៅរបស់ពលករ។ ជាជាងបំពេញតាមអ្វី Cyber ស្នើ ភ្នាក់ការកម្លាំងពលកម្មបានចរចាអត្រាប្រាក់ឈ្នួលជាមួយនឹងពលករ។ ភ្នាក់ងារបានផ្តល់ប្រាក់ចំនួន ៨១. ៥០ រីងហ្គីត (ប្រហែលជា ១៣ ដុល្លារក្នុងមួយថ្ងៃ) ដោយមិនមានប្រាក់ឈ្នួលសម្រាប់ថ្ងៃឈប់សម្រាក ប៉ុន្តែមិនបានកាត់កងអ្វីនោះទេ លើកលែងតែប្រាក់សេវាជ្រើសរើសដែលពួកគេត្រូវបង់។ ពលករបានព្រមព្រៀងដោយផ្ទាល់មាត់លើកិច្ចសន្យានេះ។

បន្ទាប់មកកិច្ចសន្យាត្រូវបានធ្វើឡើងជាភាសាអង់គ្លេស និងម៉ាឡេ ដែលគ្មានពលករណាម្នាក់យល់នោះទេ ប៉ុន្តែពួកគេបានចុះកិច្ចសន្យាដោយជឿលើសំដីរបស់ភ្នាក់ងារ។ ពលករបានកត់សម្គាល់ថាការកាត់កងត្រូវបានសរសេរឡើងជាអង់គ្លេស ហើយនៅពេលដែលពួកគេត្រលប់ទៅកាន់ផ្ទះសំណាក់របស់ពួកគេវិញ ពួកគេបានព្យាយាមបកប្រែដោយប្រើវចនានុក្រម។ ពលករមិនបានដឹងអ្វីទាំងអស់ ភ្នាក់ងារបានឆ្លើយទៅក្រុមហ៊ុន Cyber ដើម្បីរាយការណ៍ថាពលករបានព្រមព្រៀងលើអត្រាប្រាក់ឈ្នួលថ្មី ប៉ុន្តែគណៈគ្រប់គ្រងរបស់ Cyber ទទូចថានេះមិនអាចទទួលយកបាន ទោះបីជាពលករបានព្រមព្រៀងក៏ដោយ ការលក្ខខណ្ឌមិនបំពេញតាមលក្ខខណ្ឌច្បាប់ជាអប្បរមានោះទេ។

ភ្នាក់ងារបានសម្រេចចិត្តក្នុងការដកពលករចេញពីក្រុមហ៊ុន។ ខណៈពេលដែលកំពុងរងចាំចាត់តាំងទៅក្រុមហ៊ុនថ្មី ពលករមិនបានធ្វើការ ហើយដូចនេះ ពួកគេមិនទទួលបានប្រាក់ឈ្នួលអ្វីនោះទេ។ ពួកគេត្រូវបាននាំទៅកាន់ផ្ទះមួយដែលមានចម្ងាយ ៥០ km ពីផ្ទះសំណាក់ដើម។ ពួកគេបានរៀបរាប់ថាកន្លែងដែលពួកគេរស់នៅគឺតូចខ្លាំងណាស់ បុរស ១០ នាក់ក្នុងបន្ទប់មួយ និងស្ត្រី ៣០ ទៀតនៅក្នុងបន្ទប់មួយទៀត។

> បន្ទាប់ពី ១០ ថ្ងៃក្រោយមក ពលករវាយការណ៍ពីក្រុមហ៊ុនថ្មី។ ពលករលើថាលក្ខខណ្ឌការងារក្នុងក្រុមហ៊ុននេះគឺមិនល្អទាល់តែសោះ។ ពួកគេបដិសេធនឹងការរៀបចំថ្មីនេះ ហើយបានស្នើឲ្យរៀបចំទៅកន្លែងផ្សេង។ ជំនួសឲ្យការឆ្លើយតប ភ្នាក់ងារធ្វើការគម្រាមកំហែងក្នុងការប្រគល់ពួកគេដល់ប៉ូលីស ប្រសិនជាពួកគេនៅតែត្អូញត្អែរទៀត។ បន្ទាប់មកពលករសុំលិខិតឆ្លងដែនរបស់ពួកគេវិញ ដូចនេះពួកគេអាចស្វែងរកភ្នាក់ងារថៅកែដទៃផ្សេង ប៉ុន្តែភ្នាក់ងារនោះបដិសេធ។ បន្ទាប់មកពួកគេសុំត្រលប់មកប្រទេសមីយ៉ាន់ម៉ាវិញ ប៉ុន្តែភ្នាក់ងារនេះបដិសេធមិនឲ្យពួកគេទៅ។ ភ្នាក់ងារនៅតែធ្វើការគម្រាមកំហែងឲ្យប៉ូលីសចាប់ខ្លួនពួកគេ ហើយនៅពេលណាមួយនោះភ្នាក់ងារពិតជាមកផ្ទះសំណាក់ជាមួយនឹងប៉ូលីស។ បន្ទាប់ពីពេលនោះមក ពលករភ័យខ្លាចខ្លាំង ដូចនេះពួកគេរត់ចេញពីថៅកែ ប៉ុន្តែដោយសារគ្មានលិខិតឆ្លងដែន និងមិនមានលុយជាប់នឹងខ្លួនលើកលែងតែលុយតិចតួចដែលខ្លួនបានសន្សំប៉ុណ្ណោះ។ ពួកគេនៅតែនៅក្នុងប្រទេសម៉ាឡេស៊ី ជាប់អន្ទាក់រហូតដល់ពួកគេត្រូវបានចាប់ខ្លួន ឃុំខ្លួន និងត្រូវបានបណ្តេញចេញ។

ការងារដោយបង្ខំមានធាតុផ្សំចំនួនពីរ។ ទីមួយ ថាការងារគឺដោយមិនស្ម័គ្រចិត្ត មានន័យថាត្រូវបានធ្វើឡើងដោយប្រឆាំងនឹងឆន្ទៈរបស់បុគ្គល។ នេះអាចជាការជ្រើសរើសដោយបង្ខំ រស់នៅដូចជាប់ឃុំឃាំង និងការធ្វើមិនឲ្យចាកចេញពីនិយោជកបាន។ ទីពីរគឺថាការងារត្រូវបានធ្វើឡើង ដោយការគម្រាមកំហែងក្នុងការដាក់ទណ្ឌកម្ម។ ក្នុងករណីភាគច្រើន ការដាក់ទណ្ឌកម្មនេះគឺជាការគម្រាមកំហែងលើការរំលោភបំពានលើរូបរាងកាយ ប៉ុន្តែវាអាចជាការគម្រាមកំហែងដល់ក្រុមគ្រួសារ ឬគម្រាមដាក់ទណ្ឌកម្មប្រសិនបើពលកររត់គេច។ នៅក្នុងករណីនៃការជួញដូរ ពលកម្មដោយបង្ខំជាទូទៅកើតឡើងក្នុងបរិបទដែលពលករមិនត្រូវបានបើកប្រាក់ឈ្នួល ការងារសង្កត់សង្កិន (ជាឧទាហរណ៍ សេវាផ្លូវភេទ) ហើយពលករមិនមានសេរីភាពនៃការដើរហើរក្នុងការចាកចេញពីកន្លែងការងាររបស់ខ្លួននោះទេ។ ការរំលោភបំពានមួយចំនួននៅកន្លែងការងារអាចជារឿងតូចតាច ជាឧទាហរណ៍ លក្ខខណ្ឌការងារមិនល្អប្រសើរ (ក្តៅពេកត្រជាក់ពេក កង្វក់ពេក ឬលក្ខខណ្ឌមិនមានអនាម័យ)។ លក្ខខណ្ឌខ្លះអាចមានភាពធ្ងន់ធ្ងរ ប៉ុន្តែមិនមែនជាបទឧក្រិដ្ឋនោះទេ ការរំលោភបំពានដោយផ្ទាល់មាត់ ឬការកាត់កងដោយមិនមានការអនុញ្ញាតលើប្រាក់ឈ្នួល។ ការរំលោភបំពាននៅកន្លែងការងារដទៃទៀតអាចក្លាយជាបទឧក្រិដ្ឋដែលជាការពិតណាស់គឺជាពលកម្មដោយបង្ខំ ជាឧទាហរណ៍ការរំលោភបំពានរូបរាងកាយ ការលួចប្រាក់ឈ្នួល ឬពលកម្មកុមារ។

# ករណីសិក្សា

## ការការពារពលករទេសន្តប្រវេសន៍ជាកុមារ

ការបោះពុម្ពផ្សាយមួយដោយមជ្ឈមណ្ឌលទេសន្តប្រវេសន៍ Mahidol ដែលមានចំណងជើងថាជនរងគ្រោះអត់ស្រមោលនៃការជួញដូរនៅប្រទេសថៃ បង្ហាញនូវស្ថានការណ៍នៃក្មេងដែលស្វែងរកការងារធ្វើនៅប្រទេសថៃ។

ទូកបានចេញទៅសមុទ្រ ហើយ យីន មិនដឹងថាគាត់នៅកន្លែងណា ឬទូកនេសាទកំពុងទៅណានោះទេ។ គាត់ត្រូវបានបញ្ជាឲ្យលើកកេសដាក់ត្រី ឈ្នួលសម្រាប់ការងាររបស់គាត់នោះទេ។ អ្នកដែលគ្រប់គ្រងពលករមិនខ្វល់ថា យីន មិនគ្រប់អាយុនោះទេ។ យីន បានធ្វើការលើទូកអស់រយៈពេលប្រាំពីរថ្ងៃ ហើយនៅពេលដែលទូកមកដល់ផែ ក្មេងនោះត្រូវបង់បោះចោលជាមួយនឹងមិត្តភ័ក្ត្ររបស់គាត់។

បន្ទាប់មកទៀត ក្មេងនោះបានធ្លាក់ចូលក្នុងកណ្តាប់ដៃស្ត្រីថៃម្នាក់ ដែលបានចាក់សោរក្មេងប្រុសទាំងពីរនាក់នេះក្នុងបន្ទប់មួយអស់រយៈពេលបីថ្ងៃ មុនពេលដែលពួកគេត្រូវបានបញ្ជូនទៅទូកនេសាទផ្សេងទៀត។ នៅពេលដែលឃើញក្មេងទាំងពីរនេះ ម្ចាស់ទូកថ្មីទទួលយកតែមិត្តភ័ក្ត្ររបស់ យីន ដោយសារតែគាត់មានអាយុ ១៩ឆ្នាំ។ ដោយសារក្មេងពេកមិនអាចធ្វើការបាន យីន ត្រូវបានបោះបង់ចោលនៅតាមផ្លូវម្នាក់ឯង មិនចេះភាសាថៃ ហើយមិនដឹងថាគាត់នៅកន្លែងណា ហើយមិនអាចសុំជំនួយបាន។ ចុងបញ្ចប់ គាត់ចាប់ផ្តើមដើរចុះដើរឡើង។ បីថ្ងៃក្រោយមក យីន កំពុងដើរលើស្ពានអាកាសមួយ ឡានមួយឈប់ហើយបានយកគាត់ទៅប៉ុស្តិ៍ប៉ូលីស។ ប៉ុស្តិ៍ប៉ូលីសគឺនៅក្នុងស្រុក Klong Toey ទីក្រុងបាងកក។

មិនបានញ៉ាំ ឬផឹកត្រឹមត្រូវអស់រយៈពេលបីថ្ងៃ យីន ត្រូវបានបញ្ជូនទៅមជ្ឈមណ្ឌលឃុំខ្លួនអន្តោប្រវេសន៍ នៅសាន់ផ្លូ (Suan Plu) ក្នុងទីក្រុងបាងកក ដែលគាត់ត្រូវបានឃុំខ្លួននៅទីនោះអស់រយៈពេលបីខែ។ មនុស្សមកពីប្រទេសមីយ៉ាន់ម៉ា និងថៃស្ថិតក្នុងកន្លែងឃុំខ្លួនជាមួយគាត់។ ក្រោយមក យិន ត្រូវបាននិរទេសទៅម៉ែសុត (Mae Sot) នៅព្រំដែនថៃមីយ៉ាន់ម៉ា។ នៅពេលទៅដល់ ប៉ូលីសអន្តោប្រវេសន៍បានប្រគល់ខ្លួនគាត់ដល់ទាហានប្រជាធិបតេយ្យពុទ្ធសាសនាការ៉េន(DKBA) នៅមីយ៉ាវ៉ាត់ឌី (Myawaddy)។ ដោយសារ ត្រូវតែមានអ្នកណាម្នាក់ត្រូវតែលោះដើម្បីឲ្យដោះលែង យីន បុគ្គលិកអង្គការមួយរូបបានទិញ យីន ពីទាហាន ហើយគាត់ត្រូវបានបញ្ជូនត្រលប់ទៅម៉ែសុត (Mae So វិញហើយស្ថាននៅក្នុងផ្ទះដែលមានសុវត្ថិភាពរបស់អង្គការផ្តល់ជំនួយរបស់មីយ៉ាន់ម៉ា។ បន្ទាប់មក អង្គការនេះបានបញ្ជូនគាត់ទៅសាលាបណ្តុះបណ្តាល ដែលគាត់បានរៀនថៃ អង់គ្លេស និងមីយ៉ានម៉ា។ នៅកន្លែងនោះ គាត់បានរាប់អានមិត្តភ័ក្ត្រ និងមានភាពសប្បាយរីករាយ។ យិន

ពេលបច្ចុប្បន្នកំពុងស្វែងរកការអប់រំ និងការថែរក្សាត្រឹមត្រូវ ប៉ុន្តែគាត់មិនមានឯកសារស្របច្បាប់ដើម្បីស្នាក់នៅក្នុងប្រទេសថៃ ហើយនៅតែប្រឈមនឹងការចាប់ខ្លួន និរទេស ឬជួញដូរសារជាថ្មី។

## លំហាត់អនុវត្តៈ

ស្វែងរកការរំលោភបំពានសិទ្ធិ

ចំពោះរឿងក្តីទាំងពីរដែលបានបញ្ជាក់លម្អិតខាងលើ ពលកម្មដោយបង្ខំនៅម៉ាឡេស៊ី និងពលករជាកុមារនៅប្រទេសថៃ សូមបញ្ជាក់លម្អិតពីការរំលោភបំពានចម្បងលើអ្នកដែលពាក់ព័ន្ធ។ តើនេះជាការរំលោភបំពានសិទ្ធិមនុស្សមែនដែរឬទេ?

ឧទាហរណ៍នៃការរំលោភបំពានអាចជាៈ

- រំលោភកិច្ចសន្យា
- ថ្លៃសេវាថ្លៃពេក
- ប្រាក់ឈ្នួលមិនគ្រប់តាមចំនួន ឬមិនមានការបើកប្រាក់ឈ្នួល
- ម៉ោងការងារវែង
- លក្ខខណ្ឌរស់នៅមិនល្អ
- មានលទ្ធភាពតិចក្នុងការទទួលបានការថែទាំសុខភាព
- ការដកហូតឯកសារ
- ការគម្រាមកំហែងដល់សន្តិសុខ
- មិនមានសេរីភាពក្នុងការដើរហើរ

## ៧.៣.១ សកម្មភាពរដ្ឋាភិបាល ដែលអាចការពារសិទ្ធិពលករទេសន្តរប្រវេសន៍

អនុសញ្ញាអំពាវនាវដល់រដ្ឋក្នុងការបង្ការ "ការហើរ និងការងារដោយមិនស្របច្បាប់ ឬលួចលាក់របស់ពលករទេសន្តប្រវេសន៍ក្នុងស្ថានភាពដែលមិនទៀងទាត់" ហើយប្រកាសថារដ្ឋគួរតែធានា " លក្ខខណ្ឌសុវត្ថិភាព ស្មើភាព ជាមនុស្ស និងស្របច្បាប់"។ មួយផ្នែកកិច្ចការនេះ អាចសម្រេចបានតាមរយៈការបង្កើនភាពទៀងទាត់នៃការងារទេសន្តប្រវេសន៍ ដែលអនុញ្ញាតឲ្យពលករដែលមិនមានឯកសារទាំងអស់ក្នុងការក្លាយជាមានឯកសារជាបណ្តើរៗ។ ផ្តល់ភាពស្របច្បាប់ដល់ពលកម្មទេសន្តប្រវេសន៍នឹងកាត់បន្ថយវិសាលភាព និងតម្រូវការលើសេដ្ឋកិច្ចឧក្រិដ្ឋក្នុងទេសន្តប្រវេសន៍ ដែលអាចកាត់បន្ថយនូវកើតមានឡើងនូវការជួញដូរ។ ខណៈពេលដែលនេះដាក់កាតព្វកិច្ចដល់រដ្ឋាភិបាលក្នុងការការពារពលករពីការរំលោភបំពាន វាក៏អាចត្រូវបានប្រើប្រាស់ដោយរដ្ឋាភិបាល

ជាលេសមួយក្នុងការកំណត់ទិសដៅ បង្ក្រាបពលករទេសន្តប្រវេសន៍តាមរយៈបង្កើនការត្រួតពិនិត្យតាមព្រំដែន វាយឆ្មក់កន្លែងការងារ និងនិរទេសពលករដែលមិនមានឯកសារ។ លើសពីនេះទៀត មិនមានការស្នើឲ្យរដ្ឋាភិបាលក្នុងការលើកកម្ពស់លទ្ធភាពដល់ពលករទេសន្តប្រវេសន៍ដែលមានឯកសារ ឬស្នើដល់ក្រុមហ៊ុនដើម្បីជួយក្នុងការផ្តល់ភាពទៀងទាត់ដល់កម្លាំងពលកម្មរបស់ពួកគេនោះទេ។ ICRMW ចែងថារដ្ឋាភិបាលគួរតែ ″ចាត់វិធានការសមស្របដើម្បីធានាថា [ស្ថានភាពមិនទៀងទាត់] មិនកើតឡើងតទៅទៀតនោះទេ″ ប៉ុន្តែអនុសញ្ញានេះមិនបានអំពាវនាវឲ្យមានការផ្លាស់ប្តូរច្បាប់ ឬគោលនយោបាយអន្តោប្រវេសន៍នោះទេ ដែលអាចរួមបញ្ចូលនូវឧបសគ្គជាច្រើនដល់ការចូលដោយមានឯកសារទៀងទាត់។

ទោះបីជា ICRMW បង្ការមិនឲ្យមាននិរទេសតាមទំនើងចិត្តក៏ដោយ ការនិរទេសស្របច្បាប់ត្រូវបានអនុញ្ញាតក្នុងអនុសញ្ញានេះ។ ជាការពិតណាស់ ការបណ្តេញចេញជាសិទ្ធិរបស់រដ្ឋាភិបាល ទោះបីជាការនិរទេសនេះត្រូវធ្វើឡើងតាមយន្តការច្បាប់ក៏ដោយ។ ពលករទេសន្តប្រវេសន៍ពិតជាមានសិទ្ធិពាក់ព័ន្ធនឹងការនិរទេស រួមមានសិទ្ធិក្នុងការប្តឹងតវ៉ា និងសិទ្ធិតទល់នឹងការនិរទេសជាក្រុម។ យ៉ាងណាមិញ នៅមានចន្លោះសម្រាប់ការបកស្រាយពាក់ព័ន្ធនឹងគោលគំនិតនៃភាពស្របច្បាប់ ដើម្បីប្រឆាំងនឹងការនិរទេសតាមទំនើងចិត្ត។ មានសកម្មភាពមួយចំនួនដែលរដ្ឋាភិបាលអាចធ្វើបានដែលមិនកម្រិតលើសិទ្ធិពលករ។ នេះរួមមានបញ្ញត្តិកម្មលើប្រភេទនៃការងារដែលពលករទេសន្តប្រវេសន៍អាចធ្វើបាន។ នៅក្នុងប្រទេសដូចជាថៃ និងម៉ាឡេស៊ី ពលករទេសន្តប្រវេសន៍ត្រូវបានដាក់កម្រិតលើវិស័យការងារជាក់លាក់មួយចំនួន។ (ជាឧទាហរណ៍ ពលករទេសន្តប្រវេសន៍ក្នុងប្រទេសថៃ អាចធ្វើការក្នុងឧស្សាហកម្មនេសាទ កម្មន្តសាល កិច្ចការផ្ទះ ការដឹកជញ្ជូនទំនិញ កសិកម្ម និងសំណង់ប៉ុណ្ណោះ)។ ជាទូទៅ ប្រភេទការងារដែលពលករទេសន្តប្រវេសន៍ធ្វើគឺស្ថិតក្នុងប្រទេស " បី D″ ការងារដែលកង្វក់ គ្រោះថ្នាក់ និងមិនថ្លៃថ្នូរ។ ជាឧទាហរណ៍ ការងារក្នុងឧស្សាហកម្មនេសាទ អាចរួមបញ្ចូលការងារកង្វក់ដូចជាវះពោះត្រី (ជាការងារដែលធំក្លិនស្អុយ)។ ឧទាហរណ៍មួយនៃការងារគ្រោះថ្នាក់គឺធ្វើការលើទូកនេសាទកន្លែងមហាសាគរ។ ការងារមិនថ្លៃថ្នូរអាចជាអ្នកបម្រើសេវាផ្លូវភេទលក្ខណៈពាណិជ្ជកម្មដល់អ្នកនេសាទ (ទោះបីនេះមិនមែនទម្រង់ការងារស្របច្បាប់ក៏ដោយ)។

## ករណីសិក្សា

### អ្នកជួយកិច្ចការផ្ទះនៅសឹង្ហបូរីរៀបរាប់ពីហេតុការណ៍

របាយការណ៍ការឃ្លាំមើលសិទ្ធិមនុស្ស ស្តីពីអ្នកជួយកិច្ចការផ្ទះក្នុងប្រទេសសឹង្ហបូរី គឺ របាយការណ៍ ស្រ្តីជួយកិច្ចការផ្ទះចាំស្តាប់បញ្ជា ដែលបង្ហាញពីការរៀបរាប់របស់ស្រ្តីជួយកិច្ចការផ្ទះជនជាតិឥណ្ឌូនេស៊ី ដែលកំពុងបម្រើការងារក្នុងប្រទេសសឹង្ហបូរីដូចខាងក្រោមនេះ៖

"ខ្ញុំមិនត្រូវបានអនុញ្ញាតឲ្យចេញក្រៅ។ ខ្ញុំមិនដែលចេញទៅខាងក្រៅ មិនដែលសូម្បីតែទៅខាងក្រៅដើម្បីយកសំរាមចោល។ ខ្ញុំនៅក្នុងផ្ទះរហូត ខ្ញុំមិនដែលទៅផ្សារទាល់តែសោះ។ ខ្ញុំមិនត្រូវបានអនុញ្ញាតឲ្យបើកវិទ្យុស្តាប់នោះទេ។ ខ្ញុំអាចឃើញពិភពលោកខាងក្រៅនៅពេលដែលខ្ញុំហាងសម្លៀកបំពាក់ប៉ុណ្ណោះ។ ថៅកែរបស់ខ្ញុំនិយាយថា 'កុំនិយាយជាមួយអ្នកណាម្នាក់ឲ្យសោះ។ កុំនិយាយជាមួយមិត្តិភ័ក្ត ឬ អ្នកជិតខាងឲ្យសោះ'។ ខ្ញុំមិនត្រូវបានអនុញ្ញាតឲ្យទាក់ទងជាមួយសាច់ញាតិ។ ខ្ញុំបានធ្វើការអស់រយៈពេលបីឆ្នាំ។ ខ្ញុំមិនមានមនុស្សនិយាយជាមួយ។ ខ្ញុំសួរថៅកែរបស់ខ្ញុំតើខ្ញុំអាចទៅប្រទេសឥណ្ឌូនេស៊ីវិញបានឬក៏អត់ ហើយគាត់និយាយថា ទេ។ ពួកគាត់និយាយថា 'អ្នកឯងត្រូវតែបញ្ចប់កិច្ចសន្យារបស់ខ្លួន។ អ្នកឯកត្រូវតែធានាបញ្ចប់កិច្ចសន្យារបស់អ្នក មុនពេលត្រលប់ទៅវិញ'។

អ្នកជួយកិច្ចការផ្ទះមានភាពងាយរងគ្រោះជាពិសេស ដោសយារពួកគេនៅផ្តាច់ខ្លួនពីមិត្តិភ័ក្ត និងក្រុមគ្រួសារ។ បញ្ហាមានការប្រែប្រួលដោយសារតែមានទូរស័ព្ទចល័ត ហើយប្រទេសដូចជាសឹង្ហបូរី និងហុងកុង បានអនុម័តច្បាប់ដើម្បីឲ្យអ្នកជួយកិច្ចការផ្ទះមានពេលឈប់សម្រាប់ប្រចាំសប្តាហ៍ចំនួនមួយថ្ងៃ។ យ៉ាងណាមិញ ការការពារនៅតែគ្មានការធានា។ ថ្ងៃឈប់សម្រាកក្នុងប្រទេសសិង្ហបូរីគឺមិនមែនជាការតម្រូវដាច់ខាតនិយោជកអាចដកហូតទូរស័ព្ទ ហើយអ្នកជួយកិច្ចការផ្ទះមានអារម្មណ៍ភ័យខ្លាច ធ្វើឲ្យមិនហ៊ានដាក់ពាក្យបណ្តឹង។

## ៧.៣.២ អង្គការពលករទេសន្តប្រវេសន៍

អង្គការពលករទេសន្តប្រវេសន៍ខុសៗគ្នាពាក់ព័ន្ធនឹងទំហំ និងសកម្មភាព។ មានអង្គការចំនួនបីប្រភេទដែលធ្វើការការពារសិទ្ធិរបស់ពលករទេសន្តប្រវេសន៍។

## អង្គការអន្តរជាតិ

ក្រៅពី UN ដែលមានស្ថាប័នសន្ធិសញ្ញាសម្រាប់ ICRMW និងអ្នករាយការណ៍ពិសេសពីសិទ្ធិរបស់ជនមិនមែនជាពលរដ្ឋ អង្គការអន្តរជាតិដទៃទៀតដែលគ្រប់គ្រងសិទ្ធិពលករទេសន្តប្រវេសន៍ មានដូចជា ILO (អង្គការអន្តរជាតិខាងការងារ) និង IOM (អង្គការអន្តរជាតិទេសន្តប្រវេសន៍)។ ខណៈពេលដែលពួកគេនៅមានដែនកំណត់ក្នុងការផ្តល់ការប្រឹក្សា និងការស្រាវជ្រាវបច្ចេកទេស អង្គការទាំងនេះដើរតួជាស្ថាប័នកំណត់ស្តង់ដារដ៏សំខាន់។

## NGOs ជំនាញក្នុងស្រុក

អង្គការទាំងនេះផ្តល់សេវាកម្មដល់ពលករទេសន្តប្រវេសន៍ ដូចជាសេវាផ្លូវច្បាប់ ការការពារ និងការអប់រំ។ NGOs ដែលធ្វើការជាមួយពលករទេសន្តប្រវេសន៍ចំនួនពីរដែលលេចធ្លោបំផុតក្នុងតំបន់គឺ វាទិកាពលករទេសន្តប្រវេសន៍ (មានទីតាំងនៅប្រទេសហ្វីលីពីន) និងក្រុមការងារពលករទេសន្តប្រវេសន៍អាស៊ាន។ អង្គការទាំងពីរនេះពាក់ព័ន្ធយ៉ាងស៊ីជម្រៅក្នុងការតស៊ូមតិ និងការកំណត់ស្តង់ដារ។ បន្ថែមពីលើនេះទៀត អង្គការតាមមូលដ្ឋានក៏អាចផ្តល់សេវាកម្មបានដែរ (ដូចជាបណ្តាញការពារសិទ្ធិការងារ (LPN) ដែលមានទីតាំងនៅប្រទេសថៃ ឬ កម្លាំងស្ត្រី Tenaganita ក្នុងប្រទេសម៉ាឡេស៊ីជាដើម)។ ក្រុមទាំងនេះផ្តល់សេវាកម្មដូចជាសេវាផ្លូវច្បាប់ ការអប់រំសម្រាប់កុមាររបស់ពលករទេសន្តប្រវេសន៍ កម្មវិធីស្តីពីសុខភាព ជម្រក ការតស៊ូមតិលើសិទ្ធិពលករទេសន្តប្រវេសន៍ និងការផ្តល់ជំនួយមនុស្សធម៌ចំពោះពលករ និងក្រុមគ្រួសាររបស់ពួកគេ។ អង្គការទាំងនេះមួយចំនួនទទួលបានការគាំទ្រពី ILO និង IOM ដូចនេះបង្កើតនូវស្ថានភាពមួយដែលសកម្មភាពតាមមូលដ្ឋាន ទទួលបានការគាំទ្រជាអន្តរជាតិ។

## សហជីពពលករ

នេះជាការផ្តល់មធ្យោបាយក្នុងការគៀងគរពលករទេសន្តប្រវេសន៍ ដែលសម្លេងបុគ្គលរបស់គាត់មិនត្រូវបានគេដឹងលឺ។ តាមរយៈការចូលរួមក្នុងសហជីព ពលករ និងគ្រួសាររបស់ពលករទទួលបានតំណាង ការការពារ និងលទ្ធភាពក្នុងការទទួលបានយុត្តិធម៌។ យ៉ាងណាមិញ ដោយសារជារឿយៗពលករទេន្តប្រវេសន៍មិនមានសិទ្ធិក្នុងការចូលរួមក្នុងសហជីព ឬមានលទ្ធភាពក្នុងការទទួលបានសេវាពីអង្គការទាំងនេះ ឥទ្ធិពលរបស់អង្គការទាំងនេះនៅមានកម្រិតនៅឡើយ។ ក្នុងឆាកអន្តរជាតិ សហជីពដែលមានមូលដ្ឋាននៅអាមេរិក AFL-CIO ធ្វើកិច្ចការផ្តោះទៅកាន់កំណែទម្រង់អន្តោប្រវេសន៍ សិទ្ធិពលករពេញលេញរបស់ពលករបរទេស ការគ្រប់គ្រងពលករទេសន្តប្រវេសន៍ជាកុមារ ស្តង់ដារកន្លែងការងារដែលល្អប្រសើរឡើង និងអ្នកតំណាងស្របច្បាប់ដល់ពលករទេសន្តប្រវេសន៍ និងគ្រួសាររបស់ពួកគេ។

ដូចដែលបានឃើញ មានមធ្យោបាយជាច្រើនដែលពលករទេសន្តប្រវេសន៍ត្រូវបានការពារដោយអង្គការទាំងនេះ។ ការការពារពលករនៅកន្លែងការងារគឺមានសារៈសំខាន់ណាស់ ដូចនេះពួកគេមិនអាចត្រូវបានប្រព្រឹត្តមកលើមិនសមរម្យ ឬមិនត្រូវបានរំលោភបំពាន។ អង្គការអន្តរាគមន៍ក្នុងស្ថានភាពនេះតាមរយៈការជម្រាបដល់ប៉ូលីស ឬមន្ត្រីក្រសួងការងារអំពីការរំលោភបំពាននៅកន្លែងការងារ។ មានការទាមទារឲ្យធ្វើការតស៊ូមតិសម្រាប់សិទ្ធិពលករពីរដ្ឋាភិបាល និងវិស័យធុរកិច្ច ហើយដើម្បីផ្លាស់ប្តូរអាកប្បកិរិយារបស់សាធារណៈដែលមិនចូលចិត្តពលករទេសន្តប្រវេសន៍។ គ្រួសាររបស់ពលករទេសន្តប្រវេសន៍ត្រូវការជំនួយផងដែរ។ កូនៗជាច្រើនរបស់ពលករទេសន្តប្រវេសន៍មិនទទួលបានលទ្ធភាពក្នុងការទទួលបានសេវាជាមូលដ្ឋាន ដូចជាការថែទាំសុខភាព និងការអប់រំ ដែលនេះអាចត្រូវបានផ្តល់ជូនដោយ NGOs។

ខណៈពេលដែលមានផ្លូវវែងឆ្ងាយទៀត ដែលត្រូវដើរមុនពេលសិទ្ធិរបស់ពលករទេសន្តប្រវេសន៍ត្រូវបានការពារ ក៏មានភាពប្រសើរឡើងមួយចំនួនក្នុងតំបន់ក្នុងរយៈពេលប៉ុន្មានទសវត្សមកនេះ។ ដោយការចូលជាធរមាននៃ ICRMW ក្នុងឆ្នាំ២០០៣ និង ការបង្កើត NGOs ជាច្រើនដើម្បីការពារពលករទេសន្តប្រវេសន៍ គឺមានសកម្មភាពជាច្រើនក្នុងវិស័យនេះ។ យ៉ាងណាមិញ បញ្ហានៅតែមាន ហើយនេះជាករណីនៃទម្រង់ធ្ងន់ធ្ងរបំផុតនៃការរំលោភបំពានពលករទេសន្តប្រវេសន៍ គឺការជួញដូរ។

## ៧.៤ មនុស្សដែលត្រូវបានជួញដូរ

បទឧក្រិដ្ឋជួញដូរមនុស្ស ជាទូទៅត្រូវបានចាត់ទុកថាជាប្រភេទមួយនៃទាសភាព។ វាកើតឡើងនៅពេលដែលអ្នកណាម្នាក់ត្រូវបានយកចេញពីផ្ទះ ឬកន្លែងស្នាក់នៅរបស់ពួកគេ ហើយដាក់ចូលក្នុងស្ថានភាពមួយដែលពួកគេត្រូវបានកេងប្រវ័ញ្ច ការកេងប្រវ័ញ្ចនេះអាចជាពលកម្មដោយបង្ខំ ឬការងារបម្រើផ្លូវភេទ។ ការជួញដូរមនុស្សជាបញ្ហាធ្ងន់ធ្ងរមួយដែលមានការរីករាលដាលយ៉ាងខ្លាំង ក្នុងរយៈពេលម្ភៃឆ្នាំចុងក្រោយនេះដោយសារហេតុផលមួយចំនួន ជាចម្បងពាក់ព័ន្ធនឹងសាកលភាវូបនីយកម្ម៖

- ការកើនឡើងនៃបណ្តាញឧក្រិដ្ឋកម្មឆ្លងដែន៖ សាកលភាវូបនីយកម្មបាននាំឲ្យមានសកម្មភាព និងបណ្តាញបទឧក្រិដ្ឋឆ្លងដែន ដោយសារការផ្លាស់ប្តូរការទំនាក់ទំនងបច្ចេកវិទ្យា និងការធ្វើដំណើរ។ ការជួញដូរមនុស្សពេលបច្ចុប្បន្ននេះជាឧស្សាហកម្មមិនស្របច្បាប់ដែលរកចំណូលបានច្រើនបំផុត។
- សាកលភាវូបនីយកម្មនៃសេដ្ឋកិច្ច៖ ជាមួយនឹងប្រទេសកាន់តែច្រើនឡើងធ្វើការបើកចំហសេដ្ឋកិច្ចរបស់ខ្លួន និងចលនាដែលមានការកើនឡើងដើម្បីពលកម្ម និង

ការកំសាន្ត ការជួញដូរបានក្លាយជាប្រភពរកចំណូលនៃពលកម្ម។ មធ្យោបាយសេដ្ឋកិច្ចសាកលភាវូបនីយកម្ម ដែលធ្វើការបង្វិលប្រាក់ជុំវិញពិភពលោកដើម្បីធ្វើផលប្រយោជន៍ពីសកម្មភាពមិនស្របច្បាប់ ក៏មានភាពកាន់តែងាយស្រួលផងដែរ។

- ការធ្វើដំណើរដែលងាយស្រួលជាងមុន៖ បំលាស់ទីធំៗរបស់ប្រជាជនជារឿយៗពាក់ព័ន្ធនឹងបំលាស់ទីមិនទៀងទាត់របស់ប្រជាជន និងទំនិញ។ មនុស្សដែលត្រូវបានជួញដូរជាច្រើនធ្វើដំណើរស្របច្បាប់ទៅប្រទេសដទៃ គឺបានត្រឹមតែធ្លាក់ខ្លួនចូលក្នុងស្ថានភាពដែលត្រូវបានជួញដូរប៉ុណ្ណោះ។
- ការផ្លាស់ប្តូរទីផ្សារការងារ៖ ប្រទេសដែលមានការរីកចំរើនឧស្សាហកម្មឆាប់រហ័សនៅអាស៊ីអាគ្នេយ៍ ជារឿយៗត្រូវការចំនួនពលករដែលមានតម្លៃពលកម្មទាបជាច្រើន។ ជាមួយនឹងចំនួនប្រជាជនកាន់តែច្រើន ដែលមានគោលបំណងក្នុងការធ្វើដំណើរដើម្បីស្វែងរកការងារខាងក្រៅប្រទេសរបស់ពួកគេ អាចនាំឲ្យមានការកើនឡើងនូវការជួញដូរ។ លើសពីនេះទៀត ចំនួនច្រើននៃពលករស្ត្រីដែលនៅលីវអាចធ្វើឲ្យមានការកើនឡើងតម្រូវការ ក្នុងការងារបម្រើផ្លូវភេទជាលក្ខណៈពាណិជ្ជកម្ម ដែលអាចពឹងផ្អែកលើស្ត្រីដែលត្រូវបានជួញដូរ។

ច្បាប់ស្តីពីការជួញដូរមានប្រភពចេញពីច្បាប់ប្រឆាំងរបបទាសភាព ទោះបីជាការជួញដូរតាមមធ្យោបាយជាច្រើនបានក្លាយជាបទឧក្រិដ្ឋ ដែលខុសគ្នាពីទាសភាពក៏ដោយ។ ការបង្ការទាសភាពមានប្រវត្តិយូរលុងចាប់តាំងពីពាក់កណ្តាលទសវត្សឆ្នាំ ១៨០០ មកម្ល៉េះ ហើយការការពារពីអំពើទាសភាពពេលបច្ចុប្បន្ននេះ ត្រូវបានចាត់ទុកថាជាច្បាប់អន្តរជាតិទំនៀមទំលាប់។ ច្បាប់ប្រឆាំងការជួញដូរចាប់ផ្តើមតាំងពីដើមទសវត្សឆ្នាំ ១៩០០ ហើយច្បាប់ប្រឆាំងការជួញដូរដំបូងត្រូវបានហៅជាទូទៅថាជា "ច្បាប់ទាសភាពពណ៌ស"។ ច្បាប់ទាំងនេះមានគោលបំណងក្នុងការការពារស្ត្រី និងកុមារស្បែកសពីលក់ធ្វើជាទាសភាព ជាពិសេសក្នុងទ្វីបអាហ្វ្រិក និងមជ្ឈឹមបូព៌ា។ ទាសករស្ត្រីស្បែកសត្រូវបានចាត់ទុកថាជារឿងមិនពិត ដែលត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងស្ត្រី និងចាត់ទុកជនជាតិអាហ្វ្រិក និងប្រជាជនមកពីមជ្ឈឹមបូព៌ាថាជាបិសាច។ ទោះបីជាការគម្រាមកំហែងនេះមិនត្រូវបានបញ្ជាក់ពិតប្រាកដក៏ដោយ ក៏មានច្បាប់មួយចំនួនត្រូវបានអនុម័តដើម្បីបញ្ឈប់ការជួញដូរនេះ៖ កិច្ចព្រមព្រៀងអន្តរជាតិសម្រាប់ការទប់ស្កាត់ការជួញដូរទាសករជនជាតិស្បែកស (១៩០៤) អនុសញ្ញាអន្តរជាតិស្តីពីការទប់ស្កាត់ការជួញដូរទាសករជនជាតិស្បែកស (១៩១០) និងអនុសញ្ញាអន្តរជាតិដើម្បីទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ (១៩២១)។ ស្នាដៃសំខាន់មួយដែលត្រូវបានបង្កើតឡើងដោយច្បាប់ទាំងនេះគឺការធ្វើឲ្យច្បាប់ជួញដូរផ្តោតសំខាន់លើស្ត្រី និងលើការជួញដូរសម្រាប់ទាសភាពផ្លូវភេទ។ ជាការពិតណាស់នេះជាបញ្ហាធ្ងន់ធ្ងរ ប៉ុន្តែនេះមានន័យថាកាលពីមុនការជួញដូរបុរស និងការជួញដូរពលកម្មត្រូវបានយកមើលរំលងដោយអង្គការជាច្រើន ប៉ុន្តែទើបមានការផ្លាស់ប្តូរពេលថ្មីៗនេះប៉ុណ្ណោះ។

## ករណីសិក្សា

### ត្រូវបានជួញដូរទៅលើទូកនេសាទ

ការដកស្រង់ខាងក្រោមនេះគឺចេញពី អត្ថបទកាសែត *Myanmar* Times ចេញខែតុលា ឆ្នាំ២០១១ ដែលមានចំណងជើងថាពលករប្រាប់រឿងរ៉ាវពីទាសភាពលើទូកនេសាទថៃ៖

នៅថ្ងៃដែល មិនមែនជាឈ្មោះពិតរបស់គាត់ បានឃើញសមុទ្រជាលើកទីមួយ គឺនៅពេលដែលអ្នកជួញដូរបានប្រគល់គាត់ជូនថៅកែ បន្ទាប់ពីធ្វើដំណើរអស់មួយសប្តាហ៍តាមព្រៃពីមីយ៉ាន់ម៉ាទៅកាន់នាវាលើឆ្នេរសមុទ្រថៃ។

គាត់បានរៀបរាប់ថាវាជាការចាប់ផ្តើមនៃរយៈពេលប្រាំពីរខែនៃ ″ឋាននរក″ ដែលក្នុងអំឡុងពេលនោះ មានការវាយដំច្រំធាក់″រៀងរាល់ថ្ងៃ និងរៀងរាល់ម៉ោង″។

Hla Myint បានសម្រេចចិត្តរត់គេចខ្លួន ហាក់ចូលទឹក ហើយតោងពោងសង្គ្រោះជីវិតអស់រយៈពេលប្រាំម៉ោងមុនពេលដល់ច្រាំង បន្ទាប់ពីបានឃើញប្រធានក្រុមគាត់សម្លាប់កូនដៃទូកមួយរូប។

បុរសម្នាក់ដែលត្រូវបានចាប់ខ្លួនពេលព្យាយាមរត់គេច ត្រូវបានវាយ និងធ្វើទារុណកម្មធ្ងន់ធ្ងរនៅមុខអ្នកនេសាទទាំងអស់។

Hla Myint បាននិយាយ"បន្ទាប់ពីពួកគេយកគាត់ទៅខាងក្រោយទូក ឲ្យគាត់ឈរនៅកែមទូក ហើយបាញ់គាត់ចំក្បាល។ បេះដូងរបស់ខ្ញុំលោតខ្លាំងមែនទែនពេលដែលខ្ញុំឃើញហេតុការណ៍នេះ″ ។

រឿងរ៉ាវរបស់គាត់គឺជារឿងមួយក្នុងចំណោមរឿងរ៉ាវជាច្រើន នៃទាសភាពក្នុងឧស្សាហកម្មនេសាទរាប់លានដុល្លាររបស់ប្រទេសថៃ ដែលអ្នកធ្វើយុទ្ធនាការនិយាយថាឧស្សាហកម្មនេះពឹងផ្អែកលើពលកម្មដោយបង្ខំ ដើម្បីផ្គត់ផ្គង់គ្រឿងសមុទ្រដល់ភោជនីយដ្ឋាន និងផ្សារទំនើបជុំវិញពិភពលោក។

## ៧.៨.១ ពិធីសារដើម្បីបង្ការ ទប់ស្កាត់ និងដាក់ទណ្ឌកម្មលើការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ឆ្នាំ ២០០៣ (ពិធីសារ ប៉ាលីម៉ូ)

រហូតដល់ទសវត្សឆ្នាំ ១៩៩០ មានតែស្ថាប័នសិទ្ធិមនុស្សប៉ុណ្ណោះ (ដោយរួមមាន OHCHR) ដែលធ្វើការឆ្លើយតបនឹងការជួញដូរមនុស្ស។ យ៉ាងណាមិញ នៅក្នុង UN មានចលនាក្នុងការចាត់ទុកថាការជួញដូរជាអំពើឧក្រិដ្ឋ ហើយបន្ទាប់មកត្រូវបានទទួលខុសត្រូវដោយគណៈកម្មាការឧក្រិដ្ឋកម្មរបស់ UN ដែលបច្ចុប្បន្ននេះមានឈ្មោះថាជា ការិយាល័យ UN ស្តីពីគ្រឿងញៀន និងបទឧក្រិដ្ឋ (UNODC)។ ពិធីសារស្តីពីការជួញដូរគឺជាពិធីសារមួយក្នុងចំណោមពិធិសារទាំងបី នៃអនុសញ្ញារបស់អង្គការសហប្រជាជាតិដើម្បីប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន (២០០០)។ ពិធីសារពីរដទៃទៀតគ្របដណ្តប់លើការរត់ពន្ធមនុស្ស និងការអាវុធ។ ពេលខ្លះពិធីសារនេះត្រូវបានហៅថា ពិធីសារប៉ាលីម៉ូ ដែលបានដាក់ឈ្មោះតាមទីក្រុងប៉ាលីម៉ូនៅភាគខាងត្បូងរបស់ប្រទេសអ៊ីតាលី ដែលជាកន្លែងអនុសញ្ញាត្រូវបានព្រាង។ លក្ខណៈសំខាន់នៃពិធីសារគឺថាដាក់ជាបទឧក្រិដ្ឋលើសកម្មភាពនៅលើឆាកអន្តរជាតិ ដែលតាំងពីមុន ដូចជាអ្នកជ្រើសរើសអាចជួញដូរមនុស្សទៅកាន់ប្រទេសដទៃ ហើយមិនមានទោសឧក្រិដ្ឋនោះទេ ដោយសារតែការកេងប្រវ័ញ្ចពិតប្រាដកបានកើតឡើងក្នុងប្រទេសដទៃ និងឧក្រិដ្ឋជនដែលនៅខាងក្រៅដែនយុត្តាធិការដែលបទឧក្រិដ្ឋបានកើតឡើង។

បញ្ហាជាបឋមដែលបានដោះស្រាយដោយពិធីសារនេះ គឺកំណត់និយមន័យនៃការជួញដូរ ដោយមិនមាននិយមន័យណាមួយពីការជួញដូរក្នុងច្បាប់អន្តរជាតិនោះទេ។ នៅពេលនិយមន័យត្រូវបានកំណត់រួចរាល់ហើយ ទាមទារឲ្យមានការចាត់ទុកអំពើជួញដូរជាបទឧក្រិដ្ឋ ហើយនិងការពារសិទ្ធិរបស់ជនរងគ្រោះនៃការជួញដូរ។ ដោយមានភាពចម្រុះនៃកម្មវត្ថុ ជាការសំខាន់ក្នុងការចងចាំថា ពិធីសារស្តីពីការជួញដូរមិនមែនជាសន្ធិសញ្ញាសិទ្ធិមនុស្សនោះទេ ទោះបីជាវាមានធាតុផ្សំពីសិទ្ធិមនុស្ស ហើយកម្មវត្ថុរបស់វាគឺដើម្បីការពារសិទ្ធិមនុស្សក៏ដោយ។ ពិធីសារជួញដូរគឺខុសគ្នាពីសន្ធិសញ្ញាជនមិនមែនជាពលរដ្ឋដទៃទៀត ដូចជាសន្ធិសញ្ញាពលករទេសន្តប្រវេសន៍ និងជនភៀសខ្លួន ដោយនៅក្នុងពិធីសារជួញដូរនេះ មានកម្មវត្ថុច្បាស់ក្នុងការចាត់ទុកជាបទឧក្រិដ្ឋលើសកម្មភាពពាក់ព័ន្ធនឹងការជួញដូរ។ នៅពេលដែលរដ្ឋផ្តល់សច្ចាប័នលើពិធីសារ ពួកគេរំពឹងក្នុងការបង្ការ និងប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ការពារ និងជួយដល់ជនរងគ្រោះនៃការជួញដូរ និងសហការជាមួយនឹងរដ្ឋសមាជិកដទៃទៀត។

ការជួញដូរមានវត្តមានក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សចំនួនពីរ៖ ក្នុង CEDAW (មាត្រា ៦) ដែលព្យាយាមក្នុងការ"ទប់ស្កាត់គ្រប់ទម្រង់នៃការជួញដូរស្ត្រី" និងក្នុង ពិធីសារបន្ថែមទីពីរនៃ CRC ស្តីពីការលក់ដូរកុមារ ពេស្យាកម្មកុមារ និងអំពើអាសអាភាសលើកុមារ។ សន្ធិសញ្ញាទាំងពីរនេះមានដែនកំណត់របស់ខ្លួន៖ CEDAW មិនបានកំណត់និយមន័យ ឬចាត់ទុកជាបទឧក្រិដ្ឋនូវអំពើជួញដូរ ខណៈពេលដែល ពិធីសារបន្ថែម CRC ចាត់ទុកជាបទឧក្រិដ្ឋនូវពេស្យាកម្មកុមារ ប៉ុន្តែមិនបានកំណត់ពីការបំលាស់ទីកុមារ ឬពលកម្មដោយបង្ខំរបស់កុមារនោះឡើយ។

## ៧.៤.២ និយមន័យនៃការជួញដូរ

មានការជជែកវែកញែកច្រើនក្នុងអំឡុងពេល នៃការព្រាងពិធីកសារនៃការជួញដូរ ដែលរដ្ឋ និង NGOs ធ្វើការអះអាងអំពីលក្ខខណ្ឌតម្រូវដែលបុគ្គលមួយរូបអាចត្រូវបានបង្ខំឲ្យធ្លាក់ចូលការកេងប្រវ័ញ្ច តួនាទីនៃពេស្យាកម្ម និងអត្ថន័យនៃការកេងប្រវ័ញ្ចដើម្បីកំណត់ឈ្មោះប៉ុន្តែមួយចំនួនប៉ុណ្ណោះ។ និយមន័យក្នុងពិធីសារប៉ាលីម៉ូបានចែងថា៖

> ការជួញដូរមនុស្សមានន័យថា[ជាសកម្មភាពនៃ] ការជ្រើសរើស ដឹកជញ្ជូន ផ្ទេរ ដាក់លើទុក ឬទទួលបុគ្គល តាមរយៈមធ្យោបាយនៃការគម្រាមកំហែង ឬប្រើប្រាស់ទម្រង់ដទៃនៃការបង្ខំ ការចាប់ពង្រត់ បោកបន្លំ បោកប្រាស់ ឬការរំលោភអំណាច ឬស្ថិតក្នុងស្ថានភាពនៃភាពរងគ្រោះ ឬដោយសារការផ្តល់ ឬទទួលប្រាក់ ឬផលប្រយោជន៍ដើម្បីទទួលបានការព្រមព្រៀង ពីបុគ្គលមួយរូបដែលមានការគ្រប់គ្រងលើបុគ្គលដទៃទៀត ដើម្បីគោលបំណងនៃការកេងប្រវ័ញ្ច។ ការកេងប្រវ័ញ្ចរួមមាន ជាអប្បរមាន ជាការកេងប្រវ័ញ្ចពេស្យាកម្មលើអ្នកដទៃ ឬទម្រង់ណាមួយនៃការកេងប្រវ័ញ្ចផ្លូវភេទ ពលកម្មឬសេវាកម្មដោយបង្ខំ ទាសភាព ឬការអនុវត្តដែលស្រដៀងគ្នានឹងទាសភាព សេវភាព ឬការយកចេញនូវសរីរាង្គ។

មានធាតុផ្សំសំខាន់ចំនួនបីក្នុងនិយមន័យនេះ។ ចំពោះស្ថានភាពមួយដើម្បីចាត់ទុកថាជាការជួញដូរ ត្រូវមានវត្តមាននូវធាតុផ្សំទាំងបីនេះ (ទោះបីជាចំពោះកុមារ មានតែធាតុផ្សំ 'សកម្មភាព' និង 'ការកេងប្រវ័ញ្ច' គឺជាការចាំបាច់ក៏ដោយ)។

### ធាតុផ្សំ "សកម្មភាព"

ធាតុផ្សំសកម្មភាព ជាអ្វីដែលអ្នកណាម្នាក់ត្រូវតែប្រព្រឹត្តបទឧក្រិដ្ឋនៃការជួញដូរ។ សកម្មភាពដែលបានបញ្ជាក់មានដូចជា៖ ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការដាក់លើទុក ឬការទទួលមនុស្ស។ តារាងនេះគ្រប់ដណ្តប់គ្រប់ទិដ្ឋភាពទាំងអស់នៃការបំលាស់ទីក្នុងទេសន្តប្រវេសន៍ ចាប់ផ្តើមពីការជ្រើសរើសពីដំបូងរហូតដល់បុគ្គលត្រូវ

បានទទួលនៅចុងបញ្ចប់។ ការសំខាន់នៃធាតុនេះគឺថាវាចាត់ជាបទឧក្រិដ្ឋនៃដំណើរការទាំងមូល។ ការជួញដូរមិនមែនគ្រាន់តែជាការកេងប្រវ័ញ្ចលើបុគ្គលម្នាក់ប៉ុណ្ណោះទេ ប៉ុន្តែជាការលក់ ឬជ្រើសរើសអ្នកណាម្នាក់ដើម្បីធ្លាក់ចូលក្នុងស្ថានភាពដែលត្រូវបានជួញដូរផងដែរ។ ដោយសារពិធីសារនេះជាសន្និសញ្ញាព្រហ្មទណ្ឌ មានន័យថាអ្នកណាម្នាក់ដែលប្រព្រឹត្តអំពើណាមួយ ក្នុងចំណោមអំពើទាំងអស់នេះ គឺជាការប្រព្រឹត្តបទឧក្រិដ្ឋ។

## ធាតុផ្សំ“មធ្យោបាយ”

ធាតុផ្សំមធ្យោបាយ ជាអ្វីដែលអ្នកជួញដូរធ្វើដើម្បីធានាថាបុគ្គលត្រូវបានបញ្ចប់ក្នុងស្ថានភាពដែលត្រូវបានជួញដូរ ដូចជាការចាប់បង្ខំ ចាប់ពង្រត់ ឬបោកប្រាស់អ្នកណាម្នាក់។ តាមរយៈនេះ នេះគឺជាអ្វីដែលប្រែក្លាយសកម្មភាពខាងលើទៅជាបទឧក្រិដ្ឋ។ ប្រសិនជាអ្នកបើកតាក់ស៊ីម្នាក់ជូនអ្នកណាម្នាក់ទៅកន្លែងការងារមួយ ដែលពួកគេត្រូវបានជួញដូរ អ្នកបើកតាក់ស៊ីរូបនោះមិនបានប្រព្រឹត្តបទល្មើសនោះទេ (សន្មតថាអ្នកបើកបររូបនេះមិនដឹងរឿងអ្វីទាំងអស់)។ ប៉ុន្តែស្ត្រីដែលលក់កុមារទៅមេការទូកនេសាទ (ដូចជាករណីខាងលើក្នុងជំពូកនេះ) គឺច្បាស់ណាស់ជាការប្រព្រឹត្តការជួញដូរ។ និយមន័យផ្តល់នូវមានរូបភាពជាច្រើននៃ “មធ្យោបាយ” ចាប់ពីការគម្រាមកំហែងរូបរាងកាយ ដូចជាការចាប់ពង្រត់ មានទាំងការកុហក ឬបោកប្រាស់អ្នកណាម្នាក់ ហើយក៏រួមបញ្ចូលផងដែរនូវការរំលោភអំណាច និងការទទួលបានប្រាក់កម្រៃក្នុងការជួយដល់ការជួញដូរ។

## ធាតុផ្សំ “គោលបំណង”

គោលបំណងចង្អុលបង្ហាញពីអ្វីដែលបង្ខំបុគ្គលម្នាក់ឲ្យជួញដូរអ្នកដទៃ ហើយដោយយោងតាមពិធីសារនេះ នេះគឺសម្រាប់គោលបំណងនៃការកេងប្រវ័ញ្ច។ និយមន័យផ្តល់នូវឧទាហរណ៍មួយចំនួននៃការជួញដូរ ប៉ុន្តែជាការពិតមិនបានកំណត់និយមន័យពីការកេងប្រវ័ញ្ចនោះទេ។ ផ្ទុយទៅវិញ ពិធីសារនេះយល់ឃើញថាគោលបំណងទូទៅនៃការជួញដូរគឺដើម្បីកេងប្រវ័ញ្ចផ្លូវភេទ (នៅពេលដែលស្ត្រីម្នាក់ត្រូវបានបង្ខំឲ្យក្លាយជាអ្នកបម្រើផ្លូវភេទ) ឬពលកម្មដោយបង្ខំ (នៅពេលដែលបុគ្គលម្នាក់ត្រូវបានបង្ខំឲ្យធ្វើការផ្ទុយនឹងឆន្ទៈរបស់ខ្លួន មិនផ្តល់ប្រាក់ឈ្នួល ឬ បើកប្រាក់ឈ្នួលមិនគ្រប់គ្រាន់ និងមិនមានសេរីភាពក្នុងការចាកចេញពីការងាររបស់ខ្លួន)។ ទទួលស្គាល់ថាការកេងប្រវ័ញ្ចត្រូវបានកំណត់និយមន័យដោយអនុសញ្ញាស្តីពីពលកម្មដោយបង្ខំ ដែលបានបញ្ជាក់លម្អិតខាងលើថា៖ “រាល់ការងារ ឬសេវាកម្មដែលទទួលបានពីបុគ្គលណាមួយដែលស្ថិតក្នុងស្ថានភាពនៃការដាក់ទណ្ឌកម្មណាមួយ និងដែលការងារ ឬសេវាកម្មនេះមិនត្រូវបានបំពេញដោយបុគ្គលនេះដោយស្ម័គ្រចិត្តនោះទេ”។ និយមន័យក៏បានបញ្ជាក់ពីការយកចេញនូវសេរីរាង្គ ឬការជួញដូរសេរីរាង្គជាគោលបំណងមួយផងដែរ។ នេះមិនមែនជា

បទឧក្រិដ្ឋទូទៅនោះទេ ជាពិសេសនៅអាស៊ីអាគ្នេយ៍ ទោះបីជាមានករណីកើតឡើងលើបុគ្គលដែលបានបញ្ជាក់ក្នុងប្រទេសនេប៉ាល់ ចិន និងឥណ្ឌាក៏ដោយ។

និយមន័យខាងលើអនុវត្តចំពោះមនុស្សពេញវ័យប៉ុណ្ណោះ។ ដើម្បីបញ្ជាក់ថាមានការជួញដូរ កុមារដែលត្រូវបានកេងប្រវ័ញ្ចទាមទារតែការបញ្ជាក់ភ័ស្តុតាងលើធាតុសកម្មភាព និងគោលបំណងប៉ុណ្ណោះ។ ពិធីសារជួញដូរមិនបានបញ្ជាក់ច្បាស់ពីយេនឌ័រ ឬអាយុនោះទេ អ្នកណាម្នាក់ក៏អាចត្រូវបានជួញដូរបានដែរ។ ហើយក៏មិនបានបញ្ជាក់ថាត្រូវឆ្លងដែននោះទេ ដូចនេះមនុស្សអាចត្រូវបានជួញដូរទោះបីជាក្នុងប្រទេសរបស់ខ្លួនក៏ដោយ។ ពិធីសារនេះក៏មិនបានបញ្ជាក់ពីស្ថានភាពដែលមនុស្សអាចត្រូវបានជួញដូរនោះទេ ដូចនេះការជួញដូរអាចកើតមានក្នុងរោងចក្រ នៅផ្ទះ (ចំពោះពលករជួយកិច្ចការផ្ទះ) ផ្ទះបន តាមផ្លូវ (សម្រាប់កុមារសុំទាន) ឬទូកនេសាទ។ ពិធីសារនេះក៏បានបញ្ជាក់ច្បាស់ផងដែរថា ការព្រមព្រៀងរបស់ជនរងគ្រោះមិនពាក់ព័ន្ធនោះទេ ប្រសិនជាមធ្យោបាយណាមួយត្រូវបានប្រើប្រាស់។

# ការពិភាក្សា និង ការជជែកវែកញែក

## តើករណីណាមួយខាងក្រោមចាត់ទុកជាការជួញដូរ?

មានកន្លែងជាច្រើនដែលនិយមន័យនៃការជួញដូរមិនមានភាពច្បាស់លាស់។ ជាឧទាហរណ៍៖

ក. ប្រសិនជាអ្នកជ្រើសរើសមួយរូបគិតថាពួកគេបញ្ជូនអ្នកណាម្នាក់ ដើម្បីធ្វើការងារល្អមួយ ប៉ុន្តែជាការពិតវាក្លាយទៅជាស្ថានភាពនៃការជួញដូរ តើអ្នកជ្រើសរើសមានទោសពីការជួញដូរដែរឬទេ?

ខ. ប្រសិនជាអ្នកគ្រប់គ្រងមួយរូបបដិសេធ ក្នុងការបើកប្រាក់ឈ្នួលដល់ពលករទេសន្តប្រវេសន៍មួយរូប បន្ទាប់ពីគាត់ធ្វើការមួយខែ តើនេះជាការជួញដូរដែរឬទេ?

គ. ប្រសិនជាពលករទេសន្តប្រវេសន៍ម្នាក់ ត្រូវបានបៀតបៀនកេរ្តិ៍ខ្មាសជាបន្តបន្ទាប់នៅកន្លែងការងាររបស់គាត់ តើនេះជាការជួញដូរដែរឬទេ?

ឃ.ក្មេងអាយុ ៨ ឆ្នាំមួយរូបមកពីប្រទេសជិតខាងត្រូវបាននាំទៅកាន់ទីក្រុងមួយដើម្បីធ្វើក្មេងសុំទាន។ ក្មេងនោះរីករាយក្នុងការធ្វើការអ្នកសុំទាន ដោយសារគាត់ទទួលបានអាហារ និងអាចធ្វើការជាមួយមិត្តភ័ក្រ្ត ទោះបីជាគាត់មិនបានទទួលប្រាក់ឈ្នួលក៏ដោយ។ តើក្មេងរូបនេះត្រូវបានគេជួញដូរដែរឬទេ?

ង. ស្រ្តីម្នាក់បានជួប និងរៀបការជាមួយជនបរទេសម្នាក់តាមរយៈអ៊ិនធឺណែត។ នៅពេលដែលនាងធ្វើដំណើរទៅផ្ទះរបស់គាត់ នាងដឹងថាគាត់រំពឹងថានាងនឹងធ្វើការពេញមួយថ្ងៃនៅកន្លែងក្រុមហ៊ុនរបស់គាត់ ហើយគាត់ក៏បានវាយនាងផងដែរ។ ប្តីចាត់ទុកថានេះគឺជាអ្វីដែលប្រពន្ធត្រូវតែធ្វើចំពោះប្តីរបស់ខ្លួន។ តើប្រពន្ធរូបនេះត្រូវបានជួញដូរដែរឬទេ?

* ចម្លើយក្នុងប្រអប់ខាងក្រោម

ចម្លើយ

ក. មិនមែនជាការជួញដូរនោះទេ ដោយសារតែអ្នកជ្រើសរើសមិនមានគម្រោងក្នុងការបោកប្រាស់លើបុគ្គលនោះ។ យ៉ាងណាមិញ អ្នកត្រូវចងចាំក្នុងចិត្តផងដែរថា នេះជាលេសទូទៅបំផុតមួយដែលអះអាងដោយអ្នកជ្រើសរើស។

ខ. នេះមិនមែនជាការជួញដូរនោះទេ ដោយសារតែកម្រិតនៃការកេងប្រវ័ញ្ចមិនធ្ងន់ធ្ងរគ្រប់គ្រាន់។ ការកេងប្រវ័ញ្ចត្រូវតែបញ្ចូលកង្វះនូវសេរីភាព ឧទាហរណ៍ ប្រសិនជាបុគ្គលត្រូវបានបង្ការមិនឲ្យចាកចេញពីការងារ ឬ ពីទីកន្លែងការងារជាដើម។ ខណៈពេលដែលករណីទាំងនេះមិនមានជាការជួញដូរ វានៅតែជាបទឧក្រិដ្ឋ (ជាការរំលោភបំពានលើសិទ្ធិពលករ ឬការយាយី)។ យ៉ាងណាមិញ ប្រសិនជាអាចបង្ហាញភ័ស្តុតាងថាពលករទេសន្តប្រវេសន៍ ត្រូវបានជ្រើសរើសដើម្បីគោលបំណងកេងប្រវ័ញ្ច នេះអាចក្លាយជាការជួញដូរកម្លាំងពលកម្ម។

គ. នេះមិនមែនជាការជួញដូរនោះទេដោយសារហេតុផលដែលបានកំណត់ក្នុងចំនុច (ខ) ខាងលើ។

ឃ. នេះជាការជួញដូរ។ មិនចាំបាច់ធ្វើការបញ្ជាក់ពី "មធ្យោបាយ" នោះទេ នៅពេលដែលមានការពាក់ព័ន្ធនឹងកុមារ។

ង. នេះអាចជជែកវែកញែកបាន ហើយអាចជាការជួញដូរប្រសិនបើប្តីមានចេតនាប្រើប្រាស់អាពាហ៍ពិពាហ៍ដើម្បី ទទួលបានការងារដោយមិនចាំបាច់អស់ប្រាក់ឈ្នួលពីស្រ្តី (មានន័យថា គាត់បោកនាងដែលនេះបង្ហាញពី"មធ្យោបាយ") ហើយគាត់ហាមឃាត់មិនឲ្យនាងចាកចេញពីផ្ទះ (ដូចនេះបញ្ជាក់ពី "គោលបំណង")។ ប្រសិនបើមិនដូចនេះទេ អាកប្បកិរិយារបស់គាត់ត្រូវបានចាត់ទុកថាជាការយាយី ឬអំពើហិង្សាក្នុងគ្រួសារប៉ុណ្ណោះ។

## ៧.៤.៣ ធាតុផ្សំសិទ្ធិមនុស្សក្នុងពិធីសារស្តីពីការជួញដូរ

ពិធីសារពិតជាបានផ្តល់ការការពារដល់ជនរងគ្រោះនៃការជួញដូរ។ ដែលនេះអាចសម្រេចបានតាមមធ្យោបាយមួយចំនួនដូចជា តាមរយៈការការពារភាពឯកជនរបស់ជនរងគ្រោះ ផ្តល់ជូនពួកគេនូវជំនួយរូបរាងកាយ និងផ្លូវចិត្ត ធ្វើមាតុភូមិនុវត្តន៍ដល់ពួកគេ (ឬជួយពួកគេឲ្យត្រលប់មកផ្ទះវិញ)។ ជាការសំខាន់ ពិធីសារនេះថែងថា ជនរងគ្រោះនៃការជួញដូរមិនត្រូវចាត់ទុកថាជាឧក្រិដ្ឋជន ឬដាក់ពន្ធនាគារនោះទេ។ ការឆ្លើយតបជាទូទៅរបស់ប៉ូលីស នៅពេលដែលពួកគេរកឃើញបុគ្គលដែលមិនមានឯកសារគឺឃុំខ្លួនពួកគេភ្លាមៗ ដូចនេះពួកគេអាចត្រូវបានបណ្តេញចេញពីប្រទេស។ ទោះបីជានៅពេលដែលពួកគាត់ត្រលប់មកវិញ ជនរងគ្រោះអាចត្រូវដាក់ក្នុងពន្ធនាគារដោយរដ្ឋាភិបាលរបស់ខ្លួនចំពោះបទល្មើសពាក់ព័ន្ធនឹងអន្តោប្រវេសន៍។ គួរឲ្យស្តាយកង្វល់នេះមិនត្រូវបានគ្រប់ដណ្តប់ដោយផ្ទាល់ក្នុងពិធីសារនោះទេ។ យ៉ាងណាមិញចាប់តាំងពីចូលជាធរមាន មានការចេញសេចក្តីណែនាំ និងសេចក្តីសម្រេចប្រកាសថានេះគួរតែត្រូវបានចាត់ទុកថាជាស្តង់ដារអនុវត្តរបស់រដ្ឋ។

ដើម្បីយល់ដឹងពីវិធីសាស្ត្រដែលសិទ្ធិរបស់ជនរងគ្រោះនៃការជួញដូរ ត្រូវបានការពារ ជាការសំខាន់ក្នុងការពិភាក្សាពីវិធីសាស្ត្រ ដែលមនុស្សត្រូវបានធ្លាក់ចូលក្នុងស្ថានភាព ដែលត្រូវបានជួញដូរ។ ខណៈពេលដែលប្រព័ន្ធផ្សព្វផ្សាយ និងស្ថាប័នមួយចំនួនភាគ ច្រើននិយាយអំពីស្ត្រីវ័យក្មេង ដែលត្រូវបានបោកប្រាស់ ឬបង្ខំឲ្យធ្លាក់ចូលក្នុងការ ជួញដូរផ្លូវភេទ នេះមិនមែនជាទម្រង់តែមួយគត់នៃការជួញដូរនោះទេ ហើយប្រហែល ជាមិនមែនជាទម្រង់ទូទៅមួយនៃការជួញដូរនោះទេ ទោះបីជាវាជាប្រភេទដែលធ្ងន់ធ្ងរ បំផុតមួយក៏ដោយ។ ការសិក្សាកាលពីពេលថ្មីៗនេះដែលបានធ្វើឡើងនៅអាស៊ីអាគ្នេយ៍ បានគូសបញ្ជាក់ពីចំនួនបុរសយ៉ាងច្រើន ដែលត្រូវបានជួញដូរក្នុងការងារលើទូក នេសាទ ឬវិស័យកសិកម្ម។ ជារឿយៗ ពលករគិតថាពួកគេចាប់ផ្តើមការងារដែល ស្របច្បាប់ ប៉ុន្តែភ្លាមៗពួកគេជ្រាបពីលក្ខខណ្ឌការងារដែលបានដកហូតនូវសេរីភាព របស់ពួកគេ។ ដូចគ្នាចំពោះស្ត្រីជួយកិច្ចការផ្ទះផងដែរ ដែលត្រូវបានឃុំខ្លួនក្នុងផ្ទះរបស់ថៅកែរបស់ ខ្លួន។ ជារឿងទូទៅដែលជនមិនមែនជាពលរដ្ឋត្រូវបានជួញដូរជាជាងពលរដ្ឋ ចំពោះ ពលរដ្ឋអាចគ្រាន់តែរត់ចេញទៅប៉ូលីសដើម្បីសុំការការពារ ខណៈពេលដែលជនមិន មែនជាពលរដ្ឋអាចមានភាពភ័យខ្លាច ក្នុងការរាយការណ៍ទៅប៉ូលីស ហើយប្រសិនបើ ពួកគេធ្វើដូចនេះ ពួកគេប្រហែលជាមិនចេះភាសាគ្រប់គ្រាន់នោះទេ។ ខណៈពេល ដែលមានការជួញដូរទៅក្នុងឧស្សាហកម្មផ្លូវភេទ ជាពិសេសបន ដែលអតិថិជនចម្បង គឺពលករទេសន្តប្រវេសន៍តែម្តង ការជួញដូរសម្រាប់ពលកម្មគឺធំជាង និងមានការត្រួត ពិនិត្យតិចជាងក្នុងតំបន់នេះ។ ដោយសារហេតុផលនេះ កត្តាគន្លឹះក្នុងការការពារសិទ្ធិ មនុស្សដែលត្រូវបានជួញដូរ គឺតាមរយៈការផ្តល់ការការពារបន្ថែមទៀតនៅកន្លែង ការងារ។ ប៉ុន្តែ ដូចដែលផ្នែកមុនបានបញ្ជាក់លម្អិត រដ្ឋាភិបាលនៃប្រទេសដែលមាន ចំនួនពលករទេសន្តប្រវេសន៍ច្រើនមានភាពស្ទាក់ស្ទើរក្នុងការធ្វើដូចនេះ មានន័យថា ការជួញដូរសម្រាប់ពលកម្មនឹងនៅតែបន្ត។

គំរូទម្រង់ទ្រាយនៃការជួញដូរនៅអាស៊ីអាគ្នេយ៍ខុសគ្នាពីតំបន់ដទៃ។ នៅអាស៊ីខាងត្បូង ជារឿងទូទៅដែលស្ត្រីត្រូវបានជួញដូរ ទៅក្នុងការងារផ្លូវភេទលក្ខណៈពាណិជ្ជកម្មនៅ ប្រទេសឥណ្ឌាពីប្រទេសជិតខាងដូចជានេប៉ាល់ និងបង់ក្លាដេស។ ប្រជាជននៅអាស៊ី ខាងត្បូងធ្លាក់ចូលក្នុងស្ថានភាពដែលត្រូវបានជួញដូរ ក្នុងរដ្ឋជាប់ឈូងសមុទ្រ និងចំនួន ពលករយ៉ាងច្រើនធ្វើដំណើរទៅធ្វើការនៅ អារ៉ាប់រួម គូវ៉ែត និងអារ៉ាប៊ីសាអូឌីត។ មាន ការជួញដូរពីអឺរ៉ុបខាងកើតទៅអឺរ៉ុបខាងលិច និងពីអាហ្វ្រិកទៅអឺរ៉ុប សម្រាប់ពលកម្ម និង ការងារបម្រើសេវាផ្លូវភេទលក្ខណៈពាណិជ្ជកម្មផងដែរ។

# ករណីសិក្សា

## អ្នកណាត្រូវបានជួញដូរ?
## ជនរងគ្រោះដែលមិនសាកសម

ការកំណត់នូវការកើតមាននៃការជួញដូរគឺមានលក្ខណៈស្មុគស្មាញ។ ជនរងគ្រោះនៃការជួញដូរមនុស្សជាច្រើនមិនត្រូវបានកំណត់អត្តសញ្ញាណ។ មនុស្សតែម្នាក់អាចត្រូវបានជួញដូរច្រើនដង។ អាជ្ញាធរ និងអង្គការមួយចំនួនអាចបំប៉ោង ឬបន្ទាបចំនួននៃការជួញដូរ។ ដូចនេះស្ថិតិនៃការជួញដូរមនុស្សមិនអាចជឿទុកចិត្តបាន និងបង្ហាញព័ត៌មានខុស។ ការសន្និដ្ឋានពីអ្វីដែលមនុស្សអាចងាយរងគ្រោះពីការជួញដូរអាចចេញជាលទ្ធផលថាជាមនុស្សដែលមិនសាកសម។ គម្រោងអន្តរទីភ្នាក់ងារអង្គការសហប្រជាជាតិស្តីពីការជួញដូរមនុស្ស (UNIAP) ដែលធ្វើការក្នុងប្រទេសចំនួនប្រាំមួយទូទាំងមហាអនុតំបន់មេគង្គ (កម្ពុជា ចិន ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម) បានទទួលស្គាល់នូវវត្តមាននៃជនរងគ្រោះដែលមិនសាកសម និងបានចាប់នូវគម្រោងមួយ។ គម្រោងការគាំទ្រដល់ជនរងគ្រោះមិនសកសមនេះ មានសកម្មភាពជាមួយក្រុមដែលជាទៀងទាត់ត្រូវបានមើលរំលង ឬបដិសេធក្នុងការផ្តល់សេវា។ UNIAP ពន្យល់ថា៖

"ក្រុមមួយនៃជនរងគ្រោះពីការជួញដូរដែលជារឿយៗមិនសាកសម គឺជនរងគ្រោះជាបុរសនៃការកេងប្រវ័ញ្ចពលកម្ម ដែលត្រូវបានបង្ខំឲ្យធ្វើការលើទូក ឬក្នុងចំការដំណាំ ឬរោងចក្រ។ ខណៈពេលដែលច្បាប់ និងគោលនយោបាយត្រូវបានកែសម្រួលទូទាំងមហាអនុតំបន់មេគង្គទទួលស្គាល់ជនរងគ្រោះនៃការជួញដូរជាបុរស ក៏នៅមានកង្វះខាតក្នុងការផ្តល់សេវាកម្មដល់ពួកគេផងដែរ។ លើសពីនេះទៀត ប្រជាជនរួមមានអ្នកដែលត្រូវបានជ្រើសរើសតាមរយៈច្រកផ្លូវការ ដែលធ្លាក់ចូលក្នុងការងារជួយកិច្ចការផ្ទះដោយមិនទទួលបានប្រាក់កម្រៃ និងដោយបង្ខំ ឬអ្នកបម្រើផ្លូវភេទដែលចូលបម្រើដោយស្ម័គ្រចិត្ត ហើយបន្ទាប់មកត្រូវបានកេងប្រវ័ញ្ច ប៉ុន្តែមិនត្រូវបានចាត់ទុកថាត្រូវបានជួញដូរ ហើយដូចនេះមិនអាចទទួលបានជំនួយសមស្របនោះទេ។ ជារឿយៗផ្ទុយទៅវិញពួកគេត្រូវបានចាត់ទុកថាជាឧក្រិដ្ឋជន ឬត្រូវបានចាប់បង្ខំឲ្យត្រលប់មកផ្ទះវិញដោយមានបំណុល"។

## ផ្តោតសំខាន់លើ

### ភាពខុសគ្នារវាងការជួញដូរមនុស្ស និងការរត់ពន្ធមនុស្ស

ការជួញដូរមនុស្សខុសគ្នាពីការរត់ពន្ធមនុស្សតាមមធ្យោបាយមួយចំនួន។ ទស្សនៈរដ្ឋាភិបាលគឺថាមនុស្សដែលត្រូវបានជួញដូរគឺជាជនរងគ្រោះ ខណៈពេលដែលមនុស្សដែលត្រូវបានរត់ពន្ធគឺបំពានច្បាប់អន្តោប្រវេសន៍ដោយចេតនា ដើម្បីចូលទៅកាន់ប្រទេសដោយខុសច្បាប់។ នៅពេលរត់ពន្ធមនុស្ស អ្នករត់ពន្ធ និងមនុស្សដែលត្រូវបានរត់ពន្ធព្យាយាមក្នុងការដឹកជញ្ជូនដោយសម្ងាត់ ពីប្រទេសមួយទៅប្រទេសមួយដោយសារពួកគេមិនត្រូវបានអនុញ្ញាតឲ្យចូលដោយស្របច្បាប់។ ក្នុងន័យម្យ៉ាងទៀត អំពើនេះគឺស្ម័គ្រចិត្ត ហើយមនុស្សដែលពាក់ព័ន្ធត្រូវបានចាត់ទុកថាមានសេរីភាព មុនពេល អំឡុងពេល និងក្រោយពេលដឹកជញ្ជូន។ ការជួញដូរខុសគ្នាដោយសារជនរងគ្រោះទាំងនេះជារឿយៗត្រូវបានបោកប្រាស់ បង្ខំ ហើយមិនមានសេរីភាពដើម្បីជ្រើសរើសនោះទេ ( ដែលជាទូទៅពួកគេត្រូវបានបង្ខំឲ្យធ្លាក់ចូលក្នុង សេវភាព)។

ក្នុងការអនុវត្ត ការបែងចែកគឺកម្រនឹងមានភាពច្បាស់លាស់ណាស់ ដោយសារជារឿយៗមានការពិបាកក្នុងាករវាស់វែងពីកម្រិតនៃភាពស្ម័គ្រចិត្ត ជាឧទាហរណ៍ មនុស្សដែលត្រូវបានរត់ពន្ធអាចជាកម្មវត្ថុនៃការចាប់បង្ខំផងដែរ (មិនថាដើម្បីលុយបន្ថែម ឬការគម្រាមកំហែងដល់សមាជិកគ្រួសារ ឬការគម្រាមកំហែងលើសន្តិសុខរបស់ពួកគេនោះទេ)។ បុគ្គលមួយរូបអាចចាប់ផ្តើមពីការរត់ពន្ធ ប៉ុន្តែភ្លាមៗនោះអាចធ្លាក់ចូលក្នុងស្ថានភាពដែលត្រូវបានជួញដូរ។ ជាឧទាហរណ៍ ពួកគេអាចត្រូវបានបង្ខំឲ្យធ្វើការនៅកន្លែងណាមួយបន្ទាប់ដឹងថាពួកគេត្រូវបង់លុយបន្ថែមដល់ "អ្នករត់ពន្ធ" របស់ខ្លួន។ ដូចនេះ បុគ្គលមិនចាំបាច់ត្រូវបានជួញដូរចេញប្រទេសនោះទេ (ប៉ុន្តែអាចចាកចេញដោយស្ម័គ្រចិត្ត) ដើម្បីធ្លាក់ចូលក្នុងស្ថានភាពនៃការជួញដូរ។

## មាតុភូមិនិវត្តន៍

នៅក្នុងករណីខ្លះ ជាផលប្រយោជន៍ល្អប្រសើរបំផុតចំពោះជនរងគ្រោះក្នុងការត្រលប់ទៅប្រទេសដើមរបស់ខ្លួនវិញ។ ការធ្វើមាតុភូមិនិវត្តន៍គឺជាសិទ្ធិ ហើយនៅពេលដែលត្រូវធ្វើឡើងដោយត្រឹមត្រូវ គឺទាមទារឲ្យមានដំណើរការប្រឹក្សាយោបល់ដើម្បីធានាថាមនុស្សដែលត្រូវបានជួញដូរមានភាពរួចរាល់ និងមានឆន្ទៈក្នុងការត្រលប់មកវិញ។ ការវិលត្រលប់ដោយត្រឹមត្រូវគឺមានពេលសម្រាប់ការធ្វើសមាហរណកម្មឡើងវិញ និងឧបាស្រ័យផ្លូវច្បាប់។ ជាការធានាផងដែរថា បុគ្គលអាចត្រលប់មកផ្ទះដោយសុវត្ថិភាព និងមានភាពថ្លៃថ្នូរ។ យ៉ាងណាមិញនៅអាស៊ីអាគ្នេយ៍ ទាមទារឲ្យមានការរៀនសូត្របន្ថែមទៀតអំពីការអនុវត្តល្អប្រសើរក្នុងវិស័យនេះ ដោយសាររដ្ឋាភិបាលជារឿយៗធ្វើមាតុភូមិនិវត្តន៍មនុស្សដែលត្រូវបានជួញដូរដោយបង្ខំ។

ការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះនៃការជួញដូរជារឿយៗ ជាដំណោះស្រាយងាយស្រួល និងល្អប្រសើរបំផុត។ នៅក្នុងស្ថានភាពមួយចំនួន ជនរងគ្រោះនៃការជួញដូរមិនចង់ឲ្យគេនិរទេសមកផ្ទះវិញនោះទេ។ ជាឧទាហរណ៍ ពួកគេចង់ធ្វើជាពលករទេសន្តប្រវេសន៍ស្នាក់នៅប្រទេសផ្សេង និងស្វែងរកការងារ ជាជាងមកដល់ផ្ទះហើយដាច់ដៃ។ ជាការពិតណាស់ ពួកគេអាចមានបំណុលពីការធ្វើដំណើរទៅប្រទេសដទៃ ហើយត្រូវធ្វើការដើម្បីសងបំណុល។ ចុងក្រោយ ជនរងគ្រោះជារឿយៗគឺមានភាពខ្មាសអៀនដោយសារត្រូវបានជួញដូរក្នុងការបម្រើផ្លូវភេទ ហើយអាចប្រឈមនឹងការរើសអើងក្នុងភូមិស្រុករបស់ខ្លួន។

# ៧.៥ ការប្រឈមក្នុងការកំណត់អត្តសញ្ញាណមនុស្សដែលត្រូវបានជួញដូរ

ការកំណត់អត្តសញ្ញាណជនរងគ្រោះនៃការជួញដូរ អាចជាការប្រឈមក្នុងការធានាថាមនុស្សដែលត្រូវបានជួញដូរត្រូវបានការពារ។ អត្តសញ្ញាណត្រឹមត្រូវមានន័យថាជនរងគ្រោះម្នាក់ទទួលបានការការពារច្រើន ដូចជាលទ្ធភាពក្នុងការទទួលបានជំនួយផ្នែកច្បាប់ ឬការជួយរបស់NGO ជម្រក សិទ្ធិក្នុងការមិនត្រលប់ចូលទៅក្នុងស្ថានភាពដែលមិនមានសន្តិសុខ ការការពារពីកាត់ទោស និងមិនត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬបណ្តេញចេញពីប្រទេសនោះទេ។ អត្តសញ្ញាណនៃមនុស្សដែលត្រូវបានជួញដូរក្នុងពិធីសារប៉ាលឺម៉ូ គឺមានកម្រិតដោយសារមិនបានគូសបញ្ជាក់ថាអ្នកណាគេ ឬវិធីសាស្ត្រដែលបុគ្គលម្នាក់ត្រូវបានអះអាងថាត្រូវបានជួញដូរ។ ជាការសន្មតថាកិច្ចការនេះជាបន្ទុកចម្បងនៃរដ្ឋដែលបុគ្គលត្រូវបានជួញដូរទៅក្នុងរដ្ឋនោះ ទោះបីជារដ្ឋនៃសញ្ជាតិបាន

ទំនួលខុសត្រូវបន្ថែម ក្នុងការទទួលបុគ្គលនោះជាជនរងគ្រោះនៃការជួញដូរនៅពេលដែលពួកគេត្រលប់មកវិញ។

ជាការពិត មនុស្សដែលត្រូវបានជួញដូរនឹងត្រូវបានចាត់ទុកថាជាជនរងគ្រោះ ហើយរដ្ឋគួរតែមានការត្រួតពិនិត្យ និងការការពារគ្រប់គ្រាន់ដើម្បីស្វែងរក និងជួយពួកគេ។ នេះអាចធ្វើទៅបាននៅក្នុងករណីនៃការវាយឆ្មក់ និងការជួយសង្គ្រោះពីផ្ទះបន ឬរោងចក្រ។ ក្នុងស្ថានភាពទាំងនេះ ប៉ូលីស ឬអាជ្ញាធរដទៃជារឿយៗកំណត់ថាតើបុគ្គលត្រូវបានជួញដូរឬក៏អត់។ ប៉ុន្តែក្នុងករណីដែលបុគ្គលដែលគ្មានឯកសារម្នាក់បានមកប្តឹងប៉ូលីសពីរឿងរ៉ាវនៃការកេងប្រវ័ញ្ចលើគាត់ ពួកគេអាចត្រូវបានចាត់ទុកថាជាមនុស្សដែលត្រូវបានជួញដូរ (សន្មតថាអាជ្ញាធរមូលដ្ឋានដឹងពីច្បាប់) ប៉ុន្តែពួកគេក៏អាចត្រូវបានចាត់ទុកថាជាពលករមិនស្របច្បាប់ផងដែរ (និងត្រូវបាននិរទេសចេញពីប្រទេស) ប្រសិនបើអាជ្ញាធរមិនដឹង ឬមិនអាចកំណត់អត្តសញ្ញាណនៃមនុស្សដែលត្រូវបានជួញដូរ។ អ្វីដែលធ្ងន់ធ្ងរជាងនេះទៀត ក្នុងករណីទាំងនេះ អ្នកជួញដូរជារឿយៗរត់គេចពីប្រព័ន្ធយុត្តិធម៌។

## ករណីសិក្សា

### ប្រទេសថៃ (ខែមេសា ឆ្នាំ២០០៨)

អ្នកបើកឡានដឹកទំនិញរត់ពន្ធពលករទេសន្តប្រវេសន៍ចំនួន ១២១ នាក់ បានចាក់សោរពួកគេនៅខាងក្រោយឡានដឹកទំនិញរបស់គាត់ ប៉ុន្តែមិនបានធានាឲ្យមានការដកដង្ហើមគ្រប់គ្រាន់នោះទេ។ ជាលទ្ធផល ពលករភូមាចំនួន ៥៤ នាក់បានស្លាប់ដោយសារថប់ខ្យល់។ ភាគច្រើននៃស្ត្រីដែលនៅរស់ត្រូវបានចាត់ទុកថាត្រូវបានជួញដូរ និងទទួលបានជំនួយ។ យ៉ាងណាមិញ បុរសដែលនៅរស់ត្រូវចាត់ទុកថា "ជនបរទេសមិនស្របច្បាប់" ហើយត្រូវបានធ្វើនិរទេស។ នេះដោយសារច្បាប់ក្នុងប្រទេសថៃនៅពេលនោះគឺទទួលតែស្ត្រីប៉ុណ្ណោះថាជាជនរងគ្រោះនៃការជួញដូរ។ ចាប់តាំងពីពេលនោះមក ច្បាប់បានផ្លាស់ប្តូរ ហើយពេលបច្ចុប្បន្ននេះរាល់ជនរងគ្រោះទាំងអស់ត្រូវទទួលបានការប្រព្រឹត្តមកលើដូចគ្នា។ បួនឆ្នាំក្រោយមក អ្នកបើកឡានដឹកទំនិញ ម្ចាស់ឡាន និងអ្នកដែលជួយដល់ការរត់ពន្ធត្រូវបានកាត់ទោសឲ្យជាប់គុកចន្លោះពី ៦ ទៅ ១០ឆ្នាំ ក្នុងពន្ធនាគារ។

ការប្រឈមលើសពីនេះទៀត គឺថាមិនមែនគ្រប់ប្រទេសទាំងអស់នៅអាស៊ីអាគ្នេយ៍ មានច្បាប់ដែលចាត់ទុកជាបទឧក្រិដ្ឋលើការជួញដូរនោះទេ។ បញ្ហាធ្ងន់ធ្ងរមួយគឺថារដ្ឋបានទទួលស្គាល់តែស្ត្រីប៉ុណ្ណោះថាត្រូវបានជួញដូរ មិនមែនបុរសនោះទេ។ យ៉ាងណាមិញស្ថានភាពនេះបានប្រែប្រួលជាមួយនឹងការផ្តល់សច្ចាប័នលើពិធីសារ និងការផ្លាស់ប្តូរច្បាប់ជាតិ។ ទូទាំងអាស៊ីអាគ្នេយ៍ រដ្ឋភាគច្រើនបានអនុម័ត ឬធ្វើបច្ចុប្បន្នភាពច្បាប់ជួញដូររបស់ពួកគេដើម្បីអនុលោមតាមពិធីសារប៉ាលឺម៉ូ។ តារាង ១២-១ បង្ហាញពីច្បាប់ និងការអនុលោមតាមច្បាប់លើពិធីសារប៉ាលឺម៉ូ។

### តារាង ៧-១: ច្បាប់ប្រឆាំងការជួញដូរមនុស្សនៅអាស៊ីអាគ្នេយ៍

| | ការផ្ដល់សច្ចាប័នប៉ាលឺម៉ូ | ច្បាប់ជួញដូរមនុស្សក្នុងស្រុក | ខ្លឹមសារ |
|---|---|---|---|
| ប្រ៊ុយណេ | មិនមាន | ការជួញដូរមនុស្ស និងការបញ្ចារត់ពន្ធមនុស្ស (២០០៤) | ការហាមឃាត់ការបញ្ជាទិញផ្លូវភេទ និងការជួញដូរកម្លាំងពលកម្ម។ ការជួញដូរផ្លូវភេទត្រូវទទួលទោសព្រហ្មទណ្ឌរហូតដល់៣០ឆ្នាំចំណែកឯការជួញដូរកម្លាំងពលកម្មត្រូវទទួលទោសជាប់ពន្ធនាគាររហូតដល់ទៅ៣ឆ្នាំ។ |
| កម្ពុជា | មាន | ច្បាប់ស្ដីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ (២០០៧) | ច្បាប់ក្នុងស្រុកស្រដៀងគ្នានឹងពិធីការប៉ាលឺម៉ូ។ |

| | | | |
|---|---|---|---|
| ឥណ្ឌូនេស៊ី | មាន | ច្បាប់ប្រឆាំងការជួញដូរមនុស្ស (២០០៧) | ច្បាប់ក្នុងស្រុកស្រដៀងគ្នានឹងពិធីការប៉ាលឺម៉ូ។ បទឧក្រិដ្ឋទាសភាពបំណុល ការរំលោភកម្លាំងពលកម្ម ការរំលោភផ្លូវភេទ និងការជួញដូរឆ្លងដែន និងនៅខាងក្នុង។ |
| ឡាវ | មាន | គ្មានច្បាប់ជាក់លាក់ | ឡាវមានច្បាប់ឧក្រិដ្ឋជួញដូរមនុស្ស បើទោះបីជាពួកគេអនុវត្តតែទៅលើស្ត្រី កុមារ មិនមានបុរស។ |
| ម៉ាឡេស៊ី | មាន | ច្បាប់ប្រឆាំងជួញដូរមនុស្ស (២០០៧) វិសោធនកម្មនៅឆ្នាំ ២០១០ | ច្បាប់ក្នុងស្រុកស្រដៀងគ្នានឹងពិធីការប៉ាលឺម៉ូ លើកលែងតែវាចាត់ទុកពេស្យាចារដូចទៅនឹងទម្រង់នៃការកេងប្រវ័ញ្ច។ វិសោធនកម្មឆ្នាំ២០១០បានបន្ថែមនិយមន័យនៃការជួញដូរដោយរាប់បញ្ចូលគ្រប់សកម្មភាពដែលជាប់ទាក់ទងក្នុងការទទួលបាន ឬរក្សាការងារ ឬសេវានៃបុគ្គលម្នាក់តាមរយៈការបង្ខិតបង្ខំ។ |
| មីយ៉ាន់ម៉ា | មាន | ច្បាប់ស្តីពីការជួញដូរមនុស្សជាបុគ្គល (២០០៥) | ច្បាប់ក្នុងស្រុកស្រដៀងគ្នានឹងពិធីការប៉ាលឺម៉ូ។ |
| ហ្វីលីពីន | មាន | ការប្រឆាំងការជួញដូរនឹងទង្វើបុគ្គល(២០០៣) | ច្បាប់ក្នុងស្រុកស្រដៀងគ្នានឹងពិធីការប៉ាលឺម៉ូ។ ច្បាប់អនុញ្ញាតឲ្យព្រះរាជអាជ្ញារួមទាំងអង្គការក្រៅរដ្ឋាភិបាលទុកដាក់ពាក្យបណ្តឹងប្រឆាំងនឹងអ្នកជួញដូរ។ |
| សិង្ហបុរី | មិនមាន | គ្មានច្បាប់ជាក់លាក់ | ក្រមព្រហ្មទណ្ឌឧក្រិដ្ឋភាគច្រើនគឺមានទម្រង់នៃការជួញដូរ ប៉ុន្តែមិនបានប្រើប្រាស់ទៅលើកុមារអាយុ១៦ និង១៧សម្រាប់ពេស្យាចារ។ |
| ថៃ | មិនមាន | ការប្រឆាំងការជួញដូរនឹងទង្វើបុគ្គល B.E. ២៥៥១ (២០០៨) | ច្បាប់ក្នុងស្រុកស្រដៀងគ្នានឹងពិធីការប៉ាលឺម៉ូ។ |
| វៀតណាម | មាន | គ្មានច្បាប់ជាក់លាក់ | គ្មាននិយមន័យច្បាស់លាស់ពីការជួញដូរមនុស្ស ហើយគ្របដណ្តប់តែលើស្ត្រី និងកុមារ។ |
| ទីម័រ | មាន | គ្មានច្បាប់ជាក់លាក់ | គ្មានច្បាប់ឧក្រិដ្ឋកម្មគ្រប់ជ្រុងជ្រោយអំពីការជួញដូរមនុស្ស។ ទោះបីជាយ៉ាងណា ការធ្វើអន្តោប្រវេសន៍ និងការជ្រកកោន (២០០៣) ហាមឃាត់ការជួញដូរស្ត្រី និងកុមារសម្រាប់ពេស្យាចារនិងកម្លាំងពលកម្មដោយបង្ខំ។ |

## ៧.៥.១ ការឆ្លើយតបរបស់ NGO

នៅអាស៊ីអាគ្នេយ៍ អង្គការចម្បងមួយក្នុងចំណោមអង្គការចម្បងៗមួយចំនួនដែលធ្វើការដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរ គឺគម្រោងអន្តរទីភ្នាក់ងារអង្គការសហប្រជាជាតិស្តីពីការជួញដូរ (UNIAP) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០ UNIAP ធ្វើការសម្របសម្រួលក្នុង UN ដោយគៀងគរទីភ្នាក់ងារ UN ផ្សេងៗគ្នាដែលធ្វើការក្នុងវិស័យនេះ (UNDP UN Women UNICEF OHCHR និង UNODC)។ UNIAP ក៏ជាស្ថាប័នសម្របសម្រួលក្នុងតំបន់ដែលរៀបចំការឆ្លើយតបក្នុងមហាអនុតំបន់មេគង្គផងដែរ។

NGOs ដែលធ្វើការលើការជួញដូររួមមានសម្ព័ន្ធពិភពលោកប្រឆាំងនឹងការជួញដូរស្ត្រី និងកុមារ (GAATW) ដែលជាសម្ព័ន្ធមួយដែលមានអង្គការជាង ១០០ ពីទូទាំងពិភពលោក ហើយមានមូលដ្ឋាននៅប្រទេសថៃ។ បន្ថែមពីលើនេះទៀត បញ្ចប់ពេស្យាកម្ម និងការជួញដូរកុមារ (ECPAT) ផ្តោតសំខាន់លើការជួញដូរកុមារ។ អង្គការអន្តរជាតិដទៃទៀតរួមមានការប្រឆាំងនឹងទាសភាពគម្រោង SOLD សម្ព័ន្ធប្រឆាំងនឹងការជួញដូរស្ត្រី (CATW) គម្រោង Polaris និងគណៈកម្មាធិការសង្គ្រោះអន្តរជាតិ (IRC)។

**ការឆ្លើយតប៖ P ទាំងបួន**

ពិធីសារនេះផ្តល់នូវវិធានការមួយចំនួន ដែលរដ្ឋគួរតែចាត់ក្នុងការបង្ការការជួញដូរ ដូចជាការផ្លាស់ប្តូរព័ត៌មាន ការបណ្តុះបណ្តាលប៉ូលីសក្នុងការកំណត់អត្តសញ្ញាណការជួញដូរ ពង្រឹងការគ្រប់គ្រងព្រំដែន ការដាក់ទោសព្រហ្មទណ្ឌលើអ្នកជួញដូរ និងអនុម័តច្បាប់ព្រហ្មទណ្ឌជាតិ។ វិធានការណ៍ទាំងនេះត្រូវបានហៅថា "P ទាំងបួន" (ចងចាំថាពីមុនគឺ "P ទាំងបី" មុនពេលដែលមានការបន្ថែមនូវ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ)។ P ទាំងបួនមានដូចតទៅ៖

១. គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ៖ រដ្ឋាភិបាលត្រូវមានគោលនយោបាយជាធរមានដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងការបណ្តុះបណ្តាលដើម្បីប្រយុទ្ធប្រឆាំងនឹងសិទ្ធិមនុស្ស។

២. បង្ការ៖ ការត្រួតពិនិត្យ និងការអប់រំយ៉ាងសកម្មនឹងបង្ការមនុស្សពីហានិភ័យនៃការជួញដូរ។

៣. ការកាត់ទោស៖ ធានាថាច្បាប់ត្រូវបានត្រួតពិនិត្យ និងប្រើប្រាស់ ដូចនេះអ្នកជួញដូរដែលត្រូវបានសង្ស័យត្រូវបានបញ្ជូនទៅពន្ធនាគារ។

៤. ការការពារ៖ ធានាថាសិទ្ធិរបស់ជនរងគ្រោះនៃការជួញដូរត្រូវបានគោរព ហើយពួកគេត្រូវបានផ្តល់ឱកាសក្នុងស្តារឡើងវិញ និងត្រូវបានសមាហរណកម្មទៅក្នុងសហគមន៍ប្រសិនជាចាំបាច់។

សកម្មភាពជាច្រើនត្រូវបានអនុវត្តដោយអង្គការសង្គមស៊ីវិលដើម្បីរួមចំនែកដល់ P ទាំងបួន។ ការអប់រំគឺមានសារៈសំខាន់ ដោយសារសកម្មភាពសាមញ្ញអាចត្រូវបានបំពេញដើម្បីកាត់បន្ថយការជួញដូរ ដោយរួមមានការធ្វើដំណើរជាមួយសមាជិកគ្រួសារ រក្សាទំនាក់ទំនងតាមទូរស័ព្ទជាមួយគ្រួសារ និងមានការប្រុងប្រយ័ត្នបន្ថែមពាក់ព័ន្ធនឹងការទទួលការងារដែលគិតថាល្អដោយមិនមានការពិនិត្យប្រវត្តិការពិតឲ្យបានដិតដល់។

# ក. សេចក្តីសង្ខេបពីជំពូក និងចំនុចគន្លឹះ

## ពលករទេសន្តប្រវេសន៍

### ពលករទេសន្តប្រវេសន៍

ទេសន្តប្រវេសន៍ដើម្បីការងារមានវត្តមាន អស់រយៈពេលជាច្រើនសតវត្សមកហើយ ទោះបីជាចំនួនពេលបច្ចុប្បន្នមានការកើនឡើងច្រើនជាងមុនខ្លាំងក៏ដោយ។ មានបញ្ហាពីរចម្បង គឺការរំលោភបំពានលើពលករទេសន្តប្រវេសន៍ និងការជួញដូរ ដែលត្រូវបានការពារក្នុងសន្ធិសញ្ញាពីរដាច់ដោយឡែកពីគ្នា។ ចំពោះពលករទេសន្តប្រវេសន៍ ILO បានចាប់ផ្តើមធ្វើការលើបញ្ហានេះបន្ទាប់ពីសង្គ្រាមលោកលើកទីពីរមកម្ល៉េះ ហើយ UN បានអនុម័តអនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិរបស់ពលករ ទេសន្តប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ (ICRMW) ក្នុងឆ្នាំ ១៩៩០។ ICRMW គឺជាសន្ធិសញ្ញាសិទ្ធិមនុស្ស ដូចនេះវាមានការការពារទូលំទូលាយជាងនូវសិទ្ធិដោយរួមមានទាំងគ្រួសារ និងសិទ្ធិក្រៅពីកន្លែងធ្វើការ។ សន្ធិសញ្ញាមិនត្រូវបានផ្តល់សច្ចាប័នទូលំទូលាយនោះទេ ហើយក៏មិនមានប្រទេសអភិវឌ្ឍន៍ ឬប្រទេសដែលមានចំនួនពលករទេសន្តប្រវេសន៍ច្រើនបានផ្តល់សច្ចាប័នលើសន្ធិនេះនោះទេ។ ពលករទេសន្តប្រវេសន៍មួយរូបសំដៅលើ "បុគ្គលដែលនឹងចូលរួម កំពុងចូលរួម ឬធ្លាប់ចូលរួមក្នុងសកម្មភាពដែលទទួលបានកម្រៃក្នុងរដ្ឋដែលគាត់មិនមែនជាសញ្ជាតិ។" និយមន័យនេះការពារពលករទេសន្តប្រវេសន៍មុនពេល អំឡុងពេល និងក្រោយពេលធ្វើការងារ មានន័យថាពលករ ហើយមិនមានការបែងចែករវាងពលករដែលគ្មាន និងមានឯកសារនោះទេ។ សន្ធិសញ្ញាគ្រប់ដណ្តប់ការការពារសម្រាប់ពលករ ប្តី/ប្រពន្ធ និងកូនៗរបស់ពួកគេ។

### សិទ្ធិពលករទេសន្តប្រវេសន៍

មានសិទ្ធិមនុស្សបីប្រភេទចំពោះពលករទេសន្តប្រវេសន៍។ ជាដំបូង មានសិទ្ធិមនុស្សដែលមានស្រាប់ ដែលពលករត្រូវតែទទួលបាន ប៉ុន្តែរដ្ឋាភិបាលមួយចំនួនព្យាយាមក្នុងការមិនអើពើសិទ្ធិនេះ។ ជាឧទាហរណ៍ រួមមានលទ្ធភាពក្នុងការប្តឹងទៅតុលាការ សេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាពរួចផុតពីការចាប់ខ្លួនតាមទំនើងចិត្ត។ ទីពីរ មានសិទ្ធិជាក់លាក់ចំពោះពលករទេសន្ត

ប្រវេសន៍ដែលរួមមានការមិនដកហូត ឬមិនបំផ្លាញប័ណ្ណសម្គាល់ខ្លួន ប្រព្រឹត្តកម្មស្មើភាពគ្នា និងលក្ខខណ្ឌការការស្មើគ្នានឹងពលរដ្ឋ និងសិទ្ធិពាក់ព័ន្ធនឹងការស្នាក់នៅក្នុងប្រទេសមួយ សម្រាប់អំឡុងពេលមួយនៅពេលដែលពួកគេបញ្ចប់ការងារ។ មានសិទ្ធិជាពិសេសចំពោះប្រភេទមួយចំនួននៃពលករផងដែរ។ ពលករទេសន្តប្រវេសន៍ដែលមានឯកសារមានសិទ្ធិក្នុងការបង្កើតសហជីព និងមានលទ្ធភាពក្នុងការទទួលបានសេវាកម្មលំនៅដ្ឋាន និងសង្គម។ ប្រភេទពិសេសមួយចំនួននៃពលករទេសន្តប្រវេសន៍ដូចជា ពលករតាមព្រំដែន ឬពលករតាមរដូវមានសិទ្ធិក្នុងការទទួលបានសិទ្ធិស្តង់ដារទាំងអស់ ប៉ុន្តែលទ្ធភាពរបស់ពួកគេក្នុងការទទួលបានសេវាសង្គម និងការអប់រំរបស់កូនៗរបស់ពួកគេអាចមានដែនកំណត់ ដោយសារពួកគេមិនរស់នៅពេញម៉ោងក្នុងប្រទេសដែលខ្លួនធ្វើការនោះទេ។

## ការប្រឈមនៃ ICRMW

អនុសញ្ញាមានចំនុចខ្សោយមួយចំនួនដូចជាមិនមានការការពារច្បាស់លាស់ចំពោះស្ត្រី ដែលប្រឈមនឹងការរើសអើងផ្លូវភេទនៅកន្លែងការងារ ឬប្រាក់ឈ្នួលមិនស្មើភាពគ្នា។ ចំនុចខ្សោយមួយទៀតគឺការការពារពលករជួយកិច្ចការផ្ទះដែលស្ទើរតែជាស្ត្រីទាំងអស់ និងពលករជាយុវជន (ប្រជាជនដែលមានអាយុក្រោម ១៨ ឆ្នាំដែលស្វែងរកការងារ)។ ការប្រឈមមួយគឺការផ្តល់សច្ចាប័នលើសន្ធិសញ្ញាមានចំនួនតិច។ ប្រទេសអភិវឌ្ឍន៍ អាចគិតថាសន្ធិសញ្ញាផ្តល់នូវសិទ្ធិច្រើនហួសហេតុពេក ដល់ពលករទេសន្តប្រវេន៍ ហើយប្រសិនបើលក្ខខណ្ឌការងារល្អប្រសើរពេក ពលករនឹង 'ហូរជន់ជោរ' ទៅក្នុងប្រទេស។ រដ្ឋអាចចាត់ទុកថាសិទ្ធិមួយចំនួនមានភាពចម្រូងចម្រាសដូចជាការប្រព្រឹត្តលើពលករទេសន្តប្រវេសន៍ ស្មើគ្នានឹងពលករក្នុងស្រុកពាក់ព័ន្ធនឹងប្រាក់ឈ្នួល ម៉ោងបន្ថែម ថ្ងៃឈប់សម្រាក និងការបញ្ចប់កិច្ចសន្យា។ មានកង្វល់មួយថា ICRMW ទទួលស្គាល់ពលករមិនមានឯកសារ ដូចដែលរដ្ឋភាគច្រើនហៅពលករដែលមិនមានឯកសារថាជាជនទេសន្តប្រវេសន៍មិនស្របច្បាប់ ហើយពួកគេអាចត្រូវបានចាប់ខ្លួន និងនិរទេសដោយងាយស្រួល។

## ការរំលោភបំពានសិទ្ធិពលករទេសន្តប្រវេសន៍

ពលករទេសន្តប្រវេសន៍ប្រឈមនឹងការគម្រាមកំហែង ដោយសារពួកគេរស់នៅក្រៅរដ្ឋរបស់ខ្លួន ហើយពួកគេត្រូវបានចាត់ទុកថាជាបន្ទុកដល់សង្គម និងមិនល្អដល់សេដ្ឋកិច្ច។ ពលករទេសន្តប្រវេសន៍ជាច្រើនមានភាពស្ទាក់ស្ទើរក្នុងការរាយការណ៍ពីការគម្រាមកំហែង ឬការរំលោភបំពានដោយសារពួកគេយល់ឃើញថាប៉ូលីស និងប្រព័ន្ធយុត្តិជួយពួកគេបានតិចតួចបំផុត។ ពួកគេប្រឈមនឹងការបោកប្រាស់ ដោយសារក្រុមហ៊ុន ឬបុគ្គលសន្យាផ្តល់កិច្ចសន្យាការងារដែលមានរយៈពេលវែង (ជារឿយៗពាក់ព័ន្ធនឹងប្រាក់ឈ្នួល) ហើយក្រោយមកពលករទេសន្តប្រវេសន៍ជ្រាបថាមិនមានការងារធ្វើនោះទេ ឬប្រសិនបើមានការងារ លក្ខខណ្ឌមិនដូចនឹងអ្វីដែលត្រូវបានសន្យានោះទេ។ មានលក្ខខណ្ឌការងារដែលមិនល្អ ហើយពលករអាចប្រឈមនឹងការមិនបើកប្រាក់ខែ លក្ខខណ្ឌការងារកង្វក់ គ្រោះថ្នាក់ និងមិនមានអនាម័យ និងម៉ោងការវែង។ សូម្បីតែនៅក្រៅកន្លែងធ្វើការ ពលករទេសន្តប្រវេសន៍អាចប្រឈមនឹងការរើសអើងក្នុងទម្រង់ជាការជ្រែក

ជ្រៀតពីប៉ូលីស ការឆែកឆេរជាម្តងហើយម្តងទៀត មិនអាចបញ្ជូនកូនទៅសាលារៀន និងមិនអាចអនុវត្តសកម្មភាពវប្បធម៌ដូចជារៀបការ ការអនុវត្តសាសនា ឬថ្ងៃបុណ្យជាតិ។ ពលកម្មដោយបង្ខំជាទម្រង់ធ្ងន់ធ្ងរបំផុតនៃការរំលោភបំពានលើពលកម្ម។

## សកម្មភាពរបស់រដ្ឋាភិបាលដែលអាចការពារសិទ្ធិពលករទេសន្តរប្រវេសន៍

រដ្ឋត្រូវលើកកម្ពស់លក្ខខណ្ឌការងារដែលមានលក្ខណៈជាមនុស្ស និងស្របច្បាប់។ រដ្ឋគួរតែបញ្ឈប់ទេសន្តរប្រវេសន៍មិនស្របច្បាប់ និងការពារប្រជាជនពីការរំលោភបំពានដែលកើតឡើងនៅពេលប្រជាជនត្រូវបានដឹកជញ្ជូនដោយមិនស្របច្បាប់ទៅក្នុងប្រទេសមួយ។ រដ្ឋត្រូវបានអនុញ្ញាតក្នុងការនិរទេសប្រជាជនដោយស្របច្បាប់ ទោះបីជាការនិរទេសនេះត្រូវធ្វើឡើងតាមរយៈយន្តការស្របច្បាប់។ សកម្មភាពដទៃទៀតដែលរដ្ឋាភិបាលអាចធ្វើប្បញ្ញត្តិកម្ម លើប្រភេទនៃការងារដែលពលករទេសន្តរប្រវេសន៍អាចធ្វើ។ ទោះបីជាប្រភេទការងារដែលពលករទេសន្តរប្រវេសន៍អាចធ្វើបានស្ថិតក្នុងប្រភេទ "D ទាំងបី" ក៏ដោយ ឬជាការងារដែលកង្វះ គ្រោះថ្នាក់ និងបន្ទាបបន្ថោក។

## អង្គការពលករទេសន្តរប្រវេសន៍

អង្គការពលករទេសន្តរប្រវេសន៍រួមមានអង្គការអន្តរជាតិដូចជា UN ILO និង IOM។ មាន NGOs ជំនាញថ្នាក់ជាតិមួយចំនួន ដែលផ្តល់សេវាដល់ពលករទេសន្តរប្រវេសន៍ ដូចជាសេវាផ្លូវច្បាប់ ការការពារ និងការអប់រំ។ ហើយក៏មានសហជីពពលករដែលធ្វើការឆ្ពោះទៅកាន់ការកំណែទម្រង់អន្តោប្រវេសន៍ សិទ្ធិពេញលេញរបស់ពលករបរទេស ការគ្រប់គ្រងពលករទេសន្តរប្រវេសន៍ជាកុមារ ស្តង់ដារកន្លែងការងារដែលប្រសើរឡើង និងតំណាងស្របច្បាប់នៃពលករទេសន្តរប្រវេសន៍ និងគ្រួសាររបស់ពួកគេ។

## មនុស្សដែលត្រូវបានជួញដូរ

ការជួញដូរមានការកើនឡើងកាលពីពេលថ្មីៗនេះ ដោយសារការកើនឡើងនូវឧក្រិដ្ឋកម្មឆ្លងដែន និងសាកលភាវូបនីយកម្មនៃសេដ្ឋកិច្ច ទីផ្សារការងារ និងការធ្វើដំណើរ។ ច្បាប់ប្រឆាំងនឹងទាសភាពចាប់ផ្តើមក្នុងដើមទសវត្សឆ្នាំ ១៨០០ ហើយច្បាប់ប្រឆាំងនឹងការជួញដូរចាប់ផ្តើមនៅដើមទសវត្សឆ្នាំ ១៩០០។ ច្បាប់ទាំងនេះមានគោលបំណងក្នុងការការពារស្ត្រី និងកុមារជនជាតិស្បែកសពីការលក់ធ្វើជាទាសករ ជាពិសេសនៅអាហ្វ្រិក និងមជ្ឈឹមបូព៌ា ដែលពេលបច្ចុប្បន្ននេះត្រូវបានចាត់ទុកថាជាការប្រឌិត។

### ពិធីសារស្តីពីការជួញដូរ

ពិធីសារស្តីពីការជួញដូរ ជាពិធីសារមួយក្នុងចំណោមពិធីសារទាំងបីនៃអនុញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន (២០០០)។ ពិធីសារនេះចាត់ទុកជាបទឧក្រិដ្ឋនូវការជួញដូរនៅឆាកអន្តរជាតិ។ ជាពិសេសពិធីនេះបានកំណត់និយមន័យពីការជួញដូរ ដោយសារមិនមាននិយមន័យពីមុនមកនៅក្នុងច្បាប់អន្តរជាតិនោះទេ។ ការជួញដូរមានធាតុផ្សំចំនួនបី៖ សកម្មភាពនៃការជ្រើសរើស ការដឹកជញ្ជូន ឬការទទួលបុគ្គល តាមរយៈមធ្យោបាយនៃការគម្រាមកំហែង ការចាប់បង្ខំ ការចាប់ពង្រត់ ឬការបាកប្រាស់ ហើយសម្រាប់គោលបំណងនៃការជួញដូរ។ កុមារដែលត្រូវបានកេងប្រវ័ញ្ចទាមទារឲ្យមានការបង្ហាញភ័ស្តុតាងលើធាតុផ្សំសកម្មភាព និងការកេងប្រវ័ញ្ចប៉ុណ្ណោះដើម្បីបញ្ជាក់ថាមានការកើតឡើងនូវការជួញដូរ។ ពិធីសារនេះការពារជនរងគ្រោះនៃការជួញដូរដោយផ្តល់ជូនពួកគេជំនួយផ្នែករាងកាយ និងផ្លូវចិត្តដែលចាំបាច់ ធ្វើមាតុភូមិនិវត្តន៍ដល់ពួកគេ និងផ្តល់លទ្ធភាពក្នុងការប្តឹងទៅតុលាការ។ ផលប្រយោជន៍ប្រសើរបំផុតនៃជនរងគ្រោះ ប្រហែលជាការបញ្ជូនពួកគេត្រលប់មកប្រទេសកំណើតវិញ ប៉ុន្តែនេះទាមទារឲ្យមានដំណើរការពិគ្រោះយោបល់ ដើម្បីធានាថាមនុស្សដែលត្រូវបានជួញដូរមានភាពរួចរាល់ និងមានបំណងចង់ត្រលប់មកវិញ។

### ការប្រឈមក្នុងការកំណត់អត្តសញ្ញាណមនុស្សដែលត្រូវបានជួញដូរ

ការកំណត់អត្តសញ្ញាណនៃជនរងគ្រោះនៃការជួញដូរអាចមានការប្រឈម ដោយសារនេះត្រូវបានសន្មតថានឹងត្រូវបានធ្វើឡើងដោយរដ្ឋដែលបុគ្គលត្រូវបានជួញដូរទៅកាន់រដ្ឋនោះ។ ជាការពិត មនុស្សដែលត្រូវបានជួញដូរត្រូវបានចាត់ទុកថាជាជនរងគ្រោះ និងរដ្ឋអាចមានការត្រួតពិនិត្យ និងការការពារគ្រប់គ្រាន់ដើម្បីស្វែងរក និងជួយពួកគេ។ ការប្រឈមមួយគឺថាគ្រប់ប្រទេសទាំងអស់ នៅអាស៊ីអាគ្នេយ៍មានច្បាប់មួយដែលចាត់ទុកជាបទឧក្រិដ្ឋនូវអំពើជួញដូរ។ រដ្ឋខ្លះទទួលស្គាល់តែស្រ្តីប៉ុណ្ណោះថាជាជនរងគ្រោះនៃការជួញដូរ គឺមិនមែនជាបុរសនោះទេ។

### ការឆ្លើយតបរបស់ NGO

មានអង្គការជាច្រើនដូចជា UNIAP និង GAATW ដែលគោរពសិទ្ធិរបស់ជនរងគ្រោះនៃការជួញដូរ។ អង្គការទាំងត្រូវបានចាត់ទុកថាបានឆ្លើយតបនឹង P ទាំងបួនប្រឆាំងនឹងសកម្មភាពជួញដូរ៖ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ ការកាត់ទោស និងការការពារ។

## ខ. សំណួរប្រលង ឬសំណួរងាយស្រួល

- តើរឿងអវិជ្ជមានអ្វីខ្លះ ដែលប្រជាជននិយាយអំពីពលករទេសន្តប្រវេសន៍ក្នុងប្រទេសរបស់អ្នក តើអ្វីជាការរិះគន់ត្រឹមត្រូវនៃទស្សនៈទាំងនេះ? តើពលករទេសន្តប្រវេសន៍រួមចំណែកលើសេដ្ឋកិច្ច កម្លាំងពលកម្ម និងសហគមន៍ក្នុងប្រទេសអ្នកយ៉ាងដូចម្តេចខ្លះ?

- ពិភាក្សាពីច្បាប់ដែលគ្រប់គ្រងពលកម្មទេសន្តប្រវេសន៍ ក្នុងប្រទេសរបស់អ្នក។ តើច្បាប់បង្ខំឲ្យប្រជាជនធ្លាក់ចូលស្ថានភាពដែលត្រូវបានជួញដូរមែនដែរឬទេ ឬតើច្បាប់ទាំងនោះការសិទ្ធិរបស់ពួលករដែរឬទេ?
- ប្រសិនជាអ្នករស់នៅក្នុងប្រទេសបញ្ជូន តើការរៀបចំ និងការការពារអ្វីខ្លះដែលរដ្ឋាភិបាលរបស់អ្នកផ្តល់ជូនដល់ពលករដែលធ្វើដំណើរទៅបរទេសដើម្បីធ្វើការ?
- តើច្បាប់ស្តីពីការជួញដូរក្នុងប្រទេសរបស់អ្នក អនុលោមតាមពិធីសារប៉ាលីម៉ូដែរឬទេ? តើច្បាប់នេះមាននិយមន័យដូចគ្នាជាមួយនឹងពិធីសារនេះដែរឬទេ ហើយតើច្បាប់នេះផ្តល់សិទ្ធិដូចគ្នានឹងសន្និសញ្ញាប៉ាលីម៉ូដែរឬទេ? តើមានចំនុចខ្សោយចម្បងអ្វីខ្លះក្នុងច្បាប់ជាតិ?
- លើកយកករណីមួយនៃការជួញដូរដែលបានកើតឡើងក្នុងប្រទេសរបស់អ្នក។ តើស្ថានភាពនេះត្រូវបានកំណត់អត្តសញ្ញាណយ៉ាងដូចម្តេច ហើយតើជនរងគ្រោះត្រូវបានការពារយ៉ាងដូចម្តេចខ្លះ? តើអ្នកគិតថាការផ្តួចផ្តើមដោយរដ្ឋាភិបាលគ្រប់គ្រាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរដែរឬទេ?

- រៀបរាប់ពីប្រភេទទាំងបួននៃសិទ្ធិរបស់ជនមិនមែនជាពលរដ្ឋ។ ជាមួយនឹងប្រភេទនីមួយៗ បញ្ជាក់ឈ្មោះនៃស្ថាប័នអន្តរជាតិចម្បងៗ ដែលធ្វើការលើសិទ្ធិទាំងនេះ ស្ថាប័ន និងអង្គការដែលធ្វើការពារយ៉ាងសកម្មលើសិទ្ធិរបស់ជនមិនមែនជាពលរដ្ឋក្នុងប្រទេសរបស់អ្នក ហើយ និងច្បាប់ជាតិដែលពាក់ព័ន្ធដែលការពារប្រជាជនទាំងនេះ។

# គ. ឯកសារពិគ្រោះបន្ថែម

## ពលករទេសន្តប្រវេសន៍

សៀវភៅពុម្ពស្តីពីសិទ្ធិពលករទេស្តប្រវេសន៍ ដែលត្រូវបានប្រើប្រាស់បំផុតច្រើនបំផុតមាន៖

- Aris Ananta
- Evi Nurvidya Arifin
- Ryzard Chuzwelxyzol

ការស្រាវជ្រាវដ៏ច្រើនពីពលករទេសន្តប្រវេសន៍មាននៅលើគេហទំព័ររបស់ ILO៖

របាយការណ៍ស្តីពីការងារទេសន្តប្រវេសន៍ ក្នុងអាស៊ីអាគ្នេយ៍ត្រូវបានធ្វើឡើងដោយ ៖

- អង្គការឃ្លាំមើលសិទ្ធិមនុស្ស ស្ត្រីជួយកិច្ចការផ្ទះចាំស្តាប់បញ្ជាះ បញ្ចប់ការរំលោភបំពានលើពលករជួយកិច្ចការផ្ទះទេសន្តប្រវេសន៍ក្នុងប្រទេសសឹង្ហបូរី។
- អង្គការឃ្លាំមើលសិទ្ធិមនុស្ស ចុះទឹកក្រពើឡើងលើខ្លាះ ការរំលោភបំពានពលករទេសន្តប្រវេសន៍ក្នុងប្រទេសថៃ។
- ILO,ការអនុវត្តការងារ និងលក្ខខណ្ឌការងារក្នុងវិស័យនេសាទក្នុងប្រទេសថៃ។

## ការជួញដូរ

សៀវភៅលម្អិតបំផុតពីពិធីសារ គឺច្បាប់អន្តរជាតិនៃការជួញដូរមនុស្សរបស់ Anne Gallagher, New York: Cambridge University Press, (2010).

គេហទំព័រដែលមានសារៈសំខានពាក់ព័ន្ធនឹងការជួញដូររួមមាន៖

- ការបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន Nexux
- គម្រោងអន្តរទីភ្នាក់ងារអង្គការសហប្រជាជាតិស្តីពីការជួញដូរមនុស្ស (បច្ចុប្បន្នត្រូវបានហៅថា UN ACT)
- ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងបទឧក្រិដ្ឋ។

SEAHRN
Southeast Asian Human Rights Studies Network

បណ្តាញសិក្សាសិទ្ធិមនុស្សអាស៊ីអាគ្នេយ៍មានដើមកំណើតចេញពីក្តីសុបិន្តរួមមួយក្នុងការសម្រេចបាន និងដើម្បីដុះខាត់ចំណោះដឹង និងការយល់ដឹងឲ្យកាន់តែស៊ីជម្រៅរបស់សិស្សនិស្សិត និងអ្នកអប់រំ ព្រមទាំងបុគ្គល និងស្ថាប័នដទៃទៀតពីអាស៊ីអាគ្នេយ៍ក្នុងវិស័យសិទ្ធិមនុស្ស និងសន្តិភាព & ជម្លោះ។ បណ្តាញនេះស្វែងរកកិច្ចសហប្រតិបត្តិការវិស័យសិក្សាថ្នាក់តំបន់ និងជាមួយនឹងសង្គមស៊ីវិលដែលចាំបាច់ដើម្បីធ្វើឲ្យមាននិរន្តន៍ភាពការលើកកម្ពស់ និងការការពារប្រកបដោយប្រសិទ្ធិភាពនៃសិទ្ធិមនុស្សក្នុងតំបន់។

ពេលបច្ចុប្បន្ននេះ SEAHRN មានស្ថាប័នសមាជិកចំនួន ២០ ក្នុងប្រទេសអាស៊ីអាគ្នេយ៍ចំនួន ៧ (កម្ពុជា ឡាវ ម៉ាឡេស៊ី ហ្វីលីពីន ថៃ និងវៀតណាម)។ គោលបំណងរបស់បណ្តាញនេះដើម្បីបើកធ្វើចំហរដល់ស្ថាប័ន និងបុគ្គលដែលមានចំណាប់អារម្មណ៍ដែលមានទស្សនៈវិស័យដូចគ្នាលើវិស័យសិទ្ធិមនុស្ស និងសន្តិភាពនៅអាស៊ីអាគ្នេយ៍។

SEAHRN មានការប្តេជ្ញាចិត្តក្នុងការសម្រេចបាននូវកម្មវត្ថុចម្បងដូចតទៅ៖

- ដើម្បីពង្រឹងការអប់រំថ្នាក់ខ្ពស់ដើម្បីផ្តោតសំខាន់លើការសិក្សាសិទ្ធិមនុស្ស និងសន្តិភាពនៅអាស៊ីអាគ្នេយ៍តាមរយៈកម្មវិធីសិក្សានៅសាកលវិទ្យាល័យ និងការបង្កើតនូវកម្មវិធីសិក្សា

- ដើម្បីជម្រុញឲ្យមានការស្វែងយល់ និងការសម្រេចបានកាន់តែស៊ីជម្រៅទៀតនៃចំនេះដឹងសិទ្ធិមនុស្ស និងសន្តិភាពតាមរយៈការស្រាវជ្រាវសហប្រតិបត្តិការ

- ដើម្បីសម្រេចបាននូវកិច្ចសហប្រតិបត្តិការលើវិស័យសិក្សាអប់រំ និងជាមួយអង្គការសង្គមស៊ីវិលដែលល្អប្រសើរក្នុងការសម្រេចបាននូវសិទ្ធិមនុស្ស និងសន្តិភាពនៅអាស៊ីអាគ្នេយ៍ និង

- ធ្វើការតស៊ូមតិជាសាធារណៈតាមរយៈការចូលរួមយ៉ាងស៊ីជម្រៅជាមួយនឹងតួអង្គសង្គមស៊ីវិល ដោយរួមមានស្ថាប័នអន្តររដ្ឋាភិបាល នៅអាស៊ីអាគ្នេយ៍

សន្និសិទ និងការបោះពុម្ពផ្សាយ

- សន្និសិទអន្តរជាតិលើកទីបីស្តីពីសិទ្ធិមនុស្ស និងសន្តិភាព & ជម្លោះនៅអាស៊ីអាគ្នេយ៍ (ទីក្រុងកូឡាឡាំពួ ប្រទេសម៉ាឡេស៊ី ថ្ងៃទី ១៥-១៧ ខែតុលា ឆ្នា២០១៤)
- សិទ្ធិមនុស្ស និងសន្តិភាពនៅអាស៊ីអាគ្នេយ៍ វគ្គទី ២៖ ជំនះលើភាពទាល់ច្រក (ខែកញ្ញា ឆ្នាំ២០១៣)

- សិទ្ធិមនុស្ស និងសន្តិភាពនៅអាស៊ីអាគ្នេយ៍ វគ្គទី ៣៖ បំពងសម្លេង (ខែកញ្ញាឆ្នាំ ២០១៣)
- សន្និសិទអន្តរជាតិលើកទីពីរស្តីពីសិទ្ធិមនុស្ស និងសន្តិភាព & ជម្លោះនៅអាស៊ីអាគ្នេយ៍ (ទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី ខែតុលា ឆ្នាំ២០១២)
- សិទ្ធិមនុស្សនៅអាស៊ីអាគ្នេយ៍ វគ្គទី ១៖ បំបែកភាពស្ងាត់ស្ងៀម (ខែកញ្ញា ឆ្នាំ២០១១)
- សន្និសិទអន្តរជាតិលើកទីមួយស្តីពីសិទ្ធិមនុស្សនៅអាស៊ីអាគ្នេយ៍ (ទីក្រុងបាងកក ប្រទេសថៃ ខែតុលា ឆ្នាំ២០១០) ។


លេខាធិការដ្ឋានអចិន្ត្រៃយ៍

វិទ្យាស្ថានដើម្បីសិក្សាសិទ្ធិមនុស្ស និងសន្តិភាព (IHRP), មហាវិទ្យាល័យ Mahidol University

Rm. 308, 3rd Floor, Panyaphipat Bldg, Faculty of Social Science Complex, Mahidol University

Salaya Campus, Phuttamonthon, Nakhon Pathom, Thailand, 73170

អ៊ីម៉ែលរបស់បណ្តាញ៖ seahrn@gmail.com

អ៊ីម៉ែលរបស់សន្និសិទ៖ searhncon@gmail.com

www.seahrn.org

SEAHRN

Southeast Asian Human Rights Studies Network